# ចម្លើយស៊ីអាត់

ក្នុងសាសនាទេ ?............................................................................ ១៦៩
សំណួរ ២៧ - ហេតុអ្វីស្ហ៊ីអ៊ុស្វ៊ស្វ៊ឡាត្ចប្រាំដងក្នុងមួយថ្ងៃ ក្នុងបីពេល ?
.............................................................................................១៧៥
សំណួរ ២៨ - តើនីតិក្រម (គឺច្បាប់ហ្វ៊ីក្ហោះហ្វ៍) ស្ហ៊ីអ៊ុស្វ៊
ចេញមកពីប្រភពណា ? ..................................................................... ១៩៩
សំណួរ ២៩ - តើ អាប៊ូ ត៉ូលិប បានទទួលអនិច្ចកម្មជាអ្នក មានសទ្ធាទេ
ដើម្បីអស់លោកអាចស៊ីយ៉ារ៉ាស៊្វលោក បាននោះ ?.......................... ២១៥
សំណួរ ៣០ - តើស្ហ៊ីអ៊ុស្វ៊យល់ឃើញទេថាយ៉ីប៉ររ៉ អ៊ីលﷺ
ភាន់ច្រឡំនាំព្រះរាជសារមកឲ្យមូហាំម៉ាដ្ឋ ﷺ តែការពិត
ព្រះអង្គﷺត្រូវនាំមកឲ្យ អ៊ុលី អ៊ីបនូ អាប៊ី ត៉ូលិប នោះ វិញទេ ?... ២៤៣
សំណួរ ៣១ - អ្វីទៅគោលការណ៍តាគ្គីយ៉ាស្វ៊ ? .............................. ២៤៨
សំណួរ ៣២ - ហេតុអ្វីម៉ាស្វ៊ហ្វាប់យ៉ាក់ហ្វារីជាម៉ាស្វ៊ហ្វាប់
របស់រដ្ឋម្មនុញ្ញរបស់សាធារណរដ្ឋអ៊ីស្លាម នៃប្រទេស អ៊ីរ៉ង់ ?...........២៥២
សំណួរ ៣៣ - តើស្ហ៊ីអ៊ុស្វ៊ចាត់ទុកស្វ៊ឡាត្ចអាល់-វ៉ាតៀរជា
ស្វ៊ឡាត្ចវ៉ាយ៉ីបទេ ?......................................................................២៥៦
សំណួរ ៣៤ - តើជឿថាអស់ព្រះសន្តបុគ្គលជំនិតរបស់ អល់ឡោះហ្វ៍ﷻ
(អៅលីយ៉ាអ៊្ចអល់ឡោះហ្វ៍ﷻ) មានឥទ្ធិឫទ្ធិ នោះជាបទហ៊ុនបាយ (គឺស្ហ៊ីរិក)
ទេ ? .......................................................................................... ២៥៧
សំណួរ ៣៥ - យោលតាមទ្រឹស្តីស្ហ៊ីអ៊ុស្វ៊ ហេតុអ្វីឋានៈ
អ៊ីម៉ាម៉ាស្វ៊ខ្ពស់ជាងឋានៈសាស្តា(នូប៊ូវ៉ាស្វ៊) ? ................................. ២៦២
សំណួរ ៣៦ - តើអាចវែកញែកតៅហ៊ីដ្ឋដាច់ឡែកពីស្ហ៊ីរិក បានដូចម្តេច ?
.......................................................................................... ២៧៤

សំណួរ ១៤ - តើសូមជំនួយពីអ្នកណាមួយស្មើនឹងធ្វើសក្ការៈអ្នកនោះ ស្មើនឹងអំពើហ៊ុនហាយ (ស្ហ៊ីរិក) ទេ ? ........................................................ ៨០
សំណួរ ១៥ - អ្វីទៅ "បាដ្ហា (بدا)" ហេតុអ្វីជឿបាដ្ហា ? ............................ ៨៦
សំណួរ ១៦ - តើស្ហ៊ីអ៊ាស់ជឿថាគួរអានត្រូវកែ (តាស់រិហ្វ تحريف) ឬ ? ... ៩១
សំណួរ ១៧ - តើស្ហ៊ីអ៊ាស់យល់ឃើញយ៉ាងណាអំពីស្ហ៊ាហាបាស់(الصحابة) សាវករបស់ព្រះសាស្តាﷺ ? ........................................................ ១០៣
សំណួរ ១៨ - អ្វីទៅអត្ថន័យរបស់មុតអ៊ាស់ (المتعة អាពាហ៍ពិពាហ៍មានកំណត់) ហេតុអ្វីស្ហ៊ីអ៊ាស់ចាត់ទុកថាស្រប ច្បាប់ ?......... ១១៣
សំណួរ ១៩ - ហេតុអ្វីស្ហ៊ីអ៊ាស់ក្រាបប្រណិប័តន៍លើដី ទូរបាស់ ? ...... ១២៤
សំណួរ ២០ - ពេលស្ហ៊ីយ៉ារ៉ាស់ ហេតុអ្វីស្ហ៊ីអ៊ាស់ថើបទ្វារ និងជញ្ជាំងបូណីជដ្ឋានរបស់អៅលីយ៉ា ស្វែងរកពរជ័យ ដោយទង្វើនេះ ? .............................................................................................. ១២៧
សំណួរ ២១ - តើសាសនាដាច់ឡែកពីនយោបាយទេ ក្នុងសាសនាអ៊ីស្លាម ?......................................................................... ១៣៤
សំណួរ ២២ - ហេតុអ្វីស្ហ៊ីអ៊ាស់ចាត់ទុកកូនទាំងពីររបស់ អ៊ាលី អ៊ីបនូ អាប៊ីត៉លិប (ហ្ហាសាន់និងហ្ហូសៃន៍عليهم السلام) ជា "កូនរបស់ព្រះសាស្តាﷺអល់ឡោះហ្វ៍عز وجل" ?.................................... ១៤២
សំណួរ ២៣ - ហេតុអ្វីស្ហ៊ីអ៊ាស់ជឿថាខ៉ាលីហ្វាស់ជាមុខតំណែងត្រូវតែងតាំងដោយអល់ឡោះហ្វ៍عز وجل ?................................ ១៤៩
សំណួរ ២៤ - តើស្បថផ្សេងពីចំពោះព្រះនាមអល់ឡោះហ្វ៍عز وجلជាអំពើហ៊ុនហាយ (ស្ហ៊ីរិក) ទេ ? ........................................... ១៥៤
សំណួរ ២៥ - តាវ៉ាស់ស៊ូល (تَوَسُّل) ការពឹងមិត្ត អល់ឡោះហ្វ៍عز وجل មិនមែនអំពើហ៊ុនហាយ (គឺស្ហ៊ីរិក) និងជា ករណីកែប្រែ (គឺប៊ីដ្ហអ៊ាស់) នៅក្នុងសាសនាទេ ?......................................................................... ១៦១
សំណួរ ២៦ - តើធ្វើបុណ្យខួបកំណើតរបស់មិត្តជំនិតរបស់អល់ឡោះហ្វ៍عز وجلជាអំពើហ៊ុនហាយ ឬជាការកែប្រែ (ប៊ីដ្ហអ៊ាស់)

# អារម្ភកថា

بسم الله الرحمن الرحيم

បណ្តាអ្នកដែលស្គាល់ព្រឹត្តិការណ៍ក្នុងពិភពលោកមុស្លីម ដឹងច្បាស់ថាសព្វថ្ងៃ *អ៊ុមម៉ាត់* មុស្លីមបាន ក្លាយទៅជា *"អ៊ុមម៉ាត់ច្រើន"* ហើយ *"អ៊ុមម៉ាត់"* នីមួយៗមានមាគ៌ានិងទំនៀមដាច់ឡែក រីឯជីវិតសមាជិកអ៊ុមម៉ាត់នោះធ្លាក់នៅក្នុងកណ្តាប់ដៃបុគ្គលមួយចំនួន ដែលគិតថាអនុត្តរភាព (ភាពនៃបុគ្គលដែលគ្មាននរណាមួយផ្ទឹមស្មើបាន) និងការគង់នៅរបស់ខ្លួនស្ថិតនៅលើភាពប្លែកពីគេ ។

ហេតុដូច្នេះ បុគ្គលទាំងនេះមានធនដាក់ធ្វើវិនិយោគច្រើនបែប ហើយអាចប្រើមធ្យោបាយគ្រប់យ៉ាងបានតាមមហិច្ឆិតាខ្លួន ។

ស្ថានភាពនេះ មិនបានទុកឱកាសឲ្យនិកាយអ៊ីស្លាមទាំងឡាយចរចាគ្នាបានទេ ហើយមានរឿងទំនាស់ច្រើនអនេក ។ ភាគច្រើនវាជារឿងអប់រំដែលកកើតដោយសារសាសនវិទូមុស្លីមផ្នែកអប់រំ (មូតាកាល្លីមូន متاكلمون) ហើយមុស្លីមភាគច្រើនមិនស្គាល់អសទិសភាព (គឺភាពខុសគ្នា) ទាំងនោះទេ បានសេចក្តីថា របស់មានពីរ តែគេថ្លឹងតែរបស់មួយ តើធ្វើដូចម្តេចទៅនឹងដឹងថារបស់ទាំងពីរនោះ មួយណាធ្ងន់ជាងមួយណា ?

ក៏ប៉ុន្តែ មានទងដូចគ្នាច្រើនដែលអាចធ្វើឲ្យមានមូលដ្ឋានតែមួយបាន ។ ការពិត និកាយមុស្លីមនានា មានចំណុចដូចគ្នាច្រើនជាងចំណុចខុសគ្នា តែបណ្តាអ្នកគាំទ្រការមិនចុះសម្រុងគ្នាយកចិត្តទុកដាក់អំពីចំណុចខុសគ្នា

ដូច្នេះហើយបានជាពួកគេមិននិយាយអ្វីអំពីបញ្ហាដូចគ្នាទេ ដែលទាក់ទងនឹងឫសកែវនិងសាខាសាសនា ពុំនោះសោតបែរជាច្រងេងច្រងាងអួតអាងកាងក្រទាប្រទូសរ៉ាយគេឯងថា និកាយដែលខ្លួនប្រកាន់យកនោះជានិកាយត្រង់ត្រូវ ឯនិកាយដទៃជានិកាយព្រាយបិសាច អ្វីៗដែលគេបានអះអាង មិនមានអំណះអំណាងនៅក្នុងព្រះគម្ពីរគួរអាន ឬហាឌិស្សរ៉សូលុលឡោះហ្ﷺឡើយ ។ ផ្ទុយទៅវិញអល់ឡោះហ្ﷻមានព្រះបន្ទូលនៅក្នុងគួរអានថា៖

إِنَّ ٱلَّذِينَ فَرَّقُواْ دِينَهُمْ وَكَانُواْ شِيَعًا لَّسْتَ مِنْهُمْ فِي شَيْءٍ إِنَّمَآ أَمْرُهُمْ إِلَى ٱللَّهِ ثُمَّ يُنَبِّئُهُم بِمَا كَانُواْ يَفْعَلُونَ

*ជនទាំងឡាយដែលបានបំបែកសាសនារបស់ខ្លួន ហើយបានបង្កើតជានិកាយ អ្នកពុំមានអ្វីទាក់ទងជាមួយពួកទាំងនោះទេ ។ អល់ឡោះហ៍នឹងសម្រេចរឿងពួកគេ ព្រះអង្គនឹងឲ្យពួកគេដឹងអំពើទាំងឡាយដែលពួកគេបានសាង (៦:១៥៩) ។*

អល់ឡោះហ្តាអាឡាមានព្រះបន្ទូលដែរថា៖

إِنَّ هَٰذِهِۦٓ أُمَّتُكُمْ أُمَّةً وَٰحِدَةً وَأَنَا۠ رَبُّكُمْ فَٱعْبُدُونِ ﴿٩٢﴾

*ពិតណាស់ សហគមន៍នេះរបស់ពួកអ្នកជាសហគមន៍តែមួយ ។ អញជាព្រះម្ចាស់របស់ពួកអ្នក ដូច្នេះចូរពួកអ្នកគោរពបូជាអញ (២១:៩២) ។*

ផែនការសម្ងាត់ចាស់គំរឹលមួយ រៀបចំដោយអាណានិគមនិយមនៅក្នុងប្រជាជាតិមុស្លីមនោះ គឺបង្កមជ្ឈធាតុនិយម(គឺបង្កឲ្យកើតមានការសង្ស័យ) និងធ្វើឲ្យបញ្ហាកាន់តែខ្លាំងឡើងៗ រួចហើយនឹងវាយប្រហារអ៊ីស្លាមរុងរឿង ។

វិធីចាស់គំរឹលច្រើនបែបដូចគ្នានេះដែរត្រូវប្រើនៅឯតំបន់មជ្ឈឹមបូព៌ា និង

# បញ្ជីមាតិកា


អារម្ភកថា.................................................................៣

សំណួរ ១ - មួយណាត្រឹមត្រូវ "វ៉ា អ៊ីតរ៉ទី (وعترتي សន្តតិវង្សខ្ញុំ)" ឬ "វ៉ា ស៊ុនណាទី (وسنتي ប្រពៃណីខ្ញុំ/ស៊ូណាស់ខ្ញុំ)" ?..................................១៦

សំណួរ ២ - "ស្ហ៊ីអះស់" មានន័យថាអ្វី ?.........................................៣៣

សំណួរ ៣ ៖ ហេតុអ្វីចាត់ទុក អាលី អ៊ីបនូ អាប៊ី ត៏លិប صلوات الله عليه والسلام ជា វ៉ាស៊ី (អ្នកធ្វើតាមមរតកសាសន៍) និងជាអ្នកស្នងព្រះសាស្តាﷺ ?..................៣៦

សំណួរ ៤ ៖ អ៊ីម៉ាំគឺអ្នកណា ?...................................................៤១

សំណួរ ៥ - ហេតុអ្វីស្ហ៊ីអះស់ថា "អល់ឡហុំម៉ា ស្វល់លី អាឡា មូហាំម៉ាដ់ វ៉ា អាឡា អាលី មូហាំម៉ាដ់" ?...........................................................៤៤

សំណួរ ៦ - ហេតុអ្វីចាត់ទុកអ៊ីម៉ាំជាអវិរុទ្ធបុគ្គល (ម៉ាក់ស៊ូម) ?............៤៧

សំណួរ ៧ - ហេតុអ្វីស្ហ៊ីអះស់ថែម "អាស្ហ៊ហាឌូ អាន់ណា អាលីយ៉ាន វ៉ាលីយុលឡោះហ្" នៅក្នុងការប្រកាសស្ហ៊ឡាត់ ?.............................៤៩

សំណួរ ៨ - អ្នកណាទៅ ម៉ាស្ហ៊ឌី សន្តតិវង្សរបស់មូហាំម៉ាដ់ ? ហេតុអ្វីអស់លោករង់ចាំម៉ាស្ហ៊ឌីនេះដើបឡើង ?...............................................៥៣

សំណួរ ៩ - បើស្ហ៊ីអះស់ត្រូវមែននោះ ហេតុអ្វីមានគ្នាតិច ហេតុអ្វីមុស្លីមក្នុងលោកមិនទទួលស្គាល់ពួកគេ ?.........................................៥៧

សំណួរ ១០ - អ្វីទៅរ៉ច្ហ៍អះស់ (និវត្តន៍) ហេតុអ្វីជឿនិវត្តន៍ ?..................៦០

សំណួរ ១១ - អ្វីទៅស្ហ្វហ្វាអះស់ (ការធ្វើអន្តរាគមន៍ شفاعة) ដែលអស់លោកជឿនោះ ?...........................................................................៦៧

សំណួរ ១២ - តើសូមឲ្យអ្នកជួយធ្វើអន្តរាគមន៍ស្របច្បាប់ជួយធ្វើអន្តរាគមន៍ឲ្យនោះជាអំពើស្ហ៊ិរិកទេ ?...............................................៧១

សំណួរ ១៣ - តើស្វែងរកជំនួយពីអ្នកផ្សេងពីអល់ឡោះហ្ﷻនោះជាអំពើហ៊ុនហាយ (ស្ហ៊ិរិក) មួយប្រភេទទេ ?................................................៧៦

*៥:៧២ ។"*[350]

ពិតប្រាកដណាស់ សេចក្តីគោរពគ្រប់ប្រភេទចំពោះបុគ្គលណាម្នាក់ដោយមិនចាត់ទុកបុគ្គលនោះជាព្រះ មិនប្រកបដោយទង្វើរបស់ព្រះទេនោះ មិនអាចចាត់ទុកសេចក្តីគោរពនេះជាទង្វើសក្ការៈព្រះបានទេ ទោះបីសេចក្តីគោរពមានកម្រឹតខ្ពស់ប៉ុណ្ណាក៏ដោយ ។

អាស្រ័យហេតុនេះ សេចក្តីគោរពរបស់កូនចំពោះឪពុកម្តាយ ឬសេចក្តីគេរពរបស់អ៊ុមម៉ាត្ទ៍ចំពោះព្រះសាស្តាﷺនោះ មិនអាចបកស្រាយបានទេថាវាជាទង្វើគោរពសក្ការៈព្រះ ។

ដូច្នេះ ការស្វែងរកពរជ័យសិរីសួស្តីតាមរយៈសិរីវត្ថុរបស់សន្តបុគ្គលជំនិតរបស់អល់ឡោះហ្ទ៍عز وجل ការថើបទ្វារបូជនីយដ្ឋាននិងព្រះចេតិយរបស់សន្តបុគ្គលទាំងនេះ ការសូមជួយធ្វើអន្តរាគមន៍ពីបុគ្គលជំនិតរបស់ឡោះហ្ទ៍عز وجل (តាវ៉ាស់ស៊ូល) ការសូមឲ្យបាវបរិសុទ្ធរបស់អល់ឡោះហ្ទ៍عز وجلជួយ ការរំលឹកខួបកំណើតឬខួបទិវង្គតរបស់សន្តបុគ្គល ដែលមនុស្សអវិជ្ជាមួយចំនួនគិតថាជាអំពើស្ហ៊ីរិកហ៊ុនហាយ ឬជាទង្វើគោរពសក្ការៈផ្សេងពីអល់ឡោះហ្ទ៍عز وجل នោះ ពុំមែនជាទង្វើសក្ការៈព្រះផ្សេងពីអល់ឡោះហ្ទ៍عز وجلទេ ។

[350] ស៊ូរ៉ោះត្ទ៍ អាល់-ម៉ាអ៊ីដ្ទាស្ទ៍ 5:72 ។



ច្រើនតំបន់ទៀត ជាពិសេសនៅក្នុងប្រទេសកម្ពុជាក្នុងពេលថ្មីៗនេះតែម្តង ។ ការបង្កមជ្ឈធាតុនិយមនេះជម្រុញឲ្យអ្នកជ្រុលនិយមខ្លះចេញមុខនិងតាំងខ្លួនជាអ្នកអ៊ុាលិម (អ្នកប្រាជ្ញ) វាយប្រហារទៅលើអ្នកកាន់និកាយស្ហ៊ីអ៊ីតទាំងងងឹតងងល់ថា សម្រាប់ប្រទេសកម្ពុជា ទទួលស្គាល់តែនិកាយ 4 តែប៉ុណ្ណោះក្នុងសាសនាអ៊ីស្លាម ។ បើអ្នកណាហើយប្រតិបត្តិក្រៅពីនិកាយទាំង 4 នៅកម្ពុជា គឺពួកអ្នកអ៊ុាលិមគេមិនទទួលស្គាល់ជាដាច់ខាត ។ កម្ពុជាបានឯកភាពជាផ្លូវការយកនិកាយអាស្ហ៍-ស្ហាហ្វ៊ីអ៊ីជាមូលដ្ឋាន រីឯនិកាយស្ហ៊ីអ៊ីតវិញមិនអោយមានវត្តមានជាដាច់ខាតនៅកម្ពុជានេះ ។ អ្នកណាហើយប្រតិបត្តិតាមនិកាយស្ហ៊ីអ៊ីត គឺត្រូវតែបញ្ចប់ ។ តែបើនៅតែបន្តប្រតិបត្តិទៀត អ្នកទាំងនោះជាសត្រូវនឹងគេ គេនឹងប្រឆាំងដាច់អហង្កតែម្តង ។ បើអ្នកណាហើយជ្រុលខ្លួនទៅកាន់និកាយស្ហ៊ីអ៊ីត បើចង់ត្រឡប់មកកាន់និកាយស៊ុននីវិញនោះ គឺទ្វារនៅចំហរស្រាប់រង់ចាំទទួល ហើយសារភាពថាខ្លួនបានជ្រុលទៅកាន់និកាយស្ហ៊ីអ៊ីត ។ ពេលខ្លួនសុំវិលត្រឡប់មកកាន់ស៊ុននីវិញ ខ្ញុំសូមបញ្ជាក់និងសូមផ្តាំថា បើសារភាពផ្ទាល់មាត់មិនទទួលស្គាល់ឡើយ លុះត្រាតែសរសេរជាលាយលក្សណ៍អក្សរ រួចផ្តិតមេដៃទើបទទួលស្គាល់ ។ ចំណែកឯអ្នកខ្លះទៀតបានគក់ទ្រូងទ្វងស្គរប្រកាសក្តែងៗថា៖

1. សាស្តាម៉ូហាំម៉ាត់ បានសូមបួងសួងដល់អល់ឡោះហ៍អោយ អាពូតឡិប បានចូលឥស្លាម តែអល់ឡោះហ៍ទ្រង់មិនព្រម ។ សាស្តាម៉ូហាំម៉ាត់ក៏ឈប់បួងសួងទៅ ព្រោះអាពូតឡិបមានកូនច្រើន រហូតដល់ 30 នាក់ ។
2. រីឯសាស្តាមូហាំម៉ាត់ក៏ដូច្នោះដែរ គឺលោកមានភរិយាក្នុងក្របខណ្ឌចំនួន 9 នាក់ ហើយភរិយាក្រៅក្របខណ្ឌក៏ច្រើនដែរ ។ ប៉ុន្តែសាស្តាម៉ូហាំម៉ាត់ អល់ឡោះហ៍ទ្រង់ប្រទានអោយមានកូនតែ 1 នាក់ ហេតុដូច្នេះហើយទើបអល់ឡោះហ៍ទ្រង់មិនប្រទានអោយអាពូតឡិបជាឪពុកមារបស់លោកចូលសាសនាឥស្លាមនោះ ។

3. ប្រហែលជាលោកសាស្តាម៉ូហាំម៉ាត់ ចេះពន្យារកំណើតដូចយើងសព្វថ្ងៃនេះដែរក៏មិនដឹងបានជាពុំមានកូនច្រើនទេនោះ ។

4. អាពូប៉ាកើរ អ៊ូម៉ើរ អូស្មាន ធ្វើអភិបាល គ្រប់គ្រង ពុំមានកើតសង្គ្រាមទេ តែដល់ពេល អាលី ទទួលដំណែងគ្រប់គ្រង សង្គ្រាមក៏កើតភ្លាម ។ លុះដល់អាលីទទួលមរណៈភាពដំណែងក៏ធ្លាក់មកលើ ហាសាន់ ហូសេន ជាកូនប្រុសរបស់អាលី ។ គ្រាន់តែសាស្តាម៉ូហាំម៉ាត់មានចៅតែ 2 នាក់ប៉ុណ្ណោះធ្វើអោយមានមហន្តរាយវិនាសប៉ុណ្ណឹងទៅហើយ ចុះបើអល់ឡោះហ៍ទ្រង់អោយសាស្តាមូហាំម៉ាត់មានកូន និងចៅច្រើនថែមជាងនេះទៀតនោះ តើយើងទាំងអស់គ្នានេះនឹងទៅជាយ៉ាងណាវិញ ? ប្រហែលជាលោកទាំងមូលនេះពុំមានអាយុកាលមកដល់សព្វថ្ងៃនេះទេ ក៏មិនដឹង ?

5. ខ្ញុំខំនិយាយត្រឹមប៉ុណ្ណឹងហើយ បើនៅតែមិនឈប់ទៀតនោះ អ្នកទាំងនោះគឺជាសត្រូវនឹងខ្ញុំ ហើយខ្ញុំនឹងសរសេរសៀវភៅប្រឆាំងនឹងអ្នកទាំងនោះ ។ ខ្ញុំយករឿងទាំងអស់នេះបញ្ជូនទៅរាជរដ្ឋាភិបាល ។

អ៊ីម៉ាំនៅក្នុងព្រះគម្ពីរអល់ឡោះហ្ទ៍ﷻ មានពីរប្រភេទប៉ុណ្ណោះ ។ អល់ឡោះហ្ទ៍ﷻមានព្រះបន្ទូលថា៖

وَجَعَلۡنَٰهُمۡ أَئِمَّةٗ يَهۡدُونَ بِأَمۡرِنَا وَأَوۡحَيۡنَآ إِلَيۡهِمۡ فِعۡلَ ٱلۡخَيۡرَٰتِ وَإِقَامَ ٱلصَّلَوٰةِ وَإِيتَآءَ ٱلزَّكَوٰةِۖ وَكَانُواْ لَنَا عَٰبِدِينَ

*យើងបានចាត់តាំងពួកគេជាអ៊ីម៉ាំ ដែលដឹកនាំ[មនុស្ស]តាមបញ្ជារបស់យើង ។ យើងបានបើកឲ្យពួកគេដឹងនូវការប្រព្រឹត្តអំពើល្អ ការបំពេញនមស្ការ[បូជាអល់ឡោះហ្ទ៍] និងការបរិច្ចាគទាន ។ ពួកគេគោរពសក្ការៈយើង (២១:៧៣) ។*

وَجَعَلۡنَٰهُمۡ أَئِمَّةٗ يَدۡعُونَ إِلَى ٱلنَّارِۖ وَيَوۡمَ ٱلۡقِيَٰمَةِ لَا يُنصَرُونَ ﴿٤١﴾



ដូយ់អ៊ុស្ទ៉" ពីព្រោះការត្រួតត្រាផ្ទះនិងចម្ការជាភារៈរបស់ម្ចាស់ ។

ដោយចែងថា អល់ឡោះហ្ទ៍ﷻជាអ្នកត្រួតត្រាមួយគត់របស់លោកនោះ ព្រះមហាគម្ពីរគួរអានប្រឆាំងពួកពហុទេពនិយម ហើយហៅពួកគេមកគោរពសក្ការៈអល់ឡោះហ្ទ៍ﷻតែមួយថា៖

إِنَّ ٱللَّهَ رَبِّي وَرَبُّكُمۡ فَٱعۡبُدُوهُۚ هَٰذَا صِرَٰطٞ مُّسۡتَقِيمٞ

*"ពិតណាស់ អល់ឡោះហ្ទ៍ជាព្រះម្ចាស់ខ្ញុំនិងជាព្រះម្ចាស់អស់លោក ។ ដូច្នេះចូរអស់លោកគោរពបូជាព្រះអង្គ ។ នេះជាមាគ៌ាត្រង់ត្រូវ៣:៥១ ។"*[347]

ذَٰلِكُمُ ٱللَّهُ رَبُّكُمۡۖ لَآ إِلَٰهَ إِلَّا هُوَۖ خَٰلِقُ كُلِّ شَيۡءٖ فَٱعۡبُدُوهُۚ

*"នេះគឺអល់ឡោះហ្ទ៍ ព្រះម្ចាស់ពួកអ្នក ។ ពុំមានព្រះទេក្រៅពីព្រះអង្គ អ្នកបង្កើតសព្វសារពើ ។ ដូច្នេះចូរពួកអ្នកគោរពសក្ការៈព្រះអង្គ៦:១០២ ។"*[348]

لَآ إِلَٰهَ إِلَّا هُوَ يُحۡيِۦ وَيُمِيتُۖ رَبُّكُمۡ وَرَبُّ ءَابَآئِكُمُ ٱلۡأَوَّلِينَ

*"មិនមានព្រះទេក្រៅពីព្រះអង្គ ព្រះអង្គប្រទានជីវិត ព្រះអង្គប្រទានសេចក្តីស្លាប់ ព្រះម្ចាស់របស់ពួកអ្នកនិងព្រះម្ចាស់របស់បណ្តាដូនតាពួកអ្នក ៤៤:៨ ។"*[349]

وَقَالَ ٱلۡمَسِيحُ يَٰبَنِيٓ إِسۡرَٰٓءِيلَ ٱعۡبُدُواْ ٱللَّهَ رَبِّي وَرَبَّكُمۡۖ

*"រីឯអាល់-ម៉ាស៊ិះហ្ទ៍បានថ្លែងថា៖ "បណ្តាកូនចៅអ៊ិសរ៉អ៊ីលអើយ ចូរអស់លោកគោរពសក្ការៈអល់ឡោះហ្ទ៍ ព្រះម្ចាស់របស់ខ្ញុំនិងរបស់អស់លោក*

[347] ស៊ូរ៉ោះត្ទ៍ អាលី អ៊ីមរ៉ន 3:51 ។

[348] ស៊ូរ៉ោះត្ទ៍ អាល់-អាន់អ៊ុំ 6:102 ។

[349] ស៊ូរ៉ោះត្ទ៍ អាដ្ទុ-ឌូខ្ខន់ 44:8 ។

ហេតុអ្វីបានជាទង្វើតែមួយមានន័យច្រើន ?

អាយ៉ាស់គួរអានបញ្ជាក់យ៉ាងច្បាស់ថា សក្ការៈព្រះ (អ៊ិបាដ្ហាស់) គឺសេចក្ដីគោរពចំពោះអត្ថិភាពដែលចាត់ទុកជាព្រះ ដែលទង្វើរបស់អត្ថិភាពនោះត្រូវចាត់ទុកជាទង្វើព្រះ ។ ដូច្នេះ ជឿអល់ឡោះហ្ញ៍ﷻនិងជឿថាព្រះអង្គﷻអាចធ្វើទង្វើព្រះបានជាមូលដ្ឋានបឋម ផ្សំនឹងសេចក្ដីគោរព មានន័យថាសក្ការៈព្រះ ។

អ្នកពហុទេពនិយមក្នុងលោកសម្ដែងសេចក្ដីគោរពចំពោះអត្ថិភាព ដែលពួកគេគិតថាត្រូវព្រះបង្កើតមក ដែលពួកគេគិតថាអាចជួយធ្វើអន្តរាគមន៍ឲ្យបាន ហើយយ៉ាងហោចណាស់អាចលុបលាងបាបបាន ។

ពួកពហុទេពនិយមបាប៊ីលតែងតែសក្ការៈវត្ថុនៅលើមេឃ ចាត់ទុកវត្ថុទាំងនេះជា "ម្ចាស់ (ارباب អារបាប់)" ពួកគេជាជាង "ព្រះអ្នកបង្កើត" តែចាត់ទុកថាវត្ថុទាំងនេះមានមុខងារត្រួតត្រានិងចាត់ចែងរឿងលោកនិងមនុស្ស ។

រឿងណាបីអ៊ីបរ៉ហ៊ីមﷺ និងការសន្ទនារបស់ព្រះអង្គﷺជាមួយមនុស្សមួយក្រុមដែលពុំដែលចាត់ទុកថ្ងៃ ខែនិងផ្កាយជាព្រះទេ តែជាសត្វលោកមានឥទ្ធិពលដែលព្រះអ្នកបង្កើតលោកផ្ទេរអំណាចឲ្យ ។
អាយ៉ាស់គួរអានដែលថែងអំពីការសន្ទការបស់អ៊ីបរ៉ហ៊ីមﷺ ជាមួយពួកពហុទេពនិយមបាប៊ីលបញ្ជាក់ន័យលើពាក្យ "រ៉ប់"[346] ដែលមានន័យថាម្ចាស់ អ្នកត្រួតត្រា ។

ពួកអារ៉ាប់ហៅម្ចាស់ផ្ទះថា "រ៉ប់ អាល់-បៃត៍" ម្ចាស់ចម្ការថា "រ៉ប់ អាល់-

[346]មើលសូរ៉ោះត៍ អាល់-អាន់អ៊ុំ 6:76-78 ។



*យើងបានធ្វើឲ្យពួកគេទៅជាអ៊ីម៉ាំដែលហៅទៅរកភ្លើងនរក ។ នាថ្ងៃរស់ពីស្លាប់វិញ គេនឹងមិនជួយសង្គ្រោះពួកគេទេ [នេះគឺលទ្ធផលនៃអំពើទុច្ចរិតដែលពួកគេបានសាង] (២៨:៤១) ។*

1. حدثنا محمد بن الحسين عن محمد بن الحسين بن على عن محمد بن يحيي عن طلحة بن زيد عن جعفر بن محمد عن ابيه عليه السلام قال قال الائمّة في كتاب الله امامان قال الله تبارك و تعالى: وَجَعَلْنَاهُمْ أَئِمَّةً يَهْدُونَ بِأَمْرِنَا لا بامر الناس يقدمون امر الله قبل امرهم وحكم الله قبل حكمهم وقال: وَجَعَلْنَاهُمْ أَئِمَّةً يَدْعُونَ إِلَى النَّارِ يقدمون امرهم قبل امر الله و حكمهم قبل حكم الله ويأخذون باهوائهم خلافا لما في كتاب الله.

១. មូហាំម៉ាដ់ ប៊ិន អាល់-ហ៊ូសៃន៍បានតំណាលប្រាប់យើង... តមកពីត្វល់ហាស់ ប៊ិន ស្សៃដ៍ ដែលបានតំណាលតមកពី យ៉ាក់ហ្វារ ប៊ិន មូហាំម៉ាដ់ﷺ តមកពីព្រះបិតាﷺ ព្រះអង្គﷺ ដែលមានវចនៈថា៖ "អ៊ីម៉ាំនៅក្នុងព្រះគម្ពីរអល់ឡោះហ្ញ៍ﷻមានពីរប្រភេទ ។ អល់ឡោះហ្ញ៍ﷻមានព្រះបន្ទូលថា៖ *[២១:៧៣] យើងបានចាត់តាំងពួកគេជាអ៊ីម៉ាំដែលដឹកនាំ[មនុស្ស] តាមបញ្ជារបស់យើង ។* ពួកគេعليهم السلامបញ្ជោមនុស្សយកព្រះបញ្ជានិងសេចក្ដីវិនិច្ឆ័យរបស់អល់ឡោះហ្ញ៍ﷻមុនអ្វីៗទាំងអស់ ។ ព្រះអង្គﷻមានព្រះបន្ទូលថា៖ *[២៨:៤១] យើងបានធ្វើឲ្យពួកគេទៅជាអ៊ីម៉ាំដែលហៅទៅរកភ្លើងនរក ។* ពួកគេយកបញ្ជារបស់ពួកគេមុនព្រះបញ្ជារបស់អល់ឡោះហ្ញ៍ﷻ យកសេចក្ដីវិនិច្ឆ័យរបស់ពួកគេមុនសេចក្ដីវិនិច្ឆ័យរបស់អល់ឡោះហ្ញ៍ﷻ ពួកគេយកតាមយោបល់ខ្លួនឯងប្រឆាំងអ្វីដែលមាននៅក្នុងព្រះគម្ពីររបស់អល់ឡោះហ្ញ៍ﷻ ។" (بصائر الدرجات ក្បាលទី១ វគ្គទី១៥ ហាឌីស្ស២)

នៅក្នុងព្រះគម្ពីគួរអានអល់ឡោះហ្ញ៍ជាអម្ចាស់បានមានព្រះបន្ទូលថា៖

لَآ إِكۡرَاهَ فِي ٱلدِّينِۖ قَد تَّبَيَّنَ ٱلرُّشۡدُ مِنَ ٱلۡغَيِّۚ فَمَن يَكۡفُرۡ بِٱلطَّٰغُوتِ وَيُؤۡمِنۢ بِٱللَّهِ فَقَدِ ٱسۡتَمۡسَكَ بِٱلۡعُرۡوَةِ ٱلۡوُثۡقَىٰ لَا ٱنفِصَامَ لَهَاۗ وَٱللَّهُ سَمِيعٌ عَلِيمٌ ﴿٢٥٦﴾

*ពុំមានការបង្ខិតបង្ខំក្នុងសាសនាឡើយ ព្រោះមាគ៌ាត្រង់ត្រូវទីទៃពីកំហុស ។ ដូច្នេះអ្នកណាបដិសេធ ត្ហ៉ូគូត (មេដឹកនាំអាក្រក់ មនុស្សអាក្រក់ វត្ថុបិសាច) ជឿអល់ឡោះហ៍ ពិតណាស់អ្នកនោះតោងបង្កាន់ដៃមាំបំផុត ដែលមិនដាច់ជាដាច់ខាត ។ អល់ឡោះហ៍ទ្រង់ទស្សនាការ ព្រះអង្គទ្រង់ញាណ សព្វសារពើ (២:២៥៦) ។*

សេចក្តីប្រកាសរបស់អ្នកលង់ខ្លៅឆៅប្រាជ្ញាខាងលើនេះ ផ្ទុយគ្នាស្រឡះអំពីព្រះគម្ពីរគួរអាននិងប្រវត្តិសាស្ត្រអ៊ីស្លាម ។ ប៉ែតសិបពីរសមរភូមិដឹកនាំដោយរ៉សូលុលឡោះហ៍ﷺនិងអ៊ីមាំអាលីصلوات الله عليه والسلامប្រឆាំង តទល់នឹងពួកខ្មាំងសត្រូវឈ្លានពានអន្យតិរ្ថិយ ក្នុងប្រវត្តិសាស្ត្រអ៊ីស្លាមនោះទៅយ៉ាងណាទៅ ? ហេតុអ្វីអស់លោកបែរជាទៅទម្លាក់ទោសយ៉ាងខ្លីដាក់លើរ៉សូលុលឡោះហ៍ﷺនិងអ៊ីមាំអាលីصلوات الله عليه والسلامយ៉ាងនោះទៅវិញ ? ឯរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលបានចែងនៅក្នុងជំពូកទី ៣ មាត្រា ទី ៤៣ ថា *"ប្រជាពលរដ្ឋខ្មែរ ទាំងពីរភេទ មានសិទ្ធិពេញទីខាងជំនឿ ។ សេរីភាពខាងជំនឿនិងប្រតិបត្តិខាងផ្លូវសាសនា ត្រូវបានរដ្ឋធានាក្នុងល័ក្ខខណ្ឌដែលមិនប៉ះពាល់ជំនឿ ឬសាសនាដ៏ទៃទៀត ដល់សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ ។ ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ"* ក៏អស់លោកមិនបានទាំងដឹងទៅទៀតផង ។

អល់ឡោះហ៍តាអាឡាមានព្រះបន្ទូលថា៖

رَحۡمَتُ ٱللَّهِ وَبَرَكَٰتُهُۥ عَلَيۡكُمۡ أَهۡلَ ٱلۡبَيۡتِۚ إِنَّهُۥ حَمِيدٞ مَّجِيدٞ ﴿٧٣﴾

*សូមឲ្យព្រះមេត្តាធម៌អល់ឡោះហ៍និងសិរីសួស្តីនៃព្រះអង្គ កើតមានដល់*



រាជបញ្ជាឲ្យធ្វើអំពើស្ទីរិកបានដូចម្តេចទៅ ?

ព្រះមហាគម្ពីរចែងថា៖

قُلۡ إِنَّ ٱللَّهَ لَا يَأۡمُرُ بِٱلۡفَحۡشَآءِۖ أَتَقُولُونَ عَلَى ٱللَّهِ مَا لَا تَعۡلَمُونَ

*"ចូរអ្នកថ្លែង[ប្រាប់ពួកគេ]ថា៖ "អល់ឡោះហ៍មិនបញ្ជាឲ្យធ្វើអំពើលាមកទេ ។ តើអស់លោកនិយាយទម្លាក់ទៅលើអល់ឡោះហ៍នូវអ្វីដែលអស់លោកពុំដឹងទេនោះឬ ?៧:២៨"*[345]

តាមទ្រឹស្តី ព្រះរាជបញ្ជារបស់អល់ឡោះហ៍ﷻមិនផ្លាស់ប្តូរខ្លឹមសាររបស់ទង្វើទេ ។ ប្រសិនបើការក្រាបប្រណិប័តន៍អ្នកណាមួយមានន័យថាគោរពសក្ការៈអ្នកនោះជាព្រះ ហើយអល់ឡោះហ៍ដាក់ព្រះបញ្ជាឲ្យធ្វើបែបនេះមែន បានសេចក្តីថានេះជាព្រះរាជបញ្ជាឲ្យគោរពសក្ការៈអ្នកនោះជាព្រះ ។

## ដោះស្រាយបញ្ហាន័យមិនច្បាស់លាស់ និងអត្ថន័យពិតរបស់សក្ការៈព្រះ (អ៊ីបាដាស់)

រហូតមកដល់ពេលនេះ យើងបានឃើញថាការហាមគោរពសក្ការៈផ្សេងពីអល់ឡោះហ៍ﷻ ជាការហាមតែមួយរបស់សាសនាទាំងអស់ក្នុងលោកដែលគោរពសក្ការៈព្រះតែមួយ ។ ម្យ៉ាងទៀត ដែលអស់ទេវតាក្រាបប្រណិប័តន៍អាដាំعليه السلام យ៉ាកុំគូបعليه السلامនិងកូនៗព្រះអង្គعليه السلامក្រាបប្រណិប័តន៍យូស៊ុហ្វនោះមិនត្រូវចាត់ទុកជាទង្វើសក្ការៈព្រះទេ ។

345 ស៊ូរ៉ោះត៍ អាល់-អាក់រ៉ហ្វ 7:28 ។

គួរអានរំលឹកអំពីសម្តីរបស់យូស៊ុហ្វعليه السلام កាលព្រះអង្គعليه السلامសុបិនឃើញផ្កាយដប់ពីរដួង ថ្ងៃនិងខែ ក្រាបប្រណិប័តន៍ព្រះអង្គعليه السلام ។ គួរអានចែងអំពីសម្តីយូស៊ុហ្វعليه السلامថា៖

إِنِّي رَأَيْتُ أَحَدَ عَشَرَ كَوْكَبًا وَالشَّمْسَ وَالْقَمَرَ رَأَيْتُهُمْ لِي سَاجِدِينَ

*"ខ្ញុំបានឃើញ [ក្នុងសុបិន] ផ្កាយដប់មួយ ដួងអាទិត្យនិងដួងចន្ទ្រក្រាបថ្វាយបង្គំខ្ញុំ១២:៤ ។"*[344]

យូស៊ុហ្វចាត់ទុក ការក្រាបប្រណិប័តន៍របស់សាច់សាលោហិតរបស់ព្រះអង្គعز وجلនេះជាការបកស្រាយសុបិនព្រះអង្គعليه السلامដែលទៅជាពិត ផ្កាយដប់មួយដួងគឺបងៗព្រះអង្គعليه السلامទាំងដប់មួយនាក់ ថ្ងៃនិងខែគឺបិតានិងមាតាព្រះអង្គعليه السلام ។

មិនត្រឹមតែបងៗរបស់យូស៊ុហ្វعليه السلامទេ ដែលក្រាបប្រណិប័តន៍ព្រះអង្គعليه السلام យ៉ាកុគ្គូបعليه السلام បិតាព្រះអង្គعليه السلامក៏ក្រាបប្រណិប័តន៍ព្រះអង្គعليه السلامដែរ ។ ហេតុអ្វីការក្រាបប្រណិប័តន៍ ដែលជាការសម្តែងសេចក្តីគោរពដ៏ខ្ពង់ខ្ពស់នោះ ពុំមានន័យថាសក្ការៈព្រះ ?

## ការឆ្លើយដោះសាអាក្រក់ជាងបាប

ក្រុមអ្នកនិពន្ធដែលយើងបាននិយាយខាងលើនេះ មិនមានពាក្យអ្វីឆ្លើយតប ក៏បាននិយាយថាការដាក់ខ្លួនបែបនេះជាការធ្វើតាមព្រះបញ្ជារបស់អល់ឡោះហ្ម៍عز وجل ហើយមិនត្រូវចាត់ទុកជាអំពើស្ហ៊ីរិកទេ ។
ចម្លើយនេះហាក់ដូចជាឆ្គង ពត្លីកភ្លើពេក តើអល់ឡោះហ្ម៍عز وجلអាចដាក់ព្រះ

344 ស៊ូរ៉ោះត៍ យូស៊ុហ្វ 12:4 ។



*អស់លោក អាស្ល់លុល-បៃត៍ (ឱរាជកុលដ្ឋាន) អើយ ។ ព្រះអង្គជាទីកោតសរសើរ ជាព្រះដ៏មហារុងរឿង (១១:៧៣) ។"*

إِنَّمَا يُرِيدُ اللَّهُ لِيُذْهِبَ عَنكُمُ الرِّجْسَ أَهْلَ الْبَيْتِ وَيُطَهِّرَكُمْ تَطْهِيرًا ﴿٣٣﴾

*សមាជិកនៃគេហដ្ឋាន[របស់សាស្តា]អើយ អល់ឡោះហ្ម៍គ្រាន់តែប្រាថ្នាឲ្យពួកអ្នកចាកផុតពីមន្ទិល ហើយព្រះអង្គប្រាថ្នាសំអាតពួកអ្នកឲ្យបរិសុទ្ធជ្រះស្អាតតែប៉ុណ្ណោះទេ (៣៣:៣៣) ។*

قُل لَّا أَسْأَلُكُمْ عَلَيْهِ أَجْرًا إِلَّا الْمَوَدَّةَ فِي الْقُرْبَىٰ

*ចូរអ្នកថា៖ "ខ្ញុំមិនសូមឈ្នួលពីអស់លោកសម្រាប់អ្វីទាំងនេះទេ សូមឲ្យតែអាណិតស្រឡាញ់បណ្តាសាច់សាលោហិតជំនិតរបស់ខ្ញុំ (៤២:២៣) ។"*

فقال رسول الله (صلى الله عليه و آله): يا علي، هذه الآية نزلت فيك، و في سبطي، و الأئمة من و لدك.

រ៉ស៊ូលុលឡោះហ្ម៍ﷺមានព្រះវចនៈថា៖ "អ៊ុលីصلوات الله عليه والسلامអើយ ! អាយ៉ាស្ល់នេះត្រូវបើកឲ្យដឹងសំដៅមកលើអ្នកصلوات الله عليه والسلام សំដៅមកលើចៅទាំងពីរعليهم السلامរបស់ខ្ញុំﷺ និងសំដៅមកលើបណ្តាអ៊ីមុាំعليهم السلامដែលចេញមកពីកូនៗعليهم السلامរបស់អ្នកصلوات الله عليه والسلام ។" (كفاية الأثر: 155)

*អាល់-ស្វ៍ហ៊ិះហ្ម៍* លោកមុស្លីមបានសរសេរថា ស៊ែដ៍ អ៊ីបនូ អារកុំបានតំណាលថា៖ នៅឯកន្លែងមួយដែលនៅចន្លោះម៉ាក់កាស្ល់និងម៉ាឌីណាស្ល់ដែលគេហៅ "ឃុម" ព្រះសាសនៈទូតរបស់អល់ឡោះហ៍ បន្ទាប់ពីបានថ្លែងសុន្ទរកថាប្រាប់យើង បន្ទាប់ពីបានអរព្រះគុណអល់ឡោះហ៍តាអុាឡា និងបន្ទាប់ពីបានថ្លែងរំលឹកអំពីព្រះអង្គعز وجل ព្រះសាស្តាﷺមានព្រះវចនៈ

ថា៖

أَلاَ أَيُّهَا النَّاسُ، فَإِنَّمَا أَنَا بَشَرٌ يُوشِكُ أَنْ يَأْتِيَنِي رَسُولُ رَبِّي فَأُجِيبُ، وَأَنَا تَارِكٌ فِيكُم ثَقَلَيْنِ: أَوَّلُهُمَا كِتَابُ اللهِ فِيهِ الهُدىٰ وَالنُّورُ؛ فَخُذُوا بِكِتَابِ اللهِ وَاسْتَمْسِكوا بِهِ... وَأَهْلُ بَيْتِي؛ أُذَكِّرُكُمُ اللهَ فِي أَهْلِ بَيْتِي، أُذَكِّرُكُمُ اللهَ فِي أَهْلِ بَيْتِي، أُذَكِّرُكُمُ اللهَ فِي أَهْلِ بَيْتِي.

ប្រជានិករអើយ ខ្ញុំមិនមែនអ្វីក្រៅពីមនុស្សធម្មតាទេ ។ បន្តិចទៀតអ្នកនាំសាររបស់អល់ឡោះហ៍ (ពោលគឺ ទេវតាយកជីវិត) នឹងមកជួបខ្ញុំ ហើយខ្ញុំនឹងឆ្លើយតប ។ ខ្ញុំនឹងទុកឲ្យអស់លោកនូវវត្ថុសំខាន់ពីរគឺ៖ មួយគឺព្រះគម្ពីររបស់អល់ឡោះហ៍ដែលមាននូវការដឹកនាំល្អ និងពន្លឺត្រចះត្រចង់ ។ ចូរអស់ការពារខ្លួនដោយព្រះគម្ពីរអល់ឡោះហ៍ និងចូរអស់លោកតោងព្រះគម្ពីរនេះឲ្យជាប់ ។ ពីរគឺគ្រួសារខ្ញុំ ។ ចូរអស់លោកខ្លាចអល់ឡោះហ៍រឿងអ្នកផ្ទះខ្ញុំ ចូរអស់លោកខ្លាចអល់ឡោះហ៍រឿងអ្នកផ្ទះខ្ញុំ ចូរអស់លោកខ្លាចអល់ឡោះហ៍រឿងអ្នកផ្ទះខ្ញុំ ។"

បុណ្យបារមីឧត្តុង្គឧត្តម ពិសេសរបស់គ្រួសារ﷣ព្រះសាស្តាﷺ ជម្រុញអ៊ីម៉ាំអាស្ង់-ស្ហាហ្វីអ៊ីឲ្យតែងកំណាព្យដ៏ល្បីដូចតទៅ៖

يا أهل بيت رسول الله حبّكم فرض من الله في القرآن أنزله كفاكم من عظيم القد أنكم من لم يصل عليكم لا صلوة له."

*"ឱព្រះរាជកុលដ្ឋាន (អាស្ង់លុល-បៃត៍) ព្រះសាស្តាﷺរបស់អល់ឡោះហ៍ﷻអើយ សេចក្តីស្រឡាញ់[របស់អស់ទូលបង្គំ]មកលើព្រះអង្គ﷣ជាកាតព្វកិច្ចដែលអល់ឡោះហ៍ﷻ បានបើកឲ្យដឹងនៅក្នុងគួរអាន ។ បុណ្យបារមីខ្ពង់ខ្ពស់របស់ព្រះអង្គ﷣នោះគឺ បើអ្នកណាមួយមិនបួងសួងសូមពរជ័យឲ្យព្រះអង្គ﷣ទេ [ក្នុងស្វ៊ឡាត់] ស្វ៊ឡាត់របស់អ្នកនោះត្រូវមោឃៈ ។"*



អ្នកនិពន្ធមួយចំនួនបកស្រាយ អ៊ីបាដ្ញាស់ (សក្ការៈ) ថា "បន្ទាបខ្លួន" ឬ "ដាក់ខ្លួនណាស់" តែអស់លោកទាំងនេះខុសក្នុងការបកស្រាយអាយ៉ាស់គួរអានខ្លះ គឺ៖

وَإِذْ قُلْنَا لِلْمَلَٰٓئِكَةِ ٱسْجُدُوا۟ لِءَادَمَ

*"កាលយើងបានត្រាស់ទៅអស់ទេវតាថា៖ "ពួកអ្នកចូរក្រាបប្រណិប័តន៍អាដាំ២:៣៤ ។"*[342]

ការក្រាបប្រណិប័តន៍អាដាំ﷣ មានបែបបទដូចការក្រាបប្រណិប័តន៍ដែរ ។ បែបបទក្រាបប្រណិប័តន៍ទីមួយមានន័យសម្តែងសេចក្តីគោរពនិងការដាក់ខ្លួន រីឯបែបបទក្រាបប្រណិប័តន៍ទីពីរមានន័យសក្ការៈ ភក្តីភាព ។

ហេតុអ្វីការក្រាបប្រណិប័តន៍ដូចគ្នាទាំងពីរនេះមានន័យខុសគ្នា ?

គួរអានថែងថា៖ "យ៉ាក់គូប﷣បានក្រាបប្រណិប័តន៍ណាប៊ីយូស៊ុហ្វ﷣ជាមួយកូនៗព្រះអង្គ﷣ គឺ៖

وَرَفَعَ أَبَوَيْهِ عَلَى ٱلْعَرْشِ وَخَرُّوا۟ لَهُۥ سُجَّدًا ۖ وَقَالَ يَٰٓأَبَتِ هَٰذَا تَأْوِيلُ رُءْيَٰىَ مِن قَبْلُ قَدْ جَعَلَهَا رَبِّى حَقًّا ۖ

*"គេបានអញ្ជើញមាតាបិតារបស់គេឡើងទៅលើបល្ល័ង្ក ហើយពួកគេស្រុតខ្លួនចុះក្រាបថ្វាយបង្គំចំពោះមុខគេ ។ គេបានថ្លែងថា៖ "លោកឪពុកនេះគឺអត្ថន័យរបស់សុបិនរបស់កូនកាលពីមុន ។ ព្រះម្ចាស់ខ្ញុំបានធ្វើឲ្យវាទៅជាពិត១២:១០០ ។"*[343]

[342] ស៊ូរ៉ោះត៍ អាល់-បាក៏រ៉ោះត៍ 2:34 ។

[343] ស៊ូរ៉ោះត៍ យូស៊ុហ្វ 12:100 ។

*"យើងបានបញ្ជូនសាស្តាមួយរូបទៅកេសហាគមន៍នីមួយៗ [ថ្លែងប្រាប់ពួកគេថា៖] "ចូរអស់លោកគោរពបូជាអល់ឡោះហ្ ហើយចូរចោលត៏្គុត (រូបបដិមា ថៅហ្វាយ មនុស្ស វត្ថុដែលជាខ្មោច ព្រាយបិសាច)១៦:៣៦ ។"*[341]

ដោយហេតុនេះ ការគោរពសក្ការៈចំពោះតែអល់ឡោះហ្ عز وجل មួយគត់ មិនគោរពសក្ការៈបុគ្គលណាផ្សេងឡើយនោះ ជាទ្រឹស្តីមិនអាចប្រកែកបាន ហើយជាលក្ខខណ្ឌចាំបាច់អត់មិនបានរបស់តៅហ៊ីដ្ ។ បើគ្មានលក្ខខណ្ឌនេះទេ ពុំមានតៅហ៊ីដ្ទេ ។

តើមានលក្ខខណ្ឌអ្វីខ្លះដើម្បីវែកញែកឲ្យដឹង "សក្ការៈ (អ៊ីបាដ៉ាស្ង)" ?

ឧទាហរណ៍ តើថើបដៃលោកគ្រូ ឪពុកម្តាយ អស់លោកអ្នកប្រាជ្ញ ឬសម្តែងសេចក្តីគោរពឯទៀត ចំពោះបុគ្គលដែលមានសិទ្ធិលើខ្លួនយើងនោះត្រូវចាត់ទុកជាការគោរពសក្ការៈជាព្រះអស់បុគ្គលទាំងនេះដែរទេ ?

តើអាចចាត់ទុកសក្ការៈក្នុងន័យដាក់ខ្លួន គោរពយ៉ាងជ្រាលជ្រៅ បានទេ ឬផ្ទុយទៅវិញ តើមានចំណុចសំខាន់ណាមួយនៅក្នុងទង្វើនេះទេដែល - បើពុំមានចំណុចសំសាន់នេះទេ ការសម្តែងសេចក្តីគោរព ទោះជាក្រាបប្រណិប័តន៍ក៏ដោយនោះ - ពុំមានន័យថាសក្ការៈព្រះទេ ?

តើចំណុចសំខាន់នោះគឺអ្វី ដែលអាចធ្វើឲ្យការដាក់ខ្លួននិងការសម្តែងសេចក្តីគោរពដ៏ជ្រាលជ្រៅនោះទៅសក្ការៈព្រះបាន ?

# ការយល់ច្រឡំអំពីរឿងសក្ការៈ

[341] ស៊ូរ៉ោះត៍ អាន់-ណាស្ល៍ 16:36 ។



ឱ ! តើឯណាទៅអ្នកកាន់សាសនាអ៊ីស្លាមនៅកម្ពុជាដែលអះអាងថាប្រកាន់យកនិកាយអាស្ស-ស្វាហ្វីអ៊ីជាមូលដ្ឋាននោះ ? បើអ៊ីម៉ាំអាស្ស-ស្វាហ្វីអ៊ីស្រឡាញ់គ្រួសាររ៉ស៊ូលុលឡោះហ៍ صلى الله عليه وآله وسلم ម្លឹងៗនោះ ចុះហេតុអ្វីទៅបានជាអ្នកតាមអ៊ីម៉ាំអាស្ស-ស្វាហ្វីអ៊ីមួយចំនួននៅកម្ពុជា បែរជានាំគ្នាទៅផ្តន្ទាទោសគ្រួសាររ៉ស៊ូលុលឡោះហ៍ صلى الله عليه وآله وسلم យ៉ាងដូច្នោះទៅវិញ ? បានសេចក្តីថា អស់លោកទាំងនោះភ្លេច មិនបានបួងសួងសូមពរជ័យក្នុងស្វឡាត្ គឺ៖

أَللّٰهُمَّ صَلِّ عَلىٰ مُحَمَّدٍ وَ عَلىٰ آلِ مُحَمَّدٍ

*អល់ឡោះហ៍ عز وجل អើយ សូមព្រះរាជប្រទានពរជ័យដល់មូហាំម៉ាដ្ និងដល់គ្រួសារមូហាំម៉ាដ្ ។*

ដូច្នោះ ស្វឡាត្របស់អស់លោកនឹងត្រូវមោឃៈ ដូចអ៊ីម៉ាំ អាស្ស-ស្វាហ្វីអ៊ីមានស្រាសន៍ ។

អ៊ីម៉ាំ អាល់-ប៊ូខ៊រី នៅក្នុង *អាល់-ស្វហ៊ិះហ៍* របស់លោក បានកត់ត្រាទុកនូវសេចក្តីរាយការណ៍តមកពី អាប់ដាល់-រ៉ោះហ្មាន អ៊ីបនូ អាប៊ូ ឡៃឡា (عبد الرحمن بن أبي ليلى) ថា៖ "កាអាប់ អ៊ីបនូ អាល់-យ៉ាជ្រ៉ោះហ៍ បានជួបខ្ញុំ បានថា៖ "តើខ្ញុំអាចបង្ហាញលោកនូវអំណោយមួយដែលខ្ញុំបានឮមកពីព្រះសាសនៈទូតរបស់អល់ឡោះហ៍បានទេ ?" ខ្ញុំបានឆ្លើយថា៖ "បាន សូមប្រាប់ខ្ញុំមក ។" លោកបាននិយាយថា៖ "យើងបានសួរព្រះសាស្តា صلى الله عليه وآله وسلم ថាតើជូនពរដល់អាស់លុល-បៃត៍ដូចម្តេចទៅ ? ព្រះអង្គមានព្រះវចនៈថា៖ "អស់លោកគប្បីថា៖

قُولُوا: اللَّهُمَّ صَلِّ عَلَىٰ مُحَمَّدٍ وَعَلَىٰ آلِ مُحَمَّدٍ كَمَا صَلَّيْتَ عَلَىٰ إِبْرَاهِيمَ وَعَلَىٰ آلِ إِبْرَاهِيمَ، إِنَّكَ حَمِيدٌ مَجِيدٌ. اللَّهُمَّ بَارِكْ عَلَىٰ مُحَمَّدٍ وَعَلَىٰ آلِ مُحَمَّدٍ كَمَا بَارَكْتَ عَلَىٰ إِبْرَاهِيمَ وَعَلَىٰ آلِ إِبْرَاهِيمَ، إِنَّكَ حَمِيدٌ مَجِيدٌ.

*ចូរថា៖ "អល់ឡោះហ៍អឺយ សូមព្រះអង្គអាណិតមេត្តាមូហាំម៉ាដ់និងគ្រួសាររបស់មូហាំម៉ាដ់ដូច ព្រះអង្គអាណិតមេត្តាអ៊ីបរ៉ហ៊ីម និងគ្រួសាររបស់អ៊ីបរ៉ហ៊ីមដែរ ។ ពិតណាស់ ព្រះអង្គជាទីគោរពសក្ការៈ ជាអង្គទ្រង់មហារុងរឿង ។ អល់ឡោះហ៍អឺយ សូមព្រះអង្គប្រទានពរជ័យដល់មូហាំម៉ាដ់ និងគ្រួសាររបស់មូហាំម៉ាដ់ ដូចព្រះអង្គប្រទានពរជ័យដល់អ៊ីបរ៉ហ៊ីមនិងគ្រួសាររបស់អ៊ីបរ៉ហ៊ីមដែរ ។ ពិតណាស់ ព្រះអង្គជាទីគោរពសក្ការៈ ព្រះអង្គទ្រង់មហារុងរឿង ។"*

រីឯជនភ្លីភ្លើសិនដេកសិនដើរខ្លះនៅតាមសង្កាត់មាត់ញក នៅខាងក្រៅនិកាយទាំងបួននោះ មិនព្រមបករបាំងអវិជ្ជាចេញពីមតិរបស់ខ្លួនទេ ផ្ទុយទៅវិញធ្វើកាន់តែខ្លាំងលើសហ្នឹងទៀត បានមូលបង្កាច់ថា បណ្ដាអ្នកតាមមាគ៌ាអាស្ហ់លុល-បៃត៍រ៉ស៊ូលុលឡោះហ៍ﷺ សំពះអាចម៍គោអាចម៍ក្របី ។ ចំណែកពួកល្ងីល្ងើនៅខាងក្រៅប្រទេសវិញធ្វើត្រាប់តាមពួកភ្លីភ្លើ បង្ហោះតាមបណ្ដាញ facebook បានពោលពាក្យផរុសវាចាប៉ះពាល់ដល់អាស្ហ់លុល-បៃត៍រ៉ស៊ូលុលឡោះហ៍ﷺ ដោយចាត់ទុកខ្លួនជាឧត្តមភាព សឹងថានៅក្នុងភពផែនដែនលោកនេះ មិនមាននរណាមួយផ្ទឹមស្មើនឹងខ្លួនគេឡើយ បញ្ចេញឫកចង់ឲ្យគេដឹងថា ខ្លួនគេហ្នឹងខ្លាំងអស្ចារ្យរ៉ុយៗ សម្បើមណាស់ ។

អល់ឡោះហ៍តាអាឡាមានព្រះបន្ទូលថា៖

قُلْ إِن كُنتُمْ تُحِبُّونَ ٱللَّهَ فَٱتَّبِعُونِى يُحْبِبْكُمُ ٱللَّهُ

*[សាស្ដាអឺយ] ចូរអ្នកថ្លែង[ប្រាប់បណ្ដាមនុស្ស]ថា៖ "បើអស់លោក*



*"ជនណាមិនកាត់សេចក្ដីតាមអ្វីដែលអល់ឡោះហ៍បានបើកឲ្យដឹងទេ ជនទាំងនោះជាជនបំពារបំពាន ៥:៤៧ ។"*[338]

وَمَن لَّمْ يَحْكُم بِمَآ أَنزَلَ ٱللَّهُ فَأُو۟لَـٰٓئِكَ هُمُ ٱلظَّـٰلِمُونَ

*"ជនអ្នកណាមិនកាត់សេចក្ដីតាម អ្វីដែលអល់ឡោះហ៍បានបើកឲ្យដឹងទេ ជនទាំងនោះជាជនទុច្ចរិត ៥:៤៥ ។"*[339]

## ៧. តៅហ៊ីដ្ធសក្ការៈ (តៅហ៊ីដ្ធ អ៊ីបាដ្ហាស់)

អ្វីដែលសំខាន់បំផុតក្នុងតៅហ៊ីដ្ធគឺតៅហ៊ីដ្ធសក្ការៈ និងអត្ថន័យរបស់ពាក្យអ៊ីបាដ្ហាស់ (សក្ការៈ) ព្រោះមុស្លីមទាំងអស់មូលមតិគ្នាថាគោលដៅតែមួយគត់នៃសក្ការៈ (អ៊ីបាដ្ហាស់) គឺអល់ឡោះហ៍ﷻ មិនសក្ការៈបុគ្គលណាក្រៅពីព្រះអង្គﷻឡើយ; ព្រះគម្ពីរគួរអានចែងអំពីរឿងនេះថា៖

إِيَّاكَ نَعْبُدُ وَإِيَّاكَ نَسْتَعِينُ

*"ព្រះអង្គទេដែលអស់ទូលព្រះបង្គំជាខ្ញុំគោរពបូជា (ស្ដាប់បង្គាប់) ព្រះអង្គទេដែលអស់ទូលព្រះបង្គំជាខ្ញុំអង្វរសូមនូវជំនួយ ១:៥ ។"*[340]

ព្រះអាយ៉ាស់គួរអានបញ្ជាក់ថា រឿងនេះជាគោលការណ៍តែមួយក្នុងបេសកកម្មរបស់ព្រះសាស្ដាទាំងអស់عليهم السلام ព្រះសាសនៈទូតទាំងអស់មានករណីយកិច្ចផ្សព្វផ្សាយរឿងនេះ ។ ព្រះគម្ពីរគួរអានចែងអំពីរឿងនេះថា៖

وَلَقَدْ بَعَثْنَا فِى كُلِّ أُمَّةٍ رَّسُولًا أَنِ ٱعْبُدُوا۟ ٱللَّهَ وَٱجْتَنِبُوا۟ ٱلطَّـٰغُوتَ

[338] ស៊ូរ៉ោះត៍ អាល់-ម៉ាអ៊ីដ្ហាស់ 5:47 ។

[339] ស៊ូរ៉ោះត៍ អាល់-ម៉ាអ៊ីដ្ហាស់ 5:45 ។

[340] ស៊ូរ៉ោះត៍ អាល់-ហ្វាទីហ៊ាស់ 1:5 ។

*៣៨:២៦ ។"*[336]

# ៥. តៅហ៊ីដូគោរព

តៅហ៊ីដូគោរពមានន័យថា បុគ្គលជាទីគោរពជាចាំបាច់មិនអាចអត់បាន និងព្រះដែលគេត្រូវតែតាមគឺអល់ឡោះហ្ ﷻ ។

អាស្រ័យហេតុនេះ ការចាំបាច់ត្រូវតែគោរពបុគ្គលចំពូកនេះ ដូចជាព្រះសាស្តាﷺ អ៊ីមុាំ នីតិវិទូ (ហ្វាគិះហ្) ម្តាយនិងឪពុក ជាដើមជាទង្វើដែលព្រះអង្គﷻបានដាក់មកឲ្យធ្វើ ហើយវាមកពីព្រះបំណងរបស់ព្រះអង្គﷻ ។

# ៦. តៅហ៊ីដូនីតិកម្ម

តៅហ៊ីដូនីតិកម្មមានន័យថា សិទ្ធិបង្កើតច្បាប់ជារបស់អល់ឡោះហ្ﷻមួយគត់ ។ អាស្រ័យហេតុនេះ ព្រះគម្ពីរយើង (គឺគួរអាន) ចាត់ទុកច្បាប់ណាដែលនៅក្រៅប្រកខណ្ឌព្រះរាជក្រឹត្យ ជាប្រភពនៃបទក្បត់សាសនា ជាបទល្មើសនិងអំពើអាក្រក់ គឺះ

وَمَن لَّمۡ يَحۡكُم بِمَآ أَنزَلَ ٱللَّهُ فَأُوْلَٰٓئِكَ هُمُ ٱلۡكَٰفِرُونَ

*"ជនណាមិនកាត់សេចក្តីតាមអ្វីដែលអល់ឡោះហ្បានបើកឲ្យដឹងទេ ជនទាំងនោះជាជនបដិសេធសទ្ធា ៥:៤៤ ។"*[337]

وَمَن لَّمۡ يَحۡكُم بِمَآ أَنزَلَ ٱللَّهُ فَأُوْلَٰٓئِكَ هُمُ ٱلۡفَٰسِقُونَ

[336] ស៊ូរ៉ោះត៍ ស្វដ 38:26 ។

[337] ស៊ូរ៉ោះត៍ អាល់-ម៉ាអ៊ីដាស់ 5:44 ។



*ស្រឡាញ់អល់ឡោះហ្ចូរតាមខ្ញុំ ។ អល់ឡោះហ្នឹងសព្វព្រះហឫទ័យ អស់លោក (៣:៣១) ។*

قالَ رَسُوْلُ اللهِ (ص) : مَثَلُ أَهْلِ بَيْتِي فِي أُمَّتِي مَثَلُ سَفِيْنَةِ نُوْحٍ مَنْ رَكِبَها نَجا وَ مَنْ رَغِبَ عَنْها هَلَكَ

بحار الأنوار/113/27

រ៉ស៊ូលុលឡោះហ្ﷺមានវចនៈថា "ឧទាហរណ៍នៃអាស្ហ់លុល-បៃត៍ខ្ញុំﷺ ប្រៀបដូចសំពៅរបស់ ណាប៊ី នុះហ៍ អ្នកណាបានធ្វើដំណើរលើសំពៅនឹងត្រូវផុតភ័យ ចំណែកអ្នកណាដែលបានបដិសេធ (មិនឡើងលើសំពៅ) នឹងត្រូវវិនាស (លិចលង់) ។" ប៊ីហារុល-អាន់វ៉ារ ក្បាល ២៧ ទំព័រ ១១៣

អល់ឡោះហ៍តាអាឡាមានព្រះបន្ទូលថាៈ

كُنتُمۡ خَيۡرَ أُمَّةٍ أُخۡرِجَتۡ لِلنَّاسِ تَأۡمُرُونَ بِٱلۡمَعۡرُوفِ وَتَنۡهَوۡنَ عَنِ ٱلۡمُنكَرِ وَتُؤۡمِنُونَ بِٱللَّهِۗ

*[ឱបណ្តាអ្នកមានសទ្ធាជ្រះថ្លានិងមានព្រហ្មចារិយធម៌អើយ] ពួកអ្នកជាសហគមន៍ល្អបំផុតដែលបានលេចឡើងសម្រាប់បណ្តាមនុស្ស ។ ពួកអ្នកបង្គាប់ឲ្យធ្វើល្អ[តាមព្រះរាជក្រឹត្យដែលអល់ឡោះហ្ដាក់មក] ពួកអ្នកហាមប្រព្រឹត្តអំពើអាក្រក់ ពួកអ្នកមានសទ្ធាចំពោះអល់ឡោះហ្ (៣:១១០) ។*

អាប៊ូ អាប់ឌុលឡោះហ្ صلوات الله عليه والسلام មានវចនៈថាៈ «បណ្តាសហគមន៍ប្រសើរជាច់

គេបានសម្លាប់អាមីរុល-មុមីនីន صلوات الله عليه والسلام, អាល់-ហ៊ាសាន់ صلوات الله عليه والسلام និងអាល់-ហ៊ូសែន៍ صلوات الله عليه والسلام ព្រះរាជបុត្រទាំងពីររបស់អាុលី صلوات الله عليه والسلام ?»

អល់ឡោះហ៍តាអាុឡាមានព្រះបន្ទូលថាៈ

مَن قَتَلَ نَفۡسَۢا بِغَيۡرِ نَفۡسٍ أَوۡ فَسَادٖ فِي ٱلۡأَرۡضِ فَكَأَنَّمَا قَتَلَ ٱلنَّاسَ جَمِيعٗا وَمَنۡ أَحۡيَاهَا فَكَأَنَّمَآ أَحۡيَا ٱلنَّاسَ جَمِيعٗاۚ

*អ្នកណាមួយសម្លាប់មនុស្សម្នាក់ ដោយមនុស្សនោះពុំបានសម្លាប់មនុស្ស [ដោយគ្មានសិទ្ធិ] ឬពុំបានបង្កវិនាសនៅលើផែនដីទេ អ្នកនោះដូចជាបានសម្លាប់មនុស្សទាំងអស់ ។ ឯអ្នកណាមួយជួយសង្គ្រោះ[មនុស្សម្នាក់]ឲ្យមានជីវិតឡើងវិញ អ្នកនោះដូចជាបានជួយសង្គ្រោះមនុស្សទាំងអស់ឲ្យមានជីវិតឡើងវិញដែរ (៥:៣២) ។*

អាប៊ូ អាុប់ឌុលឡោះហ្វ៍ صلوات الله عليه والسلام បានមានវចនៈថាៈ "អ្នកណាបានច្រានមនុស្សម្នាក់ចេញពីសេចក្ដីវង្វេង ទៅរកមាគ៌ាដឹកនាំល្អ ហាក់ដូចជាអ្នកនោះបានធ្វើឲ្យមនុស្សនោះរស់ឡើងវិញ ។ អ្នកណាទាញមនុស្សម្នាក់ចេញពីមាគ៌ាដឹកនាំល្អទៅរកសេចក្ដីវង្វេង អ្នកនោះបានសម្លាប់មនុស្សនោះ ។" (الكافي 2 : 168 / 1)

ដោយច្រើនអាយ៉ាស៊ុច្រើនហាឌិស្សពេក យើងខ្ញុំមិនអាចបរិយាយនៅក្នុងនេះបាន យើងខ្ញុំសូមឆ្លើយសំណួរទាំងអម្បាលម៉ានដែលអស់លោកលោកស្រី និងមិត្រអ្នកអាន បានចោទសួរជាច្រើនអំពីរឿងហេតុស្ទុំអាស៊ុជូននៅទំព័រខាងមុខ ។



នៅក្នុងដំណើរការជីវិត ការរៀបចំបន្ទាប់បន្សំគ្រប់ប្រភេទអាចប្រព្រឹត្តទៅបានអាស្រ័យតែលើចំណង់ និងការអនុញ្ញាតរបស់អល់ឡោះហ្វ៍ عز وجل មួយគត់ ។ ព្រះមហាគម្ពីរគួរអានក៏ចែងអំពីការរៀបចំរបស់អល់ឡោះហ្វ៍ عز وجل នេះដែរ គឺៈ

فَٱلۡمُدَبِّرَٰتِ أَمۡرٗا

*"បណ្ដាអ្នកសម្រួលភារកិច្ច ៧៩:៥ ។"*[334]

# ៤. តៅហ៊ីដូអំណាច

តៅហ៊ីដូអំណាចមានន័យថា អំណាចជាកម្មសិទ្ធិរបស់អល់ឡោះហ្វ៍ عز وجل ហើយព្រះអង្គ جل មួយគត់ជាម្ចាស់របស់សត្វលោកទាំងអស់ ដូចគួរអានចែងថាៈ

إِنِ ٱلۡحُكۡمُ إِلَّا لِلَّهِ

*"ការវិនិច្ឆ័យនៅលើអល់ឡោះហ្វ៍តែមួយគត់ ១២:៤០ ។"*[335]

អាស្រ័យហេតុនេះ អំណាចឯទៀតកើតមានឡើងបានដោយសារព្រះបំណងព្រះអង្គ جل ដើម្បីនឹងឲ្យបុគ្គលល្អត្រឹមត្រូវគ្រប់គ្រងសហគមន៍ និងដឹកមនុស្សទៅកាន់សុខុមាលភាពនិងសុក្រឹតភាព ដូចគួរអានចែងថាៈ

يَٰدَاوُۥدُ إِنَّا جَعَلۡنَٰكَ خَلِيفَةٗ فِي ٱلۡأَرۡضِ فَٱحۡكُم بَيۡنَ ٱلنَّاسِ بِٱلۡحَقِّ

*"ដាវូដអឺយ ពិតណាស់ យើងបានតែងតាំងអ្នកជាខ៍លីហ្វ(អ្នកគ្រប់គ្រង)លើផែនដី ។ ចូរអ្នកកាត់សេចក្ដីរវាងមនុស្សទាំងឡាយដោយសេចក្ដី ពិត*

---

334 ស៊ូរ៉ោះត៍ អាន់-ណាស៊ីអាត់ 79:5 ។

335 ស៊ូរ៉ោះត៍ យូស៊ុហ្វ 12:40 ។

ហ្ការ៉ម៉ែន៍ (امام الحرمين)[332] ហើយថ្មីនេះ ស្ហៃខ៍ មូហ្ហាំម៉ាដ់ អ៊ុប់ឌុះហ្វ៍ (محمد عبده) ជាដើម បានបដិសេធការបកស្រាយនេះនៅក្នុងសៀវភៅលោកស្តីអំពីតៅហ៊ីដ្ធ ហើយទទួលយកការបកស្រាយទីមួយវិញ ។

## ៣. តៅហ៊ីដ្ធរៀបចំ (تدبير)

សព្វសារពើដែលត្រូវបង្កើតមក ជាកម្មសិទ្ធិដាច់មុខរបស់អល់ឡោះហ្វ៍ﷻ រីឯការរៀបចំសណ្តាប់ធ្នាប់របស់សត្វលោក ក៏ជាកម្មសិទ្ធិរបស់ព្រះអង្គﷻ ដែរ ។ នៅក្នុងលោកមានតែព្រះអ្នករៀបចំមួយគត់ ភ័ស្តុតាងតែមួយដែលបញ្ជាក់រឿងតៅហ៊ីដ្ធឥទ្ធិពលបង្កបង្កើតនោះ ក៏បញ្ជាក់រឿងតៅហ៊ីដ្ធរៀបចំដែរ ។

អាយ៉ាស់គួរអានច្រើនចែងថា អល់ឡោះហ្វ៍ﷻតែមួយគត់ជាអ្នករៀបចំលោក គឺ៖

قُلۡ أَغَيۡرَ ٱللَّهِ أَبۡغِي رَبّٗا وَهُوَ رَبُّ كُلِّ شَيۡءٖۚ

*"ចូរអ្នកថ្លែងថា៖ "តើខ្ញុំនឹងបួងសួងម្ចាស់ផ្សេងពីអល់ឡោះហ្វ៍ឬ ថ្វីបើព្រះអង្គជាព្រះម្ចាស់សព្វសារពើ ?" ៦:១៦៤ ។"*[333]

វិធីបកស្រាយទាំងពីរ ក្នុងការបកស្រាយតៅហ៊ីដ្ធឥទ្ធិពលបង្កបង្កើតនោះ ត្រូវប្រើសម្រាប់បកស្រាយតៅហ៊ីដ្ធរៀបចំដែរ ។ យើងយល់ឃើញថា ខ្លឹមបសាររបស់តៅហ៊ីដ្ធរៀបចំនោះ ក៏ជាកម្មសិទ្ធិដាច់មុខរបស់អល់ឡោះហ្វ៍ﷻដែរ ។

[332] សូមមើលសៀវភៅរបស់លោក ស្ហាស្ថ៍រីសតានី (الشهرستاني) *អាល់-មីឡាល់ វ៉ា អាន់-ណាហ្ហាល់ (الملل و النحل)* ដុំទី ១ ។

[333] សូរ៉ោះត៍ អាល់-អាន់អ៊ុំ 6:164 ។



សូមអល់ឡោះហ៍ប្រទានពរជ័យសិរីសួស្តីដល់មូហ្ហាំម៉ាដ់ និងព្រះរាជកុលដ្ឋានបរិសុទ្ធរបស់ព្រះអង្គដែលបានរងទុក្ខវេទនាដ៏ឈឺចាប់ ។ ព្រះអង្គបានធ្វើដូច្នោះ ដើម្បីនាំមនុស្សជាតិទៅកាន់សេចក្តីសប្បាយរីករាយឥតអវសាន និងទៅរកការបម្រើអល់ឡោះហ៍តាអ៊ាឡាដោយវិធីល្អប្រសើរបំផុត ។

នៅទីបញ្ចប់ យើងខ្ញុំសូមបួងសួងអល់ឡោះហ៍តាអ៊ាឡា សូមឲ្យយើងខ្ញុំបាននៅលើមាគ៌ាជោគជ័យ សូមឲ្យគោលបំណងរបស់យើងខ្ញុំជាគោលបំណងបរិសុទ្ធចំពោះព្រះអង្គ ។ ពិតណាស់ព្រះអង្គជាប្រភពនៃជោគជ័យ និងគ្រោះល្អ ។

ថ្ងៃទី ០១/០៨/២០១៩
ប៊ិន សាអ៊ីដ្ធ

# សំណួរ ១ - មួយណាត្រឹមត្រូវ "វ៉ា អ៊ីតរ៉ទី (وعترتي សន្តតិវង្សខ្ញុំ)" ឬ "វ៉ា ស៊ុនណាទី (وسنتي ប្រពៃណីខ្ញុំ/ស៊ូណាស្ញខ្ញុំ)" ?

អស់លោកអ្នកជំនាញហាឌីស្ហ (មូហាដ់ឌីស្ហីន) បានវាយការណ៍ហាឌីស្ហអាស្ស៊-ស្ហាក្ក៏ឡែន៍ (ហាឌីស្ហស្តីអំពីវត្ថុសំខាន់ពីរ) ពីរបែបដែលបានកត់ត្រាទុកនៅក្នុងតម្រាហាឌីស្ហ ។ ដើម្បីនឹងដឹងថាមួយណាខុស មួយណាត្រូវនោះ តម្រូវឲ្យមានការវិភាគមើល ។

១. "كتاب الله و عترتی اهل بیتی គីតាប អល់ឡោះហ្វ៎ វ៉ា អ៊ីតរ៉ទី អាស្ហ៊ុឡា បៃទី" (ព្រះគម្ពីររបស់អល់ឡោះហ្វ៎ﷻនិងសន្តតិវង្សរបស់ខ្ញុំ ព្រះរាជកុលដ្ឋានរបស់ខ្ញុំ) ឬ

២. "كتاب الله و سنتي គីតាប អល់ឡោះហ្វ៎ វ៉ា ស៊ុនណាទី" (ព្រះគម្ពីររបស់អល់ឡោះហ្វ៎និងស៊ុនណាស្ញរបស់ខ្ញុំ/ប្រពៃណីខ្ញុំ) ។

## ចម្លើយ

ហាឌីស្ហត្រឹមត្រូវពិតប្រាកដ (ស្ហ៊ហ៊ិះហ្វ៎) និងមានអំណះអំណាង របស់ព្រះសាស្តាﷺនោះ គឺ ហាឌីស្ហដែលឃ្លា "វ៉ា អាស្ហ៊ុឡា បៃទី" (ព្រះរាជកុលដ្ឋានរបស់ខ្ញុំ) ។ បណ្តាញថ្លែងព័ត៌មានបន្តបន្ទាប់ (សាណាដ់) របស់ការតំណាលហាឌីស្ហនេះដែលមានឃ្លា "ស៊ុនណាទី" (ស៊ូណាស្ញរបស់ខ្ញុំ) ជួស "អាស្ហ៊ុឡា បៃទី" (ព្រះរាជកុលដ្ឋានរបស់ខ្ញុំ) នោះ ជាមោឃៈ ដូច្នេះត្រូវច្រានចោល (ម៉ាឌូដ្ហ مردود) ។ ដូច្នេះ បណ្តាញថ្លែង ព័ត៌មានហាឌីស្ហដែលមានឃ្លា "វ៉ា អាស្ហ៊ុឡា បៃទី" ជាបណ្តាញថ្លែងព័ត៌មានត្រឹមត្រូវ

សាសនាទំទាស់ទេ ។ តែត្រូវបញ្ជាក់ថាតៅហ្វ៊ីដ្ហទាក់ទងនឹងសព្វសារពើដែលត្រូវបង្កើតមកនោះមានន័យពីរគឺ៖

ក. សាហេតុទាំងអស់ដែលមានរវាងសត្វលោកទាំងឡាយនោះ ចេញមកសាហេតុដើម គឺសាហេតុរបស់សាហេតុទាំងអស់ ។ ការពិត ព្រះដែលមិនចូលចំណុះគេ ព្រះអ្នកបង្កើតសព្វសារពើ គឺអល់ឡោះហ្វ៎ﷻ ។ សាហេតុដែលកើតមកពីអ្វីផ្សេងពីអល់ឡោះហ្វ៎ﷻ លើអ្វីដែលកើតឡើងនោះ កើតមកពីអល់ឡោះហ្វ៎ﷻ ដោយសារការអនុញ្ញាតនិងចំណង់របស់អល់ឡោះហ្វ៎ﷻ ។

ទាក់ទងនឹងទ្រឹស្តីនេះ មានប្រព័ន្ធទំនាក់ទំនងហេតុនិងផលនៅក្នុងលោកនេះដែលវិទ្យាសាស្ត្របានបំភ្លឺ ។ ក៏ប៉ុន្តែ ប្រព័ន្ធនេះទាំងមូលអាស្រ័យលើអល់ឡោះហ្វ៎ﷻមួយគត់ ព្រះអង្គﷻជាអ្នកធ្វើឲ្យប្រព័ន្ធនេះកើតមានឡើង ព្រះអង្គﷻជាអ្នកបង្កសាហេតុនិងផល ។

ខ. មានព្រះអ្នកបង្កើតតែមួយគត់ក្នុងលោក គឺអល់ឡោះហ្វ៎ﷻ ។ អល់ឡោះហ្វ៎ﷻជាសាហេតុដើមបង្អស់ នៃហេតុទាំងឡាយដែលកើតមានឡើង រីឯឥទ្ធិពលរបស់មនុស្សពុំមានលទ្ធផលទៅលើទង្វើព្រះអង្គﷻ ឡើយ ។
អាស្រ័យហេតុនេះ យើងមានតែសាហេតុមួយគត់នៅក្នុងលោកដែលផ្លាស់សព្វសារពើដែលវិទ្យាសាស្ត្រហៅថាមូលហេតុធម្មជាតិ ។

ការបកស្រាយតៅហ្វ៊ីដ្ហឥទ្ធិពលបង្កបង្កើតនេះ ជាការបកស្រាយរបស់អស់លោកអ្នកប្រាជ្ញអាស្ហ៊អារីមួយក្រុម តែអស់លោកដ៏ល្បីដូចជា អ៊ីម៉ាំ អាល់-

ឋានៈរបស់ព្រះជាទីចាំបាច់បំផុតទេ (ពោលគឺ ដែលគេត្រូវការផតចៀសបាន) ។

## ២. តៅហ៊ីដឥទ្ធិពលបង្កបង្កើត (خلقية)

តៅហ៊ីដឥទ្ធិពលបង្កបង្កើតជាលំដាប់ថ្នាក់មួយក្នុងតៅហ៊ីដ ដែលសតិប្រាជ្ញាទទួលយកបាន ហើយដែលគេបង្ហាត់បង្រៀននៅក្នុងទំនៀមទម្លាប់ ។

យោលតាមទ្រឹស្តីសតិប្រាជ្ញា សព្វសារពើផ្សេងពីអល់ឡោះហ្វ៍ﷻនៅក្នុងចំពូកមួយដែលគ្មានសុក្រឹតភាព គ្មានប្រណិតភាព ។ សព្វសារពើមានដើមកំណើតចេញមកពីប្រភពនៃព្រះគុណរបស់ព្រះ ដ៏មានព្រះហឫទ័យទូលំទូលាយដែលមានសារៈសំខាន់បំផុត ។ អាស្រ័យហេតុនេះ សុក្រឹតភាពនិងប្រណិតភាព ដែលយើងមើលឃើញក្នុងលោកនេះជាកម្មសិទ្ធិរបស់ព្រះអង្គﷻ ។

អាយ៉ាស់គួរអានច្រើនស្តីអំពីតៅហ៊ីដឥទ្ធិពលបង្កបង្កើត ។ យើងសូមលើកអាយ៉ាស់ទាំងនេះមកបង្ហាញជូន គឺៈ

قُلِ ٱللَّهُ خَٰلِقُ كُلِّ شَيۡءٖ وَهُوَ ٱلۡوَٰحِدُ ٱلۡقَهَّٰرُ

*"ចូរអ្នកថ្លែងថាៈ "អល់ឡោះហ្វ៍ជាអ្នកបង្កើតសព្វសារពើ (អ្វីដែលមាននៅលើមេឃនិងផែនដីនិងក្នុងចន្លោះទាំងពីរនោះ) ។ ព្រះអង្គគឺព្រះតែមួយគត់ ព្រះអង្គជាព្រះគ្រប់គ្រងជាធំបំផុត ១៣:១៦ ។"*[331]

ដូច្នេះ រឿងតៅហ៊ីដឥទ្ធិពលបង្កបង្កើត ជាទូទៅ មិនត្រូវពួកអ្នកប្រាជ្ញខាង

[331] ស៊ូរ៉ោះត៍ អារ-រ៉ក់ដ៍ 13:16 ។



ណាស់ ។

## -បណ្តាញថ្លែងព័ត៌មានរបស់ពាក្យ "វ៉ា អាហ្ល់ឡា បៃទី" (ព្រះរាជកុលដ្ឋានរបស់ខ្ញុំ)

លោកអ្នកជំនាញហាឌីស្ទដ៏ល្បីពីររូបបានថ្លែងអត្ថបទនេះគឺៈ

១. នៅក្នុងស្ហ៊ីហ៊ុះហ្វ៍របស់លោក លោកមុស្លីមបានតំណាលតមកពីស៊ៃដ៍ អ៊ីបនូ អាល់-អារក្ខំ ថាៈ "ថ្ងៃមួយ រ៉ស៊ូលុលឡោះហ្វ៍ﷺបានឈរសម្តែងធម៌នៅក្បែរត្រពាំងទឹកមួយដែលគេហៅថា *ឃុម* នៅត្រង់ចន្លោះម៉ាក់កាស់និងម៉ាឌីណាស់ ។ នៅក្នុងធម្មទេសនានោះ ព្រះអង្គﷺបានលើកតម្កើងអល់ឡោះហ្វ៍ﷻ បានដាស់តឿនមនុស្ស រួចហើយព្រះអង្គﷺមានព្រះវចនៈថាៈ

«ألا أيها الناس، فانّما أَنا بشرٌ يوشك أن يأتي رسول ربّي فأجيب، وأنا تارك فيكم ثقلين: أولهما كتاب الله فيه الهدى والنور، فخذوا بكتاب الله واستمسكوا به – فحثَّ على كتاب الله و رغَّب فيه ثم قال: – وأهل بيتي، أذكركم الله في أهل بيتي، أذكركم الله في اهل بيتي، أذكركم الله في اهل بيتي»

*"ប្រជារាស្ត្រអើយ ខ្ញុំជាមនុស្ស ។ អ្នកនាំសារពីព្រះម្ចាស់ខ្ញុំ (គឺទេវតាយកព្រលឹង) នឹងមកជួបខ្ញុំ ដើម្បីឆ្លើយតបការកោះហៅរបស់អល់ឡោះហ្វ៍ﷻ [ខ្ញុំសូមលាអស់លោក] តែខ្ញុំទុកឲ្យអស់លោកនូវវត្ថុសំខាន់ពីរគឺៈ មួយគឺព្រះគម្ពីរអល់ឡោះហ្វ៍ﷻ នៅក្នុងព្រះគម្ពីរនោះមានការដឹកនាំល្អនឹងពន្លឺរស្មី ដូច្នេះចូរអស់លោកកាន់ព្រះគម្ពីរអល់ឡោះហ្វ៍ﷻឲ្យជាប់ ហើយចូរអស់លោកអនុវត្តិតាមព្រះគម្ពីរនោះ ។" ព្រះអង្គﷺបានផ្តាំ[យើងឲ្យកាន់] ព្រះគម្ពីរអល់ឡោះហ្វ៍ﷻ[ឲ្យជាប់] ហើយព្រះអង្គﷺមានព្រះវចនៈថាៈ "វត្ថុទីពីរគឺសមាជិកនៃគ្រួសារខ្ញុំ (គឺព្រះរាជកុលដ្ឋានរបស់ខ្ញុំ) ។ ខ្ញុំសូមរំលឹកអស់លោក [អំពីករណីយកិច្ចដែលអស់លោកត្រូវធ្វើ]ចំពោះ*

*សមាជិកនៃគ្រួសារខ្ញុំ ។ ខ្ញុំសូមរំលឹកអស់លោក[អំពីករណីយកិច្ចដែលអស់លោកត្រូវធ្វើ]ចំពោះសមាជិកនៃគ្រួសារខ្ញុំ ។ ខ្ញុំសូមរំលឹកអស់លោក [អំពីករណីយកិច្ចដែលអស់លោកត្រូវធ្វើ]ចំពោះសមាជិកនៃគ្រួសារខ្ញុំ ។[1] "*

លោក ដារ៉ាមី (الدارمي) ក៏បានតំណាលអត្ថបទនេះដែរនៅក្នុង *ស៊ូណាន់* របស់លោក[2] ។ ចាំបាច់ត្រូវតែថា បណ្ដាញថ្លែងព័ត៌មានបន្តបន្ទាប់របស់អត្ថបទទាំងពីរច្បាស់ដូចពន្លឺថ្ងៃ ពុំមានអ្វីគួរឲ្យសង្ស័យទេ ។

២. នៅក្នុងសេចក្ដីថ្លែងការណ៍របស់លោកដែលមានឃ្លា "បណ្ដាកូនចៅខ្ញុំ ព្រះរាជកុលដ្ឋានខ្ញុំ" (វ៉ា អ៊ីតរ៉ាទី អាស្ហ្លា បៃទី) លោក តៀរមីស៊ី បាន សរសេរថាព្រះសាស្ដាﷺមានព្រះវចនៈថា៖

"إني تارك فيكم ما ان تمسكتم به لن تضلوا بعدي ، أحدهما أعظم من الأخر: كتاب الله حبل ممدود من السماء إلى والأرض عترتي أهل بيتي لن يفتقا حتى يردا عليَّ الحوض فانظروا كيف تخلفوني فيها."

*"ការពិត ខ្ញុំទុកឲ្យអស់លោកនូវវត្ថុសំខាន់ពីរ បើអស់លោកកាន់វត្ថុទាំងពីរនេះជាប់ អស់លោកនឹងមិនវង្វេងជាដាច់ខាត ។ មួយសំខាន់ជាងមួយទៀតគឺ៖ ព្រះគម្ពីរអល់ឡោះហ្ទ៍ﷻដែលជាខ្សែចងពឹងពីមេឃមកដី និង សន្តតិវង្សខ្ញុំ ព្រះរាជកុលដ្ឋានខ្ញុំ ។ ទាំងពីរនេះមិនបែកចេញពីគ្នាជាដាច់ខាត លុះពួកគេបានមកជួបខ្ញុំនៅឯស្រះ (ហៅដ្ហ៍ الحوض) [នៃអាល់-*

[1] សូមមើល *ស្ហ៍ហ៊ិះហ្ទ៍ មុស្លីម* ជុំទី ៤ ទំព័រ ១៨០៣ ហាឌីស្សលេខ ២៤០៨ (បោះពុម្ពដោយ អ៊ុប់ដ្ហាល់-បាគ្គី) ។ សូមមើល *ស្ហ៍ហ៊ិះហ្ទ៍ មុស្លីម* (ប្រែជាភាសាអង់គ្លេស) របស់លោក អ៊ុប់ឌុល ហាមីដ ស៊ីឌីគ្គី ជុំទី ៤ ហាឌីស្សលេខ ៥៩២០ ។

[2] សូមមើលសៀវភៅ ស៊ូណាន់ អាល់-ដារ៉ាមី (سنن الدارمي) ជុំទី ២ ទំព័រ ៤៣១-៤៣២ ។



សាសនា (មូតាកាល់លីមូន) គឺ "វ៉ាយីប អាល់-វូយ៉ូដ (واجِبُ الوجود)" (មានន័យថា បុគ្គលចាំបាច់បំផុត) គឺព្រះដែលមានតែព្រះអង្គﷻមួយគត់ ព្រះអង្គﷻមិនមានដៃគូទេ ពុំមានអ្វីដូចព្រះអង្គﷻឡើយ ។ នេះគឺតៅហ៊ីដដូចអល់ឡោះហ្ទ៍ﷻមានព្រះបន្ទូលនៅក្នុងព្រះមហាគម្ពីរគួរអាន គឺ៖

لَيْسَ كَمِثْلِهِۦ شَىْءٌۭ

*"ពុំមានអ្វីដូចព្រះអង្គឡើយ ៤២:១១ ។"*[328]

وَلَمْ يَكُن لَّهُۥ كُفُوًا أَحَدٌۢ

*"ពុំមានអ្វី [សព្វសត្វដែលមាននៅលើមេឃទាំងឡាយ នៅលើផែនដី និង នៅក្នុងចន្លោះទាំងពីរនោះ] ដូចព្រះអង្គឡើយ ១១២:៤ ។"*[329]

*តៅហ៊ីដ* នេះ បកស្រាយក្នុងន័យតៅហ៊ីដរាប់ចំនួន ពោលគឺ អល់ឡោះហ្ទ៍ គឺព្រះតែមួយ មិនមានព្រះពីរទេ បែបនេះនោះ មិនសក្តិសមនឹងឋានៈរបស់ព្រះជាធំបំផុតទេ ។

ខ. ព្រះសារធាតុរបស់អល់ឡោះហ្ទ៍ﷻគឺជាសូនតែមួយ មិនចម្រុះលាយឡំទេ ពីព្រោះ ប្រសិនបើអត្ថិភាពណាមួយចម្រុះដោយប៉ែកក្រៅនិងប៉ែកក្នុង បានសេចក្ដីថាអត្ថិភាពនោះត្រូវការប៉ែកទាំងនោះ ហើយ "ត្រូវការ" សំដៅទៅរក "លទ្ធភាព (គឺអាចប្រព្រឹត្តទៅបាន)" ហើយលទ្ធភាពមានន័យថាត្រូវតែមានមូលហេតុ (عِلَّة)[330] ដូច្នេះ អ្វីៗទាំងនេះមិនសមស្របនឹង

[328] ស៊ូរ៉ោះគ្ន៍ អាស្ហ៍-ស៊ូរ៉ 42:11 ។

[329] ស៊ូរ៉ោះគ្ន៍ អាល់-អ៊ីខ្លាស្ហ៍ 112:4 ។

[330] នៅក្នុងភាសាទស្សនវិជ្ជា អ្វីៗដែលអាចកើតឡើងបាន (ممكن មុមគីន) នោះជាលទ្ធផល ហើយត្រូវតែមានមូលហេតុ ។ ក្នុងភាសាអ្នកប្រាជ្ញខាងសាសនា អ្វីៗដែលត្រូវបង្កើតក្នុងពេលវេលានោះជាលទ្ធផល ហើយវាត្រូវតែមានមូលហេតុ ។

وَعَلَّمَهُۥ مِمَّا يَشَآءُۗ

*"ពួកគេបានវាយបាក់ទ័ពពួកនោះ អាស្រ័យការអនុញ្ញាតរបស់អល់ឡោះហ៍ ។ ដាវុដបានសម្លាប់យ៉ាលូត ។ អល់ឡោះហ៍បានប្រទានអំណាចគ្រងរាជ្យនិងប្រាជ្ញាញាណឲ្យគេ ព្រះអង្គបានបង្រៀនគេនូវអ្វីដែលព្រះអង្គមានព្រះបំណង ២:២៥១ ។"*[327]

## សំណួរ ៣៦ - តើអាចវែកញែកតៅហ៊ីដដាច់ឡែកពីស៊ីរិកបានដូចម្ដេច ?

## ចម្លើយ

សំខាន់បំផុតក្នុងការសិក្សាតៅហ៊ីដនិងស៊ីរិក គឺការស្គាល់លក្ខណ:វិនិច្ឆ័យឲ្យដឹងច្បាស់ថាអ្វីគឺតៅហ៊ីដ អ្វីគឺស៊ីរិក ពីព្រោះ បើពុំបានដោះស្រាយបញ្ហាដ៏សំខាន់នេះជាមុនសិនទេ នឹងពុំអាចដោះស្រាយរឿងនានាដែលពាក់ព័ន្ធនឹងលក្ខណ:វិនិច្ឆ័យបានដែរឡើយ ។ យើងនឹងអធិប្បាយ *តៅហ៊ីដ* និង *ស៊ីរិក* ក្នុងអត្ថន័យផ្សេង តែខ្លីៗ ។

### ១. តៅហ៊ីដសំខាន់បំផុត (تاذ)

តៅហ៊ីដសំហាន់បំផុតគឺ៖

ក. អល់ឡោះហ៍عز وجل យោលតាមសម្ដីរបស់អស់លោកអ្នកប្រាជ្ញខាង

[327] ស៊ូរ៉ោះត៍ អាល់-បាក៏រ៉ោះត៍ 2:251 ។



*កៅស្សារ] ។ ចូរអស់លោកប្រយ័តខ្លួនក្នុងការប្រព្រឹត្តចំពោះពួកគេ ពេលអត់ពីខ្ញុំទៅ ។"*[3]

លោក មុស្លីម និង លោក តៀរមីស៊ី ដែលនៅក្នុងចំណោមអស់លោកអ្នកចងក្រង *ស្វ៏ហ៊ិះហ៍* និង *ស៊ូណាន់* (ការរៀបចំចងក្រងហាឌីស្សដែលអាស្ស់លុល-ស៊ុនណាស្ស់ចាត់ទុកថា ជាហាឌីស្សពិតមិនក្លែងក្លាយនោះ) ធ្វើឲ្យឃ្លា *"អាស្ស់ឡាល់-បៃត៍"* លេចក្រឡែតឡើង ហើយភ័ស្ដុតាងនេះគាំទ្រមតិយើង ចំណែកឯបណ្ដាញថ្លែងបន្តហាឌីស្សទាំងពីរនេះប្រកបដោយការទៀងត្រង់និងទំនុកចិត្តខ្ពស់ណាស់ មិនចាំបាច់ត្រូវពិភាក្សាវែកញែកនិងរកពាក្យសំអាងទេ ។

## -បណ្ដាញថ្លែងព័ត៌មានរបស់ពាក្យ "វ៉ា ស៊ុនណាទី" (ស៊ុនណាស្ស់របស់ខ្ញុំ/ប្រពៃណីរបស់ខ្ញុំ)

ហាឌីស្សដែលនិយាយពីឃ្លា *"ស៊ុនណាទី"* (ស៊ុនណាស្ស់ខ្ញុំ/ប្រពៃណីខ្ញុំ) ជួសឃ្លា *"អាស្ស់ឡា បៃតី"* (ព្រះរាជកុលដ្ឋានរបស់ខ្ញុំ) ជាហាឌីស្សប្រឌិតដែលមានបណ្ដាញព័ត៌មានថ្លែងបន្តខ្សោយ ថែមទាំងត្រូវបានលាយផ្សំប្រឌិតឡើង ហើយត្រូវបានផ្សាយបន្តដោយពួកភ្នាក់ងារអ៊ូម៉ៃយ៉ាស្ស់ គឺ៖

១. នៅក្នុង *មុសតាដ្រ៉ក់* (المستدرك على الصحيحين អាល់-មុសតាដ្រ៉ក់ អាុឡាស្ស់-ស្វ៏លីហ៊ីន) របស់លោក លោក អាល់-ហាគីម អាល់-ណៃស្សាប៊ូរី (الحاكم النيسابوري) បានថ្លែងសេចក្ដីរាយការណ៍នេះតាមបណ្ដាញថ្លែង

[3] សូមមើល *ស៊ូណាន់ អាល់-តៀរមីស៊ី* ជុំទី ៥ ទំព័រ ៦៦៣ ហាឌីស្សលេខ ៣៧៧៨៨ ។

ព័ត៌មានបន្តដូចតទៅគឺ៖

عباس عن بن أبي أويس عن ابي اويس عن ثور بن زيد الدّيلمي عن عكمة عن ابن عباس قال رسول الله: "يا أيها الناس إني قد تركت فيكم ان اعتصمتم به فلن تضلّوا أبداً كتاب الله وسنّة نبيّه."

*"អ៊ុាប់បាស់ អ៊ីបនូ អាប៊ី អូវ៉ៃស៍ បានតំណាលតមកពីអាប៊ី អូវ៉ៃស៍ តមកពី ស្ហៅរី អ៊ីបនូ ស៊ីយ៉ាដ្ឋ អាដ្ឋ-ដៃឡាមី តមកពី អ៊ីក្រូម៉ាស់ តមកពី អ៊ីបនូ អ៊ុាប់បាស់ ថារ៉ស៊ូលុលឡោះហ្ញ៍ﷺមានព្រះវចនៈថា៖ "ប្រជារាស្ត្រអើយ ខ្ញុំ ទុកឲ្យអស់លោកនូវវត្ថុពីរ បើអស់លោកកាន់វត្ថុទាំងពីរនេះឲ្យជាប់ អស់លោកនឹងមិនវង្វេងជាដាច់ខាត គឺ៖ ព្រះគម្ពីរអល់ឡោះហ្ញ៍ﷻនិង ស៊ុនណាស់ (គឺប្រពៃណី) របស់ព្រះសាស្តាព្រះអង្គﷻ ។"*[4]

អ្នកថ្លែងបន្តអត្ថបទរាយការណ៍នេះគឺលោក អ៊ីសម៉ាអ៊ីល អ៊ីបនូ អាប៊ី អូវ៉ៃស៍ និងលោក អាប៊ូ អូវ៉ៃស៍ - ឪពុកនិងកូនដែលគេពុំឃើញថាជាបុគ្គលដែលអាចទុកចិត្តបានទេ ហើយអស់លោកទាំងពីរនាក់នេះត្រូវគេចោទថានិយាយកុហក ប្រឌិតការឡៃនិងក្លែងបន្លំ ។

## -មតិរបស់ អ៊ុឡាម៉ាអ៍ អាល់-រីយ៉ាល់ អំពីការបកស្រាយទាំងពីរនេះ

[4] សូមមើលសៀវភៅរបស់លោក អាល់-ហាគីម អាល់-ណៃសាបូរី *មុសតាដ្ឋរ៉ក់ (المستدرك على الصحيحين អាល់-មុសតាដ្ឋរ៉ក់ អ៊ុាឡាស្ង-ស្វ៉លីហ៊ីន)* ជុំទី ១ ទំព័រ ៩៣ ។



កូនចៅអ៊ីសរ៉អ៊ីលនៅក្នុង *ឃ្ញីហ្វាដ្ឋ* លើមាគ៌ាអល់ឡោះហ្ញ៍ﷻក៏ដោយ ព្រះឋានៈរបស់ត៉ុល្វតអនុញ្ញាតឲ្យព្រះអង្គធ្វើអ្វីច្រើនទៀតបាន ដែលទាក់ទងនឹងការកាន់អំណាចគ្រប់គ្រងទាំងស្រុង ដូចប៉ែកចុងក្រោយនៃអាយ៉ាស់ថែងថា៖

وَٱللَّهُ يُؤۡتِي مُلۡكَهُۥ مَن يَشَآءُۚ

*"អល់ឡោះហ្ញ៍មានព្រះបំណងប្រទានអំណាចគ្រងរាជ្យ ឲ្យទៅបុគ្គលណាមួយស្រេចតែលើព្រះអង្គ ។"*

៤. លក្ខខណ្ឌសំខាន់បំផុតក្នុងការទទួលឋានៈអ៊ីម៉ាម៉ាស់នោះ គឺញាណបារមី (គឺការចេះដឹងសព្វគ្រប់) សមត្ថភាពផ្លូវកាយនិងផ្លូវចិត្ត ជាពិសេសសម្រាប់អភិបាលគ្រប់គ្រងក្នុងសម័យនោះ ដែលត្រូវដឹកនាំកងទ័ពក្នុងសមរភូមិ ។[326]

យើងឃើញច្បាស់ថាមានភាពដាច់ឡែកគ្នារវាង *នូប៊ូវ៉ាស់* និង *អ៊ីម៉ាម៉ាស់* ។ ការពិត បុគ្គលអាចបានដល់ឋានៈ *នូប៊ូវ៉ាស់* ដោយពុំមែនជាអ៊ីម៉ាំអភិបាលដឹកនាំអ៊ូមម៉ាត់ ។

ដូចនេះដែរ អល់ឡោះហ្ញ៍ﷻអាចជ្រើសរើសបុគ្គលសម្រាប់ដឹកនាំសហាគមន៍ តែបុគ្គលនោះពុំមែនសាស្តាទេ ។ ជួនកាល អល់ឡោះហ្ញ៍ﷻ ទ្រង់ព្រះរាជទានឋានៈទាំងពីរនេះ ឲ្យទៅបុគ្គលណាមួយដែលមានសមត្ថភាពទទួលយកបាន ។ គួរអានថែងអំពីរឿងនេះថា៖

فَهَزَمُوهُم بِإِذۡنِ ٱللَّهِ وَقَتَلَ دَاوُۥدُ جَالُوتَ وَءَاتَىٰهُ ٱللَّهُ ٱلۡمُلۡكَ وَٱلۡحِكۡمَةَ

[326] ដកស្រង់ពីសៀវភៅរបស់បណ្ឌិត យ៉ាកុំហ្វារ ស៊ុបហានី *ម៉ាន់ស្ហ៊រ អាល់-យ៉ាវីដ អាល់-គួរអាន* (ច្បាប់អមតៈរបស់គួរអាន) ។

១. យើងអាចនិយាយបានថា ឋានៈនូប៊ូវ៉ាស៊្ញដាច់ឡែកពីឋានៈអ៊ីម៉ាម៉ាស៊្ញ និងពីតំណែងគ្រប់គ្រង ហើយឋានៈនូប៊ូវ៉ាស៊្ញជាមុខងាររបស់សាស្តា រីឯអំណាចជាមុខងាររបស់បុគ្គលម្នាក់ទៀត ដែលមានសមត្ថភាពគ្រប់គ្រាន់សម្រាប់បំពេញមុខងារនេះ ។

បណ្តាកូនចៅអ៊ីសរ៉អ៊ីលមិនដែលប្រកែកឡើយ ថាព្រះសាស្តារបស់ពួកគេមានសមត្ថភាពជាងត៉ាលូត ។ ផ្ទុយទៅវិញ ពួកគេបានប្រកែកថាខ្លួនពួកគេទេដែលមានសមត្ថភាពជាងត៉ាលូតនោះ គឺ៖ *"ពួកយើងមានសិទ្ធិជាងគេនោះទៅទៀតក្នុងការគ្រងរាជ្យ ។"*

២. ឋានៈដែលត៉ាលូតមាននោះ អល់ឡោះហ្ ﷻជាអ្នកប្រទានឲ្យ ដូចមានចែងនៅក្នុងគួរអានថា៖

إِنَّ اللَّه قَدْ بَعَثَ لَكُمْ طَالُوتَ مَلِكًا

*"អល់ឡោះហ្ បានជ្រើសរើសត៉ាលូត ជាក្សត្រិយ៍គ្រប់គ្រងអស់លោក ។"*

គួរអានចែងទៀតថា៖

إِنَّ ٱللَّهَ ٱصۡطَفَىٰهُ عَلَيۡكُمۡ

*"ការពិត អល់ឡោះហ្ បានជ្រើសរើសគេជាជាងអស់លោក ។"*

៣. ព្រះឋានន្តរសក្តិ និងមុខងាររបស់ត៉ាលូតមិនត្រឹមតែបញ្ជាកងទ័ពប៉ុណ្ណោះទេ តែព្រះអង្គជាអភិបាលគ្រប់គ្រងនិងដឹកនាំបណ្តាកូនចៅអ៊ីសរ៉អ៊ីលទៀតផង ព្រោះអល់ឡោះហ្ ﷻមានព្រះបន្ទូលថា៖ "مَلِكًا" (ស្តេច) ពោលគឺ អភិបាលដឹកនាំនិងអ្នកកាន់អំណាច ។

ទោះជាគោលការណ៍របស់អភិបាលដឹកនាំសម័យនោះ គឺការដឹកនាំបណ្តា



នៅក្នុង តាស់ស៊ីប អាល់-កាម៉ាល់ (تَهْذِيب الكَمَال) លោក ហាហ្វីស្ស[5] អាល់-មីស៊ី អ្នកស្រាវជ្រាវវិទ្យាសាស្ត្រ *អាល់-រីយ៉ាល់ (الرِّجَال)* [6] ម្នាក់ បានសរសេរអំពីលោក អ៊ីសម៉ាអ៊ីល និងឪពុកលោកដូចតទៅ គឺ៖

លោក យ៉ាស៊ុយ៉ា អ៊ីបនូ មូអ៊ីន (يحيى بن معين) *(អ៊ូឡាម៉ាអ៍ ជាន់ខ្ពស់ខាងអ៊ីលមូ អារ-រីយ៉ាល់)* មានប្រសាសន៍ថា៖ "អាប៊ូ អូវ៉ៃស៍និងកូនគាត់ (អ៊ីសម៉ាអ៊ីល) "ខ្សោយ" (ដ៏អ៊ីហ្វ ضعيف) ។" គេបានរាយការណ៍ទៀតថា លោក យ៉ាស៊ុយ៉ា អ៊ីបនូ មូអ៊ីនធ្លាប់តែនិយាយថា៖ "បុគ្គលទាំងពីររូបនេះធ្លាប់តែលួចហាឌីស្សគេ ។" លោក អ៊ីបនូ មូអ៊ីន បាននិយាយទៀតអំពីកូន (អ៊ីសម៉ាអ៊ីល) ថា៖ "គេមិនអាចជឿគាត់បានទេ ។"

ទាក់ទងនឹងកូន (អ៊ីសម៉ាអ៊ីល) លោក នីសាអ៊ី (النسائي) មានប្រសាសន៍ថា៖ "គាត់ "ខ្សោយ" មិនគួរឲ្យទុកចិត្តបានទេ ។"

លោក អាប៊ុល-ក៉ស៊ីម ឡាល់កាអ៊ី មានប្រសាសន៍ថា៖ "លោកនីសាអ៊ីបាននិយាយច្រើនដងថាគាត់មិនត្រឹមត្រូវទេ ហើយលោកបានបញ្ជាក់ថាត្រូវតែច្រានចោលសម្តីរបស់គាត់ ។"

លោក អ៊ុឌី *អ៊ូឡាម៉ាអ៍* ខាង *រីយ៉ាល់* មានប្រសាសន៍ថា៖ "អ៊ីបនូ អាប៊ីអូវ៉ៃស៍ ឪពុកមា (ឬឪពុកធំ) ខាងម្តាយរបស់ ម៉ាលិក រាយការណ៍ហាឌីស្ស

---

[5] ហាហ្វីស្ស មានន័យត្រង់ថា "អ្នកចង់ចាំ" ដែលគេប្រើសម្រាប់ហាឌីស្ស - ដូចជានៅក្នុងសៀវភៅនេះដែរ - ដើម្បីនិយាយអំពីលោកអ្នកប្រាជ្ញដែលមានការចងចាំប្រសើរបំផុត ហើយដែលបានចងចាំហាឌីស្សរត់មាត់យ៉ាងច្រើន ។

[6] រីយ៉ាល់ ឬ អ៊ីលមូ អារ-រីយ៉ាល់ ជាសាខាវិទ្យាសាស្ត្រមួយខាងហាឌីស្សដែលស្តីអំពីជីវប្រវត្តិរបស់អស់លោកអ្នកថ្លែងហាឌីស្សបន្ត ឬអ្នកសារព័ត៌មាន ។

ចម្លែកដែលពុំមានអ្នកណាទទួលយកទេ ។"[7]

នៅក្នុងអារម្ភកថាសៀវភៅ ហ្វាត់ហ៍ អាល់-បារី (فتح الباري) លោក អ៊ីបនូ ហាយ៉ារ (អាល់-អាស់ក៏ឡានី) មានប្រសាសន៍ថា៖ "គេមិនអាចសំអាងលើហាឌីស្សរបស់អ៊ីបនូ អាប៊ី អូវ៉ៃស៍បានជាដាច់ខាត ពីព្រោះលោកនីសាអ៊ីបានស្តីបន្ទោសគាត់យ៉ាងច្រើន ។"[8]

ក្នុងសៀវភៅ *ហ្វាត់ហ៍ អាល់-មុលក៍ អាល់-អាក់ឡា* ហាហ្វីស្ហ សៃយីដូ អាស់ម៉ាដ់ អ៊ីបនូ ស៊ិឌិក្ហ រាយការណ៍តមកពី សាល់ម៉ាស់ អ៊ីបនូ ស្វៃប៍ ថា៖ "គេបានឮអ៊ីសម៉ាអ៊ីល អ៊ីបនូ អាប៊ី អូវ៉ៃស៍និយាយថា៖ "ពេលណា ប្រជារាស្ត្រម៉ាឌីណាស់ទាស់គ្នាអំពីបញ្ហាណាមួយ ខ្ញុំប្រឌិតហាឌីស្សមួយឡើង ។"" [9]

ហេតុដូច្នេះ កូន (អ៊ីសម៉ាអ៊ីល អ៊ីបនូ អាប៊ី អូវ៉ៃស៍) ត្រូវគេចោទប្រកាន់ថាប្រឌិតហាឌីស្ស ហើយលោកអ៊ីបនូ មូអ៊ីនមានប្រសាសន៍ថាគាត់និយាយកុហក ។ លើសពីនេះទៀត សេចក្តីរាយការណ៍របស់គាត់មិនចេញមកពី *ស្វ៉ហ៊ិះហ៍ មុស្លីម* ទេ មិនចេញមកពី *ស៊ូណាន់ តៀរមីស៊ី* ឬតម្រា *ស្វ៉ហ៊ិះហ៍* ឯទៀតទេដែរ ។

---

[7] សូមមើលសៀវភៅរបស់លោក ហាហ្វីស្ហ អាល់-មីស៊ី *តាស់ស៊ីប អាល់-កាម៉ាល់ (تَهْذِيب الكَمال)* ជុំទី ៣ ទំព័រ ១២៧ ។

[8] សូមមើលសៀវភៅរបស់លោក អ៊ីបនូ ហាយ៉ារ *អារម្ភកថា ហ្វាត់ហ៍ អាល់-បារី (فتح الباري)* (បោះពុម្ពដោយបណ្ណាល័យ ដារ អាល់-ម៉ាក់រីហ្វាស់ دار المعرفة) ទំព័រ ៣៩១ ។

[9] សូមមើលសៀវភៅរបស់ ហាហ្វីស្ហ សៃយីដូ អាស់ម៉ាដ់ *ហ្វាត់ហ៍ អាល់-មុលក៍ អាល់-អាក់ឡា* ទំព័រ ១៥ ។



អល់ឡោះហ៍ﷻបានព្រះរាជទានឋានៈនូប៊ូវ៉ាស់ ឲ្យទៅបុរសម្នាក់ដែលមាននាមថា "ស៊ាំមូអ៊ីល صموئيل" ហើយបានព្រះរាជទានឋានៈអ៊ីម៉ាម៉ាស់ឲ្យទៅត៉ាលូត ។ នេះគឺសេចក្តីរាយការណ៍អំពីរឿងនេះ៖

ក្រោយពីព្រះសាស្តាមូសាﷺចូលទិវង្គត កូនចៅអ៊ីសរ៉ាអ៊ីលបានទូលព្រះសាស្តាសម័យពួកគេថា៖ "សូមព្រះអង្គជ្រើសរើសអ្នកដឹកនាំឲ្យអស់ទូលបង្គំផង ដើម្បីអស់ទូលបង្គំនឹងប្រយុទ្ធលើព្រះមាគ៌ាអល់ឡោះហ៍ﷻក្រោមបញ្ជាមេដឹកនាំ ។" ព្រះសាស្តារបស់ពួកគេបានតបថា៖

إِنَّ ٱللَّهَ قَدۡ بَعَثَ لَكُمۡ طَالُوتَ مَلِكٗاۚ قَالُوٓاْ أَنَّىٰ يَكُونُ لَهُ ٱلۡمُلۡكُ عَلَيۡنَا وَنَحۡنُ أَحَقُّ بِٱلۡمُلۡكِ مِنۡهُ وَلَمۡ يُؤۡتَ سَعَةٗ مِّنَ ٱلۡمَالِۚ قَالَ إِنَّ ٱللَّهَ ٱصۡطَفَىٰهُ عَلَيۡكُمۡ وَزَادَهُۥ بَسۡطَةٗ فِي ٱلۡعِلۡمِ وَٱلۡجِسۡمِۖ وَٱللَّهُ يُؤۡتِي مُلۡكَهُۥ مَن يَشَآءُۚ وَٱللَّهُ وَٰسِعٌ عَلِيمٞ

*"អល់ឡោះហ៍បានជ្រើសរើសត៉ាលូត ជាក្សត្រិយ៍គ្រប់គ្រងអស់លោក ។" ពួកគេបានថា៖ "គេអាចជាអ្នកគ្រប់គ្រងពួកយើងបានដូចម្តេចទៅ? ពួកយើងមានសិទ្ធិជាងគេនោះទៅទៀតក្នុងការគ្រងរាជ្យ រីឯគេនោះគ្មានទ្រព្យសម្បត្តិមាំទាំឡើយ!" គេ (គឺសាស្តាពួកគេ) បានថា៖ "ការពិតអល់ឡោះហ៍បានជ្រើសរើសគេជាជាងអស់លោក ។ ព្រះអង្គបានប្រទានឲ្យគេយ៉ាងសម្បើមនូវការចេះដឹងនិងរូបសម្បត្ត (គឺមានមាឌប្រសើរ) ។" អល់ឡោះហ៍មានព្រះបំណងប្រទានអំណាចគ្រងរាជ្យ ឲ្យទៅបុគ្គលណាមួយស្រេចតែលើព្រះអង្គ ។ អល់ឡោះហ៍មានព្រះហឫទ័យទូលំទូលាយ ព្រះអង្គទ្រង់ញាណសព្វសារពើ ២៖២៤៧ ។"*[325]

យើងអាចទាញយកបាននូវការសន្និដ្ឋានពីអាយ៉ាស់នេះ គឺ៖

---

[325] ស៊ូរ៉ោះត៍ អាល់-បាក៏រ៉ោះត៍ 2:247 ។

ពិតប្រាកដណាស់ មុខងារដ៏សំខាន់ថ្នាក់នេះតម្រូវឲ្យមានកម្លាំងស្មារតីដ៏ធំ និងសមត្ថភាពពិសេសពិសាលមហិមា ។ ដើម្បីបំពេញករណីយកិច្ចដ៏ធ្ងន់នេះដែលប្រកបដោយការលំបាកនិងឧបសគ្គជានិច្ច ព្រមទាំងការប្រយុទ្ធតទល់នឹងជំណង់ចិត្តឥតឈប់ឈរនោះ ត្រូវព្រមលះបង់លើមាគ៌ាអល់ឡោះហ្ ﷻ និងចេះអត់ធ្មត់ជាទីបំផុត ។ បើពុំមានសេចក្តីស្រឡាញ់អល់ឡោះហ្ ﷻ មិនចង់បានសេចក្តីគាប់ព្រះហឫទ័យព្រះអង្គ ﷻ ទេ ភារកិច្ចទាំងនេះពុំបានសម្រេចឡើយ ។

ហេតុដូច្នេះឯង បានជាអល់ឡោះហ្ ﷻ បានព្រះរាជទានឋានៈអ៊ីម៉ាម៉ាស់ឲ្យអ៊ីបរ៉ហ៊ីម ﷺ បន្ទាប់ពីបានល្បងពិសោធព្រះអង្គ ﷻ យ៉ាងតឹងរ៉ឹង ក្នុងពេលចុងក្រោយនៃជីវិតព្រះអង្គ ﷺ ។ ហេតុដូច្នេះឯងដែរ អល់ឡោះហ្ ﷻ បានផ្តល់កិត្តិយសដល់បាវប្រសើរបំផុតរបស់ព្រះអង្គ ﷻ ដូចជាព្រះសាស្តាអ៊ីស្លាម ﷺ ជាដើម ដោយព្រះរាជទានឋានៈអ៊ីម៉ាម៉ាស់និងការដឹកនាំអ៊ុមម៉ាត់ឲ្យព្រះអង្គទាំងនេះ ហើយបានជ្រើសរើសព្រះអង្គទាំងនេះជាអ្នកកាន់អំណាចនិងជាអ្នកគ្រប់គ្រងសហគមន៍ ។

## តើនូប៊ូវ៉ាស់និងអ៊ីម៉ាម៉ាស់មានទំនាក់ទំនងគ្នាទេ ?

តើគ្រប់សាស្តាដែលមានឋានៈនូប៊ូវ៉ាស់នោះ ត្រូវតែទៅជាអ៊ីម៉ាំផងដែរទេ ? ឬ តើបុគ្គលដែលមានឋានៈអ៊ីម៉ាម៉ាស់នោះ ត្រូវតែជាបុគ្គលដែលជាសាស្តាទេ ?

ចម្លើយសំណួរទាំងពីរគឺទេ ។ ដោយផ្អែកលើព្រះបន្ទូលដែលអល់ឡោះហ្ ﷻ បានបើកឲ្យដឹងនោះ យើងអធិប្បាយសំណួរទាំងនេះតាមរយៈអាយ៉ាស់ដែលត្រូវបានបើកឲ្យដឹងអំពីត៊្លូត និងអំពីការប្រយុទ្ធទល់នឹងយ៉ាលូតបុគ្គលកំណាច ។ ក្រោយពីព្រះសាស្តាមូសា ﷺ បានចូលទិវង្គត



ទាក់ទងនឹង អាប៊ូ អ៊ូវ៉ៃស៍ គ្រាន់តែនិយាយថាលោក អាប៊ូ ហ្ាតាំ អារ-រ៉ស៊ី សរសេរនៅក្នុងសៀវភៅលោក *អាល់-យ៉ារ៉ោះហ្ វ៉ាត់-តាក់ឌីល (الجرح والتعديل)* ថា៖ "អាចកត់ត្រាសេចក្តីរាយការណ៍របស់គាត់បាន តែមិនត្រូវ យកជាសំអាងទេ ហើយសេចក្តីរាយកាណ៍របស់គាត់មិនខ្លាំង (ក៏វី قوي) មិនមាំ (មុះហ្កាំ مُحكَم) ទេ" នោះគ្រប់គ្រាន់ណាស់ហើយ ។[10]

លោក អាប៊ូ ហ្ាតាំ ដែលមានប្រសាសន៍តមកពីលោក អ៊ីបនូ មូអ៊ីន នោះថា អាប៊ូ អ៊ូវ៉ៃស៍ មិនគួរឲ្យទុកចិត្តទេ ។

សេចក្តីរាយការណ៍មួយណាក៏ដោយ (រីវ៉ាយ៉ាស់ رِوَايَة) ដែលបុគ្គលណាមួយក្នុងចំណោមបុគ្គលទាំងពីររូបនេះរាយការណ៍នោះ មិនពិត (ស្វ៉ហ៊ិះហ្) ជាដាច់ខាត ។ លើសពីនេះ វាមិនស្របជាមួយសេចក្តីរាយការណ៍ពិតនិងត្រឹមត្រូវទេ ។

គប្បីកត់សម្គាល់ថាលោកអ្នកធ្វើសេចក្តីរាយការណ៍ហាឌីស្ ពោលគឺលោក ហ្ាគីម អាល់-ណៃស្ាប៊ូរី ដឹង ច្បាស់នូវកម្រិតខ្សោយរបស់ហាឌីស្ លោកគួរតែកែតម្រូវបណ្តាញថ្លែងហាឌីស្ តែលោកបែរជានាំមកនូវសាក្សីដែលអះអាងគាំទ្រកម្រិតខ្សោយរបស់ហាឌីស្នោះ ហើយបណ្តាញថ្លែងព័ត៌មានរបស់សាក្សីនោះក៏ខ្សោយ ហើយមិនគួរជឿបានទៀត ។ ដូច្នេះ ជំនួសការពង្រឹងហាឌីស្ឲ្យរឹងមាំឡើង លោកធ្វើឲ្យឃើញភាពខ្សោយរបស់ហាឌីស្នោះលេចច្បាស់ក្រឡែតឡើង ។ តទៅនេះ យើងនឹងពិនិត្យមើលសាក្សីខ្សោយ ។

[10] សូមមើលសៀវភៅរបស់លោក អាប៊ូ ហ្ាតាំ (ឬ អាប៊ូ ហ្ាទីម) អារ-រ៉ស៊ី *អាល់-យ៉ារ៉ោះហ្ វ៉ាត់-តាក់ឌីល (الجرح والتعديل)* ជុំទី ៥ ទំព័រ ៩២ ។

## -បណ្ដាញថ្លែងព័ត៌មានទីពីររបស់ពាក្យ "វ៉ា ស៊ុនណាទី" (ស៊ុនណាស្ញ់របស់ខ្ញុំ/ប្រពៃណីរបស់ខ្ញុំ)

ជាមួយបណ្ដាញថ្លែងព័ត៌មាននៅពេលខាងក្រោយ លោកអាល់-ហ្គាគីម អាល់-ណៃស្ហាប៊ូរីបរិយាយតមកពីលោក អាប៊ូ ហ្វូរ៉យ់រោះត៍ នៅក្នុងសេចក្ដីរាយការណ៍មួយដែលហៅថា *"មារហ្វ៊ុអ៊្ មَرْفُوع"* ។[11]

"إني قد ترتكت فيكم شيئين لن تضلّوا بعدهما: كتاب الله وسنتي لن يفترقا حتى يردا عليَّ الحوض"

*"ការពិត ខ្ញុំទុកឲ្យអស់លោកនូវវត្ថុពីរ [បើអស់លោកកាន់ជាប់] អស់លោកនឹងមិនវង្វេងជាដាច់ខាត គឺៈ ព្រះគម្ពីរអល់ឡោះហ្ញ៍និងស៊ុនណាស្ញ់ខ្ញុំ (ប្រពៃណីខ្ញុំ/ទំនៀមខ្ញុំ) ពួកគេនឹងមិនបែកខ្ញែក[ពីគ្នា]ឡើយ លុះពួកគេបានជួបខ្ញុំនៅឯស្រះ (ហៅថ្ញ៍ الحوض) [នៃអាល់-កៅស្ញារ] ។"*[12]

លោក អាល់-ហ្គាគីម បានថ្លែងបន្តសេចក្ដីរាយការណ៍នេះជាមួយបណ្ដាញថ្លែងញព័ត៌មានដូចតទៅគឺៈ
"អាដ់-ដាប៊ីបានរាយការណ៍តមកពីស្ញ៍លិះហ្ញ៍ អីបនូ មូសា អាត់-តល់ហ៊ី តមកពី អាុប់ដ្ញាល់-អាុស៊ីស្ញ អ៊ីបនូ រ៉ហ្ញី តមកពី អាប៊ី ស្ញ៍លិះហ្ញ៍ តមកពី អាប៊ូ ហ្វូរ៉យ់រ៉ោះត៍ ។"

---

[11] ម៉ារហ្វ៊ុអ៊្ មានន័យថា "អាចតាមដានរកឃើញ" ស្ដីពីហ្គាឌីស្ញដែលគេអាចតាមដានរកប្រភពដើមឃើញបានដល់ ម៉ាក់ស្ញ៊ុម (គឺបុគ្គលអរិរុទ្ធ - គឺព្រះសាស្ដាصلى الله عليه وآله وسلم និងអ៊ីម៉ាំទាំងឡាយعليهم السلامចំៗតែម្ដង) ទោះបីមានបណ្ដាញថ្លែងព័ត៌មានដាច់ ឬមិនដាច់ក៏ដោយ ។

[12] សូមមើលសៀវភៅរបស់លោក អាល់-ហ្គាគីម អាល់-ណៃស្ហាប៊ូរី *មុសតាដ្ញ៉រ៉ក់ (المستدرك على الصحيحين អាល់-មុសតាដ្ញ៉រ៉ក់ អាុឡាស្ញ់-ស្ញ៍លីហ៊ីន)* ជុំទី ១ ទំព័រ ៩៣ ។



ទៅបណ្ដាកូនចៅរបស់ព្រះអង្គعليه السلام អល់ឡោះហ្ញ៍عز وجلបានយល់ព្រមប្រទានឋានៈដ៏ខ្ពស់នេះឲ្យទៅបណ្ដាកូនចៅត្រឹមត្រូវ និងមានសទ្ធាជ្រះថ្លារបស់ព្រះអង្គعليه السلام ។ លើសពីព្រះអង្គعز وجلព្រះរាជទានព្រះគម្ពីរនិងប្រាជ្ញាញាណដែលជាគ្រឿងសម្គាល់នៃឋានៈនូប៊ូវ៉ាស្ញ់និងឋានៈរីសាឡាស្ញ់នោះ ព្រះអង្គعز وجلបានព្រះរាជទានឲ្យពួកគេនូវរាជាណាចក្រដ៏ធំធេងទៀតផងដែរ មានន័យថាព្រះអង្គعز وجلបានប្រទានអំណាចគ្រប់គ្រង និងអំណាចដឹកនាំបណ្ដាមនុស្សឲ្យទៅពួកគេ ។

ដូច្នេះ យើងឃើញហើយថាបណ្ដាកូនចៅខ្លះរបស់អ៊ីបរ៉ហ៊ីមعليه السلام ដូចជាយូស៊ុហ្វعليه السلام ដាវុដ្ញعليه السلام ស៊ូឡៃម៉ានعليه السلام ជាដើមត្រូវជ្រើសរើសដើម្បីដឹកនាំនិងគ្រប់គ្រងសង្គម ថែមទាំងបានទទួលឋានៈនូប៊ូវ៉ាស្ញ់ទៀតផង ។

ដូច្នេះ យើងដឹងច្បាស់ថាឋានៈអ៊ីម៉ាម៉ាស្ញ់ទីទៃពីឋានៈនូប៊ូវ៉ាស្ញ់និងឋានៈរីសាឡាស្ញ់ ហើយមានឋានៈខ្ពស់ជាងឋានៈទាំងពីរនេះ ដោយផ្អែកទៅលើទំហំអាជ្ញាធរនិងទំហំបន្ទុកទទួលខុសត្រូវរបស់ឋានៈអ៊ីម៉ាម៉ាស្ញ់ ។

## ឋានៈអ៊ីម៉ាម៉ាស្ញ់ប្រសើរជាង

បន្ទាប់ពីបានអធិប្បាយខាងលើហើយ យើងដឹងច្បាស់ថាមុខងាររបស់ *ណាប៊ី* និង *រ៉ស៊ូល* មិនលើសពីដាស់តឿននិងបង្ហាញមាគ៌ាមនុស្សទេ ។ លុះ *ណាប៊ី* ឬ *រ៉ស៊ូល* បានដល់ឋានៈអ៊ីម៉ាម៉ាស្ញ់ ព្រះអង្គនឹងមានករណីយកិច្ចទទួលខុសត្រូវសំខាន់លើសពីនោះ ព្រោះព្រះអង្គត្រូវបំពេញផែនការណ៍របស់អល់ឡោះហ្ញ៍عز وجل ត្រូវដាក់ឲ្យប្រើព្រះរាជក្រឹត្យរបស់អល់ឡោះហ្ញ៍عز وجلនៅក្នុងអ៊ុមម៉ាត់ស្ញ់គំរូនិងប្រកបដោយសុភមង្គល ក្នុងលោកនេះនិងក្នុងលោកមុខ ។

បានឆ្លងកាត់ការល្បងពិសោធន៍ដ៏លំបាកជាច្រើនទេនោះ ។

២. អាយ៉ាស់ខាងលើនេះបង្ហាញឲ្យឃើញថា អល់ឡោះហ្ទ៎ា عز وجل បានព្រះរាជទានឋានៈអ៊ីម៉ាម៉ាស់ និងមុខងារដឹកនាំសហគមន៍ឲ្យទៅអ៊ីបរ៉ហ៊ីម عليه السلام បន្ទាប់ពីបានល្បងពិសោធព្រះអង្គ عليه السلام ដោយការល្បងពិសោធដ៏លំបាក ។ បន្ទាប់ពីនោះ អ៊ីបរ៉ហ៊ីម عليه السلام បានសូមឲ្យអល់ឡោះហ្ទ៎ា عز وجل ប្រគល់ឋានៈនេះឲ្យទៅបណ្តាកូនចៅរបស់ព្រះអង្គ عليه السلام ផងដែរ ។

អាយ៉ាស់គួរអានផ្សេងទៀតចែងយ៉ាងច្បាស់ថាអល់ឡោះហ្ទ៎ា عز وجل ព្រមទទួលសំណូមរបស់អ៊ីបរ៉ហ៊ីម عليه السلام ហើយព្រះអង្គ عز وجل បានព្រះរាជទានឋានៈអ៊ីម៉ាម៉ាស់និងអំណាចគ្រប់គ្រងអុមម៉ាត់ បន្ទាប់ពីឋានៈនូប៊ូវ៉ាស់ ឲ្យទៅបណ្តាកូនចៅបរិសុទ្ធរបស់អ៊ីបរ៉ហ៊ីម عليه السلام ។ ព្រះមហាគម្ពីរគួរអានចែងអំពីរឿងនេះថាៈ

فَقَدْ ءَاتَيْنَآ ءَالَ إِبْرَٰهِيمَ ٱلْكِتَـٰبَ وَٱلْحِكْمَةَ وَءَاتَيْنَـٰهُم مُّلْكًا عَظِيمًا

*"ការពិតយើងបានប្រទានព្រះគម្ពីរនិងប្រាជ្ញា ញាណឲ្យទៅបណ្តាកូនចៅរបស់អ៊ិបរ៉ហ៊ីម ហើយយើងបានប្រទានរាជាណាចក្រដ៏ធំផងឲ្យពួកគេ ៤:៥៤ ។"*[324]

យើងអាចយល់បានអាស្រ័យអាយ៉ាស់នេះថាអ៊ីម៉ាម៉ាស់ (គឺឋានៈដឹកនាំសង្គម) មានឋានៈទីទៃពីឋានៈនូប៊ូវ៉ាស់ ហើយខ្ពស់ជាង ។ អល់ឡោះហ្ទ៎ា عز وجل បានព្រះរាជទានឋានៈនេះឲ្យទៅអ៊ីបរ៉ហ៊ីម عليه السلام បន្ទាប់ពីព្រះអង្គ عليه السلام បានឆ្លងកាត់ការល្បងពិសោធន៍ដ៏លំបាកជាច្រើនរបស់អល់ឡោះហ្ទ៎ា عز وجل ។

កាលព្រះអង្គ عليه السلام បានសូមឲ្យអល់ឡោះហ្ទ៎ា عز وجل ប្រទានឋានន្តរស័ក្តិនេះ ឲ្យ

[324] ស្វរ៉ោះត៊ុ អាន់-នីសាអ៊ុ 4:54 ។



ដូចសេចក្តីរាយការណ៍មុនដែរ សេចក្តីរាយការណ៍មួយនេះជាសេចក្តីរាយការណ៍ប្រឌិត លោក ស្វ៎លិះហ្វ៎ អ៊ីបនូ មូសា អាត់-តល់ហ៊ី ជាអ្នកថ្លែងបន្តម្នាក់របស់ហាឌីស្ហនេះ ក្នុងចំណោមអ្នកថ្លែងបន្តឯទៀត ហើយអំពី អស់លោកអ្នកថ្លែងបន្តទាំងនេះ អ៊ូឡាម៉ាអ៊ុជាន់ខ្ពស់នៃសំណាក់ *អ៊ិលមូ អាល់-រីយ៉ាល់* មានប្រសាសន៍ថាៈ

"យ៉ាស់យ៉ា អ៊ីបនូ មូអ៊ីន មានប្រសាសន៍ថាៈ "ស្វ៎លិះហ្វ៎ អ៊ីបនូ មូសាមិនគួរឲ្យទុកចិត្តទេ ។" អាប៊ូ ហាតាំ អារ-រ៉ស៊ី មានប្រសាសន៍ថាៈ "ហាឌីស្ហរបស់គាត់ខ្សោយ (ឌ្ហ៊អ៊ីហ្វ ضعيف) ហើយ "មិនធម្មតា (មុនការ المنكر)" គាត់បានថ្លែងហាឌីស្ហមិនធម្មតារបស់គាត់ច្រើន តមកពីបុគ្គលដែលគួរទុកចិត្ត ។" លោក នីសាអ៊ី មានប្រសាសន៍ថាៈ "គេមិនអាចកត់ត្រាហាឌីស្ហរបស់គាត់បានទេ ។" លោកមានប្រសាសន៍មួយកន្លែងទៀតថាៈ "ហាឌីស្ហរបស់គាត់ត្រូវច្រានចោល (ម៉ាត់រូក متروك) ។""[13]

នៅក្នុង *តាស្ទ់ស៊ីប អាត់-តាស្ទ់ស៊ីប* លោក អ៊ីបនូ ហាយ៉ារ (អាល់-អាស់ក៏ឡានី) បានសរសេរថាៈ "អ្វីដែលមិនសមស្របនឹងសម្តីរបស់បុគ្គលគួរឲ្យទុកចិត្ត ស្វ៎លិះហ្វ៎ អ៊ីបនូ មូសាកំណត់ថាវាជារបស់បុគ្គលគួរឲ្យទុកចិត្ត ។" បន្ទាប់មកលោកមានប្រសាសន៍ថាៈ "ហាឌីស្ហរបស់គាត់មិនមែនជាភ័ស្តុតាងត្រឹមត្រូវទេ ។" លោក អាប៊ូ ណាអ៊ីម មានប្រសាសន៍ថាៈ "ហាឌីស្ហរបស់គាត់ត្រូវច្រានចោល គាត់ធ្លាប់តែរាយការណ៍ហាឌីស្ហមិនធម្មតាជានិច្ច ។"[14]

[13] សូមមើលសៀវភៅរបស់លោក ហាហ្វីស្ហ អាល់-មីស៊ី *តាស្ទ់ស៊ីប អាល់-កាម៉ាល់ (تهذيب الكمال)* ជុំទី ១៣ ទំព័រ ៩៦ ។

[14] សូមមើលសៀវភៅរបស់លោក អ៊ីបនូ ហាយ៉ារ *តាស្ទ់ស៊ីប អាត់-តាស្ទ់ស៊ីប* ជុំទី ៤ ទំព័រ ៣៥៥ ។

នៅក្នុងសៀវភៅ *អាត់-តាក់រីប (تقريب)* [15] ដែរ លោក អ៊ីបនូ ហាយ៉ារ មានប្រសាសន៍ថា៖ "ហាឌីស្វគាត់ត្រូវច្រានចោល ។" នៅក្នុង *អាល់-កាស៊ីហ្វ*[16] លោក អាល់-ស្ហាហ្វាប៊ី (الذهبي) មានប្រសាសន៍ថា៖ "ហាឌីស្វរបស់គាត់ខ្សោយ ។" នៅក្នុង មីស្សាន អាល់-អ៊ិះអ៊្ទីដាល់ (مِيزَانُ الإِعْتِدَال)[17] លោក អាល់-ស្ហាហ្វាប៊ី (الذهبي) បានរាយការណ៍នូវហាឌីស្វដែលអាចប្រកែកបានមួយរបស់គាត់ ហើយថាហាឌីស្វនោះនៅក្នុងចំណោមហាឌីស្វដែលមិនគួរឲ្យទទួលយកបានឡើយ ។"

## -បណ្ដាញថ្លែងព័ត៌មានទីបីរបស់ពាក្យ "វ៉ា ស៊ុនណាទី" (ស៊ុនណាស្ទរបស់ខ្ញុំ/ប្រពៃណីរបស់ខ្ញុំ)

នៅក្នុង អាត់-តាំហ៊ីដ្ (التمهيد) លោក អ៊ីបនូ អាប់ដាល់-បារ និយាយរឿងនេះជាមួយបណ្ដាញថ្លែងព័ត៌មានដូចតទៅ៖

អាប់ដ្ អារ-រ៉ោះហ្ម៉ាន អ៊ីបនូ យ៉ាស្ស៊ីយ៉ានិយាយតមកពីអាស៊្ម៉ាដ់ អ៊ីបនូ សាអ៊ីដ្ តមកពី មូហាំម៉ាដ់ អ៊ីបនូ អ៊ីបរ៉ហ៊ីម អាដ់-ឌូបៃលី តមកពី អាលី អ៊ីបនូ ស្សៃដ្ អាល់-ហ្វារ៉អ៊ីឌី តមកពី អាល់-ហ្វូនៃនី តមកពី កាស៊្សៀរ អ៊ីបនូ អាប់ដ្ អាល់ឡោះហ្វ៍ អ៊ីបនូ អាំរូ អ៊ីបនូ អោហ្វ៍ តមកពីឪពុកគាត់ តមកពី

[15] សូមមើលសៀវភៅរបស់លោក អ៊ីបនូ ហាយ៉ារ (អាល់-អាស់ក៏ឡានី) *អាត់-តាក់រីប* (ច្បាប់បកប្រែជាភាសាអង្គេស) លេខ ២៨៩១ ។

[16] សូមមើលសៀវភៅរបស់លោក អាល់-ស្ហាហ្វាប៊ី (الذهبي) *អាល់-កាស៊ីហ្វ* (ច្បាប់បកប្រែជាភាសាអង្គេស) លេខ ២៤១២ ។

[17] សូមមើលសៀវភៅរបស់លោក អាល់-ស្ហាហ្វាប៊ី (الذهبي) *មីស្សាន អាល់-អ៊ិះអ៊្ទីដាល់ (مِيزَانُ الإِعْتِدَال)* ជុំទី ២ ទំព័រ ៣០២ ។



ការល្បងពិសោធន៍របស់អល់ឡោះហ្វ៍ﷻដ៏លំបាកមួយ គឺការធ្វើពលីកម្មអ៊ីសម៉ាអ៊ីលﷺ ហើយក្រោយពីនេះ អល់ឡោះហ្វ៍ﷻបានព្រះរាជទានឋានៈអ៊ីម៉ាម៉ាស្ទឲ្យអ៊ីបរ៉ហ៊ីមﷺ ។ នេះគឺព្រឹត្តិការណ៍ដែលបានកើតឡើងពេលព្រះអង្គﷺមានវ័យជរាហើយ ។

ព្រះអង្គﷺបានទៅជាអ្នកដឹកនាំអ៊ុមម៉ាត្ទ នៅប៉ែកចុងក្រោយនៃជីវិតព្រះអង្គﷺ កាលនោះព្រះអង្គﷺបានទទួលឋានៈនូប៊ូវ៉ាស្ទតាំងពីយូរឆ្នាំពីមុនមកហើយ ព្រោះព្រះអង្គﷺតែងតែបានទទួលការបើកឲ្យដឹងពីអល់ឡោះហ្វ៍ﷻ (គឺបានទទួលវ៉ាហ៊ីពីអល់ឡោះហ្វ៍ﷻ) ដែលជាសញ្ញានៃឋានៈនូប៊ូវ៉ាស្ទមុនព្រះអង្គﷺមានកូន ។ [323]

ខ. អាយ៉ាស្ទ ១២៤ ស៊ូរ៉ោះត្ទ អាល់-បាក៏រ៉ោះត្ទ ខាងលើនេះ បញ្ជាក់អំពីឋានៈអ៊ីម៉ាម៉ាស្ទ - ពោលគឺ គ្រប់គ្រងសហគមន៍និងដឹកនាំមនុស្ស - ខ្ពស់ជាងឋានៈនូប៊ូវ៉ាស្ទ ឬឋានៈរីសាឡាស្ទ ព្រោះ ដូចគួរអានថែងបញ្ជាក់នោះគឺកាលព្រះអង្គﷺបានទទួលឋានៈនូប៊ូវ៉ាស្ទ និងឋានៈរីសាឡាស្ទហើយ ។ ព្រះអង្គﷺចាំបាច់ត្រូវរងការល្បងពិសោធន៍មុននឹងទទួលឋានៈអ៊ីម៉ាម៉ាស្ទ ។

មូលហេតុគឺ លើសពីភារកិច្ចទទួលការបើកឲ្យដឹងព្រះរាជសារនិងការបញ្ជូនព្រះរាជសារ ឋានៈអ៊ីម៉ាម៉ាស្ទមានមុខនាទីនត្រួតត្រាសង្គម ដឹកនាំអ៊ុមម៉ាត្ទនិងគ្រប់គ្រងមនុស្ស ដើម្បីនឹងបានទៅដល់សុក្រឹតភាពនិងសុខុមាលភាព ។ ជាធម្មតាទេដែលឋានៈនេះមានខ្លឹមសារនិងមានទំហំសំខាន់ជាពិសេស ហើយមិនអាចទទួលបាននូវឋានៈនេះទេប្រសិនបើពុំ

[323] សូមមើលស៊ូរ៉ោះត្ទ អាស្ស-ស្វ៍ហ្វាត 37:99-102; ស៊ូរ៉ោះត្ទ អាល់-ហ៊ីច្ទ៍ 15:53-54; ស៊ូរ៉ោះត្ទ ហ៊្វូដ្ 11:70-71 ។

*"កាលព្រះម្ចាស់របស់អ៊ីបរ៉ហ៊ីមបានល្បងពិសោធគេដោយវាចា គេបានប្រតិបត្តិតាមវាចាទាំងនោះបានសម្រេច ។ ព្រះអង្គមានព្រះបន្ទូលថា៖ "អញនឹងតែងតាំងអ្នកជាអ៊ីម៉ាំ (គឺអ្នកដឹកនាំឥតខ្ចោះដែលអល់ឡោះហ៍ជ្រើសរើស) សម្រាប់មនុស្ស ។" គេ (គឺអ៊ីបរ៉ហ៊ីម) បានទូលថា៖ "តើនៅក្នុងបណ្តាកូនចៅទូលព្រះបង្គំជាខ្ញុំដែរទេ ?" ២:១២៤ "*[321]

អាយ៉ាស់គួរអាននេះបង្ហាញយើងនូវការពិតពីរគឺ៖

ក. អាយ៉ាស់នេះបញ្ជាក់អំពីការខុសគ្នារវាងអ៊ីម៉ាម៉ាស់, នូប៊ូវ៉ាស់និងរីសាឡាស់ ព្រោះអ៊ីបរ៉ហ៊ីមعليه السلامបានទទួលឋានៈនូប៊ូវ៉ាស់យូរឆ្នាំមកហើយមុនអល់ឡោះហ៍عز وجلបានល្បងពិសោធជាច្រើនលើក រាប់ទាំងការល្បងពិសោធន៍ធ្វើពលីកម្មព្រះរាជបុត្រព្រះអង្គعليه السلام (អ៊ីសម៉ាអ៊ីលعليه السلام) ។ នេះគឺភ័ស្តុតាងបញ្ជាក់រឿងនេះគឺ៖

យើងទាំងអស់គ្នាដឹងស្រាប់ហើយថា អល់ឡោះហ៍عز وجلបានព្រះរាជទានបុត្រពីរអង្គឲ្យអ៊ីបរ៉ហ៊ីមعليه السلام កាលព្រះអង្គعليه السلامមានវ័យចំណាស់ហើយនោះ (គឺអ៊ីសម៉ាអ៊ីលនិងអ៊ីសហ្កាក់) ដូចមានចែងនៅក្នុងព្រះគម្ពីរគួរអានថា៖

ٱلۡحَمۡدُ لِلَّهِ ٱلَّذِى وَهَبَ لِى عَلَى ٱلۡكِبَرِ إِسۡمَٰعِيلَ وَإِسۡحَٰقَۚ

*"សូមថ្វាយថោមនាការចំពោះអល់ឡោះហ៍ ព្រះអង្គបានព្រះរាជទានអ៊ិសម៉ាអ៊ីលនិងអ៊ិសហ្កាក់ឲ្យទូលព្រះបង្គំជាខ្ញុំ ថ្វីបើទូលព្រះបង្គំជាខ្ញុំជាមនុស្សជរាទៅហើយ ១៤:៣៩ ។"*[322]

[321] ស៊ូរ៉ោះត៍ អាល់-បាក៏រ៉ោះត៍ 2:124 ។

[322] ស៊ូរ៉ោះត៍ អ៊ីបរ៉ហ៊ីម 14:39 ។



តាគាត់ ។[18]

ទាក់ទងនឹង កាស្សៀរ អ៊ីបនូ អាប់ឌ័ អាល់ឡោះហ៍ អ៊ីម៉ាំ អាស្ស៊-ស្វាហ្វ៊ីអ៊ី មានប្រសាសន៍ថា៖ "គាត់ជាមេកុហកម្នាក់ ។"[19] លោក អាប៊ូ ដាវូដ មានប្រសាសន៍ថា៖ "គាត់ជាអ្នកបោកនិងជាអ្នកកុហកម្នាក់ ។"[20] លោក អ៊ីបនូ ហ៊ីបបាន់ មានប្រសាសន៍ថា៖ "អាប់ឌ័ អាល់ឡោះហ៍ អ៊ីបនូ កាស្សៀរ និយាយតមកពីឪពុកនិងជីតាគាត់ នូវតម្រាហាឌីស្ទដែលផ្អែកលើការក្លែងបន្លំ ។ និយាយស្រង់យកពីតម្រានោះនិងស្រង់យកពីសេចក្តីរាយការណ៍របស់ អាប់ឌ័ អាល់ឡោះហ៍ មិនស្របច្បាប់ទេ លើកលែងតែចង់និយាយឲ្យភ្ញាក់ផ្អើល ឬចង់រិះគន់ ។"[21]

លោក នីសាអ៊ី និងលោក ដារគូត្នី (الدارقطني) មានប្រសាសន៍ថា៖ "ហាឌីស្ទគាត់ត្រូវច្រានចោល ។" អ៊ីម៉ាំ អាស់ម៉ាដ់ [អ៊ីបនូ ហាន់បាល់] មានប្រសាសន៍ថា៖ "គាត់គឺ *មុនការ អាល់-ហាឌីស្ទ* (អ្នករាយការណ៍ហាឌីស្ទប្លែក) ហើយគាត់មិនគួរឲ្យទុកចិត្តទេ ។" លោក អ៊ីបនូ មូអ៊ីន មានយោបល់ដូចនេះដែរអំពីគាត់ ។

[18] សូមមើលសៀវភៅ អាត់-តាំហ្ស៊ីដ ជំទី ២៤ ទំព័រ ៣៣១ ។

[19] សូមមើលសៀវភៅរបស់លោក អ៊ីបនូ ហាយ៉ារ (អាល់-អាស់ក៏ឡានី) *តាស្ស៊ីប អាត់-តាស្ស៊ីប* ជុំទី ៨ ទំព័រ ៣៧៧ ។ *តាស្ស៊ីប អាល់-កាម៉ាល់ (تَهْذِيب الكَمال)* ជុំទី ២៤ ទំព័រ ១៣៨ ។

[20] សូមមើលសៀវភៅរបស់លោក អ៊ីបនូ ហាយ៉ារ (អាល់-អាស់ក៏ឡានី) *តាស្ស៊ីប អាត់-តាស្ស៊ីប* ជុំទី ៨ ទំព័រ ៣៧៧ ។ *តាស្ស៊ីប អាល់-កាម៉ាល់ (تَهْذِيب الكَمال)* ជុំទី ២៤ ទំព័រ ១៣៨ ។

[21] សូមមើលសៀវភៅរបស់លោក អ៊ីបនូ ហ៊ីបបាន់ *អាល់-ម៉ាច់រូហ៊ីន (المجروحين)* ជុំទី ២ ទំព័រ ២២១ ។

គួរឲ្យភ្ញាក់ផ្អើលដែលនៅក្នុង *អាត់-តាក់រីប* សៀវភៅជីវប្រវត្តិរបស់លោកកាស្សៀរ នោះ លោក អ៊ីបនូ ហ៊ាយ៉ារ បានត្រឹមតែថា "ខ្សោយ" (ដ្វ៏អ៊ីហ្វ) រីឯអស់លោកឯទៀតបានចោទប្រកាន់គាត់ថា និយាយកុហកដូចមនុស្សជ្រុលនិយម ។ ទន្ទឹមនេះដែរ បណ្ដាអ្នក *អ៊ីលមូ អាល់-រីយ៉ាល់* មុនៗបានចោទប្រកាន់គាត់ថានិយាយកុហកនិងក្លែងបន្លំ ។ ម្យ៉ាងទៀត លោកស្វាហ្វាប៊ីមានប្រសាសន៍ថា៖ "សម្ដីគាត់មិនសមហេតុផលហើយខ្សោយ ។"

## -សេចក្ដីរាយការណ៍គ្មានបណ្ដាញថ្លែងព័ត៌មាន

នៅក្នុងសៀវភៅ *អាល់-មូវ៉ាត់ត៍ (الموطأ)* លោក ម៉ាលិក ថាហាឌីស្វនេះជាហាឌីស្វ *មូរសាល់ (مرسل)* [22] មិននិយាយដល់បណ្ដាញថ្លែងព័ត៌មានទេ[23] យើងដឹងស្រាប់ហើយថាសេចក្ដីរាយការណ៍បែបនេះពុំមានតម្លៃទេ ។

របាយការណ៍អង្កេតនេះបង្ហាញឲ្យឃើញច្បាស់ថា ពាក្យតំណាល *"រ៉ាស៊ុនណាទី" (ស៊ុនណាស្ស់ខ្ញុំ/ប្រពៃណីខ្ញុំ)* ត្រូវប្រឌិតឡើង និងត្រូវលាយឡំដោយអស់អ្នករាយការណ៍បោកប្រាស់ ចូលដៃជាមួយពួកអ៊ូម៉ៃយ៉ាស្ស់ដែលបានប្រឌិតពាក្យតំណាលនេះឡើងដើម្បីប្រឆាំងហាឌីស្វពិត *"រ៉ា*

[22] មូរសាល់ មានន័យថា "តក់ក្រហល់" - មិនស្គាល់អ្នកបង្គ្រប់បណ្ដាញថ្លែងហាឌីស្វបន្ត ពោលគឺ ខ្វះឈ្មោះអ្នករាយការណ៍ហាឌីស្វម្នាក់ឬច្រើននាក់ ។ ពាក្យ "មូរសាល់" មានន័យត្រង់ថា "បន្ត" ពីព្រោះជាញឹកញយ ហាឌីស្វឈានទៅមុខដោយសារអ្នកតាម (តាប៊ីអ៊ី تابع) ដោយភ្លេចឈ្មោះសាវក (ស្វ៏ហ៊ាប صاحب) ដែលបាននិយាយហាឌីស្វនោះប្រាប់ ។

[23] សូមមើលសៀវភៅរបស់លោក ម៉ាលិក អ៊ីបនូ អាណាស់ *អាល់-មូវ៉ាត់ត៍ (الموطأ)* ទំព័រ ៨៨៩ ហាឌីស្វលេខ ៣ ។



*ណាប៊ី ។* អាចនិយាយម្យ៉ាងទៀតបានថា ន័យរបស់ *នូប៊ូវ៉ាស្ស់* និង *រីសាឡាស្ស់* ផ្ដោតទៅលើលក្ខណៈរបស់សាស្ដាទាំងឡាយដែលទទួលការបើកឲ្យដឹង (គឺទទួលវ៉ាហ៊ី) ពីអល់ឡោះហ្ទ៍عزّ وجلّ ។ ព្រះសាស្ដាដែលហៅថា *ណាប៊ី* នោះគឺព្រោះព្រះអង្គទាំងនេះជាអ្នកទទួលការបើកឲ្យដឹងរបស់អល់ឡោះហ្ទ៍عزّ وجلّ (គឺព្រះបន្ទូលរបស់អល់ឡោះហ្ទ៍عزّ وجلّ) និងជាអ្នកនាំដំណឹង ។ ព្រះសាស្ដាដែលហៅថា *រ៉ាស៊ូល* នោះគឺព្រោះព្រះអង្គទាំងនេះទទួលភារកិច្ចខុសត្រូវខាងបញ្ជូនព្រះរាជសារ ។

អាស្រ័យលើសេចក្ដីអធិប្បាយខាងលើ យើងអាចនិយាយសរុបបានថាព្រះសាស្ដា នៅក្នុងប្រខណ្ឌ នូប៊ូវ៉ាស្ស់ និង រីសាឡាស្ស់ គ្រាន់តែជាមគ្គទេសក៏ដែលថ្លែងប្រាប់អំពីអ្វីដែលច្បាប់អនុញ្ញាត អំពីអ្វីដែលច្បាប់ហាម និងបង្ហាញផ្លូវទៅកាន់សុខុមាលភាពនិងសុភមង្គល ។ ព្រះអង្គទាំងនេះមានតួនាទីត្រឹមតែ ទទួលខុសត្រូវខាងរាយការណ៍អំពីអ្វីដែលអល់ឡោះហ្ទ៍عزّ وجلّបានបើកឲ្យព្រះអង្គដឹង ឬបញ្ជូនព្រះរាជសារទេ ។

## ៣. ឋានៈអ៊ីម៉ាម៉ាស្ស់

យោលតាមគួរអាន ឋានៈអ៊ីម៉ាម៉ាស្ស់ខុសពីឋានៈទាំងពីរខាងលើនេះហើយទាក់ទងនឹងអាជ្ញាធរនិងអំណាចទូទៅខាងគ្រប់គ្រង និងខាងដឹកនាំអ៊ុមម៉ាត្ត់ ។

អាស្រ័យលើអាយ៉ាស្ស់គួរអានត្រចះត្រចង់ យើងសូមលើកឡើងនូវភ័ស្តុតាងជាក់ច្បាស់ខ្លះដើម្បីបញ្ជាក់រឿងនេះ គឺ៖

وَإِذِ ٱبْتَلَىٰٓ إِبْرَٰهِـۧمَ رَبُّهُۥ بِكَلِمَـٰتٍ فَأَتَمَّهُنَّ ۖ قَالَ إِنِّى جَاعِلُكَ لِلنَّاسِ إِمَامًا ۖ
قَالَ وَمِن ذُرِّيَّتِى ۖ

*ដោយមិនឆ្លងកាត់តាមមនុស្សឯទៀតទេ (ពោលគឺ ផ្សាយផ្ទាល់) ។"*[318]

ដូច្នេះ មុខងាររបស់ណាប៊ីនៅក្នុងក្របខណ្ឌទទួលការបើកឲ្យដឹងនិងផ្ទេរឲ្យទៅបណ្តាមនុស្សនូវអ្វីដែលគេបានបើកឲ្យខ្លួនដឹង ។ ព្រះមហាគម្ពីរគួរអានថែងអំពីរឿងនេះថា៖

فَبَعَثَ ٱللَّهُ ٱلنَّبِيِّـۧنَ مُبَشِّرِينَ وَمُنذِرِينَ

*"អល់ឡោះហ្ទ័បានបញ្ជូនបណ្តាសាស្តា[របស់ព្រះអង្គ]មក ដើម្បីនាំមកនូវដំណឹងល្អ (គឺបង្ហាញផ្លូវល្អ) និងដើម្បីដាស់តឿន ២:២១៣ ។"*[319]

## ២. ឋានៈរ៉ីសាឡាស់

នៅក្នុងវាក្យសព្ទ (គឺប្រជុំពាក្យសម្រាប់ប្រើក្នុងភាសាវាហ្វី) ពាក្យ រ៉សូល មានន័យថាសាស្តាដែល ក្រៅពីទទួលវ៉ាហ្វី (គឺការបើកឲ្យដឹងមកពីអល់ឡោះហ្ទ័(عز وجل)) និងផ្ទេរវ៉ាហ្វីឲ្យទៅបណ្តាមនុស្ស មានបន្ទុកនាំព្រះរាជសារ (រីសាឡាស់) និងទទួលភារកិច្ចផ្សាយព្រះរាជសារឲ្យបណ្តាមនុស្សដឹង ។ ព្រះមហាគម្ពីរគួរអានថែងថា៖

فَإِن تَوَلَّيۡتُمۡ فَٱعۡلَمُوٓاْ أَنَّمَا عَلَىٰ رَسُولِنَا ٱلۡبَلَٰغُ ٱلۡمُبِينُ

*"បើពួកអ្នកបែរក្រោយ ចូរពួកអ្នកដឹងថាសាស្តារបស់យើងមាននាទីត្រឹមតែផ្សព្វផ្សាយ[ព្រះរាជសារ]យ៉ាងជាក់ច្បាស់ប៉ុណ្ណោះ ៥:៩២ ។"*[320]

ហេតុដូច្នេះ ឋានៈថ្នាក់ *រីសាឡាស់* ជាឋានៈមួយទៀតដែលបានទៅលើ

[318] សូមមើលសៀវភៅរបស់ ស្ហៃខ៍ អាត់-ទូស៊ី (الشيخ الطوسي) *រ៉សាអ៊ីល អាល់-អាស្ហារ (الرسائل العشر)* ទំព័រ ១១១ ។

[319] ស៊ូរ៉ោះត៍ អាល់-បាក៏រ៉ោះត៍ 2:213 ។

[320] ស៊ូរ៉ោះត៍ អាល់-ម៉ាអ៊ីដាស់ 5:92 ។



*អ៊ីតរ៉ទី" (សន្តតិវង្សខ្ញុំ) ។*

ហេតុដូច្នេះ ចាំបាច់ត្រូវឲ្យបណ្តាអ្នកធ្វើធម្មទេសនា (អ្នកធ្វើឃុត្ធបាស់) នៅក្នុងម៉ាស់ឃិដ្ឋ បណ្តាអ្នកសូត្រសុន្នរកថាសាសនា បណ្តាអ្នកដឹកនាំស៊ូឡាត៍បោះបង់ចោលសេចក្តីរាយការណ៍មិនសមហេតុផល ដែលគេថាបានមកពីរ៉សូលុលឡោះហ្ទ័ﷺនោះ ហើយបែរត្រឡប់មកស្និទ្ធស្នាលជាមួយអស់បុគ្គលដែលដឹងហាឌីស្ហពិត - ហាឌីស្ហដែលលោកមុស្លីមបានរាយការណ៍នៅក្នុង *ស្ហ៍ហ៊ិះហ្ទ័* របស់លោក ជាមួយឃ្លា *"អាស្ល់ឡា បៃទី"* (ព្រះរាជកុលដ្ឋានរបស់ខ្ញុំ) និងលោកតៀរមីស៊ី[នៅក្នុងស៊ូណាន់របស់លោក] ជាមួយឃ្លា *"អ៊ីតរ៉ទី អាស្ល់ឡា បៃទី"* (សន្តតិវង្សរបស់ខ្ញុំ ព្រះរាជកុលដ្ឋានរបស់ខ្ញុំ) ។ អស់លោកអ្នកស្វែងរកចំណេះមានករណីយកិច្ចគោរពច្បាប់វិទ្យាសាស្ត្រហាឌីស្ហ និងត្រូវចេះវែកញែកឲ្យដឹងហាឌីស្ហពិត និងហាឌីស្ហខ្សោយ *(ឌ៏អ៊ីហ្វ (ضعيف)* មានន័យថាខ្សោយ ព្រោះតែមានបណ្តាញព័ត៌មានដាច់ ដោយសារតែអ្នកនាំព័ត៌មានមានប្រវត្តិរូបមិនល្អឬមិនច្បាស់ និយាយកុហក មានកំហុសច្រើនពេក ឬបានរួមដៃបំភ្លៃហាឌីស្ហជាដើម) ។

ទីបញ្ចប់ យើងបានឃើញហើយថាតាមរយៈពាក្យ *"អាស្ល់ឡា បៃទី"* នេះ ព្រះសាស្តាﷺចង់និយាយដល់បណ្តាកូនចៅព្រះអង្គ (ស្ហូរីយ៉ាស់ ذرية) ពោលគឺ ហ្វាដ្ហ៉ោះត៍ ហ្វាទីម៉ាស់, ហាសាន់, ហ៊ូសៃន៍(عليهم السلام) ដូចលោក មុស្លីមនៅក្នុង *ស្ហ៍ហ៊ិះហ្ទ័*[24] របស់លោក ដូចលោក តៀរមីស៊ី នៅក្នុង *ស៊ូណាន់*[25]

[24] សូមមើល *ស្ហ៍ហ៊ិះហ្ទ័* របស់លោក មុស្លីម ដុំទី ៤ ទំព័រ ១៨៨៣ ហាឌីស្ហលេខ ២៤២៤ ។ សូមមើលសៀវភៅរបស់លោក អាប់ឌុល-ហាមីដ ស៊ីដ្ឋីឌីគី *ស្ហ៍ហ៊ិះហ្ទ័ មុស្លីម* (ច្បាប់ប្រែជាភាសាអង់គ្លេស) ដុំទី ៤ ហាឌីស្ហលេខ ៥៩៥៥ ។

[25] សូមមើល *ស៊ូណាន់* របស់លោក តៀរមីស៊ី ដុំទី ៥ ទំព័រ ៦៦៣ ។

របស់លោកនោះបានរាយការណ៍តមកពីអ៊ុំស្ហាស្លំថា៖

نزلت هذه الأية على النّبي صلى الله عليه وأله وسّلم – **إنما يُريد الله ليُذهب عنكم الرّجس أهل البيت ويُطهِّركم** تطهيراً – في بيت أم سلمة فدعا النبيّ صلى الله عليه وأله وسلم وفاطمة وحسناً وحسيناً فجللهم وبكساء على خلف ظهره فجلّله بكساء ثم قال: اللهم هؤلاء أهل بيتي فاذهب عنهم الرّجس وطهِّرهم تطهياً. قالت أم سلمة: وأنا معهم يا نبيّ الله؟ قال: أنت على مكانك وأنت إلى خير."

*"អាយ៉ាស្ទ់ "សមាជិកនៃគេហដ្ឋាន[របស់សាស្តា]អើយ អល់ឡោះហ្ទ៍គ្រាន់តែប្រាថ្នាឲ្យពួកអ្នកចាកផុតពីមន្ទិល ហើយព្រះអង្គប្រាថ្នាសំអាតពួកអ្នកឲ្យបរិសុទ្ធជ្រះស្អាតតែប៉ុណ្ណោះទេ (៣៣:៣៣)"[26] ត្រូវដាក់ចុះមកនៅឯផ្ទះព្រះនាង អ៊្ទម សាឡាម៉ាស្ទ់ ។*

*ព្រះសាស្តាﷺដណ្តប់ហ្វាទីម៉ាស្ទ់ ហ្ហាសាន់ ហ៊្សៃសែន៍ក្នុងអាវធំ ហើយអ៊្ហលីនៅពីក្រោយព្រះអង្គﷺ ។ ព្រះ អង្គﷺបានដណ្តប់អ៊្ហលីក្នុងអាវធំនោះ ហើយមានព្រះវចនៈថា៖ "អល់ឡោះហ្ទ៍ﷻអើយ ! ពួកគេជាសន្តតិវង្សនៃកុលដ្ឋានទូលព្រះបង្គំជាខ្ញុំ (អាស្ទ់លុល-បៃត៍) ។ សូមព្រះអង្គﷻកម្ចាត់មន្ទិលពីពួកគេ សូមព្រះអង្គﷻជម្រះបន្សុទ្ធពួកគេឲ្យបរិសុទ្ធ ។" ព្រះនាង អ៊្ទម សាឡាម៉ាស្ទ់ បានទូលថា៖ "ព្រះសាស្តាﷺអល់ឡោះហ្ទ៍ﷻអើយ តើខ្ញុំម្ចាស់នៅជាមួយពួកគេទេ ?" ព្រះអង្គﷺមានព្រះវចនៈថា៖ "ចូរអ្នកនៅកន្លែងអ្នក អ្នកនៅក្នុងសេចក្តីល្អ ។"[27]*

[26] សូរ៉ោះត៍ អាល់-អាស្ហ៍ស្ហាប់ ៣៣:៣៣ ។

[27] ដកស្រង់មកពីសៀវភៅរបស់លោក ហ្ហាសាន់ អ៊ីបនូ អ៊្ហលី អាស្ស-ស្សាក្ក៌ក្វហ្ទ៍ *ស្ហ៏ហ្ហិះហ្ហ៍ ស៊្ហីហ្វាស្ទ់ ស្ហ៏ឡាត្ទ៍ អាន់-ណាប៊ីﷺ* ទំព័រ ២៨៩-២៩៤ ។



# ចម្លើយ

ដើម្បីបំភ្លឺសំណួរនេះ យើងសូមពន្យល់ពាក្យទាំងបីនេះជាមុនសិនគឺ នូប៊ូវ៉ាស្ទ់, រីសាឡាស្ទ់ (رسالة បេសកកម្មសាស្តា) និង អ៊ីម៉ាម៉ាស្ទ់ ដែលមានចែងនៅក្នុងគួរអាន ដើម្បីបង្ហាញថាឋានៈអ៊ីម៉ាម៉ាស្ទ់ខ្ពស់ជាងឋានៈទាំងពីរនោះឯទៀត ។

## ១. ឋានៈនូប៊ូវ៉ាស្ទ់

ពាក្យ ណាប៊ី (សាស្តា) ក្លាយមកពីពាក្យ ណាបាអ៍ (نبأ) ដែលមានន័យថាដំណឹងធំ ។ ដូច្នេះ ពាក្យថា ណាប៊ី មានន័យត្រង់ថា "អ្នកនាំដំណឹងសំខាន់ណាស់" ឬ "អ្នកប្រកាសដំណឹងសំខាន់ណាស់" ។[317]

ពាក្យ *ណាប៊ី* ដែលស្មើនឹងពាក្យខ្មែរថា *សាស្តា* មានប្រើនៅក្នុងគួរអានចង់និយាយអំពីបុគ្គលដែលទទួលការបើកឲ្យដឹងពីអល់ឡោះហ្ទ៍ﷻ តាមរយៈមធ្យោបាយផ្សេងៗ ហើយផ្ទេរដំណឹងដែលគេបានបើកឲ្យខ្លួនដឹងនោះឲ្យទៅបណ្តាមនុស្សដោយមិនឆ្លងកាត់តាមមនុស្សឯទៀតទេ ។ អស់លោកអ្នកជំនាញអក្សរសាស្ត្របានឲ្យអត្ថន័យពាក្យនេះថា៖

«إنّهُ مُؤدّ مِنَ اللهِ بِلا واسِطَةٍ مِنَ الْبَشَرِ»

*"សាស្តាជាបុគ្គលដែលផ្ទេរការបើកឲ្យដឹងរបស់ព្រះ ឲ្យទៅបណ្តាមនុស្ស*

[317] បើមូលសព្ទរបស់ពាក្យ *ណាប៊ី* ជាមូលសព្ទអកម្មកិរិយា ន័យរបស់ពាក្យ*ណាប៊ី* គឺន័យទីមួយ បើមូលសព្ទរបស់ពាក្យណាប៊ីជាមូលសព្ទសកម្មកិរិយា ន័យរបស់ពាក្យណាប៊ី គឺន័យទីពីរ (គឺអ្នកប្រកាសដំណឹងសំខាន់ណាស) ។

គួរអានថែងអំពីឥទ្ធិឫទ្ធិអធិធម្មជាតិ របស់បាវបរិសុទ្ធរបស់អល់ឡោះហ្វ៍ﷻ តើដែលយើងជឿអាយ៉ាស់ទាំងនេះ ដែលស្ដីអំពីឥទ្ធិពលអស្ចារ្យរបស់សិរីមន្តជំនិតរបស់អល់ឡោះហ្វ៍ﷻនោះជាអំពើហ៊ុនហាយស្ហ៊ីរិក ឬជាការប្រឌិតកាឡៃក្នុងសាសនាទេ ?

ច្បាស់ណាស់ថា ជឿលើឥទ្ធិឫទ្ធិអស្ចារ្យរបស់បាវជំនិតរបស់អល់ឡោះហ្វ៍ﷻនោះមិនបានសេចក្ដីថាចាត់ទុកបាវបរិសុទ្ធទាំងនេះជាព្រះ ឬជាម្ចាស់ទង្វើរបស់ព្រះនោះទេ ។ បើជឿដូច្នេះមែន បានសេចក្ដីថាបាវបរិសុទ្ធទាំងនេះជាព្រះនិងជាម្ចាស់ ដូច្នេះគួរអានចាត់ទុកព្រះសាស្ដាﷺដូចជា មូសាعليه السلام, អ៊ីសាعليه السلام, ស្វឡៃម៉ានعليه السلام និងព្រះសាស្ដាឯទៀតជាដើមជាព្រះ ថ្វីដ្បិតតែមុស្លីមទាំងអស់ដឹងច្បាស់ថា ព្រះមហាគម្ពីរគួរអានចាត់ទុកបុគ្គលជំនិតរបស់អល់ឡោះហ្វ៍ﷻទាំងនេះជាបាវបម្រើបរិសុទ្ធ ។

អាស្រ័យហេតុនេះ យើងឃើញច្បាស់ថាជំនឿលើឥទ្ធិឫទ្ធិអស្ចារ្យរបស់បុគ្គលជំនិតរបស់អល់ឡោះហ្វ៍ﷻ ឥទ្ធិឫទ្ធិដែលគេចាត់ទុកថាឥទ្ធិឫទ្ធិដែលចេញមកពីព្រះមហិទ្ធិឫទ្ធិឥតប្រៀបបានរបស់អល់ឡោះហ្វ៍ﷻ ហើយបុគ្គលជំនិតរបស់អល់ឡោះហ្វ៍ﷻជាអ្នកសម្ដែងឲ្យឃើញឥទ្ធិឫទ្ធិនេះ នោះមិនត្រឹមតែពុំមែនជាអំពើហ៊ុនហាយស្ហ៊ីរិកប៉ុណ្ណោះទេ តែវាថែមទាំងសមស្របនឹងទ្រឹស្ដីឯកទិទេពនិយមពិតប្រាកដទៀតផង បានសេចក្ដីថាយើងចាត់ទុកថាឥទ្ធិឫទ្ធិទាំងនេះមកពីអល់ឡោះហ្វ៍ﷻតែមួយគត់ ហើយយើងចាត់ទុកព្រះអង្គﷻជាប្រភពនៃឥទ្ធិឫទ្ធិនិងចលនាទាំងអស់ ។

## សំណួរ ៣៥ - យោលតាមទ្រឹស្ដីស្ហ៊ីអាស់ ហេតុអ្វីឋានៈអ៊ីម៉ាម៉ាស់ខ្ពស់ជាងឋានៈសាស្ដា(នូប៊ូវ៉ាស់) ?



## -អត្ថន័យរបស់ ហាឌីស្ហ អាស្ស-ស្សាក៏ឡៃន៍ (ហាឌីស្ហស្ដីអំពីវត្ថុសំខាន់ពីរ)

ព្រោះតែព្រះសាស្ដាﷺបានថែងអំពី *អ៊ីតរ៉ោះត៍* (សន្តតិវង្ស) គួបនឹងគួរអាន ដោយពិពណ៌នាថាទាំងពីរនេះ ជាព្រះអាជ្ញាធររបស់អល់ឡោះហ្វ៍ﷻសម្រាប់អ៊ុមម៉ាត់ គេអាចធ្វើសេចក្ដីសន្និដ្ឋានបានពីរគឺៈ

១. សម្ដីរបស់ព្រះសន្តតិវង្ស (អ៊ីតរ៉ោះត៍) របស់ព្រះសាស្ដាﷺ ដូចគួរអានផ្ទាល់នោះដែរ ជាអាជ្ញាធរ (ហ៊ុជ្ជ៉ាស់) ។ ដូច្នេះក្នុងរឿងសាសនា - ផ្នែកមនោគមនិងផ្នែកធម្មសាស្ត្រ - ត្រូវតែគោរពតាមទាំងពីរនេះ ហើយដោយមានអាជ្ញាធរដែលត្រូវតែអនុវត្តិតាមនោះហើយ គេមិនត្រូវបែរចេញទាំងពីរនេះទៅអនុវត្តិតាមអ្វីផ្សេងទេ ។

ទោះបីព្រះសាស្ដាﷺចូលទិវង្គតក៏ដោយ មុស្លីមបានបែកបាក់គ្នារឿងខ៊ុលីហ្វាស់និងរឿងដឹកនាំការនយោបាយរបស់អ៊ុមម៉ាត់ ហើយបានទៅជាពីរក្រុម ក្រុមនីមួយៗមានហេតុផលនិងមូលដ្ឋាន ពួកគេមិនត្រូវ ខ្វែងគំនិតគ្នារឿងអាជ្ញាធរផ្នែកបញ្ញារបស់អាស្ហលុល-បៃត៍عليهم السلام ទេ ព្រោះមុស្លីមទាំងអស់អះអាងទទួលស្គាល់ថា ហាឌីស្ហ អាស្ស-ស្សាក៏ឡៃន៍ ជាហាឌីស្ហពិតមិនក្លែងក្លាយដែលចាត់ទុកគួរអាន និងអាស្ហលុល-បៃត៍عليهم السلامរបស់ ព្រះសាស្ដាﷺជាអាជ្ញាធរផ្នែកជំនឿនិងផ្នែកច្បាប់ បើអ៊ុមម៉ាត់អ៊ីស្លាមគោរពហាឌីស្ហនេះ ទំហំអសទិសភាពនឹងរួមតូច ហើយវានឹងបើកផ្លូវទៅរកឯកភាពមុស្លីម ។

២. គួរអាន ព្រះរាជបន្ទូលរបស់អល់ឡោះហ្វ៍ﷻ ត្រូវអភិរក្សចាកផុតពីការផ្គាំផ្គងនិងកំហុស ។ ហេតុដូច្នេះ តើអាចមានការផ្គាំផ្គងម្ដេចបាន ពេល

អល់ឡោះហ្ទ៍عز وجلមានព្រះរាជបន្ទូលអំពីគួរអាននោះថា៖

لَّا يَأْتِيهِ ٱلْبَٰطِلُ مِنۢ بَيْنِ يَدَيْهِ وَلَا مِنْ خَلْفِهِۦ ۖ تَنزِيلٌ مِّنْ حَكِيمٍ حَمِيدٍ

*វិរុទ្ធភាពមិនអាចជ្រៀតចូលទៅក្នុងនោះបានឡើយ ទាំងកាលមុនទាំងកាលក្រោយ ។ [ពីព្រោះនេះគឺ]ការបើកឲ្យដឹងដែលមកពី[អល់ឡោះហ្ទ៍] ព្រះមុនិរាជ ព្រះជាទីគោរពសក្ការៈ (៤១:៤២) ។*[28]

បើគួរអានជ្រះស្អាតពីការផ្ដាំផ្ដង ដែគួនិងសមភាគីរបស់គួរអាន ពោលគឺ *អ៊ីតព៉េះត្វ៍* ក៏ត្រូវតែជ្រះស្អាតពីការផ្ដាំផ្ដងដែរ ព្រោះមិនត្រឹមត្រូវទេដែលផ្ដួបបុគ្គលផ្ដាំផ្ដងឬប្រជាជនផ្ដាំផ្ដងជាមួយគួរអាននោះ ។

ហាឌីស្ទនេះជាសាក្សីបញ្ជាក់ថា បុគ្គលទាំងអស់នោះជ្រះស្អាតពីមន្ទិលគ្រប់បែបយ៉ាង ។ ត្រូវកត់សម្គាល់ថា អវិរុទ្ធភាព (عِصْمَة) នោះមិនមែនឯកសិទ្ធិពិសេសសម្រាប់តែព្រះសាស្ដាﷺមួយទេ ។ វាមិនមែនជាការមិនអាចទៅរួចទេដែលបុគ្គលអាចរួចផុតពីបាបនោះ ទោះបីបុគ្គលនោះ ប្រុសក្ដី ស្រីក្ដី មិនមែនសាស្ដាក៏ដោយ ។ អាយ៉ាស់ុតទៅនេះជាសំអាង ។

إِنَّ ٱللَّهَ ٱصْطَفَىٰكِ وَطَهَّرَكِ وَٱصْطَفَىٰكِ عَلَىٰ نِسَآءِ ٱلْعَٰلَمِينَ ﴿٤٢﴾

*...អល់ឡោះហ្ទ៍បានជ្រើសរើសនាង បានជម្រះបន្សុទ្ធនាង (គឺព្រះអង្គបានបង្កើតនាងមកបរិសុទ្ធស្រេចហើយ) ។ ព្រះអង្គបានជ្រើសរើសនាងលើបណ្ដានារីក្នុងលោក (៣:៤២) ។*[29]

[28] ស៊ូរ៉ោះត្វ៍ ហ្វ៊ូស្សិឡាត់ 41:42 ។

[29] ស៊ូរ៉ោះត្វ៍ អាលី អ៊ីមរ៉ន 3:42 ។



*អាស្រ័យការអនុញ្ញាតរបស់អល់ឡោះហ្ទ៍ រូបសត្វស្លាបនោះនឹងទៅជាសត្វស្លាបមានជីវិត ។ ខ្ញុំនឹងព្យាបាលមនុស្សខ្វាក់ភ្នែកនិងមនុស្សកើតឃ្លង់ឲ្យជា ខ្ញុំនឹងធ្វើឲ្យមនុស្សស្លាប់រស់ឡើងវិញ អាស្រ័យការអនុញ្ញាតរបស់អល់ឡោះហ្ទ៍ ៣:៤៩ ។"*[315]

## ៣. ឥទ្ធិពលអធិធម្មជាតិរបស់ណាប៊ីស៊ូឡៃម៉ាន﵇

ព្រះគម្ពីរគួរអាន ចែងអំពីឥទ្ធិឫទអធិធម្មជាតិរបស់ណាប៊ីស៊ូឡៃម៉ាន﵇ថា៖

وَوَرِثَ سُلَيْمَٰنُ دَاوُۥدَ ۖ وَقَالَ يَٰٓأَيُّهَا ٱلنَّاسُ عُلِّمْنَا مَنطِقَ ٱلطَّيْرِ وَأُوتِينَا مِن كُلِّ شَىْءٍ ۖ إِنَّ هَٰذَا لَهُوَ ٱلْفَضْلُ ٱلْمُبِينُ

*"ស៊ូឡៃម៉ានបានទទួលកេរមរតកពីដាវុដ ហើយគេបានថា៖ "មនុស្សទាំងឡាយអើយ គេបានបង្ហាត់យើងឲ្យចេះភាសាសត្វស្លាប ហើយគេបានប្រទានឲ្យយើងនូវសព្វសារពើ ។ នេះគឺព្រះគុណូបការៈ[របស់អល់ឡោះហ្ទ៍]ដ៏ជាក់ស្ដែង ១៧:១៦ ។"*[316]

ពិតប្រាកដណាស់ ធ្វើឲ្យទឹកផុសចេញពីផ្ទាំងថ្មដោយណាប៊ីមូសា﵇ ធ្វើឲ្យសត្វស្លាបធ្វើអំពីដីឥដ្ឋមានជីវិត ធ្វើឲ្យមនុស្សឈឺដែលមិនអាចជាបានទៅជាសះស្បើយនិងធ្វើឲ្យមនុស្សស្លាប់រស់ឡើងវិញ ដោយណាប៊ីអ៊ីសា﵇ ញាណប្រាជ្ញានិងការចេះភាសាសត្វស្លាបរបស់ណាប៊ីស៊ូឡៃម៉ាន﵇នោះជាព្រឹត្តិការណ៍អស្ចារ្យ ចាត់ទុកជាឥទ្ធិឫទ្ធអធិធម្មជាតិ ។

[315] ស៊ូរ៉ោះត្វ៍ អាលី អ៊ីមរ៉ន 3:49 ។

[316] ស៊ូរ៉ោះត្វ៍ អាន់-ណាំល៍ 27:16 ។

ព្រះមហាគម្ពីរអ៊ីស្លាមបានថែងយ៉ាងជាក់ច្បាស់ នូវព្រះនាមរបស់បាវបរិសុទ្ធដែលប្រកបដោយឥទ្ធិឫទ្ធិខ្លាំងពូកែ អាស្រ័យការអនុញ្ញាតរបស់អល់ឡោះហ្ជ័ﷻ ។ យើងសូមលើកឡើងនូវព្រឹត្តិការណ៍ល្បីៗ ។

## ១. ឥទ្ធិពលអធិធម្មជាតិរបស់ណាបីមូសាعليه السلام

អល់ឡោះហ្ជ័ﷻបានបញ្ជាឲ្យណាបីមូសាعليه السلام វាយថ្មដោយដំបងព្រះអង្គعليه السلام ដើម្បីនឹងឲ្យទឹកផុសឡើង គឺ៖

وَإِذِ ٱسْتَسْقَىٰ مُوسَىٰ لِقَوْمِهِۦ فَقُلْنَا ٱضْرِب بِّعَصَاكَ ٱلْحَجَرَ ۖ فَٱنفَجَرَتْ مِنْهُ ٱثْنَتَا عَشْرَةَ عَيْنًا ۖ

*"គ្រាដែលមូសាបានបួងសួងសូមទឹកឲ្យប្រជារាស្ត្រគេ យើងមានតម្រាស់ថា៖ "ចូរអ្នកយកដំបងអ្នកវាយលើផ្ទាំងសិលាទៅ ។" ដប់ពីរប្រភពទឹកបានផុសចេញមកពីផ្ទាំងថ្មនោះ ២:៦០ ។"*[314]

## ២. ឥទ្ធិពលអធិធម្មជាតិរបស់ណាបីអ៊ីសាعليه السلام

គួរអានបានរាយការណ៍អំពីឥទ្ធិពលអស្ចារ្យរបស់ណាបីអ៊ីសាعليه السلام ច្រើនគ្រា ។ យើងសូមលើកឡើងនូវព្រឹត្តិការណ៍មួយគឺ៖

أَنِّي قَدْ جِئْتُكُم بِـَٔايَةٍ مِّن رَّبِّكُمْ أَنِّيٓ أَخْلُقُ لَكُم مِّنَ ٱلطِّينِ كَهَيْـَٔةِ ٱلطَّيْرِ فَأَنفُخُ فِيهِ فَيَكُونُ طَيْرًۢا بِإِذْنِ ٱللَّهِ ۖ وَأُبْرِئُ ٱلْأَكْمَهَ وَٱلْأَبْرَصَ وَأُحْيِ ٱلْمَوْتَىٰ بِإِذْنِ ٱللَّهِ ۖ

*"ខ្ញុំនឹងសូនរូបសត្វស្លាបពីដីឥដ្ឋ ហើយខ្ញុំនឹងផ្លុំទៅលើរូបសត្វនោះ*

[314] ស៊ូរ៉ោះត៍ អាល់-បាក៏រ៉ោះត៍ 2:60 ។



ហ្វាដ្ជ៍រ៉ោះត៍ (ព្រះនាង) ម៉ារយ៉ាំជ្រះស្អាតពីបាបទោះបីព្រះនាងមិនមែនសាស្តាក៏ដោយ ។

## សំណួរ ២ - "ស្ហ៊ីអាស់" មានន័យថាអ្វី ?

## ចម្លើយ

ក្នុងភាសាអារ៉ាប់ "ស្ហ៊ីអាស់" មានន័យត្រង់ថា "អ្នកតាម" ។ ព្រះមហាគម្ពីរគួរអានថែងថា៖

وَإِنَّ مِن شِيعَتِهِۦ لَإِبْرَٰهِيمَ ﴿٨٣﴾

*ពិតមែន អ៊ីបរ៉ហ៊ីមជាម្នាក់ដែលនៅក្នុងបក្ស (គឺស្ហ៊ីអាស់) របស់គេ (៣៧:៨៣) ។*[30]

តែមុស្លីមប្រើពាក្យ "ស្ហ៊ីអាស់" ដើម្បីហៅមនុស្សមួយក្រុមដែលជឿថាមុនចូលទិវង្គត ព្រះសាស្តាﷺ បានជ្រើសរើសអ្នកតំណាងព្រះអង្គﷺនិងស្តេចខ៍លិហ្វរបស់មុស្លីមច្រើនលើក ដូចជាក្នុងឱកាសថ្ងៃ "ក៏ទ្យេីរ" ខែស្ហ៊ុលហ៊្ជិច្ច៉ាស់ ថ្ងៃទី ១៨ ឆ្នាំទី ១០ សករាជហ៊្ជិរ៉ោះត៍និងនៅក្នុងមហាសន្និបាត (មុស្លីម) ដ៏សម្បើមមួយជាដើមដែលព្រះអង្គﷺបានតែងតាំងអ្នកតំណាងព្រះអង្គﷺនោះជាអាជ្ញាធរផ្នែកនយោបាយ ផ្នែកបញ្ញានិងផ្នែកសាសនាអត់ពីព្រះអង្គﷺទៅ ។

ដើម្បីអធិប្បាយបំភ្លឺ អត់ពីព្រះសាស្តាﷺទៅ ពួក *មូហាជ៊ីរូន* (مهاجرون)[31]

[30] ស៊ូរ៉ោះត៍ អាស្ស-ស្វហ្វហ្វាត 37:83 ។

[31] មូហាជ៊ីរូន គឺងារដែលគេហៅពួកមុស្លីមស្រុកម៉ាក់កាស់ដែលបានភៀសខ្លួនជាមួយព្រះសាស្តាﷺទៅឯស្រុក ម៉ាឌីណាស់ ។

និងពួក *អាន់ស្វារ (أنصار)* [32] បែកគ្នាជាពីរក្រុម គឺៈ

១. ក្រុមមួយជឿថា រ៉សូលុលឡោះហ្ ﷺ មិនមែនមិនដឹងរឿងខ៊ូលីហ្វាស់ទេ ហើយព្រះអង្គ ﷺ បានតែងតាំងអាលី អ៊ីបនូ អាប៊ី តន់លិប صلوات الله عليه والسلام - បុគ្គលដំបូងបង្អស់ដែលជឿព្រះអង្គ ﷺ - ជាអ្នកជំនួសព្រះអង្គ ﷺ ។

ក្រុមនេះមានពួកមូហាជិរីននិងពួកអាន់ស្វារ ជាមួយមេដឹកនាំ បានីហាស៊ីម[33] ទាំងអស់ និងបណ្ដាសាវក (ស្វ៉ហាបាស់ صحابة)[34] ល្បីៗមួយចំនួន ដូចជា សាល់-ម៉ាន អាល់-ហ្វារសុី (سلمان الفارسي), អាប៊ូ ស៊ារ៍ (أبو ذر الغِفاري), មីក្វដាដ់ (مقداد), ខាប់បាប់ អ៊ីបនូ អាល់-អារ៉ត់ (خباب بن الأرت) ។ល។ បុគ្គលទាំងអស់នេះមានជំនឿមាំ ហើយគេហៅបុគ្គលទាំងអស់នេះថា "ស៊ីអាស់របស់អាលី صلوات الله عليه والسلام" ។

តាមពិត ព្រះសាស្ដា ﷺ តែម្ដងជាអ្នកប្រើពាក្យនេះក្នុងសម័យព្រះអង្គ ﷺ ដើម្បីហៅបណ្ដាអ្នកតាម ព្រះអគ្គមហាប្រមុខរបស់អ្នកមានជំនឿជ្រះថ្លា صلوات الله عليه والسلام ។ ក្នុងពេលដែលព្រះអង្គ ﷺ ចង្អុលអាលី អ៊ីបនូ អាប៊ី តន់លិប صلوات الله عليه والسلام ព្រះអង្គ ﷺ មានព្រះវចនៈថាៈ

[32] អាន់ស្វារ គឺងារដែលគេហៅពួកមុស្លីមស្រុកម៉ាឌីណាស់ដែលបានទទួលព្រះសាស្ដា ﷺ និងពួកមុស្លីមស្រុកម៉ាក់កាស់ ដែលបានភៀសខ្លួនមកម៉ាឌីណាស់ ។

[33] បានី ហាស៊ីម គឺកុលសម្ព័ន្ធនៅស្រុកម៉ាក់កាស់របស់ព្រះសាស្ដា ﷺ និងបណ្ដាកូនចៅព្រះអង្គ ﷺ ។

[34] សាវក (ស្វ៉ហាបាស់ صحابة) គឺបណ្ដាសាវករបស់ព្រះសាស្ដា ﷺ ។ កាលពីដើមពាក្យនេះប្រើសម្រាប់តែមិត្តជំនិតរបស់ព្រះអង្គ ﷺ ប៉ុណ្ណោះដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយព្រះអង្គ ﷺ ។ ក្រោយមក ពាក្យនេះត្រូវពង្រីកដើម្បីរាប់បញ្ចូលបណ្ដាអ្នកមានជំនឿដែលគ្រាន់តែបានឃើញព្រះអង្គ ﷺ ទោះបីអស់មួយរយៈពេលតូចឬកាលពីដើមក៏ដោយ ។



២. ជំនឿលើឥទ្ធិពលអធិធម្មជាតិរបស់សិរីមន្ត ជំនិតរបស់អល់ឡោះហ្ عز وجل ដោយជឿជាក់ថា ឥទ្ធិពលនេះចេញមកពីព្រះមហិទ្ធិឫទ្ធិរបស់អល់ឡោះហ្ عز وجل ហើយជឿជាក់ថាឥទ្ធិពលនេះកើតមានឡើងតាមការអនុញ្ញាតរបស់អល់ឡោះហ្ عز وجل តាមរយៈសិរីមន្តជំនិតរបស់អល់ឡោះហ្ عز وجل ។ ការពិត សិរីមន្តជំនិតរបស់អល់ឡោះហ្ عز وجل ទាំងនេះមិនស្វ័យភាពពីអល់ឡោះហ្ عز وجل ទេ តែអាស្រ័យលើអល់ឡោះហ្ عز وجل ទាំងស្រុង ទាំងនៅក្នុងជីវិតរស់នៅ ទាំងនៅក្នុងការអនុវត្តិឥទ្ធិពលអធិធម្មជាតិនេះ ។

ហេតុដូច្នេះ យើងមិនចាត់ទុកសិរីមន្តជំនិតរបស់អល់ឡោះហ្ عز وجل ជាអល់ឡោះហ្ عز وجل ទេ ព្រោះបាវបរិសុទ្ធទាំងនេះធ្វើអ្វីតាមតែការអនុញ្ញាតរបស់អល់ឡោះហ្ عز وجل ទេនិងតាមតែព្រះឆន្ទៈព្រះអង្គ عز وجل ប៉ុណ្ណោះ ។

ព្រះគម្ពីរគួរអានថែងអំពីរឿងនេះថាៈ

وَمَا كَانَ لِرَسُولٍ أَن يَأْتِيَ بِآيَةٍ إِلَّا بِإِذْنِ اللَّهِ

*"សាស្ដាពុំមានសិទ្ធិនាំសញ្ញា [ឬអព្ភូតហេតុ] មកដោយឥតបានទទួលការអនុញ្ញាតពីអល់ឡោះហ្ទើយ ១៣:៣៨ ។"* [313]

អាយ៉ាស់នេះបញ្ជាក់យ៉ាងច្បាស់ថាជំនឿនេះ មិនត្រឹមតែពុំមែនជាអំពើហ៊ុនហាយស៊ីរិកទេ តែវាថែមទាំងសមស្របនឹងទ្រឹស្ដីឯកទិទេពទៀតផង ។

## ឥទ្ធិពលរបស់សិរីមន្តជំនិតរបស់អល់ឡោះហ្ عز وجل យោលតាមគួរអាន

[313] ស៊ូរ៉ោះត៍ អារ-រ៉ក់ដ៍ 13:38 ។

បំណាង ។ សមត្ថភាពនោះមានពីរប្រភេទគឺ៖
១. សមត្ថភាពនេះអាចជាសមត្ថភាពផ្នែកសម្ភារៈឬផ្នែកកម្លាំងកាយ ដូចជាករណីសូមឲ្យគេហុចកែវទឹកឲ្យខ្លួនជាដើម ។
២. ឬសមត្ថភាពនោះអាចជាកម្លាំងអាថ៌កំបាំង ដែលហួសក្រុបខណ្ឌសម្ភារៈនិងកាយ ដូចជាករណីបាវស្មោះត្រង់របស់អល់ឡោះហ្ទ៍عزوجل អ៊ីសាអ៊ីបន្ទូ ម៉ាយ៉ាំعليهم السلامជាដើមដែលមានសមត្ថភាពធ្វើឲ្យអ្នកជម្ងឺដែលមិនអាចជាបាននោះទៅជាសះស្បើយអាស្រ័យខ្យល់ផ្លុំរបស់ព្រះអង្គعليه السلام ។

ជំនឿទៅលើឥទ្ធិពលបរមត្ថវិជ្ជាប្រភេទនេះ ដែលអាស្រ័យនៅលើព្រះមហិទ្ធិឫទ្ធិនិងព្រះឆន្ទៈរបស់អល់ឡោះហ្ទ៍عزوجلនោះ ជាការធម្មតាទេហើយក៏ពុំមែនអំពើហ៊ុនហាយស្ហ៊ីរិកទេ ពីព្រោះ អល់ឡោះហ្ទ៍عزوجلដែលប្រទានកម្លាំងកាយឲ្យមនុស្សនោះ អាចប្រទានឥទ្ធិឫទ្ធិអធិធម្មជាតិឲ្យបាវសិរីមន្តរបស់ព្រះអង្គعزوجلបានដែរ ។

ដើម្បីបំភ្លឺចម្លើយនេះ យើងសូមឆ្លើយថាជំនឿលើឥទ្ធិឫទ្ធិអធិធម្មជាតិរបស់សិរីមន្តជំនិតរបស់អល់ឡោះហ្ទ៍عزوجلនោះមានពីរចំណុចគឺ៖
១. ជឿលើឥទ្ធិពលអធិធម្មជាតិរបស់បុគ្គលណាមួយ ដែលយើងគិតថាជាស្វ័យភាពដាច់ឡែកហើយជាប្រភពនៃឥទ្ធិពលនោះ ស្មើនឹងជឿថាបុគ្គលនោះជាម្ចាស់ទង្វើរបស់ព្រះ ។

ពិតប្រាកដណាស់ បើយើងគិតថាឥទ្ធិពលធអិធម្មជាតិនេះមិនជាប់ទាក់ទងនិងព្រះមហិទ្ធិឫទ្ធិរបស់អល់ឡោះហ្ទ៍عزوجلទេនោះ វាជាអំពើហ៊ុហាយស្ហ៊ីរិកពីព្រោះ ក្នុងករណីនេះ បុគ្គលផ្សេងពីអល់ឡោះហ្ទ៍عزوجلជាប្រភពនៃឥទ្ធិពលនោះ ។ ទម្លាក់ទង្វើរបស់អល់ឡោះហ្ទ៍عزوجلទៅលើបុគ្គលនោះ ថ្វីដ្បិតតែព្រះម្ចាស់ពិភពទាំងពួងعزوجلមួយគត់ជាប្រភពនៃឥទ្ធិពលទាំងអស់ ។



"والذي نفسي بيده إن هذا وشيعته لهم الفائزون يوم القيامة."

*"សូមស្បថចំពោះព្រះដែលក្តាប់ជីវិតខ្ញុំ ពិតណាស់ បុរសនេះ (អ៊ុាលី) និងស្ហ៊ីអ៊ុាស្ហ៍របស់គេជាអ្នកមានជ័យជំនះក្នុងថ្ងៃរស់ពីស្លាប់វិញ ។"*[35]

ហេតុដូច្នេះ "ស្ហ៊ីអ៊ុាស្ហ៍" មានន័យថាក្រុមមុស្លីមដើមសម័យអ៊ីស្លាមដែលដោយហេតុតែជឿថា *វីឡាយ៉ាស្ហ៍* (អាណាព្យាបាលភាព)[36] ស្ថិតនៅលើការបើកឲ្យដឹង (តាន់ស៊ីស៊ី ពោលគឺ ត្រូវអល់ឡោះហ្ទ៍عزوجلជ្រើសរើស) នោះត្រូវគេហៅដូចនេះឯង ហើយក្រុមនេះនៅតែជឿព្រះរាជកុលដ្ឋានរបស់ព្រះសាស្តាصلى الله عليه وآله وسلم (អាស្ហ៍លុល-បៃត៍عليهم السلام) រហូតមកដល់សព្វថ្ងៃ ។

ចាប់ពីនេះ យើងយល់ឋានៈនិងមុខងាររបស់ស្ហ៊ីអ៊ុាស្ហ៍ អាស្រ័យហេតុនេះសម្តីគ្មានហេតុផលរបស់បុគ្គលអវិជ្ជា ឬបុគ្គលបង្កគំនុំមួយចំនួនដែលថាស្ហ៊ីអ៊ុាស្ហ៍បានកើតឡើងក្នុងពេលក្រោយនោះ ទៅជាច្បាស់ក្រឡែតឡើង ។ ព័ត៌មានបន្ថែមអំពីប្រវត្តិស្ហ៊ីអ៊ុាស្ហ៍ សូមមើលសៀវភៅ អាស្ហ៍ល៍ អាស្ហ៍-ស្ហ៊ីអ៊ុាស្ហ៍ វ៉ា អ៊ូស៊្ហូលូហ្ទា (اصل الشيعه و اصولها), អាល់-មូរ៉ យ៉ាជ៉ុាអ៊ុាត់ (المراجعات) និង អាក៉ុយ៉ាន់ អាស្ហ៍-ស្ហ៊ីអ៊ុាស្ហ៍ (أعيان الشيعة)

---

[35] សូមមើលសៀវភៅរបស់លោក យ៉ាឡាល់ អាដ្ឌ៍-ឌីន អាស់-ស៊ូយូទី ( جلال الدين السيوطي) *អាដ្ឌ៍-ឌួរ អាល់-ម៉ាន់ស៊្ហូរ* (الدر المنثور) ជុំទី ៦ ក្នុងវគ្គអធិប្បាយស៊ូរ៉ោះត៍អាល់-បៃយីណាស្ហ៍ ៩៨:៧ إِنَّ ٱلَّذِينَ ءَامَنُواْ وَعَمِلُواْ ٱلصَّٰلِحَٰتِ أُوْلَٰٓئِكَ هُمْ خَيْرُ ٱلْبَرِيَّةِ "រីឯជនទាំងឡាយណាដែលមានសទ្ធា[ចំពោះអល់ឡោះហ្ទ៍] ធ្វើអំពើល្អពិតណាស់ ជនទាំងនោះជាសត្វលោកប្រសើរ បំផុត ។"

[36] បើចង់បានព័ត៌មានលំអិតអំពីវីឡាយ៉ាស្ហ៍និងវ៉ាលី
សូមមើលសៀវភៅរបស់លោក Murtada Mutahhari, Wilayah: The Station of the Master, trans. Yahya Cooper (Tehran: World Organization for Islamic Services, 1982).

២. ក្រុមមួយទៀតជឿថាឋានៈស្តេចខ៍្លីហ្វនៅលើការបោះឆ្នោត ។ ហេតុដូច្នេះ ពួកគេស្មោះស្ម័គ្រ និងចុះចូលខ្លួនចំពោះ អាប៊ូ បាការ ហើយក្រោយមកគេហៅពួកគេនេះថា "អាស្ហ់ឡាល់-ស៊ុនណាស្ហ៍" ឬ "ស៊ុននី" ។

លទ្ធផលចុងក្រោយ ទោះបីនិកាយមុស្លីមទាំងពីរនេះមានមតិស្របគ្នាច្រើនពាក់ព័ន្ធនឹងឫសគល់សាសនាក៏ដោយ តែពួកគេមានផ្ទត់គំនិតខុសគ្នារឿងខ៍្លីហ្វាស្ហ៍និងរឿងស្នងព្រះសាស្តាﷺ ។ សមាជិកក្រុមទាំងពីរជាពួកមូហ្វាឃ្យីរូននិងពួកអាន់ស្វារ ។

## សំណួរ ៣ ៖ ហេតុអ្វីចាត់ទុក អ៊ុលី អ៊ីបនូ អាប៊ី ត៍្ហលិប صلوات الله عليه والسلام ជា វ៉ាស្ហ៊ី (អ្នកធ្វើតាមមរតកសាសន៍) និងជាអ្នកស្នងព្រះសាស្តាﷺ ?

## ចម្លើយ

យើងបានអធិប្បាយរួចមកហើយ ស្ហ៊ីអ៊ុស្ហ៍ជឿជាក់ថាឋានៈខ៍្លីហ្វាស្ហ៍ត្រូវកំណត់តាមរយៈការបើកឲ្យដឹង (តាន់ស៊ីស៊ី) ហើយអត់ពីព្រះសាស្តាﷺ ទៅ *អ៊ីម៉ាម៉ាស្ហ៍* (អាណាព្យាបាលភាព) ក្នុងប្រការខ្លះ ស្រដៀងសាស្តាភាព (នូប៊ូវ៉ាស្ហ៍) ដែរ ។

ដូចព្រះសាស្តាﷺត្រូវចាត់តាំងតាមរយៈព្រះបញ្ញត្តិអល់ឡោះហ្វ៍عزوجل *វ៉ាស្ហ៊ី* (អ្នកធ្វើតាមមរតកសាសន៍) របស់ព្រះសាស្តាﷺក៏ត្រូវតែងតាំងដោយអល់ឡោះហ្វ៍عزوجلដែរ ។

ជីវប្រវត្តិរបស់រ៉ស្វូលុលឡោះហ្វ៍ﷺ ជាភ័ស្តុតាងឥតប្រកែកបានសម្រាប់



*ចំពោះអ៊ុម្ម៉ាត់ព្រះអង្គﷺទេនោះ គឺការដុសធ្មេញដោយឈើដុសធ្មេញ (មីសវ៉ាក់ مسواك), ស្ហ៍ឡាត់ អាល់-វ៉ាតៀរ និង ពលីទាន ។"*

*គេបានរាយការណ៍តមកពីព្រះសាស្តាﷺអល់ឡោះហ្វ៍عزوجلថា ព្រះអង្គﷺមានព្រះវចនៈថា៖ "អ្វីដែលជាករណីយកិច្ចចំពោះខ្លួនខ្ញុំﷺនោះមានបីគឺ៖ ដុសធ្មេញជាមួយឈើមីសវ៉ាក់, ស្ហ៍ឡាត់អាល់-វ៉ាតៀរ និងធ្វើពលីទាន ។"*[312]

ដូច្នេះ ស្ហ៍ឡាត់អាល់-វ៉ាតៀរ យោលតាមទ្រឹស្តីស្ហ៊ីអ៊ុស្ហ៍ ជាករណីយកិច្ច (គឺវ៉ាយ៉ីប) សម្រាប់ព្រះសាស្តាﷺ ហើយជាស៊ូណាត់សម្រាប់មុស្លីមឯទៀត ។

## សំណួរ ៣៩ - តើជឿថាអស់ព្រះសន្តបុគ្គលជំនិតរបស់អល់ឡោះហ្វ៍عزوجل (អៅលីយ៉ាអ៍អល់ឡោះហ្វ៍عزوجل) មានឥទ្ធិឫទ្ធិនោះជាបទហ៊ុនហាយ (គឺស្ហ៊ីរិក) ទេ ?

## ចម្លើយ

ពិតប្រាកដណាស់ថាពេលគេសូមឲ្យអ្នកណាមួយធ្វើអ្វីមួយឲ្យខ្លួន គេជឿជាក់ថាអ្នកនោះមានសមត្ថភាពធ្វើឲ្យសំណូមពររបស់ខ្លួនបានសម្រេចដូច

312 សូមមើលសៀវភៅរបស់ អ៊ុឡាម៉ាស្ហ៍ អាល់-ហ៊ីល្លី (العلامة الحلي) *តាស្ហ៍គីរ៉ោះត៍ អាល់-ហ្វ៊ុក៍ហ្វាអ៍ (تَذكِرَةُ الفُقَهاء)* ដុំទី ២ "គីតាប អាន់-នីកាស្ហ៍" អារម្ភកថាបោះពុម្ពលើកទី ៤ ។

អ៊ីស្លាមទាំងអស់នៅក្នុងរដ្ឋធម្មនុញ្ញសាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់ ។

## សំណួរ ៣៣ - តើស្ហ៊ីអុាស្ន៍ចាត់ទុកស្ហ៍ឡាត់អាល់-វ៉ាតៀរជាស្ហ៍ឡាត់វ៉ាឃ៊ីបទេ ?

## ចម្លើយ

ស្ហ៍ឡាត់ *អាល់-វ៉ាតៀរ* នៅក្នុងចំណោមស្ហ៍ឡាត់ ណាហ្វីឡាស្ន៍ បានសេចក្ដីថាស្ហ៍ឡាត់មិនចាំបាច់ពេលយប់ ហើយវាជាទង្វើស្ងួណាត់មួយដែលមុស្លីមទាំងឡាយដែលតាមព្រះសាស្ដាﷺនោះតែងតែធ្វើ តែអស់លោកអ្នកនីតិសាស្ត្រស្ហ៊ីអុាស្ន៍ (ហ្វ៊ូកហ៊្កហ្វា) ដោយផ្អែកលើព្រះគម្ពីរគួរអាន និងព្រះស៊ុនណាស្ន៍ព្រះសាស្ដាﷺមានប្រសាសន៍ថាស្ហ៍ឡាត់ *អាល់-វ៉ាតៀរ* មិនមែនជាទង្វើចាំបាច់ (វ៉ាឃ៊ីប) សម្រាប់អ្នកណាមួយទេ លើកលែងតែសម្រាប់ព្រះសាស្ដាﷺផ្ទាល់តែម្ដង ។

អុាឡាម៉ាស្ន៍ អាល់-ហ៊ីល្លី (العلامة الحلي) បានរាយការណ៍ចិតសិបលក្ខណៈពិសេសរបស់ព្រះសាស្ដាﷺនៅក្នុងសៀវភៅលោក ដែលមានចំណងជើងថា តាស្ក៍គីរ៉ោះត៍ អាល់-ហ្វ៊ូក៉ហ្វាអ៍ (تَذكِرَةَ الفُقَهاء) លោកបានចាប់ផ្ដើមមានប្រសាសន៍ថា៖

«فامّا الْواجبات عليه دون غيره من امّته امورُ: الف – السّواك، ب – الوتر، ج – الأضحية. روي عنه – صلّى الله عليه (وآله) وسلّم – أنّه قال: ثلاث كتب عليّ ولم تكتب عليكم: السّواك والوتر والاضحية...»

*"អ្វីដែលជាករណីយកិច្ចចំពោះតែព្រះសាស្ដាﷺ មិនមែនជាករណីយកិច្ច*



បញ្ជាក់ជំនឿនេះ ពីព្រោះព្រះអង្គﷺបានតែងតាំង អុាលី(صلوات الله عليه والسلام)ជាអ្នកស្នងព្រះអង្គﷺ (ជាខ៉ូលីហ្វាស្ន៍) ច្រើនឱកាស ។ ត្រង់នេះ យើងសូមលើកយកមកអធិប្បាយតែបីឱកាសទេ ។

## ១. នៅពេលចាប់ផ្ដើមបំពេញបេសកកម្មសាស្ដា

កាលព្រះសាស្ដាﷺបានទទួលមុខការពីអល់ឡោះហ្ន៍(عزّ وجلّ) ឲ្យហៅសាច់សាលោហិតព្រះអង្គﷺមកកាន់លទ្ធិ ជំនឿដែលមានព្រះតែមួយគត់ ដូចអាយ៉ាស្ន៍គួរអានចែងបញ្ជាក់ គឺ៖

وَأَنذِرۡ عَشِيرَتَكَ ٱلۡأَقۡرَبِينَ

*"ចូរអ្នកព្រមាន (ហៅមករកអល់ឡោះហ្ន៍) ញាតិសន្ដានជិតស្និទ្ធបំផុតរបស់អ្នក (២៦:២១៤) ។"* [37]

ព្រះអង្គﷺបានថ្លែងប្រាប់ពួកគេថា៖

فأيكم يوازرني في هذا الأم على أن يكون أخي ووزيري وخليفتي ووصيّي فيكم؟

*"អ្នកណាខ្លះ ក្នុងចំណោមអស់លោក នឹងជួយជ្រោមជ្រែងខ្ញុំក្នុងរឿងនេះ ដើម្បីអ្នកនោះនឹងទៅជាបងប្អូនខ្ញុំ (អាឃ៊ី أخي) ជាមន្ត្រីខ្ញុំ (វ៉ាស៊ីរី وزيري) ជាអ្នកស្នងខ្ញុំ (ខ៉ូលីហ្វាទី خليفتي) និងជាអ្នកធ្វើតាមបណ្ដាំខ្ញុំ (វ៉ាស៊ី وصيّي) ?"*

មានតែម្នាក់ទេដែលបានឆ្លើយតបព្រះរាជអំពាវនាវនេះគឺ អុាលី អ៊ីបនូ អាប៊ី តុ៉លិប(صلوات الله عليه والسلام) ។ បន្ទាប់មក នៅពីមុខសាច់ញាតិព្រះអង្គﷺ រ៉សូលុលឡោះហ្ន៍ﷺមានព្រះវចនៈថា៖

"إن هذا أخي ووصيّي خليفتي فيكم فاسمعوا له وأطيعوه."

[37] សូរ៉ោះត៍ អាស្ន៍-ស្ហ៊ូអុារ៉អ៍ ២៤:២១៤ ។

*"ពិតណាស់ គេ (អ៊ុលី) ជាបងប្អូនខ្ញុំ ជាអ្នកធ្វើតាមបណ្ដាំខ្ញុំនិងជាអ្នកស្នងខ្ញុំក្នុងចំណោមអស់លោក ។ ដូច្នេះ ចូរអស់លោកស្ដាប់គេនិងគោរពបង្គាប់គេ ។"*[38]

## ២. នៅក្នុងសមរភូមិតាប៊ុក (تبوك)

ព្រះសាស្ដា ﷺ បានប្រាប់អ៊ុលី صلوات الله عليه والسلام ថា៖

أما ترضى أن تكون منّي بمنزلة هارون من موسى إلا أنه لا نبيّ بعدي؟

*"អ្នកមិនពេញចិត្តទេ អ្នកនិងខ្ញុំ ដូចហារូននិងមូសាដែរ លើកលែងតែនឹងពុំមានសាស្ដាទេអត់ពីខ្ញុំទៅ ?"*[39]

បានសេចក្ដីថា៖ "ដូចហារូន عليه السلام ជាអ្នកធ្វើតាមបណ្ដាំនិងជាអ្នកស្នងមូសា عليه السلام បន្ទាប់ដែរ អ្នក صلوات الله عليه والسلام ជាអ្នកស្នងខ្ញុំ ﷺ ។"

## ៣. នៅក្នុងឆ្នាំទី ១០ ក្រោយពីបានភៀសខ្លួន

ពេលត្រឡប់មកពីបំពេញពិហ្ជចូលាគ្នា (ហាជ្ជ៉យ៉ាស្ស អាល់-វ៉ាដ្ទាក់

---

[38] សូមមើលសៀវភៅ *តារិក អាត់-ត៉ាបារី (تاريخ الطبري)* ជុំទី ២ ទំព័រ៦២-៦៣ ។ *តារិក អាល់-កាមីល* ជុំទី ២ ទំព័រ ៤០-៤១ ។ *មុសណាដ អាស់ម៉ាដ អ៊ីបនូ ហាន់បាល់* ជុំទី ១ ទំព័រ ១១១ ។ សៀវភៅរបស់លោក អ៊ីបនូ អាប៊ីល-ហាឌីដ (بن ابي الحديد) *ស្ហារហ៍ ណាស្ស៉យ៉ាល់-បាឡាកោះត៍ (شرح نهج البلاغة)* ជុំទី ១៣ ទំព័រ ២១០-២១២ ។

[39] សូមមើលសៀវភៅ *ស៊ីរ៉ោះត៍ អ៊ីបនូ ហ៊ីស្ហាំ (سيرة ابن هشام)* ជុំទី ២ ទំព័រ ៥២០ ។ សៀវភៅរបស់លោក អ៊ីបនូ ហាយ៉ារ (អាល់-អ៊ុស់ក្ខ៍ឡានី) *អាស្ស-ស្វ៉ាអ៊ីក អាល់-មុះហ៍រីកោះត៍ (الصواعق المحرقة)* (បោះពុម្ពលើកទី ២ អេស៊ីបត៍) គឺតាប ៩ វគ្គ ២ ទំព័រ ១២១ ។



២. ការអប់រំនិងការសិក្សាសាសនា
៣. អនុវត្តិកិច្ចផ្ទាល់ការខ្លួន
៤. កិច្ចការសាសនាពិសេស ដូចជា អាពាហ៍ពិពាហ៍ ការលែងលះគ្នា ការស្នងមរតក ជាដើម ។

លើសពីនេះ នៅក្នុងតំបន់ដែលមានប្រជានិករកាន់ម៉ាស្ហ៊ាប់ណាមួយខាងលើនេះ បទបញ្ញា (វិន័យ) ចំពោះតំបន់នោះដាក់អនុម័តដោយក្រុមព្រឹក្សានៃតំបន់នោះចុះសម្រុងនឹងម៉ាស្ហ៊ាប់នោះ រីឯសិទ្ធិរបស់បណ្ដាអ្នកកាន់ម៉ាស្ហ៊ាប់ឯទៀតក៏បានទទួលការគោរពដែរ ។

ដើម្បីបំភ្លឺសំណួរនេះ យើងសូមលើកឡើងនូវ ជំពូក 12 មាត្រា 1 នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់ គឺ៖
"សាសនាផ្លូវច្បាប់របស់អ៊ីរ៉ង់គឺអ៊ីស្លាមក្រោមឱវាទម៉ាស្ហ៊ាប់ ស្ហ៊ីអ៊ុស្ស អ៊ីស្នណា អ៊ុស្ហ់ស្ហារី (شيعة اثناء عشري) (ស្ហ៊ីអ៊ុស្សតាមដប់ពីរអ៊ីម៉ាំ) ។ នេះគឺគោលការណ៍មិនអាចកែប្រែបាន ចំណែកឯម៉ាស្ហ៊ាប់ឯទៀតដូចជាម៉ាស្ហ៊ាប់ហាណាហ្វី, ស្ហាហ្វីអ៊ី, ម៉ាលីគី, ហាន់បាលី និង ស្ហៃឌីត្រូវបានទទួលការគោរពទាំងស្រុង បណ្ដាអ្នកកាន់ម៉ាស្ហ៊ាប់ទាំងនេះមានសេរីភាពពេញទីក្នុងការអនុវត្តិតាមច្បាប់ម៉ាស្ហ៊ាប់ខ្លួន ដូចជាពិធីក្នុងសាសនា ការអប់រំនិងការសិក្សាសាសនា រឿងផ្ទាល់ខ្លួនដូចជាអាពាហ៍ពិពាហ៍ ការលែងលះគ្នា ការស្នងមរតក ឬក្នុងរឿងក្ដីក្ដាំជាដើម ។ គ្រប់តំបន់ដែលមានបណ្ដាអ្នកកាន់ម៉ាស្ហ៊ាប់នោះភាគច្រើន វិន័យច្បាប់របស់តំបន់នោះចុះសម្រុងនឹងម៉ាស្ហ៊ាប់នោះ នៅក្នុងក្របខណ្ឌអំណាចរបស់ក្រុមប្រឹក្សានៃតំបន់នោះ ដោយមានការធានាសិទ្ធិមុស្លីមដែលកាន់ម៉ាស្ហ៊ាប់ឯទៀត ។"

ជំពូកច្បាប់នេះបញ្ជាក់យ៉ាងច្បាស់ នូវការគោរពលក្ខន្តិកម៉ាស្ហ៊ាប់

# លក្ខខណ្ឌសម្រាប់ជ្រើសរើសម៉ាស្ហ៊ាប់យ៉ាក់ហ្វារី

សំណួរឯទៀតដែលត្រូវសួរត្រង់នេះគឺៈ មានលក្ខខណ្ឌអ្វីខ្លះដើម្បីជ្រើសរើសយកម៉ាស្ហ៊ាប់យ៉ាក់ហ្វារីក្នុងចំណោមម៉ាស្ហ៊ាប់អ៊ីស្លាមឯទៀត ជាប្រភព (គឺយកជាគំរូ) នៃច្បាប់និងនៃបទបញ្ញត្តិរបស់ប្រទេស ?

ចម្លើយសំណួរនេះច្បាស់ក្រឡែតតែម្តង គឺៈ ប្រជារាស្ត្រអ៊ីរ៉ង់ភាគច្រើនជាមុស្លីមកាន់ម៉ាស្ហ៊ាប់យ៉ាក់ហ្វារី ពួកគេដកស្រង់ករណីយកិច្ចផ្ទាល់ខ្លួននិងករណីយកិច្ចសហគមន៍ពីម៉ាស្ហ៊ាប់នេះ ។ ដូច្នេះ ពិតប្រាកដណាស់ជម្រើសយកម៉ាស្ហ៊ាប់យ៉ាក់ហ្វារីជាម៉ាស្ហ៊ាប់របស់ប្រទេស ជាផ្លូវច្បាប់នោះជាការធម្មតាទេ នៅក្នុងរដ្ឋធម្មនុញ្ញសាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់នោះហើយជាការចុះសម្រុងគ្នាជាមួយគំរូស្តង់ដារ៍សមហេតុផល និងសមស្របតាមច្បាប់ ។

## ឋានៈរបស់ម៉ាស្ហ៊ាប់អ៊ីស្លាមឯទៀត និងសេចក្តីគោរពចំពោះម៉ាស្ហ៊ាប់ទាំងនោះ

រដ្ឋធម្មនុញ្ញសាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់ ដែលជ្រើសយកម៉ាស្ហ៊ាប់យ៉ាក់ហ្វារីជាម៉ាស្ហ៊ាប់ផ្លូវច្បាប់នោះ តែងតែគោរពនិងផ្តល់កិត្តិយសដល់ម៉ាស្ហ៊ាប់ឯទៀត ដូចជាម៉ាស្ហ៊ាប់ស្ហាហ្វ៊ីអ៊ី, ហាន់បាលី, ហាណាហ្វ៊ី, ម៉ាលីគី និង ស្សៃឌី ជាដើម ។ ការពិត បណ្តាអ្នកកាន់ម៉ាស្ហ៊ាប់ទាំងនេះអាចអនុវត្តិតាមនីតិក្រមហ្វ៊ិក្ហោះត៍របស់ម៉ាស្ហ៊ាប់ខ្លួនបានដោយសេរី ក្នុងវិស័យៈ

១. អនុវត្តិពិធីក្នុងសាសនា



(حجة الوداع)) វិញ នៅកន្លែងមួយដែលគេហៅថា ក៏ដៀរ ឃុម ព្រះសាស្តាصلى الله عليه وآله وسلمរបស់អល់ឡោះហ៍عز وجلបានណែនាំ ឲ្យអង្គប្រជុំ[អ្នកធ្វើពិធីហាច្ជ]មហាធំស្គាល់អាលីصلوات الله عليه والسلامជា *វ៉ាលី* (អាណាព្យាបាល) របស់អ្នកមានសទ្ធាទាំងអស់ប្រុសឬស្រី ថាៈ

"من كُنت مولاه فهذا عليّ مولاه."

*"អ្នកណាក៏ដោយដែលខ្ញុំជាម្ចាស់ (មៅឡា مَوْلَى) អាលីصلوات الله عليه والسلامក៏ជាម្ចាស់របស់អ្នកនោះដែរ ។"*

ចំណុចសំខាន់និងគួរកត់សម្គាល់នោះគឺ ពេលចាប់ផ្តើមថ្លែងសុន្ទរកថាព្រះសាស្តាصلى الله عليه وآله وسلمបានសួរថាៈ

ألست أولى بكم من أنفسكم؟

*"តើខ្ញុំصلى الله عليه وآله وسلمមានអំណាចជាងគេលើអស់លោក ជាងអស់លោកមានអំណាចលើខ្លួនឯងមែនទេ ?"*

មុស្លីមទាំងអស់បានឆ្លើយតបជាឯកច្ឆ័ន្ទថាមែន ។ ហេតុដូច្នេះ ត្រូវកត់សម្គាល់ត្រង់នេះថានៅក្នុងហាឌីស្ហនេះ ព្រះសាស្តាصلى الله عليه وآله وسلمមានព្រះវចនៈថា *"ម៉ៅឡា"* ដោយមានន័យថាអាណាព្យាបាលភាពទាំងស្រុងលើបណ្តាអ្នកមានសទ្ធា ហើយអាចសន្និដ្ឋានបានថាព្រះសាស្តាصلى الله عليه وآله وسلمបានលើកឋានៈអាលីصلوات الله عليه والسلامស្មើឋានៈព្រះអង្គصلى الله عليه وآله وسلم ។ នៅក្នុងថ្ងៃនោះដែរ លោក ហាសាន់ អ៊ីបនូ ស្សាប៊ីត បានចងក្រងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រក៏ដៀរ ឃុមជាកំណាព្យដូចតទៅ ។

يناديهم يوم الغدير نبيّهم بخمّ واسمع بالرّسول مناديا فقال: فمن مولاكم ونبيّكم؟

فقالوا: ولم يدلوا أهناك التعاميا إلهك ومولانا أنت نبيّن ولم تلق منا في الولاية عاصيا

فقال له: قم يا عليّ فإنني رضيتك من بعدي إماماً وهادياً فمن كنت مولاه فهذا ولّيه

فكونوا له اتباع صدق مواليا هناك دعا: اللهم وال وليّه وكن للذي عادى عليّا معاديا.

*"ព្រះសាស្ដារបស់ពួកគេបានប្រកាសប្រាប់ពួកគេក្នុងថ្ងៃ ក៏ដៀរ ឃុម ។ ចូរស្ដាប់សេចក្ដីប្រកាសរបស់ព្រះសាស្ដា ។ ព្រះអង្គមានព្រះវចនៈថា៖ "អ្នកណាជាម្ចាស់ (ម៉ៅឡា) និងជាអាណាព្យាបាល (វ៉ាលី) របស់អស់លោក ?" មិនសម្ដែងអាកប្បកិរិយាព្រងើយកន្ដើយទេ ពួកគេបានទូលថា៖ "ព្រះម្ចាស់របស់ព្រះអង្គជាម្ចាស់ (ម៉ៅឡា) អស់ទូលបង្គំ ហើយព្រះអង្គជាអាណាព្យាបាល (វ៉ាលី) របស់អស់ទូលព្រះបង្គំ ។ ពុំមានអស់ទូលបង្គំ អ្នកណាមួយជំទាស់ព្រះអង្គទេថ្ងៃនេះ ។" បន្ទាប់ពីនោះ ព្រះអង្គមានព្រះវចនៈថា៖ "អាលីអឺយ ចូរអ្នកងើបឡើង ព្រោះខ្ញុំពេញចិត្តដែលអ្នកជាអ៊ីមុាំនិងជាមគ្គុទេសក៏អត់ពីខ្ញុំទៅ ។" [បន្ទាប់មកព្រះអង្គមានព្រះវចនៈថា៖] "ហេតុដូច្នេះ អ្នកណាក៏ដោយដែលខ្ញុំជាម្ចាស់ អាលីក៏ជាម្ចាស់របស់អ្នកនោះដែរ ។ សូមឲ្យអស់លោកជាអ្នកគាំទ្រពិតរបស់ពួកគេ ។" បន្ទាប់មក ព្រះអង្គបួងសួងថា៖ "អល់ឡោះហ្ ﷻ អឺយ សូមព្រះអង្គ ﷻ ជាមិត្តរបស់អ្នកណាដែលជាមិត្តរបស់គេ (អាលី) សូមព្រះអង្គ ﷻ ជាសត្រូវរបស់អ្នកណាដែលជាសត្រូវរបស់គេ ។"[40]*

[40] សូមមើលសៀវភៅរបស់លោក ឃ៊្វារីស្មី អាល់-ម៉ាលីគី *អាល់-ម៉ាណាគ៊ីប (المناقب)* ទំព័រ ៨០ ។ សៀវភៅរបស់លោក ស៊ីបត្ អាល់-យ៉ៅស៊ី *តាស្គីរ៉ោះត្ អាល់-ខ៊្វាស្ស អាល់-អ៊ុមម៉ាស្ (تَذكِرَةُ الخَواصّ مِنَ الأمّة فى ذِكرِ خَصائص الأئمة)* ទំព័រ ២០ ។ សៀវភៅរបស់លោក កាន់ឃ៊ី អាល់-ស្ហាហ៊្វីអ៊ី (گنجي شافعي) *គីហ្វាយ៉ាស្ អាត្-ត៊ូលិប (كِفايَة الطالِب)* ទំព័រ ១៧ និងសៀវភៅច្រើនទៀត ។



# អ៊ីរ៉ង់ ?

## ចម្លើយ

ពិតណាស់ រដ្ឋម្មនុញ្ញសាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់គោរពម៉ាស្ហាប់មុស្លីមទាំងអស់ តែម៉ាស្ហាប់មុស្លីមទាំងអស់ ដូចជាម៉ាស្ហាប់យ៉ាក់ហ្វារី ម៉ាស្ហាប់ម៉ាលីគី ម៉ាស្ហាប់ស្ហាហ្វីអ៊ី ម៉ាស្ហាប់ហាន់បាលី ម៉ាស្ហាប់ហាណាហ្វី ។ល។ មិនមានច្បាប់ដូចគ្នាទេ ទាំងរឿងផ្ទាល់ខ្លួននិងរឿងសហាគមន៍ ហើយមាននីតិក្រមមួយចំនួនខុសគ្នា ។

ម្យ៉ាងទៀត ដើម្បីបង្កើតច្បាប់និងរៀបចំវិន័យនានាសម្រាប់សហាគមន៍ ចាំបាច់ត្រូវតែមានការចុះសម្រុងគ្នា ។

ដូច្នេះ មានតែម៉ាស្ហាប់អ៊ីស្លាមមួយទេដែលត្រូវទទួលស្គាល់ជាប្រភព (គឺគំរូ) សម្រាប់អនុម័តច្បាប់ក្នុងសហាគមន៍ ពីព្រោះ ប្រសិនបើមានប្រភពនីតិក្រមផ្សេងៗគ្នា ការចុះសម្រុងគ្នានិងការរៀបចំឲ្យមានរបៀបរបបនោះច្បាស់ជាពុំបានសម្រេចឡើយ ។

អាស្រ័យហេតុនេះ មានតែម៉ាស្ហាប់អ៊ីស្លាមមួយទេដែលមានគំរូ (គឺស្តង់ដារ៍) ត្រឹមត្រូវដែលត្រូវទទួលស្គាល់ជាប្រភព (គឺយកជាគំរូ) ដើម្បីបង្កបង្កើតច្បាប់និងបទបញ្ញត្តិសម្រាប់សង្គម ដូច្នេះ នឹងអាចទប់ស្កាត់ចលាចលនិងការមិនចុះសម្រុងគ្នាបាន ដែលអាចនឹងកើតឡើងបាននៅក្នុងនីតិក្រមរបស់ប្រទេសនីមួយៗ ។ អាស្រ័យហេតុនេះ នឹងអាចបង្កើតឡើងបាននូវបទបញ្ញត្តិនានាសមស្របនឹងច្បាប់ ទាំងក្នុងសហាគមន៍ ទាំងក្នុងវិស័យឯទៀត ។

តាគ្វីយ៉ាស្ស៍ទេ ។

## សេចក្ដីសរុប

អាស្រ័យសេចក្ដីរាយការណ៍ខាងលើនេះ យើងអាចសម្រេចបានថា៖

១. *តាគ្វីយ៉ាស្ស៍* មានឫសគែរនៅក្នុងព្រះគម្ពីរគួរអាននិងនៅក្នុងទង្វើរបស់បណ្ដាសាវកព្រះសាស្ដាﷺ ហើយព្រះសាស្ដាﷺបាននុញ្ញាឲ្យប្រើ តាគ្វីយ៉ាស្ស៍ ក្នុងសម័យដើមអ៊ីស្លាម ។

២. មូលហេតុដែលស្ហ៊ីអាស្ស៍ប្រើតាគ្វីយ៉ាស្ស៍នោះគឺ ដើម្បីរួចផុតពីការកាប់សម្លាប់ដែលគេប្រព្រឹត្តមកលើខ្លួន ពីការសង្កត់សង្កិននិងការព្យាបាទដែលគេប្រព្រឹត្តមកលើម៉ាស្ស៍ហ្ហាប់នេះ ។

៣. មិនត្រឹមតែស្ហ៊ីអាស្ស៍ទេដែលប្រើ *តាគ្វីយ៉ាស្ស៍* ម៉ាស្ស៍ហ្ហាប់មុស្លីមឯទៀតក៏ប្រើតាគ្វីយ៉ាស្ស៍ដែរ ។

៤. គោលដៅរបស់ *តាគ្វីយ៉ាស្ស៍* មិនត្រឹមតែលាក់ជំនឿអ៊ីស្លាមពីពួកបដិសេធសទ្ធាប់ណ្ដោះទេ តែគោលការណ៍របស់តាគ្វីយ៉ាស្ស៍គឺការពារជីវិតមុស្លីមទាំងឡាយ បិទបាំងជំនឿផ្ទាល់ខ្លួនពីសត្រូវស្លាប់រស់ ពេលគេពុំមានមធ្យោបាយតស៊ូនឹងសត្រូវនោះ ។

## សំណួរ ៣២ - ហេតុអ្វីម៉ាស្ស៍ហ្ហាប់យ៉ាក់ហ្វារីជាម៉ាស្ស៍ហ្ហាប់របស់រដ្ឋម្មនុញ្ញរបស់សាធារណរដ្ឋអ៊ីស្លាម នៃប្រទេស



ហាឌីស្ហ៍ស្ដីអំពីកុំឌៀរនៅក្នុងប្រភេទហាឌីស្ហ៍មូតាវ៉ាតៀរ (متواتر)[41] ដែលមិនត្រឹមតែត្រូវរាយការណ៍ដោយ អ៊្លូឡាម៉ាអ៍ស្ហ៊ីអាស្ស៍ ទេ តែត្រូវរាយការណ៍ដោយប្រមាណ ៣៦០ អ្នកប្រាជ្ញស៊ុននី[42]ដែរ ហើយចំនួនអ្នកថ្លែងបន្តមានដល់ទៅ ១១០ សាវក ។ អ៊្លូឡាម៉ាអ៍មុស្លីមជាន់ខ្ពស់ម្ភៃប្រាំមួយនាក់បានសរសេរសៀវភៅដាច់ឡែកគ្នា ស្ដីអំពីបណ្ដាញថ្លែងព័ត៌មានបន្តនិងអ្នកថ្លែងបន្តរបស់ហាឌីស្ហ៍នេះ ។

លោក អាប៊ូ យ៉ាក់ហ្វារ ត៏បារី អ្នកប្រវត្តិសាស្ត្រមុស្លីមដ៏ល្បីឈ្មោះ បានចងក្រងបណ្ដាញថ្លែងព័ត៌មានបន្ត និងអ្នកថ្លែងបន្តរបស់ហាឌីស្ហ៍នេះនៅក្នុងតម្រាធំពីរ ។ ចង់បានព័ត៌មានបន្ថែម សូមមើលសៀវភៅ *អាល់-កុំឌៀរ ។*

## សំណួរ ៤ ៖ អ៊ីម៉ាំគឺអ្នកណា ?

## ចម្លើយ

ក្នុងសម័យព្រះអង្គﷺ ព្រះសាស្ដាﷺបានប្រកាសថាអត់ពីព្រះអង្គﷺទៅនឹងមាន ១២ ស្ដេច ខ៉ុលិហ្វដែលចេញមកពីសន្តតិវង្សគួរ៉យស្ស៍ទាំងអស់ ហើយអ៊ីស្លាមនឹងរុងរឿង ត្រចះត្រចង់តាមរយៈខ៉ុលិហ្វទាំង ១២ អង្គនេះ ។

[41] មូតាវ៉ាតៀរ គឺហាឌីស្ហ៍មកពីព្រះសាស្ដាﷺ ឬ អ៊ីម៉ាំអវិរុទ្ធដែលគេរាយការណ៍ដដែលៗពាសពេញ បន្តបន្ទាប់គ្នាឥតដាច់ តាមរយៈអ្នកថ្លែងការណ៍ដែលគួរទុកចិត្តបន្តបន្ទាប់គ្នា ។

[42] សូមមើលសៀវភៅរបស់លោក អ៊ីបនូ ហាយ៉ារ *អាស្ស៍-ស្វ៉ាអ៊ីក្វ អាល់-មុះហ្ក៍រីក្វោះត៍ (الصواعق المحرقة)* (បោះពុម្ពលើកទី ២ អេស៊ីបត៍) គឺតាប ៩ វគ្គ ២ ទំព័រ ១២២ ។

លោក យ៉ាបៀរ អ៊ីបនូ សាមូរ៉ោះត៍ (جابر بن سمرة) បានរាយការណ៍ថា៖

"سمعت رسول الله صلى الله عليه وأله وسلم يقول : لا يزال الإسلام عزيزاً إلى اثنى عشر خليفة ثم قال كلمة لم أسمعها فقلت لأبي ما قال؟ فقال: كلهم من قريش."

*"ខ្ញុំបានឮរ៉សូលុលឡោះហ៍ﷺមានព្រះវចនៈថា៖ "អ៊ីស្លាមនឹងគង់កិត្តិយសតាមរយៈស្ដេចខ៊័លិហ្វដប់ពីរអង្គ ។" ក្រោយមកព្រះអង្គﷺមានព្រះវចនៈតែខ្ញុំមិនយល់ ។ ដូច្នេះខ្ញុំបានសួរឪពុកខ្ញុំថា៖ "តើព្រះអង្គﷺថាអ្វី ?" គាត់បានឆ្លើយថាព្រះអង្គﷺមានព្រះវចនៈថា៖ "បុគ្គលទាំងអស់នោះនឹងចេញមកពីពួកគូរ៉យស្ញ៍ ។"*[43]

នៅក្នុងប្រវត្តិសាស្ត្រអ៊ីស្លាម មិនមានស្ដេចខ៊័លិហ្វដប់ពីរទេដែលការពារកិត្តិយសអ៊ីស្លាម លើកលែងតែអ៊ីមុាំដប់ពីរអង្គដែលស្ញ៊ីអះស្ញ៉ជឿ ព្រោះអ៊ីមុាំទាំងដប់ពីរនេះជាស្ដេចខ៊័លិហ្វទាំងដប់ពីរនោះឯង ដែលព្រះសាស្ដាﷺបានតាំងជាអ្នកស្នងព្រះអង្គﷺ ។

តទៅនេះ យើងនឹងពិនិត្យមើលថាស្ដេចខ៊័លិហ្វទាំងដប់ពីរនោះជាអ្នកណា ។ បើយើងថានោះគឺស្ដេចខ៊័លិហ្វទាំងបួនដែលអាស្ហ៍លុល-ស៊ុនណាស្ហ៍ថាជា "ស្ដេចខ៊័លិហ្វដែលបានទទួលការដឹកនាំត្រឹមត្រូវ" (អាល់-ខ៊័ឡាហ្វាអ៊ុ អារ-រ៉ស្ញ៊ីឌូន الخلفاء الراشدون) នោះ វាពុំមានស្ដេចខ៊័លិហ្វណាមួយដែលបានជួយឲ្យអ៊ីស្លាមរុងរឿង ត្រចះត្រចង់ទេ ។

[43] សូមមើលសៀវភៅរបស់លោក មុស្លីម *ស្ញ៉ហ៊ិះហ៍* (បោះពុម្ពនៅប្រទេសអេស៊ីបត៍) ដុំទី ៦ ទំព័រ ២ ។ សូមមើលសៀវភៅរបស់លោក អះប់ឌុល-ហាមីដ ស្ញ៊ីដឌីគី *ស្ញ៉ហ៊ិះហ៍ មុស្លីម* (ច្បាប់ប្រែជាភាសាអង្គ្លេស) ដុំទី ៣ ហាឌីស្ញលេខ ៤៤៨០ ។



កាលពួកស្ដេចខ៊័លិហ្វត្រកូលអ៊ូម៉ៃយ៉ាស្ហ៍ និងអះបាស៊ីយ៉ាស្ហ៍ធ្វើបាបនិងកាប់សម្លាប់ស្ញ៊ីអះស្ហ៍[311] ពួកស្ញ៊ីអះស្ហ៍តែងតែធ្វើតាគ្ញីយ៉ាស្ហ៍តាមបញ្ញាគួរអានដោយលាក់ជំនឿរបស់ខ្លួន ។ ពួកគេបានធ្វើដូច្នេះដើម្បីការពារជីវិតខ្លួនឯងនិងបងប្អូនមុស្លីមដែរនៅក្នុងស្ថានភាពលំបាកនោះ ។

ពិតប្រាកដណាស់ នៅក្នុងស្ថានភាពកៀបសង្កត់ផ្ដាច់ដង្ហើមបែបនេះ ស្ញ៊ីអះស្ហ៍ពុំមានមធ្យោបាយការពារជីវិតពីការកាប់សម្លាប់ ផ្សេងពីការធ្វើតាគ្ញីយ៉ាស្ហ៍ទេ ។ ដូច្នេះហើយ កាលពួកស្ដេចអាក្រក់អន្យតិរ្ថិយនិងបណ្ដាភ្នាក់ងារបានឈប់កាប់សម្លាប់ស្ញ៊ីអះស្ហ៍នោះ បានជាស្ញ៊ីអះស្ហ៍ឈប់ធ្វើតាគ្ញីយ៉ាស្ហ៍ ។

ត្រូវកត់សម្គាល់ថា មិនមានតែស្ញ៊ីអះស្ហ៍ទេដែលធ្វើតាគ្ញីយ៉ាស្ហ៍នោះ ។ ការពិត មុស្លីមឯទៀតក៏ប្រើតាគ្ញីយ៉ាស្ហ៍ដើម្បីការពារខ្លួនពីសត្រូវស្លាប់រស់ដែរដែលបៀតបៀនមុស្លីមគ្រប់មាស្ហ៍ហ្វាប់ ដូចជាពួក *ខ៊័រីយ្ជី (خارجي)* និងរដ្ឋបាលសង្កត់សង្កិនជាដើមដែលប្រើមធ្យោបាយមិនស្របច្បាប់ ។ ពេលឃើញថាពុំអាចតទល់នឹងពួកសត្រូវបានទេ មុស្លីមលាក់ជំនឿរបស់ខ្លួនដើម្បីការពារជីវិត ។

បើសមាជិកសហគមន៍មុស្លីម និងម៉ាស្ហ៍ហ្វាប់ទាំងអស់យោគយល់គ្នាទៅវិញទៅមកនិងរួបរួមគ្នាមែន មុស្លីមទាំងអស់នឹងមិនចាំបាច់ត្រូវប្រើ

[311] ចង់បានព័ត៌មានស្ដីអំពីការកាប់សម្លាប់ស្ញ៊ីអះស្ហ៍ ដោយស្ដេចខ៊័លិហ្វត្រកូលអ៊ូម៉ៃយ៉ាស្ហ៍និងអះបាស៊ីយ៉ាស្ហ៍ សូមមើលសៀវភៅរបស់លោក អាប៊ូល-ហ្វារ៉ជ្ញ៍ អាល់-អ៊ីស្ញហ្វាហ្ញានី (أبو الفرج الإصفهاني) *ម៉ាក៏ត៊ីល អាល់-ត៍លីប៊ីយីន (مَقاتِل الطالِبِّيين);* សូមមើលសៀវភៅរបស់ អះឡាម៉ាស្ហ៍ អាមីនី (اميني) *ស្ញ៊ហ្វាដាអ៊ុ អាល់-ហ្វាឌីឡាស្ហ៍ (شُهَداء الفَضيلة);* សូមមើលសៀវភៅរបស់លោក មូហាំម៉ាដ្ញ៍ យ៉ាវ៉ាដ្ញ៍ មុគ្និយ៉ាស្ហ៍ *អាស្ញ៉-ស្ញ៊ីអះស្ហ៍ វ៉ាល់-ហាគីមុន ។*

*ចិត្តទទួលការបដិសេធសទ្ធា ព្រះពិរោធអល់ឡោះហ្វ៍នឹងធ្លាក់មកលើជនទាំងនោះ ហើយពួកគេនឹងទទួលរងទណ្ឌកម្មធ្ងន់ ១៦:១០៦ ។"*[309]

អស់លោកអ្នកបកស្រាយគួរអាន (مفسرون មូហ្វាស់ស៊ីរូន) បានរាយការណ៍អំពីមូលហេតុនៃការដាក់អាយ៉ាស់នេះមកថា ថ្ងៃមួយ អាំម៉ារ អ៊ីបនូយ៉ាសៀរ និងឪពុកម្ដាយត្រូវសត្រូវនិងពួកបដិសេធសទ្ធាចាប់ខ្លួន បង្ខំឲ្យអស់លោកបោះបង់ចោលអ៊ីស្លាមហើយព្រមទៅជាអ្នកបដិសេធសទ្ធា និងទៅជាអ្នកហ៊ុនហាយ (ស៊ីរិក) ។ មិត្តរបស់អាំម៉ារនៅតែជឿអល់ឡោះហ្វ៍عز وجل មួយគត់និងព្រះសាស្ដាﷺដដែល ។

ដូច្នេះ ពួកគេមួយចំនួនបានស្លាប់ក្នុងនាមជំនឿរបស់ខ្លួន រីឯមួយចំនួនទៀតត្រូវសត្រូវធ្វើទណ្ឌកម្ម ។ ដើម្បីកុំឲ្យសត្រូវធ្វើទុក្ខ អាំម៉ារក៏បានថាអ្វីដែលសត្រូវចង់ឲ្យលោកថា ផ្ទុយពីក្នុងចិត្តលោក ។ ហេតុដូច្នេះ ពួកសត្រូវក៏បានដោះលែងលោក ។ ពេលលោកជួបព្រះសាស្ដាﷺអល់ឡោះហ្វ៍عز وجل លោកមានការស្ដាយក្រោយនិងមាការខូចចិត្តខ្លាំង ដែលបានថាអ្វីដែលលោកបានថានោះ ។ ដូច្នេះ ព្រះសាស្ដាﷺបានលួងលោមលោក ហើយអាយ៉ាស់ខាងលើនេះត្រូវបានដាក់មក ។[310]

អាយ៉ាស់នេះនិងអ្នកបកស្រាយគួរអានរាយការណ៍ថា អ៊ីស្លាមអនុញ្ញាតឲ្យលាក់លទ្ធិរបស់ខ្លួនដើម្បីរួចផុតពីការស្លាប់ និងរួចផុតពីការខូចខាតផ្លូវកាយនិងចិត្ត ក្នុងសម័យព្រះសាស្ដាﷺ ។

[309] ស៊ូរ៉ោះត៍ អាន់-ណាស្ល៍ 16:106 ។

[310] សូមមើលសៀវភៅរបស់លោក យ៉ាឡាល់ អាដ្ឌ-ឌីន អាស់-ស៊ូយូទី *អាដ្ឌ-ឌូរ អាល់-ម៉ាន់ស៊ូរ* (الدر المنثور) (បោះពុម្ពនៅបៃរូត) ជុំទី ៤ ទំព័រ ១៣១ ។



ជីវប្រវត្តិរបស់ស្ដេចខ៉ូលិហ្វអ៊ូម៉ៃយ៉ាស់ និងអាបាស៊ីយ៉ាស់ជាភ័ស្ដុតាងរឿងនេះ ។ រីឯអ៊ីម៉ាំទាំងដប់ពីរដែលស៊ីអាស់ជឿនោះវិញ ព្រះអង្គទាំងអស់នេះជាការសម្ដែងឲ្យឃើញនូវសទ្ធាជ្រះថ្លា និងសីលធម៌ច្បាស់ក្រឡែត នៅក្នុងសម័យកាលរបស់ព្រះអង្គគ្រប់ៗអង្គបន្តបន្ទាប់គ្នា ។

ព្រះអង្គទាំងដប់ពីរអង្គនេះ ជាអ្នកថែរក្សាព្រះស៊ុនណាស់របស់ព្រះសាស្ដាﷺរបស់អល់ឡោះហ្វ៍عز وجلដែរ និងជាបុគ្គលដែល *ស៉្វហាបាស់* (សាវក) និង *តាប៊ីអ៊ីន* (អ្នកតាម) ចំពាក់ចិត្តលើ[44] ។ អស់លោកអ្នកប្រវត្តិសាស្រ្ត ទទួលស្គាល់ថាព្រះអង្គទាំងអស់នេះមានចំណេះវិជ្ជាកំពូល និងជាបុគ្គលគួរទុកចិត្ត ។ អ៊ីម៉ាំទាំងដប់ពីរអង្គនេះ គឺ៖

១. អាលី អ៊ីបនូ អាប៊ី តាលិប
២. ហាសាន់ អ៊ីបនូ អាលី (អាល់-មុច្ចតាបា الْمُجْتَبَى)
៣. ហ៊ូសែន៍ អ៊ីបនូ អាលី
៤. អាលី អ៊ីបនូ អាល់-ហ៊ូសែន៍ (ស្សែន៍ អាល់-អាប៊ីឌីន)
៥. មូហាំម៉ាដ្ឋ អ៊ីបនូ អាលី (អាល់-បាកៀរ)
៦. យ៉ាក់ហ្វារ អ៊ីបនូ មូហាំម៉ាដ្ឋ (អាស្វ-ស្វ៉ាឌិក្ក)
៧. មូសា អ៊ីបនូ យ៉ាក់ហ្វារ (អាល់-កាស៊ីម)
៨. អាលី អ៊ីបនូ មូសា (អារ-រីដ្ឋ)
៩. មូហាំម៉ាដ្ឋ អ៊ីបនូ អាលី (អាត់-តាគី)
១០. អាលី អ៊ីបនូ មូហាំម៉ាដ្ឋ (អាន់-ណាគី)
១១. ហាសាន់ អ៊ីបនូ អាលី (អាល់-អាស់ការី)

[44] តាប៊ីអ៊ីន (អ្នកតាម ឬ អ្នកបន្ត) ផ្ដោតទៅលើមុស្លីមជំនាន់ទីពីរដែលមកក្រោយបណ្ដាសាវក ដែលពុំបានស្គាល់ព្រះសាស្ដាﷺទេតែបានស្គាល់បណ្ដាសាវកព្រះអង្គﷺ ។

១២. មូហាំម៉ាដ់ អ៊ីបនូ អាល់-ហាសាន់ (អាល់-ម៉ាស្ទុខ្ទី)

មានហាឌីស្សមូតាវ៉ាតៀរ រាយការណ៍តមកពីព្រះសាស្តាﷺ ស្តីអំពីអ៊ីមុាំចុងក្រោយបង្អស់ដែលគេហៅថា "ម៉ាស្ទុខ្ទីជាទីសង្ឃឹម" ថ្លែងបន្តដោយអស់លោកអ្នកប្រាជ្ញមុស្លីមខាងហាឌីស្ស (មូហាដ់ឌីស្សីន) ។

ដើម្បីជាព័ត៌មានបន្ថែម សៀវភៅខាងក្រោមនេះស្តីអំពីអគ្គប្រមុខឧត្តមទាំងនេះដែលព្រះសាស្តាﷺអល់ឡោះហ្ទ៍ عز وجل ផ្ទាល់បានប្រាប់ឈ្មោះ គឺ៖

១. *តាស្ទ៉ុគីរ៉េះត៊ុ អាល់-ខ៏វ៉ាស្ស៊ អាល់-អ៊ុមម៉ាស្ទ៊*
*( تَذكِرَةُ الخَواصّ مِنَ الأمّة فى ذِكرِ خَصائص الأئمة) ។*

២. *គីហ្វាយ៉ាស្ទ៊ អាល់-អាស្សារ (كفاية الأثر)*

៣. *វ៉ាហ្វីយ៉ាត់ អាល់-អ៊ុាយ៉ាន់ (وفيات الأعيان)*

៤. *អាក់យ៉ាន់ អាល់-ស៊ីអ៊ុាស្ទ៊ (أعيان الشيعة)*

(សរសេរដោយ السيد محسن بن عبد الكريم الامين العاملي សៃយីដ្ទ មុះហ្ស៊ីន អាមីន អាល់-អ៊ុាមីលី ងាយយល់ជាងសៀវភៅទាំងបី)

## សំណួរ ៥ - ហេតុអ្វីស៊ីអ៊ុាស្ទ៊ថា "អល់ឡ៉ហ៊ុមម៉ា ស្វល់លី អ៊ុាឡា មូហាំម៉ាដ់ វ៉ា អ៊ុាឡា អាលី មូហាំម៉ាដ់" ?

ពេលជូនពរណាបីមូហាំម៉ាដ់ﷺ (ស្វ៏ឡាវ៉ាត) ហេតុអ្វីអស់លោករាប់បញ្ចូលបណ្តាកូនចៅعليهم السلامព្រះអង្គﷺ ជាមួយព្រះអង្គﷺដែរដោយថា៖ "អល់ឡ៉ហ៊ុមម៉ា ស្វល់លី អ៊ុាឡា មូហាំម៉ាដ់ វ៉ា អ៊ុាឡា អាលី មូហាំម៉ាដ់ (អល់ឡោះហ្ទ៍ عز وجلអឺយ សូមព្រះរាជទានពរជ័យដល់មូហាំម៉ាដ់និងដល់បណ្តាកូនចៅរបស់មូហាំម៉ាដ់)" ?



តាគ្គីយ៉ាស្ទ៊ (تقية) មានន័យថាលាក់ជំនឿរបស់ខ្លួនពីសត្រូវ ដើម្បីចៀសវាងការខូចខាតផ្នែកសាសនា ហើយនេះជាកាតព្វកិច្ចសាសនាមួយរបស់មុស្លីមគ្រប់រូបដែលគួរអានដាក់មកជាច្បាប់ ។

មានអាយ៉ាស្ទ៊គួរអានច្រើនស្តីអំពីរឿងនេះគឺ៖

لَّا يَتَّخِذِ ٱلْمُؤْمِنُونَ ٱلْكَٰفِرِينَ أَوْلِيَآءَ مِن دُونِ ٱلْمُؤْمِنِينَ ۖ وَمَن يَفْعَلْ ذَٰلِكَ فَلَيْسَ مِنَ ٱللَّهِ فِى شَىْءٍ إِلَّآ أَن تَتَّقُوا۟ مِنْهُمْ تُقَىٰةً ۗ

*"ចូរបណ្តាអ្នកមានសទ្ធាជ្រះថ្លាកុំយកបណ្តាអ្នកបដិសេធសទ្ធាជាមិត្ត ក្រៅពបណ្តាអ្នកមានសទ្ធា[ដូចគ្នា] ។ អ្នកណាធ្វើបែបនេះ អ្នកនោះផ្តាច់ទំនាក់ទំនងពីអល់ឡោះហ្ទ៍ លើកលែងតែពួកអ្នកការពារខ្លួនព្រោះខ្លាច[មានគ្រោះថ្នាក់ពី]ពួកនោះ ៣:២៨ ។"*[308]

អាយ៉ាស្ទ៊នេះបញ្ជាក់ថាមិនអនុញ្ញាតឲ្យចងមិត្តភាពជាមួយសត្រូវទេ លើកលែងតែក្នុងន័យតាគ្គីយ៉ាស្ទ៊ (គឺលាក់លទ្ធិរបស់ខ្លួន) ដើម្បីរួចជីវិត ឬដើម្បីចៀសវាងគ្រោះថ្នាក់ ។ ក្នុងករណីនេះ គេអនុញ្ញាតឲ្យចងមិត្តភាពនិងស្រុះស្រួលជាមួយពួកសត្រូវ ។

مَن كَفَرَ بِٱللَّهِ مِنۢ بَعْدِ إِيمَٰنِهِۦٓ إِلَّا مَنْ أُكْرِهَ وَقَلْبُهُۥ مُطْمَئِنٌّۢ بِٱلْإِيمَٰنِ وَلَٰكِن مَّن شَرَحَ بِٱلْكُفْرِ صَدْرًا فَعَلَيْهِمْ غَضَبٌ مِّنَ ٱللَّهِ وَلَهُمْ عَذَابٌ عَظِيمٌ

*"អ្នកដែលមិនមានសទ្ធាចំពោះអល់ឡោះហ្ទ៍ទេ ក្រោយពីមានសទ្ធា[ចំពោះព្រះអង្គ] លើកលែងតែបុគ្គលណាដែលត្រូវគេបង្ខិតបង្ខំខណៈដែលដួងចិត្តអ្នកនោះនៅតែជឿស្មោះជានិច្ច ។ តែបុគ្គលណាដែលបើក*

[308] ស៊ូរ៉ោះត៊ុ អាលី អ៊ីមរ៉ន 3:26 ។

ហ្គាឌីស្ទនេះដែលអ្នកប្រាជ្ញទាំងអស់ទទួលស្គាល់នោះ ទាំងស៊ុននី ទាំងស្ហ៊ីអាត់ស៊ុ យោលតាមបណ្តាញអ្នករាយការណ៍ ជាកសិណសាក្សីបញ្ជាក់ថា ទ្រឹស្តីស្ហ៊ីអាត់ស៊ុជាទ្រឹស្តីត្រឹមត្រូវពាក់ព័ន្ធនឹងចំណុចពីរគឺ៖

១. មូហាំម៉ាដ់ អ៊ីបនូ អាប់ឌុលឡោះហ្វ៍ﷺ ជាព្រះសាស្តាជាទីស្រឡាញ់បង្អស់របស់អល់ឡោះហ្វ៍ﷻ និងជាសាស្តាចុងក្រោយបង្អស់ដែលត្រូវតែងតាំងឡើងជាសាស្តាសាកល អត់ពីព្រះអង្គﷺទៅពុំមានសាស្តាទៀតទេ ។

២. អាលី អ៊ីបនូ អាប៊ី តាំលិបعليه السلامជាអ្នកស្នងព្រះសាស្តាﷺ ជាអ្នកបំពេញតាមព្រះបណ្តាំព្រះអង្គﷺ និងជាខ៉លិហ្វរបស់មូស្លីមទាំងអស់អត់ពីព្រះអង្គﷺទៅ ។

## សំណួរ ៣១ - អ្វីទៅគោលការណ៍តាគ្វីយ៉ាស៊ុ ?

## ចម្លើយ

---

(បោះពុម្ពនៅបៃរូត) "បាប់ ម៉ាណាគ្វីប អាលី អ៊ីបនូ អាប៊ី តាំលិប" ជុំទី ៥ ទំព័រ ២១; នៅក្នុង *អាល់-ម៉ាណាគ្វីប* របស់លោក អ៊ីបនូ មូក៏ស្សាលី (បោះពុម្ពនៅបៃរូត ឆ្នាំ 1403 ស.ហ.) ទំព័រ ២៧; នៅក្នុង *ប៊ីហារ អាល់-អាន់វ៉ារ (بحار الأنوار)* (បោះពុម្ពនៅបៃរូតលើក ទី ២ ឆ្នាំ 1403 ស.ហ.) ជុំទី ៣៧ ទំព័រ ២៥៤; នៅក្នុង *ម៉ាអានី អាល់-អាក់ប៉ារ (معاني الأخبار)* របស់ ស្ហៃខ៍ អាស្ស៊-ស្ស៊ឌុក្ក (الشيخ صدوق) (បោះពុម្ពនៅបៃរូត ឆ្នាំ 1399 ស.ហ.) ទំព័រ ៧៩; នៅក្នុង *កាន់ស៊ អាល់-ហ្វាវ៉ាអ៊ីដ (كنز الفوائد)* (បោះពុម្ពនៅបៃរូត ឆ្នាំ 1405 ស.ហ.) ជុំទី ២ ទំព័រ ១៦៨ ជាដើម ។



## ចម្លើយ

គេបានបង្ហាញភ័ស្តុតាងហើយថា ព្រះសាស្តាﷺផ្ទាល់បានបង្ហាត់មូស្លីមឲ្យចេះបួងសួងជូនពរជ័យឲ្យព្រះអង្គﷺ ។ កាលអាយ៉ាស៊ុខាងក្រោមនេះ

إِنَّ ٱللَّهَ وَمَلَٰٓئِكَتَهُۥ يُصَلُّونَ عَلَى ٱلنَّبِيِّۚ يَٰٓأَيُّهَا ٱلَّذِينَ ءَامَنُواْ صَلُّواْ عَلَيۡهِ وَسَلِّمُواْ تَسۡلِيمًا

*អល់ឡោះហ្វ៍និងទេវតាទាំងឡាយរបស់ព្រះអង្គ ជូនពរជ័យសិរីសួស្តីដល់ព្រះសាស្តា ។ បណ្តាអ្នកមានសទ្ធាអើយ ចូរពួកអ្នកជូនពរជ័យសិរីសួស្តីដល់គេ ចូរពួកអ្នកចុះចូលយ៉ាងស្មោះអស់ពីចិត្តចំពោះគេ (៣៣:៥៦) ។*[45]

ត្រូវបានដាក់ចុះមក មូស្លីមទាំងអស់សួរព្រះសាស្តាﷺថា៖ "តើអស់ទូលបង្គំគប្បីបួងសួងពរជ័យ[ឲ្យព្រះអង្គﷺ]ដូចម្តេច ?" ព្រះសាស្តាﷺមានព្រះវចនៈថា៖

"لا تصلّوا عليّ الصلوة البتراء."

*"ចូរកុំបួងសួងពរជ័យកំបុតឲ្យខ្ញុំ ។"*

ពួកគេសួរទៀតថា៖ "តើអស់ទូលបង្គំគប្បីបួងសួងសូមពរជ័យឲ្យព្រះអង្គﷺដូចម្តេច ?" ព្រះអង្គﷺមានព្រះវចនៈថា៖ "

أَللّٰهُمَّ صَلِّ عَلىٰ مُحَمَّدٍ وَ عَلىٰ آلِ مُحَمَّدٍ

"អល់ឡ៉ហ៊ុមម៉ា ស្វ៉ល់លី អាឡា មូហាំម៉ាដ់ វ៉ា អាឡា អាលី មូហាំម៉ាដ់"

*(អល់ឡោះហ្វ៍ﷻអើយ សូមព្រះរាជប្រទានពរជ័យដល់មូហាំម៉ាដ់និងដល់គ្រួសារមូហាំម៉ាដ់ ។)*[46]

---

[45] ស៊ូរ៉ោះត៍ អាល់-អាស៊ាហ្សាប់ 33:56 ។

[46] សូមមើលសៀវភៅរបស់លោក អ៊ីបនូ ហាយ៉ារ (អាល់-អាស់ក៏ឡានី) *អាស្ស៊-ស្វ៉ាវ៉ាអ៊ីក្វ អាល់-មុះហ្ស៉ារីក្វោះត៍ (الصواعق المحرقة)* (បោះពុម្ពលើកទី ២ អេស៊ីបត៍-

បុណ្យបារីឧត្តុង្គឧត្តម ពិសេសរបស់គ្រួសារ عليه السلام ព្រះសាស្តា ﷺ ជម្រុញអ៊ីម៉ាំអាស្ង-ស្ហាហ្វ៊ីអ៊ីឲ្យតែងកំណាព្យដ៏ល្បីដូចតទៅ ។

يا أهل بيت رسول الله حبّكم فرض من الله في القرآن أنزله كفاكم من عظيم القد أنكم من لم يصل عليكم لا صلوة له."

*"ឱព្រះរាជកុលដ្ឋាន (អាស្ល់លុល-បៃត៍) ព្រះសាស្តា ﷺ របស់អល់ឡោះហ៊្វ عزّ وجلّ អើយ សេចក្តីស្រឡាញ់[របស់អស់ទូលបង្គំ]មកលើព្រះអង្គ عليه السلام ជាកាតព្វកិច្ចដែលអល់ឡោះហ៊្វ عزّ وجلّ បានបើកឲ្យដឹងនៅក្នុងគួរអាន ។ បុណ្យបារមីខ្ពង់ខ្ពស់របស់ព្រះអង្គ عليه السلام នោះគឺ បើអ្នកណាមួយមិនបួងសួងសូមពរជ័យឲ្យព្រះអង្គ عليه السلام ទេ [ក្នុងស្ឡឡាត់] ស្ឡឡាត់របស់អ្នកនោះត្រូវមោឃ: ។"*[47]

Cairo: Maktabat al-Qahirah) គីតាប ១១ វគ្គ ១ ទំព័រ ១៤៦ និងសៀវភៅស្រដៀងនេះរបស់លោក យ៉ាឡាល់ អាដ្ឋ-ឌីន អាស់-ស៊ូយូទ្វី (جلال الدين السيوطي) *អាដ្ឋ-ឌូរ អាល់-ម៉ាន់ស៊ូរ* (الدر المنثور) ជុំទី ៥ អធិប្បាយស៊ូរ៉ោះត៍ អាល់-អាស្ហ់ស្ហាប់ ៣៣:៥៦ រាយការណ៍ដោយអ្នកប្រាជ្ញខាងហាឌីស្ហ (មូហាដ្ឋ៍ឌីស្ហូន) និងអស់លោកអ្នកចងក្រងស្ហហ៊ិះហ៍និងមុសណាដ្ឋ ដូចជាលោក អាប់ដ៍ អារ-រ៉ស្សាក់ លោក អ៊ីបនូ អាប៊ី ស្ហៃបាស់ លោក អាស់ម៉ាដ្ឋ អ៊ីបនូ ហាន់បាល់ លោក អាល់-ប៊ូខ៉ារី លោក មុស្លីម លោក អាប៊ូ ដាវូដ្ឋ លោក តៀរមីស៊ី លោក នីសាអ៊ី លោក អ៊ីបនូ ម៉ាយ៉ាស់ លោក អ៊ីបនូ ម៉ាដាវ៉ៃ ជាដើម តមកពីលោក កាអ៊្ហប់ អ៊ីបនូ អ៊ុច្ចរ៉ោះត៍ តមកពីព្រះសាស្តា ﷺ ។

[47] សូមមើលសៀវភៅ *អាស្ហ-ស្ហ៍វ៉ាអ៊ីក្ហ អាល់-មុះហ្ហ៍រីក្វោះត៍ (الصواعق المحرقة)* គីតាប ១១ វគ្គ ១ ទំព័រ ១៤៨ ។ សៀវភៅរបស់លោក ស្ហាប់រ៉ាវី *អាល់-អ៊ីស្ហាហ្វ* ទំព័រ ២៩ ។ សៀវភៅរបស់លោក ហ៊ាំស្ហាវី ម៉ាលីគី *ម៉ាស្ហារីក្ហ អាល់-អាន់វ៉ារ* ទំព័រ ៨៨ ។ សៀវភៅរបស់លោក ស្ហាក្វ៊ានី *អាល់-ម៉ាវ៉ាហ៊ីប* ។ សៀវភៅរបស់លោក សាប់បាន់ *អាល់-អាស់-អាហ្វ* ទំព័រ ១១៩ ។



ស៊្ហីអាស់ទាំងអស់ក្នុងលោកចាត់ទុកយ៉ឺបរ៉ាអ៊ីល عليه السلام ជាបុគ្គលសច្ចៈ និងជាបុគ្គលស្មោះត្រង់ក្នុងការនាំព្រះរាជសារ ហើយចាត់ទុក មូហាំម៉ាដ្ឋ អ៊ីបនូ អាប់ឌុលឡោះហ៊្វ ﷺ ជាព្រះសាស្តា ﷺ ពេញច្បាប់ និងជាព្រះសាស្តាចុងក្រោយបង្អស់របស់អល់ឡោះហ៊្វ عزّ وجلّ ឯអាលី អ៊ីបនូ អាប៊ី ត៉ាលិប صلوات الله عليه والسلام ជាអ្នកស្នងព្រះសាស្តា ﷺ និងជាអ្នកបំពេញតាមព្រះបណ្តាំរបស់ព្រះសាស្តា ﷺ ។

គប្បីលើកឡើងនូវហាឌីស្ហមួយ ដែលអាស្ហ់លុល-ស៊ុនណាស់និងស៊្ហីអាស់មូលមតិគ្នាថាជាហាឌីស្ហពិត ដែលមាននៅក្នុងសៀវភៅដែលគួរទុកចិត្តបានរបស់រៀងៗខ្លួន ។ គេហៅហាឌីស្ហនោះថា "ហាឌីស្ហ អាល់-ម៉ាន់ស៊ីឡាស់ حديث المنزلة" ដែលរាយការណ៍ថាបន្ទាប់ពីបានប្រកាសឲ្យដឹងថាព្រះអង្គ ﷺ ជាព្រះសាស្តាចុងក្រោយបង្អស់ ព្រះសាស្តា ﷺ បានបង្ហាញខ្លួនអាលី صلوات الله عليه والسلام ជាអ្នកស្នងព្រះអង្គ ﷺ និងជាអ្នកបំពេញតាមព្រះបណ្តាំរបស់ព្រះអង្គ ﷺ ។ ព្រះអង្គ ﷺ ប្រាប់អាលី صلوات الله عليه والسلام ថា៖

«أما ترضى أن تكون منّي بمنزلة هارون من موسى إلاّ أنّه لانبي بعدي»

*"អ្នក صلوات الله عليه والسلام មិនពេញចិត្តទេ អ្នក صلوات الله عليه والسلام និងខ្ញុំ ﷺ ដូចហារូន عليه السلام និងមូសា عليه السلام ដែរ លើកលែងតែនឹងពុំមានសាស្តាទេអត់ពីខ្ញុំ ﷺ ទៅ ?"*[307]

[307] ហាឌីស្ហនេះមាននៅក្នុងសៀវភៅយោងច្រើន ដូចជានៅក្នុង *ស្ហហ៊ិះហ៍ អាល់-ប៊ូខ៉ារី* (បោះពុម្ពនៅផៃស៊ីបត៍) ជុំទី ៦ "បាប់ ក្ហស់វ៉ាស់ តាប៊ុក (غزوة تبوك)" ទំព័រ ៣; នៅក្នុង *ស្ហហ៊ិះហ៍ មុស្លីម* (បោះពុម្ពនៅអេស៊ីបត៍) ជុំទី ៧ "បាប់ ហ្វាដ្ឋ៍អ៊ីល អាលី អ៊ីបនូ អាប៊ី ត៉ាលិប" ទំព័រ ១២០; នៅក្នុង *ស៊ូណាន់ អ៊ីបនូ ម៉ាយ៉ាស់* (បោះពុម្ពនៅអេស៊ីបត៍) ជុំទី ១ "បាប់ ហ្វាដ្ឋ៍អ៊ីល អាស្ហហាប់ អាន់-ណាប៊ី (فضائل أصحاب النبي)" ទំព័រ ៥៥; នៅក្នុង *មុសតាដ្ឋរ៉ាក់ អាល់-ហាគីម* (បោះពុម្ពនៅបៃរូត) ជុំទី ៣ ទំព័រ ១០៩; នៅក្នុង *មុសណាដ្ឋ អាស់ម៉ាដ្ឋ អ៊ីបនូ ហាន់បាល់* ជុំទី ១ ទំព័រ ១៧០, ១៧៧, ១៧៩, ១៨២, ១៨៤-១៨៥, ជុំទី ៣ ទំព័រ ៣២; នៅក្នុង *ស្ហហ៊ិះហ៍ តៀរមីស៊ី*

النبيين وحجة الله على العالمين»

*"ខ្ញុំសូមប្ដេជ្ញាថាពុំមានព្រះទេក្រៅពីអល់ឡោះហ្វ៍ﷻ ព្រះតែមួយគត់ ព្រះអង្គﷻពុំមានដៃគូឡើយ ។ ខ្ញុំសូមប្ដេជ្ញាថាមូហាំម៉ាដ់ﷺជាបាវបម្រើនិងជាព្រះសាស្ដារបស់ព្រះអង្គﷻ ជាព្រះសាស្ដាចុងក្រោយបង្អស់និងជាព្រះភ័ស្ដុតាងរបស់អល់ឡោះហ្វ៍ﷻសម្រាប់ពិភពទាំងពួង ។"*[304]

អ៊ីមុាំអាស្ស៍-ស្វ៏ឌិក្វعليه السلامមានវចនៈដែរថា៖

«لم يبْعث الله عزّوجلّ من العرب إلاّ خمسة أنبياء: هوداً وصالحاً وإسماعيل وشعيباً ومحمّداً خاتم النّبيين – صلّى الله عليه وآله وسلّم»

*"ក្នុងចំណោមពួកអារ៉ាប់ អល់ឡោះហ្វ៍ﷻបានតែងតាំងតែសាស្ដាប្រាំអង្គទេគឺ៖ហ៊ូដ, ស្វ៏លិះហ៍, អ៊ីសម៉ាអ៊ីល, ស្វ៊អ៊ែប៍ និង មូហាំម៉ាដ់ជាសាស្ដាចុងក្រោយបង្អស់ ។"*[305]

ហាឌីស្ស៍នេះបញ្ជាក់យ៉ាងច្បាស់លាស់ថាការចោទប្រកាន់ គួរឲ្យស្អប់ខ្ពើមនេះជាការនិយាយបង្ខូច ហើយស្ស៊ីអ៊ាស្ស៍ចាត់ទុក មូហាំម៉ាដ់ អ៊ីបនូ អ៊ាប់ឌុលឡោះហ្វ៍ﷺ ជាព្រះសាស្ដាចុងក្រោយបង្អស់របស់អល់ឡោះហ្វ៍ﷻ ។[306]

[304] សូមមើលសៀវភៅ *ណាស្ហ៍ឃុស-សាអ៊ាដាស្ស៍ (نَهْجُ السّعادَة)* (បោះពុម្ពនៅបៃរូត) ជុំទី ១ ទំព័រ ១៨៨ ។ សូមមើលសៀវភៅ *អាល់-កាហ្វី* (បោះពុម្ពនៅតេហេរ៉ង់ លើកទី ២ ឆ្នាំ 1389 ស.ហ.) ជុំទី ៨ ទំព័រ ៦៧ ។

[305] សូមមើលសៀវភៅ *ប៊ីហ្ហារ អាល់-អាន់វ៉ារ (بحار الأنوار)* (បោះពុម្ពនៅបៃរូតលើកទី ២ ឆ្នាំ 1403 ស.ហ.) ជុំទី ១១ ទំព័រ ៤២ ។

[306] ចង់បានព័ត៌មានបន្ថែមស្ដីអំពីទ្រឹស្ដីស្ស៊ីអ៊ាស្ស៍ រឿងព្រះសាស្ដាﷺចុងក្រោយបង្អស់ សូមមើលសៀវភៅរបស់បណ្ឌិត យ៉ាក់ហ្វារ ស៊ុបហានី (جعفر سبحانى) *ម៉ាហ្វាហ៊ីម អាល់-គួរអាន (مفاهيم القرآن)* ។



# សំណួរ ៦ - ហេតុអ្វីចាត់ទុកអ៊ីមុាំជាអរិរុទ្ធបុគ្គល (ម៉ាក់ស្ស៊ុម) ?

## ចម្លើយ

មានភ័ស្ដុតាងច្រើនដែលបញ្ជាក់ថា អ៊ីមុាំទាំងឡាយដែលជាព្រះរាជកុលដ្ឋានទាំងអស់របស់ព្រះសាស្ដាﷺ (អាស្ស៍លុល-បៃត៍) នោះប្រកបដោយអរិរុទ្ធភាព (អ៊ីស្វម៉ាស្ស៍ عِصْمَة) ។ យើងនឹងលើកយកភ័ស្ដុតាងនោះតែមួយបង្ហាញជូន ។

យោលតាមសេចក្ដីរាយការណ៍របស់អស់លោកអ្នកប្រាជ្ញស្ស៊ីអ៊ាស្ស៍ និង ស៊ុននី ជិតចូលទិវង្គត ព្រះសាស្ដាﷺមានព្រះវចនៈថា៖

"إني تارك فيكم الثقلين كتاب الله وأهل بيتي وإنهما لن يفترقا حتى يردا عليّ الحوض."

*"ការពិត ខ្ញុំទុកឲ្យអស់លោកនូវវត្ថុសំខាន់ពីរគឺ៖ ព្រះគម្ពីរអល់ឡោះហ្វ៍ﷻ (គួរអាន) និងព្រះរាជកុលដ្ឋាន (អាស្ស៍លុល-បៃត៍) របស់ខ្ញុំ ទាំងពីរនេះនឹងមិនបែកពីគ្នាជាដាច់ខាត លុះបានមកជួបខ្ញុំនៅឯស្រះ (អាល់-ហោដ្ស៍) [នៃកៅស្ស៊ារ ក្នុងថ្ងៃរស់ពីស្លាប់វិញ] ។"*[48]

ចំណុចគួរយកចិត្តទុកដាក់ត្រង់នេះគឺ៖ មិនមានអ្វីគួរឲ្យសង្ស័យបន្តិច

[48] សូមមើលសៀវភៅរបស់ *មុសតាដ់រ៉ក់ អាល់-ហាគីម* ជុំទី ៣ ទំព័រ ១៤៨ ។ *អាស្ស៍-ស្វ៏វ៉ាអ៊ីក្វ អាល់-មុះហ្វ៍រីកោះត៍ (الصواعق المحرقة)* គីតាប ១១ វគ្គ ១ ទំព័រ ១៤៩ ។ មានអត្ថបទស្រដៀងនេះដែរនៅក្នុង *កាន់ស៊ុ៍ អាល់-អ៊ុម៉ាល់ (كنز العمال)* ជុំទី ១ វគ្គ "អាល់-អ៊ិទីស្វំ ប៊ីល គីតាប វ៉ាស់-ស៊ុនណាស្ស៍" ទំព័រ ៤៤ ។ *មុសណាដ់ អាស៊ុម៉ាដ់ អ៊ីបនូ ហាន់បាល់* ជុំទី ៥ ទំព័រ ១៨២, ១៨៩ និងសៀវភៅច្រើនទៀត ។

ឡើយ ព្រះមហាគម្ពីរគួរអានវិសេសវិសាលមិនផ្ដាំផ្ដង មិនវិរុទ្ធសោះឡើយ ។ តើសេចក្ដីផ្ដាំផ្ដងអាចប៉ះពាល់ព្រះរាជបន្ទូលរបស់អល់ឡោះហ្វ៍ عز وجل បានដូចម្ដេចទៅ បើមានព្រះអគ្គទេវតា عليه السلام អ្នកនាំព្រះរាជបន្ទូលជាអ្នកនាំសារ ដោយមានព្រះសាស្ដា صلى الله عليه وآله وسلم អល់ឡោះហ្វ៍ عز وجل ជាអ្នកទទួលព្រះរាជបន្ទូលនោះ ?

ព្រោះតែទាំងបីនេះប្រកបដោយអវិរុទ្ធភាព ជាក់ច្បាស់ដូចពន្លឺថ្ងៃ មុស្លីមក្នុងពិភពលោកទាំងមូលចាត់ទុកព្រះសាស្ដា صلى الله عليه وآله وسلم ជាបុគ្គលចាកផុតពីការប្រព្រឹត្តិផ្ដាំផ្ដងក្នុងការទទួល ក្នុងការថែរក្សានិងក្នុងការប្រាប់បន្តព្រះរាជបន្ទូលរបស់អល់ឡោះហ្វ៍ عز وجل ហើយពិតប្រាកដណាស់ថាព្រះគម្ពីរអល់ឡោះហ្វ៍ عز وجل ក៏ទៀងឥតប្រែប្រួល និងមានសច្ចភាពដូចនោះដែរ បានជាអាស្ហ៍លុល-បៃត៍របស់ព្រះសាស្ដា صلى الله عليه وآله وسلم អល់ឡោះហ្វ៍ عز وجل ក៏ចាកផុតពីការភ្លាំងភ្លាត់និងកំហុសដែរ ។ ពីព្រោះ នៅក្នុងហាឌីស្ហ៍ គេពិពណ៌នាថាបណ្ដាកូនចៅ (អ៊ីតរ៉ោះត្ហ៍) របស់ព្រះសាស្ដា صلى الله عليه وآله وسلم ស្មើនឹងព្រះមហាគម្ពីរគួរអានវិសេសវិសាលក្នុងការបង្ហាញមាគ៌ា និងក្នុងការដឹកនាំអ៊ុមម៉ាត្ហ៍ បានសេចក្ដីថាទាំងពីរនេះប្រកបដោយអវិរុទ្ធភាព (អ៊ីស្ហ៍ម៉ាស្ហ៍ عِصْمَة) ស្មើគ្នា ។

អាចនិយាយម្យ៉ាងទៀតបានថា មិនសមហេតុផលទេដែលចាត់ទុកបុគ្គលម្នាក់ឬមនុស្សច្រើននាក់ដែលមិនអវិរុទ្ធទេនោះ ស្មើនឹងព្រះគម្ពីរអល់ឡោះហ្វ៍ عز وجل ។

សក្ខីភាពបញ្ជាក់ថាអ៊ីម៉ាំទាំងឡាយ عليهم السلام អវិរុទ្ធនោះ គឺសម្ដីរបស់ព្រះសាស្ដា صلى الله عليه وآله وسلم ដូចតទៅគឺ៖

"وإنهما لن يفترقا حتى يردا عليَّ الحوض."

*"ទាំងពីរនេះនឹងមិនបែកពីគ្នាជាដាច់ខាត (ក្នុងការបង្ហាញមាគ៌ានិងក្នុងការដឹកនាំ) លុះបានមកជួបខ្ញុំនៅឯស្រះ (អាល់-ហោ្ហដ៍) [នៃកៅស្ហារ ក្នុងថ្ងៃរស់ពីស្លាប់វិញ] ។"*



*អនុញ្ញាតរបស់អល់ឡោះហ្វ៍... ២:៩៧ ។"*[303]

អាស្រ័យអាយ៉ាស្ហ៍ខាងលើនេះនិងសេចក្ដីអធិប្បាយ យើងដឹងថាពួកយ៉ាហ៊្វូឌីមួយក្រុមស្អប់យ៉ីបរ៉អ៊ីល عليه السلام ហៅយ៉ីបរ៉អ៊ីល عليه السلام ថា "ម៉ាឡាអ៊ីកាស្ហ៍ អាល់-អាស្ហាប (ملائكة العذاب ទេវតារងទុក្ខ)" ចោទព្រះអង្គ عليه السلام ថាក្បត់ក្នុងការនាំព្រះរាជសារ ។

ដូច្នេះ ទំនៀម ឬពាក្យស្លោក "ខ៉ំណា អាល់-អាមីន (خانَ الأمين សច្ចការីក្បត់)" មានដើមកំណើតមកពីប្រជារាស្ត្រយ៉ាហ៊្វូឌីដែលមានជំនឿឆ្វេង ។ ពួកអ្នកនិពន្ធនៅប្រាជ្ញាខ្លះដែលធ្លាប់ជាសត្រូវស៊្ហីអ៊្ហស្ហ៍នោះ បានរើសយកសម្ដីពួកយ៉ាហ៊្វូឌីនេះមកទម្លាក់លើកស៊្ហីអ៊្ហស្ហ៍ ថាជាសម្ដីរបស់ស៊្ហីអ៊្ហស្ហ៍ក្នុងគោលបំណងបង្ខូចកេរ្ដិ៍ឈ្មោះ ។

# តំណែងសាស្ដាយោលតាមទ្រឹស្ដីស៊្ហីអ៊្ហស្ហ៍

អនុវត្តិតាមព្រះគម្ពីគួរអាននិងព្រះស៊ុនណាស្ហ៍ និងដោយផ្អែកលើហាឌីស្ហ៍ព្រះរាជកុលដ្ឋានរបស់ព្រះសាស្ដា صلى الله عليه وآله وسلم ស៊្ហីអ៊្ហស្ហ៍មិនត្រឹមតែចាត់ទុកមូហាំម៉ាដ្ហ៍ អ៊ីបនូ អ៊្ហប់ឌុលឡោះហ្វ៍ صلى الله عليه وآله وسلم ជាព្រះសាស្ដា صلى الله عليه وآله وسلم ពិតប្រាកដដែលអល់ឡោះហ្វ៍ عز وجل តែងតាំងជាព្រះសាស្ដាសាកលប៉ុណ្ណោះទេ ពួកគេចាត់ទុកព្រះអង្គ صلى الله عليه وآله وسلم ជាព្រះសាស្ដា صلى الله عليه وآله وسلم ចុងក្រោយបង្អស់ (ខ៉ំតាំ អាល់-អាន់ណាប៊ីយ៉ាអ៊្ហ៍ خاتم الأنبياء) និងជាព្រះរាជសាសនៈទូតថ្លៃថ្លាបំផុត ។

អ៊្ហលី អ៊ីបនូ អាប៊ី ត៉្ហលិប صلوات الله عليه والسلام អ៊ីម៉ាំស៊្ហីអ៊្ហស្ហ៍ បានធ្វើជាកសិណសាក្សីថានេះជាការពិត ជាឱឡារិកថា៖

«وأشهد أن لا إله إلاّ الله وحده لاشريك له وأشهد أنّ محمّداً عبده ورسوله، خاتم

[303] ស៊្ហូរ៉ោះត្ហ៍ អាល់-បាក៉្ហរ៉ោះត្ហ៍ 2:97 ។

អាយ៉ាស់ព្រះមហាគម្ពីរគួរអាននិងហាឌីស្ហបានរាយការណ៍ថាពួកយ៉ាហ៊ូឌីគិតថាយ៉ីបរ៉អ៊ីលعليه السلامបានក្បត់ពេលផ្ទេរព្រះរាជសារ ដោយអះអាងថាអល់ឡោះហ្ទ៏﷿បានដាក់ព្រះរាជបញ្ជា ឲ្យព្រះអង្គعليه السلامប្រគល់តំណែងសាស្តាឲ្យទៅបណ្តាកូនចៅរបស់អ៊ីសរ៉អ៊ីល (យ៉ាក់គូប) តាមខ្សែលោហិតអ៊ីសហ្កាក់ តែយ៉ីបរ៉អ៊ីលعليه السلامមិនប្រតិបត្តិតាមព្រះរាជបញ្ជាទេ បែរជាប្រគល់តំណែងសាស្តាឲ្យទៅបណ្តាកូនចៅរបស់អ៊ីសម៉ាអ៊ីលវិញ ។

ហេតុដូច្នេះ ពួកយ៉ាហ៊ូឌីមួយក្រុមចាត់ទុកយ៉ីបរ៉អ៊ីលعليه السلامជាសត្រូវ[301] ហើយទន្ទេញជាប់មាត់ថា៖ "ខ៉ំណា អាល់-អាមីន (خانَ الأمين មានន័យថាសច្ចការីក្បត់)" ។ ដូច្នេះ គួរអានស្តីបន្ទោសពួកគេដែលបាននិយាយបង្កាច់នោះ ហើយបានបញ្ជាក់ថាយ៉ីបរ៉អ៊ីលعليه السلامជា *រះហ៊ុល-អាមីន* មានន័យទេវតាជាទីទុកចិត្ត គឺ៖

نَزَلَ بِهِ ٱلرُّوحُ ٱلۡأَمِينُ ١٩٣ عَلَىٰ قَلۡبِكَ لِتَكُونَ مِنَ ٱلۡمُنذِرِينَ ١٩٤

*"ព្រះវិញ្ញាណជាទីទុកចិត្តបាននាំវា (គួរអាន) ចុះមកមកក្នុងដួងចិត្តអ្នក ដើម្បីនឹងឲ្យអ្នកទៅជាជនម្នាក់ ក្នុងចំណោមអ្នកដាស់តឿនទាំងឡាយ (ដើម្បីនឹងឲ្យអ្នកហៅមនុស្សមករកអល់ឡោះហ្ទ៏) ២៦:១៩៣-១៩៤ ។"*[302]

ព្រះគម្ពីរគួរអានចែងនៅក្នុងអាយ៉ាស់មួយទៀតថា៖

قُلۡ مَن كَانَ عَدُوًّا لِّـجِبۡرِيلَ فَإِنَّهُۥ نَزَّلَهُۥ عَلَىٰ قَلۡبِكَ بِإِذۡنِ ٱللَّهِ

*"ចូរអ្នកថា៖ "បុគ្គលណាជាសត្រូវរបស់យ៉ីបរីល (គឺយ៉ីបរ៉អ៊ីល) ព្រោះគេ (គឺយ៉ីបរ៉អ៊ីល) បាននាំវា (គឺគួរអាន) មកដាក់ក្នុងដួងចិត្តអ្នកដោយការ*

---

[301] សូមមើល *តាហ្វសៀរ អាល់-ហ្វាក់រ៍ អារ-រ៉ស៊ី (التفسير الفخر الرازي)* (បោះពុម្ពនៅអេស៊ីបត៍ ឆ្នាំ 1308 ស.ហ.) ដុំទី ១ ទំព័រ ៤៣៦-៤៣៧ ។

[302] ស៊ូរ៉ោះត៍ អាស់-ស្ហ៊អារ៉អ៍ 26:193-194 ។



កាលណាអាស្ហ់លុល-បៃត៍របស់ព្រះសាស្តាﷺមិនចាកផុតពីការភ្លាំងភ្លាត់និងកំហុសទេ កាលនោះអាស្ហ់លុល-បៃត៍របស់ព្រះសាស្តាﷺនឹងបែកចេញពីគួរអានដែលគ្មានកំហុសឆ្គាំឆ្គងនោះ ហើយនឹងវង្វេង ចំណែកឯព្រះសាស្តាﷺបានបដិសេធករណីនេះដាច់អហង្ការ ។

ការពិត "អាស្ហ់លុល-បៃត៍" យោលតាមសម្តីព្រះសាស្តាﷺនោះមិនសំដៅទៅលើសាច់ញាតិ ឈាមជ័រតែមួយទាំងអស់របស់ព្រះអង្គﷺនោះទេ ព្រោះសាច់ញាតិទាំងនោះមិនចាកផុតពីការភ្លាំងភ្លាត់ទាំងអស់គ្នាទេ ។

ហេតុដូច្នេះ បណ្តាកូនចៅរបស់ព្រះអង្គﷺមួយក្រុមដាច់ឡែកប៉ុណ្ណោះដែលប្រកបដោយកិត្តិយសប្រភេទនេះ ហើយឋានៈនិងលក្ខន្តិកនេះបានតែលើសាច់ញាតិមានកំណត់ប៉ុណ្ណោះ បុគ្គលទាំងនេះគឺអ៊ីម៉ាំអាស្ហ់លុល-បៃត៍عليهم السلامនោះឯងដែល នៅក្នុងប្រវត្តិសាស្រ្តតរៀងមក ជាពន្លឺរស្មីបំភ្លឺមាគ៌ាអ៊ុមម៉ាត់ ជាអ្នកថែរក្សាព្រះស៊ុនណាស់ព្រះសាស្តាﷺនិងជាអនុរក្សច្បាប់ស្ហារីអ៊ាស់ ។

# សំណួរ ៧ - ហេតុអ្វីស្ហ៊ីអ៊ាស់ថែម "អាស្ហ់ហាឌូ អាន់ណាអ៊ាលីយ៉ាន់ វ៉ាលីយុលឡោះហ្ទ៏" នៅក្នុងការប្រកាសស្ហ៏ឡាត់ ?

ក្នុង *អាស្ហាន* (ប្រកាសស្ហ៏ឡាត់) ហេតុអ្វីថា "អាស្ហ់ហាឌូ អាន់ណាអ៊ាលីយ៉ាន់ វ៉ាលីយុលឡោះហ្ទ៏" (ខ្ញុំសូមប្តេជ្ញាថាអ៊ាលីជាវ៉ាលីរបស់អល់ឡោះហ្ទ៏﷿) ហើយសូមដឹងឮ *វីឡាយ៉ាស់* (អាណាព្យាបាលភាព)

របស់អ៊ុលី صلوات الله عليه والسلام ?

## ចម្លើយ

ដើម្បីឆ្លើយតបសំណួរនេះ យើងសូមលើកយកចំណុចខាងក្រោមនេះមកពិនិត្យ ។

១. នៅក្នុងសៀវភៅនីតិសាស្រ្ត (ហ្វីកោ្វះត្ហ៍ فقه) អ្នកនីតិសាស្រ្ត (ហ្វ៊ូក៏ហ្វា فقهاء) ស្ហ៊ីអ៊្អាស់ទាំងអស់បញ្ជាក់ធ្ងន់ថា និយាយថា៖ "ខ្ញុំសូមដឹងព្ *វីឡាយ៉ាស់* របស់អ៊ុលី صلوات الله عليه والسلام" មិនមែនប៉ែកមួយរបស់អាស្ហាននិងអ៊ីក្វ៏ម៉ាស់ទេ ហើយមិនមានសិទ្ធថាវាជាប៉ែកមួយរបស់អាស្ហាន់ឬអ៊ីក្វ៏ម៉ាស់ទេ ។

២. យោលតាមមតិគ្វរអាន អ៊ុលី صلوات الله عليه والسلام ជាម្នាក់ក្នុងចំណោម *អៅលីយ៉ាអ៍ (أولياء)* អាយ៉ាស់ខាងក្រោមនេះចែងអំពី *វីឡាយ៉ាស់* របស់ព្រះអង្គ صلوات الله عليه والسلام យ៉ាងច្បាស់លាស់ លើមុស្លីមទាំងអស់ គឺ៖

إِنَّمَا وَلِيُّكُمُ ٱللَّهُ وَرَسُولُهُۥ وَٱلَّذِينَ ءَامَنُواْ ٱلَّذِينَ يُقِيمُونَ ٱلصَّلَوٰةَ وَيُؤْتُونَ ٱلزَّكَوٰةَ وَهُمْ رَٰكِعُونَ

*"ឧបត្ថម្ភក (អ្នកទំនុកបម្រុង អ្នកគាំទ្រ...) របស់ពួកអ្នកគឺមានតែអល់ឡោះហ្ ព្រះសាស្តារបស់ព្រះអង្គ និងបណ្ដាអ្នកមានសទ្ធាជ្រះថ្លាដែលធ្វើនមស្ការនិងធ្វើសទ្ធាទានខណៈឱនលំទោន[ចំពោះអល់ឡោះហ្] ទេ (៥:៥៥) ។"*[49]

ស្ហ៊ីហ្ហិះហ្ហ៍និងមុសណាដ៍ស៊ុននីរាប់បញ្ចូលសេចក្ដីរាយការណ៍ ដែលឆ្លុះបញ្ចាំងទៅលើអាយ៉ាស់ថ្លៃថ្លាដែលត្រូវដាក់ចុះមក ដើម្បីលើកតម្កើងអ៊ុលី صلوات الله عليه والسلام ដែល ក្នុងពេលព្រះអង្គ صلى الله عليه وآله وسلم កំពុង *រុគុអ៍* (ឱនក្នុងពេលស្ហ៊ូឡាត់) ព្រះ

[49] ស៊ូរ៉ោះត្ហ៍ អាល់-ម៉ាអ៊ីដ្ហាស់ ៥:៥៥ ។



គម្ពីរនិងផ្ទុយពីព្រះស៊ុនណាស់ទៀតផង ។

## សេចក្ដីសរុប

ហ្ហាឌីស្ហ អាដ្ហ៍-ឌ្ហុះហ្ហ៍ដ្ហាស់ ដោយផ្អែកលើបណ្ដាញអ្នករាយការណ៍និងលើខ្លឹមសារវានោះ មិនអាចជឿបាន មិនអាចទុកចិត្តលើបានឡើយ ។ ដូច្នេះ សំណង់ដែលត្រូវសាងសង់ឡើងក្នុងគោលបំណងបំផ្លិចបំផ្លាញជំនឿស្មោះអស់ពីចិត្តរបស់ អាប៊ូ ត្ហ៍លិប رضي الله عنه នោះត្រូវរលំរលាយអសារបង់ ។ វង់ភក្រ្តត្រចះត្រចង់របស់បុរសគ្វរ៉យ៉ស្ហ៍ដែលមានសទ្ធាជ្រះថ្លា អ្នកការពារ ជ្រោមជ្រែងព្រះសាស្ដា صلى الله عليه وآله وسلم នឹងនៅតែភ្លឺរហូតតរៀងទៅ ។

## សំណួរ ៣០ - តើស្ហ៊ីអ៊្អាស់យល់ឃើញទេថាឃ្ជីបរ៉អ៊ីល عليه السلام ភាន់ច្រឡំនាំព្រះរាជសារមកឲ្យមូហ្ហាំម៉ាដ្ហ៍ صلى الله عليه وآله وسلم តែការពិតព្រះអង្គ عليه السلام ត្រូវនាំមកឲ្យ អ៊ុលី អ៊ីបនូ អាប៊ី ត្ហ៍លិប នោះវិញទេ ?

## ចម្លើយ

មុននឹងអធិប្បាយបំភ្លឺថាការចោទប្រកាន់មិនសមហេតុផលសមផល មកលើស្ហ៊ីអ៊្អាស់ដោយបុគ្គលអវិជ្ជា ឬទុរជនអន្យតិរ្ថិយនោះ គប្បីរំលឹកដើមកំណើតនៃការចោទប្រកាន់នេះ ។

## ដើមកំណើតនៃការនិយាយបង្ខូចនេះ

ឡើយ ។

អាស្រ័យហេតុនេះ អត្ថន័យរបស់ហាឌីស្ហ អាដ្ហ-ឌុះហ៊្ហាស្ហ៍ ដែលសន្មតថា អាប៊ូ ត៏លិប ជាកាហ្វៀរនោះមិនសមហេតុផលទេ មិនអាចជឿបានឡើយ ។ យើងនឹងឆ្លើយបំភ្លឺរឿងនេះនិងបង្ហាញភ័ស្តុតាងច្បាស់លាស់ដកស្រង់ពីព្រះគម្ពីរអល់ឡោះហ្ទ៏ﷻនិងព្រះស៊ុនណាស់ព្រះសាស្តាﷺ ។

ក. ព្រះមហាគម្ពីរគួរអានថែងអំពីរឿងនេះថា៖

وَٱلَّذِينَ كَفَرُواْ لَهُمۡ نَارُ جَهَنَّمَ لَا يُقۡضَىٰ عَلَيۡهِمۡ فَيَمُوتُواْ وَلَا يُخَفَّفُ عَنۡهُم مِّنۡ عَذَابِهَاۚ كَذَٰلِكَ نَجۡزِي كُلَّ كَفُورٖ

*"រីឯជនទាំងឡាយដែលបដិសេធសទ្ធានឹងទទួលរងនូវភ្លើងនរក ។ គេនឹងមិនឲ្យពួកគេស្លាប់ទេ ទណ្ឌកម្មពួកគេនឹងមិនត្រូវបន្ធូរបន្ថយទេ ។ បែបនេះឯងដែលយើងតបស្នងអ្នកណាដែលមិនដឹងគុណ ៣៥:៣៦ ។"*[300]

ខ. ព្រះស៊ុនណាស់ព្រះសាស្តាﷺ ក៏បដិសេធការជួយធ្វើអន្តរាគមន៍ឲ្យពួកកាហ្វៀរដែរ ។ លោក អាប៊ូ ស្ទុរ អាល់-ឌ៊ីហារី រាយការណ៍តមកពីព្រះសាស្តាﷺអល់ឡោះហ្ទ៏ﷻថា៖

«أُعطيت الشّفاعة وهي نائلةٌ من أُمّتي من لا يشرك بالله شيئاً».

*"ការជួយធ្វើអន្តរាគមន៍របស់ខ្ញុំបានតែលើអ្នកអ៊ុមម៉ាត់ខ្ញុំទេ ដែលមិនហ៊ុនហាយជាមួយអល់ឡោះហ្ទ៏ﷻ ។"*

អាស្រ័យហេតុនេះ ហាឌីស្ហ អាដ្ហ-ឌុះហ៊្ហាស្ហ៍ដែលថែងថាអាប៊ូ ត៏លិបជាកាហ្វៀរនោះមិនត្រឹមត្រូវ មិនសមហេតុសមផលទេ ព្រមទាំងផ្ទុយពីព្រះ

[300] ស្ហ៊ូរ៉ោះត្ហ៍ អាល់-ហ្វាតៀរ 35:36



អង្គصلوات الله عليه والسلامដោះចិញ្ចៀនព្រះអង្គصلوات الله عليه والسلامឲ្យទៅអ្នកក្រម្នាក់ ។[50] ពេលអាយ៉ាស់នេះ ដែលស្តីអំពីអាលីصلوات الله عليه والسلام ត្រូវបានដាក់ចុះមក លោកហ៊ាសាន់ អ៊ីបនូស្ហាប៊ីត បានចងក្រងព្រឹត្តិការណ៍ជាកំណាព្យដូចតទៅ៖

فأنت الذي أعطيت إذ أنت راكع

فدتك نفوس القوم يا خير راكع

فأنزل فيك الله خير ولاية

وبينهما في مُحكمات الشرائع

*"ព្រះអង្គគឺបុគ្គលដែលបរិច្ចាគពេលកំពុងរូគុអ៏ ។ សូមមិត្តទាំងអស់បានបូជាជីវិតដើម្បីព្រះអង្គ ឱបុគ្គលប្រសើរជាង់អស់អ្នកឱនទាំងឡាយអើយ ។ ដូច្នេះហើយ បានជាអល់ឡោះហ្ទ៏ﷻដាក់វីឡាយ៉ាស់ប្រសើរបំផុតមកឲ្យព្រះអង្គ ហើយបានពន្យល់វីឡាយ៉ាស់នេះតាមរយៈបញ្ញត្តិនៃច្បាប់ស្ហារីអ៊ាស់ ។"*

៣. ព្រះសាស្តាﷺមានព្រះវចនៈថា៖

إنما الأعمال بالنّيات.

*"ការពិត ទង្វើ[ត្រូវវិនិច្ឆ័យ]អាស្រ័យបំណង ។"*

ដោយហេតុថា *វីឡាយ៉ាស់* របស់អាលីصلوات الله عليه والسلامជាគោលការណ៍មួយមានថែងនៅក្នុងគួរអាននោះ ហើយមួយឃ្លាដែលបាននិយាយខាងលើនេះមិនត្រូវចាត់ទុកជាប៉ែកមួយរបស់ *អាស្ទាន* (ឬ *អ៊ីក៏ម៉ាស់*) ទេនោះ តើមានកំហុស

[50] សៀវភៅយោងស្តីអំពីមូលហេតុដែលអាយ៉ាស់នេះត្រូវដាក់ចុះមកនោះ ច្រើនជាងសេចក្តីអធិប្បាយខាងលើនេះ ។ សូមលើកយកសៀវភៅយោងខ្លះមកដាក់ជូន គឺ៖ *តាហ្ស៊ៀរ អាត់-ត៏បារី (تفسير الطبري)* ជុំទី ៦ ទំព័រ ១៨៦ ។ *អាស្ហ៊កាំ អាល់-គួរអាន (احكام القرآن) (تفسير الجصاص)* ជុំទី ២ ទំព័រ ៥៤២ ។ *តាហ្ស៊ៀរ អាល់-បៃដ្ហ៏វី (تفسير البيضاوي)* ជុំទី ១ ទំព័រ ៣៤៥ ។ *អាដ្ហ-ឌួរ អាល់-ម៉ាន់ស្ហ៊ូរ (الدر المنثور)* ជុំទី ២ ទំព័រ ២៩៣ ។

អ្វីបើគេសូត្រមួយឃ្លានេះ គួបនឹងការប្តេជ្ញាដឹងឮសាស្តាភាពរបស់ព្រះសាស្តាﷺនោះ ?

ត្រង់នេះ ចាំបាច់ត្រូវនិយាយថាបើដោយសារតែបញ្ចូលឃ្លាមួយក្នុង *អាស្ទាន* ស្ទ៏អុស្ទ័ត្រូវគេថ្កោលទោសនោះ តើសមហេតុផលទេទាក់ទងនឹងករណីពីរដូចតទៅនេះ ?

១. សៀវភៅប្រវត្តិសាស្ត្រពិតប្រាកដបញ្ជាក់អះអាងថាឃ្លានេះ

حيّ على خير العمل (ហៃ្យ៉ា អាឡា ខ្ញុំរីល-អុម៉ាល់ - ចូរមកសាងអំពើល្អប្រសើរបំផុត) ជាប៉ែកមួយរបស់ *អាស្ទាន*[51] តែក្នុងរជ្ជកាលស្តេចខ៉ូលិហ្វទីពីរ ឃ្លានេះត្រូវលុបចោលដោយមានលេសថាពេលប្រជារាស្ត្រឮពាក្យ "អំពើល្អប្រសើរបំផុត" ពួកគេនឹងគិតថា ស្វ៏ឡាត់ប្រសើរជាង *យ៉ីហាដ្ឋ* ហើយនឹងឈប់ចូលរួមក្នុង *យ៉ីហាដ្ឋ ។* ករណីនេះក៏នៅក្នុងស្ថានភាពនេះតរៀងមក ។ [៥២]

[51] សូមមើលសៀវភៅ *កាន់ស៊ុ អាល់-អ៊ុម៉ាល់ (كنز العمال)* "គីតាប អាស្វ៉-ស្វ៏ឡាត់" ជុំទី ៤ ទំព័រ ២៦៦ ។ សៀវភៅ *អាត្ត-ត៏បារ៉នី (الطبراني)* "កាណា ប៊ីឡាល់ យុស៊ីន ប៊ីស-ស៊ុបហ៍ ហ្វាយ៉ាគ្គុល: ហៃ្យ៉ា អុឡា ខ្ញុំរ៉ល់-អុម៉ាល់" ។ *ស៊ូណាន បៃហាគ្គី (سنن الكبرى بيهقي)* ជុំទី ១ ទំព័រ ៤២៤-៤២៥ ។ សៀវភៅរបស់លោក ម៉ាលិក អាល់-មូវ៉ាត្តត្ត៏ (الموطأ) ជុំទី ១ ទំព័ ៩៣ ។

[52] សូមមើលសៀវភៅ *កាន់ស៊ុ អាល់-អៀរហ្វាន* ជុំទី ២ ទំព័រ ១៥៨ ។ សូមមើលសៀវភៅ *ស្វ៊ីរ៉ត្ត អាល់-មុសតាគ្គីម វ៉ា យ៉ាវ៉ាហៀរ អាល់-អាក្ខបារ វ៉ា អាល់-អាស្វារ* ជុំទី ២ ទំព័រ ១៩២ ។ សូមមើលសៀវភៅ *ស្ហារហ៍ អាត់-តាច្ចរីដ្ឋ (شرح التجريد)* របស់លោក អាល់-គ្គូស្ហយ៉ី (القوشجي) "អំពីអ៊ីម៉ាម៉ាស្វ"ទំព័រ ៤៨៤៖

«صعد المنبر وقال: أيّها الناس ثلاث كنّ على عهد رسول الله أنا أنهى عنهنّ وأحرمهنَ وأعاقب عليهنّ وهي متعة النساء ومتعة الحج وحيّ على خير العمل».



*មិនអើពើអំពីប្រភេទហ៉ាឌីស្ហដែលគាត់បានឮនោះទេ ។"*[298]

លោក ណាបាទី ក៏ចាត់ទុកគាត់ជាអ្នករាយការណ៍ខ្សោយដែរ ហើយបាននិយាយដល់ឈ្មោះគាត់នៅក្នុងសៀវភៅលោក ដែលមានចំណងជើងថា *អាត់-តាស្វ់លិល អុឡាល់-កាមីល* លោកបង្ហាញតែឈ្មោះរបស់អ្នករាយការណ៍ខ្សោយ ។ [299]

យើងឃើញថាអ្នករាយការណ៍សំខាន់ៗរបស់ *ហ៉ាឌីស្ហ អាដ្ឋ-ឌ្ហុះហ្ប៉ាដ្ឋាស្វ់* ជាអ្នករាយការណ៍ខ្សោយ មិនអាចទុកចិត្តបានទេ ។

## ហ៉ាឌីស្ហ អាដ្ឋ-ឌ្ហុះហ្ប៉ាដ្ឋាស្វ់ មិនសមស្របនឹងព្រះគម្ពីរអល់ឡោះហ្ទ៏ﷻនិងព្រះស៊ុនណាស្វ់ព្រះសាស្តាﷺទេ ។

ហ៉ាឌីស្ហខាងលើនេះសន្មតថាព្រះសាស្តាﷺនឹងយកអាប៊ូ ត៏លិបចេញពីបាតនរកទៅកាន់រណ្តៅរាក់មួយដែលនៅក្នុងនរកនោះ ដើម្បីសម្រាលទណ្ឌកម្មដែលពោលនោះ ឬព្រះអង្គﷺចង់ធ្វើអន្តរាគមន៍ឲ្យលោកក្នុងថ្ងៃជំនុំជម្រះ ។ តែព្រះគម្ពីរគួរអាននិងព្រះស៊ុនណាស្វ់ព្រះសាស្តាﷺទទួលស្គាល់ថាការសម្រាលទណ្ឌកម្ម និងការជួយធ្វើអន្តរាគមន៍របស់ព្រះសាស្តាﷺនោះបានតែលើបណ្តាអ្នកមានសទ្ធានិងមុស្លីមទេ ។ ហេតុដូច្នេះ ប្រសិនបើ អាប៊ូ ត៏លិប ជាកាហ្វៀរមែននោះ ព្រះសាស្តាﷺប្រាកដជាមិនអាចជួយសម្រាលទណ្ឌកម្ម ឬជួយធ្វើអន្តរាគមន៍ឲ្យលោកបាន

[298] សូមមើលសៀវភៅរបស់លោក អាស្វ់-ស្វាហ្វាប៊ី *មីស៊ាន អាល់-អ៊ិអ៊័ទីដ្ឋាល់ (ميزان الأعتدال)* (បោះពុម្ពនៅបៃរូត ឆ្នាំ 1382 ស.ហ.) ជុំទី ៣ ទំព័រ ៤២៣ ។

[299] សូមមើល ស្ហៃខ៍ អាល់-អាប់តាស់ ទំព័រ ៧៥ ។ *មីស៊ាន អាល់-អ៊ិអ៊័ទីដ្ឋាល់ (ميزان الأعتدال)* ជុំទី ៣ ទំព័រ ៤២៣ ។

លោក អាប៊ូ ហ្កាទីម មានប្រសាសន៍អំពីគាត់ថាៈ

«لا يحتجّ به»

*"គេមិនអាចទុកចិត្តគាត់បានទេ ។"*[295]

លោក អាប៊ូ ស៊ារ៉អុស្ម មានប្រសាសន៍អំពីគាត់ថា سيّئ الحفظ (សៃយ៉ាកុំ អាល់-ហ្ហ៊ីហ្វស្ហ៍) មានន័យថា មិនសូវមានការចងចាំ ។ [296]

ឃ. ឡៃស្ហ៍ អ៊ីបនូ សាអ៊ុជុំ

ពេលយើងសិក្សាសៀវភៅរបស់អស់លោក អ្នកជំនាញខាងស្រាវជ្រាវអំពីអ្នករាយការណ៍ហាឌីស្ហ៍ស៊ុននី (អ៊ីលម៍ អារ-រីយ៉ាល់) យើងឃើញថាអ្នករាយការណ៍ហាឌីស្ហ៍ដែលមានឈ្មោះថា "ឡៃស្ហ៍" នោះជាបុគ្គលដែលគេមិនស្គាល់ឬខ្សោយ មិនអាចជឿសម្ដីបានទេ ។ [297]

លោក ឡៃស្ហ៍ អ៊ីបនូ សាអ៊ុជុំ ជាអ្នករាយការណ៍ខ្សោយ មិនយកចិត្តទុកដាក់អំពីអ្វីៗដែលគាត់បានឮ មិនយកចិត្តទុកដាក់នឹងមនុស្សដែលគាត់បានស្រង់យកសម្ដីនោះទេ ។

លោក យ៉ាស្ហ៊ុយ៉ា អ៊ីបនូ មូអ៊ីនមានប្រសាសន៍អំពីគាត់ថាៈ

«إنّه كان يتساهل في الشّيوخ والسمّاع»

*"គាត់មិនអើពើអំពីឈ្មោះរបស់បណ្ដាអ្នកដែលគាត់ស្រង់យកសម្ដីទេ ឬ*

[295] សូមមើលសៀវភៅរបស់លោក អាស្ហ-ស្ហាហ្ហាបី *មីស៊ាន អាល់-អ៊ុអ៊ុទីដាល់ (ميزان الأعتدال)* (បោះពុម្ពនៅបៃរូត ឆ្នាំ 1382 ស.ហ.) ជុំទី ២ ទំព័រ ៦៣៥ ។

[296] សូមមើលសៀវភៅរបស់លោក អាស្ហ-ស្ហាហ្ហាបី *មីស៊ាន អាល់-អ៊ុអ៊ុទីដាល់ (ميزان الأعتدال)* (បោះពុម្ពនៅបៃរូត ឆ្នាំ 1382 ស.ហ.) ជុំទី ២ ទំព័រ ៦៣៥ ។

[297] សូមមើលសៀវភៅរបស់លោក អាស្ហ-ស្ហាហ្ហាបី *មីស៊ាន អាល់-អ៊ុអ៊ុទីដាល់ (ميزان الأعتدال)* (បោះពុម្ពនៅបៃរូត ឆ្នាំ 1382 ស.ហ.) ជុំទី ៣ ទំព័រ ៤២០-៤២៣ ។



២. ឃ្លា الصلوة خير من النوم (អាស្ស-ស្វ៍ឡាត្តុំ ខ៉យ់រុន មីនណាន់-ណៅម៍ - ស្វ៍ឡាត្តប្រសើរជាងដេក) មិនមែនប៉ែកមួយរបស់ *អាស្សាន* ទេក្នុងសម័យព្រះសាស្ដាﷺ តែត្រូវដាក់ចូលក្នុងអាស្សានក្រោយមក[53] ។ ហេតុដូច្នេះនៅក្នុងសៀវភៅ អាល់-អ៊ុម (كتاب الأم) អ៊ីម៉ាំស្ហាហ្វីអ៊ីមានប្រសាសន៍ថាៈ

"أكره في الأذان الصلوة خير من النوم لأن أبا محذورة لم يذكره."

*"ខ្ញុំមិនចូលចិត្តទេដែលយើងសូត្រក្នុងអាស្សានថា អាស្ស-ស្វ៍ឡាត្តុំ ខ៉យ់រុន មីនណាន់-ណៅម៍ នោះ ពីព្រោះ អាប៊ូ មាស្ហ៊ូរ៉ះត៍ (អ្នកថ្លែងការណ៍និងមូហាជុំឌីស្ហ៊ន) មិនរាប់បញ្ចូលឃ្លានេះ[ក្នុងកម្រងហាឌីស្ហ៍លោក]ទេ ។"*[54]

## សំណួរ ៨ - អ្នកណាទៅ ម៉ាស្ហ៊ូឌី សន្ដតិវង្សរបស់មូហាំម៉ាជុំ ? ហេតុអ្វីអស់លោករង់ចាំម៉ាស្ហ៊ូឌីនេះងើបឡើង ?

## ចម្លើយ

ក្នុងចំណោមបញ្ហាច្រើន ដែលព្រះសាសនាមានមតិស្របគ្នានោះគឺ "អ្នកសង្គ្រោះសាកលលោក" ដែលនឹងងើបឡើងនាអវសានកាល ។ មិនត្រឹមតែមុស្លីមទេ ពួកយ៉ាហ៊ូឌីនិងពួកគ្រិស្តក៏រង់ចាំបុរសនេះងើបឡើងដែរ ដែលនឹងសាបព្រោះយុត្តិធម៌ក្នុងពិភពលោក ។ បើយើងមើលគម្ពីរសញ្ញា

[53] សូមមើលសៀវភៅ *កាន់ស្ហ៍ អាល់-អ៊ុម៉ាល់ (كنز العمال)* "គីតាប អាស្ស-ស្វ៍ឡាត្តុំ" ជុំទី ៤ ទំព័រ ២៧០ ។

[54] កត់ត្រានៅក្នុងសៀវភៅ *ដាឡាអ៊ីល អាស្ស-ស្ហ៊ីឌ្ហិក្ហ* ជុំទី ៣ "អាល់-គ៉ីសម៍ អាស្ស-ស្ហានី" ទំព័រ ៩៧ ។

ចាស់និងសញ្ញាថ្មី យើងនឹងអាចយល់រឿងនេះបាន ។[55]

ទាក់ទងនឹងរឿងនេះ លោកអ្នកប្រាជ្ញខាងហាឌីស្សមានប្រសាសន៍ថាព្រះសាស្ដាﷺមានព្រះវចនៈថា៖

لو لم يبق من الدهر إلا يوم لبعث الله رجلاً من أهل بيتي يملأها عدلاً كما مُلئت جوراً.

*"ទោះបីលោកនោះនៅសល់អាយុកាលតែមួយថ្ងៃក៏ដោយ ក៏អល់ឡោះហ៍ ﷻនឹងចាត់បញ្ជូនមកនូវបុរសម្នាក់ ដែលចេញមកពីអាស់លុល-បៃត៍ខ្ញុំ (គឺចេញមកពីសន្តតិវង្សខ្ញុំ) ។ បុរសនោះនឹងសាបព្រោះយុត្តិធម៌និង សមធម៌ពេញផែនដី ដូចកាលវាពោរពេញដោយការសង្កត់សង្កិននោះដែរ ។"*[56]

ដូច្នេះ យើងបានរៀបរាប់រួចមកហើយ អាជ្ញាធរព្រះសាសនាទទួលស្គាល់ជំនឿលើការងើបឡើងរបស់បុរសអ្នកសង្គ្រោះសាកលលោក ព្រមទាំងច្រើនហាឌីស្សដែរដែលស្ដីអំពីម៉ាស់ឌីជាទីសង្ឃឹម នៅក្នុងតម្រាស្វ័ហ៊ិះហ៍ និងមុសណាដ៍របស់អាស្ហ៍លុល-ស៊ុនណាស្ហ៍ ។ អស់លោកអ្នកប្រាជ្ញខាងហាឌីស្សរបស់និកាយអ៊ីស្លាមទាំងពីរ (ស្ហ៊ីអាស្ហ៍និងស៊ុននី) បានសរសេរសៀវភៅល្អៗច្រើនស្ដីអំពីបុរសនេះ ។[57]

---

[55] សូមមើលទំនុករបស់ស្ដេចដាវីឌ ៩៦-៩៧; គម្ពីរដានីយ៉ែល កណ្ឌទី ១២ សញ្ញាចាស់ ។ ដំណឹងល្អតាមម៉ាថាយ កណ្ឌ ២៤; ដំណឹងល្អតាមម៉ាកុស កណ្ឌ ១៣; ដំណឹងល្អតាមលូកា កណ្ឌ ២១ សញ្ញាចាស់ ។ សេចក្ដីរាយការណ៍ទាំងនេះស្ដីអំពីបុគ្គលជាទីសង្ឃឹមដែលពិភពលោករង់ចាំ ។

[56] សូមមើល *ស៊ូណាន់ អាប៊ូ ដាវុដ* (បោះពុម្ពនៅប្រទេសអេស៊ីបត៍ដោយ Taziyyah Press, n.d.) ជុំទី ២ ទំព័រ ២០៧; *យ៉ាណាប៊ិអ៊ុ អាល់-មូវ៉ាដ្ដាស្ហ៍ (ينابيعُ المودّة)* ទំព័រ ៤៣២; *នូរ អាល់-អាប់ស្វារ (نورُ الأبصار)* បាប់ ២ ទំព័រ ១៥៤ ។

[57] ដូចជាសៀវភៅរបស់លោក មូហាំម៉ាដ់ អ៊ីបនូ យូស៊ុហ្វ អ៊ីបនូ អាល់-កាន់ឈ៊ី អាស្ហ៍-ស្ហាហ៊្វីអ៊ី *អាល់-បាយ៉ាន ហ្វី អាក់បារ ស្វហ៊ីប អាស់-ស្ហាម៉ាន់ ( البيان فى اخبار*



ប្រសាសន៍ទាំងនេះបង្ហាញឲ្យឃើញថាលោក អាប់ឌុល-ម៉ាលិក អ៊ីបនូ អ៊ុម៉ៃរ៍មានលក្ខណៈដូចតទៅគឺ៖

១. លោកខ្សោយខាងការចងចាំ និងភ្លេចភ្លាំងច្រើន ។

២. លោក "ខ្សោយ" យោលតាមអ្នកប្រាជ្ញខាង *អ៊ីលម៍ អារ-រីយ៉ាល់* មិនអាចទុកចិត្តបានទេ ។

៣. លោកភ្លាត់ភ្លាំងច្រើន ។

៤. លោកលាយឡំហាឌីស្សមិនពិតជាមួយហាឌីស្សពិត ។

លក្ខណៈតែមួយ ក្នុងចំណោមលក្ខណៈទាំងអស់ខាងលើនេះបណ្ដាលឲ្យហាឌីស្សរបស់លោក អាប់ឌុល-ម៉ាលិក អ៊ីបនូ អ៊ុម៉ៃរ៍គ្មានការសមហេតុផល ។ ចុះបើលក្ខណៈទាំងអស់នេះមាននៅក្នុងខ្លួនរបស់បុគ្គលតែម្នាក់ ?

គ. លោក អាប់ឌុល-អាស៊ីស អ៊ីបនូ មូហាំម៉ាដ់ អាដ់-ដារ៉ាវ៉ារឌី

អ្នកប្រាជ្ញស៊ុននី ជំនាញខាងការស្រាវជ្រាវផ្នែកអ្នករាយការណ៍ហាឌីស្ស (អ៊ីលម៍ អារ-រីជ្ជយ៉ាល់) ចាត់ទុកលោក អាដ់-ដារ៉ាវ៉ារឌី ជាបុគ្គលភ្លេចភ្លាំងមានការចងចាំខ្សោយណាស់មិនអាចជឿហាឌីស្សលោកបានទេ ។

លោក អាស្ហ៍ម៉ាដ់ អ៊ីបនូ ហាន់បាល់ មានប្រសាសន៍អំពីលោក អាដ់-ដារ៉ាវ៉ារឌីថា៖

«إذا حدّث من حفظه جاء ببواطيل»

*"ពេលគាត់ថ្លែងហាឌីស្សតាមការចងចាំ គាត់ភ្លាត់ភ្លាំង និយាយក្រៅរឿង ។"*[294]

---

[294] សូមមើលសៀវភៅរបស់លោក អាស្ហ៍-ស្ហាហាប៊ី *មីស្សាន អាល់-អ៊ិអ៍ទីដាល់ (ميزان الأعتدال)* (បោះពុម្ពនៅបៃរូត ឆ្នាំ 1382 ស.ហ.) ជុំទី ២ ទំព័រ ៦៣៤ ។

*ខ្សោយ ។"*[292]

ប្រសាសន៍នេះបញ្ជាក់ថាសម្ដីរបស់លោកស៊ុហ្វយ៉ាន អាស្ស៊-ស្សៅរីជាសម្ដីបោកប្រាស់ រាយការណ៍តមកពីអ្នករាយការណ៍ខ្សោយឬដែលគេមិនស្គាល់ ។

ហេតុដូច្នេះ ហាឌីស្សរបស់លោកមិនអាចយកជាការបានឡើយ ។

ខ. លោក អុាប់ឌុល-ម៉ាលិក អ៊ីបនូ អុ៊ម៉ៃរ៍

លោក អាស្ស-ស្សាហ្ហាប៊ីមានប្រសាសន៍អំពីលោក អុ៊ីបនូ អុ៊ម៉ៃរ៍ថាៈ

«طالَ عمره وساء حفظه. قال ابو حاتم. ليس بحافظٍ، تغيّر حفظه. وقال احمد. ضعيف يخلّط، وقال ابن معين: مخلط، وقال ابن خراش: كان شعبة لايرضاه وذكر الكوسج عن احمد انّه ضعّفه جدّاً»

*"គាត់ជាបុរសវ័យជរា មានអាយុវែង មានបញ្ហាខាងការចងចាំ ។ អាប៊ូហាតាំមានប្រសាសន៍ថាៈ "គាត់ចងចាំហាឌីស្សមិនបានទេ គាត់មិនអាចចងចាំអ្វីបានទេព្រោះគាត់មានវ័យចាស់ជរា ។" អាស្មា៉ដ្ជ អុ៊ីបនូ ហាន់បាល់មានប្រសាសន៍ដែរថាៈ "អុាប់ឌុល-ម៉ាលិក អុ៊ីបនូ អាល់-អុ៊ម៉ៃរ៍ខ្សោយ ភាន់ច្រឡំច្រើន (ពោលគឺ លោករាយការណ៍ហាឌីស្សប្រឌិត) ។" អុ៊ីបនូ មូអុ៊ីនមានប្រសាសន៍ថាៈ "គាត់លាយឡំហាឌីស្សមិនពិតជាមួយហាឌីស្សពិត ។" អុ៊ីបនូ ខ៊ិរ៉ស្ស៍មានប្រសាសន៍ថាៈ "ស្ស៊ុអ៊ូបាស្ស៍មិនចូលចិត្តគាត់ទេ ។" កៅសាជ្ជ៍មានប្រសាសន៍តមកពីអាស្មា៉ដ្ជ អុ៊ីបនូ ហាន់បាល់ថាអុាប់ឌុល-ម៉ាលិក អុ៊ីបនូ អុ៊ម៉ៃរ៍ខ្សោយណាស់នាអវសានជីវិតគាត់ ។"*[293]

[292] សូមមើលសៀវភៅរបស់លោក អាស្ស-ស្សាហ្ហាប៊ី *មីស្សាន អាល់-អុ៊អុ៊ទីដ្ឋាល់ (ميزان الأعتدال)* (បោះពុម្ពនៅបៃរូត ឆ្នាំ 1382 ស.ហ.) ជុំទី ២ ទំព័រ ១៦៩ ។

[293] សូមមើលសៀវភៅរបស់លោក អាស្ស-ស្សាហ្ហាប៊ី *មីស្សាន អាល់-អុ៊អុ៊ទីដ្ឋាល់ (ميزان الأعتدال)* (បោះពុម្ពនៅបៃរូត ឆ្នាំ 1382 ស.ហ.) ជុំទី ២ ទំព័រ ៦៦០ ។



ប្រជុំហាឌីស្សទាំងនេះបានបញ្ជាក់អំពីភិនភាគ និងទ្រង់ទ្រាយមុខរបស់បុរសនេះដែលសមនឹងព្រះរាជបុត្របង្កើតរបស់ អុ៊ីម៉ាំ ហាសាន់ អាល់-អុាស់ការី صلوات الله عليه والسلام[58] អុ៊ីម៉ាំទី ១១ ដែលស្ស៊ីអុាស្ស៍តាម ។ យោលតាមហាឌីស្សទាំងនេះ ព្រះនាមរបស់មហាបុរសនេះដូចព្រះនាមរបស់ព្រះសាស្ដា صلى الله عليه وآله وسلم[59] ដែរ ។ មហាបុរសនេះជាអុ៊ីម៉ាំទីដប់ពីរ[60] ហើយជាសន្ដតិវង្សរបស់ហ្វាសៃន៍ អុ៊ីបនូ អុាលី អាប៊ី ត៊ិលិប صلوات الله عليه والسلام ។[61]

តាមព្រះរាជបញ្ជារបស់អល់ឡោះហ្វ៍ عز وجل ម៉ាស្ស៍ឌីជាទីរង់ចាំ ប្រសូត្រក្នុងឆ្នាំ ២៥៥ សករាជហ៊ីជ្រ៉េាះត៊្ស៍ ហើយ សព្វថ្ងៃនេះព្រះអង្គមានព្រះជន្មគង់នៅដូចមនុស្សឯទៀត តែនៅក្នុងស្ថានភាពកំបាំង (កុយ់បាស្ស៍ الغيبة)

*(صاحب الزمان)*; សៀវភៅរបស់លោក អុាលី អុ៊ីបនូ ហ្វូសាំ អាដ្ជឌីន ដែលគេហៅថា មុតតាគ្គី អាល់-ហ៊ីនឌី (متقي الهندي) *អាល់-ប៊ូរហ្វាន ហ្វី អុាឡាម៉ាត់ ម៉ាស្ស៍ឌី អាខៀរ អាស្ស-ស្សាម៉ាន់*; សៀវភៅរបស់លោក អាស្មា៉ដ្ជ អាមីន អាល់-មីស្សរី ( حمد امين مصري) *ម៉ាស្ស៍ឌី វ៉ាល់-ម៉ាស្ស៍ដ្ឋាវីយ៉ាស្ស៍* ជាដើម ។ អុ៊ូឡាម៉ាស្ស៊ីអុាស្ស៍បានសរសេរសៀវភៅ ច្រើនទាក់ទងនឹងរឿងនេះ ដូចជា *អាល់-ម៉ាឡាហ៊ីម វ៉ាល់-ហ៊ីតាន់ (الملاحم والفتن)* ជាដើម ។

[58] សូមមើលសៀវភៅ *យ៉ាណាប៊ីអុ៊ អាល់-ម៉ាវ៉ាដ្ជដ្ឋាស្ស៍ (يَنابيعُ المودّة)* ភាគទី ៧៦ កណ្ឌ "សីលធម៌" រាយការណ៍តមកពី យ៉ាបៀរ អុ៊ីបនូ អុាប់ដ្ឋាល់ឡោះហ្វ៍ អាល់-អាន់ស្សរី (جابر بن عبد الله الأنصاري) ។

[59] សូមមើលសៀវភៅ *ស្សហ៊ិះហ្វ៍ តៀរមីស្ស៊ី* (បោះពុម្ពនៅ New Delhi, 1342 សហ.) ជុំទី ២; សៀវភៅ *មុសណាដ្ជ អាស្មា៉ដ្ជ អុ៊ីបនូ ហាន់បាល់* (បោះពុម្ពនៅ អេស៊ីបត៍ ឆ្នាំ 1313 សហ.) ជុំទី ១ ទំព័រ ៣៧៦ ។

[60] សូមមើលសៀវភៅ *យ៉ាណាប៊ីអុ៊ អាល់-ម៉ាវ៉ាដ្ជដ្ឋាស្ស៍ (يَنابيعُ المودّة)* ទំព័រ ៤៤៣ ។

[61] សូមមើលសៀវភៅ *យ៉ាណាប៊ីអុ៊ អាល់-ម៉ាវ៉ាដ្ជដ្ឋាស្ស៍ (يَنابيعُ المودّة)* ទំព័រ ៤៣២ ។

ចាំបាច់ត្រូវកត់សម្គាល់ថាអាយុវែងបែបនេះមិនត្រូវនឹងវិទ្យាសាស្ត្រនិងការសិក្សាទេ ហើយក៏មិនត្រូវនឹងការសមហេតុផលនៃការបើកឲ្យដឹងទេដែរ ។ សព្វថ្ងៃនេះ វិទ្យាសាស្ត្រចាប់ផ្តើមអាចធ្វើឲ្យមនុស្សមានអាយុជីវិតវែង ជឿជាក់ថាមនុស្សអាចនឹងរស់បានយូរអង្វែង បើគេចាកផុតពីការខូចបង់និងការឈឺចាប់ សេចក្តីសង្ឃឹមមានជីវិតយឺនយូរនឹងកាន់តែភ្លឺថ្លាឡើង ។ ប្រវត្តិសាស្ត្របានកត់ទុកនូវឈ្មោះអ្នកដែលមានអាយុវែងជាងគេ ។

ទាក់ទងនឹងព្រះសាស្តានុះហ៍ﷺ ព្រះមហាគម្ពីរគួរអានថែងថា៖

فَلَبِثَ فِيهِمۡ أَلۡفَ سَنَةٍ إِلَّا خَمۡسِينَ عَامٗا

*"គេបានរស់នៅជាមួយពួកគេមួយពាន់ឆ្នាំខ្វះហាសិបឆ្នាំ (២៩:១៤) ។"*[62]

ទាក់ទងនឹងណាប៊ីយូនុសﷺ គួរអានថែងថា៖

فَلَوۡلَآ أَنَّهُۥ كَانَ مِنَ ٱلۡمُسَبِّحِينَ ۝١٤٣ لَلَبِثَ فِي بَطۡنِهِۦٓ إِلَىٰ يَوۡمِ يُبۡعَثُونَ ۝١٤٤

*"បើសិនជាគេមិនមែនជាម្នាក់ ក្នុងចំណោមអ្នកថ្វាយសេចក្តីសើ្វចសរសើរ [ចំពោះអល់ឡោះហ្ទ៍]ទេនោះ គេប្រាកដជានៅក្នុងពោះវាររហូតដល់ថ្ងៃមួយដែលពួកគេនឹងរស់ពីស្លាប់ឡើងវិញជាមិនខាន (៣៧:១៤៣-១៤៤) ។"*[63]

ស្រដៀងគ្នាដែរ ដោយផ្អែកលើមតិគួរអាននិងមតិមុស្លីមទាំងអស់ ព្រះសាស្តាខ៊ិដ្ឍៀរﷺ និងព្រះសាស្តាអ៊ីសាﷺនៅតែមានព្រះជន្មនៅឡើយ ហើយនៅតែគង់ព្រះជន្មនៅរហូត ។

[62] ស៊ូរ៉ោះត៍ អាល់-អាន់កាប៊ូត 29:14 ។

[63] ស៊ូរ៉ោះត៍ អាស្ស-ស្វហ្វ៊ហ្វាត 37:143-144 ។



ការណ៍ដែលយកជាការមិនបាន ។

២. ហាឌីស្ស អាដ្ឌ-ឌុះហ្វ៍ដ្ឋាស៍មិនសមស្របនឹងព្រះគម្ពីរអល់ឡោះហ្វ៍عز وجل និងព្រះស៊ុនណាស់ព្រះសាស្តាﷺទេ ។

# បណ្តាញអ្នករាយការណ៍ហាឌីអាដ្ឌ-ស្វឌុះហ្វ៍ដ្ឋាស៍ ជាបណ្តាញរាយការណ៍ដែលយកជាការមិនបាន

យើងបានអធិប្បាយរួចមកហើយ អ្នករាយការណ៍ហាឌីស្ស អាដ្ឌ-ឌុះហ្វ៍ដ្ឋាស៍គឺ ស៊ុហ្វយ៉ាន អ៊ីបនូ សាអ៊ីដ្ឌ អាស្ស-ស៊ៅរី, អាប់ឌុល-ម៉ាលិក អ៊ីបនូ អ៊ុម៉ែរ៍, អាប់ឌុល-អាស៊ីស អ៊ីបនូ មូហាំម៉ាដ្ឌ អាដ្ឌ-ដ្វារ៉ាវឌី និង ឡៃស្ស៍ អ៊ីបនូ សាអាដ្ឌ ។

យើងសូមលើកយកប្រសាសន៍របស់អស់លោកអ្នកប្រាជ្ញ ម៉ាស្ស់ហ្វាប់ស៊ុននី ជំនាញខាងអ្នករាយការណ៍ហាឌីស្ស (អ៊ីលម៍ អារ-រីយ៉ាល់) ដើម្បីនឹងអាចដឹងច្បាស់អំពីប្រវត្តិរូបរបស់អ្នករាយការណ៍ហាឌីស្សទាំងនេះ ។

ក. លោក ស៊ុហ្វយ៉ាន អ៊ីបនូ សាអ៊ីដ្ឌ អាស្ស-ស៊ៅរី

លោក អាប៊ូ អាប់ឌុលឡោះហ្វ៍ មូហាំម៉ាដ្ឌ អ៊ីបនូ អាស៍ម៉ាដ្ឌ អ៊ុស្សម៉ាន អាស្ស-ស្វាហ្វាប៊ី អ្នកប្រាជ្ញស៊ុននីល្បីមួយរូបផ្អែកអ្នករាយការណ៍ហាឌីស្សមានប្រសាសន៍អំពីលោក ស៊ុហ្វយ៉ានថា៖

«كان يدلّس عن الضّعفاء»

*"គាត់ធ្លាប់តែរាយការណ៍ហាឌីស្សប្រឌិត តមកពីអ្នករាយការណ៍*

# វិភាគហាឌីស្ហ អាដ់-ឌុះហ៍ដាស់

លោកអ្នកនិពន្ធខ្លះ ដូចជាលោក អាល់-ប៊ូខ៏រី និងលោក មុស្លីម ជាដើម បានរាយការណ៍អាងលើអស់លោកអ្នករាយការណ៍ហាឌីស្ហ ស៊ុហ្វយ៉ាន អ៊ីបនូ សាអ៊ីដ អាស្ហ-ស្ហៅរី, អាប់ឌុល-ម៉ាលិក អ៊ីបនូ អ៊ូម៉ៃរ៍, អាប់ឌុល-អាស៊ីស អ៊ីបនូ មូហាំម៉ាដ់ អាដ់-ដារ៉ាវ៉ារឌី និង ឡៃស្ហ៍ អ៊ីបនូ សាអាដ់ ថា ហាឌីស្ហពីរខាងក្រោមនេះជាហាឌីស្ហរបស់ព្រះសាស្ដាﷺ គឺ៖

"وجدته في غمرات من النار فاخرجته إلى ضحضاح لعله تنفعه شفاعتي يوم القيامة فيجعل في ضحضاح من النار يبلغ كعبيه يغلي منه دماغه."

*"ខ្ញុំឃើញលោក (គឺអាប៊ូ ត៉ូលិប) នៅក្នុងភ្លើងដែលឆេះសន្ធោសន្ធៅ ហើយខ្ញុំបានលើកលោកទៅឯ "ឌុះហ៍ដាស់"[290] ។ នាថ្ងៃរស់ពីស្លាប់វិញ ការជួយធ្វើអន្តរាគមន៍របស់ខ្ញុំអាចនឹងជួយលោកបាន លោកនឹងបាននៅក្នុងរណ្ដៅភ្លើងមួយដែលមានជម្រៅដល់ប៉ែកលើនៃជើងរបស់លោក វានឹងធ្វើខួរក្បាលលោកពុះកញ្ជ្រោល ។"[291]*

ទោះជាមានហាឌីស្ហនិងភ័ស្តុតាងច្បាស់លាស់ច្រើន ដែលបញ្ជាក់ថា អាប៊ូ ត៉ូលិបមានសទ្ធាជ្រះថ្លាស្មោះអស់ពីចិត្ត ហើយដែលសរឲ្យឃើញថា ការនិយាយសំអុយនេះ (គឺហាឌីស្ហ អាដ់-ដុះហ៍ដាស់) គួរឲ្យស្អប់ខ្ពើមក្ដី យើងនឹងពិនិត្យហាឌីស្ហនេះដោយយកចិត្តទុកដាក់នឹងពីរចំណុចគឺ៖

១. បណ្ដាញអ្នករាយការណ៍ហាឌីស្ហ អាដ់-ឌុះហ៍ដាស់ ជាបណ្ដាញរាយ

[290] ឌុះហ៍ដាស់ មានន័យត្រង់ថា រណ្ដៅដែលមានជម្រៅទាបជាងកំពស់មនុស្ស ។

[291] សូមមើលសៀវភៅ *ស៊ហ៊ិះហ៍ អាល់-ប៊ូខ៏រី* (បោះពុម្ពនៅប្រទេសអេស៊ីបត៍) ជុំទី ៨ "គីតាប អាល់-អាដាប់" "បាប់ គូនីយ៉ាស់ អាល់-មុស្ហរិក" ទំព័រ ៥៦ ។ សូមមើលសៀវភៅ *ស៊ហ៊ិះហ៍ អាល់-ប៊ូខ៏រី* (ប្រែជាភាសាអង្គ្លេស) របស់លោក មុះហ៍ស៊ីនខាន (អ្នកបកប្រែ) ជុំទី ៨ កណ្ឌ ៧៨ ហាឌីស្ហ ២២៧ ។



# សំណួរ ៩ - បើស្ហ៊ីអាស់ត្រូវមែននោះ ហេតុអ្វីមានគ្នាតិច ហេតុអ្វីមុស្លីមក្នុងលោកមិនទទួលស្គាល់ពួកគេ ?

# ចម្លើយ

ទទួលស្គាល់ការពិតពីការខុស មិននៅលើចំនួនអ្នកតាមតិចឬច្រើនទេ ។ សព្វថ្ងៃនេះ ប្រៀបនឹងប្រជារាស្ត្រមិនមែនមុស្លីមក្នុងពិភពលោក មុស្លីមមានចំនួនមួយភាគប្រាំឬមួយភាគប្រាំមួយ (បានសេចក្ដីថាតិច ជាងប្រជារាស្ត្រមិនមែនមុស្លីម ៥ ឬ ៦ ដង) ។ បណ្ដាអ្នកសក្ការៈរូបបដិមា បណ្ដាអ្នកសក្ការៈគោ និងបណ្ដាអ្នកមិនជឿអធិធម្មជាតិមានចំនួនច្រើនជាងគេនៅទិសជិតបូព៌ាប្រទេស ។

មានប្រជាជនលើសពីមួយពាន់លាននាក់ ប្រទេសចិននៅក្នុងបក្សគ្មានសាសនាកុម្មុយនិស្ត ។ នៅក្នុងប្រទេសឥណ្ឌាដែលមានប្រជាជនប្រមាណមួយពាន់លាននាក់នោះ អ្នកសក្ការៈគោនិងអ្នកសក្ការៈរូបបដិមាមានចំនួនច្រើនជាងគេបង្អស់ ។

ភាគច្រើនមិនមែនជាបញ្ញាណនៃភាពសមហេតុផលទេ ។ ព្រះគម្ពីរគួរអានជំទាស់ភាគច្រើនជាញឹកញយ ហើយលើកតម្កើងភាគតិចមួយចំនួន ។ ឧទាហរណ៍៖

وَلَا تَجِدُ أَكْثَرَهُمْ شَـٰكِرِينَ

*"ព្រះអង្គនឹងឃើញថាពួកគេភាគច្រើនមិនដឹងព្រះគុណទេ (៧:១៧) ។"*[64]

[64] ស៊ូរ៉ោះត៍ អាល់-អាក់រ៉ហ្វ 7:17 ។

إِنْ أَوْلِيَآؤُهُۥٓ إِلَّا ٱلْمُتَّقُونَ وَلَٰكِنَّ أَكْثَرَهُمْ لَا يَعْلَمُونَ

*"អ្នកថែរក្សាបូជនីយវិហារនោះ គឺមានតែបណ្ដាអ្នកមានសទ្ធាស៊ីប់ចិត្តទេ តែពួកគេភាគច្រើនមិនដឹងទេ (៨:៣៤) ។"*[65]

وَقَلِيلٌ مِّنْ عِبَادِيَ ٱلشَّكُورُ

*"បាវបម្រើរបស់អញតិចណាស់ដែលដឹងគុណ (៣៤:១៣) ។"*[66]

ហេតុដូច្នេះ មនុស្សប្រាកដនិយមមិនត្រូវខ្លាចមានអ្នកតាមជំនឿរបស់ខ្លួនតិចនោះទេ ហើយក៏មិនត្រូវមានទោទនភាពដែលមានគ្នាជឿច្រើននោះទេដែរ ។ ត្រូវអុជចន្លុះបំភ្លឺសតិអារម្មណ៍ខ្លួនឯងជាជាង ហើយទាញយកផលប្រយោជន៍ពីពន្លឺត្រចះត្រចង់នោះ ។

ថ្ងៃមួយបុរសម្នាក់ បានសួរព្រះអគ្គមហាប្រមុខរបស់អ្នកមានសទ្ធាជ្រះថ្លា អាលីصلوات الله عليه والسلامថា៖ "ហេតុអ្វីគូប្រឆាំងព្រះអង្គក្នុងសមរភូមិយ៉ាម៉ាល់ ដែលមានគ្នាច្រើនជាងគេនោះជាខាងខុស ?" អ៊ីមុាំصلوات الله عليه والسلامមានវចនៈថា៖

"إن الحق والباطل لا يعرفان بأقدار الرجال ، إعرف الحق تعرف أهله إعرف الباطل تعرف أهله."

*"ត្រូវនិងខុសមិននៅលើចំនួនមនុស្សទេ ។ បើលោកស្គាល់ការពិត លោកអាចស្គាល់អ្នកតាមវា បើលោកស្គាល់ការខុស លោកអាចស្គាល់អ្នកតាមវា ។"*

[65] ស៊ូរ៉ោះត៍ អាល់-អាន់ហ្វាល 8:34 ។

[66] ស៊ូរ៉ោះត៍ សាបាអ៍ 34:13 ។



២. លោកគាំទ្រជ្រោមជ្រែងនិងការពារព្រះសាស្ដាﷺ ឥតមានគូប្រៀបលោកលះបង់ខ្លួននៅលើមាគ៌ាអ៊ីស្លាម ។

៣. ព្រះសាស្ដាﷺស្រឡាញ់លោកណាស់ ។

៤. លោកមានឯកសិទ្ធិធ្វើអន្តរាគមន៍ចំពោះអល់ឡោះហ្ﷻ ។

ពាក្យចោទប្រកាន់ដោយមូលបង្កាច់គួរឲ្យស្អប់ខ្ពើមនិងមិនអាចទទួលយកបានឡើយរបស់បុគ្គលមួយចំនួននោះមិនសមហេតុផលឡើយ ។

ការពិតពីរបានលេចច្បាស់ក្រឡែតឡើងគឺ៖

១. ព្រះសាស្ដាﷺអល់ឡោះហ្ﷻ, បណ្ដាសាវករបស់ព្រះសាស្ដាﷺ, អាមីរុល-មុមីនីនصلوات الله عليه والسلام និងអ៊ីមុាំអាស្ហលុល-បៃត៍عليهم السلامទទួលស្គាល់ថាអាប៊ូត៍លិប؏មានសទ្ធាជ្រះថ្លាស្មោះអស់ពីចិត្ត ។

២. ការចោទប្រកាន់ មូលបង្កាច់អាប៊ូ ត៍លិប؏មិនសមហេតុ សមផលទេ ។ ការនិយាយមូលបង្កាច់ទាំងនេះមានគោលបំណងនយោបាយចេញមកពីពួកស្ដេចខ៏លិហ្វអ៊ូម៉ៃយ៉ាស់ និងអាប់បាស៊ីយ៉ាស់មួយចំនួនដែលរមែងតែព្យាបាទអាស្ហលុល-បៃត៍عليهم السلام និងបណ្ដាកូនចៅវង្សត្រកូលរបស់អាប៊ូត៍លិប ។

គប្បីវិភាគមើលការប្រឌិតឡើងនូវលេសដែលជាក់ស្ដែងបំផុត ដើម្បីបំផ្លិចបំផ្លាញគុណសម្បត្តិរបស់កល្យាណសាវករូបនេះ របស់ព្រះសាស្ដាﷺ ដោយលើកយកហាឌីស្ហមួយដែលគេហៅថា "ហាឌីស្ហ អាឌ្-ឌុះហ្ហ៍ដ្ហាស់ (ضحضاح)" មកឲ្យអស់លោកអ្នកអានពិចារណាប្រៀបធៀបជាមួយអាយ៉ាស់គួរអាន ជាមួយព្រះស៊ុនណាស់ឥតប្រកែកបានរបស់ព្រះសាស្ដាﷺ និងជាមួយសតិប្រាជ្ញាថ្លាឈ្វេង យើងនឹងឃើញថាការចោទប្រកាន់ទាំងនេះមិនសមហេតុផលទេ ។

«لَو وُضع ايمانُ أبي طالبٍ في كفّة ميزان وايمان هذا الخلق في الكفّة الأخرى لرجح ايمانه»

*"បើគេដាក់ជំនឿរបស់អាប៊ូ តូលិបលើដៃជញ្ជីងម្ខាង ដាក់ជំនឿរបស់មនុស្សទាំងនេះលើដៃជញ្ជីងម្ខាងទៀត ជំនឿរបស់អាប៊ូ តូលិបនឹងធ្ងន់ជាងគេ ។"*[288]

២. អ៊ីម៉ាំអាស្ស៍-ស្វ៉ឌិក្កលោតមានវចនៈតមកពីព្រះសាស្តាអល់ឡោះហ្ម៍ថា៖

«إنّ اصحاب الكهف أسرّوا الإيمان وأظهروا الكفر فآتاهم الله أجرهم مرّتين، وإنّ أباطالبٍ أسرّ الإيْمانَ وَأظْهَرَ الشِّركَ فَآتاهُ اللهُ أجْره مرّتين»

*"កន្យាណមិត្តគុហា (អាស្ហ៍ហ្វាប់ អាល់-កាស់ហ្វ៍ أَصْحَابُ الكَهْف) បានលាក់ជំនឿរបស់ខ្លួន បានធ្វើពើជាអសទ្ធា ។ ដូច្នេះ អល់ឡោះហ្ម៍បានប្រទានរង្វាន់ឲ្យពួកគេជាពីរ ។ អាប៊ូ តូលិបក៏បានលាក់ជំនឿរបស់លោកដែរ លោកបានធ្វើពើជាអទ្ធា ។ ដូច្នេះ អល់ឡោះហ្ម៍ប្រទានរង្វាន់ជាពីរឲ្យលោក ។"*[289]

សេចក្តីរាយការណ៍ទាំងនេះបញ្ជាក់ថាអាប៊ូ តូលិបមានគុណសម្បត្តិគួរឲ្យកោតសរសើរជាទីបំផុតដូចតទៅគឺ៖

១. លោកជឿអល់ឡោះហ្ម៍និងព្រះសាស្តាស្មោះអស់ពីចិត្ត ។

[288] សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាប៊ី អាល់-ហាឌីដ្ (بن ابي الحَديد) *ស្ហារហ្ម៍ ណាស្ហ៍យ៉ាល់-បាឡាក្កោះត៍ (شرح نهج البلاغة)* (បោះពុម្ពលើកទី ២) ជុំទី ១៤ ទំព័រ ៦៨ ។ សូមមើលសៀវភៅ *អាល់-ហ៊ូជ្ជយ៉ាស់* ទំព័រ ១៨ ។

[289] សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាប៊ី អាល់-ហាឌីដ្ (بن ابي الحَديد) *ស្ហារហ្ម៍ ណាស្ហ៍យ៉ាល់-បាឡាក្កោះត៍ (شرح نهج البلاغة)* (បោះពុម្ពលើកទី ២) ជុំទី ១៤ ទំព័រ ៧០ ។ សូមមើលសៀវភៅ *អាល់-ហ៊ូជ្ជយ៉ាស់* ទំព័រ ១៧, ១១៥ ។



មុស្លីមគ្រប់រូបចាំបាច់ត្រូវវិភាគមើលសំណួរនេះ តាមវិធីវិទ្យាសាស្ត្រនិងតាមការសមហេតុផល ហើយយកអាយ៉ាស់ខាងក្រោមនេះជាចន្លុះបំភ្លឺផ្លូវគឺ៖

وَلَا تَقْفُ مَا لَيْسَ لَكَ بِهِۦ عِلْمٌ

*"ចូរអ្នកកុំតាមអ្វីដែលអ្នកមិនដឹងមិនស្គាល់នោះឡើយ (១៧:៣៦) ។"*[67]

សេចក្តីបន្ថែម ទោះបីស្ហ៊ីអ៊ុស់មិនមានចំនួនស្មើអាស្ហ៍លុល-ស៊ុនណាស់ក៏ដោយ បើធ្វើការរាប់ឲ្យត្រឹមត្រូវ យើងនឹងឃើញថាស្ហ៊ីអ៊ុស់មានចំនួនមួយភាគបួននៃប្រជានិករមុស្លីមក្នុងលោក រស់នៅក្នុងតំបន់លោកដែលមានប្រជានិករមុស្លីម ។ នៅក្នុងប្រវត្តិសាស្ត្រតរៀងមក មានអ្នកសរសេរ អ្នកប្រាជ្ញនិងនិពន្ធវណ្ណកម្មអក្សរសិល្ប និងឯកសារស្ហ៊ីអ៊ុស់ច្រើន ។ គួរកត់សម្គាល់ថាអ្នកបង្កើតវិទ្យាសាស្ត្រអ៊ិស្លាមភាគច្រើនជាស្ហ៊ីអ៊ុស់ ដូចជា៖

-អាប៊ូ អាល់-អាស់វ៉ាដ្ អាល់-ឌូអ៊ុលី (أبو الأسود الدؤلي) អ្នកបង្កើតវិទ្យាសាស្ត្រវាក្យសម្ព័ន្ធអារ៉ាប់ (គឺអ្នកបង្កើតលំដាប់ពាក្យក្នុងភាសាអារ៉ាប់) (អ៊ីលមូ អាន់-ណាហ្ហ៊ូ علم النحو) ។

-ខ៉ាលីល អ៊ីបនូ អាស្ហ៍ម៉ាដ្ (الخليل بن احمد) អ្នកបង្កើតកាព្យសាស្ត្រអារ៉ាប់ (អ៊ីលមូ អាល់-អ៊ុរូដ្ឋ علم العروض)

-មូអ៊ុស់ អ៊ីបនូ មុស្លីម អ៊ីបនូ អាប៊ី សារ៉ោះត៍ អាល់-គូហ្វី អ្នកបង្កើតវិទ្យាសាស្ត្រដើមកំណើតពាក្យអារ៉ាប់ (អ៊ីលមូ អាស្ហ៍-ស្វារហ្វ៍ عِلْمُ الصَّرْف)

-អាប៊ូ អ៊ុប់ឌុលឡោះហ្ម៍ មូហាំម៉ាដ្ អ៊ីបនូ អ៊ុមរ៉ាន កាទីប យ៉ូរ៉សានី (ម៉ារស្ហ៊ាបានី) អ្នកបង្កើតវិទ្យាសាស្ត្រវោហារកោសល្យអារ៉ាប់មុនគេម្នាក់ (អ៊ីលមូ អាល់-បាឡាក្កោះត៍ علم البلاغة)

ជាដើម ។[68]

[67] ស៊ូរ៉ោះត៍ អាល់-អ៊ិសរ៉អ៍ (ឬ បានី-អ៊ិសរ៉អ៊ីល) 17:36 ។

ចង់បានព័ត៌មានលំអិតទាក់ទងនឹងចំនួនស្នាដៃរបស់អ៊ូឡាម៉ាអ៊ំ និងអ្នកប្រាជ្ញស្ហ៊ីអុាស់ ដែលច្រើនរាប់មិនអស់នោះ សូមមើលសៀវភៅដ៏មានតម្លៃ *អាស្ហ់-ស្ហារីអុាស់ អ៊ីឡា តាស្វ៉ានីហ្វ អាស្ហ់-ស្ហ៊ីអុាស់ (الذريعة إلى تصانيف الشيعة)* ដើម្បីស្គាល់ស្ហ៊ីអុាស់ល្បីៗ សូមអានសៀវភៅ *អាក់យ៉ាន អាស្ហ់-ស្ហ៊ីអុាស់ (أعيان الشيعة)* និងសៀវភៅ *តារិក អាស្ហ់-ស្ហ៊ីអុាស់ (تاريخ الشيعة)* ដើម្បីស្គាល់ប្រវត្តិសាស្ត្រស្ហ៊ីអុាស់ ។

## សំណួរ ១០ - អ្វីទៅរ៉ៃជ៉អុាស់ (និវត្តន៍) ហេតុអ្វីជឿនិវត្តន៍ ?

## ចម្លើយ

ក្នុងភាសាអារ៉ាប់ *រ៉ៃជ៉អុាស់* មានន័យត្រង់ថា "ត្រឡប់មកវិញ" តែពាក្យនេះត្រូវប្រើក្នុងន័យថា "ការវិលត្រឡប់វិញរបស់បុគ្គលមួយក្រុមក្រោយពីបានស្លាប់ហើយ មុនថ្ងៃរស់ពីស្លាប់វិញ" ។ ការពិតនេះមិនផ្ទុយពីសុភវិនិច្ឆ័យ និងការសមហេតុផលនៃប្រកាសនា (គឺការបើកឲ្យដឹង) ទេ ។

តាមទស្សនៈអ៊ីស្លាមនិងជំនឿព្រះឯទៀត សារធាតុរបស់មនុស្សស្ថិតនៅលើវិញ្ញាណបរិបូរ ដែលគេហៅដែរថា "អាត្ម័ន" (ណាហ្វ៉ស៍ نَفْس) ក្រោយពីបាត់បង់រូបកាយវានៅតែរស់រហូត ។

ម្យ៉ាងទៀត តាមទស្សនៈគួរអាន អល់ឡោះហ៍عزوجلទ្រង់មានមហិទ្ធិឫទ្ធិ ពុំមានអ្វីអាចរារាំងឬទប់ទល់ឥទ្ធិពលព្រះអង្គعزوجلបានឡើយ ។

[68] ទាក់ទងនឹងរឿងនេះ សូមមើលសៀវភៅ *តាក់ស៊ីស អាស្ហ់-ស្ហ៊ីអុាស់ (التأسيس الشيعة)* សរសេរដោយ សៃយីដ ហាសាន់ អាស្ហ់-ស្វាដ៉ូរ៍ (سيد حسن الصدر) ។



«والله الذي لا إله إلا هو ما مات ابو طالبٍ رضي الله عنه حتّى أسلم»

*"សូមស្បថចំពោះអល់ឡោះហ៍عزوجل ពុំមានព្រះក្រៅពីព្រះអង្គعزوجلឡើយ ។ អាប៊ូ ត៉ក់លិបرضي الله عنهពុំបានចាកលោកនេះដោយពុំបានទទួលយកសាសនាអ៊ីស្លាមទេ ។"[286]*

គ. គេបានរាយការណ៍ និងបានអះអាងបញ្ជាក់តាមរយៈបណ្ដាញព័ត៌មានច្រើនថាលោក អុាប់បាស់ អ៊ីបនូ អុាប់ឌុល-មុត្តត៉ក់លិប និងលោក អាប៊ូ បាការ អ៊ីបនូ អាប៊ូ ក៊ូហ៊ាហ្វាស់ មានប្រសាសន៍ថា៖

«إن أبا طالبٍ ما ماتَ حتّى قال: لا إله إلاّ الله مُحمّد رسول الله»

*"អាប៊ូ ត៉ក់លិបពុំបានចាកលោកនេះដោយពុំបានថ្លែងថា "ឡា អ៊ីឡាហា អ៊ីលឡុលឡោះហ៍ មូហាំម៉ាដាន់ រ៉ស៊ូលុលឡោះហ៍" ឡើយ ។"[287]*

## ៦. អាប៊ូ ត៉ក់លិបនៅក្នុងខ្សែភ្នែកអាស្ហ់លុល-បៃត៍عليهم السلام

អ៊ីម៉ាំអាស្ហ់លុល-បៃត៍عليهم السلامទាំងអស់បានបញ្ជាក់ច្រើនគ្រាថា អាប៊ូ ត៉ក់លិបមានសទ្ធាជ្រះថ្លា ព្រះអង្គទាំងអស់عليهم السلامបានគាំទ្រថាលោកបានលះបង់ខ្លួនដើម្បីការពារព្រះសាស្ដាصلى الله عليه وآله وسلم ។ យើងសូមលើកមកបង្ហាញជូននូវភ័ស្តុតាងពីរគឺ៖

ក. អ៊ីម៉ាំអាល់-បាគៀរមានវចនៈថា៖

[286] សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាប៊ី អាល់-ហាឌីដ្ឋ (بن ابي الحَدِيد) *ស្ហារហ៍ ណាស្ហ់យ៉ាល់-បាឡាក៉ោះត៍ (شرح نهج البلاغة)* (បោះពុម្ពលើកទី ២) ដុំទី ១៤ ទំព័រ ៧១ ។

[287] សូមមើលសៀវភៅ *អាល់-ក៉ាដៀរ* (បោះពុម្ពនៅបៃរូត ឆ្នាំ 1378 ស.ហ.) ដុំទី ៧ ទំព័រ ៣៩៨ ដកស្រង់ពី តាហ្វសៀរ អាល់-វ៉ាគ៊ីអ៊ំ ។

វចនៈដោយមានទឹកមុខក្រោធថា៖

«مَه، فضّ الله فاك، والّذي بعث محمداً بالحق نبيّاً لو شفع أبي في كلّ مذنب على وجه الأرض لشفّعه الله»

*"ស្ងាត់មាត់ទៅ ! សូមអល់ឡោះហ៍(عز وجل)វាយបំបែកមាត់អ្នកឯង ! ខ្ញុំសូមស្បថចំពោះអល់ឡោះហ៍(عز وجل)ដែលបានតែងតាំងមូហាំម៉ាដ់(صلى الله عليه وآله وسلم)ជាព្រះសាស្ដា បើ អាប៊ូ ត៏លិប បិតាខ្ញុំ ធ្វើអន្តរាគមន៍ឲ្យបុគ្គលមានបាបគ្រប់គ្នានៅលើផែនដី អល់ឡោះហ៍(عز وجل)នឹងព្រមទទួលការធ្វើអន្តរាគមន៍របស់លោក ។"*[284]

អាលី អាមីរុល-មុមីនីន(صلوات الله عليه والسلام)មានវចនៈដែរថា៖

«كانّ والله ابو طالب عبد مناف بن عبد المطّلب مؤمناً مسلماً يكتم إيمانه مخافةً على بني هاشمِ أن تنابذها قريش»

*"សូមស្បថចំពោះអល់ឡោះហ៍(عز وجل) ! អាប៊ូ ត៏លិប អាប់ឌុល-ម៉ាណាហ្វ អ៊ីបនូ អាប់ឌុល-មុត្ត៏លិបជាមុស្លីមនិងជាអ្នកមានសទ្ធាស៊ប់ចិត្តពិតប្រាកដ ។ លោកបានលាក់ជំនឿពីភ្នែកពួកគូរ៉យស្ហ៍[អសទ្ធា] ដើម្បីនឹងកុំឲ្យពួកគេបៀតបៀនបានី ហាស៊ីម ។"*[285]

សម្ដីទាំងនេះរបស់អ៊ីម៉ាំអាលី(صلوات الله عليه والسلام)មិនត្រឹមតែបញ្ជាក់ថា អាប៊ូ ត៏លិប មានសទ្ធាស៊ប់ចិត្តប៉ុណ្ណោះទេ តែថែមទាំងចាត់ទុកអាប៊ូ ត៏លិបក្នុងចំណោមអៅលីយ៉ាម្នាក់ (គឺជំនិតអល់ឡោះហ៍(عز وجل)) ដែលអាចធ្វើអន្តរាគមន៍ឲ្យអ្នកឯទៀតបានអាស្រ័យការអនុញ្ញាតរបស់អល់ឡោះហ៍(عز وجل) ។

ខ. លោក អាប៊ូ ស្ងារ អាល់-គ៊ីហ្វារី មានប្រសាសន៍អំពី អាប៊ូ ត៏លិប ថា៖

[284] សូមមើលសៀវភៅ *អាល់-ហ៊ុជ្ជយ៉ាស្ហ៍* ទំព័រ ២៤ ។

[285] សូមមើលសៀវភៅ *អាល់-ហ៊ុជ្ជយ៉ាស្ហ៍* ទំព័រ ២៤ ។



សេចក្ដីណែនាំខ្លីនេះបង្ហាញឲ្យឃើញច្បាស់ថា *រ៉ាជ់អាស្ហ៍* ក្នុងទស្សនៈសុភវិនិច្ឆ័យ មិនមែនមិនអាចកើតឡើងបានទេ ពីព្រោះយើងនឹងឃើញតាមការរិះគិតថា ការរស់ឡើងវិញរបស់បុគ្គលមួយក្រុមនេះងាយស្រួលបំផុត ជាងការបង្កើតដំបូងបង្អស់ទៅទៀតដែលអល់ឡោះហ៍(عز وجل)បានបង្កើតឡើង ។

ហេតុដូច្នេះ ព្រះជាម្ចាស់ដែលបង្កើតពួកគេមកក្នុងគ្រាដំបូងនោះអាចធ្វើឲ្យពួកគេរស់ឡើងវិញបានដោយគ្មានបញ្ហាឡើយ ។ យោលតាមការសមហេតុផលនៃប្រកាសនា មានឧទាហរណ៍ *រ៉ាជ់អាស្ហ៍* ច្រើននៅក្នុងប្រជាជាតិមុនៗ ។

ទាក់ទងនឹងរឿងនេះ ព្រះគម្ពីរគួរអានចែងថា៖

وَإِذۡ قُلۡتُمۡ يَٰمُوسَىٰ لَن نُّؤۡمِنَ لَكَ حَتَّىٰ نَرَى ٱللَّهَ جَهۡرَةٗ فَأَخَذَتۡكُمُ ٱلصَّٰعِقَةُ وَأَنتُمۡ تَنظُرُونَ ۝٥٥ ثُمَّ بَعَثۡنَٰكُم مِّنۢ بَعۡدِ مَوۡتِكُمۡ لَعَلَّكُمۡ تَشۡكُرُونَ ۝٥٦

*"[ចូរពួកអ្នករឭកដល់]គ្រាដែលពួកអ្នកបានថា៖ "មូសាអើយ ដរាបណាយើងមិនបានឃើញអល់ឡោះហ៍យ៉ាងជាក់ស្ដែងទេ (ឃើញរូបអល់ឡោះហ៍ពិត) ដរាបនោះយើងនឹងមិនជឿលោកទេ !" ដូច្នេះរន្ទះបានប្រល័យជីវិតពួកអ្នកក្នុងពេលដែលពួកអ្នកកំពុងសម្លឹងមើល ។ បន្ទាប់មកយើងបានឲ្យពួកអ្នករស់ឡើងវិញ ក្រោយពីការស្លាប់របស់ពួកអ្នក ដើម្បីនឹងឲ្យពួកអ្នកដឹងគុណ (២:៥៥-៥៦) ។"*[69]

មួយកន្លែងទៀត គួរអានចែងអំពីអ៊ីសា អាល់-ម៉ាស៊ិះហ៍(عليه السلام)ថា៖

[69] ស៊ូរ៉ោះត៍ អាល់-បាក៏រ៉ោះត៍ 2:55-56 ។

وَأُحۡيِ ٱلۡمَوۡتَىٰ بِإِذۡنِ ٱللَّهِۖ

*"ខ្ញុំនឹងធ្វើឲ្យមនុស្សស្លាប់រស់ឡើងវិញ អាស្រ័យការអនុញ្ញាតរបស់អល់ឡោះហ្ (៣:៤៩) ។"*[70]

ព្រះគម្ពីរគួរអានមិនត្រឹមតែយល់ស្រប ចំពោះការអាចកើតឡើងបានរបស់ *រ៉ូចអ៊្ហាស្វ៉* ប៉ុណ្ណោះទេ ថែមទាំងអះអាងបញ្ជាក់ថាវានឹងកើតឡើងមែន ហើយមនុស្សមួយក្រុមនឹងរស់ឡើងវិញពិតមែន បន្ទាប់ពីបានចាក ចោលលោកនេះហើយ ។ នៅក្នុងអាយ៉ាស្ទ័ពីរខាងលើនេះ គួរអានផ្តោតទៅលើការវិលត្រឡប់មកវិញរបស់បុគ្គលមួយក្រុម ក្រោយពីបានស្លាប់ហើយ មុនថ្ងៃរស់ពីស្លាប់មកដល់ ។

﴿وَإِذَا وَقَعَ الْقَوْلُ عَلَيْهِمْ أَخْرَجْنَا لَهُمْ دَابَّةً مِنَ الْأَرْضِ تُكَلِّمُهُمْ أَنَّ النَّاسَ كَانُوا بِآيَاتِنَا لَا يُوقِنُونَ وَيَوْمَ نَحْشُرُ مِنْ كُلِّ أُمَّةٍ فَوْجًا مِمَّنْ يُكَذِّبُ بِآيَاتِنَا فَهُمْ يُوزَعُونَ﴾

*"កាលណាព្រះបន្ទូល[ដាក់ទណ្ឌកម្ម]ធ្លាក់មកលើពួកគេ [មុនរស់ពីស្លាប់ឡើងវិញ] យើងនឹងឲ្យមានឡើងនូវចរកម្នាក់ (ច:រ:ក: គឺមនុស្សអ្នកដើរ) ពីផែនដីសម្រាប់ពួកគេ មកថ្លែង[ដោយពាក្យពេជន៍ពីរោះស្តាប់ចំពោះបណ្តាអ្នកមានសទ្ធា និងដោយពាក្យពេជន៍អាក្រក់ចំពោះពួកបដិសេធសទ្ធា ព្រមទាំងថ្លែង]ថាមនុស្ស[ទុច្ចរិត...]ទាំងឡាយមិនជឿជាក់បណ្តាសញ្ញាយើងទេ ។ ថ្ងៃដែលយើងនឹងប្រមូល ក្នុងសហាគមន៍នីមួយៗ នូវមនុស្សមួយភាគី [ដែលមិនស្មោះត្រង់ ទុច្ចរិត មិនដុសខាត់ចិត្តខ្លួន ថែមទាំងធ្វើឲ្យប្រាជ្ញាខ្លួនអាប់] ដែលបានបដិសេធសញ្ញាទាំងឡាយរបស់យើង គេនឹងរៀបពួកគេជាក្រុម (២៧:៨២-៨៣) ។"*[71]

[70] ស្ទូរ៉េាះត្ទ័ អាលី អ៊ីមរ៉ន 3:49 ។

[71] ស្ទូរ៉េាះត្ទ័ អាន់-ណាំល៍ 27:82-83 ។



*"មូហាំម៉ាដ្ទ័ ព្រះសាស្តាﷺរបស់អល់ឡោះហ្ និងជនទាំងឡាយដែលតាមគេរមែងមានចិត្តតឹងរ៉ឹងចំពោះពួកបដិសេធសទ្ធា និងអាណិតអាសូរគ្នាឯង ៤៨:២៩ ។"*[282]

គួរអានចែងទៀតថា៖

لَا تَجِدُ قَوْمًا يُؤْمِنُونَ بِاللَّهِ وَالْيَوْمِ الْآخِرِ يُوَادُّونَ مَنْ حَادَّ اللَّهَ وَرَسُولَهُ وَلَوْ كَانُوا آبَاءَهُمْ أَوْ أَبْنَاءَهُمْ أَوْ إِخْوَانَهُمْ أَوْ عَشِيرَتَهُمْ ۚ أُولَٰئِكَ كَتَبَ فِي قُلُوبِهِمُ الْإِيمَانَ

*"អ្នកនឹងរកមិនបានទេ នូវក្រុមមនុស្សដែលមានសទ្ធាចំពោះអល់ឡោះហ្ និងចំពោះថ្ងៃអវសាន ដែលយកជនទាំងឡាយដែលប្រឆាំងអល់ឡោះហ្ និងព្រះសាស្តាព្រះអង្គមកជាមិត្តនោះ ទោះបីបណ្តាជន[ប្រឆាំង]នោះជាឪពុកពួកគេ ជាកូនពួកគេ ជាបងប្អូនពួកគេ ឬជាអ្នកជំនិត[ឬជាជនរួមសហាគមន៍]ពួកគេក៏ដោយ ។ អល់ឡោះហ្បានចារជំនឿនៅក្នុងបេះដូងជនទាំងនោះ... ៥៨:២២ ។"*[283]

អាយ៉ាស្ទ័ទាំងពីរនេះ និងសេចក្តីស្រឡាញ់និងសេចក្តីគោរពរបស់ព្រះសាស្តាﷺចំពោះ អាប៊ូ ត៉ូលិប កម្ចាត់សេចក្តីសង្ស័យអំពីជំនឿជ្រះថ្លារបស់លោកលើអល់ឡោះហ្عزّ وجلّនិងព្រះសាស្តាﷺ ។

៥. សាវកមួយក្រុមរបស់ព្រះសាស្តាﷺបានអះអាងជាច្រើនដងថា អាប៊ូត៉ូលិបមានជំនឿពិត ។

ក. បុរសម្នាក់ ដោយមិនដឹងថា អ៊ុាលី អាមីរុល-មុមីនីនصلوات الله عليه والسلام មានវត្តមាននៅទីនោះដែរ បាននិយាយបង្អាច់ អាប៊ូ ត៉ូលិប ។ អ៊ីមុាំអ៊ុាលីصلوات الله عليه والسلامមាន

[282] ស្ទូរ៉េាះត្ទ័ អាល់-ហ្វាត់ហ៊្ 48:29 ។

[283] ស្ទូរ៉េាះត្ទ័ អាល់-មូយ៉ាដ្ឋាឡាស្ទ័ 58:22 ។

ក. អ្នកប្រវត្តិសាស្ត្រមួយក្រុមបានរាយការណ៍ថា ព្រះសាស្ដាﷺបានប្រាប់ អ៊ាគ៊ីល អ៊ីបនូ អាប៊ី ត៏លិប ថា៖

«إنّي أحبّك حبّين حبّاً لقرابتك منّي وحبّاً لما كنت أعلم من حبّ عمّي إيّاك»

*"ខ្ញុំស្រឡាញ់លោក ដោយមានមូលហេតុពីរគឺ៖ មួយគឺលោកជាសាច់ញាតិខ្ញុំ ពីរគឺលោកឪពុកមាខ្ញុំ (គឺអាប៊ូ ត៏លិប) ស្រឡាញ់លោក ។"*[280]

ខ. លោក ហ៊ាឡាប៊ី បានរាយការណ៍នៅក្នុងស៊ីរ៉ោះត៏លោកថាព្រះសាស្ដាﷺអល់ឡោះហ្ ﷻមានព្រះវចនៈសរសើរ អាប៊ូ ត៏លិប ឪពុកមាព្រះអង្គﷺថា៖

«ما نالت قريش منّي شيئاً أكرهه (أي اشدّ الكراهة) حتّى مات أبو طالب»

*"ដរាបណា អាប៊ូ ត៏លិប មានជីវិត ដរាបនោះពួកបដិសេធសទ្ធាគូរ៉យ៉ស្ហ៏ មិនអាចបៀតបៀនខ្ញុំបានឡើយ ។"*[281]

ច្បាស់ណាស់ សេចក្ដីស្រឡាញ់និងសេចក្ដីគោរពដែលព្រះសាស្ដាﷺ មានចំពោះអាប៊ូ ត៏លិបជាភ័ស្ដុតាងជាក់ស្ដែងថាលោកមានសទ្ធាជ្រះថ្លាពិតមែន ពីព្រោះអាយ៉ាស់គួរអានចែងថា ព្រះសាស្ដាﷺអល់ឡោះហ្ ﷻ ស្រឡាញ់តែបណ្ដាអ្នកមានសទ្ធាទេ ហើយព្រះអង្គﷺប្រឆាំងពួកបដិសេធសទ្ធានិងពួកពហុទេពនិយមអន្សតិរ្ថិយ ។ ព្រះមហាគម្ពីរគួរអានចែងអំពីរឿងនេះថា៖

مُحَمَّدٌ رَسُولُ اللَّهِ ۚ وَالَّذِينَ مَعَهُ أَشِدَّاءُ عَلَى الْكُفَّارِ رُحَمَاءُ بَيْنَهُمْ ۖ

[280] សូមមើលសៀវភៅ *តារីក អាល់-ខ៏មីស (تاريخ الخميس)* ជុំទី ១ ទំព័រ ១៦៣ (បោះពុម្ពនៅបៃរូត) ។ សូមមើលសៀវភៅ *អាល់-អ៊ីសទីអ៊ាប់ (الإستيعا)* ជុំទី ២ ទំព័រ ៥០៩ ។

[281] សូមមើលសៀវភៅ *ស៊ីរ៉ោះត៏ អាល់-ហ៊ាឡាប៊ីយ៉ាស់* (បោះពុម្ពនៅអេស៊ីបត៍) ជុំទី ១ ទំព័រ ៣៩១ ។



ក្នុងគោលបំណងផ្ដល់នូវមូលបទមាំដើម្បីបំភ្លឺសំណួរ *រ៉ាជ់អ៊ាស់* ដោយមានអាយ៉ាស់ទាំងពីរនេះជាមូលដ្ឋាន យើងសូមលើកឡើងនូវចំណុចដូចតទៅ៖

១. អស់លោកអ្នកស្រាយគួរអាន (មូហ្វាស់ស៊ីរូន مفسرون) យល់ឃើញថាអាយ៉ាស់ទាំងពីរនេះស្ដីអំពីថ្ងៃរស់ពីស្លាប់វិញ អាយ៉ាស់មួយចែងអំពីសញ្ញាសម្គាល់ពេលមុនរស់ពីស្លាប់មួយ ដូចលោក យ៉ាឡាល់ អាល់-ឌីន អាស់-ស៊ូទី បានអធិប្បាយនៅក្នុងតម្រាសម្រាយគួរអាន (តាហ្វ៊ីសៀរ) របស់លោក *អាដ់-ឌូរ អាល់-ម៉ាន់ស៊ូរ (الدر المنثور)* តមកពី អ៊ីបនូ អាប៊ី ស្ហៃបាស់ តមកពី ហ៊្វូស្ហៃហ្វាស់ ថា *"ឌូរូច អាដ់-ដាប់បាស់"* (ក្នុងអាយ៉ាស់ទី ១) ជាព្រឹត្តិការណ៍មួយ ក្នុងចំណោមព្រឹត្តិការណ៍ច្រើន ដែលកើតឡើងមុនថ្ងៃរស់ពីស្លាប់វិញ ។[72]

២. ប្រាកដណាស់ថាក្នុងថ្ងៃរស់ពីស្លាប់វិញ មនុស្សទាំងអស់នឹងត្រូវប្រមូល ហើយមិនត្រឹមតែក្រុមមួយជាពិសេសនៃរាល់សហគមន៍ទេ ។ ទាក់ទងនឹងការប្រមូលមនុស្សទាំងអស់ គួរអានចែងថា៖

ذَٰلِكَ يَوْمٌ مَّجْمُوعٌ لَّهُ ٱلنَّاسُ

*"ថ្ងៃនោះមនុស្សទាំងពួងនឹងត្រូវប្រមូលជុំគ្នា (១១:១០៣) ។"*[73]

មួយកន្លែងទៀត គួរអានចែងថា៖

وَيَوْمَ نُسَيِّرُ ٱلْجِبَالَ وَتَرَى ٱلْأَرْضَ بَارِزَةً وَحَشَرْنَٰهُمْ فَلَمْ نُغَادِرْ مِنْهُمْ أَحَدًا

*"ថ្ងៃដែលយើងនឹងធ្វើឲ្យភ្នំទាំងឡាយអាចដើរបាន អ្នកនឹងឃើញផែនដីជា*

[72] សូមមើលសៀវភៅ*អាដ់-ឌូរ អាល់-ម៉ាន់ស៊ូរ* (الدر المنثور) ជុំទី ៥ ទំព័រ ១៧៧ ក្នុងវគ្គអធិប្បាយស៊ូរ៉ោះត៏ អាន់-ណាំល៏ 27:82-83 ។

[73] ស៊ូរ៉ោះត៏ ហ៊្វូដ 11:103 ។ នៅក្នុង *អាដ់-ឌូរ អាល់-ម៉ាន់ស៊ូរ* ជុំទី ៣ ទំព័រ ៣៤៩ គេបកស្រាយថ្ងៃថាថ្ងៃរស់ពីស្លាប់វិញ ។

*ផ្លែរាបស្មើ ហើយយើងនឹងប្រមូលពួកគេ (គឺមនុស្សទាំងឡាយ) ដោយឥត ចោលអ្នកណាម្នាក់ឡើយ (១៨:៤៧) ។"*[74]

ហេតុដូច្នេះ ក្នុងថ្ងៃរស់ពីស្លាប់វិញ មនុស្សទាំងអស់នឹងត្រូវប្រមូលជុំគ្នា មិន ត្រឹមតែក្រុមមួយជាពិសេសទេ ។

៣. អាយ៉ាស់ទី ២ ដែលយើងបាននិយាយខាងនេះ ផ្តោតយ៉ាងច្បាស់ទៅ លើការប្រមូលក្រុមមួយជាពិសេសនៃរាល់សហគមន៍ មិនមែនមនុស្ស ទាំងអស់ទេ ដូចមានចែងដូចតទៅ៖

وَيَوْمَ نَحْشُرُ مِن كُلِّ أُمَّةٍ فَوْجًا مِّمَّن يُكَذِّبُ بِـَٔايَـٰتِنَا فَهُمْ يُوزَعُونَ

*"ថ្ងៃដែលយើងនឹងប្រមូល ក្នុងសហគមន៍នីមួយៗ នូវមនុស្សមួយភាគី [ដែលមិនស្មោះត្រង់ ទុច្ចរិត មិនដុស ខាត់ចិត្តខ្លួន ថែមទាំងធ្វើឲ្យប្រាជ្ញាខ្លួនអាប់] ដែលបានបដិសេធសញ្ញាទាំងឡាយរបស់យើង គេនឹងរៀបពួកគេជាក្រុម (២៧:៨៣) ។"*[75]

ព្រះបន្ទូលមួយនេះបញ្ជាក់យ៉ាងជាក់លាក់ថា មិនមែនមនុស្សទាំងអស់ទេ ដែលនឹងត្រូវប្រមូល ។

## សរុបសេចក្តី

សេចក្តីរាយការណ៍នាំមុខខ្លីៗទាំងបីនេះបញ្ជាក់យ៉ាងច្បាស់ថា ការប្រមូល ក្រុមមនុស្សមួយជាពិសេស ដែលបដិសេធសញ្ញាទាំងឡាយរបស់

[74] ស៊ូរ៉ោះត៏ អាល់-កាស្ហ្វ 18:47 ។

[75] ស៊ូរ៉ោះត៏ អាន់-ណាំល៍ 27:83 ។



ហ្ាឡាប៊ី អាស្ហ-ស្ហាហ្វិអ៊ី និងលោក មូហ្ាំម៉ាដ្ទ អាដ្ទ-ឌ្ទីយ៉ារ អាល់-បាក់រី ជាដើមបានរាយការណ៍នៅក្នុងសៀវភៅ *តារិខ្ អាល់-ខ៏មីស* អំពីអាប៊ូ ត៏លិប កាលលោកបានប្រកាសហៅប្រជារាស្ត្រលោកឲ្យគាំទ្រព្រះសាស្ដា ﷺ អល់ឡោះហ្ ﷻ ថា៖

«يا معشر قريش كونوا له ولاةً، ولحزبه حماةً، والله لايسلك أحد منكم سبيله إلاّ رشد ولا يأخذ أحدٌ يهديه إلاّ سعد، ولو كان لنفسي مدّة ولأجلي تأخّر لكففتُ عنه الهزائز ولدفعتُ عنه الدَّواهي. ثم هلك»

*"បងប្អូនខ្ញុំអឺយ សូមបងប្អូនជួយគាំទ្រនិងជាមិត្តរបស់មូហ្ាំម៉ាដ្ទ ﷺ សូមបងប្អូនការពារបក្សរបស់គេ ﷺ ។ ខ្ញុំសូមស្បថចំពោះអល់ឡោះហ្ ﷻ ថា អ្នកណាតាមគេ ﷺ អ្នកនោះនឹងចម្រុងចម្រើន ។ បើខ្ញុំមានជីវិតយឺនយូរ ខ្ញុំនឹងការពារមិនឲ្យគ្រោះថ្នាក់បៀតបៀនគេ ﷺ បានជាដាច់ខាត ។" បន្ទាប់ពីនោះ លោកក៏បានអស់ជីវិត ។"*[279]

## ៩. សេចក្តីស្រឡាញ់ និងសេចក្តីរាប់អានរបស់ព្រះសាស្ដា ﷺ ចំពោះ អាប៊ូ ត៏លិប បញ្ជាក់ថាលោកមានសទ្ធាជ្រះថ្លាមែន ។

ច្រើនលើក ច្រើនគ្រា ព្រះសាស្ដា ﷺ អល់ឡោះហ្ ﷻ បានកោតសរសើរឪពុកមាព្រះអង្គ ﷺ សម្តែងសេចក្តីស្រឡាញ់និងសេចក្តីរាប់អានចំពោះលោក ។ យើងសូមលើកមកបង្ហាញនូវភ័ស្តុតាងពីរ ។

[279] សូមមើលសៀវភៅ *តារីខ្ អាល់-ខ៏មីស (تاريخ الخميس)* ជុំទី ១ ទំព័រ ៣០០-៣០១ (បោះពុម្ពនៅបៃរូត) ។ សូមមើលសៀវភៅ *ស៊ីរ៉ោះត៏ អាល់-ហ្ាឡាប៊ីយ៉ាស្ហ* (បោះពុម្ពនៅអេស៊ីបត៍) ជុំទី ១ ទំព័រ ៣៩១ ។

لَما مثّلَ الدينُ شخصاً فقاما

فذاك بمكةَ آوى وحامى

وهذا بيثربَ جسّ الحماما

وما ضرّ مجدَ أبي طالبٍ

جهولٌ لغيٍّ أو بصيرٌ تعامى

*"បើពុំមាន អាប៊ី ត៏លិប និងបុត្រលោកទេ សាសនា[អ៊ីស្លាម]ប្រាកដជាមិនអាចកើតជារូបរាងឡើងបានទេ ។*
*លោកបានផ្តល់ជម្រកនិងទីពឹងពាក់ដល់ព្រះអង្គ ﷺ ។ បុត្រលោកបានឈានទៅរករណ្តៅមរណៈ [ដើម្បីការពារព្រះសាស្តា ﷺ] នៅឯយ៉ាស្រ៊ីប ។*[277]
*ពុំមានអ្នកណាអាចបំផ្លាញកេរ្តិ៍ឈ្មោះរបស់អាប៊ូ ត៏លិបបានឡើយ ទាំងបុគ្គលអវិជ្ជា ទាំងបុគ្គលចេះដឹងដែលធ្វើពើជាមិនដឹង ។"*[278]

# ៣. មរតកសាសន៍របស់ អាប៊ូ ត៏លិប ជាភ័ស្តុតាងបញ្ជាក់យ៉ាងជាក់ច្បាស់ថាលោកមានជំនឿជ្រះថ្លាមែន ។

លោកអ្នកប្រវត្តិសាស្ត្រមុស្លីមល្បីៗក្នុងពិភពលោក ដូចជាលោក អាល់-

[277] យ៉ាស្រ៊ីប ជាឈ្មោះដើមរបស់ក្រុងមួយ ដែលត្រូវគេហៅក្រោយមកថា ម៉ាឌីណាស្ហ៍ អាន់-ណាប៊ី (ទីក្រុងរបស់ព្រះសាស្តា ﷺ) ក្រោយពីព្រះសាស្តាមូហាំម៉ាដ ﷺ បានភៀសខ្លួនមកកាន់ទីនេះ ។ សព្វថ្ងៃនេះគេហៅខ្លីៗថា ម៉ាឌីណាស្ហ៍ ។

[278] សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាប៊ី អាល់-ហាឌីដ្ឋ (ابن ابي الحَدِيد) *ស្ហារហ៍ ណាស្ហ៍ យ៉ាល់-បាឡាក្ហោះត៍ (شرح نهج البلاغة)* (បោះពុម្ពលើកទី ២) ជុំទី ១៤ ទំព័រ ៨៤ ។



អល់ឡោះហ្ (عزّ وجلّ) នោះ យោលតាមវិចារណាការអោយ៉ាស្ហ៍ទីពីរ ជាព្រឹត្តិការណ៍មួយដែលនឹងកើតឡើងមុនថ្ងៃរស់ពីស្លាប់វិញ ។ នេះព្រោះតែក្នុងថ្ងៃរស់ពីស្លាប់វិញ មនុស្សទាំងអស់នឹងត្រូវប្រមូលជុំគ្នា មិនត្រឹមតែក្រុមនីមួយជាពិសេសទេ ។

សេចក្តីបំភ្លឺនេះបង្ហាញភ័ស្តុតាងបញ្ជាក់មតិវិលត្រឡប់មកវិញរបស់មនុស្សមួយក្រុមក្រោយពីស្លាប់ មុនថ្ងៃរស់ពីស្លាប់វិញ ហើយគេហៅបាតុភូតនេះថា *រ៉ាជ្ញ៉ាស្ហ៍* ។

អាស្ហ៍លុល-បៃត៍របស់ព្រះសាស្តា ﷺ ដែលស្មើនឹងគម្ពីរអាន ដែលជាអ្នកស្រាយព្រះរាជប្រកាសនា (គឺព្រះបន្ទូលអល់ឡោះហ្ (عزّ وجلّ)) នោះ បានពន្យល់រឿងនេះ ដើម្បីនិយាយសង្ខេប យើងសូមលើកយកមកតែពីរវចនៈរបស់ព្រះអង្គទេ គឺ៖

អ៊ីមុាំអាស្ហ៍-ស្ហ៍ឌិក្ហ (صلوات الله عليه والسلام) មានវចនៈថា៖

أيام الله ثلاثة: يوم القائم ويوم الكرّة ويوم القيامة.

*"ថ្ងៃរបស់អល់ឡោះហ្ (عزّ وجلّ) មានបីគឺ៖ ថ្ងៃអាល់-ក៏អ៊ីម (صلوات الله عليه والسلام) [ងើបឡើង] (គឺថ្ងៃអ៊ីមុាំអាល់-ម៉ាស្ហ៍ឌី) ថ្ងៃ "និវត្តន៍" និងថ្ងៃរស់ពីស្លាប់វិញ ។"*

ព្រះអង្គ (صلوات الله عليه والسلام) មានវចនៈដែរថា៖

ليس منّا من لم يؤمن بكرّتنا.

*"អ្នកណាមិនជឿថាយើងនិវត្តន៍វិញទេ អ្នកនោះមិនមែនកនយើងទេ ។"*

ដល់ដំណាក់ការនេះ គប្បីគូសបញ្ជាក់ចំណុចសំខាន់ពីរគឺ៖

## ១. ទស្សនៈរបស់រ៉ច់អ៊ុស់

ក្នុងការវិភាគមើលហេតុរបស់រ៉ច់អ៊ុស់ យើងជួបប្រទះនូវគោលដៅដ៏វិសេសពីរ មួយគឺបង្ហាញឲ្យឃើញថា អ៊ីស្លាមមានសម្រស់និងភាពត្រចះត្រចង់ និងបង្ហាញឲ្យឃើញថាអសទ្ធា (គុហ្វរ៍) ជាការថោកទាប ពីរគឺតបស្នងមនុស្សដែលមានសទ្ធាជ្រះថ្លានិងធ្វើល្អ និងដាក់ទោសមនុស្សអសទ្ធាគាបសង្កត់សង្កិនគេ ។

## ២. អសទិសភាពធំពីររវាងរ៉ច់អ៊ុស់ និងតាណាស៊ុក (التَّنَاسُخ វដ្តសង្សារ)

ចាំបាច់ត្រូវលើកឡើងថាក្នុងទស្សនៈស្ស៊ីអ៊ុស់ រឿងរ៉ច់អ៊ុស់មិនមានន័យថាជឿលើវដ្តសង្សារ (តាណាស៊ុខ គឺការវិលកើត វិលស្លាប់) នោះជាដាច់ខាត ពីព្រោះទ្រឹស្តីវដ្តសង្សារផ្អែកលើការបដិសេធថ្ងៃរស់ពីស្លាប់វិញ ហើយចាត់ទុកលោកជានេះវង់មូលវិលវល់ ជុំមួយចប់ហើយមានជុំមួយទៀតឥតចប់ ជុំក្រោយក៏ដូចជុំមុនដែរ ។

យោលតាមទ្រឹស្តីនេះ វិញ្ញាណរបស់មនុស្សម្នាក់ៗត្រឡប់មកលោកនេះវិញក្រោយពីបានស្លាប់ហើយ មកចូលរូបមួយទៀតវិញ ។ ដូច្នេះ បើវិញ្ញាណនោះល្អកាលពីជីវិតមុន វានឹងវិលមកចូលរូបវិញហើយនឹងបានសោយសុខក្នុងជីវិតថ្មីនេះ តែបើវិញ្ញាណនោះអាក្រក់ វានឹងវិលមកចូលរូបវិញហើយសោយទុក្ខក្នុងជីវិតថ្មីនោះ ។ និវត្តន៍នេះគឺការរស់ពីស្លាប់វិញរបស់វិញ្ញាណ ។

ផ្ទុយពីនេះ ព្រោះតែអ្នកជឿរ៉ច់អ៊ុស់គោរពតាមច្បាប់អ៊ីស្លាម អ្នកនោះជឿ



លើសពីនេះ អាប៊ូ ត្ព៍លិប គាំទ្រអ៊ុលី صلوات الله عليه والسلام កូនប្រុសជាទីស្រឡាញ់របស់លោកឲ្យនៅអបអមនិងជ្រោមជ្រែងព្រះសាស្តា صلى الله عليه وآله وسلم អល់ឡោះហ្វ៍ عز وجل សូមឲ្យអ៊ុលី صلوات الله عليه والسلام ជួយព្រះសាស្តា صلى الله عليه وآله وسلم ក្នុងគ្រប់ពេលលំបាក នាដើមសម័យអ៊ីស្លាម ។

លោក អ៊ីបនូ អាប៊ូ អាល់-ហ្ចាឌីដ្ឋ អាល់-មុអ្ត៍តាស៊ីលី (بن ابي الحديد المعتزلي) មានប្រសាសន៍នៅក្នុងសៀវភៅលោក ស្ហារហ៍ ណាស្ហ៍យ៉ាល់-បាឡាកោះត្ហ៍ ថា អាប៊ូ ត្ព៍លិប បានប្រាប់ អ៊ុលី صلوات الله عليه والسلام កូនប្រុសលោកថា៖ "ព្រះសាស្តា صلى الله عليه وآله وسلم អល់ឡោះហ្វ៍ عز وجل ហៅកូនទៅរកអ្វីដែលល្អប្រសើរ ។ ដូច្នេះចូរកូននៅខាងព្រះអង្គ صلى الله عليه وآله وسلم ជានិច្ច ។"[276]

ពិតប្រាកដណាស់ អាប៊ូ ត្ព៍លិប បានបម្រើព្រះសាស្តា صلى الله عليه وآله وسلم និងបានលះបង់ខ្លួនដើម្បីការពារព្រះសាសនាអ៊ីស្លាម នេះជាភ័ស្តុតាងបញ្ជាក់ថា អាប៊ូ ត្ព៍លិប មានសទ្ធាជ្រះថ្លាជាក់ច្បាស់មែន ។

ហេតុដូច្នេះឯងបានជាលោកអ្នកប្រាជ្ញដ៏ល្បីមួយរូប គឺលោក អ៊ីបនូ អាប៊ូ អាល់-ហ្ចាឌីដ្ឋ បានចងក្រងកំណាព្យស្តីអំពីតួនាទីរបស់អាប៊ូ ត្ព៍លិបនៅក្នុងការការពារព្រះសាស្តា صلى الله عليه وآله وسلم និងព្រះសាសនាបរិសុទ្ធរបស់ព្រះអង្គ صلى الله عليه وآله وسلم ថា៖

ولولا ابوطالبٍ وابنُهُ

សូមមើលសៀវភៅ *អាត្ត់-ត្ព៍បាក្ហត់ អាល់-គុបរ៉* *(الطبقات الكبرى)* (បោះពុម្ពនៅបៃរូត ឆ្នាំ 1380 ស.ហ.) ជុំទី ១ ទំព័រ ១១៩ ។

[276] សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាប៊ី អាល់-ហ្ចាឌីដ្ឋ (بن ابي الحَدِيد) *ស្ហារហ៍ ណាស្ហ៍យ៉ាល់-បាឡាកោះត្ហ៍* *(شرح نهج البلاغة)* (បោះពុម្ពលើកទី ២) ជុំទី ១៤ ទំព័រ ៥៣ ។

អស់លោកអ្នកនិពន្ធខ្លះ ក្នុងគោលបំណងបៀតបៀនអ្នកមានសទ្ធាជ្រះថ្លាគ្នូរ៉យ៉ស្ង៍ម្នាក់ គឺឪពុកមារបស់ព្រះសាស្តាﷺ អ្នកការពារសាសនានៅក្នុងស្ថានភាពលំបាកតាំងពីដើមសម័យអ៊ីស្លាមម្ល៉េះនោះ ជាការខុសស្រឡះ ។

## ២. អាកប្បកិរិយារបស់ អាប៊ូ ត៉្វលិប ចំពោះព្រះសាស្តាﷺ បញ្ជាក់ថាលោកមានជំនឿមែន ។

អស់លោកអ្នកប្រវត្តិសាស្ត្រល្បីៗរាយការណ៍ថា អាប៊ូ ត៉្វលិប បានលះបង់ខ្លួនដើម្បីការពារព្រះសាស្តាﷺអល់ឡោះហ្វ៍ﷻ នេះបញ្ជាក់ឲ្យឃើញថាលោកមានសទ្ធាជ្រះថ្លាមែន ។

អាប៊ូ ត៉្វលិបសុខចិត្តនារទេសទៅរស់នៅទីដាច់ស្រយាលឯជ្រលងភ្នំដែលគេហៅ ស្ហ្សអ៊ុប អាប៊ូ ត៉្វលិប (شعب أبي طالب) ដែលជាទឹកដីរបស់គ្នូរ៉យ៉ស្ង៍បីឆ្នាំជាមួយព្រះសាស្តាﷺ ដើម្បីការពារអ៊ីស្លាមនិងព្រះសាស្តាﷺ ។ លោកបានរស់នៅជាមួយព្រះសាស្តាﷺលុះពហិការ (គឺការបិទមិនឲ្យមានទំនាក់ទំនងលក់ដូរវវាងពីរក្រុម) ផ្នែកសេដ្ឋកិច្ចមកលើមុស្លីមបានចប់ដោយទទួលរងការឈឺចាប់និងការលំបាកខ្លាំង ។[275]

---

[275] សូមមើលសៀវភៅ ស៊ីរ៉ោះត៍ អាល់-ហាឡាប៊ីយ៉ាស្ញ (បោះពុម្ពនៅអេស៊ីបត៍) ជំទី ១ ទំព័រ ១៣៤; សូមមើលសៀវភៅ *តារីក៊ អាល់-ខ៊ំមីស (تاريخ الخميس)* ជំទី ១ ទំព័រ ២៥៣-២៥៤ (បោះពុម្ពនៅបៃរូត) ។ សូមមើលសៀវភៅ *ស៊ីរ៉ោះត៍ អ៊ីបនូ ហ៊ីស្ហាំ* (បោះពុម្ពនៅបៃរូត) ជំទី ១ ទំព័រ ១៨៩ ។ សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាប៊ី អាល់-ហាឌីដ្ឋ (بن ابي الحَدِيد) *ស្ហារហ៍ ណាស្ញយ៉ាល់-បាឡាក៊ោះត៍ (شرح نهج البلاغة)* (បោះពុម្ពលើកទី ២) ជំទី ១៤ ទំព័រ ៥២ ។ សូមមើលសៀវភៅ *តារីក៊ អាល់-យ៉ាក៊ូប៊ី (تاريخ اليعقوبي)* ដើមជំទី ២ ។ សូមមើលសៀវភៅ *អាល់-អ៊ីស្វ៉ាបាស្ញ (الإصَابة)* (បោះពុម្ពនៅអេស៊ីបត៍ ឆ្នាំ 1358 ហ.ស.) ជំទី ៤ ទំព័រ ១១៥ ។



ថ្ងៃរស់ពីស្លាប់វិញ ហើយយល់ឃើញថាវិញ្ញាណដែលបានបែកចេញពីរូបហើយមិនអាចវិលមកចូលរូបមួយទៀតវិញបានជាដាច់ខាត ។[76]

តែពួកគេជឿថា មនុស្សមួយក្រុមនឹងត្រឡប់មកក្នុងលោកនេះវិញមុនថ្ងៃរស់ពីស្លាប់ បន្ទាប់ពីបានសម្រេចធម្មកម្មទាំងឡាយនិងផលប្រយោជន៍នៃនិវត្តន៍នោះហើយ ពួកគេនឹងស្លាប់ម្តងទៀត ហើយនឹងត្រូវប្រមូលជុំជាមួយមនុស្សឯទៀតក្នុងថ្ងៃរស់ពីស្លាប់ ។ ក្រោយពីវិញ្ញាណបានបែកចេញពីរូប វិញ្ញាណនឹងមិនទៅចូលរូបផ្សេងទៀតជាដាច់ខាត ។

## សំណួរ ១១ - អ្វីទៅស្ហាហ្វាអ៊ាស្ញ (ការធ្វើអន្តរាគមន៍ شفاعة) ដែលអស់លោកជឿនោះ ?

## ចម្លើយ

*ស្ហាហ្វាអ៊ាស្ញ* (ការធ្វើអន្តរាគមន៍ شفاعة) ជាគោលការណ៍មួយ ក្នុងចំណោមគោលការណ៍ច្រើនទៀត ដែលអ៊ីស្លាមអះអាងថាត្រឹមត្រូវ ដែលនិកាយមុស្លីមនិងមាស្ញហ្ហាប់ទាំងអស់ទទួលស្គាល់ ហើយដែលអនុវត្តិតាមគួរអាននិងស៊ុនណាស្ញ ដោយមិនគិតពីមតិរបស់ខ្លួនពាក់ព័ន្ធនឹងលទ្ធផលរបស់ស្ហាហ្វាអ៊ាស្ញនោះទេ ។ ស្ហាហ្វាអ៊ាស្ញមានន័យថាមនុស្សត្រឹមត្រូវ

---

[76] បដិសេធជំនឿលើវដ្តសង្សារ (តាណាស៊ុក្ខ) លោក ស្វ៉ាដ្ឌ័រ អាល់-មូតាអ៊ាល់លីហ៊ីន (صدرالمتألهين) (មូឡា ស្វ៉ាដ្ឌ័រ ملا صدرا) មានប្រសាសន៍នៅក្នុងសៀវភៅលោក *អាល់-អាស់ហ្វារ អាល់-អារបាអ៊ាស្ញ (الأسفار الأربَعة)* ជំទី ៩ បាប់ ៨ កណ្ឌ ១ ទំព័រ ៣ ថា៖

فلون تعلقت نفس منسلخة ببدن أخر عند كونه جنيناً أو غير ذلك يزلم كون أحدهما بالقوة والأخر بالفعل وكون الشئ بما هو بالفعل والقوة. وذلك ممتنع لأن التركيب بينهما طبيعي وإتحادي التركيب الطبيعي يستحيل بين أمرين أحدهما بالفعل والأخر بالقوة.

ដែលមានឋានៈពិសេសនិងនៅក្បែរអល់ឡោះﷻនោះ អាចជួយ អង្វរសុំអល់ឡោះﷻឲ្យលើកលែងទោសឲ្យអ្នកធ្វើខុស ឬជួយអង្វរសុំឲ្យលើកកិត្តិយសឲ្យអ្នកខ្លះ ។

ព្រះសាស្ដាﷺមានព្រះវចនៈថា៖

"أعطيت خمساً وأعطيت الشفاعة فأدخرتها لأمتي."

*"គេបានធ្វើសម្បទានឲ្យខ្ញុំនូវវត្ថុប្រាំ... ហើយគេបានធ្វើសម្បទានឲ្យខ្ញុំនូវការជួយធ្វើអន្តរាគមន៍ដែលខ្ញុំប្រកាន់ទុកឲ្យអ៊ុមម៉ាត់ខ្ញុំ ។"*[77]

## ទំហំរបស់ស្ហាហ្វាអ៊ុស់

គួរអានបដិសេធគំនិតធ្វើអន្តរាគមន៍ ដែលមានលក្ខណៈដាច់ខាតនិងឥតលក្ខខ័ណ្ឌ ។ ការជួយធ្វើអន្តរាគមន៍ ពុំមានប្រសិទ្ធិភាពទេបើពុំមានលក្ខខ័ណ្ឌដូចតទៅនេះ គឺ៖

មួយ - អ្នកជួយធ្វើអន្តរាគមន៍ ចាំបាច់ត្រូវតែបានទទួលការអនុញ្ញាតពីអល់ឡោះﷻ ដើម្បីជួយធ្វើអន្តរាគមន៍ ។ ចំពួកមនុស្សដែលអាចជួយធ្វើអន្តរាគមន៍បានគឺអស់បុគ្គលដែល លើសពីជាជំនិតរបស់ អល់ឡោះﷻ ផ្លូវធម៌ ថែមទាំងត្រូវអល់ឡោះﷻអនុញ្ញាត[ឲ្យជួយធ្វើអន្តរាគមន៍]ទៀតផង ។ ទាក់ទងរឿងនេះ ព្រះមហាគម្ពីរគួរអានថែងថា៖

لَّا يَمْلِكُونَ ٱلشَّفَٰعَةَ إِلَّا مَنِ ٱتَّخَذَ عِندَ ٱلرَّحْمَٰنِ عَهْدًا

*"ពួកគេនឹងពុំមានអំណាចធ្វើអន្តរាគមន៍ទេ លើកលែងតែអ្នកណាដែល*

[77] សូមមើលសៀវភៅ *មុសណាដ់ អាស់ម៉ាដ់ អ៊ីបនូ ហាន់បាល់* ជំទី ១ ទំព័រ ៣០១; *ស្វ៉ាហ៊ិះហ៍ អាល់-ប៊ូខ៉ារី* (បោះពុម្ពនៅ ប្រទេសអេស៊ីបត៍) ជំទី ១ ទំព័រ ៩១ ។



នាអវសានសនជីវិតលោក អាប៊ូ តូលិប បានណែនាំឲ្យពួកមេដឹកនាំគូរ៉យ៉ស្វ៍គាំទ្រព្រះសាស្ដាﷺថា៖

أوصي بنصر نبيِّ الخيرِ أربعةً

ابنى عليّاً وشيخَ القومِ عبّاسا

وحمزةَ الأسدِ الحامي حقيقته

وجعفراً أن تذودوا دونه النّاسا

كونوا فداءً لكم أُمّي وما ولدتْ

في نصرِ احمدَ دون الناسِ أتراسا

*"ខ្ញុំសូមផ្ដែផ្ដាំអ្នកទាំងបួន អ៊ុាលី(صلوات الله عليه والسلام) កូនប្រុសឪពុក, អ៊ុាប់បាស់ មេដឹកនាំបានី អ៊ុាប់បាស់, ហ៉ាំស្សាស់ រាជសីហ៍[របស់អល់ឡោះﷻ] ដែលតែងតែការពារសច្ចធម៌របស់ព្រះសាស្ដាﷺ និង យ៉ាក់ហ្វារ កូនប្រុសឪពុក សូមអ្នកទាំងអស់គ្នាគាំទ្រព្រះសាស្ដាﷺអល់ឡោះﷻទាំងស្រុង ។ សូមអ្នកជាទីស្រឡាញ់ទាំងបួននាក់របស់ខ្ញុំស្មោះត្រង់ចំពោះអាស៊ម៉ាដ់ ដូចខែលការពារព្រះអង្គﷺពីសត្រូវ ។"*[274]

មនុស្សគ្រប់រូបដែលមានប្រាជ្ញាគ្រប់គ្រាន់និងមិនលំអៀងនោះ ទទួលស្គាល់វណ្ណកម្មអក្សរសាស្ត្រប្រកបដោយទេពកោសល្យទាំងនេះថា ជាភ័ស្តុតាងបញ្ជាក់អំពីជំនឿរបស់ អាប៊ូ តូលិប ចំពោះអល់ឡោះﷻនិងចំពោះសាស្ដាភាពរបស់ព្រះសាស្ដាﷺ ។ ភ័ស្តុតាងទាំងនេះបង្ហាញឲ្យឃើញថាទ្រឹស្ដីស៊្មីអ៊ុស់ដែលថាអាប៊ូ តូលិបជាបុគ្គលមានសទ្ធាជ្រះថ្លានោះ ជាទ្រឹស្ដីត្រឹមត្រូវមែន ហើយបង្ហាញឲ្យឃើញថាការចោទប្រកាន់របស់

[274] សូមមើលសៀវភៅរបស់លោក អ៊ីបនូ ស្ហាស់រ៉ អាស្ហ៊ូប អាល់-ម៉ាស៊ាន់ដារ៉ានី (ابن شهر آشوب المازندراني) *មូតាស្ហាប៊ីហ្វាត់ អាល់-គួរអាន (متشابهات القرآن)* កន្លែងស្រាយស៊ូរ៉ោះត៍ អាល់-ហាជ្ជ៍ តពីអាយ៉ាស់ "ولينصرنّ الله من ينصره" ។

*ព្រះអង្គﷺជាអ្នកមានគុណចំពោះទូលបង្គំ ជាអ្នកណែនាំស្មោះត្រង់និងជាទីទុកចិត្ត ។*
*ទូលបង្គំដឹងច្បាស់ថាសាសនារបស់មូហាំម៉ាដ្ឋﷺ ជាសាសនាល្អប្រសើរជាច់អស់សាសនាក្នុងលោក ។"*[272]

يا شاهد الله عليّ فاشهد

أنّي على دين النّبيّ أحمد

من ضَلّ في الدّين

فإنّي مُهتَدي

*"ឱសាក្សីរបស់អល់ឡោះហ៍ﷻអើយ សូមព្រះអង្គﷺធ្វើសាក្សីឲ្យទូលបង្គំថាទូលបង្គំជឿសាសនារបស់អាហ្ម៉ាដ្ឋ ។ [សូមព្រះអង្គﷺធ្វើសាក្សីឲ្យទូលបង្គំថា] អ្នកខ្លះវង្វេងចេញពីសាសនា ទូលបង្គំនៅក្នុងចំណោមអ្នកដែលបានទទួលការដឹកនាំល្អ ។"*[273]

---

[272] សូមមើលសៀវភៅ *ខ៊ូន់ស្សាណាស់ អាល់-អាដាប់ អាល់-បាក់ដាឌី (خزانة الأدب البغدادي)* ជំទី ១ ទំព័រ ២៦១ ។ សូមមើលសៀវភៅ *តារីក អ៊ីបនូ កាស៊្សៀរ (تاريخ ابن كثير)* ជំទី ៣ ទំព័រ ៤២ ។ សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាប៊ី អាល់-ហាឌីដ្ឋ (بن ابي الحَدِيد) *ស្ហារហ៍ ណាស្ហ៍យ៉ាល់-បាឡាកោះត៍ (شرح نهج البلاغة)* (បោះពុម្ពលើកទី ២) ជំទី ១៤ ទំព័រ ៥៥ ។ សូមមើលសៀវភៅ *ហ្វាត់ហ៍ អាល់-បារី (فتح الباري)* ជំទី ៧ ទំព័រ ១៥៣-១៥៥ ។ សូមមើលសៀវភៅ *អាល់-អ៊ីស្វ៊ាបាស់ (الإصابة)* (បោះពុម្ពនៅអេស៊ីបត៍ ឆ្នាំ 1358 ហ.ស.) ជំទី ៤ ទំព័រ ១១៦ ។ សូមមើលសៀវភៅ *ឌីវ៉ាន អាប៊ី ត៍លិប (ديوان أبي طالب)* ទំព័រ ១២ ។

[273] សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាប៊ី អាល់-ហាឌីដ្ឋ (بن ابي الحَدِيد) *ស្ហារហ៍ ណាស្ហ៍យ៉ាល់-បាឡាកោះត៍ (شرح نهج البلاغة)* (បោះពុម្ពលើកទី ២) ជំទី ១៤ ទំព័រ ៧៨ ។ សូមមើលសៀវភៅ *ឌីវ៉ាន អាប៊ី ត៍លិប (ديوان أبي طالب)* ទំព័រ ៧៥ ។



*បានធ្វើកតិកាសញ្ញាជាមួយព្រះដ៏មានមេត្តាធម៌ប៉ុណ្ណោះ (១៩:៨៧) ។"*[78]

គួរអានថែងទៀតថា៖

يَوۡمَئِذٖ لَّا تَنفَعُ ٱلشَّفَٰعَةُ إِلَّا مَنۡ أَذِنَ لَهُ ٱلرَّحۡمَٰنُ وَرَضِيَ لَهُۥ قَوۡلٗا

*"ថ្ងៃនោះ ការជួយធ្វើអន្តរាគមន៍នឹងមានប្រយោជន៍សម្រាប់តែអ្នកណាដែល[អល់ឡោះហ៍] ព្រះដ៏មានមេត្តាធម៌អនុញ្ញាតឲ្យទេ ហើយព្រះអង្គនឹងសព្វព្រះហឫទ័យសម្ដីអ្នកនោះ (២០:១០៩) ។"*[79]

**ពីរ** - បុគ្គលដែលគេជួយធ្វើអន្តរាគមន៍ឲ្យនោះ ត្រូវសក្ដិសមនឹងបាននូវព្រះមេត្តាប្រណីតាមរយៈអ្នកជួយធ្វើអន្តរាគមន៍ឲ្យនោះដែរ ។ បានសេចក្ដីថា ជំនឿលើអល់ឡោះហ៍ﷻរបស់បុគ្គលនោះនិងទំនាក់ទំនងផ្លូវធម្ម របស់បុគ្គលនោះជាមួយអ្នកជួយធ្វើអន្តរាគមន៍ឲ្យនោះមិនត្រូវដាច់ទេ ។ ហេតុដូច្នេះ ពួកអសទ្ធាដែលមិនជឿអល់ឡោះហ៍ﷻទេ និងពួកមុស្លីមសាងបាបមួយចំនួន ដូចជាឃាតករនិងពួកដែលមិនស្វ៊ឡាត់ទេ ដែលមិនមានទំនាក់ទំនងផ្លូវធម៌ជាមួយអ្នកជួយធ្វើអន្តរាគមន៍ឲ្យជាដើមនោះ នឹងមិនត្រូវបានទទួលការជួយធ្វើអន្តរាគមន៍ឲ្យទេ ។
ទាក់ទងនឹងបុគ្គលដែលមិនស្វ៊ឡាត់ទេ ដែលបិសេធថ្ងៃរស់ពីស្លាប់វិញនោះ គួរអានថែងថា៖

فَمَا تَنفَعُهُمۡ شَفَٰعَةُ ٱلشَّٰفِعِينَ

*"ដូច្នេះ ការជួយធ្វើអន្តរាគមន៍របស់បណ្ដាអ្នកធ្វើអន្តរាគមន៍នឹងពុំមានប្រយោជន៍សម្រាប់ពួកគេទេ (៧៤:៤៨) ។"*[80]

---

[78] ស៊ូរ៉ោះត៍ ម៉ារយ៉ាំ 19:87 ។

[79] ស៊ូរ៉ោះត៍ ត៍ហា 20:109 ។

[80] ស៊ូរ៉ោះត៍ អាល់-មុដ្ឋដ្ឋាស្ស៊ៀរ 74:48 ។

ទាក់ទងនឹងពួកប្រព្រឹត្តខុស គួរអានចែងថា៖

مَا لِلظَّٰلِمِينَ مِنۡ حَمِيمٖ وَلَا شَفِيعٖ يُطَاعُ

*"ពួកទុច្ចរិតនឹងពុំមានមិត្តស្មោះភក្តីទេ និងពុំមានអ្នកជួយធ្វើអន្តរាគមន៍ដែលគេស្តាប់ទេ (៤០:១៨) ។*[81]

## ទស្សនៈរបស់ស្ឝាហ្វាអុស្ហ់

*ស្ឝាហ្វាអុស្ហ់* ដូច *តៅបាស្ហ់* (ស្មារលាកំហុស) ដែរ ជាពន្លឺនៃសេចក្តីសង្ឃឹមសម្រាប់បុគ្គលដែលអាចលះបង់កំហុស នៅកណ្តាលមាគ៌ាខុសនិងបាបបាន ហើយដែលលះបង់ជីវិតដើម្បីគោរពអល់ឡោះហ្ញ៉ عزّوجلّ ព្រោះពេលណាបុគ្គលសាងកំហុសណាមួយគិតថា អាចទទួលបាននូវការជួយធ្វើអន្តរាគមន៍របស់អ្នកធ្វើអន្តរាគមន៍ឲ្យ ដោយមានលក្ខខ័ណ្ឌខ្លះ (មិនមែនគ្រប់លក្ខខ័ណ្ឌទេ) បុគ្គលនោះនឹងព្យាយាមរក្សាព្រំដែននេះ មិនបំពានព្រំដែននេះទេ ។

## លទ្ធផលរបស់ស្ឝាហ្វាអុស្ហ់

អស់លោកអ្នកស្រាយគួរអានមានមតិផ្សេង ពាក់ព័ន្ធនឹងលទ្ធផលរបស់ការជួយធ្វើអន្តរាគមន៍ គឺ៖ តើលទ្ធផលរបស់ការជួយធ្វើអន្តរាគមន៍នោះគឺការលើកលែងទោស ឬការលើកតម្កើងឋានៈរបស់បុគ្គល ?

តែព្រះវចនៈរបស់ព្រះសាស្តា صلى الله عليه وآله وسلم មួយនេះ

"إن شفاعتي يوم القيامة لأهل الكبائر من أمتي."

*"ការជួយធ្វើអន្តរាគមន៍របស់ខ្ញុំក្នុងថ្ងៃរស់ពីស្លាប់វិញនោះ ត្រូវបានទៅ*

[81] ស៊ូរ៉ោះត៍ ក៏ហ្វៀរ ឬ អាល់-មុមីន 40:18 ។



*នាមព្រះអង្គ عزّوجلّ ឲ្យព្រះសាស្តា صلى الله عليه وآله وسلم ដើម្បីលើកស្ទួយព្រះអង្គ صلى الله عليه وآله وسلم ។ ដូច្នេះ ព្រះម្ចាស់ព្រះរាជបល្ល័ង្កគឺព្រះជាទីសក្ការៈបូជា (អាល់-ម៉ាស្ហ៍មូដ្ឋ) ឯព្រះសាស្តាព្រះអង្គ عزّوجلّ គឺបុគ្គលគួរឲ្យកោតសរសើរ (មូហ៊ាំម៉ាដ្ឋ) ។"*[271]

والله لن يصلوا إليْك بجمعهم

حتّى أُوسّدَ في التُّراب دفينا

فاصدَعْ بأمرِكَ ما عليكَ غضاضةٌ

وابشر بذلك وقرّمنك عيوناً

ودعوتني وعَلمتُ أنك ناصحي

ولقد دعوتَ وكُنتَ ثَمّ أمينا

ولقد علمتُ بأنّ دينَ محمدٍ

من خيرِ أديانِ البريّةِ دِينا.

*"សូមស្បថចំពោះអល់ឡោះហ្ញ៉ عزّوجلّ ពួកសត្រូវមិនអាចបៀតបៀនព្រះអង្គ صلى الله عليه وآله وسلم បានឡើយដរាបណាទូលបង្គំនៅមានជីវិត ។*

*ដូច្នេះ ចូរកុំខ្លាច ចូរព្រះអង្គ صلى الله عليه وآله وسلم បំពេញភារកិច្ចដែលគេបានប្រគល់មកឲ្យព្រះអង្គ صلى الله عليه وآله وسلم ចុះ ។ ចូរព្រះអង្គ صلى الله عليه وآله وسلم រីករាយ ចូរព្រះអង្គ صلى الله عليه وآله وسلم សម្រាកភ្នែក (គឺកុំសោកសៅ) ។*

*ព្រះអង្គ صلى الله عليه وآله وسلم បាននាំទូលបង្គំមកកាន់សាសនាព្រះអង្គ صلى الله عليه وآله وسلم ទូលបង្គំដឹងថា*

[271] សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាប៊ី អាល់-ហ្ញាឌីដ្ឋ (بن ابي الحَدِيد) *ស្ហារហ៍ណាស្ហ៍យ៉ាល់-បាឡាកោះត៍ (شرح نهج البلاغة)* (បោះពុម្ពលើកទី ២) ជុំទី ១៤ ទំព័រ ៧៨ ។ សូមមើលសៀវភៅ *តារីក៏ អ៊ីបនូ អាសាកៀរ (تاريخ ابن عساكر)* ជុំទី ១ ទំព័រ ២៥៧ ។ សូមមើលសៀវភៅ *តារីក៏ អ៊ីបនូ កាស្ឍៀរ (تاريخ ابن كثير)* ជុំទី ១ ទំព័រ ២៦៦ ។ សូមមើលសៀវភៅ *តារីក៏ អាល់-ខ៏មីស (تاريخ الخميس)* ជុំទី ១ ទំព័រ ២៥៤ ។

*អង្គ ﷺ ដឹកនាំនិងឃាត់មនុស្សឲ្យចៀសឆ្ងាយពីបាប តាមព្រះបញ្ជារបស់អល់ឡោះហ្ ﷻ ។"*[269]

ألم تعلموا أنا وجدنا محمداً

رسولاً كموسى خطّ في أوّل الكتب

وأنّ عليه في العباد محبّةً

ولا حيفَ فيمن خصّه الله بالحُب.

*"អស់លោកមិនដឹងទេឬថា យើងចាត់ទុកមូហាំម៉ាដ់ ﷺ ជាព្រះសាស្តា ﷺ [របស់អល់ឡោះហ្ ﷻ] ដូចមូសា عليه السلام ដែរ ដែលមានចែងនៅក្នុងព្រះគម្ពីរមុនៗ? មនុស្សស្រឡាញ់ព្រះអង្គ ﷺ មិនត្រូវបៀតបៀនបុគ្គលដែលអល់ឡោះហ្ ﷻ ធ្វើឲ្យមនុស្សបាក់ចិត្តស្រឡាញ់ទេ ។"*[270]

لَقد أكرمَ اللهُ النّبيَّ محمّداً

فَأكرمُ خلقِ اللهِ في الناسِ أحمدُ

وشقَّ له من اسمِهِ ليُجلَّه

فذو العرشِ محمودُ وهذا محمداً

*"អល់ឡោះហ្ ﷻ លើកស្ទួយមូហាំម៉ាដ់ ﷺ ។ បុគ្គលថ្លៃថ្នូរបំផុតដាច់អស់សត្វលោកគឺអាស់ម៉ាដ់ ﷺ ។ អល់ឡោះហ្ ﷻ បានព្រះរាជទានព្រះរាជ*

[269] សូមមើលសៀវភៅ *អាល់-ហ៊ុច្ចយ៉ាស់* ទំព័រ ៥៧ ។ សូមមើលសៀវភៅ *មុសតាដ់រ៉ក់ អាល់-ហ្វាគីម* (បោះពុម្ពនៅបៃរូត) ជុំទី ២ ទំព័រ ៦២៣ ។

[270] សូមមើលសៀវភៅ *តារីក្ហ អ៊ីបនូ កាស៊ៀរ (تاريخ ابن كثير)* ជុំទី ១ ទំព័រ ៩២; សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាប៊ី អាល់-ហាឌីដ្ឋ (بن ابي الحَدِيد) *ស្ហារហ៍ ណាស្ហ៍យ៉ាល់-បាឡាក្វោះត៌ (شرح نهج البلاغة)* (បោះពុម្ពលើកទី ២) ជុំទី ១៤ ទំព័រ ៧២ ។



*បណ្តាអ្នកអ៊ុមម៉ាត់ខ្ញុំដែលបានប្រព្រឹត្តបាបធំ"*[82] គាំទ្រមតិទីមួយ ។

## សំណួរ ១២ - តើសូមឲ្យអ្នកជួយធ្វើអន្តរាគមន៍ស្របច្បាប់ជួយធ្វើអន្តរាគមន៍ឲ្យនោះជាអំពើស្ហ៊ីរិកទេ ?

ក្នុងការវិភាគសំណួរនេះ គេសន្មតជាមុនថាការជួយធ្វើអន្តរាគមន៍ (ស្ហាហ្វាអុស់) នៅលើអល់ឡោះហ្ ﷻ ទាំងស្រុង ដូចគួរអានចែងថាៈ

قُل لِّلَّهِ ٱلشَّفَٰعَةُ جَمِيعًاۖ

*"ចូរអ្នកថាៈ "ការធ្វើអន្តរាគមន៍ទាំងអស់ជាកម្មសិទ្ធិរបស់អល់ឡោះហ្ (៣៩:៤៤) ។"*[83]

ដូច្នេះ បែរទៅរកអ្នកធ្វើអន្តរាគមន៍ផ្សេងពីអល់ឡោះហ្ ﷻ មានន័យថាសូមសិទ្ធដាច់មុខរបស់អល់ឡោះហ្ ﷻ ពីបាររបស់ព្រះអង្គ ﷻ ហើយការពិតស្វែងរកជំនួយបែបនេះបានសេចក្តីថា គោរពសក្ការៈអ្វីផ្សេងពីអល់ឡោះហ្ ﷻ ហើយមិនត្រូវនឹង "ទ្រឹស្តីឯកទិទេពនិយមក្នុងសក្ការៈ" (តៅហ៊ីដ្ធ ហ្វ៊ីល-អ៊ីបាដ្ហាស់ توحيد في العبادة) ទេ ។

## ចម្លើយ

ត្រង់នេះ *ស្ហ៊ីរិក* (ហ៊ុនហាយ شرك) មិនមានន័យថាហ៊ុនហាយក្នុងសារធាតុដើម ក្នុងអំណាចបង្កើត ឬ ក្នុងការគ្រប់គ្រងលោកទេ តែមាន

[82] សូមមើល *ស៊ូណាន់ អ៊ីបនូ ម៉ាយ៉ាស់* ជុំទី ២ ទំព័រ ៥៨៣; *មុសណាដ់ អ៊ីបនូ ហាន់បាល់* ជុំទី ៣ ទំព័រ ២១៣; *ស៊ូណាន់ អ៊ីបនូ ដាវុដ្ធ* ជុំទី ២ ទំព័រ ៥៣៧; ស៊ូណាន់ អាត់-តៀរមីស៊ី ជុំទី ៤ ទំព័រ ៤៥ ។

[83] ស៊ូរ៉ោះត៌ អាស់-ស៊ូម៉ារ៍ 39:44 ។

ន័យថាហ៊ុនហាយក្នុងការគោរពសក្ការៈព្រះﷻ ។

បំភ្លឺចំណុចនេះ ស្ថិតនៅលើការបកស្រាយត្រឹមត្រូវរបស់ពាក្យសក្ការៈនិង ពាក្យភ័ក្តិភាព ។ យើងទាំងអស់គ្នាដឹងច្បាស់ថាក្នុងការបកស្រាយពាក្យ "សក្ការ:" គេមិនអនុញ្ញាតឲ្យយើងចាត់ទុក "សក្ការ:" ថាចុះចូលខ្លួន ចំពោះអ្នកបង្កើតទេ ហើយក៏ពុំមែនសំណូមចំពោះបាវ[អល់ឡោះហ្ﷻ] ទេ ។

យោលតាមព្រះគម្ពីរគួរអាន ទេវតាបានក្រាបប្រណិប័តន៍អាដាំعليه السلام៖

فَإِذَا سَوَّيْتُهُۥ وَنَفَخْتُ فِيهِ مِن رُّوحِى فَقَعُوا۟ لَهُۥ سَٰجِدِينَ ﴿٧٢﴾ فَسَجَدَ ٱلْمَلَٰٓئِكَةُ كُلُّهُمْ أَجْمَعُونَ ﴿٧٣﴾

*"កាលណាអញបានឲ្យគេមានរូបរាង និងបានផ្លុំវិញ្ញាណអញទៅឯគេ ហើយ កាលនោះចូរពួកអ្នកក្រាបប្រណិប័តន៍គេ ។" ទេវតាទាំងអស់បាន ក្រាបប្រណិប័តន៍ (៣៨:៧២-៧៣) ។"*[84]

ការក្រាបប្រណិប័តន៍នេះ ដែលអល់ឡោះហ្ﷻបានបញ្ជាឲ្យធ្វើនោះ មិន មានន័យថាឲ្យសក្ការៈអាដាំعليه السلامនោះទេ បើដូច្នេះមែនអល់ឡោះហ្ﷻនឹង មិនបញ្ជាឲ្យធ្វើបែបនេះទេ ។

ស្រដៀងនេះដែរ កូនៗរបស់យ៉ាកុគូបعليه السلام ព្រមទាំងយ៉ាកុគូបعليه السلامដែរ បានក្រាបប្រណិប័តន៍យូសុហ្វعليه السلام៖

وَرَفَعَ أَبَوَيْهِ عَلَى ٱلْعَرْشِ وَخَرُّوا۟ لَهُۥ سُجَّدًا ۖ

*"គេបានអញ្ជើញមាតាបិតារបស់គេឡើងទៅលើបល្ល័ង្ក ហើយពួកគេស្រុត*

[84] ស៊ូរ៉ោះត៍ ស្វដ 38:72-73 ។



ជាងមនុស្សឯទៀត ជាអ្នកថែរក្សាព្រះសាស្តាﷺ ។[268]

ដើម្បីបំភ្លឺ យើងសូមលើកមកបង្ហាញជូននូវភ័ស្តុតាងច្បាស់លាស់ដែល បញ្ជាក់ថា អាប៊ូ ត៉ូលិប ជាបុគ្គលមានជំនឿជ្រះថ្លា ។

## ១. វណ្ណកម្មអក្សរសាស្ត្ររបស់ អាប៊ូ ត៉ូលិប ឆ្លុះបញ្ចាំង ជំនឿរបស់លោក

អស់លោកអ្នកប្រាជ្ញ និងអស់លោកអ្នកប្រវត្តិសាស្ត្របានរាយការណ៍អំពី កំណាព្យពោរពេញដោយវោហារកោសល្យរបស់ អាប៊ូ ត៉ូលិប ។ វណ្ណកម្ម ដ៏ឆ្នើមទាំងនេះសរឲ្យឃើញថាលោកមានសទ្ធាជ្រះថ្លា ។ តទៅនេះ យើង បង្ហាញជូននូវស្នាដៃខ្លះរបស់លោក គឺ៖

ليعلمْ خيارُ النّاس أنّ محمّداً

نبيٌّ كموسى والمسيح ابنِ مريمِ

أتانا بهديٍّ مثلَ ما أتيابِهِ

فكلّ بأمرِ الله يهدي ويَعصم.

*"បណ្តាអ្នកថ្លៃថ្នូរត្រូវដឹងថាមូហាំម៉ាដ់ﷺជាព្រះសាស្តាដូចមូសាعليه السلام និង អាល់-ម៉ាស៊ិះហ៍عليه السلام ព្រះរាជបុត្ររបស់ម៉ារយ៉ាំ ។ ព្រះអង្គﷺនាំព្រះរស្មី ត្រចះត្រចង់មកឲ្យយើងស្រដៀងព្រះអង្គទាំងពីរដែរعليهما السلام ។ ព្រះអង្គគ្រប់*

[268] ព័ត៌មានបន្ថែម សូមមើលសៀវភៅ *ស៊ីរ៉ោះត៍ អាល់-ហាឡាប៊ីយ៉ាស់* (បោះពុម្ពនៅអេស៊ីប៉ត៍) ជុំទី ១ ទំព័រ ១៣៤ ។ សូមមើលសៀវភៅ *ស៊ីរ៉ោះត៍ អ៊ីបនូ ហ៊ីស្សាំ* (បោះពុម្ពនៅបៃរូត) ជុំទី ១ ទំព័រ ១៨៩ ។ សូមមើលសៀវភៅ *អាប៊ូ ត៉ូលិប មុមីន គូរ៉យ៉ស្ស៍* (បោះពុម្ពនៅបៃរូត) ទំព័រ ១០៩ ។ សូមមើលសៀវភៅ អាត់-ត៉ូបាកូត់ អាល់-គុបរ៉ (الطبقات الكبرى) (បោះពុម្ពនៅបៃរូត) ជុំទី ១ ទំព័រ ១១៧ ។

បន្ទាប់ពីបានទទួលដំណឹងល្អនេះ អ៊ាប់ឌុល-មុត្តត៍លិប បានក្រាបប្រណិប័តន៍អរព្រះគុណ (ស៊ូយ្ជូដ អាស់-ស៊ុករ៍ سجود الشكر) អល់ឡោះហ្ ﷻ ។ កាលនោះ លោកមានប្រសាសន៍អំពីព្រះរាជកុមារដ៏មានព្រះភាគអង្គនេះថា៖

«انّه كان لي ابنٌ وكنت به مُعجباً وعليه رقيقاً وإنّي زوّجته — كريمةً من كرائم قومي آمنة بنت وهب بن عبدمناف ابن زهرة فجاءت بغلام فسمّينُهُ محمّداً مات ابوهُ واُمُّه وكفلتهُ أنّا وعَمّهُ (يعني أباً طالب»

*"ខ្ញុំមានកូនប្រុសជាទីស្រឡាញ់ម្នាក់ ។ ខ្ញុំបានរៀបអាពាហ៍ពិពាហ៍គេជាមួយនារីថ្លៃថ្នូរម្នាក់ដែលមាននាមថា អាមីណាស់ បុត្រីរបស់ អាល់-វ៉ាហ្ហាប់ អ៊ីបនូ អ៊ាប់ឌុល-ម៉ាណាហ្វ (وهب بن عبد المناف) ។ ស្ត្រីនេះបានប្រសូតបុត្រម្នាក់ដែលខ្ញុំបានដាក់ឈ្មោះឲ្យថាមូហ៊ាំម៉ាដ់ ។ ក្រោយមកបន្តិច ឪពុកនិងម្ដាយគេបានចាកលោកនេះ ។ ឪពុកមារបស់គេ អាប៊ូ ត៍លិប និងខ្ញុំបានចិញ្ចឹម បីបាច់ ថែរក្សាគេ ។"*[267]

សេចក្ដីរាយការណ៍នេះបង្ហាញថា អ៊ាប់ឌុល-មុត្តត៍លិប ស្គាល់អនាគតត្រចះត្រចង់របស់កូនកំព្រារូបនេះ ដូច្នេះឯងបានជាលោកប្រគល់កុមារកំព្រាឲ្យទៅកូនប្រុសជាទីស្រឡាញ់របស់លោកថែរក្សា គឺ អាប៊ូ ត៍លិប មិនប្រគល់មុខងារអស្ចារ្យឥតប្រៀបបាននេះឲ្យទៅអ្នកផ្សេងទេ ។

យោលតាមបិតាដែលជឿព្រះតែមួយគត់ និងមានជំនឿរឹងមាំរបស់លោក អាប៊ូ ត៍លិប ជាបុរសដែលមានជំនឿស្មោះនិងទៀងត្រង់បំផុត ស័ក្តិសម

[267] សូមមើលសៀវភៅ *ស៊ីរ៉ោះត៍ អាល់-ហ្ហាឡាប៊ីយ៉ាស់* (បោះពុម្ពនៅអេស៊ីបត៍) ជុំទី ១ ទំព័រ ១៣៧; *ស៊ីរ៉ោះត៍ អាល់-ហ្ហាឡាប៊ីយ៉ាស់* (បោះពុម្ពនៅបៃរូត) ជុំ ទី ១ ទំព័រ ១១៤-១១៥ ។



*ខ្លួនចុះក្រាបថ្វាយបង្គំចំពោះមុខគេ (១២:១០០) ។"*[85]

បើយើងចាត់ទុកការឱនលំទោននេះស្មើនឹងសក្ការៈយូស៊ុហ្វ عليه السلام ព្រះសាស្ដាយ៉ាក់កូប عليه السلام ដែលមានឋានៈអរិរុទ្ធភាព (عِصْمَة) នោះ ប្រាកដជាព្រះអង្គ عليه السلام មិនបានធ្វើបែបនេះ និងមិនពេញចិត្តនឹងទង្វើរបស់កូនៗព្រះអង្គ عليه السلام ទេ ។ តែពុំមានរបៀបសម្ដែងអាការឱនលំទោនណាដែលថ្លៃថ្នូរជាងការក្រាបប្រណិប័តន៍ទេ ។

ហេតុដូច្នេះ យើងត្រូវតែវែកញែករវាងទស្សនៈ "ឱនលំទោន" ឬ "សូមពីអ្នកក្រៅពីអល់ឡោះហ្ ﷻ" ឲ្យដាច់ឡែកពី "សក្ការៈអល់ឡោះហ្ ﷻ" ។ ន័យពិតរបស់សក្ការៈ គឺគិតថាសត្វលោកជាអល់ឡោះហ្ ﷻ ហើយសក្ការៈសត្វលោកនោះ (វត្ថុឬមនុស្ស) ឬចាត់ទុកបាតុភូតនីមួយដែលជាសត្វលោករបស់អល់ឡោះហ្ ﷻ នោះ ហើយសន្មតថាគេតែងតាំងវាដើម្បីអនុវត្តិទង្វើរបស់អល់ឡោះហ្ ﷻ ដូចជាគ្រប់គ្រងពិភពលោក លុបលាងទោសជាដើម ។

តែសម្ដែងការឱនលំទោនចំពោះអ្នកណាម្នាក់ ដោយមិនចាត់ទុកអ្នកនោះជាព្រះទេ មិនគិតថាអ្នកនោះ ប្រុសឬស្រី ត្រូវគេប្រគល់អំណាចឲ្យធ្វើទង្វើព្រះទេ ការឱនលំទោនបែបនេះមិនមានន័យផ្សេងពីការសម្ដែងសេចក្ដីគោរពចំពោះអ្នកនោះទេ ដូចករណីទេវតាដែរដែលសម្ដែងគារវៈចំពោះអាដាំ عليه السلام ឬដូចកូនៗរបស់យ៉ាក់កូប عليه السلام សម្ដែងសេចក្ដីគោរពចំពោះយូស៊ុហ្វ عليه السلام ។

ទាក់ទងនឹងរឿងនេះ ត្រូវនិយាយដែរថាសន្មតថាសិទ្ធិធ្វើអន្តរាគមន៍ត្រូវ

[85] ស៊ូរ៉ោះត៍ យូស៊ុហ្វ 12:100 ។

បានប្រគល់ឲ្យទៅអ្នកធ្វើអន្តរាគមន៍ស្របច្បាប់ ហើយបុគ្គលទាំងនោះអាចជួយធ្វើអន្តរាគមន៍ ឬលុបលាងបាបឲ្យមនុស្សបានដោយពុំមានលក្ខខ័ណ្ឌទេនោះនឹងនាំទៅរកអំពើហ៊ុនហាយ (ស្ហ៊ីរិក) ព្រោះបានសេចក្តីថាស្វែងអ្វីដែលជាកម្មសិទ្ធិរបស់អល់ឡោះហ្វ៍ﷻ ពីបុគ្គលក្រៅពីព្រះអង្គﷻ ។

តែពេលយើងគិតថាក្រុមបាវបរិសុទ្ធរបស់អល់ឡោះហ្វ៍ﷻ បានទទួលការអនុញ្ញាតដោយមានលក្ខខ័ណ្ឌខ្លះ ក្នុង ការជួយធ្វើអន្តរាគមន៍ឲ្យអ្នកប្រព្រឹត្តខុសដោយមិនសន្មតទេថា ក្រុមបុគ្គលបរិសុទ្ធទាំងនេះមានឋានៈស្ហាហ្វាអ៊ុស្សុំពិសេស ហើយគិតថាលក្ខខ័ណ្ឌសំខាន់បំផុតគឺការអនុញ្ញាតនិងសេចក្តីពេញចិត្តរបស់អល់ឡោះហ្វ៍ﷻនោះ ពិតប្រាកដណាស់ដែលប្រវារកបាវត្រឹមត្រូវ[របស់អល់ឡោះហ្វ៍ﷻ] ដើម្បីជួយធ្វើអន្តរាគមន៍ឲ្យនោះមិនមានន័យថាទទួលស្គាល់បាវទាំងនោះជាព្រះទេ ហើយក៏មិនមានន័យថាការទទួលខុសត្រូវកិច្ចការរបស់អល់ឡោះហ្វ៍ﷻនោះ ត្រូវបានប្រគល់មកលើបាវទាំងនោះទេដែរ ។ តែមានន័យថាសូមអ្នកណាម្នាក់ដែលសក្តិសមនឹងការជួយធ្វើអន្តរាគមន៍នេះ ។

សម័យព្រះសាស្តាﷺ អ្នកប្រព្រឹត្តខុសបានមករកព្រះអង្គﷺដើម្បីសូមព្រះអង្គﷺឲ្យលើកលែងទោស ព្រះ អង្គﷺមិនបានចោទពួកគេទាំងនោះថាហ៊ុនហាយ (ស្ហ៊ីរិក) ទេ ។ នៅក្នុងស៊ូណាន់របស់លោក អ៊ីបនូ ម៉ាយ៉ាស្ហ់ គេបានរាយការណ៍ថាព្រះសាស្តាﷺមានព្រះវចនៈថា៖

"أتدرون ما خيّرني ربي الليلة؟ قلنا: الله ورسوله أعلم. قال: فإنه خيّرني بين أن يدخل نصف امتي والجنة وبين الشفاعة فاخترت الشفاعة قلنا يا رسول الله أدعُ الله أن يجعلنا من أهلها قال هى لكل مسلم."

*"អស់លោកដឹងទេថា អល់ឡោះហ្វ៍ﷻបានធ្វើសម្បទានអ្វីឲ្យខ្ញុំយប់នេះ ?"*



*ឪពុកមាគេខាងឪពុកនឹងយកគេមកចិញ្ចឹម ។"*[264]

បន្ទាប់មក សៃហ្វ៍ អ៊ីបនូ ស៊ី យ៉ាស៊ាន បានរៀបរាប់អំពីអនាគតសាស្តាអង្គនេះថា៖

«يعبد الرّحمن ويدحض الشّيطان ويخمد النّيران ويكسر الأوثان. قوله فصلٌ وحكمه عدلٌ ويأمر بالمعروف ويفعله وينهى عن المنكر ويبطله»

*"គេនឹងគោរពសក្ការៈព្រះដ៏មានព្រះមេត្តាករុណា គេនឹងទប់ទល់ស្ហៃតន គេនឹងពន្លត់ភ្លើងនិងកម្ទេចរូបបដិមា ។ សម្តីរបស់គេជាសម្តីពិត ការវិនិច្ឆ័យរបស់គេជាការវិនិច្ឆ័យសមធម៌និងត្រឹមត្រូវ ។ គេនឹងដឹកនាំមនុស្សទៅរកមាគ៌ាល្អ ខ្លួនគេផ្ទាល់ជាមនុស្សប្រព្រឹត្តល្អ ។ គេហាមប្រព្រឹត្តអាក្រក់និងលុបបំបាត់អំពើអាក្រក់ ។"*[265]

បន្ទាប់មក សៃហ្វ៍ អ៊ីបនូ ស៊ី យ៉ាស៊ាន បានប្រាប់អាប់ឌុល-មុត្តាលិបថា៖

«انّك لجدّه يا عبد المطلب غير كذب»

*"អាប់ឌុល-មុត្តាលិបអើយ ពិតប្រាកដណាស់ លោកជាជីតារបស់គេ ។"*[266]

[264] សូមមើលសៀវភៅ *ស៊ីរ៉ោះត៍ អាល់-ហាឡាប៊ីយ៉ាស្ស់* (បោះពុម្ពនៅអេស៊ីប៍) ជំទី ១ ទំព័រ ១៣៦-១៣៧; ស៊ីរ៉ោះត៍ អាល់-ហាឡាប៊ីយ៉ាស្ស់ (បោះពុម្ពនៅបៃរូត) ជំទី ១ ទំព័រ ១១៤-១១៥ ។

[265] សូមមើលសៀវភៅ ស៊ីរ៉ោះត៍ អាល់-ហាឡាប៊ីយ៉ាស្ស់ (បោះពុម្ពនៅអេស៊ីប៍) ជំទី ១ ទំព័រ ១៣៦-១៣៧; ស៊ីរ៉ោះត៍ អាល់-ហាឡាប៊ីយ៉ាស្ស់ (បោះពុម្ពនៅបៃរូត) ជំទី ១ ទំព័រ ១១៤-១១៥ ។

[266] សូមមើលសៀវភៅ ស៊ីរ៉ោះត៍ អាល់-ហាឡាប៊ីយ៉ាស្ស់ (បោះពុម្ពនៅអេស៊ីប៍) ជំទី ១ ទំព័រ ១៣៦-១៣៧; ស៊ីរ៉ោះត៍ អាល់-ហាឡាប៊ីយ៉ាស្ស់ (បោះពុម្ពនៅបៃរូត) ជំទី ១ ទំព័រ ១១៤-១១៥ ។

របស់ អាប៊ូ ត៏លិប ជឿព្រះតែមួយគត់និងមានជំនឿរឹងមាំបំផុត ។ លោក យ៉ាក៏គូប៊ី (اليعقوبي) បានសរសេរនៅក្នុងសៀវភៅប្រវត្តិសាស្ត្ររបស់លោក អំពី អាប៉ូឌុល-មុត្តត៏លិបថា៖

«رفض عبادة الأصنام ووحّدالله عزّ وجل»

*"អាប៉ូឌុល-មុត្តត៏លិបមិនចូលរួមក្នុងការគោរពសក្ការៈរូបបដិមាទេ លោកមិនគោរពសក្ការៈអ្វីក្រៅពីអល់ឡោះហ៍ﷻមួយគត់ទេ ។"*[263]

យើងសូមបែរមកមើលបិតាដែលគោរពសក្ការៈអល់ឡោះហ៍ﷻ ដែលមានជំនឿរឹងមាំនោះថាអ្វីខ្លះអំពីបុត្ររបស់ខ្លួន គឺ អាប៊ូ ត៏លិប ។

## អាប៉ូឌុល-មុត្តត៏លិប រៀបរាប់អំពី អាប៊ូ ត៏លិប

ប្រវត្តិសាស្ត្របានឲ្យដឹងថា គេបានដឹងជាមុនហើយបានប្រាប់ អាប៉ូឌុល-មុត្តត៏លិបឲ្យដឹងអំពីអនាគតត្រចះត្រចង់របស់ព្រះសាស្តាﷺ និងសាស្តាភាពរបស់ព្រះអង្គﷺ ។

កាល សៃហ្វ៍ អ៊ីបនូ ស៊ី យ៉ាស៊ាន (سيف بن ذي يزن) បានកាន់កាប់ប្រទេសអាប៊ីស៊ីនី អាប៉ូឌុល-មុត្តត៏លិបបានមកជួបលោកក្នុងពិធីមួយ ។ បន្ទាប់ពីបានថ្លែងសុន្ទរកថាប្រកបដោយវោហារកោសល្យ អភិបាលស្រុកអាប៊ីស៊ីនីបានប្រាប់លោកថា៖ "សាស្តាថ្មែថ្នូរមួយអង្គនឹងកើតឡើងនៅក្នុងត្រកូលលោក ។" ពាក់ព័ន្ធនឹងភិណ្ឌភាគព្រះសាស្តាﷺ សៃហ្វ៍ អ៊ីបនូ ស៊ី យ៉ាស៊ាន បានថា៖

«اسمه محمّد – صلى الله عليه (وآله) وسلّم – يموت أبوه وأُمّه ويكفله جدّه وعمّه»

*"ឈ្មោះរបស់គេគឺមូហ៊ាំម៉ាដ់ ។ ឪពុកនិងម្តាយគេនឹងស្លាប់ ។ ជីតានិង*

[263] សូមមើលសៀវភៅ *តារិក អាល់-យ៉ាក៏គូប៊ី* (تاريخ اليعقوبي) ជុំទី ២ ទំព័រ ៧ ។



*យើងបានទូលថា៖ "មានតែអល់ឡោះហ៍ﷻនិងព្រះសាស្តាﷺព្រះអង្គﷻទេដែលទ្រង់ញាណជាងគេ ។" ព្រះសាស្តាﷺមានព្រះវចនៈថា៖ "ព្រះអង្គﷻបានឲ្យខ្ញុំមានសិទ្ធជ្រើសរើសយកវត្ថុមួយ ក្នុងចំណោមវត្ថុពីរ គឺ៖ មួយគឺពាក់កណ្តាលអ៊ុមម៉ាត់ខ្ញុំនឹងបានចូលឋានសួគ៌ ពីរគឺសិទ្ធិធ្វើអន្តរាគមន៍ ។ ដូច្នេះខ្ញុំជ្រើសរើសយកវត្ថុទីពីរ ។" យើងបានទូលថា៖ "ព្រះសាស្តាﷺអល់ឡោះហ៍ﷻអើយ សូមព្រះអង្គﷺសូមអល់ឡោះហ៍ﷻឲ្យអស់ទូលបង្គំស័ក្តិសមនឹងបានវា (គឺអន្តរាគមន៍) ។" ព្រះអង្គﷺមានព្រះវចនៈថា៖ "វានឹងបានលើមុស្លីមទាំងអស់ ។"*[86]

នៅក្នុងហាឌីស្សនេះ គេបានបង្ហាញឲ្យឃើញច្បាស់ថាបណ្តាសាវករបស់ព្រះសាស្តាﷺសូមព្រះអង្គﷺឲ្យជួយធ្វើអន្តរាគមន៍ ថា៖ "សូមព្រះអង្គﷺសូមអល់ឡោះហ៍ﷻ..." ។
ព្រះមហាគម្ពីរគួរអានចែងដែរថា៖

وَلَوْ أَنَّهُمْ إِذ ظَّلَمُوٓاْ أَنفُسَهُمْ جَآءُوكَ فَٱسْتَغْفَرُواْ ٱللَّهَ وَٱسْتَغْفَرَ لَهُمُ ٱلرَّسُولُ لَوَجَدُواْ ٱللَّهَ تَوَّابًا رَّحِيمًا

*"ប្រសិនបើពេលពួកគេ (គឺពួកបដិសេធសទ្ធា) ធ្វើខុសលើខ្លួនឯង ពួកគេបានមករកអ្នក សូមខមាទោសចំពោះអល់ឡោះហ៍ ហើយសាស្តាជួយសូមខមាទោស[ចំពោះអល់ឡោះហ៍]ឲ្យពួកគេ[ដែរ] ពួកគេនឹងឃើញ ថាអល់ឡោះហ៍ទទួលការសា្តយក្រោយ រាងចាល ព្រះអង្គមានព្រះមេត្តាករុណាប្រណី (៤:៦៤) ។"*[87]

មួយកន្លែងទៀត គួរអានចែងអំពីកូនៗរបស់យ៉ាក៏គូបؑថា៖

[86] សូមមើល *ស៊ូណាន់ អ៊ីបនូ ម៉ាយ៉ាស្ហ៍* ជុំទី ២ "បាប់ ស៊ិករ៍ អាស្ហ៍-ស្ហាហ្វាអាស្ហ៍" ទំព័រ ៥៨៦ ។

[87] ស៊ូរ៉ោះត៍ អាន់-នីសាអ៍ 4:64 ។

قَالُواْ يَٰٓأَبَانَا ٱسۡتَغۡفِرۡ لَنَا ذُنُوبَنَآ إِنَّا كُنَّا خَٰطِـِٔينَ

*"ពួកគេ (បងប្អូនរបស់យូស៊ុហ្វ) បានថ្លែងថា៖ "លោកឪពុក សូមលោកឪពុកជួយអង្វរសូមខមាទោសចំពោះអល់ឡោះហ្វ៍ﷻឲ្យកូនៗផង ដែលកូនរាល់គ្នាបានធ្វើបាបកម្ម ។ កូនរាល់គ្នាបានប្រព្រឹត្តខុស (១២:៩៧) ។"*[88]

ព្រះសាស្ដាយ៉ាក់គូបعليه السلامក៏បានសន្យាពួកគេថានឹងអង្វរសូមអល់ឡោះហ្វ៍ﷻឲ្យលើកទោសឲ្យពួកគេ ដោយមិនចោទពួកគេថាហ៊ុនហាយ (ស្ហ៊ីរិក) ទេ (ដែលបានសូមព្រះអង្គعليه السلام ឲ្យជួយអង្វរសូមអល់ឡោះហ្វ៍ﷻឲ្យលើកលែងទោសនោះ) ថា៖

قَالَ سَوۡفَ أَسۡتَغۡفِرُ لَكُمۡ رَبِّيٓۖ إِنَّهُۥ هُوَ ٱلۡغَفُورُ ٱلرَّحِيمُ

*"គេ (យ៉ាក់គូប) បានថា៖ "ឪពុកនឹងជួយសូមខមាទោសចំពោះព្រះម្ចាស់ឪពុកឲ្យកូនរាល់គ្នា ។ ពិតណាស់ ព្រះអង្គទ្រង់អត់ឱន ព្រះអង្គមានព្រះមេត្តាករុណាប្រណី (១២:៩៨) ។"*[89]

## សំណួរ ១៣ - តើស្វែងរកជំនួយពីអ្នកផ្សេងពីអល់ឡោះហ្វ៍ﷻនោះជាអំពើហ៊ុនហាយ (ស្ហ៊ីរិក) មួយប្រភេទទេ ?

### ចម្លើយ

ការសមហេតុផលនិងប្រកាសនា (គឺតាមអាយ៉ាត់) បានបញ្ជាក់ឲ្យដឹងថាមនុស្សជាតិទាំងអស់ និងបាតុភូតទាំងអស់ក្នុងលោកនេះត្រូវការអល់ឡោះហ្វ៍ﷻដើម្បីទ្រទ្រង់អាត្មា ។

[88] ស៊ូរ៉ោះត៍ យូស៊ុហ្វ 12:97 ។

[89] ស៊ូរ៉ោះត៍ យូស៊ុហ្វ 12:98 ។



មិនសូមឲ្យខ្ញុំដកទ័ពចេញ ចោលការប៉ុនប៉ងកម្ទេចកាក់បាស្ហ ?"

ដោយទុកចិត្តលើអល់ឡោះហ្វ៍ﷻទាំងស្រុង អាប់ឌុល-មុត្តត៏លិប បានតបវិញថា៖

«أنا ربّ الإبل وللبيت ربّ يمنعُهُ يحميه»

*"ខ្ញុំជាម្ចាស់របស់អូដ្ឋ រីឯព្រះមហាគ្រឹះនេះ (គឺកាក់បាស្ហ) មានម្ចាស់វាដែរ ដែលការពារវា ។"*[261]

បន្ទាប់ពីនោះលោកបានត្រឡប់ទៅម៉ាក់កាស្ហវិញ ។ លោកបានចាប់កងលើទ្វារកាក់បាស្ហ ហើយថា៖

يا ربِّ لا أرجولهم سواكا

يا ربِّ فامنع منهم حماكا

إنّ عدوّ البيت من عاداكا

إمنعهم أن يخربوا فناكا

*"ព្រះម្ចាស់អើយ ទូលព្រះបង្គំជាខ្ញុំមិនសង្ឃឹមលើអ្នកណាក្រៅពីព្រះអង្គﷻទេ ។ ព្រះម្ចាស់អើយ សូមព្រះអង្គﷻការពារបូជណីយដ្ឋានព្រះអង្គﷻពីសត្រូវព្រះអង្គﷻ ។ សត្រូវរបស់ព្រះមហាគ្រឹះនេះមកឈ្លានពានព្រះអង្គﷻ សូមព្រះអង្គﷻឃាត់ពួកគេកុំឲ្យកម្ទេចព្រះមហាគ្រឹះព្រះអង្គﷻ ។"*[262]

សម្ដីនេះជាភ័ស្តុតាងច្បាស់លាស់បញ្ជាក់ថា អាប់ឌុល-មុត្តត៏លិប បិតា

[261] សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាល់-អាស្សៀរ (ابن الأثير) *កាមីល* (បោះពុម្ពនៅអេស៊ីបត៍ ឆ្នាំ 1348 ស.ហ) ជុំទី ១ ទំព័រ ២៦១ ។

[262] សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាល់-អាស្សៀរ (ابن الأثير) *កាមីល* (បោះពុម្ពនៅអេស៊ីបត៍ ឆ្នាំ 1348 ស.ហ) ជុំទី ១ ទំព័រ ២៦១ ។

មានសទ្ធាទេ ដើម្បីអស់លោកអាចស៊ីយ៉ារ៉ាស់លោក បាននោះ ?

## ចម្លើយ

អាប៊ូ ត៌ូលិប បុត្ររបស់ អ៊ុប់ឌុល-មុត្ត៌លិប បិតារបស់ អ៊ាលី អាមីរុល-មុមីនីន صلوات الله عليه والسلام ឪពុកមារបស់ព្រះសាស្ដា ﷺ សម្រាប់ស៊ីអ៊ុស្វ ជាបុរសដែលមានសទ្ធា ដែលជឿព្រះសាស្ដា ﷺ អល់ឡោះហ៍ ﷻ ជាសាវករបស់ព្រះសាស្ដា ﷺ និងជាអ្នកការពារព្រះអង្គ ﷺ គ្រប់កាលៈទេសៈ តាំងពីដើមសម័យអ៊ីស្លាមម្ល៉េះ ។

## ត្រកូលរបស់ អាប៊ូ ត៌ូលិប

លោកបានប្រសូតនៅក្នុងត្រកូល អ៊ុប់ឌុល-មុត្ត៌លិប ព្រះអយ្យកោរបស់ព្រះសាស្ដា ﷺ អ្នកតាមអ៊ីបរ៉ហ៊ីម អាល់-ខ៊ុលីល (គឺព្រះសាស្ដាអ៊ីបរ៉ហ៊ីម) عليه السلام ។ ប្រវត្តិសាស្ត្រឧបទ្វីបអារ៉ាប់បង្ហាញឲ្យឃើញថា អ៊ុប់ឌុល-មុត្ត៌លិប នាពេលមានចលាចលនិងប្រកបដោយគ្រោះថ្នាក់ក្នុងជីវិតលោក លោកមិនដែលចោលអល់ឡោះហ៍ ﷻ មិនដែលបោះបង់ការការពារលទ្ធិឯកទិទេពនិយមឡើយ ។

កាល អាប់រ៉ហ្វាស់ (أبرهة) លើកទ័ពដំរីដ៏ធំមកវាយម៉ាក់កាស់ ក្នុងគោលបំណងកម្ទេចកាក់បាស់ អាប់រ៉ហ្វាស់បានចាប់អូដ្ឋរបស់អ៊ុប់ឌុល-មុត្ត៌លិប ។ ពេលអ៊ុប់ឌុល-មុត្ត៌លិបមកទារអូដ្ឋវិញ អាប់រ៉ហ្វាស់សួរលោកដោយភ្ញាក់ផ្អើលថា៖ "ហេតុអ្វីលោកបែរជាសូមយកអូដ្ឋលោកវិញ



ទាក់ទងរឿងនេះ ព្រះមហាគម្ពីរគួរអានថែងថា៖

يَـٰٓأَيُّهَا ٱلنَّاسُ أَنتُمُ ٱلْفُقَرَآءُ إِلَى ٱللَّهِ ۖ وَٱللَّهُ هُوَ ٱلْغَنِىُّ ٱلْحَمِيدُ

*"មនុស្សអើយ ពួកអ្នកត្រូវការអល់ឡោះហ៍ រីឯអល់ឡោះហ៍វិញ ទ្រង់គ្រប់គ្រាន់សម្រាប់ព្រះអង្គឯង ព្រះអង្គសមជាទីគោរពសក្ការៈ (៣៥:១៥) ។"*[90]

មួយកន្លែងទៀត គួរអានថែងថាជោគជ័យទាំងអស់ជារបស់ព្រះម្ចាស់ពិភពទាំងពួង គឺ៖

وَمَا ٱلنَّصْرُ إِلَّا مِنْ عِندِ ٱللَّهِ ٱلْعَزِيزِ ٱلْحَكِيمِ

*"ជ័យជំនះមកពីអល់ឡោះហ៍តែមួយគត់ ព្រះអង្គគឺព្រះឫទ្ធិម័ត (គឺអ្នកមានឫទ្ធិខ្លាំងពូកែ) ព្រះអង្គគឺព្រះមុនិរាជ (៣:១២៦) ។"*[91]

គោរពតាមគោលការណ៍នេះដែលអ៊ីស្លាមអះអាងថាត្រឹមត្រូវនោះ យើងមុស្លីមទាំងឡាយ សូត្រព្រះអាយ៉ាស់នេះនៅក្នុងគ្រប់ស្វ៍ឡាត៌ គឺ៖

إِيَّاكَ نَعْبُدُ وَإِيَّاكَ نَسْتَعِينُ

*"ព្រះអង្គទេដែលអស់ទូលព្រះបង្គំជាខ្ញុំគោរពបូជា (ស្ដាប់បង្គាប់) ព្រះអង្គទេដែលអស់ទូលព្រះបង្គំជាខ្ញុំអង្វរសូមនូវជំនួយ (១:៥) ។"*[92]

តទៅនេះយើងបំភ្លឺសំណួរខាងនេះ គឺ៖ ស្វែងរកជំនួយពីអ្នកផ្សេងពីអល់ឡោះហ៍ ﷻ មានពីរខ គឺ៖

១. មួយគឺយើងស្វែងរកការគាំទ្រពីមនុស្សផ្សេង ឬពីបាតុភូតដោយជឿថា

---

[90] ស៊ូរ៉ោះត៌ អាល់-ហ្វាត្ទៀរ៍ 35:15 ។

[91] ស៊ូរ៉ោះត៌ អាលី អ៊ីមរ៉ន 3:126 ។

[92] ស៊ូរ៉ោះត៌ អាល់-ហ្វាទីហ៊ាស់ 1:5 ។

មនុស្សនោះ ឬបាតុភូតនោះជាបេក្ខជនឯករាជ្យរឿងអំណាចរបស់ខ្លួន ឬរឿងទង្វើរបស់ខ្លួន ហើយសន្មតថាអ្នកនោះឬបាតុភូតនោះមិនត្រូវការអល់ឡោះហ៍ﷻជួយគាំគ្រទេ ។

មិនបាច់ឆ្ងល់ទេ ស្វែងរកការគាំទ្រពីគេផ្សេងពីអល់ឡោះហ៍ﷻដោយរបៀបនេះជាទង្វើហ៊ុនហាយ (ស្ហ៊ិរិក) ទាំងស្រុង ។ ព្រះមហាគម្ពីរគួរអានថែងអំពីភាពឥតខ្លឹមសាររបស់ទង្វើក្នុងអាយ៉ាស់ថា៖

قُلْ مَن ذَا ٱلَّذِى يَعْصِمُكُم مِّنَ ٱللَّهِ إِنْ أَرَادَ بِكُمْ سُوٓءًا أَوْ أَرَادَ بِكُمْ رَحْمَةً ۚ وَلَا يَجِدُونَ لَهُم مِّن دُونِ ٱللَّهِ وَلِيًّا وَلَا نَصِيرًا

*"ចូរអ្នកថ្លែង[ប្រាប់ពួកគេ]ថា៖ "តើអ្នកណាអាចជួយអស់លោកឲ្យរួចផុតពីអល់ឡោះហ៍បាន បើសិនជាព្រះអង្គមានបំណងអាក្រក់លើអស់លោក ឬបើសិនជាព្រះអង្គមានបំណងប្រោសមេត្តាអស់លោក ?" ពួកគេនឹងមិនមានអ្នកឧបត្ថម្ភ និងអ្នកជួយសង្គ្រោះឡើយក្រៅពីអល់ឡោះហ៍ (៣៣:១៧) ។"*[93]

២. ពីរគឺយើងស្វែងរកជំនួយពីអ្នកផ្សេងដោយជឿថា អ្នកនោះជាបុគ្គលដែលត្រូវការអល់ឡោះហ៍ﷻ ដែលមិនមែនជាបេក្ខជនឯករាជ្យទេ ឯឥទ្ធិពលរបស់បុគ្គលនោះមកពីអល់ឡោះហ៍ﷻ ហើយអាស្រ័យលើឥទ្ធិពលនេះ អាចដោះស្រាយបញ្ហាខ្លះ[របស់បាវអល់ឡោះហ៍ﷻ]បាន ។

ដោយមានគំនិតនេះជាមូលដ្ឋាន បុគ្គលដែលយើងស្វែងរកជំនួយនោះបានទទួលសម្បទាន "សន្ធានកម្ម" (គឺអាជ្ញាកណ្ដាល) ពីអល់ឡោះហ៍ﷻ ដើម្បីបំពេញសេចក្ដីត្រូវការខ្លះ ។ ស្វែងរកជំនួយតាមរបៀបនេះ ការពិត វាជាការស្វែងរកការគាំទ្រពីអល់ឡោះហ៍ﷻ ដែលបានធ្វើឲ្យអាជ្ញាកណ្ដាល

[93] ស៊ូរ៉ោះត៍ អាល់-អាស់ស្ហាប់ 33:17 ។



ក. ព្រះរាជកុលដ្ឋានទាំងអស់នេះជារាជវង្សកុលសម្ព័ន្ធគូរ៉យស្ហ៍ និងជាត្រកូល បានី ហ្ហាស្ហ៊ិម ។
ខ. ព្រះអង្គទាំងអស់ជាប់សាលោហិត ជាមួយព្រះសាស្ដាﷺអល់ឡោះហ៍ﷻ មិនអាចទទួលអំណោយទាន (ស្ហ៍ដ្ហាកោ្វះត៍) បានទេ ។
គ. ព្រះអង្គទាំងអស់ប្រកបដោយបារមីអវិរុទ្ធ ពុំនោះទេព្រះអង្គទាំងអស់នឹងឃ្លាតចាកពីព្រះមហាគម្ពីរគួរអានជាស្វ័យប្រវត្ត ព្រោះព្រះសាស្ដាﷺមានព្រះវចនៈថា៖ "ទាំងពីរនេះ (គឺគួរអាននិងអ៊ិតរ៉ោះត៍) នឹងមិនបែកគ្នាជាដាច់ខាត លុះពួកគេបានមកជួបខ្ញុំនៅឯស្រះ[កៅស្ហារ] ។"

ឃ. ព្រះអង្គទាំងអស់មានចំនួនដប់ពីរអង្គ ជាអ្នកការពារនិងជាអ្នកដឹកនាំមុស្លីមទាំងអស់ និងជាអ្នកស្នងព្រះសាស្ដាﷺអល់ឡោះហ៍ﷻបន្តបន្ទាប់គ្នា ។

ង. ព្រះឧត្ដរាធិការីរបស់ព្រះសាស្ដាﷺទាំងដប់ពីរអង្គនេះ ជាប្រភពនៃសេចក្ដីរុងរឿងនិងវិរោចនភាពរបស់អ៊ីស្លាម ។

គុណសម្បត្តិទាំងនេះបញ្ជាក់ច្បាស់ថា គោលដៅរបស់ព្រះសាស្ដាﷺ ពេលព្រះអង្គﷺមានព្រះវចនៈអំពីព្រះរាជកុលដ្ឋានរបស់ព្រះអង្គﷺដែលព្រះអង្គﷺដាក់បញ្ជាឲ្យតាមនោះ សំដៅទៅលើអ៊ីមុាំបរិសុទ្ធទាំងដប់ពីរអង្គនៃព្រះរាជវង្សព្រះអង្គﷺនោះឯងដែលស្ហ៊ីអ្ហស់គោរពស្រឡាញ់ និងតាម ដែលពួកគេតោងជាប់ដោយស្គាល់បុណ្យស័ក្តិនិងបារមីរបស់ព្រះអង្គច្បាស់ដែលមកពីអល់ឡោះហ៍ﷻនោះ ។

## សំណួរ ២៩ - តើ អាប៊ូ ត៉ លិប បានទទួលអនិច្ចកម្មជាអ្នក

ព្រះអភិញ្ញារបស់ព្រះអង្គﷺ ។

៣. ព្រះអគ្គមហាប្រមុខរបស់បណ្ដាអ្នកមានសទ្ធាជ្រះថ្លា អ៊ុលី អ៊ីបនូ អាប៊ី ត៉លិប صلوات الله عليه والسلام មានវចនៈថាបណ្ដាអ្នកដឹកនាំមុស្លីមទាំងអស់នៅក្នុងវង្សត្រកូល បានី ហ្វាស៊ីម ។ នេះគឺភ័ស្តុតាងច្បាស់លាស់មួយទៀតដែលអះអាងបញ្ជាក់ថាសម្ដីរបស់ស៊ីអុាស៊ូរឿងព្រះរាជកុលដ្ឋាននោះ ជាសម្ដីពិតមែន កាលព្រះអង្គ صلوات الله عليه والسلام មានវចនៈ ថា៖

«إنّ الأئمّة من قُريش غرسوا في هذا البطن – من بني هاشم لاتَصلح عَلى من سواهُم ولا تَصلح الولاة من غيرهم»

*"អ៊ីមុាំ (អ្នកដឹកនាំដែលមកពីអល់ឡោះហ៍ﷻ) នឹងចេញមកពីវង្សត្រកូលគួរ៉យ៉ស៍ ។ ពួកគេត្រូវតែងតាំងឡើងនៅក្នុងត្រកូលហ្វាស៊ីម ។ អ្នកឯទៀតមិនស័ក្ដិសមដឹកនាំមនុស្សទេ អ្នកឯទៀតមិនមានសិទ្ធិកាន់ក្ដាប់រដ្ឋបាលទេ ។"*[260]

## សេចក្ដីសរុប

យើងអាចដកស្រង់ពីហាឌីស្ហទាំងនេះបាននូវការពិតពីរគឺ៖

១. ចាំបាច់ត្រូវតាមព្រះរាជកុលដ្ឋានព្រះសាស្ដាﷺ គួបនឹងការគោរពតាមព្រះគម្ពីរអល់ឡោះហ៍ﷻ ។

២. ព្រះរាជកុលដ្ឋានរបស់ព្រះសាស្ដាﷺ ដែលត្រូវណែនាំឲ្យស្គាល់ថាស្មើនឹងគួរអាន ថាជាអាជ្ញាធរគំរូសម្រាប់មុស្លីមទាំងអស់នោះ មានលក្ខណៈពិសេសដូចតទៅគឺ៖

[260] សូមមើលសៀវភៅ *ណាស្ហ៍ល់-បាឡាកោះត៍ (نهج البلاغة)* ឃុត្តបាស៊ូ ១៤៤ ។



និងអន្តរការីទាំងនេះកើតមានឡើងបាន ហើយបានធ្វើសម្បទានឥទ្ធិពល និងលទ្ធផលឲ្យទៅពួកគេ ដើម្បីបំពេញសេចក្ដីត្រូវការរបស់អ្នកឯទៀត ។ តាមការពិត ជីវិតរបស់មនុស្សគ្រប់រូបស្ថិតនៅលើការស្វែងរកជំនួយពីអាជ្ញាកណ្ដាលនិងអន្តរការីទាំងនេះ គ្មានបុគ្គលទាំងនេះទេ ជីវិតមនុស្សនឹងច្របូកច្របល់ ។

បើឃើញថា អាជ្ញាកណ្ដាលទាំងនេះជាភ្នាក់ងារសម្រាប់អនុវត្តិការជួយគាំទ្ររបស់អល់ឡោះហ៍ﷻ ហើយជឿថាអាជ្ញាកណ្ដាលទាំងនេះកើតមកពីអល់ឡោះហ៍ﷻ ហើយមានអល់ឡោះហ៍ﷻជាអ្នកប្រទានឥទ្ធិពលឲ្យនោះ ការស្វែងរកជំនួយបែបនេះមិនផ្ទុយនឹងតៅហ៊ីដ (គឺទ្រឹស្ដីឯកទិទេពនិយម) ទេ ។

បើកសិករដែលមានជំនឿលើព្រះដោយស្មោះ ស្វែងរកជំនួយតាមរយៈភ្នាក់ងារបែបនេះ ដូចជាដី ទឹក ធាតុ អាកាសនិងថ្ងៃជាដើមដើម្បីដាំដំណាំឲ្យវាដុះឡើងលុះមានផលានុផល ការពិតកសិករនោះបានស្វែងរកជំនួយពីអល់ឡោះហ៍ﷻ ព្រោះព្រះអង្គﷻជាអ្នកប្រទានឥទ្ធិពលនិងសកម្មភាពឲ្យទៅភ្នាក់ងារទាំងនេះ ។

ពិតហើយថា ស្វែងរកពំនាក់អាស្រ័យតាមរបៀបខាងលើនេះសមស្របទៅតាមទ្រឹស្ដីតៅហ៊ីដពេញលេញណាស់ ។ ការពិត ព្រះមហាគម្ពីរគួរអានដាស់តឿនយើងឲ្យស្វែងរកជំនួយតាមរយៈវត្ថុ ដូចជាការអត់ធ្មត់និងស្ហ៍ឡាត់ជាដើម ដូចមានចែងនៅក្នុងអាយ៉ាស់៖

وَٱسۡتَعِينُواْ بِٱلصَّبۡرِ وَٱلصَّلَوٰةِۚ

*"ចូរពួកអ្នកស្វែងរកជំនួយតាមអំណត់ និងតាមនមស្ការប្រូជា*

*អល់ឡោះហ្ទ៍] (២:៤៥) ។"*[94]

ច្បាស់ណាស់ថា ភាពខ្ជាប់ខ្ជួននិងអំណត់ជាគុណសម្បត្តិមួយរបស់មនុស្ស ក៏ប៉ុន្តែគេជាស់តឿនយើងឲ្យស្វែងរកជំនួយតាមរយៈគុណសម្បត្តិនេះ ។ របៀបស្វែងរកជំនួយខាងលើនេះមិនមែនផ្ទុយពីការបែរទៅរកជំនួយពីអល់ឡោះហ្ទ៍عزوجلទេ ដូចមានចែងនៅក្នុងអាយ៉ាស់ថា៖

إِيَّاكَ نَعْبُدُ وَإِيَّاكَ نَسْتَعِينُ

*"ព្រះអង្គទេដែលអស់ទូលព្រះបង្គំជាខ្ញុំគោរពបូជា (ស្តាប់បង្គាប់) ព្រះអង្គទេដែលអស់ទូលព្រះបង្គំជាខ្ញុំអង្វរសូមនូវជំនួយ (១:៥) ។"*[95]

## សំណួរ ១៤ - តើសូមជំនួយពីអ្នកណាមួយស្មើនឹងធ្វើសក្ការៈអ្នកនោះ ស្មើនឹងអំពើហ៊ុនហាយ (ស្ហ៊ីរិក) ទេ ?

សំណួរនេះមកពីន័យត្រង់ ឬក្រៅរបស់អាយ៉ាស់គួរអានខ្លះ ដែលហាមបួងសួងអ្នកផ្សេងពីអល់ឡោះហ្ទ៍عزوجل ។

وَأَنَّ ٱلْمَسَٰجِدَ لِلَّهِ فَلَا تَدْعُواْ مَعَ ٱللَّهِ أَحَدًا

*"ម៉ាស់ឃ្ជិដ្ឋ (វិហារ) ទាំងឡាយជាកម្មសិទ្ធិរបស់អល់ឡោះហ្ទ៍ ដូច្នេះចូរពួកអ្នកកុំបួងសួងអ្នកណាផ្សេងគួបជាមួយអល់ឡោះហ្ទ៍ [ហើយចូរកុំយកពួករូបបដិមាមកចូលរួមផងឡើយ] (៧២:១៨) ។"*[96]

---

94 ស៊ូរ៉ោះត្ហ៍ អាល់-បាក៏រ៉ោះត្ហ៍ 2:45 ។

95 ស៊ូរ៉ោះត្ហ៍ អាល់-ហ្វាទីហ្ហាស់ 1:5 ។

96 ស៊ូរ៉ោះត្ហ៍ អាល់-ឃ្ជីន 72:18 ។



*បុរសទាំងពីរអង្គនេះនៅតែកាន់កាប់រដ្ឋាភិបាល ។"*[259]

ហាឌីស្ហទាំងពីរនេះជាភ័ស្តុតាងច្បាស់លាស់បញ្ជាក់ថា ការអះអាងរបស់ស្ហ៊ីអ៊ាស់ដែលថា "អ៊ីម៉ាំទាំងដប់ពីរអង្គ ដែលស្ហ៊ីអ៊ាស់តាមនោះជាអភិបាលពេញច្បាប់របស់មនុស្សទូទៅ អត់ពីព្រះសាស្តាصلى الله عليه وآله وسلمទៅ" នោះជាការអះអាងត្រឹមត្រូវ ។ នេះព្រោះតែ ក្នុងអ៊ីស្លាម យើងពុំឃើញមានស្តេចខ៉លិហ្វដប់ពីរអង្គណាដែលត្រឹមត្រូវទេ អត់ពីព្រះសាស្តាصلى الله عليه وآله وسلمទៅនោះ ដែលយកចិត្តទុកដាក់រឿងមុស្លីម ដែលយកចិត្តទុកដាក់អំពីសេចក្តីរុងរឿងនិងវិពោចនភាពរបស់អ៊ីស្លាម ក្រៅពីអ៊ីម៉ាំដប់ពីរអង្គដែលចេញមកពីព្រះរាជកុលដ្ឋានព្រះសាស្តាصلى الله عليه وآله وسلمនោះ ។

ក្រៅពីស្តេចខ៉លិហ្វបួនអង្គដែលគេស្គាល់ថាជា "ស្តេចខ៉លិហ្វដែលបានទទួលការដឹកនាំត្រឹមត្រូវ" (អាល់-ខ៉ុឡាហ្វាអ៊ អារ-រ៉ាស្ហ៊ីឌូន الخلفاء الراشدون) នោះ បណ្តាអ្នកកាន់ក្តាប់ឯទៀត គឺស្តេចខ៉លិហ្វត្រកូលអ៊ូម៉ៃយ៉ាស់និងអ៊ាបាស៊ីយ៉ាស់ ដែលល្បីល្បាញក្នុងប្រវត្តិសាស្ត្រថាជាបុគ្គលគ្មានសីលធម៌នោះ ជាបុគ្គលអាស្រូវសម្រាប់អ៊ីស្លាមនិងមុស្លីមទាំងអស់ ។

ដូច្នេះ អាស់លុល-បៃត៍ ដែលព្រះសាស្តាصلى الله عليه وآله وسلمបានណែនាំឲ្យស្គាល់ថាជាបុគ្គលស្មើនឹងគួរអាននិងជាអាជ្ញាធរគំរូ សម្រាប់មុស្លីមទាំងអស់ក្នុងលោកនោះ ជាអ៊ីម៉ាំដែលចេញមកពីព្រះរាជវង្សព្រះសាស្តាصلى الله عليه وآله وسلم ដែលជាអ្នកការពារព្រះស៊ុនណាស់ព្រះសាស្តាصلى الله عليه وآله وسلمអល់ឡោះហ្ទ៍عزوجل និងជាអ្នកទទួល

---

259 សូមមើលសៀវភៅរបស់លោក មុស្លីម *ស្ហ៍ហ៊ិះហ្ទ៍* (បោះពុម្ពនៅប្រទេសអេស៊ីបត៍) ដុំទី ៦ ទំព័រ ២ ។ សូមមើលសៀវភៅរបស់លោក អ៊ាប់ឌុល-ហ្វាមីដ្ឋ ស្ហ៊ីដ្ឋឌីគី *ស្ហ៍ហ៊ិះហ្ទ៍ មុស្លីម* (ច្បាប់ប្រែជាភាសាអង្លេស) ដុំទី ៣ ហាឌីស្ហលេខ ៤៤៧៨ ។

២. ព្រះសាស្ដាﷺ មិនត្រឹមតែរៀបរាប់អំពីគុណសម្បត្តិរបស់អាស់លុល-បៃត៍عليهم السلامប៉ុណ្ណោះទេ ព្រះអង្គﷺថែមទាំងបានប្រាប់ចំនួនទៀតផងថាមាន ១២ អង្គ ។

លោក មុស្លីម បានរាយការណ៍តមកពីលោក យ៉ាបៀរ អ៊ីបនូ សាមូរ៉ោះត៍ ថា៖

«سَمِعتُ رَسُولَ الله – صلّى الله عليه (وآله) وسلم – يقول: لايزال الاسلام عزيزاً إلى اثني عشر خليفةً. ثمّ قال كلمة لم أفْهمها، فقلت لأبي: ما قال؟ فقال كلّهم من قريش»

*"ខ្ញុំបានឮរ៉សូលុលឡោះហ៍ﷺមានព្រះវចនៈថា៖ "អ៊ីស្លាមនឹងគង់កិត្តិយសតាមរយៈស្ដេចខ៍លិហ្វាដប់ពីរអង្គ ។" ក្រោយមកព្រះអង្គﷺមានព្រះវចនៈតែខ្ញុំមិនយល់ ។ ដូច្នេះខ្ញុំបានសួរឪពុកខ្ញុំថា៖ "តើព្រះអង្គﷺថាអ្វី ?" គាត់បានឆ្លើយថាព្រះអង្គﷺមានព្រះវចនៈថា៖ "បុគ្គលទាំងអស់នោះនឹងចេញមកពីពួកគូរ៉យស៍ ។"*[258]

លោក មុស្លីម អ៊ីបនូ អាល់-ហាច្ច៉យ៉ាច្ច៉ បានរាយការណ៍មកពីព្រះសាស្ដាﷺអល់ឡោះហ៍عزّ وجلّដែរថា៖

«لايزال أمر النّاس ماضياً ما وليَهُم إثْنا عشر رجلاً»

*"បញ្ហារបស់ប្រជានុរាស្ត្រនឹងត្រូវដោះស្រាយបានយ៉ាងត្រឹមត្រូវ ដរាបណា*

[258] សូមមើលសៀវភៅរបស់លោក មុស្លីម *ស្វ៍ហ៊ិះហ៍* (បោះពុម្ពនៅប្រទេសអេស៊ីបត៍) ជុំទី ៦ ទំព័រ ២ ។ សូមមើលសៀវភៅរបស់លោក អាប់ឌុល-ហាមីដូ ស៊ីដូឌីគី *ស្វ៍ហ៊ិះហ៍ មុស្លីម* (ច្បាប់ប្រែជាភាសាអង់គ្លេស) ជុំទី ៣ ហាឌីស្សលេខ ៤៨៨០ ។



وَلَا تَدْعُ مِن دُونِ ٱللَّهِ مَا لَا يَنفَعُكَ وَلَا يَضُرُّكَ

*"ចូរអ្នកកុំបួងសួងផ្សេងពីអល់ឡោះហ៍ឡើយ នូវអ្វីដែលមិនអាចផ្ដល់គុណប្រយោជន៍និងទោសដល់អ្នកបានឡើយនោះ (១០:១០៦) ។"*[97]

ដោយយកអាយ៉ាស់ទាំងនេះជលេស មនុស្សមួយក្រុមជឿថាសូមជំនួយពីអ្នកផ្សេងនិងបួងសួងសន្តបុគ្គលដែលបានចូល ទិវង្គតហើយឬសច្ចបុគ្គលនោះ ជាអំពើហ៊ុនហាយនិងជាការធ្វើសក្ការៈបុគ្គលទាំងនោះ ។

## ចម្លើយ

ក្នុងបំណងបំភ្លឺចម្លើយតបសំណួរនេះ យើងត្រូវពន្យល់អត្ថន័យរបស់ពាក្យទាំងពីរគឺ៖ *ឌូអាអ៍* (បួងសួង) និង *អ៊ីបាដាស់* (សក្ការៈ) ។

ការពិត ពាក្យ "ឌូអាអ៍" មានន័យត្រង់ថា "សូម" និង "បួងសួង" រីឯពាក្យ "អ៊ីបាដាស់" មានន័យថា "សក្ការៈ" មិនគួរគិតថាពាក្យទាំងពីរនេះមានន័យដូចគ្នាទេ ។ បានសេចក្ដីថាពាក្យ "សូម" ឬ "បួងសួង" មិនអាចមានន័យថា "សក្ការៈ" ឡើយ ពីព្រោះ ៖

**មួយ** ៖ ពាក្យ "ដាក់វ៉ាស់ دَعْوة" (ក្លាយមកពី ឌូអាអ៍) មានប្រើនៅក្នុងអាយ៉ាស់គូរអានខ្លះតែមិនមែនក្នុងន័យ "អ៊ីបាដាស់" ទេ ។ ឧទាហរណ៍ ៖

قَالَ رَبِّ إِنِّى دَعَوْتُ قَوْمِى لَيْلًا وَنَهَارًا

*"គេ (គឺនុះហ៍) បានទូលថា៖ "ព្រះម្ចាស់អើយ ទូលព្រះបង្គំជាខ្ញុំបានហៅប្រជារាស្ត្រទូលព្រះបង្គំជាខ្ញុំទាំងយប់ ទាំងថ្ងៃ (៧១:៥) ។"*[98]

[97] ស៊ូរ៉ោះត៍ យូនូស 10:106 ។

[98] ស៊ូរ៉ោះត៍ នុះហ៍ 71:5 ។

តើយើងអាចនិយាយបានទេថានុះហ៍عليه السلامចង់មានន័យថា៖ "ទូលព្រះបង្គំជាខ្ញុំបាន *សក្ការៈ* ប្រជារាស្ត្រទូលព្រះបង្គំជាខ្ញុំទាំងយប់ ទាំងថ្ងៃ" ? ដូច្នេះគេមិនអាចនិយាយបានថា *ដ្វាក់វ៉ាស៊ុ* និង *អ៊ីបាដ្វាស៊ុ* មានន័យដូចគ្នាទេ ឬមិនអាចនិយាយបានទេថា ស្វែងរកជំនួយពីព្រះសាស្តាឬបុគ្គលត្រឹមត្រូវវាដូចសក្ការៈព្រះសាស្តាឬបុគ្គលត្រឹមត្រូវនោះដែរ ពីព្រោះ *ដ្វាក់វ៉ាស៊ុ* ឬ *នីដ្វាអ៊ុ* (ហៅ) មានន័យសាមញ្ញជាងសក្ការៈ ។

**ពីរ** ៖ *ឌូអ៊ាអ៊ុ* ក្នុងអាយ៉ាស៊ុនេះ មិនមានន័យថាបួងសួងសោះ តែមានន័យថាការសូមពិសេសដែលអាចជាផ្នែក ឬភាគមួយរបស់ពាក្យ "សក្ការៈ" ពីព្រោះ ក្រុមអាយ៉ាស៊ុទាំងនេះស្តីអំពីពួកសក្ការៈរូបបដិមាដែលយករូបចម្លាក់ជាព្រះ ។

ប្រាកដណាស់ ការគោរព ការបួងសួងនិងការអង្វរកររបស់ពួកសក្ការៈរូបដិមាឧទ្ទិសទៅឯរូបចម្លាក់ដែលពួកគេចាត់ទុកថា ជាម្ចាស់សិទ្ធិផ្ញើអន្តរាគមន៍ លើកលែងទោស ។ល។ ហើយទទួលស្គាល់ថាជាម្ចាស់ដាច់ខ្សែករបស់រឿងទាំងឡាយក្នុងលោកនេះនិងលោកមុខ ។ ច្បាស់ណាស់ថាក្នុងលក្ខខ័ណ្ឌបែបនេះ បែរទៅរកសត្វលោកទាំងនេះដើម្បីបួងសួងឬសូមអ្វីមួយត្រូវចាត់ទុកថាជាការសក្ការៈនិងជាការគោរពបូជាជាព្រះ ។

យើងសូមលើកមកនូវភ័ស្តុតាងច្បាស់ក្រឡែតមួយដែលបញ្ជាក់ថា ការអង្វរករ ឬការបួងសួងរបស់ពួកសក្ការៈ រូបបដិមាជាការសម្តែងនូវជំនឿពួកគេចំពោះរូបចម្លាក់ដែលជាព្រះរបស់ពួកគេ គឺអាយ៉ាស៊ុ៖

فَمَآ أَغۡنَتۡ عَنۡهُمۡ ءَالِهَتُهُمُ ٱلَّتِي يَدۡعُونَ مِن دُونِ ٱللَّهِ مِن شَيۡءٖ

*"ព្រះទាំងឡាយរបស់ពួកគេ ដែលពួកគេបានធ្វើសក្ការបូជាក្រៅពី*



សួរ ស៊ែដ្ធ័ អ៊ីបនូ អាល់-អារក្ខំ ថា៖ "អ្នកណាទៅព្រះរាជកុលដ្ឋានរបស់ព្រះសាស្តាﷺនោះ ? តើត្រូវរាប់បញ្ចូលព្រះមហេសីព្រះអង្គﷺក្នុងព្រះរាជកុលដ្ឋានព្រះអង្គﷺទេ ?" ស៊ែដ្ធ អ៊ីបនូ អាល់-គារក្ខំ បានតបថា៖

«لا وَايم الله إن المرأة تكون مع الرّجل العصر من الدّهر ثمّ يطلّقها فترجع إلى أبيها وقومها. أهل بيته أصله وعصبته الذّين حُرِمُوا الصّدقه بعده»

*"ទេ សូមស្បថចំពោះអល់ឡោះហ៍(عزّ وجلّ) ។ ស្ត្រីរស់នៅជាមួយបុរស (ជាស្វាមីភរិយា) មួយរយៈពេល បើបុរសលែងលះភរិយាខ្លួន ភរិយានោះនឹងត្រឡប់ទៅនៅជាមួយឪពុកនិងបងប្អូនខ្លួនវិញ ។ ព្រះរាជកុលដ្ឋានព្រះសាស្តាﷺ គឺបណ្តាអ្នកដែលជាប់នឹងព្រះអង្គﷺតាំងពីដើមកំណើតមកម្ល៉េះ (គឺដែលជាប់ឈាមជ័រជាមួយព្រះអង្គﷺ) ដែលជាប់វង្សត្រកូលជាមួយព្រះអង្គﷺ ដែលជាសាច់សាលោហិតរបស់ព្រះអង្គﷺ គឺបណ្តាបុគ្គលដែលពុំមានសិទ្ធិទទួលយកអំណោយទាន (គឺស្ការកាត់) អត់ពីព្រះអង្គﷺទៅ ។"*[257]

ហ្វាឌីស្ហបញ្ជាក់ច្បាស់ថា "បណ្តាកូនចៅរបស់ព្រះសាស្តាﷺ" ដែលចាំបាច់ត្រូវតាម ដូចចាំបាច់ត្រូវតាមគួរអានដែរនោះ មិនមានន័យថាបណ្តាមហេសីរបស់ព្រះអង្គﷺទេ តែព្រះរាជកុលដ្ឋានព្រះសាស្តាﷺ ដែលលើសពីមានសាច់សាលេហិតជាមួយព្រះសាស្តាﷺ ថែមទាំងមានទំនាក់ទំនងផ្នែកវិញ្ញាណជាមួយព្រះអង្គﷺ មានគុណសម្បត្តិនិងបារមីពិសេសពិសាលដើម្បីដាក់គូបនឹងព្រះគម្ពីរគួរអាន និងជាប្រភពនៃគំរូសម្រាប់មុស្លីមទាំងអស់ក្នុងលោកយកតម្រាប់តាម ។

---

[257] សូមមើលសៀវភៅ *ស្វ៏ហ៊ិះហ៍ មុស្លីម* (បោះពុម្ពនៅអេស៊ីបត៍) ដុំទី ៧ "បាប់ហ្វាដ្ធ៏អ៊ីល អ៊ាលី អ៊ីបនូ អាប៊ី ត៏លិប" ទំព័រ ១២៣ ។ សូមមើលសៀវភៅរបស់លោក អ៊ាប់ឌុល-ហាមីដ្ធ ស៊ីដ្ឋឌីគី *ស្វ៏ហ៊ិះហ៍ មុស្លីម* (ប្រែជាភាសាអង្គ្លេស) ដុំទី ៤ កណ្ឌ ៣១ ហាឌីស្ហ ៥៩២៣ ។

ហាឌីស្ហខាងលើនេះបញ្ជាក់ច្បាស់ថា ព្រះសាស្តាﷺបានអំពាវនាវមុស្លីមទាំងអស់ឲ្យតាមព្រះសន្តតិវង្សព្រះអង្គﷺ ដែលព្រះអង្គﷺចាត់ទុកជាអាជ្ញាធរគូបជាមួយព្រះគម្ពីរអល់ឡោះហ៍ﷻ សម្រាប់មនុស្សទាំងអស់ ក្នុងការយកតម្រាប់តាម អត់ពីព្រះអង្គﷺទៅនោះ ។ ព្រះអង្គﷺមានព្រះវចនៈច្បាស់លាស់ថា៖ "ព្រះគម្ពីរគួរអាននិងបណ្តាកូនចៅខ្ញុំនឹងមិនបែកពីគ្នាជាដាច់ខាត ។"

ព្រះរាជកុលដ្ឋានព្រះសាស្តាﷺ (អាស្ហ៍លុល-បៃត៍) ដែលព្រះសាស្តាﷺ អល់ឡោះហ៍ﷻបានណែនាំឲ្យស្គាល់គូបនឹងគួរអាននោះ ប្រកបដោយគុណសម្បត្តិអរិរុទ្ធ (អ៊ីសម៉ាស្ហ៍ عِصْمَة) តាំងពីកំណើត ហើយជាបុគ្គលដែលប្រកបដោយប្រភពនៃព្រះអភិញ្ញាអ៊ីស្លាម ។ បើពុំដូច្នេះទេ ព្រះរាជកុលដ្ឋានទាំងនេះនឹងបែកខ្ញែកពីព្រះគម្ពីរអល់ឡោះហ៍ﷻ (គួរអាន) ថ្វីដ្បិតតែព្រះសាស្តាﷺមានព្រះវចនៈថា៖ "គួរអាននិងបណ្តាកូនចៅខ្ញុំនឹងមិនបែកពីគ្នាជាដាច់ខាត លុះពួកគេបានមកជួបខ្ញុំនៅឯស្រះ[កៅស្ហ៊រ] ។"

ដោយហេតុនេះ ចាំបាច់ត្រូវស្គាល់អាស្ហ៍លុល-បៃត៍عليهم السلامនិងគុណសម្បត្តិដ៏ខ្ពង់ខ្ពស់របស់អស់បុគ្គលទាំងនេះយ៉ាងច្បាស់លាស់ ដែលជាលក្ខណៈពិសេសដាច់មុខរបស់អ៊ីម៉ាំស្ហ៊ីអ៊ាស្ហ៍ ដែលសុទ្ធតែជាព្រះរាជវង្សរបស់ព្រះសាស្តាﷺនោះ ។

ហាឌីស្ហដែលអស់លោកអ្នកប្រាជ្ញជំនាញខាងហាឌីស្ហបានប្រមូលនោះជាភ័ស្តុតាងបំភ្លឺរឿងនេះ គឺ៖

១. បន្ទាប់ពីបានលើកឡើងនូវហាឌីស្ហ "អាល់-ស្ហាក់ឡែន៍" លោក មុស្លីម អ៊ីបន្ង អាល់-ហាច់យ៉ាច់ មានប្រសាសន៍ថា៖ "យ៉ាស៊ីដ្ហ អ៊ីបន្ង ហៃយ៉ាំ បាន



*អល់ឡោះហ៍នោះ មិនមានប្រយោជន៍សម្រាប់ពួកគេទាល់តែសោះ... (១១:១០១) ។"*[99]

ហេតុដូច្នេះ អាយ៉ាស្ហ៍ខាងលើនេះមិនទាក់ទងនឹងសាច់រឿងយើងទេ ។ សាច់រឿងយើងទាក់ទងនឹងបាវម្នាក់ដែលបួងសួងបាវ[របស់អល់ឡោះហ៍ﷻ]ម្នាក់ទៀត ។ បាវមុនមិនចាត់ទុកបាវក្រោយនេះជាម្ចាស់និងជាព្រះទេ ហើយក៏មិនចាត់ទុកបាវក្រោយនេះ ជាម្ចាស់រឿងទាំងអស់ក្នុងលោកនេះ និងលោកមុខទេដែរ តែបាវនោះចាត់ទុកបាវក្រោយនេះជាបាវសច្ចៈដែលអល់ឡោះហ៍ﷻស្រឡាញ់ ដែលត្រូវជ្រើសរើសជាសាស្តាឬជាអ៊ីម៉ាំ (អគ្គប្រមុខដឹកនាំ) ហើយដែលអល់ឡោះហ៍ﷻបានសន្យាថានឹងទទួលការអង្វរករឲ្យបាវឯទៀតរបស់ព្រះអង្គﷻ ដូចព្រះអង្គﷻមានព្រះបន្ទូលថា៖

﴿ وَلَوْ أَنَّهُمْ إِذ ظَّلَمُوٓاْ أَنفُسَهُمْ جَآءُوكَ فَٱسْتَغْفَرُواْ ٱللَّهَ وَٱسْتَغْفَرَ لَهُمُ ٱلرَّسُولُ لَوَجَدُواْ ٱللَّهَ تَوَّابًا رَّحِيمًا ﴾

*"ប្រសិនបើពេលពួកគេ (គឺពួកបដិសេធសទ្ធា) ធ្វើខុសលើខ្លួនឯង ពួកគេបានមករកអ្នក សូមខមាទោសចំពោះអល់ឡោះហ៍ ហើយសាស្តាជួយសូមខមាទោស[ចំពោះអល់ឡោះហ៍]ឲ្យពួកគេ[ដែរ] ពួកគេនឹងឃើញថាអល់ឡោះហ៍ទទួលការស្តាយក្រោយ រាងចាល ព្រះអង្គមានព្រះមេត្តាករុណាប្រណី (៤:៦៤) ។"*[100]

**បី ៖** អាយ៉ាស្ហ៍ដែលយើងបានដកស្រង់មកនេះបញ្ជាក់ច្បាស់ថាសូមជំនួយពីគេម្នាក់ (ដ្ហាក់វ៉ាស្ហ៍) មិនគ្រាន់តែមានន័យថាសូមសេចក្តីត្រូវឬសូមឲ្យធ្វើអ្វីមួយនោះទេ តែជាការសូមដោយសទ្ធាសប់ចិត្ត" នៅក្នុងអាយ៉ាស្ហ៍

---

[99] ស្ហូរ៉ោះត៍ ហ៊្វដ្ហ 11:101 ។

[100] ស្ហូរ៉ោះត៍ អាន់-នីសាអ៍ 4:64 ។

មួយដែលពាក្យ "អ៊ិបាដាត់" នៅបន្ទាប់ពាក្យ "ដ្វាក៍វ៉ាត់" គឺៈ

وَقَالَ رَبُّكُمُ ٱدۡعُونِيٓ أَسۡتَجِبۡ لَكُمۡۚ إِنَّ ٱلَّذِينَ يَسۡتَكۡبِرُونَ عَنۡ عِبَادَتِي سَيَدۡخُلُونَ جَهَنَّمَ دَاخِرِينَ

*"ព្រះម្ចាស់ពួកអ្នកមានព្រះបន្ទូលថាៈ "ចូរពួកអ្នកបួងសួងអញ អញនឹងឆ្លើយតប[ការបួងសួងរបស់]ពួកអ្នក ។ ពិតមែន ជនទាំងឡាយណាដែលរអើមធ្វើសក្ការបូជាអញ ជនទាំងនោះនឹងចូលនរកយ៉ាងអាម៉ាស់មុខ (៤០:៦០) ។""*[101]

យើងសម្គាល់ឃើញថានៅដើមអាយ៉ាត់ ពាក្យ *"អាដ្វ៊ូនី"* (បួងសួងអញ) តាមពីក្រោយដោយពាក្យ "អ៊ិបាដាទី" (សក្ការបូជាអញ) ។ នេះបញ្ជាក់ថា "ដ្វាក៍វ៉ាត់" មានន័យថារបៀបសូមពិសេសមួយ ឬការស្វែងរកជំនួយពីបុគ្គលមួយចំនួនដែលគេទទួលស្គាល់ថាប្រកបដោយព្រះគុណសម្បត្តិ ។

# សេចក្ដីសរុប

យើងសរុបសេចក្ដី អាស្រ័យចំណុចទាំងបីខាងលើនេះថា អត្ថន័យសំខាន់របស់អាយ៉ាត់គួរអានទាំងនេះគឺ ហាមបួងសួងពួកគោរពរូបបដិមាដែលចាត់ទុករូបចម្លាក់ជាដៃគូរបស់អល់ឡោះហ៍ﷻ ឬដែលមានអំណាចធ្វើអន្តរាគមន៍ ហើយតាមរយៈអាកប្បកិរិយាឱនលំទោន រាបទាប ឬយំសោក ហាមស្វែងរកជំនួយ ការជួយគាំ និងការសូមឲ្យជួយធ្វើអន្តរាគមន៍ ឬហាមសូមឲ្យជួយបំពេញសេចក្ដីត្រូវការដោយជឿថា ពួកវាទាំងនោះជាព្រះដែលគេប្រគល់អំណាចបំពេញកិច្ចការរបស់អល់ឡោះហ៍ﷻ និងទង្វើខ្លះទាក់ទងនឹងលោកនេះនិងលោកមុខឲ្យ ។

---

[101] ស៊ូរ៉ោះត៍ ក៏ហ្វៀរ៍ ឬ អាល់-មុមីន 40:60 ។



*ពួកគេបានមកជួបខ្ញុំនៅឯប្រភពទឹកផុស[អាល់-កៅស្ញារ] ។"*[256]

ចាំបាច់ត្រូវរំលឹកថាហាឌីស្ញស្ដីអំពីរឿងនេះមានច្រើនណាស់ មិនអាចលើកយកបង្ហាញទាំងអស់បានទេ ។ សៃយីដ្វ មៀរ ហាមីដ្វ អាល់-ហ៊ូសៃន៍ បានប្រមូលបណ្ដាញរាយការណ៍បន្តរបស់ហាឌីស្ញទាំងនេះ នៅក្នុងសៀវភៅលោក *អ៊ូបាកូត់ អាល់-អាន់វ៉ារ (عبقات الأنوار)* ដែលមានប្រាំមួយក្បាល ។

ហាឌីស្ញទាំងនេះបញ្ជាក់ឲ្យឃើញច្បាស់ថា តាមអាស្ល់លុល-ប៉ៃត៍របស់ព្រះសាស្ដាﷺជាប់គួបនឹងព្រះគម្ពីរអល់ឡោះហ៍ﷻ និងព្រះស៊ុនណាត់ព្រះសាស្ដាﷺ ជាកាតព្វកិច្ចអ៊ីស្លាមចាំបាច់មួយ ។ មិនអើពើអំពីហាឌីស្ញ (គឺសម្ដី) របស់ព្រះរាជកុលដ្ឋានព្រះសាស្ដាﷺបណ្ដាលឲ្យដើរលើផ្លូវខុស នាំឲ្យវិនាស ។

អ្នកណាទៅជាបណ្ដាកូនចៅរបស់ព្រះសាស្ដាﷺ ដែលព្រះសាស្ដាﷺ អល់ឡោះហ៍ﷻដាក់បញ្ជាឲ្យយើងស្ដាប់បង្គាប់ជាចាំបាច់នោះ ? ដើម្បីបំភ្លឺចំណុចនេះ យើងត្រូវវិភាគអត្ថន័យរបស់ពាក្យ "បណ្ដាកូនចៅ (អ៊ិតរ៉ោះត៍) របស់ព្រះសាស្ដាﷺ" ដោយផ្អែកលើហាឌីស្ញ ។

# អ្នកណាគឺអាស្ល់លុល-ប៉ៃត៍របស់ព្រះសាស្ដាﷺ ?

---

[256] សូមមើលសៀវភៅ *មុសតាដ្រ៉ក់ អាល់-ហាគីម* ជុំទី ៣ ទំព័រ ១៤៨; *អាស្វ៊-ស្វ៉ាវ៉ាអ៊ិក្វ អាល់-មុះហ្វ៍រីក្វោះត៍ (الصواعق المحرقة)* ខណ្ឌ ១១ វគ្គ ១ ទំព័រ ១៤៩ និងសូមមើលសេចក្ដីរាយការណ៍ច្រើនទៀតនៅក្នុងសៀវភៅ *មុសណាដ្វ អាស់ម៉ាដ្វ អ៊ីបន្វ ហាន់បាល់* ជុំទី ៥ ទំព័រ ១៨២, ១៨៩, *កាន់ស៊ុ អាល់-អ៊ុមម៉ាល់* ជុំទី ១ "បាប់ អាល់-អ៊ិទីស្វ៉ំ ប៊ីល គីតាប វ៉ាស់-ស៊ុនណាត់" ទំព័រ ៤៤ ។

فحث على كتاب الله و رغّب فيه ثم قال: – وأهل بيتي، أذكركم الله في أهل بيتي، أذكركم الله في اهل بيتي، أذكركم الله في اهل بيتي»

*"ប្រជាពស្ត្រអើយ ខ្ញុំជាមនុស្សម្នាក់ ។ បន្តិចទៀតអ្នកនាំសាររបស់ព្រះម្ចាស់ ﷻ ខ្ញុំនឹងមកជួបខ្ញុំ ហើយខ្ញុំនឹងឆ្លើយតបអល់ឡោះហ្ទ៍ ﷻ ។ ខ្ញុំទុកឲ្យអស់លោកនូវវត្ថុសំខាន់ពីរ មួយគឺព្រះគម្ពីរអល់ឡោះហ្ទ៍ ﷻ ដែលមាននូវមគ៌ាទេសក៍ដឹកនាំនិងពន្លឺ ដូច្នេះចូរអស់លោកទទួលយកព្រះគម្ពីរអល់ឡោះហ្ទ៍ ﷻ ហើយកាន់ឲ្យជាប់ ។" ព្រះអង្គ ﷺ បានជាស់តឿនយើងឲ្យកាន់ព្រះគម្ពីរអល់ឡោះហ្ទ៍ ﷻ ឲ្យជាប់ រួចហើយព្រះអង្គ ﷺ មានព្រះវចនៈបីដងថា៖ "និងព្រះរាជកុលដ្ឋានខ្ញុំ ។ ចូរអស់លោកខ្លាចអល់ឡោះហ្ទ៍ ﷻ រឿងព្រះរាជកុលដ្ឋានខ្ញុំ ។ ចូរអស់លោកខ្លាចអល់ឡោះហ្ទ៍ ﷻ រឿងព្រះរាជកុលដ្ឋានខ្ញុំ ។ ចូរអស់លោកខ្លាចអល់ឡោះហ្ទ៍ ﷻ រឿងព្រះរាជកុលដ្ឋានខ្ញុំ ។"*[255]

៩. អស់លោកអ្នកប្រាជ្ញជំនាញខាងហាឌីស្ហបានរាយការណ៍ថា ព្រះសាស្តា ﷺ មានព្រះវចនៈថា៖

«إنّي تارِكٌ فيكم الثّقلين كتاب الله وأهل بيتي وإنّهما لن يفترقا حتى يردا عليّ الحْوضَ»

*"ខ្ញុំទុកឲ្យអស់លោកនូវវត្ថុមានតម្លៃពីរគឺ៖ ព្រះគម្ពីរអល់ឡោះហ្ទ៍ ﷻ (គួរអាន) និងព្រះរាជកុលដ្ឋានខ្ញុំ ។ ទាំងពីរនេះមិនបែកគ្នាជាដាច់ខាត លុះ*

[255] សូមមើលសៀវភៅ *ស្ហ៍ហ៊ិះហ្ទ៍ មុស្លីម* (បោះពុម្ពនៅអេស៊ីបត៍) ជុំទី ៧ "បាប់ ហ្វាឌ៏អ៊ីល អាលី អ៊ីបនូ អាប៊ី ត៏លិប" ទំព័រ ១២២-១២៣ ។ សូមមើលសៀវភៅ *ស្ហ៍ហ៊ិះហ្ទ៍ មុស្លីម* ជុំទី ៤ ទំព័រ ១៨០៣ ហាឌីស្ហ ២៤០៨ (បោះពុម្ពដោយ អាប់ដុល-បាគ្គី) ។ សូមមើលសៀវភៅរបស់លោក អាប់ឌុល-ហាមីដូ ស៊ីដ្ឋឌីគ្គី *ស្ហ៍ហ៊ិះហ្ទ៍ មុស្លីម* (ប្រែជាភាសាអង់គ្លេស) ជុំទី ៤ ហាឌីស្ហ ៥៩២០ ។



តើអាយ៉ាស់ទាំងនេះជាប់ទំនាក់ទំនងអ្វី ជាមួយការអង្វរករវិញ្ញាណបរិសុទ្ធ ដែលចាត់ទុកជាបារគំរូ ហើយដែលជាបារជាទីស្រឡាញ់និងថ្លៃថ្លារបស់អល់ឡោះហ្ទ៍ ﷻ នោះ ?

គួរអានចែងថា៖

وَأَنَّ ٱلْمَسَٰجِدَ لِلَّهِ فَلَا تَدْعُواْ مَعَ ٱللَّهِ أَحَدًا

*"ម៉ាស់យ៉ិដ្ឋ (វិហារ) ទាំងឡាយជាកម្មសិទ្ធិរបស់អល់ឡោះហ្ទ៍ ដូច្នេះចូរពួកអ្នកកុំបួងសួងអ្នកណាផ្សេងគួបជាមួយអល់ឡោះហ្ទ៍ [ហើយចូរកុំយកពួករូបបដិមាមកចូលរួមផងឡើយ] (៧២:១៨) ។"*[102]

អាយ៉ាស់នេះផ្តោតទៅលើវិធី ដែលពួកអារ៉ាប់មុនសម័យអ៊ីស្លាមប្រើសម្រាប់បួងសួងរូបចម្លាក់ វត្ថុនៅលើ អាកាស ទេវតានិងយ៉ិន ដែលពួកគេគោរពសក្ការៈ ។ អាយ៉ាស់នេះនិងអាយ៉ាស់ទាក់ទងឯទៀតពោលដល់ការបួងសួងមនុស្សឬវត្ថុដែលចាត់ទុកជាទីសក្ការៈ ។

ប្រាកដណាស់ សូមពីពួកទាំងនេះ ក្នុងជំនឿបែបនេះស្មើនឹងសក្ការៈពួកទាំងនេះ ។ តើអាយ៉ាស់ទាំងនេះមានអ្វីទាក់ទងនឹងទស្សនៈដែលថា សូមឲ្យមនុស្សម្នាក់បួងសួងឲ្យខ្លួន ដោយមិនចាត់ទុកមនុស្សនោះជាព្រះជាម្ចាស់ ឬជាអ្នកមានសមត្ថភាពគ្រប់គ្រងពិភពលោកទេ តែចាត់ទុកមនុស្សនោះជាបារស្មោះត្រង់ដែលអល់ឡោះហ្ទ៍ ﷻ ស្រឡាញ់ ?

អ្នកខ្លះអាចគិតថាគេអាចបួងសួងបុគ្គល ដែលមានសទ្ធាជ្រះថ្លាវិសេសវិសាលបានតែពេលបុគ្គលទាំងនេះនៅរស់ទេ តែធ្វើបែបនេះក្រោយពី

[102] ស៊ូរ៉ោះត៍ អាល់-យ៉ិន 72:18 ។

បុគ្គលទាំងនេះស្លាប់វាជាអំពើហ៊ុនហាយស្ហ៊ីរិក ។ យើងសូមតបថា៖

**មួយ** ៖ យើងសូមជំនួយពីវិញ្ញាណបរិសុទ្ធរបស់បារល្អ[របស់អល់ឡោះហ៍عز وجل] ដូចព្រះសាស្តានិងអ៊ីម៉ាំعليهم السلام ដូចអាយ៉ាស់គួរអានចែងនោះ ដែលនៅរស់និងកំពុងរស់នៅក្នុងបារស៊ាក់ (برزخ) មិនសូមពីសាកសពរបស់ព្រះអង្គعليهم السلامស្លាប់នៅក្នុងដីនោះទេ ។ វត្តមានយើងនៅក្បែរបូជនីយដ្ឋានរបស់ព្រះអង្គعليهم السلامនោះជួយពង្រឹងការទាក់ទង និងស្មារតីផ្តោតទៅឯវិញ្ញាណក្ខន្ធព្រះអង្គعليهم السلام ។ យោលតាមហ្ាឌីស្ហ នៅឯទីកន្លែងទាំងនេះគេធានាថាការបួងសួងទាំងឡាយនឹងបានសម្រេច ។

**ពីរ** ៖ អត្ថិភាពរបស់ព្រះអង្គعليهم السلام រស់ឬស្លាប់ មិនអាចជាលក្ខខ័ណ្ឌសម្រាប់វែកញែកឲ្យដឹងថាអ្វីដែលស្របតាមតៅហ៊ីដ្ហ អ្វីជាអំពើស្ហ៊ីរិកនោះបានទេ ។ តែសម្តីយើងទេដែលត្រូវវែកញែកថាវានៅក្នុងអំពើស្ហ៊ីរិក ឬសមស្របនឹងតៅហ៊ីដ្ហនោះ មិនមែនការអង្វរករទាំងនេះដែលបានសម្រេច ឬមិនបានសម្រេចនោះទេ ។

យើងណឹងបំភ្លឺរឿងនេះ (គឺរឿងសារៈសំខាន់ ឬមិនសំខាន់របស់ការបួងសួងប្រភេទនេះ) នៅពេលក្រោយ ។

## សំណួរ ១៥ - អ្វីទៅ "បាដ្វា (بدا)" ហេតុអ្វីជឿបាដ្វា ?

## ចម្លើយ

ក្នុងភាសាអារ៉ាប់ ពាក្យ *"បាដ្វា"* មានន័យត្រង់ថា "បាតុភូត" និង "ការលេចឡើង" ក្នុងភាសាអស់លោកអ្នកប្រាជ្ញស្ហ៊ីអ៊ុស្ហ់ ប្រើសម្រាប់ហៅការ



*បណ្តាកូនចៅរបស់ខ្ញុំ ព្រះរាជកុលដ្ឋានខ្ញុំ ។"*[253]

២. លោក តៀរមីស៊្ហី បានសរសេរនៅក្នុងសៀវភៅដដែលដែរថា៖

«قالَ رسُولُ اللهِ – صلّى الله عليه (وآله) وسلّم – إنِّيْ تارِكٌ فِيْكُمْ ما إنْ تَمَسّكْتُمْ بِهِ لَنْ تَضِلُّوا بَعْدِيْ أحَدُهُما أعظمُ مِنَ الآخر: كتاب الله حَبلٌ ممدودٌ من السَّماء إلى الأرض وعترتي أهل بَيتي ولن يفترقا حتّى يردا عليّ الحوض، فانظُرُوا كيف تخلفوني فيهما»

*"ព្រះសាស្តាصلى الله عليه وآله وسلمអល់ឡោះហ៍عز وجلមានព្រះវចនៈថា៖ "ខ្ញុំទុកឲ្យអស់លោកនូវវត្ថុសំខាន់ពីរ បើអស់លោកកាន់យកជាប់ អស់លោកនឹងមិនវង្វេងជាដាច់ខាត ។ មួយមានឧត្តមភាពលើសមួយទៀត គឺ៖ ព្រះគម្ពីរអល់ឡោះហ៍عز وجل ដែលជាខ្សែចងភ្ជាប់មេឃនិងដី មួយទៀតគឺបណ្តាកូនចៅខ្ញុំ ព្រះរាជកុលដ្ឋានខ្ញុំ ។ ទាំងពីរមិនបែកពីគ្នាជាដាច់ខាត រហូតដល់ពួកគេបានជួបខ្ញុំនៅឯស្ពាន[កៅស្ហារ] ។ ចូរអស់លោកប្រយ័តខ្លួនក្នុងការ ប្រព្រឹត្តចំពោះពួកគេ ពេលអត់ពីខ្ញុំទៅ ។"*[254]

៣. លោក មុស្លីម អ៊ីបនូ អាល់-ហ្ាជ្ជ៉ាជ្ជ (مسلم بن الحجاج) បានរាយការណ៍នៅក្នុងស្ហ៊ហ៊ិះហ៊្របស់លោក តមកពីព្រះសាស្តាصلى الله عليه وآله وسلمថា៖

«ألا أيها الناس، فانّما أَنا بشرٌ يوشك أن يأتي رسول ربّي فأجيب، وأنا تارك فيكم ثقلين: أولهما كتاب الله فيه الهدي والنور، فخذوا بكتاب الله واستمسكوا به –

[253] សូមមើលសៀវភៅ *ស្ហ៊ហ៊ិះហ៊្ តៀរមីស៊្ហី* (បោះពុម្ពនៅបៃរូត) "គីតាប អាល់-ម៉ាណាគ្វីប" "បាប់ ម៉ាណាគ្វីប អាស្ហ់ល៍ បៃត៍ អាន់-ណាប៊ី" ជុំទី ៥ ទំព័រ ៦៦២ ហ្ាឌីស្ហ ៣៧៨៦ ។

[254] សូមមើលសៀវភៅ *ស្ហ៊ហ៊ិះហ៊្ តៀរមីស៊្ហី* (បោះពុម្ពនៅបៃរូត) "គីតាប អាល់-ម៉ាណាគ្វីប" "បាប់ ម៉ាណាគ្វីប អាស្ហ់ល៍ បៃត៍ អាន់-ណាប៊ី" ជុំទី ៥ ទំព័រ ៦៦៣ ហ្ាឌីស្ហ ៣៧៨៨ ។

ហ្ហាឌីស្ទទាំងនេះបញ្ជាក់ឲ្យឃើញច្បាស់ថា ប្រភពរបស់ហ្ហាឌីស្ទអ៊ីមុាំស្ហ៊ីអាស់ គឺព្រះស៊ុនណាស់ព្រះសាស្ដាﷺតែម្ដង ។

## ២. ភ័ស្តុតាងបញ្ជាក់ថា ចាំបាច់ត្រូវតាមអាស់លុល-បៃត៍عليهم السلامរបស់ព្រះសាស្ដាﷺ ។

អស់លោកអ្នកប្រាជ្ញជំនាញខាងហ្ហាឌីស្ទ (មូហ្ហាដ្ឌ៉ីស្ទីន) ទាំងពីរម៉ាស់ហ្ហាប់ ស៊ុននីនិងស្ហ៊ីអាស់ បានរាយការណ៍ថាព្រះសាស្ដាﷺ អល់ឡោះហ្ទ៍عز وجلបានទុកឲ្យនូវមរតកដ៏មានតម្លៃពីរ ហើយថាព្រះអង្គﷺ បានផ្ដាំផ្ញើឲ្យ មុស្លីមគ្រប់រូបប្រកាន់យកមរតកទាំងពីរនេះឲ្យជាប់ដើម្បីនឹងមានសុខុមាលភាពនិងបាននៅលើមាគ៌ាល្អ នោះគឺ៖ ព្រះគម្ពីរអល់ឡោះហ្ទ៍عز وجلនិងព្រះរាជកុលដ្ឋានعليهم السلامព្រះអង្គﷺ (អាស់លុល-បៃត៍عليهم السلام) ។

យើងសូមលើកយកមកបង្ហាញជូននូវហ្ហាឌីស្ទទាំងនេះខ្លះ គឺ៖

១. លោក តៀរមីស៊ី បានរាយការណ៍នៅក្នុងស៊ូហ្ហ៊ិះហ្ហ៍របស់លោក តមកពីលោក យ៉ាបៀរ អ៊ីបនូ អាប់ឌុលឡោះហ្ទ៍ អាល់-អាន់ស៊ូរី ថាព្រះសាស្ដាﷺអល់ឡោះហ្ទ៍عز وجلមានព្រះវចនៈថា៖

«يا أيُّها النّاسُ إنِّي قَدْ تَرَكْتُ فِيْكُمْ ما إنْ أخَذْتُمْ بِه لَنْ تَضِلُّوا: كِتابَ اللهِ وَعِتْرَتي أهلَ بَيْتِي»

*"ប្រជារាស្ត្រអើយ ខ្ញុំទុកឲ្យអស់លោកនូវវត្ថុពីរ បើអស់លោកកាន់វត្ថុពីរនេះជាប់ អស់លោកនឹងមិនវង្វេងជាដាច់ខាត គឺ៖ ព្រះគម្ពីរអល់ឡោះហ្ទ៍عز وجلនិង*



ផ្លាស់ប្ដូរក្នុងដំណើរវាសនារបស់មនុស្ស ដែលបណ្ដាលមកពីអំពើល្អនិងត្រឹមត្រូវរបស់មនុស្សនោះ ។ បាដ្ហា (بدا) ជារឿងសំខាន់កំពូលមួយរបស់ធម្មសាលាស្ហ៊ីអាស់ថាមវន្ត ក្នុងការបកស្រាយប្រកាសនា (គឺក្នុងការរិះគិតអាយ៉ាស់គូរអាន) ហើយចេញមកពីការសមហេតុផល ។

តាមទស្សនៈគូរអាន មនុស្សមិនអាស្រ័យលើវាសនាខ្លួនយ៉ាងដាច់ស្រេចទេហើយនុះទេ ផ្ទុយទៅវិញ ផ្លូវទៅកាន់សុខុមាលភាពត្រូវបើកចំហសម្រាប់មនុស្ស បើមនុស្សត្រឡប់មកកាន់ផ្លូវល្អនិងប្រព្រឹត្តគប្បីវិញ មនុស្សនឹងអាចផ្លាស់ប្ដូរ គោលដៅអវសានរបស់ជីវិតខ្លួនបាន ។ គូរអានចង្អុលបង្ហាញការពិតនេះថា វាជាគោលការណ៍សាកលដូចត ទៅ៖

إِنَّ ٱللَّهَ لَا يُغَيِّرُ مَا بِقَوۡمٍ حَتَّىٰ يُغَيِّرُواْ مَا بِأَنفُسِهِمۡۗ

*"ពិតណាស់ អល់ឡោះហ្ទ៍មិនផ្លាស់ប្ដូរ[ស្ថានភាព]មនុស្សមុនពួកគេកែ[ស្ថានភាព]ខ្លួនពួកគេសិនទេ ។"*[103]

គូរអានថែងមួយកន្លែងទៀតថា៖

وَلَوۡ أَنَّ أَهۡلَ ٱلۡقُرَىٰٓ ءَامَنُواْ وَٱتَّقَوۡاْ لَفَتَحۡنَا عَلَيۡهِم بَرَكَٰتٖ مِّنَ ٱلسَّمَآءِ وَٱلۡأَرۡضِ

*"បើប្រជាជនស្រុកនោះមានសទ្ធា ខ្លាចក្រែងអល់ឡោះហ្ទ៍សិប់ចិត្ត យើងច្បាស់ជានឹងបើកមកលើ (គឺប្រទានឲ្យ) ពួកគេនូវពរជ័យសិរីសួស្ដីពីមេឃនិងផែនដី ។"*[104]

ទាក់ទងនឹងការផ្លាស់ប្ដូរវាសនារបស់ព្រះសាស្ដាយូនូសعليه السلام គូរអានថែងថា៖

---

[103] ស៊ូរ៉ោះត៍ អារ-រ៉ាក់ដ៍ 13:11 ។

[104] ស៊ូរ៉ោះត៍ អាល់-អាក់រ៉ហ្វា 7:96 ។

فَلَوْلَآ أَنَّهُۥ كَانَ مِنَ ٱلْمُسَبِّحِينَ ﴿١٤٣﴾ لَلَبِثَ فِى بَطْنِهِۦٓ إِلَىٰ يَوْمِ يُبْعَثُونَ ﴿١٤٤﴾

*"បើសិនជាគេមិនមែនជាម្នាក់ ក្នុងចំណោមអ្នកថ្វាយសេចក្តីស្ញើចសរសើរ [ចំពោះអល់ឡោះហ្ម៍]ទេនោះ គេប្រាកដជានៅក្នុងពោះវាហូតដល់ថ្ងៃមួយដែលពួកគេនឹងរស់ពីស្លាប់ឡើងវិញជាមិនខាន (៣៧:១៤៣-១៤៤) ។"*[105]

ដូច្នេះ អាយ៉ាស់ចុងក្រោយបញ្ជាក់ថាព្រះសាស្តាយូនូស(عليه السلام)នឹងនៅក្នុងពន្ធនាគារពិសេសនោះ (គឺក្នុងពោះត្រីបាឡែន) រហូតដល់ថ្ងៃរស់ពីស្លាប់វិញ (ថ្ងៃគីយ៉ាម៉ាត់) បើព្រះអង្គ(عليه السلام)ពុំបានប្រព្រឹត្តល្អទេ (គឺសក្ការ បូជាអល់ឡោះហ្ម៍(عز وجل)) នោះដែលជាលទ្ធផលក្នុងការផ្លាស់ប្តូរដំណើរវាសនានិងសន្តិសុខរបស់ព្រះអង្គ(عليه السلام) ។

ហាឌីស្ហ៍អ៊ីស្លាមក៏ទទួលស្គាល់ការពិតនេះដែរ ។ ទាក់ទងនឹងរឿងនេះ ព្រះសាស្តា(صلى الله عليه وآله وسلم)មានព្រះវចនៈថា៖

إن الرجل ليحرم الرزق بالذنب يصيبه ولا يردّ القدر إلا الدعاء ولا يزيد في العمر إلا البرّ.

*"ដោយសារបាបដែលខ្លួនបានធ្វើ បានជាមនុស្សត្រូវបាត់បង់គ្រឿងទ្រទ្រង់ជីវិត ។ ពុំមានអ្វីអាចផ្លាស់ប្តូរវាសនានិងកម្មវាសនារបស់មនុស្សបានទេ លើកលែងតែការអង្វរករ បួងសួង ។ ពុំមានអ្វីអាចធ្វើឲ្យមនុស្សមានអាយុវែងបានទេ លើកលែងតែទង្វើល្អ ។"*[106]

---

[105] សូរ៉ោះត៍ អាស្ស៍-ស្វ៍ហ្វាត 37:143-144 ។

[106] សូមមើលសៀវភៅ *មុសណាដ៍ អាស្ម៉ាដ៍ អ៊ីបនូ ហាន់បាល់* ដុំទី ៥ ទំព័រ ២៧៧ ។ សូមមើលសៀវភៅ *មុសតាដ្រ៉ក់ អាល់-ហាគីម* ដុំទី ១ ទំព័រ ៤៩៣ និងសេចក្តីថ្លែងការណ៍ស្រដៀងនេះដែរនៅក្នុង *អាត់-តាជ៍ អាល់-យ៉ាមិអ៍ លីល-អ៊ូស្វិល (التاج الجامع للأصول)* ដុំទី ៥ ទំព័រ ១១១ ។



ព្រះអង្គ(صلوات الله عليه والسلام)មានវចនៈដែរថា៖

«حديثي حديثُ أبي، وحديث أبي حديث جدّي، وحديث جدّي حديث الحسين، وحديث الحسين حديث الحسن، وحديث الحسن حديث اميرالمؤمنين، وحديث اميرالمؤمنين حديث رسول الله – صلّى الله عليه (وآله) وسلّم –، وحديث رسول الله قَولُ اللهِ عزَّوَجَلَّ»

*"សម្តីខ្ញុំគឺសម្តីព្រះបិតាខ្ញុំ សម្តីព្រះបិតាខ្ញុំគឺសម្តីព្រះអយ្យកោខ្ញុំ សម្តីព្រះអយ្យកោខ្ញុំគឺសម្តីរបស់អាល់-ហ៊ូសែន(صلوات الله عليه والسلام) សម្តីអាល់-ហ៊ូសែន(صلوات الله عليه والسلام)គឺសម្តីរបស់អាល់-ហាសាន់(صلوات الله عليه والسلام) សម្តីអាល់-ហាសាន់(صلوات الله عليه والسلام)គឺសម្តីព្រះរាជអគ្គមហាប្រមុខរបស់បណ្តាអ្នកមានសទ្ធាជ្រះថ្លា អាមីរុល-មុមីនីន(صلوات الله عليه والسلام) សម្តីអាមីរុល-មុមីនីន(صلوات الله عليه والسلام)គឺព្រះវចនៈព្រះសាស្តា(صلى الله عليه وآله وسلم)អល់ឡោះហ្ម៍(عز وجل) ព្រះវចនៈព្រះសាស្តា(صلى الله عليه وآله وسلم)អល់ឡោះហ្ម៍(عز وجل)មកពីអល់ឡោះហ្ម៍ ព្រះដ៏មហាខ្ពង់ខ្ពស់ ព្រះមហាថ្កុំថ្កើងឥតប្រៀបបាន ។"*[251]

២. អ៊ីមុាំ មូហាំម៉ាដ៍ អាល់-បាគៀរ(صلوات الله عليه والسلام) មានវចនៈប្រាប់យ៉ាប៊ៀរ [អ៊ីបនូអាប់ឌុលឡោះហ្ម៍ អាល់-អានស្វ៍រី ابر بن عبد الله الأنصاري] ថា៖

*"ព្រះបិតាខ្ញុំបានរាយការណ៍ប្រាប់ខ្ញុំ តមកពីព្រះសាស្តា(صلى الله عليه وآله وسلم)អល់ឡោះហ្ម៍(عز وجل) ដែលបានរាយការណ៍តមកពីយ៉ឺប្រ៉អ៊ីល(عليه السلام) ដែលបានរាយការណ៍តមកពីអល់ឡោះហ្ម៍(عز وجل) ហើយអ្វីដែលខ្ញុំរាយការណ៍នោះមកពីបណ្តាញព័ត៌មាននេះឯង ។"*[252]

---

[251] សូមមើលសៀវភៅ *យ៉ាមិអ៍ អាហាឌីស្ហ៍ អាស្ស៍-ស្ហីអ៊ាស្ស៍ (جامع أحاديث الشيعة)* ដុំទី ១ ទំព័រ ១២៧ ។

[252] សូមមើលសៀវភៅ *យ៉ាមិអ៍ អាហាឌីស្ហ៍ អាស្ស៍-ស្ហីអ៊ាស្ស៍ (جامع أحاديث الشيعة)* ដុំទី ១ ទំព័រ ១២៨ ។

ព្រះរាជនីតិក្រម (ច្បាប់ហ្វីកោ្ហះហ្វ៍) មកតាមរយៈព្រះសាស្តាﷺរបស់ព្រះអង្គعز وجل ។ យើងដឹងច្បាស់ថាព្រះសាស្តាﷺអល់ឡោះហ្វ៍عز وجلជាបុគ្គលតែមួយដែលទទួលវ៉ាហ៊ី (ការបើកឲ្យដឹងពីអល់ឡោះហ្វ៍عز وجل) និងព្រះរាជបញ្ញាផ្នែកសាសនាពីអល់ឡោះហ្វ៍عز وجل ហើយជាអ្នកចែកវាឲ្យមនុស្សទាំងអស់ ។

ច្បាស់ណាស់ថា ដែលស្ហ៊ីអាស្ហ់ចាត់ទុកហាឌីស្ហអាស្ហ់លុល-បៃត៍عليهم السلامជាប្រភពនៃនីតិក្រម (ច្បាប់ហ្វីកោ្ហះហ្វ៍) របស់ពួកគេនោះ មិនបានសេចក្តីថាពួកគេមិនត្រូវការហាឌីស្ហព្រះសាស្តាﷺនោះទេ ។ ផ្ទុយទៅវិញ ពួកគេជឿហាឌីស្ហព្រះរាជកុលដ្ឋានعليهم السلامព្រះសាស្តាﷺ ព្រោះហាឌីស្ហទាំងនេះបំភ្លឺអត្ថន័យហាឌីស្ហព្រះសាស្តាﷺអល់ឡោះហ្វ៍عز وجل ។

ហេតុដូច្នេះ អ៊ីម៉ាំអវិរុទ្ធស្ហ៊ីអាស្ហ់មិននិយាយតាមតែក្បាលចិត្តឯងទេ ។ សម្តីរបស់អ៊ីម៉ាំអវិរុទ្ធស្ហ៊ីអាស្ហ់សុទ្ធតែដូចសម្តីរបស់ព្រះសាសាដាﷺ ។

ដើម្បីបញ្ជាក់ទ្រឹស្តីនេះ យើងគប្បីលើកមកនូវសម្តីខ្លះរបស់ព្រះរាជកុលដ្ឋានعليهم السلامព្រះសាស្តា ។

១. អ៊ីម៉ាំអាស្ហ់-ស្ហ៍ឌិក្ហصلوات الله عليه والسلامបានឆ្លើយតបបុរសម្នាក់ ដែលបានសួរព្រះអង្គصلوات الله عليه والسلام ថា៖

«مهما أجبتك فيه بشئ فهو عن رسول الله – صلّى الله عليه (وآله) وسلّم –لسنا نقول برأينا من شئ»

*"ចម្លើយទាំងអស់ដែលខ្ញុំឆ្លើយតបលោកនោះ មកពីព្រះសាស្តាﷺអល់ឡោះហ្វ៍عز وجل យើងមិននិយាយអ្វីតាមតែចិត្តឯងទេ ។"*[250]

---

[250] សូមមើលសៀវភៅ *យ៉ាមិអ៍ អាហាឌីស្ហ អាស្ហ់-ស្ហ៊ីអាស្ហ់ (جامع أحاديث الشيعة)* ជុំទី ១ ទំព័រ ១២៩ ។



អាស្រ័យហាឌីស្ហនេះនិងហាឌីស្ហស្រដៀងនេះដែរ គេអាចវិនិច្ឆ័យបានថា ដោយសារតែមនុស្សសាងបាបនិងល្មើសបង្គាប់ មនុស្សត្រូវបាត់បង់គ្រឿងទ្រទ្រង់ជីវិត តែទង្វើគម្បីរបស់មនុស្សដូចជាការអង្វរករ បួងសួង ជាដើមអាចផ្លាស់ប្តូរដំណើរជោគវាសនាបាន ឯទង្វើល្អរបស់មនុស្សអាចធ្វើឲ្យជីវិតយឺនយូរបាន ។

## សរុបសេចក្តី

តើអាយ៉ាស្ហ់គួរអាននេះនិងហាឌីស្ហទាំងឡាយមានន័យថា មនុស្សអាស្រ័យទង្វើរបស់ខ្លួន អាចប្រព្រឹត្តលើជោគវាសនារបស់ខ្លួនបានឬ ?

ឬក៏ មិត្តរបស់អល់ឡោះហ្វ៍عز وجل ដូចជាព្រះសាស្តាឬអ៊ីម៉ាំعليهم السلامជាដើម បានប្រាប់អ្នកណាមួយថាបើអ្នកនោះនៅតែប្រព្រឹត្តខ្លួនបែបនោះដដែល អ្នកនោះនឹងជួបប្រទះជោគវាសនាដែលបានកំណត់រួចហើយ តែការកែប្រែការប្រព្រឹត្តខ្លួននឹងធ្វើឲ្យជោគវាសនាអ្នកនោះអាចផ្លាស់ប្តូរបាន ។

ការពិតនេះដែលហូរចេញមកពីព្រះប្រកាសនា (គឺមកពីសម្តីអល់ឡោះហ្វ៍عز وجل) និងស៊ុនណាស្ហ់ព្រះសាស្តាﷺ ហើយដែលជាលទ្ធផលនៃការស្រាវជ្រាវត្រឹមត្រូវនោះ ហៅថា *បាដ្ហា* ក្នុងភាសាអ្នកប្រាជ្ញស្ហ៊ីអាស្ហ់ ។

ចាំបាច់ត្រូវបញ្ជាក់ថា ទស្សនៈ *បាដ្ហា* មិនមាននៅតែក្នុងប៉ែកស្ហ៊ីអាស្ហ់ដាច់មុខទេ នៅក្នុងសំណេររបស់អាស្ហ់លុល-ស៊ុនណាស្ហ់និងនៅក្នុងសម្តីរបស់ព្រះសាស្តាﷺក៏យើងឃើញមានទស្សនៈនេះដែរ ។ ឧទាហរណ៍ ព្រះសាស្តាﷺបានប្រើពាក្យ *បាដ្ហា* ក្នុងហាឌីស្ហខាងក្រោមនេះ គឺ៖

"بَدَا لله عز وجلَّ أن يَبْتَلِيَهم."

*"អល់ឡោះហុ៍عز وجلគិតនឹងល្បងពិសោធន៍ពួកគេ ។"*[107]

ចាំបាច់ត្រូវរំលឹកថារឿង *បាដ្ញា* មិនពាក់ព័ន្ធនឹងការផ្លាស់ប្ដូរក្នុងព្រះអភិញ្ញាទេ ព្រោះតាំងពីដើមម្ល៉េះ អល់ឡោះហុ៍عز وجلទ្រង់ញាណដំណើរធម្មតានៃការប្រព្រឹត្តរបស់មនុស្ស និងឥទ្ធិពលរបស់ទង្វើដែលធ្វើឲ្យដំណើរនេះប្រែប្រួលហើយដែលជាដើមហេតុរបស់ *បាដ្ញា* ។

អល់ឡោះហុ៍عز وجلផ្ទាល់ថែងអំពីទស្សនៈនេះនៅក្នុងគួរអានថា៖

يَمْحُواْ ٱللَّهُ مَا يَشَآءُ وَيُثْبِتُ ۖ وَعِندَهُۥٓ أُمُّ ٱلْكِتَـٰبِ

*"អល់ឡោះហុ៍លុបចោល (គឺឈប់ឲ្យប្រើទៀត) ព្រះអង្គបង្កើតអ្វីមួយស្រេចតែលើព្រះអង្គ ។ ព្រះមេគម្ពីរនៅឯព្រះអង្គ (គម្ពីរដើម គឺព្រះគម្ពីរអភិរក្ស) ។"*[108]

ដូច្នេះ ក្នុងពេលបើកឲ្យដឹង *បាដ្ញា* អល់ឡោះហុ៍عز وجلបើកឲ្យយើងឃើញការពិតមួយដែលត្រូវកំណត់ហើយនៅឯព្រះអង្គعز وجل តាំងពីយូរមកហើយ ។ អ៊ីមុាំអាស្-ស្វ៉ឌិក្វصلوات الله عليه والسلامមានវចនៈថា៖

"ما بدا الله في شئ إلا كان في علمه قبل أن يبدو له."

*"សម្រាប់អល់ឡោះហុ៍عز وجل មិនដែលមានពេលណាមួយដែលបាដ្ញាកើត*

[107] សូមមើលសៀវភៅរបស់លោក ម៉ាច់ដ្ឌ៍ អាល់-ឌីន អាល់-មូបារ៉ក់ អ៊ីបនូ មូហ៊ាំម៉ាដ្ឋ អាល់-ឃ្យ៉ូសរី (مجد الدين المبارك بن محمد الجزري) *អាន់-នីហ្វាយ៉ាស្ហ ហ៊្វី ក៊្ហរីប អាល់-ហ៊ាឌីស្ហ វ៉ាល់-អាស្ហារ (النِهَايَة فِي غَرِيب الحَدِيث والأَثَر)* ជុំទី ១ ទំព័រ ១០៩ ។

[108] ស្ហូរ៉ោះត៍ អារ-រ៉ក់ដ្ឌ៍ 13:39 ។



*មូហ៊ាំម៉ាដ្ឋصلى الله عليه وآله وسلم អ្នកនោះជាកាហ៊្វៀរ ។"*[249]

សរឲ្យឃើញថាស្ហ៊ីអាស្ហគោរពស៊ុនណាស្ហព្រះសាស្ដាصلى الله عليه وآله وسلم លើសម៉ាស្ហហ្វាប់មុស្លីមឯទៀត និងសរឲ្យឃើញថាបណ្ដាអ្នកដែលចោទប្រកាន់ស្ហ៊ីអាស្ហថាមិនស្គាល់ និងមិនយកចិត្តទុកដាក់នឹងព្រះស៊ុនណាស្ហព្រះសាស្ដាصلى الله عليه وآله وسلمទេនោះ ជាបណ្ដាអ្នកដែលនិយាយខុសស្រឡះនិងគ្មានហេតុផល ។

ដើម្បីបំភ្លឺមតិស្ហ៊ីអាស្ហ ទាក់ទងនឹងហាឌីស្ហរបស់ព្រះរាជកុលដ្ឋានعليهم السلامព្រះសាស្ដាصلى الله عليه وآله وسلم យើងត្រូវវិភាគពីរចំណុច គឺ៖

១. ខ្លឹមសារហាឌីស្ហរបស់អ៊ីមុាំអវិរុទ្ធعليهم السلام

២. ភ័ស្តុតាងបញ្ជាក់ថា ចាំបាច់ត្រូវតាមអាស្ហលុល-បៃត៍عليهم السلامរបស់ព្រះសាស្ដាصلى الله عليه وآله وسلم ។

បានទទួលភ័ស្តុតាងប្រាកដប្រជាហើយ យើងនឹងពិនិត្យប្រធានបទទាំងពីរនេះដោយសង្ខេប គឺ៖

## ១) ខ្លឹមសារហាឌីស្ហ របស់ព្រះរាជកុលដ្ឋានعليهم السلامព្រះសាស្ដាصلى الله عليه وآله وسلم

យោលតាមមតិស្ហ៊ីអាស្ហ មានតែព្រះម្ចាស់ពិភពទាំងពួងعز وجلទេដែលមានសិទ្ធិបង្កើតច្បាប់សម្រាប់មនុស្សជាតិ ។ អល់ឡោះហុ៍عز وجلប្រទានវិន័យនិង

[249] សូមមើលសៀវភៅ *អ៊ូស្ហ៊ូល អាល់-កាហ៊្វី (صول الكافي)* ជុំទី ១ "គីតាប អាល់-ហ្វាដ្ឋល៍ អាល់-អ៊ីលម៍" "បាប់ អាល់-អាក៏ដ្ឋ៍ ប៊ីស-ស៊ុនណាស្ហ វ៉ា ស្ហាវ៉ាហ៊ីដ្ឋ អាល់-គីតាប" ហាឌីស្ហ ៦ ។

*សម្តីនោះសក្តិសមនឹងអ្នកពាយការណ៍សម្តីនោះ ។"*[247]

ស្រដៀងនេះដែរ អ៊ីម៉ាំអាល់-បាគៀរ صلوات الله عليه والسلام ចាត់ទុកការពឹងផ្អែកលើព្រះស៊ុនណាស្ន៎ព្រះសាស្តា صلى الله عليه وآله وسلم ជាលក្ខខណ្ឌសំខាន់បំផុតមួយសម្រាប់អស់លោកអ្នកនីតិសាស្ត្រ (ហ្វ៊ូក៊ហ្វា គឺអ្នកជំនាញច្បាប់អ៊ីស្លាម) ព្រះអង្គ صلوات الله عليه والسلام មានវចនៈថា៖

«إنّ الفقيه حقّ الفقيه الزّاهد في الدّنيا، الرّاغب في الآخرة، المتمسّك بسنّة النّبيّ – صلّى الله عليه (وآله) وسلّم»

*"អ្នកនីតិសាស្ត្រពិតប្រាកដគឺអ្នកដែលមិនអើពើលោកនេះទេ ដែលស្វែងរកលោកមុខ ដែលតោងព្រះស៊ុនណាស្ន៎ព្រះសាស្តា صلى الله عليه وآله وسلم ជាប់ ។"*[248]

មេដឹកនាំស៊ីអ៊ាស្ន៎ល្បីៗ មានឧត្តមភាទេពកោសល្យផ្នែកស៊ុនណាស្ន៎បំផុតដល់ថ្នាក់បដិសេធអ្វីដែលផ្ទុយពីព្រះគម្ពីរអល់ឡោះហ្ន៎ عز وجل និងព្រះស៊ុនណាស្ន៎ព្រះសាស្តា صلى الله عليه وآله وسلم ហើយចាត់ទុកជាបទបដិសេធសាសនា (គុហ្វរ៍ كفر) ។ អ៊ីម៉ាំអាស្ស៍-ស្វ៍ឌិក្ស صلوات الله عليه والسلام មានវចនៈអំពីរឿងនេះថា៖

«مَنْ خالَفَ كِتابَ اللهِ وَسُنَّةَ مُحَمَّدٍ – صلّى الله عليه وآله وسلّم فَقَدْ كَفَرَ»

*"អ្នកណាប្រឆាំងព្រះគម្ពីរអល់ឡោះហ្ន៎ عز وجل និងព្រះស៊ុនណាស្ន៎របស់*

[247] សូមមើលសៀវភៅ *អ៊ូស្វ៊ូល អាល់-កាហ្វី (صول الكافي)* ជុំទី ១ "គីតាប អាល់-ហ្វាដ្ន៎ល៍ អាល់-អ៊ីលម៍" "បាប់ អាល់-អាក់ដ្ន៍ ប៊ីស-ស៊ុនណាស្ន៎ វ៉ា ស្វាវ៉ាហ៊ីដ អាល់-គីតាប" ហាឌីស្ស ២ ។

[248] សូមមើលសៀវភៅ *អ៊ូស្វ៊ូល អាល់-កាហ្វី (صول الكافي)* ជុំទី ១ "គីតាប អាល់-ហ្វាដ្ន៎ល៍ អាល់-អ៊ីលម៍" "បាប់ អាល់-អាក់ដ្ន៍ ប៊ីស-ស៊ុនណាស្ន៎ វ៉ា ស្វាវ៉ាហ៊ីដ អាល់-គីតាប" ហាឌីស្ស ៨ ។



*ឡើងដោយព្រះអង្គ عز وجل មិនដឹងវាតាំងពីយូរមកហើយនោះឡើយ ។"*[109]

## ទស្សនៈវិជ្ជារបស់បាដ្វា

ប្រាកដណាស់ ប្រសិនបើមនុស្សដឹងថាអាចកែប្រែជោគវាសនាខ្លួនបាន មនុស្សនឹងព្យាយាមសាងអនាគតឲ្យប្រសើរជាងមុន ហើយនឹងខិតខំដឹកនាំជីវិតទៅរកផ្លូវល្អដោយការប្រព្រឹត្តល្អ និងការព្យាយាមប្រសើរជាងមុន ។

អាចនិយាយម្យ៉ាងទៀតបានថា ដូចការស្នាលារកំហុស (តៅបាស្ន៎) និងការធ្វើអន្តរាគមន៍ (ស្វាហ្វាអ៊ាស្ន៎) ដែលជួយសង្គ្រោះមនុស្សឲ្យចាកផុតសេចក្តីអស់សង្ឃឹមនិងការធុញទ្រាន់ក្នុងជីវិតនោះ ចំណែកឯសច្ចភាពរបស់បាដ្វាធ្វើឲ្យមានសេចក្តីរីករាយ ហើយធ្វើឲ្យមានសុទិដ្ឋិនិយមចំពោះអនាគត ។ អាស្រ័យទស្សនវិស័យនេះ មនុស្សដឹងថា តាមរយៈព្រះបញ្ញត្តិរបស់អល់ឡោះហ្ន៎ عز وجل នោះ ខ្លួនអាចផ្លាស់ប្តូរជោគវាសនារបស់ខ្លួន ហើយអាចឈានទៅរកអនាគតល្អប្រសើរជាងមុន និងជោគវាសនារុងរឿងបាន ។

## សំណួរ ១៦ - តើស៊ីអ៊ាស្ន៎ជឿថាគួរអានត្រូវកែ (តាស្ន៍រិហ្វ تحريف) ឬ ?

## ចម្លើយ

[109] សូមមើលសៀវភៅ *អ៊ូស្វ៊ូល អាល់-កាហ្វី* ជុំទី ១ "គីតាប អាត់-តៅហ៊ីដ" "បាប់ អាល់-បាដ្វា" ហាឌីស្ស ៩ ។

អ្នកប្រាជ្ញស៊ីអ៊ុស្ទំល្បីៗ បដិសេធការអាចមានការបំប្លែងគួរអាន ។ គួរអាន ដែលនៅក្នុងដៃយើងសព្វថ្ងៃនេះ ជាព្រះគម្ពីរដែលត្រូវបើកឲ្យព្រះសាស្តាﷺដឹង ដោយមិនត្រូវបន្ថែម មិនត្រូវកាត់ចោលទេ ។ ដើម្បីបំភ្លឺរឿងនេះ យើងសូមបង្ហាញភ័ស្តុតាងជាក់ស្តែងមួយចំនួន ។

១. ព្រះម្ចាស់ភពផែនដែនចក្រវាលបានធានា ការថែរក្សានិងការអភិរក្ស ព្រះមហាគម្ពីរពីពួកមុស្លីម ថា៖

إِنَّا نَحْنُ نَزَّلْنَا ٱلذِّكْرَ وَإِنَّا لَهُۥ لَحَٰفِظُونَ

*"យើងជាអ្នកប្រទានចុះមក (គឺបើកឲ្យដឹង) នូវអ្នករំឭក (គឺគួរអាន) ហើយ យើងជាអ្នកអភិរក្សវា ។"*[110]

ប្រាកដណាស់ថាស៊ីអ៊ុស្ទំទាំងអស់ក្នុងលោក ដែលយកគួរអានជាមាគ៌ា គំនិតនិងជាឥរិយាបថនោះ ជឿអាយ៉ាស្ទំគួរអានពិសិដ្ឋ ជឿជាក់លើព្រះ រាជសារគួរអាននោះ និងលើការអភិរក្សព្រះមហាគម្ពីររបស់អល់ឡោះហ្ទ៍ عزوجل ។

២. អ៊ីម៉ាំអាលី صلوات الله عليه والسلام អ៊ីម៉ាំទីមួយរបស់ស៊ីអ៊ុស្ទំដែលជាសាវកជានិច្ចរបស់ព្រះសាស្តាﷺ ហើយអ្នកកត់ត្រាព្រះប្រកាសនា (គឺអ្នកសរសេរគួរអាន ទុក) បានអំពាវនាវហៅមនុស្សមករកគួរអានច្រើនលើកថា៖

«واعلموا أنّ هذا القرآن هو النّاصح الّذي لايغشّ والهادي الّذي لايضلّ»

*"ចូរអស់លោកដឹងថាគួរអាននេះឲ្យដំបូន្មាន ដោយមិនធ្វើឲ្យខុសជាដាច់ខាត ហើយដឹកនាំដោយមិនធ្វើឲ្យវង្វេងជាដាច់ខាត ។"*[111]

[110] ស៊ូរ៉ោះត៍ អាល់-ហ៊ីជ្រ៍ 15:9 ។

[111] សូមមើល *ណាស្ទ៍យ៉ាល់-បាឡាកោត៍ (نهج البلاغة)* (បោះពុម្ពផ្សាយដោយ ស៊ុបហ៊ី អាស្ទ-ស្វ៍លិះហ៊្ទ៍) ឃុត្ទបាស្ទំ ១៧៦ ។



ស៊ីអ៊ុស្ទំចាត់ទុកព្រះគម្ពីរអ៊ីស្លាម ជាប្រភពនៃច្បាប់សាសនាដែលប្រាកដ ប្រជាបំផុត ។

២) ព្រះស៊ុនណាស្ទំ - ដែលជាព្រះវចនៈ ជាទង្វើរបស់ព្រះសាស្តាﷺ អល់ឡោះហ្ទ៍ عزوجل និងជាអ្វីដែលព្រះអង្គﷺចាត់ទុកថាត្រឹមត្រូវនោះ - ជា ប្រភពច្បាប់នីតិសាស្រ្ត (គឺហ្វីកោ្ទះហ្ទ៍) ស៊ីអ៊ុស្ទំទីពីរ ។ អ៊ីម៉ាំអាស្ទ៍លុល-បៃត៍عليهم السلامទាំងអស់របស់ព្រះសាស្តាﷺ យ៉ាងដាច់ខាត ត្រូវចាត់ទុកជាអ្នក ផ្សាយបន្តព្រះស៊ុនណាស្ទំរបស់ព្រះសាស្តាﷺ និងជាអ្នកទទួលព្រះ អភិញ្ញារបស់ព្រះសាស្តាﷺ ។
តែស៊ីអ៊ុស្ទំព្រមទទួលស្គាល់ហាឌីស្ទព្រះសាស្តាﷺ ដែលបានមកពីអស់ បុគ្គលជាទីទុកចិត្ត ក្រៅពីអ៊ីម៉ាំعليهم السلامផងដែរ ។

ចាំបាច់ត្រូវពិនិត្យភ័ស្តុតាងដែលបញ្ជាក់ថា ត្រូវតែពឹងផ្អែកលើព្រះ ស៊ុនណាស្ទំព្រះសាស្តាﷺ ។

អ៊ីម៉ាំស៊ីអ៊ុស្ទំណែនាំឲ្យបក្សពួកព្រះអង្គعليهم السلام តោងព្រះស៊ុនណាស្ទំព្រះ សាស្តាﷺនិងព្រះគម្ពីរឲ្យជាប់ ហើយព្រះអង្គعليهم السلامឲ្យតម្លៃទៅលើព្រះគម្ពីរ អល់ឡោះហ្ទ៍និងព្រះស៊ុនណាស្ទំគូបគ្នា ។ អ៊ីម៉ាំអាស្ទ-ស្វ៍ឌិក្ទ صلوات الله عليه والسلام មានព្រះ វចនៈថា៖

«إذا وَرَد عليكم حديثٌ فوجدتم له شاهداً من كتاب الله أومن قول رسول الله – صلّى الله عليه (وآله) وسلّم – وإلا فالّذي جاءكم به اولى به»

*"រាល់ពេលដែលអស់លោកបានឮសម្តីណាមួយ បើអស់លោកឃើញថា សម្តីនោះសមស្របនឹងព្រះគម្ពីរអល់ឡោះហ្ទ៍ عزوجل និងព្រះវចនៈរបស់ព្រះ សាស្តាﷺអល់ឡោះហ្ទ៍ عزوجل ចូរអស់លោកទទួលយកសម្តីនោះ ពុំនោះទេ*

អល់ឡោះហ៍ عزوجل ។ អស់អ៊ីម៉ាំស្ហ៊ីអ៊ុស្ទបានបង្ហាញព្រះគម្ពីរអ៊ីស្លាមជាគំរូសម្រាប់យកតម្រាប់តាម ដែលខ្ពង់ខ្ពស់បំផុតនៃព្រះរាជច្បាប់របស់អល់ឡោះហ៍ عزوجل ហើយយល់ឃើញថាមតិនីមួយៗត្រូវតែប្រៀបធៀបនឹងគួរអាន គេនឹងទទួលយកមតិនោះបើសមស្របនឹងគួរអាន ពុំនោះទេត្រូវបដិសេធចោល ។

អ៊ីម៉ាំស្ហ៊ីអ៊ុស្ទទី ៦ អ៊ីម៉ាំ អាស្ទ-ស្ទឌិក صلوات الله عليه والسلام មានព្រះវចនៈអំពីរឿងនេះថា៖

«وكُلّ حديثٍ لايوافق كتاب الله فهو زخرف»

*"សម្ដីណាដែលមិនសមស្របនឹងព្រះគម្ពីរអល់ឡោះហ៍ عزوجل ទេ សម្ដីនោះពុំមានតម្លៃទេ ។"*[245]

អ៊ីម៉ាំ អាស្ទ-ស្ទឌិក صلوات الله عليه والسلام មានព្រះវចនៈតមកពីព្រះសាស្ដា صلى الله عليه وآله وسلم ដែរថា៖

«أيّها النّاس ما جاءكم عنّي يوافق كتاب الله فأنا قلته وما جاءكم يخالف كتاب الله فلم أقلّه»

*"ប្រជារាស្ត្រអើយ ពេលណាអស់លោកបានឮសម្ដីដែលគេថាជាសម្ដីខ្ញុំដែលសមស្របនឹងព្រះគម្ពីរអល់ឡោះហ៍ عزوجل វាជាសម្ដីខ្ញុំមែន ពុំនោះទេវាពុំមែនសម្ដីខ្ញុំទេ ។"*[246]

ហាឌីស្ទទាំងពីរនេះបង្ហាញឲ្យឃើញយ៉ាងច្បាស់ក្រឡែតថា អស់មេដឹកនាំ

[245] សូមមើលសៀវភៅ *អ៊ូស្ហ៊ូល អាល់-កាហ្វី (صول الكافي)* ជុំទី ១ "គីតាប អាល់-ហ្វាដ្ហ៍ល៍ អាល់-អ៊ិលម៍" "បាប់ អាល់-អាក់ហ្ស៍ ប៊ីស-ស៊ុនណាស្ទ វ៉ា ស្ហាវ៉ាហ៊ីដ្ឌ អាល់-គីតាប" ហាឌីស្ទ ៣ ។

[246] សូមមើលសៀវភៅ *អ៊ូស្ហ៊ូល អាល់-កាហ្វី (صول الكافي)* ជុំទី ១ "គីតាប អាល់-ហ្វាដ្ហ៍ល៍ អាល់-អ៊ិលម៍" "បាប់ អាល់-អាក់ហ្ស៍ ប៊ីស-ស៊ុនណាស្ទ វ៉ា ស្ហាវ៉ាហ៊ីដ្ឌ អាល់-គីតាប" ហាឌីស្ទ ៥ ។



«اِنَّ اللهَ سُبْحانَهُ لَمْ يَعِظْ أحَداً بِمِثْلِ هَذَا الْقُرآنِ فَإنَّهُ حَبْلُ اللهِ الْمَتِيْنُ وَسَبَبُهُ الْمُبِيْنُ. »

*"អល់ឡោះហ៍ជាទីគោរពសក្ការៈ មិនដែលជម្រុញអ្នកណាមួយទៅរកអ្វីមួយដូចព្រះអង្គ عزوجل បានជម្រុញទៅរកគួរអាននោះឡើយ ដែលជាខ្សែនិងជាចំណងជាក់ស្ដែងរបស់ព្រះអង្គ عزوجل ។"*[112]

«ثم أنزل عليه الكتاب نوراً تطفأ مصابيحهن وسراجاً لايخبوا توقّده. ومنهاجاً لايضلّ نهجه... وفرقاناً لايخمد برهانه »

*"អល់ឡោះហ៍ عزوجل បានបញ្ជូនមកនូវព្រះគម្ពីរ ដែលជាពន្លឺឥតអវសាន ជាចង្កៀងដែលមិនរលត់ជាដាច់ខាត ជាផ្លូវដែលមិនធ្វើឲ្យអ្នកតាមព្រះគម្ពីរនោះវង្វេងជាដាច់ខាត ហើយដែលវែកការពិតចេញពីការវង្វេងដោយមិនធ្វើឲ្យស្ពឹកជាដាច់ខាត ។"*[113]

ពាក្យពេជន៍ត្រចះត្រចង់ទាំងនេះរបស់អ៊ីម៉ាំទីមួយ صلوات الله عليه والسلام របស់ស្ហ៊ីអ៊ុស្ទសឲ្យឃើញច្បាស់ថា ព្រះមហាគម្ពីរគួរអានជារស្មីត្រចះត្រចង់ដែលគង់នៅរហូតនៅលើផ្លូវអ្នកមានសទ្ធាដែលកាន់ជាប់គួរអាននោះ មិនរលត់ មិនធ្វើឲ្យវង្វេងជាដាច់ខាត ។"

៣. អ្នកប្រាជ្ញស្ហ៊ីអ៊ុស្ទទាំងអស់ បានរាយការណ៍ហាឌីស្ទព្រះសាស្ដា صلى الله عليه وآله وسلم មួយនេះ គឺ៖ "ខ្ញុំទុកឲ្យអស់លោកនូវវត្ថុសំខាន់ពីរ មួយគឺព្រះគម្ពីរអល់ឡោះហ៍ عزوجل (គួរអាន) មួយទៀតគឺសន្តតិវង្សខ្ញុំ ព្រះរាជកុលដ្ឋានខ្ញុំ ។

[112] សូមមើល *ណាស្ទយ៉ាល់-បាឡាកោត្ត៍ (نهج البلاغة)* (បោះពុម្ពផ្សាយដោយ ស្ហ៊ុបហ៊ី អាស្ទ-ស្ទលិះហ៍) ឃុត្តបាស្ទ ១៧៦ ។

[113] សូមមើល *ណាស្ទយ៉ាល់-បាឡាកោត្ត៍ (نهج البلاغة)* (បោះពុម្ពផ្សាយដោយ ស្ហ៊ុបហ៊ី អាស្ទ-ស្ទលិះហ៍) ឃុត្តបាស្ទ ១៩៨ ។

បើអស់លោកកាន់វត្ថុទាំងពីរនេះជាប់ អស់លោកនឹងមិនវង្វេងជាដាច់ខាត ។"

ហាឌីស្ហនេះនៅក្នុងចំណោមហាឌីស្ហអ៊ីស្លាមមូតាវ៉ាតៀរ (متواتر)[114] ដែលរាយការណ៍ដោយស្ហ៊ីអាស្ហ៍និងស៊ុននី ហើយដែលបញ្ជាក់ច្បាស់ថា តាមមតិស្ហ៊ីអាស្ហ៍ ព្រះគម្ពីរអល់ឡោះហ្ទ៍ﷻ (គួរអាន) មិនត្រូវបំប្លែងជាដាច់ខាត ។ ប្រសិនបើមានការកាឡៃ (តាស់រីហ្វ) មែននោះ គួរអាននឹងបាត់បង់លក្ខន្តិកមគ្គទេសក៍ដឹកនាំនិងអ្នកការពារពីការវង្វេង ហើយមតិនេះមិនសមស្របនឹងហាឌីស្ហខាងលើនេះទេ ។

ហាឌីស្ហរបស់អ៊ីម៉ាំស្ហ៊ីអាស្ហ៍ ដែលអស់លោកអ្នកប្រាជ្ញនិងអស់លោកអ្នកនីតិសាស្ត្រ (ហ្វូកុំហ្វា فقهاء) បានរាយការណ៍នោះ បញ្ជាក់ថាគួរអានជាខ្នាតគំរូដើម្បីវែកការពិតចេញពីការឆ្គាំឆ្គង និងជាមធ្យោបាយដើម្បីវែកញែកសីលធម៌ឲ្យដាច់ឡែកអសីលធម៌ ។ ក្នុងន័យនេះ គ្រប់ពាក្យពេជន៍ដែលឮមកដល់យើង ទោះជាហាឌីស្ហក៏ដោយ ត្រូវតែមានគួរអានយោង បើពាក្យពេជន៍ទាំងនេះសមស្របតាមអាយ៉ាស្ហ៍ នឹងចាត់ទុកថាពិត ពុំនោះទេ ត្រូវចាត់ទុកថាខុសហើយត្រូវបដិសេធជាស្វ័យប្រវត្ត ។

ហាឌីស្ហច្រើននៅក្នុងសៀវភៅអស់លោកអ្នកនីតិសាស្ត្រ និងអស់លោកអ្នករាយការណ៍ហាឌីស្ហស្ហ៊ីអាស្ហ៍ស្តីអំពីរឿងនេះ យើងសូមលើកយកមកបង្ហាញជូនខ្លះ គឺ៖
អ៊ីម៉ាំអាស្ហ៍-ស្វ៉ឌិក្ហ صلوات الله عليه والسلام មានវចនៈថា៖

[114] មូតាវ៉ាតៀរ គឺហាឌីស្ហមកពីព្រះសាស្តាﷺ ឬ អ៊ីម៉ាំអវិរុទ្ធដែលគេរាយការណ៍ដដែលៗពាសពេញ បន្តបន្ទាប់គ្នាឥតដាច់ តាមរយៈអ្នកថ្លែងការណ៍ដែលគួរទុកចិត្តបន្តបន្ទាប់គ្នា ។



ហាឌីស្ហទាំងអស់ខាងលើនេះ ដែលត្រូវដកស្រង់មកពីស្ហ៊ហ៊ិះហ្ទ៍និងមុសណាដ៍ត្រឹមត្រូវរបស់អាស្ហ៍លុល-ស៊ុនណាស្ហ៍ ជាភ័ស្តុតាងបញ្ជាក់ថាមតិស្ហ៊ីអាស្ហ៍ជាមតិត្រឹមត្រូវក្នុងរឿងអនុញ្ញាតឲ្យស្ហ៍ឡាត់ស្ហ៊ហ៊្វូរ និងអាស្ហរម៉ាក់រីបនិងអ៊ីស្ហាអ៍ជាមួយគ្នា ដោយអាចធ្វើបានជាទូទៅគ្រប់ឱកាស និងគ្រប់ទីកន្លែង ។

# សំណួរ ២៨ - តើនីតិក្រម (គឺច្បាប់ហ្វីកោ្វះហ្ទ៍) ស្ហ៊ីអាស្ហ៍ចេញមកពីប្រភពណា ?

## ចម្លើយ

ស្របតាមព្រះគម្ពីរអល់ឡោះហ្ទ៍ﷻនិងស៊ុនណាស្ហ៍ព្រះសាស្តាﷺ ស្ហ៊ីអាស្ហ៍ដកស្រង់ច្បាប់សាសនាមកពីក្នុងប្រភពសំខាន់បួន គឺ៖
១. ព្រះគម្ពីរអល់ឡោះហ្ទ៍ﷻ (គួរអាន)
២. ព្រះស៊ុនណាស្ហ៍ព្រះសាស្តាﷺ
៣. មតិឯកច្ឆន្ទ (إِجْمَاع)
៤. ប្រាជ្ញា (العقل) ។

ក្នុងចំណោមប្រភពនីតិក្រមខាងលើនេះ ព្រះគម្ពីរអល់ឡោះហ្ទ៍ﷻនិងព្រះស៊ុនណាស្ហ៍ព្រះសាស្តាﷺជាប្រភពនីតិក្រមសំខាន់ ជាងគេក្នុងនីតិក្រមស្ហ៊ីអាស្ហ៍ (ហ្វីកោ្វះហ្ទ៍) ដែលយើងលើកមកអធិប្បាយដោយខ្លីៗ ។

១) ព្រះមហាគម្ពីរអល់ឡោះហ្ទ៍ﷻ (គួរអាន)

បណ្តាអ្នកតាមម៉ាស្ហ៍ហ្វាប់ស្ហ៊ីអាស្ហ៍ ចាត់ទុកព្រះគម្ពីរគួរអានជាប្រភពច្បាប់របស់ពួកគេដែលប្រាកដប្រជាបំផុត និងជាក្បួនខ្នាតសម្រាប់យល់ច្បាប់

នោះទេ ហើយបានស៊្ហឡាត់ម៉ាក់រីប និងអ៊ីស្ហាអ៊ុំគួបគ្នាបន្ទាប់ពីយប់បាន កន្លងហួសទៅបន្តិច ។ លោកបានឆ្លើយតបអ្នកសួរថា៖ "ខ្ញុំបានឃើញព្រះសាស្ដាﷺតែងតែស៊្ហឡាត់បែបនេះឯង ។" លោកអាប៊ូ ហ៊្វូរ៉យ់រ៉ោះត៊ុក៏បាន អះអាងដែរថាលោកអ៊ីបនូ អាល់-អ៊ុាប់បាស់និយាយពិត ។ ទាក់ទងនឹងរឿងនេះសូមមើលហាឌីស្ហ ២, ៧, ៩ និង ១៥ ។

អាស្រ័យហាឌីស្ហខាងលើនេះ មិនមានអ្វីគួរឲ្យសង្ស័យឡើយថាលោកអ៊ីបនូ អាល់-អ៊ុាប់បាស់បានស៊្ហឡាត់ពីរ គួបគ្នាដូចស្ហ៊ីអ៊ុាស់ស៊្ហឡាត់ដែរសព្វថ្ងៃនេះ ។

## ៦. ទង្វើរបស់ព្រះសាស្ដាﷺ ជាគំរូសម្រាប់អនុញ្ញាតឲ្យស៊្ហឡាត់ពីរគួបគ្នា

ចាប់ពីហាឌីស្ហ ២១ មក គេឃើញច្បាស់ថាព្រះសាស្ដាﷺបានស្នាក់នៅឯម៉ាក់កាស់នៅឡើយ ពេលដល់ពេលវេលាស៊្ហឡាត់ម៉ាក់រីប តែព្រះអង្គﷺបានពន្យារ លុះព្រះអង្គﷺបានទៅដល់ខណ្ឌសារ៉ហ្វ់ដែលឆ្ងាយពីម៉ាក់កាស់ ៩ ម៉ៃល្ស៍ ព្រះអង្គﷺបានស៊្ហឡាត់ម៉ាក់រីបនិងអ៊ីស្ហាអ៊ុំគួបគ្នានៅទីនេះ ដោយមិនទុកចន្លោះពេល ។

ច្បាស់ណាស់ថា ទោះជាព្រះព្រះសាស្ដាﷺបានចាកចេញពីម៉ាក់កាស់នៅដើមពេលវេលាម៉ាក់រីបក្ដី យប់បានមកដល់ក្រៃលហើយ មុននឹងបានទៅដល់ខណ្ឌសារ៉ហ្វ់ ពីព្រោះមធ្យោបាយធ្វើដំណើរសម័យនោះយឺត ដូច្នេះហើយបានជាព្រះសាស្ដាﷺស៊្ហឡាត់ម៉ាក់រីប និងអ៊ីស្ហាអ៊ុំជាមួយគ្នាក្នុងពេលជិតដល់ពេលវេលារបស់អ៊ីស្ហាអ៊ុំ ។



«ما لَمَ يُوافِقْ مِنَ الْحَدِيْثِ الْقُرآنَ فَهُوَ زُخْرُفٌ»

*"ពាក្យពេជន៍ណាដែលមិនស្របនឹងគួរអានទេទុកជាមោឃៈ ។"*[115]

ហាឌីស្ហបញ្ជាក់ច្បាស់ថាពុំមានអ្វីអាចបង្ខូចគួរអានបានឡើយ ដូច្នេះហើយបានជាគេចាត់ទុកព្រះមហាគម្ពីរជាខ្នាតគំរូ ដើម្បីវែកញែកឲ្យឃើញខុសត្រូវ ។

៥. អ្នកប្រាជ្ញស្ហ៊ីអ៊ុាស់ជំនាញៗនៃសិក្សាធិការអ៊ីស្លាម និងស្ហ៊ីអ៊ុាស់មុនៗបានទទួលស្គាល់ជានិច្ចថា គួរអានមិនអាចមាននូវកំហុសឆ្គាំឆ្គងឡើយ ។ យើងមិនអាចលើកយកឈ្មោះលោកទាំងអស់ មកអធិប្បាយជូនបានទេ សូមលើកមកបង្ហាញជូនខ្លះជាឧទាហរណ៍ គឺ៖

១- លោក ابو جعفر محمد بن علي الحسين بابويه القمي អាប៊ូ យ៉ាក់ហ្វារ មូហាំម៉ាដ់ អ៊ីបនូ អ៊ុាលី ហ៊្វូសែន៍ បាប៊ូវៃហ្វ៍ អាល់-គុម្មី ដែលគេហៅថា "ស្ហៃខ៍ អាល់-ស៊្ហឌុក្វ (الشيخ الصدوق)" ទទួលមរណៈភាពឆ្នាំ ៣៨១ សករាជហ៊ីជ្រ៉ោះត៊ុ មានប្រសាសន៍ថា៖ "ជំនឿយើងរឿងគួរអាននោះគឺជាព្រះបន្ទូលរបស់អល់ឡោះហ្វ៍ﷻនិងជាព្រះប្រកាសនា ។ នេះគឺព្រះគម្ពីរដែលកំហុសឆ្គាំឆ្គងមិនអាចជ្រៀតចូលទៅក្នុងនោះបានទេ ជាគម្ពីរដែលអល់ឡោះហ្វ៍ﷻបើកឲ្យដឹង ព្រះមុនិរាជ ព្រះទ្រង់ញាណដែលជាអ្នកបញ្ជូននិងជាអ្នកការពារគម្ពីរនោះ ។"[116]

២- السيد المرتضى علي بن الحسين الموسوي العلاوي សៃយីដ្ អាល់-មូរតាដ្ហ៍ អ៊ុាលី

[115] សូមមើល *អ៊ូស៊្ហូល អាល់-កាហ្វី (اصول الكافي)* "គីតាប ហ្វាដ្ហល៍ អាល់-អ៊ីលម៍" "បាប់ អាល់-អាក់ស៊ី ប៊ីសស៊ុនណាស់ វ៉ា ស្ហាវ៉ាហ៊ីឌី អាល់-គីតាប" ហាឌីស្ហ ៤ ។

[116] សូមមើលសៀវភៅ *អាល់-អ៊ីទីក៉ហ្វាត់ (الاعتقادات)* ទំព័រ ៩៣ ។

អ៊ីបនូ អាល់-ហ៊្វសែន៍ អាល់-មូសាវី អាល់-អាឡាវី ទទួលមរណៈភាពឆ្នាំ ៤៣៦ សករាជហ៊ីជ្រ៉េះត៍ មានប្រសាសន៍ថា៖ "សាវកមួយក្រុមរបស់ព្រះសាស្តាﷺ ដែលមានអាប់ឌុលឡោះហ្ម៍ អ៊ីបនូ ម៉ាស់អ៊ូដ (عبد الله بن مسعود) និង អ៊ូបៃ អ៊ីបនូ កាអាប់ (أبي بن كعب) បានសូត្រគួរអានច្រើនសាពីដើមដល់ចប់ឲ្យព្រះសាស្តាﷺស្តាប់ នេះបញ្ជាក់ថាគួរអានត្រូវរៀបរៀងនិងដាក់ឲ្យមានរបៀបកាលព្រះសាស្តាﷺនៅមានព្រះជន្ម ដោយមិនត្រូវបន្ថែម មិនត្រូវបន្ថយ ។" [117]

៣- លោក អាប៊ូ យ៉ាក់ហ្វារ មូហាំម៉ាដ់ អ៊ីបនូ ហាសាន់ ទូស៊ី (ابو جعفر محمد بن حسن طوسي) ហៅ "ស្ហៃខ៍ អាល់-ត៏អ៊ីហ្វាស់ (شيخ الطائفة)" ទទួលមរណៈភាពឆ្នាំ ៤៦០ សករាជហ៊ីជ្រ៉េះត៍ មានប្រសាសន៍ថា៖ "មតិដែលថា មានការបន្ថែមឬការលុបនៅក្នុងគួរអានមិនអាចយកជាការបានទេទល់នឹងសេចក្តីបំភ្លឺរបស់គួរអាននេះ ហើយមុស្លីមទាំងអស់មូលមតិគ្នាថាមិនអាចមានការបន្ថែមនៅក្នុងគួរអានបានទេ ។ ចំណែកឯការលុបនោះវិញ សាសនារបស់មុស្លីមទាំងឡាយបដិសេធ ។ មតិដែលថាពុំមានការបន្ថែមក្នុងគួរអានស្របនឹងសាសនាយើង ហើយ សៃយីដ្ មូរតាដ្ហ៍ ក៏យល់ស្របដែរ ។ ទំនងហាឌីស្ហ៍ក៏បង្ហាញឲ្យឃើញការពិតនេះដែរ ។ មនុស្សមួយក្រុមតូច ស្ហ៊ីអាស់និងស៊ុននី បានរាយការណ៍អំពីហាឌីស្ហ៍ដែលស្តីអំពីការលុបឬការផ្លាស់កន្លែងអាយ៉ាស់ ។ ហាឌីស្ហ៍ទាំងនេះប្រាប់ព័ត៌មានចម្លែកមិនផ្អែកលើវិទ្យាសាស្ត្រទេ ឬមិនមានគោលបំណងចលនាសមស្របទេ គប្បីកុំយកចិត្តទុកដាក់ ។" [118]

---

[117] សូមមើល *ម៉ាជ់ម៉ាក់ អាល់-បាយ៉ាន (مجمع البيان)* ចម្លើយរបស់ សៃយីដ្ អាល់-មូរតាដ្ហ៍ ឆ្លើយតប ម៉ាសាអ៊ីល អាល់-ត៏រ៉ាប់លូស៊ីយ៉ាត់ (المسائل الطرابلسيات) ។

[118] សូមមើលសៀវភៅ *អាត់-ទីបយ៉ាន (التبيان)* ជុំទី ១ ទំព័រ ៣ ។



ដើម្បីយល់ថា ដែលគេអនុញ្ញាតឲ្យ ស្ហ៍ឡាត់ពីរជាមួយគ្នាក្នុងពេលធ្វើដំណើរនោះ គេក៏អនុញ្ញាតឲ្យស្ហ៍ឡាត់ពីរជាមួយគ្នាពេលនៅផ្ទះដែរ ។

## ៤. បំពេញស្ហ៍ឡាត់ពីរគួបគ្នាក្នុងពេលមានអាសន្ន ជាគំរូសម្រាប់ដាក់ឲ្យអនុវត្តិតាមគ្រប់កាលៈទេសៈ ។

ហាឌីស្ហ៍ច្រើននៅក្នុងស្ហ៍ហ៊ិះហ៍ និងមុសណាដ់ថ្លែងបញ្ជាក់ថាព្រះសាស្តាﷺនិងបណ្តាសាវកព្រះអង្គﷺតែងតែស្ហ៍ឡាត់ពីរជាមួយគ្នា ដូចស្ហ៊ីអាស់ថា ក្នុងពេលមានអាសន្ន ដូចជាមានភ្លៀងធ្លាក់ នៅក្នុងស្ថានការណ៍ភ័យខ្លាច ឬនៅក្នុងអាកាសធាតុឈឺថ្កាត់ជាដើម ។

អាស្រ័យហេតុនេះ អស់លោកអ្នកនីតិសាស្ត្រម៉ាស់ហាប់ផ្សេងៗបានចេញច្បាប់ (ហ្វាតាវ៉ា فتاوى) អនុញ្ញាតឲ្យធ្វើបានក្នុងករណីអាសន្នជាដើម ទោះបីហាឌីស្ហ៍ចែងអំពីរឿងនេះក៏ដោយថាវាមិនខុសគ្នាទេ ពេលចាំបាច់និងពេលធម្មតានោះ ព្រោះព្រះសាស្តាﷺតែងតែស្ហ៍ឡាត់ពីរគួបគ្នាពេលព្រះអង្គﷺមិននៅក្នុងស្ថានភាពភ័យខ្លាចឬមានភ្លៀងធ្លាក់ទេនោះ ។ ទាក់ទាងនឹងរឿងនេះ សូមមើលហាឌីស្ហ៍ ៣, ១១, ១២ និង ២២ ។

## ៥. ទង្វើរបស់បណ្តាសាវកព្រះសាស្តាﷺ ជាគំរូដាក់ឲ្យអនុវត្តិជាទូទៅ ។

ហាឌីស្ហ៍ទាំងនេះបញ្ជាក់ថា បណ្តាសាវកភាគច្រើនតែងតែស្ហ៍ឡាត់ពីរគួបគ្នា ដូចជាអាប់ឌុលឡោះហ្ម៍ អ៊ីបនូ អាប់បាស់ ជាដើមដែលបានពន្យារស្ហ៍ឡាត់ម៉ាក់រីបលុះដល់យប់ងងឹត ផ្កាយរះ មិនយកចិត្តទុកដាក់នឹងអ្នកដទៃដែលស្រែកថា "ដល់ពេលស្ហ៍ឡាត់ហើយ ដល់ពេលស្ហ៍ឡាត់ហើយ"

គ្នានៅអុរ៉ហ្វាស្ទំជាការស្របតាមច្បាប់ ។[244] ម្យ៉ាងទៀត ហាឌីស្ហច្រើនទៀតបញ្ជាក់ថាអាចបំពេញស្វ៍ឡាត់ពីរបន្តបន្ទាប់គ្នានៅទីកន្លែង និងក្នុងឱកាសផ្សេងពីនៅអុរ៉ហ្វាស្ទំបាន ។ អ្នកខ្លះយល់ឃើញថាថ្ងៃអុរ៉ហ្វាស្ទំនិងតំបន់អុរ៉ហ្វាស្ទំមិនមែនជាករណីពិសេសទេ ។ ទាក់ទងនឹងរឿងនេះ សូមមើលហាឌីស្ហ ១៨ ។

ហេតុដូច្នេះ ព្រោះតែគេអាចស្វ៍ឡាត់ស្ហហ្វ៊រនិងអាស្ហរបន្តបន្ទាប់គ្នា ដោយមិនទុកចន្លោះពេល ក្នុងពេលវេលារបស់ស្ហហ្វ៊របាន ដូចថ្ងៃអុរ៉ហ្វាស្ទំដែរនោះ មុស្លីមទាំងអស់គ្នាមូលមតិគ្នារឿងនេះ ហើយថាគេអាចបំពេញស្វ៍ឡាត់បែបនេះនៅទីកន្លែងឯទៀតនិងក្នុងឱកាសឯទៀតបានដែរ ។

## ៣. របៀបបំពេញស្វ៍ឡាត់ពីរគូបគ្នា ដោយមិនទុកចន្លោះពេល ក្នុងពេលធ្វើដំណើរ ជាគំរូសម្រាប់ដាក់ឲ្យ អនុវត្តិតាមជាទូទៅ ។

អស់លោកអ្នកនីតិសាស្ត្រ (فقهاء) និកាយហាន់បាលី, ម៉ាលីគី និង ស្ហាហ្វីអ៊ីចាត់ទុកថាស្វ៍ឡាត់ពីរគូបគ្នាក្នុង ពេលធ្វើដំណើរនោះជាការស្របច្បាប់ ។ ហាឌីស្ហបានបញ្ជាក់ថា ធ្វើដំណើរនិងនៅផ្ទះនោះមិនខុសគ្នាទេ ព្រោះព្រះសាស្តាﷺតែងតែស្វ៍ឡាត់ពីរបន្តបន្ទាប់គ្នា នៅពេលធ្វើដំណើរនិងពេលព្រះអង្គﷺនៅផ្ទះ ។

ទាក់ទងនឹងរឿងនេះ សូមមើលហាឌីស្ហ ៣, ១១, ១៣, ១៩ និង ២២

[244] សូមមើលសៀវភៅ *អាល់-ហ្វាគ្ហិះហ៍ អុឡា អាល់-ម៉ាស្ហាហ៊ីប អាល់-អុរបាអាស្ទំ (الفقه على المذاهب الأربعة)*, "គីតាប អាស្វ-ស្វ៍ឡាស្ទំ, អាល់-យ៉ាំអ៊ុ បៃន៍ អាស្វ-ស្វ៍ឡាតៃន៍ តាក់ឌីម៉ាន វ៉ា តាក់យ៉ឺរ៉ន" ។



៤- លោក អាប៊ូ អុលី ត៍បារសុី (أبو علي الطبرسي) អ្នកនិពន្ធសៀវភៅសម្រាយគូរអាន *ម៉ាជ្ម៉ាក់ អាល់-បាយ៉ាន* បានសរសេរថា៖ "សហាគមន៍អ៊ីស្លាមទាំងអស់មូលមតិគ្នាថា មិនអាចមានការបន្ថែមក្នុងគូរអានទេ តែទាក់ទងនឹងការលុបអាយ៉ាស្ទំនោះ បក្សពួកយើងខ្លះនិងអ្នកកាន់ម៉ាស្ហហាប់ស៊ុននី "ហាស្ហាវ៉ាយ៉ាស្ទំ (الحشويه)" មួយក្រុមបានរាយការណ៍ហាឌីស្ហដែលទទួលស្គាល់ថាមានការបន្ថែមនៅក្នុងគូរអាន តែអ្វីដែលម៉ាស្ហហាប់យើងទទួលយកនិងចាត់ទុកថាត្រឹមត្រូវនោះវាផ្ទុយពីនេះ ។"[119]

៥- លោក អុលី អ៊ីបនូ ត៍វុស អាល់-ហ៊ីលលី (علي بن طاووس الحلي) ហៅ "សៃយីដុ អ៊ីបនូ ត៍វុស" ទទួលមរណភាពឆ្នាំ ៦៦៤ សករាជហ៊ីជ្រ៉ោះត៍ មានប្រសាសន៍ថា៖ "មតិស្ហីអុស្ទំគឺការបំប្លែងពុំកើតមានឡើងនៅក្នុងគូរអានទេ ។"[120]

៦- ស្ហៃខ៍ សៃដុំ អាដ្ទំ-ឌីន អាល់-អុមីលី (شيخ زين الدين العاملي) ទទួលមរភាពឆ្នាំ ៨៧៧ សករាជហ៊ីជ្រ៉ោះត៍ បានធ្វើអធិប្បាយអាយ៉ាស្ទំ إِنَّا نَحۡنُ نَزَّلۡنَا ٱلذِّكۡرَ وَإِنَّا لَهُۥ لَحَٰفِظُونَ *(យើងជាអ្នកប្រទានចុះមក (គឺបើកឲ្យដឹង) នូវអ្នករំឭក (គឺគូរអាន) ហើយយើងជាអ្នកអភិរក្សវា (១៥:៩))*[121] ថា៖ "មានន័យ៖ "យើង (គឺអល់ឡោះហ៍ﷻ) នឹងការពារនិងថែរក្សាគូរអានឲ្យចាកផុតពីការខូច ពីការផ្លាស់ប្តូរនិងពីការបន្ថែម ។"[122]

[119] សូមមើល *ម៉ាជ្ម៉ាក់ អាល់-បាយ៉ាន (مجمع البيان)* ទំព័រ ១០ ។

[120] សូមមើលសៀវភៅ សាអុដ្ទំ អាល់-ស្វូអ៊ូដុ (سعد السعود) ទំព័រ ១៤៤ ។

[121] ស៊ូរ៉ោះត៍ អាល់-ហ៊ីជ្ហ៍ 15:9

[122] សូមមើលសៀវភៅ *អ៊ីស្ហហារ អាល់-ហាក់ (اظهار الحق)* ក្បាលទី ២ ទំព័រ ១៣០ ។

៧- ក្ហ្ឌី សៃយីដ្ នូរ អាដ្ទ់-ឌីន ទុសតារី (قاضي السيد نور الدين التستري) អ្នកនិពន្ធសៀវភៅ អ៊ិះហ៊្ក្ហក្ហ៍ អាល់-ហាក្ហ៍ (اِحقاق الحَق) ទទួលមរណភាពឆ្នាំ ១០១៩ សករាជហ៊ិជ្រើះត៍ មានប្រសាសន៍ថា៖ "មតិរបស់ស៊ីអ៊ាស់អ៊ីម៉ាំមីយ៉ាស់មួយចំនួនដែលថា អាចមានការបំប្លែងនៅក្នុងគួរអាននោះ ស៊ីអាស់ទូទៅមិនអាចទទួលយកបានទេ ។ មានតែពួកគេខ្លះទេដែលមានជំនឿដូច្នេះ ហើយស៊ីអ៊ាស់មិនទទួលយកជំនឿនេះទេ ។" [123]

៨- លោក មូហាំម៉ាដ្ទ់ អ៊ីបនូ ហ៊្សៃសន៍ (محمد بن حسين) ហៅ "បាហ្ទាអ៍ អ៊ុដ្-ឌីន អាល់-អ៊ាមីលី (بهاء الدين العاملي)" ទទួលមរណភាពឆ្នាំ ១០៣០ សករាជហ៊ិជ្រើះត៍ មានប្រសាសន៍ថា៖ "អ្វីដែលត្រឹមត្រូវគឺព្រះមហាគម្ពីរគួរអានរុងរឿងចាកផុតពីការបន្ថែមឬការកាត់បន្ថយ រីឯការអះអាងថាឈ្មោះ "អាមីរុល-មុមីនីនصلوات الله عليه والسلام" ត្រូវលុបចោលពីក្នុងគួរអាននោះ អស់លោកអ្នកប្រាជ្ញខាងវិទ្យាសាស្ត្រអ៊ីស្លាមមិនទទួលស្គាល់ទេ ។ អ្នកណាក៏ដោយដែលធ្វើការស្រាវជ្រាវក្នុងប្រវត្តិសាស្ត្រនិងក្នុងហាឌីស្ យោលតាមរាប់ពាន់ហាឌីស្ររាយការណ៍ដោយសាវកនោះ នឹងយល់ថាគួរអានត្រូវចងក្រងទាំងអស់ឡើងក្នុងសម័យព្រះសាស្ដាصلى الله عليه وآله وسلمដោយមិនកែប្រែទេ ។" [124]

៩- លោក ហ្វៃដ្ទ៍ កាស្ហានី (فيض كاشاني) អ្នកនិពន្ធសៀវភៅ គីតាប អាល់-វ៉ាហ្វ៊ី (كتاب الوافي) ទទួលមរណភាពឆ្នាំ ១០៩១ សករាជហ៊ិជ្រើះត៍ ក្រោយពីបានលើកអាយ៉ាស់ إِنَّا نَحْنُ نَزَّلْنَا ٱلذِّكْرَ وَإِنَّا لَهُۥ لَحَـٰفِظُونَ *(យើងជាអ្នកប្រទានចុះមក (គឺបើកឲ្យដឹង) នូវអ្នករំឭក (គឺគួរអាន) ហើយយើងជាអ្នកអភិរក្សវា (១៥:៩))*[125] ដែលចែងថា គួរអានពុំមានការខូចខាតទេនោះ

---

[123] សូមមើលសៀវភៅ *អាឡា អារ-រ៉ោះហ្ម៉ាន* ទំព័រ ២៥ ។

[124] សូមមើលសៀវភៅ *អាឡា អារ-រ៉ោះហ្ម៉ាន* ទំព័រ ២៥ ។

[125] ស៊ូរ៉ោះត៍ អាល់-ហ៊ីជ្រ៍ 15:9 ។



បំពេញស៊ូឡាត់ពីរគួបគ្នាបាន (ស៊ូហ្វរនិងអ៊ាស្វារ ម៉ាក់រីបនិងអ៊ីស្ហាអ៍) នៅក្នុងពេលតែមួយ ដោយមិនទុកចន្លោះពេល ។ ទាក់ទងនឹងរឿងនេះ សូមមើល ហាឌីស្ ១០, ១៦, ១៩ និង ២២ ។

ច្បាស់ណាស់ថា ប្រសិនបើហាឌីស្ខាងលើនេះមានន័យថាអាចពន្យារស៊ូឡាត់ស៊ូហ្វររហូតដល់ពេលក្រោយរបស់វាបាន (គឺដល់ពេលម្លប់របស់សព្វវត្ថុមានប្រវែងស្មើនឹងសព្វវត្ថុនោះ) ហើយបំពេញស៊ូឡាត់អ៊ាស្វារនៅក្នុងដើមពេលវេលារបស់វា ដើម្បីនឹងឲ្យស៊ូឡាត់ទាំងពីរមានលំដាប់បន្តបន្ទាប់គ្នានៅក្នុងរយៈពេលត្បិតត្បៀត ដូចអាស់ហ្លុល-ស៊ុនណាស់ថានោះ វាប្រាកដជាមានការលំបាកច្រើន ព្រោះគោលបំណងនៃការបំពេញស៊ូឡាត់ពីរគួបគ្នាដោយពុំទុកចន្លោះពេលនោះគឺធ្វើឲ្យមានការងាយស្រួលក្នុងការប្រកបកិច្ចការនានា ។

ដូច្នេះ ហាឌីស្ខាងលើនេះមានន័យថា អាចបំពេញស៊ូឡាត់ពីរគួបគ្នាដោយមិនទុកចន្លោះពេលបាន នៅក្នុងពេលវេលារួមរបស់ស៊ូឡាត់ទាំងពីរពេលណាក៏បានក្នុងពេលរួមនេះ ពីដើមពេលរួមរហូតដល់ចុងពេលរួមនេះ មិនមែនបំពេញស៊ូឡាត់មួយនៅចុងអំឡុងពេលរបស់វា មួយទៀតនៅដើមពេលវេលារបស់វានោះទេ ។

## ២. បំពេញស៊ូឡាត់ពីរគួបគ្នា ដោយមិនទុកចន្លោះពេលនៅឯអ៊ារ៉ហ្វាស់នោះជាគំរូ សម្រាប់ដាក់ឲ្យអនុវត្តិតាមជាទូទៅ

ម៉ាស់ហ្ទាប់អ៊ីស្លាមទាំងអស់មូលមតិគ្នាថា ស៊ូឡាត់ស៊ូហ្វរនិងអ៊ាស្វារគួប

*អ៊ុាស្វារជាមួយគ្នា ព្រមទាំងម៉ាក់រីបនិងអ៊ីស្វាអ៍ដែរ ដោយមិនទុកពេលចន្លោះទេ ថ្វីដ្បិតតែព្រះអង្គﷺមិននៅក្នុងការធ្វើដំណើរ ឬរងភ្លៀងភ្លាក់ទេក៏ដោយ ។" លោកអ្នករាយការណ៍មានប្រសាសន៍ថា៖ "ខ្ញុំបានសួរអ៊ីបនូអ៊ុាប់បាស់ថាហេតុអ្វីព្រះសាស្តាﷺធ្វើដូច្នេះ ?" លោកបានតបថា៖ "ព្រះអង្គﷺចង់ឲ្យអ៊ុម៉ាត់ព្រះអង្គﷺមានការងាយស្រួល ។"*[243]

## សេចក្តីសរុប

ហាឌីស្ទទាំងនេះជាភ័ស្តុតាងច្បាស់ក្រឡែតដែលអះអាងបញ្ជាក់ថា មតិស្ទីអ៊ុស្ទរឿងស្ទ័ឡាត់បន្តបន្ទាប់គ្នាដោយមិនទុកចន្លោះពេលនោះ ជាមតិត្រឹមត្រូវនិងស្របច្បាប់មែន ។

## ១. បំពេញស្វ័ឡាត់ពីរជាមួយគ្នា ដោយមិនទុកចន្លោះពេលមានន័យថាធ្វើឲ្យមានការងាយស្រួល ក្នុងការប្រកបកិច្ចការនិងចៀសវាងការលំបាក ។

ហាឌីស្ទច្រើនអះអាងបញ្ជាក់ថា ប្រសិនបើការបំពេញស្វ័ឡាត់ស្ទូហ្វូរនិងអ៊ុាស្វារ ម៉ាក់រីបនិងអ៊ីស្វាអ៍ គូបគ្នា ដោយមិនទុកចន្លោះពេលត្រូវហាមឃាត់មែននោះ វានឹងធ្វើឲ្យមានការលំបាកលំបិនក្នុងការប្រកបកិច្ចការរបស់មុស្លីម ។ អាស្រ័យហេតុនេះឯង ដើម្បីធ្វើឲ្យមុស្លីមមានការងាយស្រួលក្នុងការប្រកបកិច្ចការនោះ បានជាព្រះសាស្តាﷺអនុញ្ញាតឲ្យ

[243] សូមមើលសៀវភៅរបស់លោក មុតតាគ្គី អាល់-ហ៊ីនឌី *កាន់ស៊ុ អាល់-អ៊ុម៉ាល់ (كنز العمال)* (បោះពុម្ពឆ្នាំ 1391 ស.ហ ដោយរោងពុម្ព ហាឡាប់ ទីក្រុងអាលេប) ជុំទី ៨ "គីតាប អាស្វ-ស្វ័ឡាត់" វគ្គស្តីអំពីស្វ័ឡាត់អ្នកដំណើរ ទំព័រ ២៤៧ ។



លោកបានប្រកាសថា៖ "តើការខូចខាតអាចប៉ះពាល់គួរអានបានដូចម្តេចទៅ ? ហាឌីស្ទដែលស្តីអំពីការខូចខាតនោះផ្ទុយពីព្រះមហាគម្ពីររបស់អល់ឡោះហ្ ﷻ ហើយត្រូវចាត់ទុកថាមិនសមហេតុផលទេ ។" [126]

១០- ស្ហៃក៏ ហ៊្វូរ អ៊ុាមីលី (الشيخ الحر العاملي) ទទួលមរណភាពឆ្នាំ ១១០៤ សករាជហ៊ិជ្រ៉ោះត៍ បានសរសេរថា៖ "ការស្រាវជ្រាវក្នុងប្រវត្តិសាស្ត្រនិងក្នុងហាឌីស្ទនឹងបង្ហាញឲ្យឃើញថា គួរអានអាចទុកចិត្តបាន ហើយត្រូវចងក្រងនិងរៀបរៀងឡើងកាលព្រះសាស្តាﷺនៅមានព្រះជន្ម ។ កសិណល្អបំផុតគឺហាឌីស្ទសន្ធឹកសន្ធាប់ស្តីអំពីរឿងនេះ រាយការណ៍ដោយសាវករាប់ពាន់នាក់ ។" [127]

១១- អ្នកស្រាវជ្រាវដ៏ល្បី ឈ្មោះ "កាស៊ីហ្វ អាល់-គ៊ីត៍អ៍ (كاشِف الغِطاء)" បានថ្លែងនៅក្នុងសៀវភៅដ៏ល្បីរបស់លោក ដែលមានចំណងជើងថា "កាស្វ់ហ្វ៍ អាល់-គ៊ីត៍អ៍ (كَشفُ الغِطاء)" ថា៖ "ពិតប្រាកដណាស់ថាគួរអានអាស្រ័យការថែរក្សានិងការការពាររបស់ព្រះនោះ គង់នៅឥតខូចខាត ដូចគួរអាននិងមតិតែមួយរបស់អស់លោកអ្នកប្រាជ្ញបានអធិប្បាយយ៉ាងក្បោះក្បាយគ្រប់សម័យ ។ ការប្រឆាំងពីសំណាក់មនុស្សមួយក្រុមតូចមិនគប្បីយកចិត្តទុកដាក់ទេ ។"

១២- អាយ៉ាទុលឡោះហ្ ឃ៊ុមៃនី (آية الله خمينى) មគ្គុទេសក៍បដិវត្តន៍អ៊ីស្លាមបានថ្លែងនៅក្នុងសុន្ទរកថាមួយ ដែលយើងសូមលើកយកមកបញ្ជាក់រឿងនេះ ថា៖ "បុគ្គលគ្រប់រូបដែលដឹងថា តើមុស្លីមត្រូវប្រុងប្រយ័តខ្លាំងបែបណាខ្លះក្នុងការចងក្រង រក្សា កត់ត្រាទុក សូត្រ និងសរសេរគួរអាននោះ

[126] សូមមើល *តាហ្ស៊ៀរ អាល់-ស្វ៍ហ្វី (تفسير الصافي)* ជុំទី ១ ទំព័រ ៥១ ។

[127] សូមមើលសៀវភៅ *អាឡា អារ-រ៉ោះហ្ម៉ាន* ទំព័រ ២៥ ។

បុគ្គលទាំងនោះនឹងសច្ចាថាមតិដែលថាគួរអានត្រូវបំប្លែនោះមិនសមហេតុផលទេ ហើយចាត់ទុកមតិនេះថាមិនអាចជឿបានទេ ។ ហាឌីស្សរាយការណ៍រឿងនេះជាហាឌីស្សខ្សោយឬខ្វះការពិចារណា ជាហាឌីស្សក្លែងក្លាយឬជាហាឌីស្សដែលផ្តោតទៅលើការបកស្រាយគួរអាន ឬជាហាឌីស្សច្រើនប្រភេទទៀតដែលទាមទារសៀវភៅអធិប្បាយវែងនិងស្មុគស្មាញ ។

បើនៅតែមានការញញើតញញើមរឿងនេះ យើងនឹងបង្ហាញជូននូវប្រវត្តិគួរអាន និងព្រឹត្តិការណ៍ដែលបានកើតឡើងច្រើនសតវត្សរ៍មកហើយ ដើម្បីបំភ្លឺថាគួរអានរុងរឿងជាព្រះគម្ពីរពិតៗ ដែលយើងកាន់ក្នុងដៃ ។ ភាពខុសគ្នាក្នុងការសូត្រគួរអាននោះជារឿងថ្មីៗនេះ ដែលពុំទាក់ទងនឹងអ្វីដែលយ៉ីប្រអ៊ីល(عليه السلام)បានបើកឲ្យដឹង នៅក្នុងចិត្តបរិសុទ្ធរបស់ព្រះសាស្តាﷺនោះទេ ។"[128]

## សេចក្តីសរុប

មុស្លីមទាំងឡាយ ស្ហ៊ីអាស់និងស៊ុននីភាគច្រើន ទទួលស្គាល់ថាព្រះគម្ពីរនេះគឺគួរអានដែលគេបានបើកឲ្យព្រះសាស្តាﷺដឹង ដែលចាកផុតពីការបំប្លែងបំភ្លៃ ពីការបន្ថែមឬការកាត់ចោល ។

សម្រាប់ស្ហ៊ីអាស់ រឿងបំភ្លៃគួរអានត្រូវបដិសេធយ៉ាងច្បាស់លាស់ហើយ តែបើហាឌីស្សខ្សោយខ្លះ ដែលស្តីអំពីរឿងនេះក្លាយទៅជាមូលហេតុចោទប្រកាន់ យើងយល់ឃើញថាហាឌីស្សទាំងនេះមិនចេញមកពីតែក្រុមស្ហ៊ីអាស់ទេ ព្រោះអ្នកអធិប្បាយស៊ុននីច្រើននាក់ក៏បានរាយការណ៍

[128] សូមមើល *តាស់ស៊ីប អាល់-អ៊ូស្ហូល* "អត្ថបទសិក្សារបស់អ៊ីម៉ាំ យ៉ូមៃនី" ជុំទី ២ ទំព័រ ៩៦ (សរសេរដោយ យ៉ាក់ហ្វារ ស៊ុបហានី (جعفر سبحاني)) ។



*អាស្មានមួយ អ៊ីក្វ៉ាម៉ាស់ពីរ ។"*[240]

២១. នៅក្នុងសៀវភៅ *កាន់ស៍ អាល់-អ៊ុមម៉ាល់* គេបានលើកហាឌីស្សនេះមកអធិប្បាយ គឺ៖

«عن جابر أنّ رسول اللّه – صلّى الله عليه وآله وسلّم – غربت له الشّمس بمكّة فجمع بينهما بسرف»

*"យ៉ាបៀរ [អ៊ីបនូ អាប់ឌុលឡោះហ្ស៍] មានប្រសាសន៍ថា៖ "កាលព្រះសាស្តាﷺអល់ឡោះហ្ស៍(عزّ وجلّ)នៅឯម៉ាក់កាស់ ថ្ងៃបានលិច ។ ពេលព្រះអង្គﷺបានទៅដល់កន្លែងមួយដែលហៅថា "សារ៉ហ្វ៍"[241] ព្រះអង្គﷺបានបំពេញស្វ៍ឡាត់ពីរ [ម៉ាក់រីបនិងអ៊ីស្ហាអ៍ជាមួយគ្នា] មិនទុកចន្លោះពេលទេ ។"*[242]

២២. នៅក្នុងសៀវភៅ *កាន់ស៍ អាល់-អ៊ុមម៉ាល់* គេបានរាយការណ៍តមកពីលោក អ៊ីបនូ អាប់បាស់ថា៖

«جمع رسول الله – صلّى الله عليه (وآله) وسلّم – بين الظّهر والعصر، والمغرب والعشاء بالمدينة في غير سفرٍ ولامطرٍ، قال: قلت لابن عبّاس: لم تراه فعل ذلك؟ قال: أراد التّوسعة على امّته»

*"នៅម៉ាឌីណាស់ ព្រះសាស្តាﷺអល់ឡោះហ្ស៍(عزّ وجلّ)បានស្វ៍ឡាត់ស្ហូហ្ស៍រនិង*

[240] សូមមើលសៀវភៅរបស់លោក មុតតាគី អាល់-ហ៊ិនឌី *កាន់ស៍ អាល់-អ៊ុមម៉ាល់ (كنز العمال)* (បោះពុម្ពឆ្នាំ 1391 ស.ហ ដោយរោងពុម្ព ហាឡាប់ ទីក្រុងអាលេប) ជុំទី ៨ "គីតាប អាស្វ៉-ស្វ៍ឡាត់" វគ្គស្តីអំពីស្វ៍ឡាត់អ្នកដំណើរ ទំព័រ ២៤៧ ។

[241] សារ៉ហ្វ៍ សង្កាត់មួយមានចម្ងាយ ៩ ម៉ៃស៍ពីម៉ាក់កាស់ ។

[242] សូមមើលសៀវភៅរបស់លោក មុតតាគី អាល់-ហ៊ិនឌី *កាន់ស៍ អាល់-អ៊ុមម៉ាល់ (كنز العمال)* (បោះពុម្ពឆ្នាំ 1391 ស.ហ ដោយរោងពុម្ព ហាឡាប់ ទីក្រុងអាលេប) ជុំទី ៨ "គីតាប អាស្វ៉-ស្វ៍ឡាត់" វគ្គស្តីអំពីស្វ៍ឡាត់អ្នកដំណើរ ទំព័រ ២៤៧ ។

គេអាចបំពេញស្ឡ៏ទ្បាត់ទាំងពីរនេះនៅឯទីកន្លែងផ្សេង បានដែរ ។"

១៩. លោក អាល់-មុតតាគ្គី អាល់-ហ៊ិនឌី (المتقي الهندي) មានប្រសាសន៍នៅក្នុងសៀវភៅលោក *កាន់ស៊ុ អាល់-អ៊ុមម៉ាល់ (كنز العمال)* ថា៖

«قال عبدالله: جمع لنا رسول الله صلّى الله عليه وآله وسلّم مقيماً غير مسافر بين الظّهر والعصر، والمغرب والعشاء. فقال رجلٌ لإبن عمر: لِمَ ترى النّبي صلّى الله عليه وآله وسلّم فعل ذلك؟ قال: لأن لايحرج امّته إن جمع رجلٌ»

*"អ៊ុប់ឌុលឡោះហ៍ [អ៊ីបនូ អ៊ុម៉ារ] មានប្រសាសន៍ថា៖ "ព្រះសាស្ដាﷺ អល់ឡោះហ៍ﷻ ពេលព្រះអង្គﷺនៅផ្ទះ មិនធ្វើដំណើរទេ ព្រះអង្គﷺ ស្ឡ៏ទ្បាត់ស៊ូហ្ស៊ីរនិងអ៊ុស្ស៊រ ព្រះអង្គﷺស្ឡ៏ទ្បាត់ម៉ាក់រីបនិងអ៊ីស្សាអ៍ជាមួយគ្នា មិនទុកចន្លោះពេលទេ ។" គេបានសួរអ៊ីបនូ អ៊ុម៉ារថា៖ "ហេតុអ្វីព្រះសាស្ដាﷺធ្វើដូច្នេះ ?" លោកបានតបថា៖ "ដើម្បីនឹងកុំឲ្យអ៊ុមម៉ាត់ព្រះអង្គﷺលំបាកលំបិន បើមានអ្នកណាមួយចង់ធ្វើដូច្នេះ ។"*[239]

២០. ដូចគ្នាដែរ មានសរសេរនៅក្នុងសៀវភៅ *កាន់ស៊ុ អាល់-អ៊ុមម៉ាល់* ថា៖

«عن جابر، أنّ النّبيّ – صلّى الله عليه (وآله) وسلّم – جمع بين الظّهر والعصر بأذانٍ وإقامتين»

*"យ៉ាបៀរ [អ៊ីបនូ អ៊ុប់ឌុលឡោះហ៍] មានប្រសាសន៍ថា៖ "ព្រះសាស្ដាﷺ អល់ឡោះហ៍ﷻបានស្ឡ៏ទ្បាត់ស៊ូហ្ស៊ីរនិងអ៊ុស្ស៊រជាមួយគ្នា ដោយសូត្រ*

[239] សូមមើលសៀវភៅរបស់លោក មុតតាគ្គី អាល់-ហ៊ិនឌី *កាន់ស៊ុ អាល់-អ៊ុមម៉ាល់ (كنز العمال)* (បោះពុម្ពឆ្នាំ 1391 ស.ហ ដោយរោងពុម្ព ហាទ្បាប់ ទីក្រុងអាលេប) ជុំទី ៨ "គីតាប អាស្ស៊-ស្ឡ៏ទ្បាត់" វគ្គស្ដីអំពីស្ឡ៏ទ្បាត់អ្នកដំណើរ ទំព័រ ២៤៦ ។



ហាឌីស្ស៍ខ្សោយបែបនេះដែរ យើងសូមលើកយកមកបង្ហាញជូនខ្លះ គឺ៖

១. លោក អាប៊ូ អ៊ុប់ឌុលឡោះហ៍ មូហាំម៉ាដ់ អ៊ីបនូ អាស្ម៉ាដ់ អាល់-អាន់ស្ស៊ារី អាល់-គួរទូប៊ី (ابو عبد الله محمد ابن احمد الانصاري القرطبي) នៅក្នុងសេចក្ដីអធិប្បាយគួរអាន បានរាយការណ៍តមកពី អាប៊ូ បាការ អាល់-អាន់បាស៊ីដែលបានរាយការណ៍តមកពីអ៊ូបៃ អ៊ីបនូ កាអ៊ុប់ ថាស៊ូរ៉ោះត៍ "អាល់-អាស៊ស្ស៊ាប់" ដែលមាន ៧៣ អាយ៉ាស់នោះ សម័យព្រះសាស្ដាﷺ ស្មើនឹងស៊ូរ៉ោះត៍ "អាល់-បាក៏រ៉ោះត៍" ដែលមាន ២៨៦ អាយ៉ាស់ ថាស៊ូរ៉ោះត៍ចោលដុំថ្ម (អាយ៉ាស់ អារ-រ៉យ៉ុំ) នៅក្នុងអាយ៉ាស់នេះ ។ ឥឡូវនេះ អាយ៉ាស់ខាងលើនេះមិនមាននៅក្នុងស៊ូរ៉ោះត៍ "អាល់-អាស៊ស្ស៊ាប់" ទេ ។ នៅក្នុងសៀវភៅនេះដែរ លោកបានរាយការណ៍សម្ដីរបស់អ៊ែស្ស៊ាស់ដែលថា៖ "ស៊ូរ៉ោះត៍ "អាល់-អាស៊ស្ស៊ាប់" មាន ២០០ អាយ៉ាស់សម័យព្រះសាស្ដាﷺ ។ ក្រោយមក ពេលគេកត់ត្រាគួរអានជាលាយលក្ខអក្សរ អាយ៉ាស់បានបាត់ នៅសល់តែកំណែសព្វថ្ងៃនេះ ។"[129]

២. លោកអ្នកនិពន្ធសៀវភៅ អាល់-អ៊ីតកួន (الإتقان) បានរាយការណ៍ថា ចំនួនស៊ូរ៉ោះត៍ព្រះគម្ពីរ ប្រមូលដោយលោក អ៊ូបៃ កាអ៊ុប់ មាន ១១៦ ព្រោះស៊ូរ៉ោះត៍ពីរដែលមានចំណងជើងថា "អាល់-ហាហ្វ៍ដ៍ (سورة الحفد)" និង "អាល់-ខាល់អ៊ុ (سورة الخلع)" ត្រូវបានរាប់បញ្ចូលក្នុងចំនួនស៊ូរ៉ោះត៍ទាំងនេះ ។

ទាំងអស់គ្នាដឹងថាព្រះមហាគម្ពីរគួរអានមាន ១១៤ ស៊ូរ៉ោះត៍ មិនឃើញមានស៊ូរ៉ោះត៍ទាំងពីរនេះទេ ។[130]

[129] សូមមើល *តាហ្ស៊ៀរ អាល់-គួរទូប៊ី (تفسير القرطبي)* ជុំទី ១៤ ទំព័រ ១១៣ ខាងដើមនៃសេចក្ដីអធិប្បាយស៊ូរ៉ោះត៍ អាល់-អាស៊ស្ស៊ាប់ ។

[130] សូមមើល *អាល់-អ៊ីតកួន (الإتقان)* ជុំទី ១ ទំព័រ ៦៧ ។

៣- លោក ហ៊ីបាទុលឡោះហ៍ អ៊ីបនូ សាឡាម៉ាស់ បានរាយការណ៍នៅក្នុងសៀវភៅលោក អាន់-ណាស៊ីក្ហ វ៉ាល់-មុនស៊ូក្ហ (الناسخ و المنسوخ) តមកពីលោក អាណាស់ អ៊ីបនូ ម៉ាលិក ថា៖ "សម័យព្រះសាស្ដា ﷺ យើងសូត្រស៊ូរ៉ោះត៍ធំស្មើស៊ូរ៉ោះត៍ "តៅបាស់" តែខ្ញុំចាំបានតែមួយអាយ៉ាស់ទេ គឺ៖

«لَوْ اَنَّ لِابْنِ آدَمَ وادِيينِ مِنَ الذَّهَبِ لَابْتَغى اِلَيْهِما ثالِثاً وَلَوْ اَنَّ لَهُ ثالِثاً لَابْتَغى اِلَيْها رابِعاً وَلَايَمْلأُ جَوفَ اِبْنِ آدَمَ اِلاّ التُّرابُ وَيَتُوبُ اللهُ عَلى مَنْ تابَ »

"ប្រសិនបើកូនអាដាំមានមាសពីរច្រកភ្នំ ចង់បានច្រកភ្នំមាសទីបីថែមទៀត ។ ប្រសិនបើគេមានបីច្រកភ្នំមាស ចង់បានច្រកភ្នំមាសទីបួន ។ ពុំមានអ្វីធ្វើឲ្យពោះកូនអាដាំពេញទេ មានតែដីទេដែលធ្វើឲ្យគេបាត់ឃ្លាន (ស្លាប់) ។ អល់ឡោះហ៍បែរមករកអ្នកណាដែលត្រឡប់មករកព្រះអង្គវិញ ។"

យើងដឹងថាពុំមានអាយ៉ាស់នេះនៅក្នុងគម្ពីរអានទេ ហើយមិនសមស្របនឹងរចនាបថអក្សរសិល្បគម្ពីរអានទេ ។

៤- លោក យ៉ាឡាល់ អាដ់-ឌីន អាល់-ស៊ូយូទី (جلال الدين السيوطي) នៅក្នុងសេចក្ដីអធិប្បាយគម្ពីរអាន អាល់-ឌូរ អាល់-ម៉ាន់ស៊ួរ (الدر المنثور) រាយការណ៍តមកពីលោក អ៊ុម៉ារ អ៊ីបនូ អាល់-ខុត្តប់ ថា ស៊ូរ៉ោះត៍ "អាល់-អាស់ស្ហាប់" វែងដូចស៊ូរ៉ោះត៍ "អាល់-បាក៏រ៉ោះត៍" ដែរ ហើយអាយ៉ាស់ចោលដុំថ្ម (អាយ៉ាស់ អារ-រ៉យ៉ុំ) នៅក្នុងស៊ូរ៉ោះត៍នេះ ។[131]

យើងឃើញថាស៊ីអ៊ាស់និងស៊ុននីមួយចំនួនតូច បានរាយការណ៍ហាឌីស្សខ្សោយស្ដីអំពីការអាចមានការបំប្លែងគម្ពីរអាន ។ ហាឌីស្សទាំងនេះ ដែល

[131] សូមមើល *អាល់-ឌូរ អាល់-ម៉ាន់ស៊ួរ (الدر المنثور)* ជុំទី ៥ ទំព័រ ១៨០ ខាងដើមសេចក្ដីអធិប្បាយស៊ូរ៉ោះត៍ អាល់-អាស់ស្ហាប់" ។



មូអាស់ អ៊ីបនូ យ៉ាបាល់ (معاذ بن جبل) ថា៖

«خرجنا مع رسول الله صلّى الله عليه (وآله) وسلّم في غزوة تبوك فكان يصلّي الظّهر والعصر جميعاً والمغرب والعشاء جميعاً»

*"កាលយើងទៅធ្វើសង្គ្រាមតាប៊ុក ជាមួយព្រះសាស្ដា ﷺ អល់ឡោះហ៍ ﷻ ព្រះអង្គ ﷺ បានស្ហ៍ឡាត់ស្ហូហ្វ៊ូរនិងអាស្ហារ ស្ហ៍ឡាត់ម៉ាក់រីបនិងអ៊ីស្ហាអ៍ បន្តបន្ទាប់គ្នា មិនទុកចន្លោះពេលទេ ។"*[237]

១៨. លោក ម៉ាលិក អ៊ីបនូ អាណាស់ បានសរសេរនៅក្នុងសៀវភៅលោក អាល់-មូវ៉ាត្តត៏អ៍ ថា៖

«عن ابن شهاب انّه سأل سالم بن عبدالله: هل يجمع بين الظّهر والعصر في السّفر؟ فقال: نعم لابأس بذلك، ألم تر إلى صلاة النّاس بعرفة؟»

*"អ៊ីបនូ ស្ហាហ្វាប់បានសួរសាលីម អ៊ីបនូ អាប់ឌុលឡោះហ៍ថា៖ "តើអាចស្ហ៍ឡាត់ស្ហូហ្វ៊ូរនិងអាស្ហារជាមួយគ្នាបានទេក្នុងពេលធ្វើដំណើរ ?" លោកបានឆ្លើយថា៖ "បាន មិនមានបញ្ហាទេ ។ លោកមិនឃើញគេស្ហ៍ឡាត់ថ្ងៃអារ៉ហ្វាស់ទេ ?"*[238]

សូមរំលឹកថាមុស្លីមទាំងអស់ចាត់ទុកថាគេអនុញ្ញាតឲ្យស្ហ៍ឡាត់ស្ហូហ្វ៊ូរ និងអាស្ហារបន្តបន្ទាប់គ្នា នៅឯវាលអារ៉ហ្វាស់ ក្នុងពេលវេលារបស់ស្ហូហ្វ៊ូរ ដោយមិនទុកចន្លោះពេល ។ សាលីម អ៊ីបនូ អាប់ឌុលឡោះហ៍មានប្រសាសន៍ថា៖ "ដូចគេបំពេញស្ហ៍ឡាត់ទាំងពីរនៅ ឯអារ៉ហ្វាស់ដែរ

[237] សូមមើលសៀវភៅ *ស្ហ៍ហ៊ិះហ៍ មុស្លីម* (បោះពុម្ពនៅអេស៊ីបត៍) ជុំទី ២ "គីតាប អាស្ស-ស្ហ៍ឡាស់" "វគ្គស្ដីអំពីស្ហ៍ឡាត់ផ្គុំគ្នា នៅផ្ទះ" ទំព័រ ១៥២ ។

[238] សូមមើលសៀវភៅរបស់លោក ម៉ាលិក អ៊ីបនូ អាណាស់ *អាល់-មូវ៉ាត្តត៏អ៍* (បោះពុម្ពលើកទី ៣ នៅបៃរូត ហ.ស 1403) "គីតាប អាស្ស-ស្ហ៍ឡាស់" ទំព័រ ១២៥ ហាឌីស្ស ១៨០ ។

*"ដល់ពេលស្វ៍ឡាត់ហើយ ។" អ៊ីបនូ អ៊ុាប់បាស់ មិនថាអ្វីទេ ។ បុរសនោះបានប្រាប់ម្ដងទៀត ។ លោកមិននិយាយអ្វីទេ ។ បុរសនោះក៏បានស្រែកទៀតថា៖ "ដល់ពេលស្វ៍ឡាត់ហើយ ។" លោកនៅស្ងៀមហើយក៏បាននិយាយថា៖ "លោកចង់បង្ហាត់បង្រៀនយើងរឿងស្វ៍ឡាត់ឬ ? យើងតែងតែស្វ៍ឡាត់ពីរគួបគ្នា កាលព្រះសាស្ដាﷺអល់ឡោះហ្វ៍ﷻនៅមានព្រះជន្មនៅឡើយ ។"*[235]

១៦. លោក មុស្លីម បានរាយការណ៍ថា៖

«إنّ رسول الله – صلّى الله عليه (وآله) وسلّم – جمع بين الصّلاة في سفرة سافرها في غزوة تبوك فجمع بين الظّهر والعصر، والمغرب والعشاء. قال سعيدٌ : فقلت لابن عبّاس: ما حمله على ذلك؟ قال: أراد أن لايحرج امّته»

*"ព្រះសាស្ដាﷺអល់ឡោះហ្វ៍ﷻបានស្វ៍ឡាត់រួម កាលព្រះអង្គﷺទៅធ្វើសង្គ្រាមតាប៊ុក ។ ព្រះអង្គﷺបានស្វ៍ឡាត់ស្ហ្វ៊ហ្ររ៍ជាមួយអ៊ុាស្វារ ព្រះអង្គﷺបានស្វ៍ឡាត់ម៉ាក់រីបជាមួយអ៊ីស្វាអ៍ ។ សាអ៊ីដបានសួរអ៊ីបនូ អាល់-អ៊ុាប់បាស់ថា៖ "ហេតុអ្វីព្រះអង្គﷺធ្វើដូច្នេះ ?" លោកបានថា៖ "ព្រះអង្គﷺមិនចង់ឲ្យអ៊ុម៉ាត់ព្រះអង្គﷺលំបាកលំបិនទេ ។"*[236]

១៧. លោក អ៊ីបនូ អាល់-ហ៊ាជ់យ៉ាជ់ បានរាយការណ៍តមកពីលោក

[235] សូមមើលសៀវភៅ *ស្វ៍ហ៊ិះហ្វ៍ មុស្លីម* (បោះពុម្ពនៅបៃរូត) ជុំទី ២ "គីតាប អាស្វ-ស្វ៍ឡាស់" "វគ្គស្ដីអំពីស្វ៍ឡាត់ផ្គុំគ្នានៅ ផ្ទះ" ទំព័រ ១៥៣ ។ សូមមើលសៀវភៅរបស់លោក អ៊ុាប់ឌុល ហាមីដ ស្វីដឌីគី ស្វ៍ហ៊ិះហ្វ៍ មុស្លីម (ប្រែជាភាសាអង់គ្លេស) ជុំទី ១ កណ្ឌ ១០០ វគ្គស្ដីអំពីការផ្គុំស្វ៍ឡាត់នៅផ្ទះ កណ្ឌទី ៤ ហាឌីស្វ ១៥២៤ ។

[236] សូមមើលសៀវភៅ *ស្វ៍ហ៊ិះហ្វ៍ មុស្លីម* (បោះពុម្ពនៅអេស៊ីបត៍) ជុំទី ២ "គីតាប អាស្វ-ស្វ៍ឡាស់" "វគ្គស្ដីអំពីស្វ៍ឡាត់ផ្គុំគ្នា នៅផ្ទះ" ទំព័រ ១៥១ ។



ខ្សោយនោះ ដោយធៀបនឹងមតិមុស្លីមភាគច្រើន ស្ហ៊ីអ៊ុាស់និងស៊ុននី មិនគួរទុកចិត្តបានទេ ។ អាយ៉ាស់គួរអាន ហាឌីស្វអ៊ីស្លាមពិតហើយច្រើន មតិទូទៅរបស់សាវកព្រះសាស្ដាﷺ រាប់ពាន់នាក់និងមុស្លីមក្នុងលោក ផ្ដោតទៅរកចំណុចតែមួយដែលថាការបំប្លែងនិងការលុប ការផ្លាស់ប្ដូរនិងការបន្ថែមពុំអាចកើតឡើងបាននៅក្នុងព្រះគម្ពីរគួរអានទេ ក្នុងសម័យព្រះសាស្ដាﷺមានព្រះជន្មនៅឡើយនោះ ។

តែយើងដឹងថាក្នុងរជ្ជកាលទីមួយ អាប៊ូ បាការ ដែលជាស្ដេចខ្ទ័លិហ្វកាន់អំណាចសម័យនោះ ពេលអត់ពីព្រះសាស្ដាﷺទៅ បានចងក្រងគួរអានដោយមានអ៊ុម៉ារជាទីព្រឹក្សា ។ ក្រោយមក អ៊ុស្វម៉ាន ឡើងកាន់អំណាចបានចងក្រងគួរអានមួយលើកទៀត ។ លេខរៀងរបស់ស្វរ៉េះត៍ដែលអល់ឡោះហ្វ៍ﷻបានដាក់មកត្រូវផ្លាស់ប្ដូរ ។ ឧទហរណ៍ ស្វរ៉េះត៍ អាល់-ហ្វាទីហ៊ាស់ សព្វថ្ងៃនេះមានលំដាប់លេខរៀងទីមួយ តែយោលតាមលំដាប់លេខរៀងដែលអល់ឡោះហ្វ៍ﷻដាក់ចុះមកនោះ មានលំដាប់លេខរៀងទី ៥ ។ រីឯស្វរ៉េះត៍ អាល់-អ៊ុឡាក្វ ដែលអល់ឡោះហ្វ៍ﷻបានដាក់ចុះមកមុនគេនោះ ទៅជាមានលំដាប់លេខរៀងទី ៩៦ វិញ ។[132]

## សំណួរ ១៧ - តើស្ហ៊ីអ៊ុាស់យល់ឃើញយ៉ាងណាអំពីស្វ៍ហាបាស់(الصحابة) សាវករបស់ព្រះសាស្ដាﷺ ?

## ចម្លើយ

យោលតាមស្ហ៊ីអ៊ុាស់ អ្នកដែលមានកិត្តិយសបានជួបនិងបាននៅអបអម

[132] កំណត់ហេតុរបស់អ្នកបកប្រែ ។

ព្រះសាស្តាﷺនោះចែកជាពីរក្រុម ។ មុននឹងអធិប្បាយបំភ្លឺរឿងនេះ គប្បីដឹងថាតើពាក្យ "ស្វ៊ហ្ហាបាស្ង" មានន័យថាអ្វី ។

ពាក្យថា "សាវក" របស់ព្រះសាស្តាﷺ មានអត្ថន័យផ្សេងៗ គឺ៖

១- លោក សាអ៊ីដ្ធ អ៊ីបនូ មូសៃយីប (سعيد بن المسيب) មានប្រសាសន៍ថា៖ "សាវក (ស្វ៊ហ្ហាបាស្ង) គឺបុគ្គលដែល បាននៅជុំជាមួយព្រះសាស្តាﷺ មួយឬពីរឆ្នាំ បានចូលរួមធ្វើសង្គ្រាមនៅខាងព្រះអង្គﷺក្នុងពីរឬបីសមរភូមិ ។" [133]

២- លោក អាល់-វ៉ាគីឌី (الواقدي) មានប្រសាសន៍ថា៖ "អស់លោកអ្នកប្រាជ្ញបានថ្លែងថាអ្នកណាដែលបានឃើញព្រះសាស្តាﷺ ដែលបានរិះគិតអំពីសាសនា ដែលបានកាន់សាសនាអ៊ីស្លាម សម្រាប់យើង អស់ទាំងអ្នកនោះជាសាវករបស់ព្រះសាស្តាﷺ ទោះបីពួកគេបានជួបព្រះអង្គﷺតែមួយម៉ោងក៏ដោយ ។" [134]

៣- លោក មូហាំម៉ាដ្ធ អ៊ីបនូ អ៊ីសម៉ាអ៊ីល អាល់-ប៊ូខ៉រី (محمد بن إسماعيل البخاري) មានប្រសាសន៍ថា៖ "មុស្លីមណាក៏ដោយដែលបាននៅជុំជាមួយព្រះសាស្តាﷺ ឬដែលបានឃើញព្រះអង្គﷺ ត្រូវចាត់ទុកជាសាវក ។" [135]

[133] សូមមើលសៀវភៅ *អ៊ុសដ្ធ អាល់-ក៏ាបាស្ង ( أسد الغابة)* ជុំទី ១ ទំព័រ ១១-១២ បោះពុម្ពនៅប្រទេសអេស៊ីបត៍ ។

[134] សូមមើលសៀវភៅ *អ៊ុសដ្ធ អាល់-ក៏ាបាស្ង ( أسد الغابة)* ជុំទី ១ ទំព័រ ១១-១២ បោះពុម្ពនៅប្រទេសអេស៊ីបត៍ ។

[135] សូមមើលសៀវភៅ *អ៊ុសដ្ធ អាល់-ក៏ាបាស្ង ( أسد الغابة)* ជុំទី ១ ទំព័រ ១១-១២ បោះពុម្ពនៅប្រទេសអេស៊ីបត៍ ។



បាននោះទេ ថែមទាំង ដោយយកតម្រាប់តាមព្រះសាស្តាﷺដែរនោះ អាចពន្យារស្វ៊ឡាត្ធ៉ម៉ាក់រីប ហើយអាចស្វ៊ឡាត្ធ៉ម៉ាក់រីបនោះជាមួយអ៊ីស្ហាអ៊ុ ក្នុងពេលវេលារបស់អ៊ីស្ហាអ៊ុបានដែរ ។

១៤. លោក អាល់-ប៊ូខ៉រី បានសរសេរនៅក្នុងស្វ៊ហ៊ិះហ្ហ៍របស់លោកដែរថា៖

«قال ابن عمر وأبو أيّوب وابن عبّاس رضي الله عنهم: صلّى النّبيّ صلّى الله عليه (وآله) وسلّم المغرب والعشاء»

*"អាប់ឌុលឡោះហ៍ អ៊ីបនូ អ៊ុម៉ារ, អាប៊ូ អៃយូប និង អ៊ីបនូ អាល់-អាប់បាស់ មានប្រសាសន៍ថា៖ "ព្រះសាស្តាﷺបានស្វ៊ឡាត្ធ៉ម៉ាក់រីបនិងអ៊ីស្ហាអ៊ុ [ជាមួយគ្នាដោយមិនទុកចន្លោះពេល] ។"*[234]

លោក អាល់-ប៊ូខ៉រី បានលើកហាឌីស្ហមួយនេះមកអធិប្បាយថាព្រះសាស្តាﷺបានស្វ៊ឡាត្ធ៉ម៉ាក់រីបនិងអ៊ីស្ហាអ៊ុ ជាមួយគ្នាដោយមិនទុកចន្លោះពេល ។ ច្បាស់ណាស់ ព្រះអង្គﷺមិនដែលព្រងើយកន្តើយរឿងស្វ៊ឡាត្ធ៉ឡើយ ។

១៥. លោក មុស្លីម អ៊ីបនូ អាល់-ហ្ហាច្ជ៉យ៉ាច្ជ៉ បានសរសេរនៅក្នុងស្វ៊ហ៊ិះហ្ហ៍លោកថា៖

«قال رجلٌ لابن عبّاس الصلوة فسكت ثمّ قال الصّلوة فسكت ثمّ قال الصّلوة فسكت، ثمّ قال: لا امّ لك أتعلّمنا بالصّلوة وكنّا نجمع بين الصّلاتين على عهد رسول الله – صلّى الله عليه (وآله) وسلّم»

*"គេបានប្រាប់អ៊ីបនូ អាល់-អាប់បាស់ [ពេលលោកពន្យារស្វ៊ឡាត្ធ៉] ថា៖*

[234] សូមមើលសៀវភៅ *ស្វ៊ហ៊ិះហ្ហ៍ អាល់-ប៊ូខ៉រី* (បោះពុម្ពនៅប្រទេសអេស៊ីបត៍ ដោយរោងពុម្ព អាមីរីយ៉ាស្ង ឆ្នាំ 1314 ស.ហ.) "បាប់ អាស្វ-ស្វ៊ឡាត្ធ៉" ជុំទី ១ ទំព័រ ១១៣ វគ្គស្តីអំពីស្វ៊ឡាត្ធ៉អ៊ីស្ហាអ៊ុ ។

១៣. លោក អាប៊ូ អ៊ុប់ឌុលឡោះហ្ម៍ អាល់-ប៊ូខ៊ំរី បានទុកមួយចំពូកពិសេសដែលស្តីអំពីរឿងនេះ នៅក្នុងស្វ័ហ៊ិះហ្ម៍របស់លោក ក្រោមចំណងជើងថា "بابُ تأخيرِ الظُّهر الى الْعَصْرِ ការពន្យារស្វ័ឡាត់ស្ញូហ្វ៊ូរលុះដល់ស្វ័ឡាត់អ៊ុស្វូរ" [232] ដែលជាភ័ស្តុតាងមាំមួនបញ្ជាក់ថាគេអាចពន្យារស្វ័ឡាត់ស្ញូហ្វ៊ូរទៅស្វ័ឡាត់ជាមួយអ៊ុស្វូរ មុនពេលវេលាដាច់មុខរបស់ស្វ័ឡាត់អ៊ុស្វូរបាន ។ លោក អាល់-ប៊ូខ៊ំរី បានលើកឡើងនូវហាឌីស្ហដូចតទៅគឺ៖

«إنّ النّبيّ – صلّى الله عليه (وآله) وسلّم – صلّى بالمدينة سبعاً وثمانياً، الظّهر والعصر، والمغرب والعِشاء»

*"ព្រះសាស្តាﷺអល់ឡោះហ្ម៍﷿បានស្វ័ឡាត់ ជាបន្តបន្ទាប់គ្នាប្រាំបីរ៉ក់អ៊ាត់ស្ញូហ្វ៊ូរនិងអ៊ុស្វូរ បានស្វ័ឡាត់ប្រាំពីររ៉ក់អ៊ាត់ម៉ាក់រីបនិងអ៊ីស្ហាអ៍ នៅឯម៉ាឌីណាស្ហ ។"*[233]

ហាឌីស្ហនេះបង្ហាញឲ្យឃើញថា គេមិនត្រឹមតែអាចពន្យារស្វ័ឡាត់ស្ញូហ្វ៊ូរ ហើយអាចស្វ័ឡាត់ស្ញូហ្វ៊ូរនោះ ជាមួយអ៊ុស្វូរក្នុងពេលវេលារបស់អ៊ុស្វូរ

(ប្រែជាភាសាអង្គ្លេស) ជុំទី ១ កណ្ឌ ១០០ វគ្គស្តីអំពីការផ្តុំស្វ័ឡាត់នៅផ្ទះ កណ្ឌទី ៤ ហាឌីស្ហ ១៥២០ ។

[232] សូមមើលសៀវភៅ ស្វ័ហ៊ិះហ្ម៍ អាល់-ប៊ូខ៊ំរី (បោះពុម្ពនៅប្រទេសអេស៊ីបត៍ ដោយរោងពុម្ព អាមីរីយ៉ាស្ហ ឆ្នាំ 1314 ស.ហ.) "បាប់ អាស្វ-ស្វ័ឡាត់" "بابُ تأخيرِ الظُّهر الى الْعَصْرِ" ជុំទី ១ ទំព័រ ១១០ ។

[233] សូមមើលសៀវភៅ *ស្វ័ហ៊ិះហ្ម៍ អាល់-ប៊ូខ៊ំរី* (បោះពុម្ពនៅប្រទេសអេស៊ីបត៍ ដោយរោងពុម្ព អាមីរីយ៉ាស្ហ ឆ្នាំ 1314 ស.ហ.) "បាប់ អាស្វ-ស្វ័ឡាត់" "بابُ تأخيرِ الظُّهر الى الْعَصْرِ" ជុំទី ១ ទំព័រ ១១០ ។ សូមមើល *ស្វ័ហ៊ិះហ្ម៍ អាល់-ប៊ូខ៊ំរី* (ប្រែជាភាសាអង្គ្លេស) របស់លោក មូហាំម៉ាដ្ហ មុះហ្ម៍ស៊ីន ខាន ជុំទី ១ កណ្ឌ ១០ ហាឌីស្ហ ៥១៨ ។



៤- លោក អាស្ហ៊ម៉ាដ្ហ អ៊ីបនូ ហាន់បាល់ (أحمد بن حنبل) មានប្រសាសន៍ថា៖ "អ្នកណាក៏ដោយដែលបាននៅជុំ ជាមួយព្រះសាស្តាﷺមួយខែ មួយថ្ងៃ មួយម៉ោង ឬគ្រាន់តែបានឃើញព្រះអង្គﷺ អ្នកនោះនៅក្នុងចំណោមសាវក ។" [136]

សម្រាប់អស់លោកអ្នកប្រាជ្ញស៊ុននី ទទួលស្គាល់ "ភាពត្រឹមត្រូវរបស់សាវក" ជាលក្ខខ័ណ្ឌឥតប្រកែកបាន ។ អ្នកណាក៏ដោយដែលគេទទួលស្គាល់ថាជាសាវករបស់ព្រះសាស្តាﷺ អ្នកនោះត្រូវចាត់ទុកថាត្រឹមត្រូវ ។ [137]

ដោយផ្អែកលើគួរអាន យើងនឹងវិភាគរឿងនេះ ហើយនឹងលើកយកមតិស្ហ៊ីអ៊ុស្ហដែលហូរចេញមកពីការសមហេតុផលនៃព្រះប្រកាសនា (តាមអ្វីដែលអល់ឡោះហ្ម៍﷿បើកដឹង) ។

នៅក្នុងប្រវត្តិសាស្ត្រឃើញមានឈ្មោះសាវកព្រះសាស្តាﷺលើសពី ១២ ០០០ នៅក្នុងចំណោមឈ្មោះទាំង មានបុគ្គលគ្រប់ប្រភេទ ។

ពិតមែន នៅជុំជាមួយព្រះសាស្តាﷺ ជាកិត្តយសធំមួយ ។ អ្នកណាដែលបានទទួលកិត្តិយសនេះ សហាគមន៍មុស្លីមគោរពអ្នកនោះ ព្រោះអ្នកនោះជាបុគ្គលមុខគេហើយបានលើកទង់ជ័យអ៊ីស្លាម ។

[136] សូមមើលសៀវភៅ *អ៊ុសដ្ហ៍ អាល់-ក៊ំបាស្ហ* (أسد الغابة) ជុំទី ១ ទំព័រ ១១-១២ បោះពុម្ពនៅប្រទេសអេស៊ីបត៍ ។

[137] សូមមើលសៀវភៅ *អាល់-អ៊ីសទីអ៊ាប់ ហ្វី អ៊ីសម៉ាអ៍ អាល់-អាស្វហាប់ (الإستيعاب في أسماء الأصحاب)* ជុំទី ១ ទំព័រ ២ នៅរឹម ដើមទំព័រ "អាល់-អ៊ីស្វ័បាស្ហ (الإصَابة)" ។ សូមមើលសៀវភៅ *អ៊ុសដ្ហ៍ អាល់-ក៊ំបាស្ហ* (أسد الغابة) ជុំទី ១ ទំព័រ ៣ បោះពុម្ពនៅប្រទេសអេស៊ីបត៍ រាយការណ៍ដោយលោក អ៊ីបនូ អាស្ទៀរ ។

ព្រះគម្ពីរគួរអានលើកតម្កើងបក្សពួកដំបូងទាំងនេះរបស់អ៊ីស្លាមថា៖

لَا يَسْتَوِى مِنكُم مَّنْ أَنفَقَ مِن قَبْلِ ٱلْفَتْحِ وَقَـٰتَلَ ۚ أُو۟لَـٰٓئِكَ أَعْظَمُ دَرَجَةً مِّنَ ٱلَّذِينَ أَنفَقُوا۟ مِنۢ بَعْدُ وَقَـٰتَلُوا۟ ۚ

*"ពួកគេ [ដែលមិនបរិច្ចាគនិងមិនប្រយុទ្ធនោះ] មិនស្មើពួកអ្នកទេដែលបរិច្ចាគទ្រព្យមុនជ័យជំនះនិងប្រយុទ្ធ [លើមាគ៌ាអល់ឡោះហ្ទ៍]។ ជនទាំងនេះមានឋានន្តរស័ក្តិខ្ពង់ខ្ពស់លើសគេ ជាងជនទាំងឡាយដែលបរិច្ចាគនិងប្រយុទ្ធពេលក្រោយ (៥៧:១០)។"*[138]

ក៏ប៉ុន្តែ ត្រូវទទួលស្គាល់ថាការបាននៅជុំជាមួយព្រះសាស្ដាﷺនោះមិនមែនជាឱកាសកែខ្លួនសម្រាប់ពួកគេទាំងអស់ទេ ដែលធានាថាពួកគេមានសទ្ធាជ្រះថ្លាមួយជីវិត ហើយធ្វើឲ្យពួកគេបាននៅក្នុងលំដាប់ថ្នាក់បុគ្គលត្រឹមត្រូវជាស្វ័យប្រវត្តនោះ។

ដើម្បីអធិប្បាយបំភ្លឺចំណុចនេះ ចាំបាច់ផ្អែកលើគួរអានជាចម្បងដែលមុស្លីមទាំងអស់ទទួលស្គាល់ ហើយប្រវាទៅរកដើម្បីដោះស្រាយបញ្ហានេះ។

## "សាវក" តាមទស្សនៈគួរអាន

យោលតាមខ្លឹមសារព្រះប្រកាសនា (គឺតាមព្រះបន្ទូលអល់ឡោះហ្ទ៍عزوجل) បណ្ដាអ្នកដែលមានកិត្តិយស បានរស់នៅជុំជាមួយព្រះសាស្ដាﷺហើយបានជួបព្រះអង្គﷺនោះមានពីរក្រុមគឺ៖

[138] ស៊ូរ៉ោះត៍ អាល់-ហាឌីដ 57:10 ។



១២. លោក មុស្លីម បានរាយការណ៍តមកពីលោក អាប៊ូ ស៊្ហូបៃរ៍ តមកពីលោក សាអ៊ីដ អ៊ីបនូ យ៉ូបៃរ៍ តមកពីលោក អាល់-អាប់បាស់ នៅក្នុងស្ហ៊ហ៊ិះហ្វ៍លោកថា៖

«جمع رسول الله – صلّى الله عليه (وآله) وسلّم – بين الظّهر والعصر، والمغرب والعشاء في المدينة، من غير خوفٍ ولامطرٍ»

*"ព្រះសាស្ដាﷺអល់ឡោះហ្ទ៍عزوجلបានស្ហ៊ឡាត់ស្ហ៊ហ្ទ៍រ និងអ៊ុស្ហរជាមួយគ្នា ស្ហ៊ឡាត់ម៉ាក់រីបនិងអ៊ីស្ហាអ៍ជាមួយគ្នានៅឯម៉ាឌីណាស់ ដោយមិនទុកចន្លោះពេល ថ្វីដ្បិតតែព្រះអង្គﷺមិននៅក្នុងស្ថានការណ៍គ្រោះថ្នាក់ឬខ្លាចភ្លៀងទេក៏ដោយ។"*[230]

លោក សាអ៊ីដ អ៊ីបនូ យ៉ូបៃរ៍ មានប្រសាសន៍ថា៖ "ខ្ញុំបានសួរលោក អាល់-អាប់បាស់ ថាហេតុអ្វីព្រះសាស្ដាﷺធ្វើដូច្នេះ?" លោក អ៊ីបនូ អាល់-អាប់បាស់ បានឆ្លើយថា៖ "ព្រះអង្គﷺមិនចង់ឲ្យអ្នកណាមួយក្នុងអ៊ុមម៉ាត់ព្រះអង្គﷺនោះលំបាកលំបិនទេ។"[231]

របស់លោក អ៊ុប់ឌុល ហាមីដ ស្ហីដ្ឌីគី (ប្រែជាភាសាអង្គ្លេស)។ សូមមើលស្ហ៊ហ៊ិះហ្វ៍ មុស្លីម (ប្រែជាភាសាអង្គ្លេស) ជុំទី ១ កណ្ឌ ១០០ វគ្គស្ដីអំពីការផ្គុំស្ហ៊ឡាត់នៅផ្ទះ កណ្ឌទី ៤ ហាឌីស្ហ ១៥១៦។

[230] សូមមើលសៀវភៅ *ស្ហ៊ហ៊ិះហ្វ៍ មុស្លីម* (បោះពុម្ពនៅអេស៊ីបត៍) ជុំទី ២ "គីតាប អាស្ហ៍-ស្ហ៊ឡាត់" វគ្គស្ដីអំពីស្ហ៊ឡាត់ផ្គុំនៅផ្ទះ ទំព័រ ១៥២។ សូមមើលសៀវភៅរបស់លោក អ៊ុប់ឌុល ហាមីដ ស្ហីដ្ឌីគី (ប្រែជាភាសាអង្គ្លេស)។ សូមមើលស្ហ៊ហ៊ិះហ្វ៍ មុស្លីម (ប្រែជាភាសាអង្គ្លេស) ជុំទី ១ កណ្ឌ ១០០ វគ្គស្ដីអំពីការផ្គុំស្ហ៊ឡាត់នៅផ្ទះ កណ្ឌទី ៤ ហាឌីស្ហ ១៥២០។

[231] សូមមើលសៀវភៅ *ស្ហ៊ហ៊ិះហ្វ៍ មុស្លីម* (បោះពុម្ពនៅអេស៊ីបត៍) ជុំទី ២ "គីតាប អាស្ហ៍-ស្ហ៊ឡាត់" វគ្គស្ដីអំពីស្ហ៊ឡាត់ផ្គុំនៅផ្ទះ ទំព័រ ១៥២។ សូមមើលសៀវភៅរបស់លោក អ៊ុប់ឌុល ហាមីដ ស្ហីដ្ឌីគី (ប្រែជាភាសាអង្គ្លេស) *ស្ហ៊ហ៊ិះហ្វ៍ មុស្លីម*

*រឿងនេះ ព្រះអង្គ ﷺ មានព្រះវចនៈថា៖ "ខ្ញុំមិនចង់ឲ្យអ៊ុមម៉ាត់ខ្ញុំលំបាកដោយឥតប្រយោជន៍ទេ ។"*[227]

១១. លោក មុស្លីម អ៊ីបនូ អាល់-ហាជ្ជ៉ាជ្ជ៉បានរាយការណ៍តមកពីលោក អាប៊ូ ស្សូបៃរ៍ ដែលបានរាយការណ៍តមកពីលោក សាអ៊ីដ្ជ អ៊ីបនូ យូបៃរ៍ តមកពីលោក អ៊ីបនូ អាប់បាស់ថា៖

«صلّى رسول الله – صلّى الله عليه (وآله) وسلّم – الظّهر والعصر جميعاً بالمدينة في غير خوفٍ ولا سفر»

*"ព្រះសាស្ដា ﷺ អល់ឡោះហ៊ូ عز وجل បានស្វ៊ឡាត់ស្សូហ៊្វរ និងអាស្សរជាមួយគ្នាដោយមិនទុកចន្លោះពេលវេលានៅម៉ាឌីណាស់ ថ្វីដ្បិតតែព្រះអង្គ ﷺ មិននៅក្នុងស្ថានភាពភ័យខ្លាចសត្រូវឬនៅក្នុងការធ្វើដំណើរទេក៏ដោយ ។"*[228]

លោក អាប៊ូ ស្សូបៃរ៍ មានប្រសាសន៍ថា៖ "ខ្ញុំបានសួរលោកសាអ៊ីដ្ជថាហេតុអ្វីព្រះសាស្ដា ﷺ ធ្វើដូច្នេះ ។" លោកបានតបថា៖ "ខ្ញុំបានសួរលោកអ៊ីបនូ អាប់បាស់អំពីរឿងនេះ លោកបានឆ្លើយថា[ព្រះសាស្ដា ﷺ]មិនចង់ឲ្យអ៊ុមម៉ាត់ព្រះអង្គ ﷺ លំបាកលំបិនទេ ។" [229]

---

[227] សូមមើលសៀវភៅរបស់លោក មូហាំម៉ាដ្ជ អាស់-ស្សារក៏នី *ស្សារហ៍ មូវ៉ាត្តអ៍ ម៉ាលិក (شرح موطأ مالك)* (បោះពុម្ពនៅអេស៊ីបត៍) ដុំទី ១ "វគ្គស្ដីអំពីស្វ៊ឡាត់ផ្តុំនៅផ្ទះ និងក្នុងពេលធ្វើដំណើរ" ទំព័រ ២៩៤ ។

[228] សូមមើលសៀវភៅ *ស្វ៊ហ៊ិះហ៍ មុស្លីម* (បោះពុម្ពនៅអេស៊ីបត៍) ដុំទី ២ "គីតាប អាស្វ-ស្វ៊ឡាត់" វគ្គស្ដីអំពីស្វ៊ឡាត់ផ្តុំនៅ ផ្ទះ ទំព័រ ១៥១ ។ សូមមើលសៀវភៅរបស់លោក អាប់ឌុល ហាមីដ្ជ ស្ស៊ីដ្ឌីគី (ប្រែជាភាសាអង្គ្លេស) *ស្វ៊ហ៊ិះហ៍ មុស្លីម* (ប្រែជាភាសាអង្គ្លេស) ដុំទី ១ កណ្ឌ ១០០ វគ្គស្ដីអំពីការផ្តុំស្វ៊ឡាត់នៅផ្ទះ កណ្ឌទី ៤ ហាឌីស្ស ១៥១៦ ។

[229] សូមមើលសៀវភៅ *ស្វ៊ហ៊ិះហ៍ មុស្លីម* (បោះពុម្ពនៅអេស៊ីបត៍) ដុំទី ២ "គីតាប អាស្វ-ស្វ៊ឡាត់" វគ្គស្ដីអំពីស្វ៊ឡាត់ផ្តុំនៅ ផ្ទះ ទំព័រ ១៥១ ។ សូមមើលសៀវភៅ



# ក្រុមទីមួយ

ក្រុមទីមួយគឺបណ្ដាអ្នក ដែលអាយ៉ាស់អមតៈគួរអានសរសើរនិងលើកស្ទួយ ហើយដែលគួរអានបង្ហាញថាជាអ្នកចាក់គ្រឹះថ្មីថ្កើងរបស់អ៊ីស្លាម ។ អាយ៉ាស់ព្រះគម្ពីរខាងក្រោមនេះថៃងអំពីបណ្ដាសាវកក្រុមនេះគឺ៖

## ១- អ្នកមុនគេ

وَٱلسَّـٰبِقُونَ ٱلْأَوَّلُونَ مِنَ ٱلْمُهَـٰجِرِينَ وَٱلْأَنصَارِ وَٱلَّذِينَ ٱتَّبَعُوهُم بِإِحْسَـٰنٍ رَّضِىَ ٱللَّهُ عَنْهُمْ وَرَضُوا۟ عَنْهُ وَأَعَدَّ لَهُمْ جَنَّـٰتٍ تَجْرِى تَحْتَهَا ٱلْأَنْهَـٰرُ خَـٰلِدِينَ فِيهَآ أَبَدًا ۚ ذَٰلِكَ ٱلْفَوْزُ ٱلْعَظِيمُ

*"បណ្ដាជនដំបូងបង្អស់ក្នុងចំណោមជនភៀសខ្លួន និងបណ្ដាអ្នកជួយជ្រោមជ្រែង និងបណ្ដាជនដែលបានតាមពួកគេក្នុងការប្រព្រឹត្តិល្អ អល់ឡោះហ៍ទ្រង់សព្វព្រះហឫទ័យពួកគេ ហើយពួកគេក៏ស្រឡាញ់ព្រះអង្គដែរ ។ ព្រះអង្គបានត្រៀមទុកនូវសួនសួគ៌ទាំងឡាយសម្រាប់ពួកគេដែលមានស្ទឹងហូរនៅខាងក្រោម ពួកគេនឹងនៅក្នុងនោះជានិច្ចអនន្ត ។ នេះជាជ័យជំនះដ៏ធំមហិមា (៩:១០០) ។"*[139]

## ២- បណ្ដាអ្នកដែលបានធ្វើកិច្ចសន្យានៅក្រោមដើមឈើ

لَّقَدْ رَضِىَ ٱللَّهُ عَنِ ٱلْمُؤْمِنِينَ إِذْ يُبَايِعُونَكَ تَحْتَ ٱلشَّجَرَةِ فَعَلِمَ مَا فِى قُلُوبِهِمْ فَأَنزَلَ ٱلسَّكِينَةَ عَلَيْهِمْ وَأَثَـٰبَهُمْ فَتْحًا قَرِيبًا

*"ពិតណាស់ អល់ឡោះហ៍សព្វព្រះហឫទ័យអ្នកមានសទ្ធាជ្រះថ្លាទាំងឡាយ កាលពួកគេបានសច្ចាស្មោះស្ម័គ្រចំពោះអ្នកនៅក្រោមដើម*

---

[139] ស៊ូរ៉ោះត៍ អាត់-តៅបាស់ 9:100 ។

*ឈើ ។ ព្រះអង្គទ្រង់ញាណនូវអ្វីដែលមាននៅក្នុងចិត្តពួកគេ ។ ដូច្នេះព្រះអង្គបានប្រទានសេចក្ដីស្ងប់មកលើពួកគេ ហើយបានតបស្នងពួកគេដោយជ័យជំនះដ៏ជិតមួយ ។"*[140]

៣- អ្នកភៀសខ្លួន (មូហ្ហាយ៉ីរីន)

لِلۡفُقَرَآءِ ٱلۡمُهَٰجِرِينَ ٱلَّذِينَ أُخۡرِجُواْ مِن دِيَٰرِهِمۡ وَأَمۡوَٰلِهِمۡ يَبۡتَغُونَ فَضۡلٗا مِّنَ ٱللَّهِ وَرِضۡوَٰنٗا وَيَنصُرُونَ ٱللَّهَ وَرَسُولَهُۥٓۚ أُوْلَٰٓئِكَ هُمُ ٱلصَّٰدِقُونَ

*"[ទ្រព្យដែលបានមកពីសត្រូវជា]របស់ជនភៀសខ្លួនទ័លក្រដែលត្រូវគេបណ្ដេញចេញពីទីលំនៅ ហើយត្រូវគេដកហូតទ្រព្យពេលពួកគេស្វែងរកព្រះឧបការគុណនិងសេចក្ដីគាប់ព្រះហឫទ័យរបស់អល់ឡោះហ៍ ហើយពួកគេបានគាំទ្រ[មូលហេតុ]អល់ឡោះហ៍និងព្រះសាស្ដាព្រះអង្គ ។ ជនទាំងនោះជាអ្នកសច្ចៈទៀងត្រង់ (៥៩:៨) ។"*[141]

៤- មិត្តរួមសមរភូមិ

مُّحَمَّدٞ رَّسُولُ ٱللَّهِۚ وَٱلَّذِينَ مَعَهُۥٓ أَشِدَّآءُ عَلَى ٱلۡكُفَّارِ رُحَمَآءُ بَيۡنَهُمۡۖ تَرَىٰهُمۡ رُكَّعٗا سُجَّدٗا يَبۡتَغُونَ فَضۡلٗا مِّنَ ٱللَّهِ وَرِضۡوَٰنٗاۖ سِيمَاهُمۡ فِي وُجُوهِهِم مِّنۡ أَثَرِ ٱلسُّجُودِۚ

*"មូហ៊ាំម៉ាដ់ជាព្រះសាស្ដារបស់អល់ឡោះហ៍ ជនទាំងឡាយដែលតាមគេរមែងមានចិត្តតឹងរ៉ឹងចំពោះពួកបដិសេធនិងអាណិតអាសូរគ្នាឯង ។ អ្នកនឹងឃើញពួកគេលំឱនកាយក្រាបប្រណិប័តន៍ ស្វែងរកព្រះគុណអល់ឡោះហ៍និងសេចក្ដីគាប់ព្រះហឫទ័យ ។ សញ្ញាសំគាល់របស់ពួកគេនៅលើមុខពួកគេដោយសារការក្រាបប្រណិប័តន៍ (៤៨:២៩) ។"*[142]

[140] ស៊ូរ៉ោះត៊ អាល់-ហ្វាត់ហ៊ 48:18 ។

[141] ស៊ូរ៉ោះត៊ អាល់-ហ៊ាស្ស៊ើរ 59:8 ។

[142] ស៊ូរ៉ោះត៊ អាល់-ហ្វាត់ហ៊ 48:29 ។



*ស្ហ៊ូហ្រ៊ និងអ៊ុាស្វារដោយមិនទុកចន្លោះពេលវេលា រាល់ពេលព្រះអង្គចង់ធ្វើដំណើរពេលយប់ ព្រះអង្គﷺស៊ឡាត៊ម៉ាក់រីបនិងអ៊ីស្ហាអ៊ដោយមិនទុកចន្លោះពេលវេលា ។"*[225]

៩. លោក មូហ៊ាំម៉ាដ់ អាស់-ស្ហារក៊ូនី បានរាយការណ៍ហ៊ាឌីស្ហនេះនៅក្នុងសៀវភៅលោក ស្ហារហ៊ មូវ៉ាត់ត៊អ៊ តមកពីអាប៊ូ ស្ហាក់ស្ហាអ៊ថា៖

«إنّ بن عباس صلّى بالبصرة الظّهر والعصر ليس بينهما شيءٌ والمغرب والعِشاء ليس بينهما شيءٌ»

*"នៅឯស្រុកបាស់រ៉ោះត៊ [អ៊ុាប់ឌុលឡោះហ៍] អ៊ីបនូ អ៊ុាប់បាស់ បានស៊ឡាត៊ស្ហ៊ូហ្រ៊និងអ៊ុាស្វារជាមួយគ្នា ដោយមិនទុកចន្លោះពេលវេលារវាងទាំងពីរស៊ឡាត៊នេះ បានស៊ឡាត៊ម៉ាក់រីបនិងអ៊ីស្ហាអ៊ជាមួយគ្នាដោយមិនទុកចន្លោះពេលវេលារវាងទាំងពីរស៊ឡាត៊នេះ ។"*[226]

១០. លោកស្ហារក៊ូនីបានរាយការណ៍តមកពីលោកត៊ូបារ៉នី ដែលបានរាយការណ៍តមកពីលោកអ៊ីបនូ ម៉ាស់អ៊ូដ ថា៖

«جَمَعَ النَّبِيُ صلى الله عليه (وآله) وسلّم بين الظّهر والعصر وبين المغرب والعشاء. فقال: صنعت هذا لئلاّ تحرج أمّتي»

*"ព្រះសាស្ដាﷺអល់ឡោះហ៍ عز وجل បានស៊ឡាត៊ស្ហ៊ូហ្រ៊ និងអ៊ុាស្វារជាមួយគ្នា បានស៊ឡាត៊ម៉ាក់រីបនិងអ៊ីស្ហាអ៊ជាមួយគ្នា ។ ពេលគេសួរព្រះអង្គﷺអំពី*

[225] សូមមើលសៀវភៅរបស់លោក ម៉ាលិក អ៊ីបនូ អាណាស់ *អាល់-មូវ៉ាត់ត៊អ៊* (បោះពុម្ពលើកទី ៣ នៅបៃរូត ហ.ស 1403) "គីតាប អាស្ស៊-ស៊ឡាស៊" ទំព័រ ១២៥ ហ៊ាឌីស្ហ ១៨១ ។

[226] សូមមើលសៀវភៅរបស់លោក មូហ៊ាំម៉ាដ់ អាស់-ស្ហារក៊ូនី *ស្ហារហ៊ មូវ៉ាត់ត៊អ៊ ម៉ាលិក (شرح موطأ مالك)* (បោះពុម្ពនៅអេស៊ីបត៍) ជុំទី ១ "វគ្គស្ដីអំពីស៊ឡាត៊ផ្ដុំនៅផ្ទះ និងក្នុងពេលធ្វើដំណើរ" ទំព័រ ២៩៤ ។

អាប៊ូ ហ្ស៊ូរ៉យ់ពោះត្តុំថា៖

«إن رسول الله – صلّى الله عليه (وآله) وسلّم – كان يجمع بين الظّهر والعصر في سفره الى تبوك»

*"ព្រះសាស្តាﷺអល់ឡោះហ្ ﷻបានស្ញ៉ូឡាត្តុំម៉ាក្កុំរីប និងអ៊ីស្ហាអ៊ុំជាមួយគ្នា ដោយមិនទុកចន្លោះពេលវេលា កាលព្រះអង្គﷺធ្វើដំណើរទៅតាប៊ុក ។"* [223]

៧. លោក ម៉ាលិក អ៊ីបនូ អាណាស់ បានរាយការណ៍ហាឌីស្សនេះតមកពី ណាហ្វីអ៊ុំថា៖

«إنّ عبد الله بن عمر كان إذا جمع الامراء بين الغرب والعشاء في المطر جمع معهم»

*"កាលពួកគេមេដឹកនាំស្ញ៉ូឡាត្តុំម៉ាក្កុំរីបនិងអ៊ីស្ហាអ៊ុំជាមួយគ្នា ដោយមិនទុកចន្លោះពេលវេលា កណ្តាលភ្លៀង អាប់ឌុលឡោះហ្ អ៊ីបនូ អ៊ូម៉ារក៏បានស្ញ៉ូឡាត្តុំដូចនេះដែរ ។"* [224]

៨ លោក ម៉ាលិក អ៊ីបនូ អាណាស់ បានរាយការណ៍តមកពី អាលី អ៊ីបនូ អាល់-ហ៊ូសៃន៍ ថា៖

«كان رسول الله – صلّى الله عليه (وآله) وسلّم – إذا أراد أن يسير يومه جمع بين الظّهر والعصر وإذا أراد أن يسير ليله جمع بين المغرب والعشاء»

*"រាល់ពេលដែលព្រះសាស្តាﷺចង់ធ្វើដំណើរពេលថ្ងៃ ព្រះអង្គﷺស្ញ៉ូឡាត្តុំ*

[223] សូមមើលសៀវភៅរបស់លោក ម៉ាលិក អ៊ីបនូ អាណាស់ *អាល់-មូវ៉ាត្តត៉ូអ៊ុំ* (បោះពុម្ពលើកទី ៣ នៅបៃរូត ហ.ស 1403) "គីតាប អាស្ស៊ូ-ស្ញ៉ូឡាស្ស៊ុំ" ទំព័រ ១២៤ ហាឌីស្ស ១៧៥ ។

[224] សូមមើលសៀវភៅរបស់លោក ម៉ាលិក អ៊ីបនូ អាណាស់ *អាល់-មូវ៉ាត្តត៉ូអ៊ុំ* (បោះពុម្ពលើកទី ៣ នៅបៃរូត ហ.ស 1403) "គីតាប អាស្ស៊ូ-ស្ញ៉ូឡាស្ស៊ុំ" ទំព័រ ១២៥ ហាឌីស្ស ១៧៩ ។



## ក្រុមទីពីរ

ក្រុមមនុស្សមួយទៀត ដែលបានស្គាល់ព្រះសាស្តាﷺនោះគឺពួកមនុស្សមុខពីរ ចិត្តអាក្រក់ ដែលគួរអានបើក ឲ្យស្គាល់ចរិតគ្រោះថ្នាក់ហើយបានប្រាប់ព្រះសាសាﷺឲ្យដឹង ។

នេះគឺអាយ៉ាស្សុំខ្លះដែលថែងអំពីមនុស្សក្រុមនេះ ។

១- ពួកលាក់ពុតត្បុតបើកមុខ

إِذَا جَآءَكَ ٱلْمُنَٰفِقُونَ قَالُوا۟ نَشْهَدُ إِنَّكَ لَرَسُولُ ٱللَّهِ ۗ وَٱللَّهُ يَعْلَمُ إِنَّكَ لَرَسُولُهُۥ وَٱللَّهُ يَشْهَدُ إِنَّ ٱلْمُنَٰفِقِينَ لَكَٰذِبُونَ

*"ពេលពួកលាក់ពុតមករកអ្នក ពួកគេថា៖ "យើងខ្ញុំសូមប្តេជ្ញាថាលោកជាសាស្តារបស់អល់ឡោះហ្មែន" [តែសំដីទាំងនេះពុំមែនសំដីដែលចេញពីក្នុងចិត្តពួកគេទេ] ។ អល់ឡោះហ្ទ្រង់ញាណ[យ៉ាងពិតប្រាកដ]ថាអ្នកជាសាស្តាព្រះអង្គ ។ អល់ឡោះហ្ជាសាក្សីបញ្ជាក់ថាពួកលាក់ពុតជាមនុស្សកុហកភូតភរ (៦៣:១) ។"* [143]

២- ពួកលាក់ពុតត្បុតបិទមុខ

وَمِمَّنْ حَوْلَكُم مِّنَ ٱلْأَعْرَابِ مُنَٰفِقُونَ ۖ وَمِنْ أَهْلِ ٱلْمَدِينَةِ ۙ مَرَدُوا۟ عَلَى ٱلنِّفَاقِ لَا تَعْلَمُهُمْ ۖ نَحْنُ نَعْلَمُهُمْ ۚ

*"ក្នុងចំណោមចរកជនអារ៉ាប់នៃវាលលំហា (គឺពួកអ៊ុក្រាប) ដែលអបអមពួកអ្នក អ្នកខ្លះជាជនលាក់ពុតនៅក្នុងចំណោមអ្នកស្រុកម៉ាឌីណាស្សុំផង*

[143] ស៊ូរ៉ោះត្តុំ អាល់-មូណាហ្វីគ្គូន 63:1 ។

*ដែរ ។ ពួកគេថ្នឹកក្នុងការលាក់ពុតត្បុត អ្នកមិនស្គាល់ពួកគេទេ [តែ]យើងស្គាល់ពួកគេ (៩:១០១) ។"*[144]

៣- មនុស្សដែលមានជម្ងឺចិត្ត

وَإِذْ يَقُولُ ٱلْمُنَـٰفِقُونَ وَٱلَّذِينَ فِى قُلُوبِهِم مَّرَضٌ مَّا وَعَدَنَا ٱللَّهُ وَرَسُولُهُۥٓ إِلَّا غُرُورًا

*"[ចូរពួកអ្នកនឹកឃើញ]គ្រាដែលពួកលាក់ពុតនិងពួកដែលមានជម្ងឺនៅក្នុងដួងចិត្តបានថា៖ "អល់ឡោះហ្ទ៍និងសាស្តាព្រះអង្គមិនបានសន្យាអ្វីចំពោះយើងក្រៅពីការបោកបញ្ឆោតទេ !" (៣៣:១២)"*[145]

៤- ពួកសាងបាប

وَءَاخَرُونَ ٱعْتَرَفُوا۟ بِذُنُوبِهِمْ خَلَطُوا۟ عَمَلًا صَـٰلِحًا وَءَاخَرَ سَيِّئًا عَسَى ٱللَّهُ أَن يَتُوبَ عَلَيْهِمْ ۚ إِنَّ ٱللَّهَ غَفُورٌ رَّحِيمٌ

*"ជនឯទៀត[ដែលពុំមែនជនលាក់ពុតទេ ពួកគេ]បានទទួលស្គាល់[និងសារភាព]បាបខ្លួន ។ ពួកគេបានលាយឡំអំពើល្អជាមួយអំពើអាក្រក់ចូលគ្នា ។ អល់ឡោះហ្ទ៍អាចបែរមករកពួកគេ[ដោយអាណិតអាសូរពួកគេ] ។ អល់ឡោះហ្ទ៍មានព្រះខន្តីប្រណីទោស ព្រះអង្គមានព្រះមេត្តាករុណាប្រណី (៩:១០២) ។"*[146]

ក្រៅពីអាយ៉ាស់គួរអាន មានហាឌីស្ហច្រើនដែលយើងទទួលបានមកពីព្រះសាស្តាﷺដែលស្តីបន្ទោសសាវកមួយចំនួន ។ ឧទាហរណ៍៖

[144] ស៊ូរ៉ោះត៍ អាត់-តៅបាស់ 9:101 ។

[145] ស៊ូរ៉ោះត៍ អាល់-អាស់ស្ហាប់ 33:12 ។

[146] ស៊ូរ៉ោះត៍ អាត់-តៅបាស់ 9:10២ ។



៤. លោក ម៉ាលិក អ៊ីបនូ អាណាស់ បានថ្លែងហាឌីស្ហនេះតមកពី មូអាស់ អ៊ីបនូ យ៉ាបាល់ ថា៖

«فكان رسول الله صلّى الله عليه (وآله) وسلّم يجمعُ بين الظّهر والعصر، والمغرب والعشاء»

*"ព្រះសាស្តាﷺអល់ឡោះហ្ទ៍عز وجلបានស៊ូឡាត់អាស្ហារ ក្រោយស៊ូហ្ហ៊ រភ្លាមបានស៊ូឡាត់អ៊ីស្ហាអ៍ភ្លាមក្រោយស៊ូឡាត់ម៉ាក៏រីប ។"*[221]

៥. លោក ម៉ាលិក អ៊ីបនូ អាណាស់ បានរាយការណ៍ហាឌីស្ហនេះតមកពី ណាហ្វីអ៍ តមកពីអាប់ឌុលឡោះហ្ទ៍ អ៊ីបនូ អ៊ូម៉ារ ថា៖

«كان رسول الله صلّى الله عليه (وآله) وسلّم إذا عجل به السّير يجمع بين المغرب والعشاء»

*"រាល់ពេលព្រះសាស្តាﷺអល់ឡោះហ្ទ៍عز وجلប្រញាប់ ព្រះអង្គﷺស៊ូឡាត់អ៊ីស្ហាអ៍ភ្លាមបន្ទាប់ស៊ូឡាត់ម៉ាក៏រីប ។"*[222]

៦. លោក ម៉ាលិក អ៊ីបនូ អាណាស់ បានរាយការណ៍ហាឌីស្ហនេះតមកពី

ហាឌីស្ហ ១៧៨ ។ សូមមើលសៀវភៅ *ស៊ូហ៊ិះហ្ទ៍ មុស្លីម* (បោះពុម្ពនៅបៃរូត) ជុំទី ២ "គីតាប អាស្វ-ស៊ូឡាស់" "វគ្គស្តីអំពីស៊ូឡាត់ជុំគ្នានៅផ្ទះ" ទំព័រ ១៥១ ។

[221] សូមមើលសៀវភៅរបស់លោក ម៉ាលិក អ៊ីបនូ អាណាស់ *អាល់-មូវ៉ាត់ត៍អ៍* (បោះពុម្ពលើកទី ៣ នៅបៃរូត ហ.ស 1403) "គីតាប អាស្វ-ស៊ូឡាស់" ទំព័រ ១៣៤ ហាឌីស្ហ ១៧៦ និង *ស៊ូហ៊ិះហ្ទ៍ មុស្លីម* (ប្រែជាភាសាអង្លេស) ជុំទី ២ ទំព័រ ១៥២ បោះពុម្ពនៅអេស៊ីបត៍ ។

[222] សូមមើលសៀវភៅរបស់លោក ម៉ាលិក អ៊ីបនូ អាណាស់ *អាល់-មូវ៉ាត់ត៍អ៍* (បោះពុម្ពលើកទី ៣ នៅបៃរូត ហ.ស 1403) "គីតាប អាស្វ-ស៊ូឡាស់" ទំព័រ ១២៥ ហាឌីស្ហ ១៧៧ ។

*អល់ឡោះហ៊ ﷻ ស្ហ៊ឡាត់អ៊ាស្ហារភ្លាមក្រោយស្ហ៊ឡាត់ស្ហ៊ហ៊្ររ ស្ហ៊ឡាត់អ៊ីស្ហាអ៊ភ្លាមក្រោយស្ហ៊ឡាត់ម៉ាក់រីប ។" អ៊ាប់ឌុលឡោះហ៊ អ៊ីបនូ ស្ហាគ៊ីក មានប្រសាសន៍ថា៖ "ខ្ញុំសង្ស័យ ក៏បានសួរ អាប៊ូ ហ៊្ររ៉យ៉រ៉ោះត៍ អំពីរឿងនេះ ។ អាប៊ូ ហ៊្ររ៉យ៉រ៉ោះត៍បានអះអាងថាសម្តីរបស់អ៊ាប់បាស់ជាសម្តីពិត ។"*[219]

នៅក្នុងហាឌីស្សនេះ សាវកពីរនាក់គឺ អ៊ាប់ឌុលឡោះហ៊ អ៊ីបនូ អ៊ាប់បាស់ និង អាប៊ូ ហ៊្ររ៉យ៉រ៉ោះត៍ បានអះអាងបញ្ជាក់ថាព្រះសាស្តា ﷺ បានស្ហ៊ឡាត់អ៊ាស្ហារភ្លាមក្រោយស្ហ៊ឡាត់ស្ហ៊ហ៊្ររ បានស្ហ៊ឡាត់អ៊ីស្ហាអ៊ភ្លាមក្រោយស្ហ៊ឡាត់ម៉ាក់រីបមែន ហើយអ៊ាប់បាស់បានយកតម្រាប់តាមព្រះសាស្តា ﷺ ។

៣. លោក ម៉ាលិក អ៊ីបនូ អាណាស់ (مالك بن أنس) អ្នកបង្កើតម៉ាស្ហ៊ហាប់ម៉ាលីគី (គឺមេនិកាយម៉ាលីគី) បាន សរសេរនៅក្នុងសៀវភៅលោកដែលមានចំណងជើងថា *អាល់-មូវ៉ាត្តត្អ៊* (الموطأ) ថា៖

«صلّى رسول الله صلّى الله عليه (وآله) وسلّم الظّهر والعصر جميعاً، والمغرب والعشاء جميعاً في غير خوفٍ ولاسفرٍ»

*"ព្រះសាស្តា ﷺ អល់ឡោះហ៊ ﷻ បានបំពេញស្ហ៊ឡាត់ស្ហ៊ហ៊្ររ និងស្ហ៊ឡាត់អ៊ាស្ហារបន្តបន្ទាប់គ្នាភ្លាមៗ បានបំពេញស្ហ៊ឡាត់ម៉ាក់រីបនិងអ៊ីស្ហាអ៊បន្តបន្ទាប់គ្នាភ្លាមៗ ក្នុងពេលដែលព្រះអង្គ ﷺ មិនស្ថិតនៅក្នុងស្ថានការណ៍ភ័យខ្លាចសត្រូវឬក្នុងពេលធ្វើដំណើរនោះទេ ។"*[220]

---

[219] សូមមើលសៀវភៅ *មុសណាដ្ហ៍ អាស់ម៉ាដ្ហ៍ អ៊ីបនូ ហ៊ាន់បាល់* ជុំទី ១ ទំព័រ ២៥១ ។

[220] សូមមើលសៀវភៅរបស់លោក ម៉ាលិក អ៊ីបនូ អាណាស់ *អាល់-មូវ៉ាត្តត៏អ៊* (បោះពុម្ពលើកទី ៣ នៅបៃរូត ហ.ស 1403) "គីតាប អាស្ហ-ស្ហ៊ឡាស្ហ" ទំព័រ ១២៥



១- លោក អាប៊ូ ហាស៊ីម បានរាយការណ៍តមកពីលោក សាស្ហល៍ អ៊ីបនូ សាអ៊ាដ្ហ៍ ថាព្រះសាស្តា ﷺ មានព្រះ វចនៈថា៖

﴿أنا فرطكم على الحوض من ورد شرب ومن شرب لم يظمأ ابداً وليردنّ عليّ أقوامٌ أعرفهم ويعرفوني ثمّ يحال بيني وبينهم﴾

*"ខ្ញុំណាត់ជួបអស់លោកនៅឯកន្លែងទឹកផុស អ្នកណាបានទៅដល់កន្លែងនោះហើយបានផឹកទឹកនោះ អ្នកនោះនឹងបាត់ស្រេករហូត ។ មានអ្នកខ្លះមកជួបខ្ញុំដែលខ្ញុំស្គាល់ ពួកគេក៏ស្គាល់ខ្ញុំដែរ តែពួកគេនឹងត្រូវបំបែកចេញពីខ្ញុំ ។"*

លោកអាប៊ូ ហាស៊ីមបានថា៖ "ពេលខ្ញុំកំពុងអានហាឌីស្សនេះ លោក នុអ៊ម៉ាន អ៊ីបនូ អាប៊ី អ៊ៃយ៉ាស្ហ បានសួរខ្ញុំ ថាតើខ្ញុំបានឮដូចលោកសាស្ហល៍ដែរឬទេ ។ ខ្ញុំបានឆ្លើយថាខ្ញុំបានឮដូចសាស្ហល៍ដែរ ។ គាត់បាននិយាយបន្តថា៖ "ខ្ញុំសូមសច្ចាថាអាប៊ូ សាអ៊ីដ្ហ៍ អាល់-ឃុដ្ហ៍រីបានបន្ថែមឃ្លាតទៅនេះនៅក្នុងហាឌីស្សនេះគឺ៖ ថាព្រះសាស្តា ﷺ មានព្រះវចនៈថា៖

﴿اِنَّهُمْ مِنِّي فيقال انّك لاتدري ما أحدثوا بعدك فأقول سحقاً سحقاً لمن بدَّل بعدي﴾

*"ពួកគេទាំងនោះជាសាច់ខ្ញុំ ។" គេបានថា៖ "ព្រះអង្គមិនដឹងទេថាពួកគេធ្វើអ្វីខ្លះអត់ពីព្រះអង្គទៅ ?" ព្រះអង្គមានព្រះវចនៈថា៖ "អបមង្គល អបមង្គលលើអ្នកណាដែលកែប្រែ[ច្បាប់]ពេលអត់ពីខ្ញុំ ។"*[147]

ឃ្លា "មានអ្នកខ្លះមកជួបខ្ញុំដែលខ្ញុំស្គាល់ ពួកគេក៏ស្គាល់ខ្ញុំដែរ" និងឃ្លា

---

[147] សូមមើលសៀវភៅ យ៉ាមិអ៊ អាល់-អ៊ូស្ហូល (جَامِعْ الأُصُوْل) របស់លោក អ៊ីបនូ អាស្ហៀរ ជុំទី ១១ ទំព័រ ១២០ ហាឌីស្ស ៧៩៧២ "បាប់ អាល់-ហៅដ្ហ៍ ហ្វី វ៉ុរុដ្ហ៍ អាន់-ណាស់ អ៊ាឡៃហ៍" ។

"អ្នកណាដែលកែប្រែ[ច្បាប់]ពេលអត់ពីខ្ញុំ" ទាក់ទងនឹងបណ្ដាសាវករបស់ព្រះសាស្ដាﷺជាចាំបាច់ ដែលបាននៅអបអមព្រះអង្គﷺនោះ ។ លោក អាល់-ប៊ូខ៉រី និងលោក មុស្លីម ក៏បានរាយការណ៍ហាឌីស្ហនេះដែរ ។

លោក អាល់-ប៊ូខ៉រី និងលោក មុស្លីម មានប្រសាសន៍ថាគេបានធ្វើសេចក្ដីរាយការណ៍ថាព្រះសាស្ដាﷺមានព្រះវចនៈថា៖

﴿يرد عليَّ يوم القيامة رهطٌ من اصحابى – أو قال من أمّتي – فيحلؤون عن الحوض فأقول يا ربّ أصحابى فيقول انّه لاعلم لك بما أحدثوا بعدك اِنّهم اِرتدّوا على أدبارهم القهقرى﴾

*"ថ្ងៃរស់ពីស្លាប់វិញ សាវករបស់ខ្ញុំមួយក្រុម ឬរបស់សហាគមន៍ខ្ញុំ នឹងមកជួបខ្ញុំ ហើយនឹងត្រូវគេដេញចេញឆ្ងាយពីទឹកផុស[កៅស្ហារ] ខ្ញុំនឹងថា៖ "ព្រះម្ចាស់អើយ ពួកគេជាគ្នាទូលព្រះបង្គំជាខ្ញុំ ។" អល់ឡោះហ៊្វعزّ وجلّនឹងមានព្រះបន្ទូលថា៖ "អ្នកមិនដឹងថាពួកគេបានធ្វើអ្វីទេពេលអត់ពីអ្នក ពួកគេបានត្រឡប់ទៅកាន់សភាពដើមរបស់ពួកគេវិញ (គឺសម័យអវិជ្ជា) ។"*[148]

## សេចក្ដីសរុប

អាស្រ័យអាយ៉ាស់គួរអាននិងស៊ុនណាស់ព្រះសាស្ដាﷺ យើងឃើញជាក់ច្បាស់ថាសាវកនិងមនុស្ស ដែលបានរស់នៅអបអមជាមួយព្រះសាស្ដាﷺមិនប្រកបដោយសីលធម៌ទាំងអស់គ្នាទេ ហើយក៏ពុំមានចរិតដូចគ្នាទេដែរ ។ សាវកមួយចំនួនទៅជាបុគ្គលប្រសើរនិងត្រចះត្រចង់ដោយសារការនៅអបអមជាមួយព្រះសាស្ដាﷺនេះឯង ដែលប្រកបដោយសេចក្ដីថ្លៃថ្នូរកំពូល ហើយការបម្រើដ៏មានតម្លៃរបស់បុគ្គលទាំងនេះបានធ្វើឲ្យអ៊ីស្លាម

[148] សូមមើលសៀវភៅ យ៉ាមិអ៊ អាល់-អ៊ូស្ហូល (جَامِعُ الأُصُوْل) របស់លោក អ៊ីបនូ អាស្សៀរ ហាឌីស្ហ ៧៩៧៣ ។



*عزّ وجلّបានពន្យារស្ហ៍ឡាត់ស្ហ៊ូហ្ស៊រ ហើយបានស្ហ៍ឡាត់អាស្ហរភ្លាមបន្ទាប់ពីនោះ ។ ដូចគ្នាដែរ ព្រះអង្គﷺបានពន្យារស្ហ៍ឡាត់ម៉ាក់រីប ហើយបានស្ហ៍ឡាត់អ៊ីស្ហាអ៊ ភ្លាមបន្ទាប់ពីនោះ ។" លោក (គឺអាប៊ូ ស្ហាក់ស្ហាអ៊) មានប្រសាសន៍ថា៖ "ខ្ញុំក៏យល់ឃើញដូចនេះដែរ ។""*[218]

ហាឌីស្ហនេះបង្ហាញឲ្យឃើញច្បាស់ថា ព្រះសាស្ដាﷺបានស្ហ៍ឡាត់ស្ហ៊ូហ្ស៊រ និងអាស្ហរបន្តបន្ទាប់គ្នាភ្លាមៗ បានស្ហ៍ឡាត់ម៉ាក់រីបនិងអ៊ីស្ហាអ៊បន្តបន្ទាប់គ្នាភ្លាមៗ ដោយមិនទុកពេលចន្លោះរវាងស្ហ៍ឡាត់ទាំងពីរទេ ។

២. លោក អាស្ហ៍ម៉ាដ្ហ៍ អ៊ីបនូ ហាន់បាល់ មានប្រសាសន៍តមកពីលោក អាប់ឌុលឡោះហ្ហ៍ អ៊ីបនូ ស្ហាគីក្វ ថា៖

«خطبنا ابن عبّاس يوماً بعد العصر حتّى غربت الشّمس وبدت النّجوم وعلّق النّاس ينادونه الصّلوة وفي القوم رجلٌ من بني تميم فجعل يقول: الصّلوة الصّلوة: فغضب قال أتعلّمنى بالسّنّة؟ شهدت رسول الله صلّى الله عليه (وآله) وسلّم جمع بين الظّهر والعصر، والمغرب والعشاء. قال عبدالله فوجدت في نفسي من ذلك شيئاً فلقيت أبا هريرة فسألته فوافقه»

*"ក្រោយស្ហ៍ឡាត់អាស្ហរ អ៊ីបនូ អាប់បាស់ បាននិយាយជាមួយយើងរហូតដល់ថ្ងៃលិច លុះផ្កាយរះ ។ មនុស្សម្នាចាប់ផ្ដើមប្រកាសថាដល់ពេលស្ហ៍ឡាត់ហើយ ។ នៅក្នុងចំណោមមនុស្សដែលមានវត្តមាននៅទីនោះ មានបុរសកុលសម្ព័ន្ធ បានី-តាមីម ម្នាក់ដែលស្រែកឮៗថា អាស្ហ៍-ស្ហ៍ឡាត់ៗ ។ អ៊ីបនូ អាប់បាស់ក្រោធ បានប្រាប់គាត់ថា៖ "លោកចង់បង្ហាត់ឲ្យខ្ញុំចេះដឹងស៊ុនណាស់ព្រះសាស្ដាﷺឬ ? ខ្ញុំបានឃើញព្រះសាស្ដាﷺ*

[218] សូមមើលសៀវភៅ *មុសណាដ្ហ៍ អាស្ហ៍ម៉ាដ្ហ៍ អ៊ីបនូ ហាន់បាល់* ជុំទី ១ ទំព័រ ២២១ ។ លោក អាប់ឌុល ហាមីដ្ហ ស្ហ៊ីដ្ហឌ្ហីគីក៏ បានធ្វើសេចក្ដីរាយការណ៍ដូចនេះដែរ ។ សូមមើល ស្ហ៍ហ៊ីះហ្ហ៍ មុស្លីម (ប្រែជាភាសាអង្គេស) ជុំទី ១ កណ្ឌ ១០០ ។

លក្ខខណ្ឌពិសេសទេ អនុញ្ញាតឲ្យធ្វើបែបនេះបានគ្រប់ពេលនិងគ្រប់ទីកន្លែង ។

លោកអ្នកអធិប្បាយហាឌីស្ហូងទៀតថា ហាឌីស្ហនេះមានន័យថាគេអាចចាំបន្តិចបាន រួចហើយស្ហ៊ឡាត់ស្ហូហ្ហ៊រនៅចុងពេលវេលាដាច់មុខរបស់វា រួចហើយស្ហ៊ឡាត់អាស្ហរនៅដើមពេលវេលារបស់វា ។ គេអាចចាំបន្តិចបាន រួចហើយស្ហ៊ឡាត់ម៉ាក់រីបនៅចុងពេលដាច់មុខរបស់វា រួចហើយស្ហ៊ឡាត់អ៊ីស្ហាអ៉នៅដើមពេលវេលារបស់វា ។

ដើម្បីបំភ្លឺចំណុចនេះ យើងនឹងពិនិត្យមើលហាឌីស្ហទាក់ទងនឹងរឿងនេះ ដើម្បីបង្ហាញថាបំពេញស្ហ៊ឡាត់ពីរបន្តបន្ទាប់គ្នា (យ៉ាំអ៊) នោះសមស្របនឹងសម្ដីស្ហ៊ីអាស់ ពោលគឺ គេអាចបំពេញស្ហ៊ឡាត់ទាំងពីរបាននៅក្នុងពេលវេលារបស់ស្ហ៊ឡាត់មួយទៀតបាន មិនមែននៅឯចុងពេលវេលាដាច់មុខរបស់ស្ហ៊ឡាត់នោះ ឯមួយទៀតនៅដើមពេលវេលារបស់វានោះទេ ។

១. លោកអាស្ហ៊ម៉ាដ្ធ អ៊ីបនូ ហាន់បាល់ អ្នកបង្កើតម៉ាស្ហ៊ហ្ហាប់ (គឺនិកាយ) ហាន់បាលី មានប្រសាសន៍នៅក្នុងមុសណាដ្ធរបស់លោក តមកពីលោកយ៉ាបៀរ អ៊ីបនូ ស្ហ៊ៃដ្ធ ថា៖

«أخبرني جابر بن زيد انّه سمع ابن عبّاس يقول: صلّيت مع رسول الله صلّى الله عليه (وآله) وسلّم ثمانياً جميعاً وسبعاً جميعاً. قال قلت له يا أبا الشّعثاء اظنّه أخّر الظّهر وعجل العصر وأخّر المغرب وعجّل العشاء، قال وأنا أظُنُّ ذلك»

*"យ៉ាបៀរ អ៊ីបនូ ស្ហ៊ៃដ្ធ បានថាខ្ញុំបានឮ អ៊ីបនូ អាប់បាស់ មានប្រសាសន៍ថា៖ "ខ្ញុំបានស្ហ៊ឡាត់ពីក្រោយព្រះ សាស្ដាﷺអល់ឡោះហ្ម៉ ﷻ ប្រាំបីរ៉ក់អាត់រួមគ្នានិងប្រាំពីររ៉ក់អាត់រួមគ្នា ។" លោកមានប្រសាសន៍ថា៖ "ខ្ញុំបានប្រាប់អាប៊ូ ស្ហាក់ស្ហាអ៊ថា៖ "ខ្ញុំយល់ឃើញថាព្រះសាស្ដាﷺអល់ឡោះហ្ម៉*



រឹងមាំកាលពីទើបនឹងបានកកើតឡើង ។
មួយប៉ែកទៀត រួមមានពួកលាក់ពុតត្បុតមានចិត្តអន្យតិរ្ថិយ សាងបាបកម្ម ។ [149]

## សំណួរ ១៨ - អ្វីទៅអត្ថន័យរបស់មុតអាស់ (المتعة អាពាហ៍ពិពាហ៍មានកំណត់) ហេតុអ្វីស្ហ៊ីអាស់ចាត់ទុកថាស្របច្បាប់ ?

## ចម្លើយ

អាពាហ៍ពិពាហ៍ជាការយល់ព្រមរវាងបុរសនិងស្ត្រី ។ ជួនកាលសម្ព័ន្ធនេះជាសម្ព័ន្ធអចិន្ត្រៃយ៍ ដូច្នេះកិច្ចព្រមព្រៀងនេះមិនមានកំណត់ពេលទេ ជួលកាលសម្ព័ន្ធនេះមានរយៈកាលកំណត់ ដូច្នេះកិច្ចព្រមព្រៀងនេះមានកំណត់ពេល ។

នេះគឺអាពាហ៍ពិពាហ៍ពីរប្រភេទស្របច្បាប់អ៊ីស្លាម ។ ខុសគ្នាតែត្រង់រយៈពេលទេ មួយមានរយៈពេលអចិន្ត្រៃយ៍ (គឺរហូត) មួយទៀតមានកំណត់ពេល ។ លក្ខខ័ណ្ឌតទៅនេះមានសុពលភាពទាំងក្នុងអាពាហ៍ពិពាហ៍មានកំណត់ពេល (មុតអាស់) ទាំងក្នុងអាពាហ៍ពិពាហ៍អចិន្ត្រៃយ៍ គឺ៖
១- មិនត្រូវមានឧបសគ្គផ្នែកសាសនាទេ នៅក្នុងអាពាហ៍ពីពាហ៍ឧទាហរណ៍ដូចជារួមខ្សែលោហិតជាមួយគ្នា ឬមានខ្សែលោហិតជិតគ្នា

---

[149] ចង់បានព័ត៌មានលំអិត សូមមើលសេចក្ដីអធិប្បាយរបស់ស្ហ៊រ៉ោះត៍ អាល់-មូណាហ្វ៊ីគូន 63 ។

ណាស់ជាដើម ដែលធ្វើឲ្យអាពាហ៍ពិពាហ៍មោឃៈ ។

២- ប្រាក់ខាន់ស្លា (ម៉ាស្ហ័រ مهر ទ្រព្យសម្រាប់ប្រគល់ឲ្យទៅស្ត្រី) ដែលប៉ែកទាំងពីរយល់ស្របគ្នាត្រូវចុះនៅក្នុងកិច្ចព្រមព្រៀង ។

៣- ត្រូវកំណត់រយៈពេលរបស់អាពាហ៍ពិពាហ៍ ។

៤- ត្រូវចុះកិច្ចព្រមព្រៀងស្របតាមច្បាប់ ។

៥- កូនដែលកើតពីអាពាហ៍ពិពាហ៍នេះជាកូនស្របច្បាប់ ដូចកូនដែលកើតពីអាពាហ៍ពិពាហ៍គ្មានកំណត់ពេលដែរ ហើយមានសិទ្ធិមានអត្តសញ្ញាណដោយមានឈ្មោះក្នុងលិខិតកំណើត ។ ដូច្នេះ ត្រង់នេះមិនមានភាពខុសគ្នាទេ រវាងកិច្ចព្រព្រៀងអាពាហ៍ពិពាហ៍គ្មានកំណាត់និងអាពាហ៍ពិពាហ៍មានកំណត់នោះ ។

៦- កូនៗនៅក្នុងបន្ទុកឪពុក ហើយទទួលមរតកពីឪពុកនិងម្ដាយ ។

៧- លុះផុតពេលកំណត់ បើស្ត្រីមិនឈប់មានរដូវខែទេ ត្រូវនៅក្នុងរយៈពេលរង់ចាំ (អ៊ីដ្ហាស្ហ៍ العدة) បើនៅក្នុងចន្លោះពេលនេះ ស្ត្រីឃើញថាខ្លួនមានផ្ទៃពោះ ស្ត្រីនោះមិនត្រូវរៀបការណាមួយទេលុះកើតកូនរួច ។

ដូចគ្នាដែរ ត្រូវគោរពច្បាប់ឯទៀតរបស់អាពាហ៍ពិពាហ៍គ្មានកំណត់ (គឺអចិន្ត្រៃយ៍) នៅក្នុងអាពាហ៍ពិពាហ៍មានកំណត់ (គឺមុតអ៊្ហាស្ហ៍) ។ ខុសគ្នាតែមុតអ៊្ហាស្ហ៍ (អាពាហ៍ពិពាហ៍មានកំណត់ពេល) ដែលត្រូវដាក់មកដើម្បីបំពេញសេចក្ដីត្រូវការរបស់បុរសនោះ ការចាយរបស់ស្ត្រីមិននៅក្នុងបន្ទុកបុរសទេ ។ ពេលចុះហត្ថលេខាក្នុងកិច្ចព្រមព្រៀង បើស្ត្រីមិននិយាយអំពីលក្ខខ័ណ្ឌមរតកទេ ស្ត្រីនឹងមិនទទួលមរតកពីស្វាមីទេ ។ ភាពខុសគ្នាទាំងពីរនេះមិនជះឥទ្ធិពលទៅលើប្រភេទអាពាហ៍ពិពាហ៍ទេ ។

យើងទាំងអស់គ្នាដឹងថា សាសនាអ៊ីស្លាមជាសរុបច្បាប់អចិន្ត្រៃយ៍ដែលឆ្លើយតបសេចក្ដីត្រូវការទាំងអស់របស់សង្គម ។ ឧទាហរណ៍ បើយុវជននិស្សិតត្រូវស្នាក់នៅក្នុងប្រទេសឯនាយច្រើនឆ្នាំ ឬស្នាក់នៅឯស្រុកឆ្ងាយ



ដូចគ្នាដែរ យើងអាចស្ហ៍ឡាត់ *ម៉ាក់រីប* បានពេលដល់ថ្ងៃលិចស្របតាមច្បាប់បញ្ញត្តិ (ម៉ាក់រីប អាស្ហ៍-ស្ហារ៉អ៊ី) ហើយអាចស្ហ៍ឡាត់ *អ៊ីស្ហាអ៍* បន្ទាប់ពីនោះភ្លាមបាន ។ យើងអាចពន្យារពេលស្ហ៍ឡាត់ *ម៉ាក់រីប* រហូតដល់មុនដើមពេលវេលាសម្រាប់តែស្ហ៍ឡាត់អ៊ីស្ហាអ៍បាន ដោយស្ហ៍ឡាត់ម៉ាក់រីបឲ្យចប់ស្រេចបាច់មុនពេលវេលាដាច់មុខរបស់ស្ហ៍ឡាត់អ៊ីស្ហាអ៍មកដល់ រួចស្រេចហើយអាចស្ហ៍ឡាត់អ៊ីស្ហាអ៍បន្ទាប់ពីនោះបាន ។

ដូច្នេះ យើងអាចស្ហ៍ឡាត់ម៉ាក់រីបនិងអ៊ីស្ហាអ៍បន្តបន្ទាប់គ្នាបាន តែគប្បីស្ហ៍ឡាត់ម៉ាក់រីបក្រោយពេលថ្ងៃលិច ស្របតាមច្បាប់បញ្ញត្តិ និងគប្បីស្ហ៍ឡាត់អ៊ីស្ហាអ៍ក្រោយពេលថ្ងៃលិចបាត់អស់នៅឯទិសខាងលិច ។

នេះគឺមតិស្ហ៊ីអ៊្ហាស្ហ៍ ចំណែកឯអាស្ហ៍លុល-ស៊ុនណាស្ហ៍វិញថាមិនអនុញ្ញាតឲ្យស្ហ៍ឡាត់ *ស្ហ៊ូហ្ស៊ូរ* និង *អ៊្ហាស្ហ្វារ* ឬ *ម៉ាក់រីប* និង *អ៊ីស្ហាអ៍* បន្តបន្ទាប់គ្នានៅកន្លែងណាមួយឬពេលណាមួយទេ ។ អនុញ្ញាតឲ្យធ្វើបែបនេះដោយមានលក្ខខណ្ឌពិសេសនិងនៅក្នុងទីកន្លែងពិសេសទេ ។ តែចំណុចមិនចុះសម្រុងគ្នាគឺ បំពេញស្ហ៍ឡាត់ទាំងពីរគ្រប់ពេលនិងគ្រប់ទីកន្លែង ដូចគេអនុញ្ញាតឲ្យស្ហ៍ឡាត់បន្តបន្ទាប់គ្នានៅអ៊្ហារ៉ហ្វាស្ហ៍ និងមុស្ហ្ដាលីហ្វាស្ហ៍នោះដែរ ។

៥. មុស្លីមទាំងអស់មូលមតិគ្នាថា ព្រះសាស្ដាﷺបានបំពេញស្ហ៍ឡាត់ទាំងពីរនេះបន្តបន្ទាប់គ្នា តែគេអធិប្បាយហាឌីស្ហ៍នេះពីរបែបគឺ៖

ក. ស្ហ៊ីអ៊្ហាស្ហ៍ថាគេអនុញ្ញាតឲ្យស្ហ៍ឡាត់ស្ហ៊ូហ្ស៊ូរ ក្នុងពេលវេលាកំណត់របស់វារួចហើយស្ហ៍ឡាត់អ៊្ហាស្ហ្វារភ្លាម បន្ទាប់ពីស្ហ៍ឡាត់ស្ហ៊ូហ្ស៊ូរ ។ ដូចគ្នាដែរ គេអនុញ្ញាតឲ្យស្ហ៍ឡាត់ម៉ាក់រីបក្នុងពេលកំណត់របស់វា រួចហើយស្ហ៍ឡាត់អ៊ីស្ហាអ៍ភ្លាមបន្ទាប់ពីម៉ាក់រីប ។ គេដាក់ឲ្យអនុវត្តិច្បាប់ដោយពុំមាន

ច. ពេលវេលារួមរបស់ *ម៉ាក់រីប* និង *អ៊ីស្ហាអ៊ុ* ចាប់ពីចុងបញ្ចប់នៃពេលវេលាដាច់មុខរបស់ម៉ាក់រីប (គឺពេលសម្រាប់តែស្ហ៊ូឡាត់ម៉ាក់រីបបាន) រហូតដល់ដើមពេលវេលាដាច់មុខរបស់អ៊ីស្ហាអ៊ុ (គឺពេលសម្រាប់តែស្ហ៊ូឡាត់អ៊ីស្ហាអ៊ុបាន) ។

យោលតាមទ្រឹស្តីស្ហ៊ីអ៊ាស់ នៅក្នុងអំឡុងពេលរួមនេះ គេអនុញ្ញាតឲ្យស្ហ៊ូឡាត់*ម៉ាក់រីប* និង *អ៊ីស្ហាអ៊ុ* បន្តបន្ទាប់គ្នាបានដោយមិនមានចន្លោះពេលរវាងស្ហ៊ូឡាត់ទាំងពីរ ។ តែអាស្ហ់លុល-ស៊ុនណាស្ហ់ថាអំឡុងពេលដែលចាប់ពីដើមម៉ាក់រីបទៅដល់ពេលថ្ងៃជិតលិច (ស្ហ៊ូវ៉ាល់ អាស្ហ់-ស្ហាហ្វាក់ (الزوال الشفق) គឺពេលជិតអស់ពណ៌ក្រហម) នោះ ជាពេលវេលាសម្រាប់តែម៉ាក់រីបទេ មិនអនុញ្ញាតឲ្យស្ហ៊ូឡាត់អ៊ីស្ហាអ៊ុនៅក្នុងអំឡុងពេលនេះទេ ។ ពួកគេយល់ឃើញដែរថាអំឡុងពេលចន្លោះថ្ងៃជិតលិចនិង "ពេលពាក់កណ្តាលយប់" ដែលសាសនាកំណត់នោះ សម្រាប់តែអ៊ីស្ហាអ៊ុទេ មិនអនុញ្ញាតឲ្យស្ហ៊ូឡាត់ម៉ាក់រីបក្នុងអំឡុងពេលនេះទេ ។

សរុបគឺ យោលតាមទ្រឹស្តីស្ហ៊ីអ៊ាស់ ពេលដល់ "ពាក់កណ្តាលថ្ងៃ" តាមច្បាប់សាសនា (ស្ហ៊ូហ្ហ៊ូរ អាស្ហ់-ស្ហារ៉អ៊ី) យើងអាចស្ហ៊ូឡាត់ស្ហ៊ូហ្ហ៊ូរបាន រួចស្រេចហើយយើងអាចស្ហ៊ូឡាត់អាស្ហួរបានភ្លាមៗ ។ យើងអាចពន្យារស្ហ៊ូឡាត់ស្ហ៊ូហ្ហ៊ូរបានដែរ អាចស្ហ៊ូឡាត់ស្ហ៊ូហ្ហ៊ូរបានមុនដើមពេលវេលាដាច់មុខរបស់ស្ហ៊ូឡាត់អាស្ហួរ រួចរាល់ហើយ យើងអាចស្ហ៊ូឡាត់អាស្ហួរតាមក្រោយបាន ។

ដូច្នេះ យើងអាចស្ហ៊ូឡាត់ស្ហ៊ូហ្ហ៊ូរនិងអាស្ហួរបន្តបន្ទាប់គ្នាបាន តែយកល្អឲ្យស្ហ៊ូឡាត់ស្ហ៊ូហ្ហ៊ូរក្រោយពីថ្ងៃចាប់ផ្តើមជ្រេ ឲ្យស្ហ៊ូឡាត់អាស្ហួរពេលណាម្លប់របស់សព្វវត្ថុមានប្រវែងស្មើនឹងសព្វវត្ថុនោះ ។



ឬពុំមានមធ្យោបាយរៀបអាពាហ៍ពិពាហ៍គ្មានកំណត់ទេ យុវជននោះមានវិធីដោះស្រាយបីគឺះ

ក. នៅលីវ ។

ខ. ធ្លាក់ខ្លួនទៅក្នុងអំពើពេស្យាចារ ឬបាប ។

គ. រៀបការតាមច្បាប់ខាងលើនេះជាមួយស្ត្រី ដែលច្បាប់អនុញ្ញាតដោយមានកំណត់ពេល ។

ទាក់ទងនឹងករណីទីមួយ គប្បីសារភាពថាជាញឹកញយគេទទួលបរាជ័យពីព្រោះចៀសវាងការរួមភេទ ការអត់ធ្មត់និងទ្រាំនោះ ស្ទើរតែមិនអាចធ្វើបានឡើយ ហើយនេះជាមធ្យោបាយដែលមនុស្សទាំងអស់គ្នាមិនអាចរើសយកបានទេ ។

អ្នកដែលជ្រើសយកមធ្យោបាយទីពីរ ធ្លាក់ទៅក្នុងការប្រព្រឹត្តកន្លងករណីយកិច្ចនិងការអស់សង្ឃឹម ។ អំពើទាំងនេះជាអំពើដែលអ៊ីស្លាមហាម (ហ្ហារ៉ាំ) ហើយពេញចិត្តប្រព្រឹត្តអំពើនេះដោយយកលេសថាចាំបាច់នោះជាការលំអៀងប្រាជ្ញានិងសីលធម៌ ។

ដូច្នេះ មានតែមធ្យោបាយទីបីទេដែលអ៊ីស្លាមយល់ព្រមឲ្យជ្រើសយក ដូចក្នុងសម័យព្រះសាស្តាﷺដែរ ដែលក្រោយមកបានក្លាយទៅជារឿងខ្វែងមតិគ្នា ។

យើងចាំបាច់ត្រូវរំលឹកបណ្តាអ្នកដែលខ្លាចថា អាពាហ៍ពិពាហ៍មានកំណត់ពេល (មុតអាស្ហ់) មិនស្របច្បាប់ទេនោះ សូមឲ្យបណ្តាអ្នកទាំងនោះដឹងថាអស់លោកអ្នកនីតិសាស្ត្រ (فقهاء) និងអស់លោកអ្នកប្រាជ្ញមុស្លីមព្រមទទួលយក អ្វីដែលស្រដៀងអាពាហ៍ពិពាហ៍គ្មានកំណត់ពេលនេះដែរ ។ អស់លោកអ្នកប្រាជ្ញទាំងនេះមូលមតិ គ្នាលើចំណុចដែលថាគូស្វាមីភរិយា

អាចធ្វើកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍អចិន្ត្រៃបាន ដោយមានបំណងថាទាំងពីរបែកផ្លូវគ្នាដោយការលែងលះគ្នាក្រោយពីមួយឆ្នាំ ឬលើសពីមួយ ឬតិចជាងមួយឆ្នាំ ។

យើងឃើញច្បាស់ថាកិច្ចព្រមព្រៀងបែបនេះជាកិច្ចព្រមព្រៀង "អចិន្ត្រៃយ៍ (គឺគ្មានកំណត់ពេល)" តែអាការក្រៅទេ តែតាមការពិតវាជាកិច្ចព្រមព្រៀងដែលមានកំណត់ពេល ។ ភាពខុសគ្នារវាងប្រភេទអាពាហ៍ពិពាហ៍ "អចិន្ត្រៃយ៍" នេះនិងអាពាហ៍ពិពាហ៍មានកំណត់ពេល (មុតអ៊ាស់) នោះគឺអាពាហ៍ពិពាហ៍មានកំណត់ពេល (គឺមុតអ៊ាស់) មានកំណត់ពេលទាំងអាការក្រៅ ទាំងតាមការពិត រីឯអាពាហ៍ពិពាហ៍អចិន្ត្រៃយ៍វិញអចិន្ត្រៃតែអាការក្រៅទេ តែតាមការពិតនោះវាមានកំណត់ពេល ។

ហេតុអ្វីអ្នកដែលអនុញ្ញាតអាពាហ៍ពិពាហ៍អចិន្ត្រៃយ៍ ដែលអស់លោកអ្នកនីតិសាស្ត្រមុស្លីមទទួលស្គាល់នោះ ខ្លាចដាក់ឲ្យអនុវត្តិនិងអនុញ្ញាតអាពាហ៍ពិពាហ៍មានកំណត់ពេល (មុតអ៊ាស់) ?

យើងយល់ហើយថាអ្វីគឺមុតអ៊ាស់ យើងនឹងបង្ហាញភ័ស្តុតាងដែលបញ្ជាក់ថាហេតុអ្វីមុតអ៊ាស់ត្រឹមត្រូវតាមច្បាប់សាសនា ហើយហេតុអ្វីមុតអ៊ាស់ត្រូវដាក់ជាបញ្ញត្តិជាពីរដំណាក់ការគឺ៖
១. ភាពស្របច្បាប់របស់មុតអ៊ាស់ក្នុងដើមសម័យអ៊ីស្លាម ។
២. មិនលុបចោលច្បាប់នេះ កាលព្រះសាស្តាﷺអល់ឡោះហ្ទ៍عز وجلនៅមានព្រះជន្ម ។

ភ័ស្តុតាងច្បាស់លាស់ដែលបញ្ជាក់ថា មុតអ៊ាស់ស្របច្បាប់នោះគឺអាយ៉ាស់៖



ម៉ាក់រីបមកដល់) ។

គ. ពេលវេលារួមរបស់ *ស្ហ៊ូហ្ស៊ូរ* និង *អ៊ាស្ហ៊ារ* គឺអំឡុងពេលដែលនៅចន្លោះពេលវេលាដាច់មុខរបស់ *ស្ហ៊ូហ្ស៊ូរ* និងដើមពេលវេលាដាច់មុខរបស់ *អ៊ាស្ហ៊ារ ។*

ទ្រឹស្តីរបស់ស៊្មីអ៊ាស់គឺ ក្នុងពេលរួមនេះ គេអាចស្ម៏ឡាត់ *ស្ហ៊ូហ្ស៊ូរ* និង *អ៊ាស្ហ៊ារ* បាន បន្តបន្ទាប់គ្នាដោយមិនមានចន្លោះរវាងទាំងពីរស្ម៏ឡាត់នេះ ។
ក៏ប៉ុន្តែអាស្ហ៊ុលុល-ស៊ុនណាស់ជឿថាពេលវេលាសម្រាប់តែ *ស្ហ៊ូហ្ស៊ូរ* នោះចាប់ផ្តើមពី *ស្ហ៊ូហ្ស៊ូរ អាស្ហ៊-ស្ហារ៉អ៊ី* (វ៉ាក់ទូ អាល់-ស៊ុវ៉ាល់) រហូតដល់ម្លប់របស់វត្ថុអ្វីមួយវែងស្មើវត្ថុនោះ ហើយនៅក្នុងអំឡុងពេលនេះមិនអនុញ្ញាតឲ្យស្ម៏ឡាត់ *អ៊ាស្ហ៊ារ* ទេ ។ ពួកគេនិយាយបន្ថែមថាអំឡុងពេលនៅចន្លោះចប់ *ស្ហ៊ូហ្ស៊ូរ* និងដើម *ម៉ាក់រីប* នោះ ទុកសម្រាប់តែស្ម៏ឡាត់ *អ៊ាស្ហ៊ារ* ទេ មិនអនុញ្ញាតឲ្យស្ម៏ឡាត់ *ស្ហ៊ូហ្ស៊ូរ* នៅក្នុងចន្លោះពេលនេះទេ ។

ឃ. ពេលវេលាសម្រាប់តែស្ម៏ឡាត់ *ម៉ាក់រីប* (គឺពេលវេលាដាច់មុខរបស់ម៉ាក់រីប) ចាប់ពីដើមពេលថ្ងៃលិចដែលច្បាប់កំណត់ (ម៉ាក់រីប អាស្ហ៊-ស្ហារ៉អ៊ី) រហូតដល់ពេលគេបានស្ម៏ឡាត់បីរ៉ក់អ៊ាត់របស់ម៉ាក់រីបចប់បរិបូរ ហើយនៅក្នុងអំឡុងពេលនេះ មិនអនុញ្ញាតឲ្យស្ម៏ឡាត់អ្វីផ្សេងពីម៉ាក់រីបទេ ។

ង. ពេលវេលាសម្រាប់តែស្ម៏ឡាត់ *អ៊ីស្ហាអ៍* គឺពេលដែលនៅសល់មុន "ពេលកណ្តាលយប់" តាមច្បាប់សាសនា គឺពេលដែលនៅសល់សម្រាប់តែស្ម៏ឡាត់បួនរ៉ក់អ៊ាត់របស់អ៊ីស្ហាអ៍បានប៉ុណ្ណោះ មិនអនុញ្ញាតឲ្យស្ម៏ឡាត់អ្វីផ្សេងពីអ៊ីស្ហាអ៍បានទេនៅក្នុងអំឡុងពេលនេះ ។

៣. អ្នកកាន់និកាយហាន់បាលី, ម៉ាលីគី និង ស្ហាហ្វីអ៊ី ថាៈ "គេអនុញ្ញាតឲ្យស្វ៉ឡាត់ *ស្ហ៊ូហ្ស៊រ* និង *អាស្ហារ* បន្តបន្ទាប់គ្នា ឬ *ម៉ាក់រីប* និង *អ៊ីស្ហាអ៍* បន្ទាប់គ្នា (ពោលគឺ ក្នុងពេលតែមួយ) ដោយមិនទុកឲ្យមានពេលចន្លោះរវាងស្វ៉ឡាត់ទាំងពីរទេនោះ ពេលធ្វើដំណើរលើសពីកន្លែងទាំងពីរនេះបាន (ពោលគឺ លើសពីអារ៉ហ្វាស់និងមុស្ទូហ្វាស់) ។ អ្នកខ្លះក្នុងនិកាយទាំងនេះអះអាងដែរថាគេអនុញ្ញាតឲ្យធ្វើស្វ៉ឡាត់ពីរបន្តបន្ទាប់គ្នាបាន ក្នុងពេលប្រចុចប្រចំ ដូចជាពេលភ្លៀង ពេលឈឺ ឬ ពេលខ្លាចសត្រូវ ។[217]

៤. មតិរបស់ស្ហ៊ីអាស់គឺ ស្វ៉ឡាត់ *ស្ហ៊ូហ្ស៊រ* និង *អាស្ហារ* ស្វ៉ឡាត់ *ម៉ាក់រីប* និង *អ៊ីស្ហាអ៍* មានពេលវេលាដាច់ឡែកគ្នានិងមានពេលវេលារួមគ្នា គឺៈ

ក. ពេលវេលាដាច់មុខរបស់ស្វ៉ឡាត់ *ស្ហ៊ូហ្ស៊រ* (គឺសម្រាប់តែ*ស្ហ៊ូហ្ស៊រ)* ចាប់ពី "ពាក់កណ្តាលថ្ងៃ" តាមច្បាប់សាសនា (ស្ហ៊ូហ្ស៊រ អាស្វ-ស្ហារ៉អ៊ី) (ពោលគឺពេលថ្ងៃជ្រេ (វ៉ាក់ទូ អាល់-ស្សាវ៉ាល់)) រហូតដល់គេបានស្វ៉ឡាត់ស្ហ៊ូហ្ស៊របួនរ៉ាក់អាត់ចប់ ។ ក្នុងអំឡុងពេលដែលមានកម្រិតនេះ គេស្វ៉ឡាត់បានតែស្ហ៊ូហ្ស៊រទេ ។

ខ. ពេលវេលាដាច់មុខរបស់ស្វ៉ឡាត់ *អាស្ហារ* (គឺសម្រាប់តែ*អាស្ហារ)* គឺមានកម្រិតពេលមុនស្វ៉ឡាត់ *ម៉ាក់រីប* ។ គឺចាប់ពីរ៉ាក់អាត់ទីមួយរហូតដល់ចប់រ៉ាក់អាត់ទីបួនរបស់ស្វ៉ឡាត់ *អាស្ហារ* (ពោលគឺ ពេលវេលារបស់អាស្ហារ គឺពេលដែលនៅសល់ដែលគេអាចស្វ៉ឡាត់បួនរ៉ាក់អាត់បាន មុនស្វ៉ឡាត់

[217] ស្រង់មកពីសៀវភៅ *អាល់-ហ្វាគ្វិះហ៍ អាឡា អាល់-ម៉ាស្ហាហ៊ីប អាល់-អារបាអាស់ (الفقه على المذاهب الأربعة)*, "គីតាប អាស្វ-ស្វ៉ឡាស់, អាល់-យ៉ាំអ៊ុ បៃន៍ អាស្វ-ស្វ៉ឡាតៃន៍ តាក់ទីម៉ាន វ៉ា តាក់ឃីរ៉ាន" ។



فَمَا ٱسْتَمْتَعْتُم بِهِۦ مِنْهُنَّ فَـَٔاتُوهُنَّ أُجُورَهُنَّ فَرِيضَةً

*"រីឯបណ្តាស្ត្រី ដែលពួកអ្នកបានត្រេកត្រអាលជាមួយ[ដោយស្របតាមអាពាហ៍ពិពាហ៍] (គឺមុតអាះត៍) ចូរពួកអ្នកប្រគល់ខាន់ស្លាឲ្យពួកនាងតាមកំណត់កាតព្វកិច្ច (៤:២៤) ។"*[150]

ពាក្យនៅក្នុងអាយ៉ាស់នេះជាភ័ស្តុតាងជាក់ស្តែងដែលបញ្ជាក់ថាគេបើកឲ្យដឹងអំពីមុតអាស់ គឺៈ

**មួយ** ៖ ពាក្យ "អ៊ីសទីមតាអ៊ុ" (استمتاع)[151] សំដៅទៅលើ "អាពាហ៍ពិពាហ៍មានកំណត់" ពីព្រោះបើមានន័យថា អាពាហ៍ពិពាហ៍អចិន្ត្រៃ នោះ សំនួនសេចក្តីច្បាស់ជានឹងបញ្ជាក់រឿងនេះ ។

**ពីរ** ៖ ពាក្យ "អ៊ូយ៉ូរហ៊ុនណា" (أُجُورَهُنَّ) មានន័យថា "ប្រាក់ខាន់ស្លា" នោះជាភ័ស្តុតាងច្បាស់លាស់បញ្ជាក់ថា គេនិយាយអំពី *មុតអាស់* (អាពាហ៍ពិពាហ៍មានកំណត់ពេល) ពីព្រោះបើគេនិយាយអំពីអាពាហ៍ពិពាហ៍អចិន្ត្រៃ គេនឹងប្រើពាក្យ "មាស្ហ៍រ (مهر) ឬពាក្យ "ស្វ៉ដាក់ (صداق)" ។

**បី** ៖ អស់លោកអ្នកស្រាយគួរអានស្ហ៊ីអាស់និងស៊ុននីបានសរសេរថាអាយ៉ាស់នេះត្រូវបើកឲ្យដឹងអំពីអាពាហ៍ពិពាហ៍មានកំណត់ពេល ។

លោក យ៉ាឡាល់ អាដ្ឋ-ឌីន អាល់-ស៊ូយូទី (جلال الدين السيوطي) នៅក្នុងសេចក្តីអធិប្បាយគួរអាន អាល់-ឌូរ អាល់-ម៉ាន់ស៊ួរ (الدر المنثور) រាយការណ៍តមកពីលោក អ៊ីបនូ យ៉ារៀរ និងលោក អាស់-ស៊ុដ្ឌី ថាអាយ៉ាស់ខាង

[150] ស៊ូរ៉ោះត៍ អាន់-នីសាអ៍ 4:24 ។

[151] ពាក្យនេះមានដើមកំណើតមកពីពាក្យ មុតអាស់ ស្តីអំពីលក្ខណៈមិនបិតថេរ ។

លើនេះទាក់ទងនឹងអាពាហ៍ពិពាហ៍មានកំណត់ពេល ។[152]

លោក អាប៊ី យ៉ាក្កុំហ្វារ មូហាំម៉ាដ់ អ៊ីបនូ យ៉ារៀរ ត្ត៍បារី (ابو جعفر محمد بن جرير طبري) នៅក្នុងសេចក្តីអធិប្បាយគួរអានរបស់លោក បានរាយការណ៍តមកពីលោក អាស់-ស៊ុដូឌី លោក មូយ៉ាហ៊ីដ្ និងលោក អាុប់បាស់ថា អាយ៉ាស់នេះទាក់ទងនឹងអាពាហ៍ពិពាហ៍មានកំណត់ពេល ។[153]

បួន - អ្នកចងក្រងហាឌីស្ស្រត្រឹមត្រូវដោយមានបណ្តាញថ្លែងព័ត៌មានបន្តគួរទុកចិត្តបានក៏ទទួលស្គាល់រឿងនេះដែរ ។ ឧទាហរណ៍ លោកមុស្លីម អ៊ីបនូ អាល់-ហាច្ច៉ាច្ច (مسلم بن الحجاج) បានរាយការណ៍នៅក្នុងហាឌីស្ស របស់លោក តមកពីលោក យ៉ាបៀរ អ៊ីបនូ អាុប់ឌុលឡោះហ្វ៍ និងលោក សាឡាម៉ាស់ អ៊ីបនូ អាក់វ៉ាអ៍ (سَلَمَةُ بن الأكوع) ថា៖

«خرج علينا منادي رسول الله صَلَّى الله عليه (وآله) وَسلَّم فقال إِنَّ رسول الله قد أذن لكم أن تستمتعوا؛ يعني متعة النِّساء »

*"អ្នកនាំពាក្យរបស់ព្រះសាស្តាﷺអល់ឡោះហ្វ៍បានមកជួបយើង ហើយបានថា៖ "ព្រះសាស្តាﷺអល់ឡោះហ្វ៍អនុញ្ញាត អ៊ីសទីមតាអ៍ (استمتاع) ឲ្យអស់លោក ពោលគឺ ការត្រេកត្រអាលជាមួយស្ត្រីដោយមានកំណត់ពេល (គឺមុតអាស់) ។"*[154]

[152] សូមមើលសៀវភៅរបស់លោក *អាដ់-ឌូរ អាល់-ម៉ាន់ស៊ូរ (الدر المنثور)* ជុំទី ២ ទំព័រ ១៤០ តពីអាយ៉ាស់មុន ។
[153] សូមមើលសៀវភៅ *យ៉ាមិអ៍ អាល់-បាយ៉ាន ហ្វី តាហ្វ់សៀរ អាល់-គួរអាន (جامع البيان في تفسير القرآن)* ជុំទី ៥ ទំព័រ ៩ ។
[154] សូមមើល *ស្ហ៊ីហ៊ះហ្វ៍ មុស្លីម (صحيح مسلم)* ជុំទី ៤ ទំព័រ ១៣០ បោះពុម្ពនៅប្រទេសអេស៊ីបត៍ ។



ដូច្នេះអស់បុគ្គលដែលថា ពិធីបុណ្យរំលឹកវិញ្ញាណក្ខន្ធមិត្តជំនិតរបស់អល់ឡោះហ្វ៍ជាអំពើហ៊ុនហាយជាមួយអល់ឡោះហ្វ៍នោះ ពុំមានហេតុផលទេ ។

## សំណួរ ២៧ - ហេតុអ្វីស៊ីអាស់ស្ម៍ឡាត់ប្រាំដងក្នុងមួយថ្ងៃក្នុងបីពេល ?

## ចម្លើយ

ដើម្បីបំភ្លឺសំណួរនេះ យើងត្រូវពិនិត្យមើលមតិរបស់អស់លោកអ្នកនីតិសាស្ត្រ (ហ្វ៊ិក្ហ៍ហ្វា) ខាងសាសនា ទាក់ទងនឹងរឿងនេះ ។

១. ម៉ាស្ហាប់មុស្លីមទាំងអស់មូលមតិគ្នាថានៅ *អារ៉ាហ្វាស់*[215] គេអាចស្ម៍ឡាត់ *ស្ហូហ្វូរ* និង *អាស្វារ* បន្តៗគ្នាបាន ដោយគ្មានចន្លោះពេលរវាងស្ម៍ឡាត់ទាំងពីរនេះ ។ នៅឯ *មុស្ហដាលីហ្វាស់*[216] គេអនុញ្ញាតឲ្យស្ម៍ឡាត់ *ម៉ាក់រីប* និង *អ៊ីស្ហាអ៍* ក្នុងពេលអ៊ីស្ហាបន្តបន្ទាប់គ្នាដែរ ។

២. អ្នកកាន់និកាយហាណាហ្វ៊ីថា៖ "ស្ម៍ឡាត់ *ស្ហូហ្វូរ* និង *អាស្វារ* បន្តន្ទាប់គ្នាដោយមិនទុកឲ្យមានពេលចន្លោះ ស្ម៍ឡាត់ *អ៊ីស្ហា* ក្រោយពី *ម៉ាក់រីប* ភ្លាមនោះត្រូវអនុញ្ញាតឲ្យធ្វើបានតែនៅឯអារ៉ាហ្វាស់ និងមុស្ហដាលីហ្វាស់ទេ ។ មិនអនុញ្ញាតឲ្យធ្វើបែបនេះក្រៅពីពីរឱកាសនេះទេ ។

[215] អារ៉ាហ្វាស់ គឺវាលមួយមានចម្ងាយ ២១ គីឡូម៉ែត្រពីខាងជើងម៉ាក់កាស់ គឺកន្លែងដែលអ្នកបំពេញពិធីហាច្ចឈប់សម្រាកចាប់ពីថ្ងៃត្រង់ទៅថ្ងៃលិច ក្នុងថ្ងៃទី ៩ ខែស៊្ហុលហ៊ីច្ចយ៉ាស់ (ថ្ងៃអារ៉ាហ្វាស់) នេះគឺពិធីមួយក្នុងការបំពេញពិធីហាច្ច ។
[216] មុស្ហដាលីហ្វាស់ គឺកន្លែងមួយដែលអ្នកបំពេញពិធីហាច្ចឈប់ដើម្បីរើសដុំថ្មសម្រាប់ចោលមិនិត្តរូបស្ទែត្ននៅមីណា ។

الكريم ويطهر عليهم من بركاته كلّ فضلٍ عميمٍ»

*"មុស្លីមក្នុងលោកធ្វើពិធីបុណ្យខួបខែកំណើតព្រះសាស្ដាﷺ ។ ពួកគេធ្វើពិធីជុបលៀង ដាក់ទានក្នុងយប់ខែនេះ ធ្វើទង្វើល្អប្រសើរនានា ថ្លែងរៀបរាប់អំពីប្រវត្តិកំណើតព្រះអង្គﷺ ថ្លែងប្រាប់មូលមនុស្សឲ្យដឹងអំពីព្រះធម៌មេត្តានិងបុណ្យបារមីរបស់ព្រះអង្គﷺ ។"*[214]

អត្ថបទនេះបញ្ជាក់ថា ពិធីបុណ្យខួបមិត្តជំនិតរបស់អល់ឡោះហ្ទ៍ﷻនោះជាការស្របច្បាប់និងជាទង្វើប្រសើរ ដែលសមស្របនឹងមតិគួរអាននិងទង្វើរបស់មុស្លីមទូទៅ ហើយបញ្ជាក់ឲ្យឃើញថាខុសអស់បុគ្គលណាដែលអះអាងថាពិធីបុណ្យនេះជាទង្វើប៊ីដ្ទអ៊ាស្ស់ (គឺការកែប្រែក្នុងសាសនា) នោះព្រោះប៊ីដ្ទអ៊ាស្ស់គឺការទទួលស្គាល់ទង្វើមួយដែលគួរអាន និងស៊ុនណាស្ស់មិនទទួលស្គាល់ ទោះជាមានលក្ខណៈពិសេសឬទូទៅក៏ដោយ ចំណែកឯពិធីបុណ្យដែលយើងបានរៀបរាប់ខាងនេះមកហើយនោះ មានចែងនៅក្នុងអាយ៉ាស្ស់គួរអាននិងនៅក្នុងទង្វើរបស់មុស្លីមតាំងពីយូរមកហើយ ។

ពិធីបុណ្យទាំងនេះត្រូវរៀបចំឡើង ក្នុងគោលបំណងសម្ដែងការលើកកិត្តិយសនិងសេចក្ដីគោរពបាវថ្លៃថ្លារបស់អល់ឡោះហ្ទ៍ﷻ ព្រមទាំងទទួលស្គាល់ថាអស់សិរីមន្តទាំងនេះនៅក្នុងអំណាចអល់ឡោះហ្ទ៍ﷻ និងត្រូវការព្រះម្ចាស់ពិភពទាំងពួងខានមិនបាន ។

ដូច្នេះ ទង្វើនេះសមស្របទៅតាមគោលការណ៍តៅហ៊ីដ្ទនិងលទ្ធិឯកទិទេពនិយម (គឺទ្រឹស្ដីមានព្រះតែមួយ) ។

[214] សូមមើលសៀវភៅ *តារិក្ហ អាល់-ខ្ហ៏មិស (تاريخ الخميس)* របស់លោក ហ៊្វូសៃន៍ អ៊ីបនូ មូហ្ហាម៉ាដ្ទ់ អាដ្ទ់-ឌ្ទីយ៉ារ បាក់រី (បោះ ពុម្ភនៅបៃរូត) ជុំទី ១ ទំព័រ ២២៣ ។



ហ្ហាឌីស្សគួរឲ្យទុកចិត្តស្ដីអំពីរឿងនេះ ដែលមានបណ្ដាញថ្លែងព័ត៌មានបន្តមានច្រើនណាស់ មិនអាចលើកមកអធិប្បាយជូនទាំងអស់បានទេនៅក្នុងសៀវភៅនេះ ។ ហេតុដូច្នេះ អស់លោកអ្នកប្រាជ្ញនិងអស់លោកអ្នកស្រាយគួរអានមុស្លីមទទួលស្គាល់មូលមតិគ្នាថា *មុតអ៊ាស្ស់* (អាពាហ៍ពិពាហ៍មានកំណត់ពេល) ត្រូវដាក់ជាបញ្ញត្តិឲ្យប្រើក្នុងសម័យអ៊ីស្លាមទើបនឹងកកើតនិងក្នុងសម័យព្រះសាស្ដាﷺ ។

តើអត្តន័យរបស់អាយ៉ាស្ស់ *មុតអ៊ាស្ស់* ត្រូវលើកចោលទេ ?

ប្រហែលជាអ្នកដែលសង្ស័យថា មុតអ៊ាស្ស់មានលក្ខណៈមិនស្របច្បាប់មានចំនួនតិចណាស់ក្នុងសម័យព្រះសាស្ដាﷺអល់ឡោះហ្ទ៍ﷻ ។ នេះបង្ហាញឲ្យឃើញថាច្បាប់នេះមិនត្រូវលើកចោលទេ ។

ហ្ហាឌីស្សនិងប្រវត្តិសាស្ត្រអ៊ីស្លាមបង្ហាញឲ្យឃើញថា ព្រះបញ្ញត្តិនេះត្រូវដាក់ឲ្យមុស្លីមទាំងអស់ប្រើជាទូទៅ រហូតដល់សម័យស្ដេចខ្ហ៏លិហ្វទីពីរដែលបានហាមប្រើព្រះបញ្ញត្តិនេះ ។

លោក មុស្លីម អ៊ីបនូ អាល់-ហ្ហាជ្ជ៉យ៉ាជ្ជ៉ បានរាយការណ៍នៅក្នុងស្ស៏ហ្ហ៊ិះហ្ហ៍របស់លោកថាលោក អ៊ីបនូ អ៊ាប់បាស់ និងលោក អាល់-ស្ហ៊ូបៃរ៍ ប្រឆាំងការហាមធ្វើមុតអ៊ាស្ស់ជាមួយស្ត្រី និងមុតអ៊ាស្ស់ពេលបំពេញពិធីហ្ហាជ្ជ ។ លោក យ៉ាជ្ជបៀរ អ៊ីបនូ អ៊ាប់ឌុលឡោះហ្ទ៍ មានប្រសាសន៍ថា៖

"فعلنا هما مع رسول الله ثم نهانا عنهما عُمر فلم نعد لهما."

"ក្នុងសម័យព្រះសាស្ដាﷺអល់ឡោះហ្ទ៍ﷻ យើងធ្លាប់តែធ្វើទាំងពីរនេះ (គឺមុតអ៊ាស្ស់ទាំងពីរ) ។ ក្រោយមក អ៊ូម៉ារ បានហាមយើងធ្វើមុតអ៊ាស្ស់ទាំងពីរ

នេះ ក្រោមយពីនោះមកយើងលែងធ្វើមុតអ៊ុស្ង់ទៀត ។" [155]

នៅក្នុងសៀវភៅស្រាយគួរអានរបស់លោក លោក យ៉ាឡាល់ អាដ៌្-ឌីន អាស់-ស៊ូយូទ្វី (جلال الدين السيوطي) បានរាយការណ៍តមកពីលោក អ៊ាប់ដ៏ាល់-រ៉ស្សាក់ លោក អាប៊ូ ដ៉ារ៉ូដ និងលោក អ៊ីបនូ យ៉ារៀរ អស់លោកទាំងនេះបានរាយការណ៍តមកពីលោក អាល់-ហ៊ាកាំ ថាគេបានសួរលោកថា៖ "តើអាយ៉ាស់មុតអ៊ុស្ង់ត្រូវលើកចោលទេ ?" លោកបានតបថា៖ "ទេ អ៊ាលី صلوات الله عليه والسلام មានវចនៈថា៖

"لولا أن عمر نهى عن المتعة ما زنى إلا شقيّ."

*"បើអ៊ូម៉ារមិនបានហាមធ្វើមុតអ៊ុស្ង់ទេនោះ នឹងពុំមានអ្នកមួយប្រព្រឹត្តអំពើអតិចរិយានិងអំពើសហាយស្មន់គ្នា (ស៊ីណា) ឡើយ លើកលែងតែមនុស្សអាក្រក់ប៉ុណ្ណោះ ។"* [156]

លោក អ៊ាលី អ៊ីបនូ មូហាំម៉ាដ់ កៅស្សាយ៉ី (علي بن محمد القَوْشَجي) មានប្រសាសន៍ដែរថា៖ "អ៊ូម៉ារ អ៊ីបនូ អាល់-ខុត្តប់ បានប្រកាសពីលើវេទិកាថា៖

"أيها الناس ثلاث كنّ على عهد رسول الله أنا أنهي عنهنّ و أحرمهنّ وأعاقب عليهنّ وهى متعة النساء ومتعة الحج وحيّ على خير العمل."

*"ប្រជារាស្ត្រអើយ គេបានអនុញ្ញាតឲ្យធ្វើវត្ថុបីប្រការសម័យព្រះសាស្ដា ﷺ អល់ឡោះហ្ (عزّ وجلّ) ពេលនេះខ្ញុំហាមធ្វើវត្ថុបីប្រការនោះ ។ ខ្ញុំធ្វើទោសអ្នកណាដែលធ្វើវត្ថុបីប្រការនោះ ។ វត្ថុបីប្រការនោះគឺ មុតអ៊ុស្ង់ជាមួយស្ត្រី*

[155] សូមមើល *ស្វ៉ហ៊ិះហ្ មុស្លីម (صحيح مسلم)* ជុំទី ១ ទំព័រ ៣៩៥ ។ សូមមើល ស៊ូណាន អាល់-បៃហ្គាគ្គី (سنن الكبرى بيهقي) ជុំទី ៧ ទំព័រ ២០៦ ។

[156] សូមមើលសៀវភៅ *អាដ៌្-ឌួរ អាល់-ម៉ាន់ស៊ួរ* (الدر المنثور) ជុំទី ២ ទំព័រ ១៤០ សេចក្តីអធិប្បាយមុតអ៊ុស្ង់ ។



*"អល់ឡោះហ្ ព្រះម្ចាស់អស់ទូលព្រះបង្គំជាខ្ញុំអើយ សូមព្រះមេត្តាប្រទានចុះមកពីលើមេឃ ឲ្យអស់ទូលព្រះបង្គំជាខ្ញុំនូវអាហារដែលជាពិធីលៀងធំមួយ សម្រាប់អស់ទូលព្រះបង្គំជាខ្ញុំ សម្រាប់អ្នកដំបូងបង្អស់និងសម្រាប់អ្នកចុងក្រោយបង្អស់ក្នុងចំណោមអស់ទូលព្រះបង្គំជាខ្ញុំ ហើយជាសញ្ញាមួយដែលមកពីព្រះអង្គ ។ សូមព្រះអង្គមេត្តាប្រទានជីវព្រឹត្តឲ្យអស់ទូលព្រះបង្គំជាខ្ញុំ ព្រះអង្គជាអ្នកផ្តត់ផ្គង់ប្រសើរបំផុត ៥:១១៤ ។"* [213]

ព្រះសាស្តាអ៊ីសា (عليه السلام) សូមឲ្យអល់ឡោះហ្ (عزّ وجلّ) ប្រទានអាហារមកពីលើមេឃ ហើយសន្យាថានឹងធ្វើពិធីបុណ្យខួបរំលឹកថ្ងៃនេះ ។
ពេលព្រះសាស្តាថ្លៃថ្នូរ ដូចណាប៊ីអ៊ីសា (عليه السلام) ធ្វើពិធីបុណ្យខួបរំលឹកថ្ងៃដែលគេដាក់អាហារសួគ៌ចុះនោះ ដែលធ្វើឲ្យអង្គប្រាណរីករាយនោះ ហេតុអ្វីមុស្លីមក្នុងលោកមិនរៀបចំពិធីបុណ្យខួបរំលឹកថ្ងៃដាក់គួរអាន ឬថ្ងៃកំណើតព្រះសាស្តា ﷺ ដែលជាព្រះមាគ៌ាទៅកាន់សុខុមាលភាព និងជាអ្នកសង្គ្រោះមនុស្សជាតិ តើទង្វើបែបនេះជាអំពើហ៊ុនហាយ ឬជាការកែប្រែ (ប៊ីដ្អ៊ុស្ង់) នៅក្នុងសាសនាទេ ?

## ទង្វើរបស់ពួកមុស្លីម

អ្នកកាន់សាសនាអ៊ីស្លាមក្នុងសម័យយូរអង្វែងមកហើយបានធ្វើពិធីបុណ្យបែបនេះ ដើម្បីរំលឹកវិញ្ញាណក្ខន្ធព្រះសាស្តា ﷺ ។
នៅក្នុងសៀវភៅ តារិក្ អាល់-ខ៉ូមិស (تاريخ الخميس) លោក ហ៊ូសៃន៍ អ៊ីបនូ មូហាំម៉ាដ់ អាដ៌្-ឌីយ៉ារ បាក់រី បានសរសេរថា៖

«ولايزال أهل الإسلام يحتفلون بشهر مولده عليه السّلام ويعملون الولائم ويتصدّقون في لياليه بأنواع الصّدقات ويظهرون السّرور ويزيدون في المبرّات ويعتنون بقرائة مولده

[213] ស៊ូរ៉ោះត៍ អាល់-ម៉ាអ៊ីដ៉ាស្ង់

នៅក្នុងព្រះគម្ពីរគួរអាន អល់ឡោះហ្ ﷻ ថែងអំពីព្រះសាស្តា ﷺ ថា៖

وَرَفَعۡنَا لَكَ ذِكۡرَكَ

*"យើងលើកតម្កើងឲ្យអ្នកនូវពិសុរុតសព្វអ្នក ? ៩៤:៤"*[212]

អាយ៉ាស់នេះសឲ្យឃើញច្បាស់ថា អល់ឡោះហ្ ﷻ ចង់ឲ្យសេចក្តីរុងរឿង និងសេចក្តីថ្កុំថ្កើងរបស់ព្រះសាស្តា ﷺ កើនឡើងនៅក្នុងលោក ។ អល់ឡោះហ្ ﷻ ផ្ទាល់លើកតម្កើងព្រះអង្គ ﷺ នៅក្នុងគួរអាន ។

យើងអនុវត្តិតាមព្រះគម្ពីរអល់ឡោះហ្ ﷻ ដោយរៀបចំព្រះពិធីបុណ្យនេះ ដោយគោរពព្រះគំរូសុក្រឹតដ៏មហារុងរឿងនេះ ។ ធ្វើបែបនេះ យើងគ្រាន់តែយកតម្រាប់តាមព្រះម្ចាស់ពិភពទាំងពួងទេ ។
មុស្លីមនៅក្នុងព្រះពិធីបុណ្យនេះ ពុំមានគោលបំណងអ្វីក្រៅពីគោលបំណងពង្រឹងព្រះកិត្យានុភាពរបស់ព្រះសាស្តា ﷺ ទេ ។

## ការដាក់វ៉ាហ៊្យុចុះមក មិនមែនមិនសូវសំខាន់ជាងការដាក់ចុះនូវអាហារ (អាល់-ម៉ាអ៊ីដាស់) នោះទេ

ព្រះមហាគម្ពីរគួរអានថែងអំពីរឿងនេះតាមរយៈព្រះវចនៈរបស់ព្រះសាស្តាអ៊ីសា عليه السلام ថា៖

قَالَ عِيسَى ٱبۡنُ مَرۡيَمَ ٱللَّهُمَّ رَبَّنَآ أَنزِلۡ عَلَيۡنَا مَآئِدَةٗ مِّنَ ٱلسَّمَآءِ تَكُونُ لَنَا عِيدٗا لِّأَوَّلِنَا وَءَاخِرِنَا وَءَايَةٗ مِّنكَۖ وَٱرۡزُقۡنَا وَأَنتَ خَيۡرُ ٱلرَّٰزِقِينَ

*"អ៊ីសា បុត្ររបស់ម៉ារយ៉ាំ បានទូល[ទៅកាន់អល់ឡោះហ្]ថា៖*

[212] ស៊ូរ៉ោះតុ អាល់-អាស្ហ្សារ ឬ អាល់-អ៊ីនស្ហីរ៉ោះហ្ 94:4 ។



*មុតអុាស្ហុំពេលបំពេញពិធីហាច្ជ និងថា "ហៃយ៉ា អុាឡា ខ្ហយ់រីល-អុាម៉ាល់ (حي على خير العمل ចូរមកសាងអំពើល្អប្រសើរបំផុត) [ក្នុងអាស្ហាន] ។"*[157]

មានហាឌីស្ហច្រើនណាស់ស្តីអំពីរឿងនេះ មិនអាចលើកយកទាំងអស់មកបង្ហាញជូនក្នុងសៀវភៅតូចនេះបានទេ ។[158]

មុតអុាស្ហុំជាអាពាហ៍ពិពាហ៍មួយប្រភេទ ព្រោះអាពាហ៍ពិពាហ៍មានលាក្ខណៈអចិន្ត្រៃនិងមានពេលកំណត់ ។ ស្ត្រីដែលបានធ្វើកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍មានពេលកំណត់ជាភារិយាពេញច្បាប់របស់បុរស ឯបុរសជាស្វាមីពេញច្បាប់របស់ស្ត្រី ។ អាពាហ៍ពិពាហ៍ប្រភេទនេះមានថែងនៅក្នុងអាយ៉ាស់គួរអានទាំងអស់ដែលស្តីអំពីអាពាហ៍ពិពាហ៍ ។

[157] សូមមើលសៀវភៅ *ស្ហារហ៍ អាល់-តាច្ជរីដ* របស់ លោក អាល់-កៅស្ហាជ្ជី (شرح التجريد القوشجي) "មាបាហ៊ីស្ហ អាល់-អ៊ីម៉ាម៉ាស្ហ (المباحث الإمامة)" ទំព័រ ៤៨៤ ។
[158] ព័ត៌មានបន្ថែម សូមមើលសៀវភៅយោងខាងក្រោមនេះគឺ៖ *មុសណាដ់ អាស្ហម៉ាដ់ អ៊ីបនូ ហាន់បាល់* ដុំទី ៣ ទំព័រ ៣៥៦, ៣៦៣ ។ *អាល់-បាយ៉ាន វ៉ាត់-តាប់យីន (البيان والتبيين)* របស់លោកអាល់-យ៉ាហ៊ីស្ហ (الجاحظ) ដុំទី ២ ទំព័រ ២២៣ ។ *អាស្ហកាម អាល់-គួរអាន (احكام القرآن)* របស់លោក អាល់-យ៉ាស្ហស្ហ (الجصاص) ដុំទី ១ ទំព័រ ៣៤២ ។ *តាហ្វសៀរ អាល់-គួរទូប៊ី (تفسير القرطبي)* ដុំទី ២ ទំព័រ ៣៧០ ។ គីតាប អាល់-ម៉ាប់ស៊ុត្ត (كتاب المبسوط) របស់លោក សារ៉ក្ហុស៊ី អាល់-ហាណាហ្វី (سرخسي الحنفي) "គីតាប អាល់-ហាច្ជ", "បាប់ អាល់-គួរអាន" ។ ស្ហាដ់ អាល់-ម៉ាអាដ់ (زاد المعاد) របស់លោក អ៊ីបនូ អាល់-កូយ់យីម (ابن قيم) ដុំទី ១ ទំព័រ ៤៤៤ ។ កាន់ស្ហ អាល់-អ៊ុមម៉ាល់ (كنز العمال ) ដុំទី ៨ ទំព័រ ២៩៣ ។ មុសណាដ់ អាប៊ូ ដាវុដ អាត់-ត្ហយ៉ាលីស៊ី (مسند ابو داؤد الطيالسي) ទំព័រ ២៤៧ ។ តារិក្ហ អាត់-ត្ហបារី (تاريخ الطبري) ដុំទី ៥ ទំព័រ ៣២ ។ អាល់-មុសតាប៊ីន របស់លោក ត្ហបារី ។ តាហ្វសៀរ រ៉ាស្ហី ដុំទី ៣ ទំព័រ ២០២ ។ តាហ្វសៀរ អាប៊ូ ហៃយ៉ាន់ ដុំទី ៣ ទំព័រ ២១៨ ។

គួរអានថែងថា៖

إِلَّا عَلَىٰٓ أَزۡوَٰجِهِمۡ أَوۡ مَا مَلَكَتۡ أَيۡمَٰنُهُمۡ وَٱلَّذِينَ هُمۡ لِفُرُوجِهِمۡ حَٰفِظُونَ ۝٥

*"ពួកគេការពារខ្មាស (វៀរចាកមេថុន) ។ [ពួកគេវៀរចាកការរួមដំណេកជាមួយស្ត្រីផ្សេង] វៀរលែងតែជាមួយបណ្ដាភរិយាពួកគេ ឬជាមួយទាសីពួកគេ[ដោយស្របតាមច្បាប់អល់ឡោះហ៍] (២៣:៥-៦) ។"*[159]

ស្ត្រីរៀបដែលអាពាហ៍ពិពាហ៍តាមកិច្ចព្រមព្រៀង មានកំណត់ស្របតាមច្បាប់ ស្ត្រីនោះនៅក្នុងចំណោមស្ត្រីដែលពាក្យគួរអានហៅថា "إِلَّا عَلَىٰ أَزۡوَٰجِهِمۡ" *(វៀរលែងតែជាមួយបណ្ដាភរិយាពួកគេ)* មិនផ្សេងពីនេះទេ ។ ហេតុដូច្នេះ ស្ត្រីដែលរៀបការជាមួយបុរសតាមកិច្ចព្រមព្រៀងមុតអ្ញុស្ញ់ទៅជាភរិយារបស់បុរសនោះ ហើយស្ត្រីនោះនៅក្នុងចំណោមបណ្ដាស្ត្រីដែលរាប់បញ្ចូលក្នុងពាក្យ "أَزۡوَٰجِهِمۡ" ។

អាយ៉ាស្ញ់ខាងលើនេះ (ស៊ូរ៉ោះត៍ អាល់-មុមីនូន) អនុញ្ញាតឲ្យរួមភេទជាមួយភរិយានិងទាសី តែស្ត្រីដែលរៀបការតាមកិច្ចព្រមព្រៀងមានកំណត់នោះក៏នៅក្នុងចំណោមភរិយាដែរ ។

អាល់-មុមីនូន ដែលអ្នកខ្លះថាជាអាយ៉ាស្ញ់ដែលលើកអាយ៉ាស្ញ់ឯទៀតចោលនោះ ត្រូវបើកឲ្យដឹងនៅឯម៉ាក់កាស្ញ់ (មុនព្រះសាស្ដាﷺភៀសខ្លួនទៅម៉ាឌីណាស្ញ់) រីឯស៊ូរ៉ោះត៍ អាន់-នីសាអ៍ ដែលមានអាយ៉ាស្ញ់មុតអ្ញុស្ញ់នោះ ត្រូវបើកឲ្យដឹងនៅឯម៉ាឌីណាស្ញ់ (ក្រោយពីព្រះសាស្ដាﷺបានភៀសខ្លួន) ។

[159] អាល់-មុមីនូន 23:5-6 ។



ٱلۡمُفۡلِحُونَ

*"ដូច្នេះជនទាំងឡាយណាដែលជឿគេ លើកកិត្តិយសគេ ជួយសង្គ្រោះគេ ប្រតិបត្តិតាមរស្មីដែលត្រូវដាក់ចុះមកជាមួយគេនោះ ជនទាំងនោះនឹងមានជ័យជំនះ ៧:១៥៧ ។"*[211]

អាយ៉ាស្ញ់នេះសឲ្យឃើញយ៉ាងជាក់ច្បាស់ថា លើកតម្កើងព្រះសាស្ដាﷺ អល់ឡោះហ៍عز وجلជាទង្វើត្រឹមត្រូវ និងស័ក្តិសមតាមមតិអ៊ីស្លាម ពិធីបុណ្យខួបកំណើតព្រះសាស្ដាﷺរំលឹកវិញ្ញាណក្ខន្ធព្រះសាស្ដាﷺ និងពិធីគោរពព្រះអង្គﷺនោះ ជាទង្វើដែលធ្វើឲ្យអល់ឡោះហ៍عز وجلទ្រង់សព្វព្រះហឫទ័យ ។ អាយ៉ាស្ញ់នេះថែងអំពីគុណសម្បត្តិបួនរបស់បណ្ដាអ្នកដែលមានជ័យជំនះបានដល់សុខុមាលភាពគឺ៖

ក. ជំនឿ ٱلَّذِينَ ءَامَنُواْ بِهِۦ (ជនទាំងឡាយណាដែលជឿគេ) ។

ខ តាមរស្មីព្រះអង្គ وَٱتَّبَعُواْ ٱلنُّورَ ٱلَّذِيٓ أُنزِلَ مَعَهُۥٓ (ប្រតិបត្តិតាមរស្មីដែលត្រូវដាក់ចុះមកជាមួយគេ)

គ ជួយគាំទ្រព្រះអង្គﷺ وَنَصَرُوهُ (ជួយគាំទ្រគេ)

ឃ លើកកិត្តិយសព្រះសាស្ដាﷺ وَعَزَّرُوهُ (លើកកិត្តិយសគេ) ។

ដូច្នេះ លើកតម្កើងនិងគោរពព្រះសាស្ដាﷺគួបជាមួយជំនឿ ជួយគាំទ្រព្រះអង្គﷺនិងស្ដាប់បញ្ជាព្រះអង្គﷺ ជាករណីយកិច្ចរបស់អ្នកមានសទ្ធាឯរំលឹកវិញ្ញាណក្ខន្ធព្រះសាស្ដាﷺគឺ *"លើកកិត្តិយសគេ"* ។

## ធ្វើពិធីបុណ្យបញ្ជាក់ថា យើងគោរពនិងស្ដាប់បង្គាប់អល់ឡោះហ៍عز وجل

[211] ស៊ូរ៉ោះត៍ អាល់-អាក់រ៉ហ្វ 7:157 ។

សម្រាប់បណ្ដាអ្នកប្រាជ្ញក៏ដោយ យើងនឹងបង្ហាញភ័ស្ដុតាងដែលបញ្ជាក់ថាវាជារឿងស្របច្បាប់ ដើម្បីលុបបំបាត់ចម្ងល់រឿងនេះ ។

## ធ្វើពិធីបុណ្យជាការសម្ដែងសេចក្ដីស្រឡាញ់របស់យើង

ព្រះមហាគម្ពីរគួរអានណែនាំឲ្យមុស្លីមស្រឡាញ់ព្រះសាស្ដាﷺ និងព្រះរាជកុលដ្ឋានព្រះអង្គﷺថា៖

قُل لَّآ أَسۡـَٔلُكُمۡ عَلَيۡهِ أَجۡرًا إِلَّا ٱلۡمَوَدَّةَ فِي ٱلۡقُرۡبَىٰۗ

*"ចូរអ្នកថា៖ "ខ្ញុំមិនសូមឈ្នួលពីអស់លោកសម្រាប់អ្វីទាំងនេះទេ (គឺការផ្សាយការអប់រំ) សូមឲ្យតែអាណិតស្រឡាញ់បណ្ដាសាច់សាលោហិតជំនិតរបស់ខ្ញុំ ៤២:២៣ ។"*[210]

ប្រាកដណាស់ ធ្វើពិធីបុណ្យរំលឹកវិញ្ញាណក្ខន្ធព្រះសន្តបុគ្គលជាការបង្ហាញនូវសេចក្ដីស្រឡាញ់ និងសេក្ដីរាប់អានរបស់ប្រជាពលរាស្ត្រចំពោះសិរីមន្តទាំងនេះ ជាទង្វើស្របនឹងគួរអាន ។

## ធ្វើពិធីបុណ្យ ជាការសម្ដែងសេចក្ដីគោរពចំពោះព្រះសាស្ដាﷺ

គួរអានចាត់ទុកទង្វើលើកតម្កើង និងការគាំទ្រព្រះសាស្ដាﷺអល់ឡោះហ្វ៍ عز وجل ជាគំរូគារវៈនិងសុខុមាលភាព ។

فَٱلَّذِينَ ءَامَنُواْ بِهِۦ وَعَزَّرُوهُ وَنَصَرُوهُ وَٱتَّبَعُواْ ٱلنُّورَ ٱلَّذِيٓ أُنزِلَ مَعَهُۥٓ أُوْلَٰٓئِكَ هُمُ

[210] ស៊ូរ៉ោះត៍ អាស្ស៊ូរ៉ 42:23 ។



តើអាយ៉ាស់ដែលត្រូវបានបើកឲ្យដឹងនៅឯម៉ាក់កាស់នោះ អាចលើកចោលនូវអាយ៉ាស់ដែលនឹងត្រូវបើកឲ្យនៅឯម៉ាឌីណាស់ (គឺនៅពេលក្រោយ) បានដូចម្ដេចទៅ ?

ភ័ស្ដុតាងជាក់ស្ដែងមួយទៀតដែលបញ្ជាក់ថា ពុំមានការលើកអាយ៉ាស់មុតអ៊ុស់ចោលក្នុងសម័យព្រះសាស្ដាﷺនោះ គឺហាទីស្ស៍សន្ទឹកសន្ទាប់ដែលបដិសេធការលើកអាយ៉ាស់នេះចោល ក្នុងសម័យព្រះសាស្ដាﷺ ឧទាហរណ៍ហាទីស្ស៍ដែលលោក យ៉ាឡាល់ អាដ្ឌ-ឌីន អាស់-ស៊ូយូទី បានរាយការណ៍និងបានថ្លែងអធិប្បាយនៅក្នុង អាដ្ឌ-ឌូរ អាល់-ម៉ាន់ស៊ូរ (الدر المنثور) នោះជាដើម ។[160]

សូមរំលឹកថាអ៊ីម៉ាំអាស្ល់លុល-បៃត៍ عليهم السلام យោលតាមបញ្ញត្តិហាទីស្ស៍ អាស្ស៊ុ-ស្ហាក្ក៏ឡៃន៍ ដែលជាព្រះមគ្គទេសក៏ដឹកនាំអ៊ុមម៉ាត់និងដែលមិនបែកចេញពីគួរអាននោះ បានបញ្ជាក់លក្ខណៈស្របច្បាប់របស់អាពាហ៍ពិពាហ៍មុតអ៊ុស់ ហើយច្រានចោលមតិដែលថាអាយ៉ាស់មុតអ៊ុស់ត្រូវលើកចោលនោះ ។[161]

ការដែលអ៊ីស្លាមអាចដោះស្រាយបញ្ហារបស់សង្គម គ្រប់សម័យកាលនោះ បញ្ជាក់ឲ្យដឹងថាអាពាហ៍ពិពាហ៍ប្រភេទនេះមានកល្ខណៈត្រឹមត្រូវ ស្របច្បាប់ តាមលក្ខខ័ណ្ឌអធិប្បាយខាងលើនេះហើយ ។ សព្វថ្ងៃ មធ្យោបាយប្រសើបំផុតសម្រាប់ការពារយុវជនពីការផុងខ្លួនក្នុងអំពើអាស្រូវ និងអំពើ

[160] សូមមើលសៀវភៅ *អាដ្ឌ-ឌូរ អាល់-ម៉ាន់ស៊ូរ* (الدر المنثور) ជុំទី ២ ទំព័រ ១៤០-១៤១ សេចក្ដីអធិប្បាយមុតអ៊ុស់ ។

[161] សូមមើលសៀវភៅ *វ៉ាសាអ៊ីល អាស្ស៊ុ-ស៊ីអ៊ុស់ (وسائل الشيعة)* ជុំទី ១៤ ទំព័រ ៤៣៦ "គីតាប អាន់-នីកាស់" វគ្គមុខស្ដីអំពី មុតអ៊ុស់ ។

ខុសសីលធម៌នោះ គឺអាពាហ៍ពិពាហ៍មានកំណត់ពេលត្រឹមត្រូវតាមលក្ខខណ្ឌច្បាប់ ។

## សំណួរ ១៩ - ហេតុអ្វីស៊ីអ្ហាស់ក្រាបប្រណិប័តន៍លើដីទូរបាស់ ?

## ចម្លើយ

អ្នកខ្លះគិតថាក្រាបប្រណិប័តន៍លើដី ឬទូរបាស់ដែលយកមកពីកន្លែងបញ្ចុះសពទុក្ករបុគ្គលប្រៀបបាននឹងគោរពសក្ការៈដីនោះ ហើយចាត់ទុកជាអំពើហ៊ុនហាយមួយ (គឺស្ហ៊ីរិក) ។

ដើម្បីឆ្លើយតបសំណួរនេះ ត្រូវដឹងថាមានការខុសគ្នារវាងឃ្លា "អាស់-ស៊ូឃ្ជូដ លិលឡាស់" (ក្រាបប្រណិប័តន៍ *ដើម្បី* អល់ឡោះហ្វ៍ عز وجل) និងឃ្លា "អាស់-ស៊ូឃ្ជូដ អ្ហុឡាល់-អារដ្ហ៍" (ក្រាបប្រណិប័តន៍ *លើ* ដី) ។ បញ្ហារបស់បុគ្គលនិយាយខាងលើនេះ គឺពួកគេមិនចេះវែកញែកន័យរបស់ឃ្លាទាំងពីរនេះទេ ។

ច្បាស់ណាស់ អត្ថន័យរបស់ *"អាស់-ស៊ូឃ្ជូដ លិលឡាស់"* គឺ "ក្រាបប្រណិប័តន៍ដើម្បីអល់ឡោះហ្វ៍ عز وجل (គឺផ្តោតចិត្តទៅរកអល់ឡោះហ្វ៍ عز وجل)" រីឯ *"អាស់-ស៊ូឃ្ជូដ អ្ហុឡាល់-អារដ្ហ៍"* មានន័យថា "ក្រាបប្រណិប័តន៍លើដី" ។ អាចនិយាយបានម្យ៉ាងទៀតថា ដែលយើងក្រាបប្រណិប័តន៍លើដីនោះ យើងក្រាបប្រណិប័តន៍ដើម្បីអល់ឡោះហ្វ៍ عز وجل (គឺផ្តោតចិត្តទៅងអល់ឡោះហ្វ៍ عز وجل) តាមគោលការណ៍ មុស្លីមទាំងអស់ក្នុងលោកក្រាបប្រណិប័តន៍លើអ្វីមួយដើម្បីអល់ឡោះហ្វ៍ عز وجل ។ អស់ទាំងអ្នកធ្វើពិធីហ្ហាជ្ជ



*គេនឹងឲ្យបញ្ជីខ្ញុំក្នុងដៃស្តាំ ។"*[209]

ហ្ហាឌីស្សទាក់ទងនឹងការពឹងពាក់មិត្តជំនិតរបស់អល់ឡោះហ្វ៍ عز وجل មានច្រើនណាស់ ។ ហ្ហាឌីស្សដែលយើងបានលើកមកបង្ហាញហើយនេះបញ្ជាក់ថាតាវ៉ាស់ស៊ូល (គឺការពឹងពាក់) ជាការស្របច្បាប់ ហើយសមស្របនឹងព្រះស៊ុនណាស់ព្រះសាស្តា ﷺ សមស្របនឹងទង្វើរបស់បណ្តាសាវកនិងអស់លោកអ្នកប្រាជ្ញល្បីៗ មិនបាច់អធិប្បាយបន្ថែមទេ ។

សេចក្តីអធិប្បាយនេះ បញ្ជាក់ឲ្យឃើញការមិនសមហេតុផលរបស់បុគ្គលដែលអះអាងថា *តាវ៉ាស់ស៊ូល* តាម រយៈបុគ្គលជំនិតរបស់អល់ឡោះហ្វ៍ عز وجل នោះជាអំពើហ៊ុនហាយនិងជាអំពើប៊ីដ្ហអ្ហុស់ (គឺកែប្រែ) នៅក្នុងសាសនា ។

## សំណួរ ២៦ - តើធ្វើបុណ្យខួបកំណើតរបស់មិត្តជំនិតរបស់អល់ឡោះហ្វ៍ عز وجل ជាអំពើហ៊ុនហាយ ឬជាការកែប្រែ (ប៊ីដ្ហអ្ហុស់) ក្នុងសាសនាទេ ?

## ចម្លើយ

ទោះបីការគោរព និងការរំលឹកវិញ្ញាណក្ខន្ធបាវថ្លៃថ្លារបស់អល់ឡោះហ្វ៍ عز وجل ដោយធ្វើបុណ្យខួបកំណើតរបស់សិរីមន្តទាំងនេះ ជារឿងឥតប្រកែកបាន

[209] សូមមើលសៀវភៅរបស់លោក អ៊ីបនូ ហ្ហាយ៉ាជ្រ អាល់-អ្ហុស់ក៏ឡានី *អាស្ស-ស្ហ៏វ៉ាអ្ហុីក្វ អាល់-មុះហ្ហ៍រីក្វោះត្វ៍ (الصواعق المحرقة)* (បោះពុម្ពនៅអេស៊ីបត៍ ទីក្រុងកៃរ៍) ទំព័រ ១៧៨ ។

وأنّك مأمُونٌ على كلّ غالِبِ

وانك أدْنى الْمرسلينَ وسيلةً

إلى الله يا بْنَ الأكرمينَ الاطائب

*"ទូលព្រះបង្គំជាខ្ញុំសូមប្ដេជ្ញាថាពុំមានព្រះទេក្រៅពីព្រះអង្គ ﷻ ថាគេបានប្រគល់អទិស្សមានការណ៍ទាំងអស់ឲ្យព្រះអង្គ ﷺ ។ ទូលព្រះបង្គំជាខ្ញុំសូមប្ដេជ្ញាថា ក្នុងចំណោមព្រះសាស្ដាទាំងអស់ ឱព្រះរាជបុត្ររបស់អស់បុគ្គលថ្លៃថ្លា របស់អស់បុគ្គលបរិសុទ្ធអើយ ព្រះអង្គ ﷺ ជាមធ្យោបាយ (វ៉ាស៊ីឡាស្ញ) ជិតអល់ឡោះហ្ ﷻ បំផុត ។"*[208]

ទោះបីព្រះសាស្ដា ﷺ បានឮកំណាព្យនេះពីមាត់ ស្វាដ់ អ៊ីបនូ ក៏រ៉ីប ក៏ដោយ ក៏ព្រះអង្គ ﷺ មិនដែលហាមគាត់ ឬចោទប្រកាន់គាត់ថាប្រព្រឹត្តអំពើហ៊ុនហាយ (គឺស្ហ៊ីរិក) ឬកែប្រែ (ប៊ីដូអាស្ញ) ក្នុងជំនឿសាសនាឡើយ ។

អ៊ីម៉ាំ អាស្ញ-ស្វាហ្វីអ៊ី ក៏បាននិយាយអំពីរឿងនេះដែរនៅក្នុងកំណាព្យរបស់លោក គឺ៖

آلُ النَّبِيِّ ذَرِيعتِي

فهُمُ إليهِ وسِيْلَتِي

أرجوهِمْ اعطى غداً

بيدي اليمينِ صحيفتِي

*"ព្រះរាជកុលដ្ឋានរបស់ព្រះសាស្ដា ﷺ ជាទីពឹងពាក់ (វ៉ាស៊ីឡាស្ញ) របស់ខ្ញុំដើម្បីទៅរកអល់ឡោះហ្ ﷻ ។ ខ្ញុំសង្ឃឹមថា អាស្រ័យព្រះអង្គទាំងនេះ عليهم السلام*

[208] សូមមើលសៀវភៅរបស់ សៃយីដ្ អាស្ញម៉ាដ្ អ៊ីបនូ ស្សៃនី អាដ្-ដាស្ញឡាន់ (أحمد بن زيني دحلان) *អាដ្-ឌូរ៉ារ៍ អាស់-ស៊ុននីយ៉ាស្ញ (الدرر السنية)* ទំព័រ ២៩ រាយការណ៍ដោយ អាត្-ត្ហបារ៉ានី (الطبراني) ។



នៅឯព្រះមហាគ្រឹះអល់ឡោះហ្ ﷻ ក្រាបប្រណិប័តន៍លើថ្មម៉ាស់យ៊ិដ្អាល់-ហារ៉ាមដូចគ្នាដែរ តែគោលបំណងរបស់ពួកគេគឺក្រាបប្រណិប័តន៍ដើម្បីអល់ឡោះហ្ ﷻ (គឺផ្ដោតចិត្តទៅឯអល់ឡោះហ្ ﷻ) ។

ដោយបានឃើញហើយ គេដឹងច្បាស់ថាការក្រាបប្រណិប័តន៍លើដី លើអនុផលិតផលមកពីរុក្ខជាតិ ។ល។ មិនមានន័យថាគោរពសក្ការៈវត្ថុទាំងនោះទេ តែមានន័យថាក្រាបប្រណិប័តន៍ដើម្បីអល់ឡោះហ្ ﷻ និងគោរពសក្ការៈព្រះអង្គ ﷻ ដោយបន្ទាបខ្លួន និងដោយដាក់ខ្លួនទៀបនឹងដី ។ ស្រដៀងគ្នាដែរ គេដឹងច្បាស់ថាការក្រាបប្រណិប័តន៍ *លើទូរបាស្ញ* ខុសគ្នាពីក្រាបប្រណិប័តន៍ *ដើម្បីទូរបាស្ញ* (គឺសំពះទូរបាស្ញ មិនសំពះអល់ឡោះហ្ ﷻ ទេ) ។

ព្រះគម្ពីរគួរអានចែងថា៖

وَلِلَّهِ يَسْجُدُ مَنْ فِي السَّمَاوَاتِ وَالْأَرْضِ

*ប្រជានិករដែលនៅលើមេឃទាំងឡាយ និងផែនដីក្រាបប្រណិប័តន៍អល់ឡោះហ្ (១៣:១៥) ។*[162]

ព្រះសាស្ដា ﷺ ក៏មានព្រះវចនៈដែរថា៖

"جُعِلَتْ لِيَ الأَرْضُ مَسْجِداً وَ طَهُوْراً."

*"គេបានចាត់តាំងដី[បរិសុទ្ធ]ជាកន្លែងក្រាបប្រណិប័តន៍សម្រាប់ខ្ញុំ និងជាភ្នាក់ងារជម្រះបន្សុទ្ធ ។"*

ដូច្នេះ "ក្រាបប្រណិប័តន៍ *ដើម្បី* អល់ឡោះហ្ ﷻ" និង "ក្រាបប្រណិប័តន៍ *លើ* ដី ឬ *ទូរបាស្ញ*" មិនត្រឹមតែខុសគ្នាឆ្ងាយប៉ុណ្ណោះទេ តែទាំងពីរនេះ

[162] សូមមើលគួរអាន ស្វរ៉ោះត៍ អាររ៉ាក់ដ្ គឺស្វរ៉ោះត៍ទី ១៣ អាយ៉ាស្ញ ១៥ ។

ថែមទាំងត្រូវគ្នាយ៉ាងសក្តិសមទៀតផង ។ នេះព្រោះតែការក្រាបប្រណិប័តន៍លើអនុផលិតផលរុក្ខជាតិជាអំពើរាបទាប និងជាការដាក់ខ្លួនមួយបែបដ៏ប្រសើរបំផុតចំពោះអល់ឡោះហ្ ﷻតែមួយគត់ ។ ដើម្បីអធិប្បាយបំភ្លឺមតិរបស់ស្ុីអ្ាស្ុ គប្បីលើកយកមកនូវពាក្យពេជន៍របស់ព្រះអគ្គមហាប្រមុខ អ៊ីមុាំអាស្ុ-ស្ុឌិក្វ صلوات الله عليه والسلام មកអធិប្បាយ គឺ៖

عن هشام ابن الحكم قال: قلت لأبي عبد الله: أخبرني عما يجوز السجود عليه وعمّا لا يجوز؟ قال: السجود لا يجوز إلا على الأرض أو ما أنبتت الأرض إلا ما أكل أو لبس. فقلت له جعلت فداك ما العلّة في ذلك؟ قال لأن السجود هو الخضوع لله عز وجلّ فلا ينبغي أن يكون على ما يؤكل و يلبس لأن أبناء الدنيا عبيد ما يأكلون ويلبسون. الساجد في سجوده في عبادة الله عز وجلّ فلا ينبغي أن يضع جبهته في سجوده على معبود أبناء الدنيا الذين اغتروا بغرورها. والسجود على الأرض أفضل لأنه أبلغ في التواضع والخضوع لله عز وجلّ.

*ហ៊ីស្ាំ អ៊ីបនូ អាល់-ហ្កាំបានតំណាលថា៖ "ខ្ញុំបានសួរអាប៊ូ អ្ាប់ឌុលឡោះហ្* صلوات الله عليه والسلام *(គឺអ៊ីមុាំអាស្ុ-ស្ុឌិក្វ* صلوات الله عليه والسلام*) អំពីវត្ថុដែលគេអនុញ្ញាតឲ្យក្រាបប្រណិប័តន៍លើបាន និងអំពីវត្ថុដែលគេហាមក្រាបប្រណិប័តន៍លើ ។" អ៊ីមុាំមានវចនៈថា៖ "អនុញ្ញាតឲ្យក្រាបប្រណិប័តន៍តែលើដីនិងលើអ្វីៗដែលដុះលើដីនោះទេ មិនរាប់បញ្ចូលអ្វីដែលអាចបរិភោគបាននិងអ្វីដែលអាចស្លៀកពាក់បានទេ ។" ខ្ញុំបានសួរថា៖ "ទូលបង្គំសូមបូជាខ្លួនដើម្បីព្រះអង្គ* صلوات الله عليه والسلام *ហេតុអ្វីទៅ ?" ព្រះអង្គ* صلوات الله عليه والسلام *បានតបវិញថា៖ "នៅក្នុងការក្រាបប្រណិប័តន៍ បុគ្គលសម្តែងនូវការដាក់ខ្លួននិងការគោរពចុះចូលខ្លួនចំពោះអល់ឡោះហ្ ﷻ ។ ដូច្នេះ មិនសក្តិសមទេដែលក្រាបប្រណិប័តន៍លើវត្ថុដែលអាចបរិភោគបាន ឬដែលអាចស្លៀកពាក់បាននោះ ពីព្រោះមនុស្សវត្តនិយមជាទាសៈរបស់វត្ថុដែលខ្លួនបរិភោគនិងស្លៀកពាក់ ។ បុគ្គលដែលនៅក្នុងការក្រាបប្រណិប័តន៍ស្ថិតនៅក្នុងសភាពក្រាបអភិវន្ទន៍ដ៏ខ្ពង់ខ្ពស់ចំពោះអល់ឡោះហ្ ﷻ ។ ហេតុដូច្នេះ មិន*



របស់អល់ឡោះហ្ ﷻដែរ ។

២. លោក អាប៊ូ អ្ាប់ឌុលឡោះហ្ អាល់-ប៊ូខ៊ារី មានប្រសាសន៍នៅក្នុងស្ុហ៊ិះហ្លោកថា៖

«إنّ عمر بن الخطّاب رضي الله عنه كان إذا قحطوا إستسقى بالعبّاس بن عبدالمطلب فقال: ألّلهمّ إنّا كنّا نتوسّل إليك بنبيّنا فتسقينا وإنّا نتوسّل إليك بعمّ نبيّنا فاسقِنا. قال فيسقون»

*"គ្រប់ពេលដែលរាំងភ្លៀង អ៊្ុម៉ារ អ៊ីបនូ អាល់-ខត្តុ័តប់បានស្ុំឡាត់សូមឲ្យមានភ្លៀងតាមរយៈ អ្ាប់បាស់ អ៊ីបនូ អ្ាប់ឌុល-មុត្តុ័លិប (ឪពុកមារបស់ព្រះសាស្តា* ﷺ*) ថា៖ "អល់ឡោះហ្* ﷻ*អើយ អស់ទូលព្រះបង្គំជាខ្ញុំតែងតែទៅរកព្រះអង្គ* ﷻ *តាមរយៈព្រះសាស្តា* ﷺ*របស់អស់ទូលព្រះបង្គំជាខ្ញុំ ហើយព្រះអង្គ* ﷻ*បានធ្វើឲ្យមានភ្លៀងមកលើអស់ទូលព្រះបង្គំជាខ្ញុំ ។ ពេលនេះអស់ទូលព្រះបង្គំជាខ្ញុំទៅរកព្រះអង្គ* ﷻ *តាមរយៈឪពុកមារបស់ព្រះសាស្តា* ﷺ*របស់អស់ទូលព្រះបង្គំជាខ្ញុំ ដើម្បីព្រះអង្គ* ﷻ*នឹងឲ្យអស់ទូលព្រះបង្គំជាខ្ញុំមានទឹកផឹក ។" ពួកគេក៏បានសម្រេចដូចបំណង ។"*[207]

៣. ការពឹងពាក់ (គឺតាវ៉ាស់ស៊ូល) មិត្តជំនិតរបស់អល់ឡោះហ្ ﷻជាទង្វើទូទៅ ដល់ថ្នាក់មុស្លីមនាដើមសម័យអ៊ីស្លាមតែងតែយកព្រះសាស្តា ﷺ ជាអន្តរការីរវាងពួកគេនិងអល់ឡោះហ្ ﷻ ។
លោក សាវ៉ាដ្ុ អ៊ីបនូ ក៊្ុរីប បានសូត្រកំណាព្យនេះឲ្យព្រះសាស្តា ﷺស្តាប់ គឺ៖

وأشْهَدُ انَّ الله لا ربَّ غَيْرُهُ

[207] សូមមើល *ស្ុហ៊ិះហ្ អាល់-ប៊ូខ៊ារី*(បោះពុម្ពនៅប្រទេសអេស៊ីបត៍ ដុំទី ២ "គីតាប អាល់-យ៉ុមអ្ាស្ុ", "បាប់ អាល់-អ៊ីសទីសក្វ៉ុ (الاستسقاء)" ទំព័រ ២៧ ។

អស់លោកអ្នករាយការណ៍ហាឌីស្ហ ចាត់ទុកហាឌីស្ហនេះជាហាឌីស្ហដែលទទួលយកបាន ។ លោក ហាគីម ណៃសាបូរី ក្រោយពីបានថ្លែងហាឌីស្ហនេះនៅក្នុងមុសតាដ្រ៉ក់ បានបញ្ជាក់ថាហាឌីស្ហនេះស្ហ៊ហ៊ិះហ្វ៍ (គឺពិត) ។ លោក អ៊ិបនូ ម៉ាយ៉ាស្ហ៍ ដែលបានរាយការណ៍តមកពីលោក អាប៊ូ អ៊ីសហាក់ នោះក៏បានថាវាជាហាឌីស្ហស្ហ៊ហ៊ិះហ្វ៍ដែរ ។ លោក តៀរមីស៊ី អះអាងបន្ថែមថាវាជាហាឌីស្ហពិតនៅក្នុងសៀវភៅ អាប់វ៉ាប់ អាល់-អាដ់អ៊ីយ៉ាស្ហ៍ (أبواب الأدعية) ។ លោក មូហាំម៉ាដ់ ណាស៊ីប អារ-រ៉ហ្វាអ៊ី ក៏មានប្រសាសន៍នៅក្នុង អាត់-តាវ៉ាស់ស៊ូល អ៊ីឡា ហាគីកេ្ហះត៍ អាត់-តាវ៉ាស់ស៊ូល ដែរថា៖

«لاشك أن هذا الحديث صحيح ومشهورٌ... وقد ثبت فيه بلاشكّ ولاريب ارتداد بصر الأعمى بدعاء رسول الله صلّى الله عليه (وآله) وسلّم له»

*"ហាឌីស្ហនេះប្រាកដជាពិត មិនគួរឲ្យសង្ស័យទេ... ដែលរាយការណ៍ថាអាស្រ័យការបួងសួងរបស់ព្រះសាស្តាﷺអល់ឡោះហ្វ៍ عزّ وجلّ បុរសខ្វាក់ភ្នែកមើលឃើញវិញ ។"*[206]

ហាឌីស្ហនេះសឲ្យឃើញថា *តាវ៉ាស់ស៊ូល* តាមរយៈព្រះសាស្តាﷺដើម្បីបំពេញបំណងបុគ្គលនោះ ជាទង្វើដែលគេអនុញ្ញាតឲ្យធ្វើ ហើយព្រះសាស្តាﷺបានបង្ហាត់បុរសនោះឲ្យចេះបួងសួងអល់ឡោះហ្វ៍ عزّ وجلّ ដោយយកព្រះសាស្តាﷺជាអន្តរការីរវាងខ្លួននិងអល់ឡោះហ្វ៍ عزّ وجلّ ។ នេះគឺប្រភេទតាវ៉ាស់ស៊ូល ដូចតាវ៉ាស់ស៊ូលតាមរយៈសន្តបុគ្គលនិងមិត្តជំនិត

អាស់-ស៊ូយូទី ទំព័រ ៥៩; *អាត់-តាវ៉ាស់ស៊ូល វ៉ាល់-វ៉ាស៊ីឡាស្ហ៍ (التوسل والوسيلة)* របស់លោក អ៊ិបនូ តៃមីយ៉ាស្ហ៍ (ابن تيمية) (បោះពុម្ពនៅបៃរូត) ទំព័រ ៩៨ ។

[206] សូមមើលសៀវភៅ *អាត់-តាវ៉ាស់ស៊ូល អ៊ីឡា ហាគីកេ្ហះត៍ អាត់-តាវ៉ាស់ស៊ូល* (បោះពុម្ពនៅបៃរូត) ទំព័រ ១៥៨ ។



*ស័ក្តិសមទេ ដែលដាក់ថ្វាសលើអ្វីដែលមនុស្សចចេសវត្តនិយមគោរពសក្ការៈនោះ ។ ក្រាបប្រណិប័តន៍លើដីជាវិធីក្រាបប្រណិប័តន៍ប្រសើរបំផុតមួយ ពីព្រោះវាជាមធ្យោបាយដែលសមរម្យបំផុតសម្រាប់សម្តែងអាការដាក់ខ្លួននិងអាការរាបទាបចំពោះអល់ឡោះហ្វ៍ عزّ وجلّ ។*[163] "

ពាក្យពេជន៍ដ៏ភ្លឺថ្លានេះបញ្ជាក់ភស្តុតាងយ៉ាងជាក់ច្បាស់ថា ការក្រាបប្រណិប័តន៍លើដីជាមធ្យោបាយដ៏ ស័ក្តិសមបំផុតមួយដើម្បីសម្តែងឲ្យឃើញនូវអាការដាក់ខ្លួននិងអាការរាបទាបចំពោះអល់ឡោះហ្វ៍ عزّ وجلّ ព្រះតែមួយគត់ ។

ដូច្នេះ គេអាចសួរបានថា៖ ហេតុអ្វីស្ហ៊ីអាស្ហ៍ក្រាបប្រណិប័តន៍តែលើដី ឬលើអនុផលិតផលមួយចំនួនប៉ុណ្ណោះ ហេតុអ្វីពួកគេមិនក្រាបប្រណិប័តន៍លើវត្ថុផ្សេង ?

ចម្លើយសំណួរនេះគឺ៖ ដូចទង្វើគោរពសក្ការៈដែរដែលត្រូវតែចេញមកពីព្រះនីតិបញ្ញត្តិអ៊ីស្លាមនោះ ចំណែកឯលក្ខខណ្ឌរបស់ទង្វើគោរពសក្ការៈនោះ ប៉ែកនានានិងវិធីប្រតិបត្តិក៏ត្រូវតែអធិប្បាយបំភ្លឺក្រោមពន្លឺព្រះវចនៈនិងព្រះទង្វើរបស់ព្រះសាស្តាﷺដែរ ពីព្រោះ យោលតាមព្រះគម្ពីរគួរអានរ៉ស៊ូលុលឡោះហ្វ៍ﷺជាគំរូប្រសើរបំផុតសម្រាប់មនុស្សជាតិទាំងមូល ។

## សំណួរ ២០ - ពេលស៊ីយ៉ាវ៉ាស្ហ៍ ហេតុអ្វីស្ហ៊ីអាស្ហ៍ថើបទ្វារនិងជញ្ជាំងបូណីជដ្ឋានរបស់អៅលីយ៉ា ស្វែងរកពរជ័យ

[163] សូមមើលសៀវភៅ *ប៊ីហារ អាល់-អាន់វ៉ារ (بحار الانوار)* ក្បាលទី ៥៨ ទំព័រ ១៤៧ និងសៀវភៅ *អ៊ីឡាល់ អាល់-ស្ហារ៉អ៊ីអ៊ំ (علل الشرائع)* ។

ដោយទង្វើនេះ ?

## ចម្លើយ

ស្វែងរកពរជ័យ (តាបារុក التَّبَرُّك) តាមរយៈព្រះសារីរិកធាតុ (ឬព្រះបូជណីយដ្ឋានឯទៀត) របស់មិត្តជំនិតរបស់អល់ឡោះហ៑៿នោះមិនមែនទង្វើរបស់ក្រុមមុស្លីមដាច់ឡែកមួយទេ ។ ព្រឹត្តិការណ៍នេះធ្លាប់មានមកហើយ ដែលគេបានរាយការណ៍នៅក្នុងព្រះជីវប្រវត្តិរបស់ព្រះសាស្ដាﷺ និងនៅក្នុងជីវប្រវត្តិរបស់បណ្ដាសាវកព្រះអង្គﷺ ។

មិនត្រឹមតែព្រះសាស្ដាﷺនិងបណ្ដាសាវកព្រះអង្គﷺទេ ដែលបានធ្វើទង្វើនេះ តែព្រះសាស្ដាមុនៗក៏ធ្លាប់ធ្វើទង្វើនេះដែរ ។ ខាងក្រោមនេះគឺភ័ស្តុតាងដកស្រង់ពីក្នុងគួរអាន និងស៊ុនណាស់ដែលចែងថាការស្វែងរកពរជ័យតាមរយៈព្រះសីរិកធាតុ (និងព្រះបូជណីដ្ឋាន) របស់មិត្តជំនិតរបស់អល់ឡោះហ៑៿នោះសមស្របតាមច្បាប់ ។

១. នៅក្នុងគម្ពីរគួរអានយើង យូស៊ុហ្វ សច្ចការី﵇បានបង្ហាញខ្លួនចំពោះបងៗព្រះអង្គ﵇ ហើយបានលើកទោសឲ្យពួកគេ ថា៖

ٱذۡهَبُواْ بِقَمِيصِى هَٰذَا فَأَلۡقُوهُ عَلَىٰ وَجۡهِ أَبِى يَأۡتِ بَصِيرٗا

*"ចូរអស់លោកយកអាវខ្ញុំនេះទៅដាក់លើមុខឪពុកខ្ញុំ លោកនឹងមើលឃើញ ិញដូចដើម (១២:៩៣) ។"*[164]

បន្ទាប់មក គួរអានចែងថា៖

فَلَمَّآ أَن جَآءَ ٱلۡبَشِيرُ أَلۡقَىٰهُ عَلَىٰ وَجۡهِهِۦ فَٱرۡتَدَّ بَصِيرٗاۖ

[164] សូរ៉ោះត៍ យូស៊ុហ្វ 12:93 ។



របស់លោក តមកពីលោក អ៊ុស្មម៉ាន អ៊ីបនូ ហ៊្វាសៃនហ្វ៍ (عثمان بن حنيف) ថា៖

«إنَّ رَجُلاً ضَرِيْرَ الْبَصَرِ أتى النبی صلّی اللهُ عليه (وآله) وسلّم فقال ادع الله أن يعافيني، قال: إن شئت دعوت لك وإن شئت أخّرت ذاك فهو خير، فقال: أدعه. فأمره أن يتوضّأ فيحسن وضوئه فيصلي ركعتين ويدعو بهذا الدّعاءِ. اللّهمَّ إني أسئلك واتوجّه إليك بنبيك محمّد نبيّ الرّحمة يا محمّد إنّي توجّهت بك إلى ربّي في حاجتي هذه، فتقضيَ لی اللّهم شفعه فيّ»

*"មានបុរសខ្វាក់ភ្នែកម្នាក់បានមករកព្រះសាស្ដាﷺ ទូលព្រះអង្គﷺថា៖ "សូមព្រះអង្គﷺសូមអល់ឡោះហ៑៿ ឲ្យទូលបង្គំបានជាសះស្បើយផង ។" ព្រះសាស្ដាﷺមានព្រះវចនៈថា៖ "បើលោកចង់មែន ខ្ញុំនឹងបួងសួងឲ្យលោក តែបើលោកយល់ព្រម យកល្អ ខ្ញុំនឹងបួងសួងពេលក្រោយ ។" បុរសខ្វាក់ភ្នែកទូលថា៖ "សូមព្រះអង្គﷺបួងសួងទៅ ។" ព្រះសាស្ដាﷺក៏បានឲ្យគាត់យកទឹកវូឌុអ៊ុយ៉ាងផ្ចិតផ្ចង់ ឲ្យគាត់ស្ឡឹទ្បាត់ពីររ៉ក់អាត់ ហើយឲ្យបួងសួងថា៖ "អល់ឡោះហ៑៿អើយ ទូលព្រះបង្គំជាខ្ញុំសូមបួងសួងព្រះអង្គ៿តាមរយៈមូហាំម៉ាដ់ﷺ ព្រះសាស្ដានៃព្រះមេត្តាធម៌ ។ មូហាំម៉ាដ់ﷺអើយ ទូលបង្គំសូមពឹងព្រះអង្គﷺដើម្បីជួយសូមអល់ឡោះហ៑៿ឲ្យទូលបង្គំ ។ អល់ឡោះហ៑៿អើយ សូមព្រះអង្គﷺអនុញ្ញាតឲ្យមូហាំម៉ាដ់ﷺ ធ្វើជាអ្នកធ្វើអន្តរាគមន៍ឲ្យទូលព្រះបង្គំជាខ្ញុំផង ។""*[205]

[205] សូមមើល *មុសណាដ់ អាស់ម៉ាដ់ អ៊ីបនូ ហាន់បាល់* ជុំទី ៤ "សេចក្ដីថ្លែងការណ៍របស់អ៊ុសម៉ាន អ៊ីបនូ ហ៊្វូណៃហ្វ៍" ទំព័រ ១៣៨; *មុសតាដ់រ៉ក់ អាល់-ហាគីម (مستدرك الحاكم)* (បោះពុម្ពនៅបៃរូត) ជុំទី ១ "គីតាប ស្វ៏ឡាស់ អាត់-តាតៅវ៉ាក់" ទំព័រ ៣១៣; *ស៊ូណាន់ អ៊ីបនូ ម៉ាយ៉ាស់* (បោះពុម្ពដោយ ដារ អាល់-អ៊ិះហ៊ុាយ៉ា អាល់-គូតូប អាល់-អារ៉ាប៊ីយ៉ាស់" ជុំទី ១ ទំព័រ ៤៤១; *អាត់-តាជ់* ជុំទី ១ ទំព័រ ២៨៦; *យ៉ាមិអ៊ អាស្វ-ស្វ៏គៀរ (الجامع الصغير)* របស់លោក យ៉ាឡាល់ អាដ់-ឌីន

*"ពួកគេ (បងប្អូនរបស់យូស៊ីហ្វ) បានថ្លែងថា៖ "លោកឪពុក សូមលោកឪពុកជួយអង្វរសូមខមាទោសចំពោះអល់ឡោះហ្ទ៍ឲ្យកូនៗផង ដែលកូនរាល់គ្នាបានធ្វើបាបកម្ម ។ កូនរាល់គ្នាបានប្រព្រឹត្តខុស ។" គេ (យ៉ាក់គូប) បានថា៖ "ឪពុកនឹងជួយសូមខមាទោសចំពោះព្រះម្ចាស់ឪពុកឲ្យកូនរាល់គ្នា ។ ពិតណាស់ ព្រះអង្គទ្រង់អត់ឱន ព្រះអង្គមានព្រះមេត្តាករុណាប្រណី ១២:៩៧-៩៨ ។"*[204]

អាយ៉ាត់ខាងលើនេះសឲ្យឃើញថា កូនៗរបស់ណាពីយ៉ាក់គូបﷺបានពឹងពាក់លើការអង្វរបួងសួងរបស់បិតាខ្លួន ដើម្បីសូមអភ័យទោសពីអល់ឡោះហ្ទ៍ﷻ ។ ព្រះសាស្តាយ៉ាក់គូបﷺមិនត្រឹមតែពុំបានឆ្លើយបដិសេធសំណូមពររបស់ពួកគេទេ ព្រះអង្គﷺថែមទាំងបានសន្យាថានឹងបួងសួងសូមខមាទោសឲ្យពួកគេទៀតផង ។

៣. *តាវ៉ាស់ស៊ូល* តាមរយៈអស់បុគ្គលដែលប្រកបដោយវិញ្ញាណថ្លៃថ្នូរ ដែលអល់ឡោះហ្ទ៍ﷻលើកតម្កើងជាពិសេស ក្នុងបំណងចូលទៅជិតអល់ឡោះហ្ទ៍ﷻ ។

តាំងពីដើមសម័យអ៊ីស្លាមមកម្ល៉េះ គេអនុញ្ញាតឲ្យធ្វើតាវ៉ាស់ស៊ូលបែបនេះ ហើយបណ្ដាសាវករបស់ព្រះសាស្តាﷺធ្លាប់តែធ្វើទង្វើនេះជាទូទៅ ។

យើងសូមបង្ហាញភ័ស្តុតាង ដោយផ្អែកលើហាឌីស្ឋបញ្ជាក់អំពីទង្វើរបស់បណ្ដាសាវកព្រះសាស្តាﷺនិងបុគ្គលល្បីៗក្នុងអ៊ីស្លាម ។

១. លោក អាស់ម៉ាជ់ អ៊ីបនូ ហ្វាន់បាល់ មានប្រសាសន៍នៅក្នុងមុសណាជ់

[204] សូរ៉ោះត៍ យូស៊ុហ្វ 12:97-98 ។



*"លុះអ្នកនាំដំណឹងល្អបានមកដល់ គេបានដាក់អាវ[របស់យូស៊ីហ្វ]លើមុខគេ (យ៉ាក់គូប) គេក៏មើលឃើញវិញ (១២:៩៦) ។"*[165]

អាយ៉ាត់គួរអាននេះជាភ័ស្តុច្បាស់ក្រឡែត ដែលបញ្ជាក់ថាព្រះសាស្តាអល់ឡោះហ្ទ៍ យ៉ាក់គូបﷺ បានជាសះស្បើយដោយសារអាវរបស់ព្រះសាស្តាមួយអង្គទៀត (គឺអាវរបស់ព្រះសាស្តាយូស៊ុហ្វﷺ) ។ គួរអានថែងថា អាវនោះឯងជាដើមហេតុធ្វើឲ្យភ្នែកព្រះសាស្តាយ៉ាក់គូបﷺមើលឃើញវិញ ។

តើគេអាចនិយាយបានទេថា ព្រះសាស្តាទាំងពីរអង្គនេះعليهم السلامចេញពីក្របខ័ណ្ឌឯកទិទេពនិយម (គឺចេញពីសាសនាអល់ឡោះហ្ទ៍ﷻ) និងចេញពីក្របខ័ណ្ឌគោរពសក្ការៈអល់ឡោះហ្ទ៍ﷻ ?

២. ពិតប្រាកដណាស់ថាកាលដើរឆ្វេលព្រះមហាគ្រឹះរបស់អល់ឡោះហ្ទ៍ﷻ (តាវ៉ាហ្វ) ព្រះសាស្តាអ៊ីស្លាមﷺ ធ្លាប់តែប៉ះឬថើបថ្មខ្មៅ (ហ្វាយ៉ារ អាល់-អាស់វ៉ាជ់ الحجر الأسود) ។
លោក អាល់-ប៊ូខ៏រី បានថ្លែងនៅក្នុងស្ហ៍ហ៊ិះហ្ទ៍លោកថា៖ "បុរសម្នាក់បានសួរអាុបឌុលឡោះហ្ទ៍ អ៊ីបនូ អ៊ូម៉ារ រឿងប៉ះថ្មខ្មៅ ។ លោកបានឆ្លើយថា៖

"رأيت رسول الله صلى الله عليه وأله وسلم يستلمه ويقبّله."

*"ខ្ញុំបានឃើញព្រះសាស្តាﷺអល់ឡោះហ្ទ៍ﷻប៉ះនិងថើបវា (គឺហ្វាយ៉ារ អាល់-អាស់វ៉ាជ់ الحجر الأسود) ។"*[166]
ដូច្នេះ បើប៉ះនិងថើបថ្មជាទង្វើហ៊ានហាយជាមួយអល់ឡោះហ្ទ៍ﷻមែននោះ

[165] សូរ៉ោះត៍ យូស៊ុហ្វ 12:96 ។

[166] សូមមើល *ស្ហ៍ហ៊ិះហ្ទ៍ អាល់-ប៊ូខ៏រី* (បោះពុម្ពនៅប្រទេសអេស៊ីបត៍) ដុំទី ២ ទំព័រ ១៥១-១៥២ "គីតាប អាល់-ហ្វាជ់" "បាប់ តាក់ប៊ីល អាល់-ហ្វាយ៉ារ" ។

ព្រះសាស្ដាដែលជាអ្នកការពារលទ្ធិឯកទិទេពនិយម (គឺអ្នកការពារតៅហ៊ីដ្ធ) នោះប្រាកដជាមិនបានធ្វើទង្វើនេះជាដាច់ខាត ។

៣. នៅក្នុងស៊ូហ្ហិះហ៍ ក្នុងមុសណាដ៍ ក្នុងសៀវភៅប្រវត្តិសាស្ត្រនិងក្នុងហាឌីស្ហ មានហាឌីស្ហសន្ធឹកសន្ធាប់ស្ដីអំពីការស្វែងរកពរជ័យតាមរយៈវត្ថុផ្ទាល់ខ្លួនរបស់ព្រះសាស្ដាﷺដូចជាសំលៀកបំពាក់ ទឹកវូឌុអ៍ ក្អមទឹក ។ល។ ជាដើម ។ ហាឌីស្ហទាំងនេះលុបបំបាត់ការសង្ស័យអំពីការស្របច្បាប់របស់ទង្វើនេះ ។

មិនអាចលើកមកអធិប្បាយហាឌីស្ហទាំងអស់ដែលអំពីរឿងនេះ នៅក្នុងសៀវភៅតូចនេះបានទេ យើងសូមលើកមកបង្ហាញជូនតែហាឌីស្ហខ្លះ គឺ៖

ក. នៅក្នុងស៊ូហ្ហិះហ៍របស់លោក លោក អាល់-ប៊ូខ៉ារី បានរាយការណ៍ហាឌីស្ហដែលស្ដីអំពីគុណសម្បត្តិរបស់ព្រះសាស្ដាﷺ និងបណ្ដាសាវកព្រះអង្គﷺថា៖

"وإذا كادوا توضأ يقتتلون على وضوئه."

*"ពេលព្រះសាស្ដាﷺយកទឹកវូឌុអ៍ ពួកគេ (គឺមុស្លីម) ប្រញាយទឹកដែលខ្ទាតពេលព្រះអង្គធ្វើវូឌុអ៍នោះ ។"*[167]

ខ. លោក អ៊ីបនូ ហាយ៉ារ មានប្រសាសន៍ថា៖

"إن النبيّ صلى الله عليه وأله وسلم كان يؤتي بالصبيان فيبرك عليهم."

*"ពួកគេនាំកូនក្មេងទៅជួបព្រះសាស្ដាﷺ ។ ព្រះអង្គﷺសូត្រសូមពរជ័យ*

[167] សូមមើល *ស៊ូហ្ហិះហ៍ អាល់-ប៊ូខ៉ារី* (បោះពុម្ពនៅប្រទេសអេស៊ីបត៍) ដុំទី ៣ ទំព័រ ១៩៥ ។



ស្រឡាញ់និងលើកតម្កើងជាពិសេស ។

## តាវ៉ាស់ស៊ូលមានច្រើនប្រភេទ

តាវ៉ាស់ស៊ូលអាចមាន ៣ ប្រភេទ គឺ៖

១. *តាវ៉ាស់ស៊ូល* តាមរយៈនៃការធ្វើទង្វើល្អ ដូចលោក យ៉ាឡាល់ អាដ៉្-ឌីន អាស់-ស៊ូយូទី (جلال الدين السيوطي) បានអធិប្បាយអំពីព្រះអាយ៉ាស់ وَٱبۡتَغُوٓاْ إِلَيۡهِ ٱلۡوَسِيلَةَ *(ចូរស្វែងរកមធ្យោបាយ [ឬអន្តរការី]ដើម្បី[ខិតចូល]ទៅរកព្រះអង្គ)* ថា៖

«عَنْ قتادَة في قَوله تعالى ﴿وَابْتَغُوا إِلَيْهِ الْوَسِيلَةَ﴾ قال: تقربوا إلى الله بطاعته والعمل بما يرضيه»

*"ក៏តាដាស់មានប្រសាសន៍អំពីអាយ៉ាស់ "ចូរស្វែងរកមធ្យោបាយ [ឬអន្តរការី]ដើម្បី[ខិតចូល]ទៅរកព្រះអង្គ" ថា៖ "ព្យាយាមខិតចូលទៅជិតអល់ឡោះហ៍ﷻដោយគោរពព្រះអង្គﷻ និងដោយប្រព្រឹត្តអ្វីដែលព្រះអង្គﷻសព្វព្រះហឫទ័យ ។""*[203]

២. *តាវ៉ាស់ស៊ូល* តាមរយៈនៃការបួងសួងរបស់បណ្ដាបាវថ្លៃថ្នូររបស់អល់ឡោះហ៍ﷻ ដូចព្រះគម្ពីរគួរអានចែងនៅក្នុងសម្ដីបងៗរបស់ណាបីយូស៊ុហ្វعليه السلامថា៖

قَالُواْ يَـٰٓأَبَانَا ٱسۡتَغۡفِرۡ لَنَا ذُنُوبَنَآ إِنَّا كُنَّا خَٰطِـِٔينَ ﴿٩٧﴾ قَالَ سَوۡفَ أَسۡتَغۡفِرُ لَكُمۡ رَبِّيٓۖ إِنَّهُۥ هُوَ ٱلۡغَفُورُ ٱلرَّحِيمُ ﴿٩٨﴾

[203] សូមមើលសៀវភៅ *អាដ៉្-ឌូរ អាល់-ម៉ាន់ស៊ូរ* (الدر المنثور) (បោះពុម្ពនៅបៃរូត) ដុំទី ២ ទំព័រ ២៨០ សេចក្ដីអធិប្បាយ អាយ៉ាស់កំពុងនិយាយនេះ ។

អាល់-អាក្ក់រ៉ប (لسان العرب) ថា៖

«تَوسّل إليه بكذا، تقرّب إليه بحرمة آصرةٍ تعطفه عليه»

*"ដែលលោកពឹងពាក់បុគ្គលណាមួយ ដើម្បីអាចទៅជិតព្រះអង្គបាននោះ ព្រោះតែបុគ្គលរូបនោះជាបុគ្គលជាទីស្រឡាញ់របស់ព្រះអង្គ ។"*[201]

ព្រះមហាគម្ពីរគួរអានថែងថា៖

يَـٰٓأَيُّهَا ٱلَّذِينَ ءَامَنُواْ ٱتَّقُواْ ٱللَّهَ وَٱبْتَغُوٓاْ إِلَيْهِ ٱلْوَسِيلَةَ وَجَـٰهِدُواْ فِى سَبِيلِهِۦ لَعَلَّكُمْ تُفْلِحُونَ

*"បណ្ដាអ្នកមានសទ្ធាអើយ ចូរកោតក្រែងខ្លាចអល់ឡោះហ្ស៍[ដោយសេចក្តីគោរព] ចូរស្វែងរកមធ្យោបាយ [ឬអន្តរការី]ដើម្បី[ខិតចូល]ទៅរកព្រះអង្គ ចូរតស៊ូក្នុងមាគ៌ាព្រះអង្គ ដើម្បីពួកអ្នកនឹងមានជ័យជំនះ [បានទៅដល់សុខុមាលភាព] ៥:៣៥ ។"*[202]

លោក យ៉ៅហារី (الجوهري) បានអធិបាយអំពី *"វ៉ាសីឡាស់"* (មធ្យោបាយ, អន្តរកម្ម) ដូចតទៅ៖

«الْوسيلةُ ما يتقرّب به إلى الغير»

*"វ៉ាសីឡាស់ គឺអ្វីដែលអាចឲ្យយើងខិតចូលទៅជិតបុគ្គលម្នាក់ទៀតបាន ។"*

អាស្រ័យហេតុនេះ យើងអាចពឹងផ្អែកលើការគោរពសក្ការៈដ៏ស្មោះចំពោះអល់ឡោះហ្ស៍និងលើទង្វើល្អបាន ដើម្បីខិតចូលទៅជិតព្រះម្ចាស់ពិភពទាំងពួង ឬជូនកាលពឹងផ្អែកលើបុគ្គលថ្លៃថ្លាដែលអល់ឡោះហ្ស៍

[201] សូមមើលសៀវភៅ *លីសាន អាល់-អាក្ក់រ៉ប (لسان العرب)* ជុំទី ១១ ទំព័រ ៧២៤ ។

[202] ស៊ូរ៉ោះត៍ អាល់-ម៉ាអ៊ីដាស់ 5:35 ។



*ឲ្យពួកវា ។"*[168]

លោក មូហាំម៉ាដ់ ត៏ហ្ហៀរ អាល់-ម៉ាក់គី (محمد طاهر المكّي) មានប្រសាសន៍ថា៖ "គេបានរាយការណ៍ថា អ៊ូម ស្វាប៊ីត បាននិយាយថា៖ "ថ្ងៃមួយព្រះសាស្ដាﷺអល់ឡោះហ្ស៍បានមកជួបខ្ញុំ បានសោយទឹកក្នុងថង់ទឹកធ្វើអំពីស្បែកសត្វដែលគេព្យួរនៅទីនោះ ។ ខ្ញុំបានផ្ទុះទៅកាត់យកមាត់ថង់នោះ ។""

បន្ទាប់មក លោកមានប្រសាសន៍ថា៖ *"លោកតៀរមីស៊ីក៏បានរាយការណ៍ហាឌីស្ហនេះដែរ"* ហើយលោកមានប្រសាសន៍ថា៖ *"នេះគឺហាឌីស្ហពិត (ស្វ៊ហ៊ិះហ្ស៍) និងត្រឹមត្រូវ (ហាសាន់) ។ អ្នកអធិប្បាយហាឌីស្ហនេះបាននិយាយនៅក្នុងសៀវភៅ រីយ៉ាដ់ អាស្វ-ស្វ៉លីហ៊ីន ថា៖ "អ៊ូម ស្វាប៊ីត បានកាត់មាត់ថង់ទឹកដើម្បីយកកន្លែង ដែលព្រះសាស្ដាﷺបានដាក់បបូរមាត់ព្រះអង្គﷺលើនោះទុកសម្រាប់ខ្លួននាងផ្ទាល់ ដើម្បីស្វែងរកពរជ័យ ។ បណ្ដាសាវកក៏ព្យាយាមផឹកទឹក ត្រង់កន្លែងដែលព្រះសាស្ដាﷺបានសោយនោះដែរ ។"*[169]

"كان رسول الله صلى الله عليه وأله وسلم إذا صلى الغداة جاء خدم المدينة بأنيتهم فيها الماء فما يؤتي بإناء إلا غمس يده فيه فربما جاؤوه في الغداة الباردة فيغمس يده فيها."

[168] សូមមើល *អាល់-អ៊ីស្វ៉ាបាស់ (الإصابة)* (បោះពុម្ពនៅអេស៊ីបត៍) "ឃុត្តបាស់ អាល់-គីតាប" ទំព័រ ៧ ។

[169] សូមមើលសៀវភៅរបស់លោក មូហាំម៉ាដ់ ត៏ហ្ហៀរ អាល់-ម៉ាក់គី (محمد طاهر المكّي) *តាបារ្រុក អាស្វ-ស្វាហាបាស់* (تبرك الصحابة) បកប្រែដោយ អាន់ស្វ៉ារី កណ្ឌ ១ ទំព័រ២៩ ។

*"ពួកអ្នកបម្រើស្រុកម៉ាឌីណាស៊្ញ តែងតែទៅជួបព្រះសាស្តាﷺ អល់ឡោះហ្ម៍عز وجل ក្រោយស្វឺឡាត់ពេលព្រឹក (ស៊ុបហ្ញ៍) ជាមួយក្អមដាក់ទឹកពេញ ។ ព្រះសាស្តាﷺបានជ្រលក់ព្រះសិរីហត្ថព្រះអង្គﷺក្នុងក្អមទឹកទាំងនោះ គ្រប់ៗក្អម ទោះបីច្រើនលើកក្នុងអាកាសត្រជាក់នៃពេលព្រឹកក៏ដោយ ។ ព្រះសាស្តាﷺបានជ្រលក់ព្រះហត្ថព្រះអង្គﷺរាល់ដងក្នុងក្អមពួកគេ ។"*[170]

ភ័ស្តុតាងទាំងនេះបញ្ជាក់ឲ្យដឹងច្បាស់ថាការស្វែងរកពរជ័យ តាមរយៈវត្ថុផ្ទាល់ខ្លួនរបស់មិត្តជំនិតរបស់អល់ឡោះហ្ម៍عز وجلនោះ មានលក្ខណៈស្របច្បាប់ ។ ភ័ស្តុតាងទាំងក៏បញ្ជាក់ឲ្យឃើញដែរថាបណ្តាអ្នកដែលចោទស្ហ៊ីអ៊ុស្ទ៍ថាហ៊ុនហាយ (ស្ហ៊ីរិក) ជាមួយអល់ឡោះហ្ម៍عز وجلដោយប្រព្រឹត្តបែបនេះនោះ មិនដឹងយ៉ាងច្បាស់លាស់ទេថាតៅហ៊្វីដនិងស្ហ៊ីរិកខុសគ្នាបែបណាទេ ។

ការហ៊ុនហាយ (ស្ហ៊ីរិក) ឬ គោរពសក្ការផ្សេងពីអល់ឡោះហ្ម៍عز وجلមានន័យថាយកសត្វលោកណាមួយជាព្រះគួបជាមួយអល់ឡោះហ្ម៍عز وجل ហើយចាត់ទុកថាសត្វលោកមួយនោះមានអំណាចដូចព្រះដែរ ដាច់ឡែកពីអល់ឡោះហ្ម៍عز وجل ។ តែស្ហ៊ីអ៊ុស្ទ៍ចាត់ទុកអ្វីៗដែលជាកម្មសិទ្ធិរបស់មិត្តជំនិតអល់ឡោះហ្ម៍

[170] សូមមើល *ស្វ៍ហ៊ិះហ្ម៍ មុស្លីម (صحيح مسلم)* ជុំទី ៧ "គីតាប អាល់-ហ្វាដ៏អ៊ីល (كتاب فضائل)", "បាប់ គូរប៍ អាន់-ណាប៊ី មិន អាន់-ណាស់វ៉ា តាបាររូគីហ៊ីម ប៊ីហ៊ី" ទំព័រ ៧៩ ។ ព័ត៌មានបន្ថែម សូមមើលសៀវភៅទាំងនេះគឺ៖ *ស្វ៍ហ៊ិះហ្ម៍ អាល់-ប៊ូខរី* "គីតាប់ អាល់-អាស្ហ៊ីរីបាស្ទ៍" ។ *អាល់-មូវ៉ាត្ត៍អ៊ៈ (الموطأ)* របស់លោក ម៉ាលិក ជុំទី ១ "វគ្គជូនពរព្រះសាស្តាﷺ" ទំព័រ ១៣៨ ។ *អ៊ុសដ៍ អាល់-គ៏បាស្ទ៍ (اسد الغابة)* ជុំទី ៥ ទំព័រ ៩០ ។ *មុសណាដ៍ អាស្មាំដ៍ អ៊ីបនូ ហ្វាន់បាល់ (مسند احمد ابن حنبل)* ជុំ ៤ ទំព័រ ៣២ ។ *អាល់-អ៊ីសទីអ៊ាប់ (الإستيعا)* ជុំទី ៣ នៅរឹមដើមទំព័រ "អាល់-អ៊ីស្វ៍បាស្ទ៍ (الإصَابة)" ទំព័រ ៦៣១ ។ *ហ្វាតហ្ម៍ អាល់-បារី (فتح الباري)* ជុំទី ១ ទំព័រ ២៨១-២៨២ ។



«انّ رسول الله سمع عمر وهو يقول: وأبى. فقال إنّ الله يَنهاكم أن تحلِفوا بآبائكم ومن كان حالفاً فليحلف بالله أو يسكت»

*"ព្រះសាស្តាﷺអល់ឡោះហ្ម៍عز وجلឮអ៊ូម៉ារស្បថលើឪពុកគាត់ ។ ព្រះអង្គﷺមានព្រះវចនៈថា៖ "អល់ឡោះហ្ម៍عز وجل ហាមអស់លោកស្បថលើឪពុកអស់លោក ។ បើចង់ស្បថ ចូរស្បថលើអល់ឡោះហ្ម៍عز وجل ឬនៅស្ងៀម ។"*[200]

ទោះបីហាឌីស្ហ៍នេះមិនមានទម្ងន់ស្មើអាយ៉ាស្ទ៍គួរអាន និងហាឌីស្ហ៍ដែលអនុញ្ញាតឲ្យស្បថលើអ្វីផ្សេងពីព្រះអល់ឡោះហ្ម៍عز وجلនោះក៏ដោយ តែការហាមស្បថលើឪពុកខ្លួនចំពោះអ៊ូម៉ារនិងមនុស្សជំនាន់គាត់នោះ ព្រោះតែឪពុករបស់ពួកគាត់ភាគច្រើនជាបុគ្គលគោរពបូជារូបបដិមា និងជាមនុស្សពហុទេពនិយម ។ ពួកបដិសេធ សទ្ធានិងពួកគោរពបូជារូបបដិមាមិនស័ក្តិសមនៅក្នុងពាក្យសម្បថរបស់ពួកមុស្លីមទេ ។

## សំណួរ ២៥ - តាវ៉ាស់ស៊ូល (تَوَسُّل) ការពឹងមិត្តអល់ឡោះហ្ម៍عز وجل មិនមែនអំពើហ៊ុនហាយ (គឺស្ហ៊ីរិក) និងជាករណីកែប្រែ (គឺប៊ីដ្ហអ៊ុស្ទ៍) នៅក្នុងសាសនាទេ ?

## ចម្លើយ

*តាវ៉ាស់ស៊ូល* មានន័យថាពឹងពាក់សន្តបុគ្គល (អៅលីយ៉ា) ដើម្បីអាចចូលជិតអល់ឡោះហ្ម៍عز وجلបានដោយសារអន្តរការរបស់សន្តបុគ្គលនោះ ។ លោក អ៊ីបនូ ម៉ាន់ស៊្ហូរ (ابن منظور) មានប្រសាសន៍នៅក្នុងសៀវភៅ លីសាន

[200] សូមមើល *ស៊ូណាន់ អាល់-គុបរ៉ (سنن الكبرى)* ជុំទី ១០ ទំព័រ ២៩; *ស៊ូណាន់ អាន់-នីសាអ៊ី (النسائي)* ជុំទី ៧ ទំព័រ ៤-៥ ។

*នេះ ។"*[199]

យើងឃើញច្បាស់ថាពុំមានអ៊ីច្ទីហ្វាជ់ (គឺខិតខំរិះគិត) ណាមួយអាចមិនអើពើអត្ថបទនិងហាឌីស្ទទាំងនេះ ហើយអាចបដិសេធទង្វើអល់ឡោះហ្ទ៍عز وجلនៅក្នុងគួរអាន បដិសេធសម្ដីព្រះសាស្ដាصلى الله عليه وآله وسلمនិងទង្វើរបស់បណ្ដា សាវកព្រះអង្គصلى الله عليه وآله وسلمនោះបានឡើយ ដូចជាព្រះអគ្គមហាប្រមុខរបស់អ្នកមានសទ្ធាជ្រះថ្លា (អាលីصلوات الله عليه والسلام) ជាដើម ដោយចោទថាអល់ឡោះហ្ទ៍عز وجلនិងអស់បុគ្គលថ្លៃថ្នូរទាំងនេះស្ទីរិក និងហ៊ុយហាយជាមួយអល់ឡោះហ្ទ៍عز وجل ។

## សេចក្ដីសរុប

ឧទាហរណ៍ទាំងនេះសឲ្យឃើញថា ស្បថលើអ្វីផ្សេងពីអល់ឡោះហ្ទ៍عز وجلជាការស្របច្បាប់ ដោយយោលតាមមតិព្រះគម្ពីរអល់ឡោះហ្ទ៍عز وجل តាមព្រះស៊ុនណាស្ទ់របស់ព្រះសាស្ដាصلى الله عليه وآله وسلم និងតាមទង្វើរបស់បណ្ដាអ្នកមានសទ្ធា ។ ពុំអាចប្រកែកទង្វើនេះបានទេ ហើយមិនផ្ទុយនឹងតៅហ៊ីដ្ទទេ ។

ដូច្នេះ បើន័យក្រៅរបស់ហាឌីស្ទផ្ទុយពីអ្វីដែលគេបាននាំមកបញ្ជាក់ដោយមានភ័ស្ដុតាងច្បាស់លាស់នោះ ត្រូវតែអធិប្បាយបំភ្លឺឲ្យសមគៅតាមគោលការណ៍របស់គួរអាននិងហាឌីស្ទដែលមិនអាចប្រកែកបាន ។

អ្នកខ្លះបានលើកហាឌីស្ទមានន័យមិនប្រាកដមកបង្ហាញ គឺ៖

[199] សូមមើល *ណាស្ទ់យ៉ាល់-បាឡាកោ៎ត្ទ៍ (نهج البلاغة)* (បោះពុម្ពផ្សាយដោយ មូហ៊ាំម៉ាដ្ទ់ អាប់ឌុះហ្ទ៍) ឃុត្ទបាស្ទ់ ៩ ។ ចង់បានព័ត៌មានបន្ថែម សូមមើលឃុត្ទបាស្ទ់ ១៦៨, ១៨២ និង ១៨៧ ។ មើលឃុត្ទបាស្ទ់ ៦ និង ៥៤ ។



عز وجل ដូចមិត្តជំនិតរបស់អល់ឡោះហ្ទ៍عز وجلផ្ទាល់ដែរនោះ ជាវត្ថុដែលអល់ឡោះហ្ទ៍عز وجلបានបង្កើតមក ហើយការពិត វត្ថុទាំងនេះត្រូវការអល់ឡោះហ្ទ៍عز وجلខានមិនបាន ទាំងក្នុងការមានអត្ថិភាពឬក្នុងការមានឥទ្ធិពល (និយាយឲ្យស្រួលស្ដាប់គឺ វត្ថុទាំងនេះមានរូបរាងឡើងជាវត្ថុឬមានឥទ្ធិពលនោះដោយសារតែអល់ឡោះហ្ទ៍عز وجلមួយគត់) ។

ស្ទីអាស្ទ់ស្វែងរកពរជ័យតាមរយៈវត្ថុទាំងនេះ ដែលពាក់ព័ន្ធនឹងអ៊ីម៉ាំនិងបុគ្គលមុនៗរបស់ខ្លួនក្នុងសាសនាអល់ឡោះហ្ទ៍عز وجلនោះ ព្រោះពួកគេសម្ដែងសេចក្ដីគោរពនិងសេចក្ដីស្រឡាញ់ដ៏ស្មោះ ចំពោះសន្តបុគ្គលទាំងនេះតែម្យ៉ាងប៉ុណ្ណោះ ។

ដែលស្ទីអាស្ទ់ថើបព្រះចេតិយ ឬទ្វារព្រះចេតិយ ឬជញ្ជាំងព្រះចេតិយនោះក្នុងពេលស៊ីយ៉ារ៉ាស្ទ់ព្រះចេតិយ ព្រះសាស្ដាصلى الله عليه وآله وسلمនិងព្រះរាជកុលដ្ឋានព្រះអង្គعليهم السلامនោះ ព្រោះតែពួកគេស្រឡាញ់ព្រះសាស្ដាصلى الله عليه وآله وسلمនិងបណ្ដាកូនចៅព្រះអង្គ ។ នេះជារឿងមនោសញ្ចេតនាមនុស្សដែលកើតមានឡើងក្នុងខ្លួនបុគ្គលដែលទទួលអារម្មណ៍ស្រឡាញ់ ។ កវីដ៏មានវោហារម្នាក់បានថា៖

أمُرُّ عَلَى الدِّيارِ دِيار سَّلْمى
أقَبِّلُ ذَا الجْدارَ وَذَا الجْدارا
وَما حُبُّ الدِّيارِ شَغَفْنَ قَلْبِي
وَلَكِنْ حُبُّ مَنْ سَكَنَ الدِّيارا

"ខ្ញុំឆ្លងកាត់ស្រុកមួយ ស្រុកសាឡាម៉ា ។ ខ្ញុំថើបជញ្ជាំងនេះ ខ្ញុំថើបចញ្ជាំងនោះ ។ មិនមែនសេចក្ដីស្រឡាញ់គ្រឹះស្ថាននេះធ្វើឲ្យបេះដូងខ្ញុំរំជើបរំជួលទេ តែសេចក្ដីស្រឡាញ់ចំពោះបុគ្គលដែលស្ថិតនៅឯគ្រឹះស្ថាននោះ ។"

## សំណួរ ២១ - តើសាសនាដាច់ឡែកពីនយោបាយទេ ក្នុងសាសនាអ៊ីស្លាម ?

## ចម្លើយ

ជាដំបូងយើងត្រូវអធិប្បាយបំភ្លឺពាក្យ "នយោបាយ" បង្ហាញនូវទំនាក់ទំនងដែលមានរវាងនយោបាយនិងសាសនា ។ ពាក្យ "នយោបាយ" មានសម្រាយពីរគឺៈ

១. ជួនកាលនយោបាយមានន័យថា "ការបោកប្រាស់, កលល្បិច, ការប្រើគ្រប់មធ្យោបាយដើម្បីទៅដល់គោលដៅសំខាន់នីមួយ" ។ អាចនិយាយម្យ៉ាងទៀតបានថា បើចង់បានលទ្ធផលត្រូវប្រើគ្រប់មធ្យោបាយ ។ ការពិតន័យរបស់ពាក្យនយោបាយ ដែលមិនស្របតាមន័យពិតរបស់ពាក្យទេនោះ មានន័យត្រឹមតែថាបញ្ឆោតនិងបោកប្រាស់ទេ តែន័យនេះមិនសមស្របនឹងមាគ៌ាសាសនាទេ ។

២. ន័យទីពីររបស់ពាក្យ "នយោបាយ" គឺការរៀបចំសង្គមកិច្ចក្នុងសហគមន៍តាមគោលការអ៊ីស្លាម ។ នយោបាយដែលមានន័យថារៀបចំរឿងមុស្លីមសមស្របតាមគូរអាននិងសុនណាស់ ជាប៉ែកសំខាន់មួយរបស់សាសនា ។ យើងសូមរំលឹកភ័ស្តុតាងដែលបញ្ជាក់ថាសាសនានិងនយោបាយចុះសម្រុងគ្នា និងភ័ស្តុតាងដែលបញ្ជាក់ថាចាំបាច់ត្រូវបង្កើតរដ្ឋបាលអ៊ីស្លាម ។

ភ័ស្តុតាងប្រសើរបំផុតគឺវិធីរបស់ព្រះសាស្តា ﷺ សម័យព្រះអង្គ ﷺ បំពេញបេសកកម្មដែលមានពេលល្អនិងពេលអាក្រក់ ។ ការសិក្សាសម្តីនិងទង្វើរបស់ព្រះសាស្តា ﷺ បញ្ជាក់ឲ្យឃើញច្បាស់ថា ចាប់តាំងពីដើមបេសកកម្ម



បើមុស្លីមភាគច្រើនគិតថា ការស្បថលើអ្វីផ្សេងពីអល់ឡោះហ្ទ៍ ﷻ ជាអំពើពហុទេពនិយម តើពួកមុស្លីមទាំងនោះ យល់ឃើញយ៉ាងណាអំពីទង្វើមួយនេះរបស់ព្រះសាស្តា ﷺ (ពោលគឺ ស្បថលើឪពុករបស់បុរសនោះ) ?

៣. ក្រៅពីព្រះគម្ពីរអល់ឡោះហ្ទ៍ ﷻ និងសុនណាស់ព្រះសាស្តា ﷺ ទង្វើរបស់បណ្តាសាវកជំនិតរបស់ព្រះសាស្តា ﷺ អល់ឡោះហ្ទ៍ ﷻ ក៏ជាភ័ស្តុតាងដែរ ដែលបញ្ជាក់ថាការស្បថលើអ្វីផ្សេងពីអល់ឡោះហ្ទ៍ ﷻ នោះជាទង្វើស្របច្បាប់

អាលី អ៊ីបនូ អាប៊ី ត៌លិប صلوات الله عليه والسلام បានស្បថលើជីវិតព្រះអង្គ صلوات الله عليه والسلام ច្រើនកន្លែងនៅក្នុងឃុត្តបាស់គ្រចះគ្រចង់របស់ព្រះអង្គ صلوات الله عليه والسلام កាលព្រះអង្គ صلوات الله عليه والسلام មានវចនៈថាៈ

«ولعمري ليضعّفنّ لكم التّيه من بعدى أضعافا»

*"សូមស្បថលើជីវិតខ្ញុំ អត់ពីខ្ញុំទៅអស់លោកនឹងកាន់តែវង្វេងខ្លាំងឡើង ។"*[198]

ព្រះអង្គ صلوات الله عليه والسلام មានវចនៈមួយកន្លែងទៀតថាៈ

«وَلعمري لإنْ لم تنزع عن غيّك وشقاقك لتعرفنّهم قليلً يطلبونك»

*"ខ្ញុំសូមស្បថលើជីវិតខ្ញុំ បើលោកមិនដកខ្លួនចេញពីការលាក់ពុតត្បុត ពីការកំណាញ់និងពីការប្រទូសបះបោរទេ លោកនឹងបានឃើញអ្វីទាំង*

[198] សូមមើល *ណាស្ស៍យ៉ាល់-បាឡាក៉ោត្ត៍ (نهج البلاغة)* (បោះពុម្ពផ្សាយដោយមូហ៊ាំម៉ាដ្ញ អាប់ឌុះហ្ទ៍) ឃុត្តបាស់ ១៦១ ។

លោក អាស៊ុម៉ាជ៉ូ អ៊ីបនូ ហ្កាន់បាល់ មេនិកាយហ្កាន់បាលី បានថ្លែងតមកពីព្រះសាស្តាﷺអល់ឡោះហ្ទ៍عز وجل នៅក្នុងមុសណាជ៉ូថា៖

﴿ فلعمري لأن تكلّم بمعروفٍ وتنهى عن منكرٍ خيرٌ من أن تسكت ﴾

*"សូមស្បថលើជីវិតខ្ញុំ បើលោកណែនាំឲ្យប្រព្រឹត្តល្អ ហាមប្រព្រឹត្តអាក្រក់ វាប្រសើរជាងនៅស្ងៀម ។"*[196]

នៅក្នុងស្ហ៍ហ៊្វិះហ៊្វ៍របស់លោក ដែលអាស្ស៍លុល-ស៊ុនណាស្ស៍ចាត់ទុកជាស្ហ៍ហ៊្វិះហ៊្វ៍ត្រឹមត្រូវមួយ ក្នុងចំណោមប្រជុំហ្កាឌីស្ហ៍ត្រឹមត្រូវទាំងប្រាំមួយ លោក មុស្លីម អ៊ីបនូ អាល់-ហ្កាច់យ៉ាច់មានប្រសាសន៍ថា៖

«جاءَ رَجل إلى النّبيّ (صلَّى الله عليه و آله) فقال يا رسول الله أيُّ الصَّدقة أعظم اجراً؟ فقال: أما وأبيك لتنبانَّه أن تصدّق وأنت صحيحٌ شحيحٌ تخشى الفقر وتأمل البقاء...»

*"គេបានសួរព្រះសាស្តាﷺអល់ឡោះហ្ទ៍عز وجلថា៖ "តើទានមួយណាដែលបានបុណ្យធំជាងគេ ?" ព្រះអង្គﷺមានព្រះវចនៈថា៖ "សូមស្បថនឹងឪពុកលោក ទានដែលប្រសើរបំផុតនោះគឺទានដែលលោកឲ្យក្នុងពេលមានសុខភាពល្អនិងក្នុងពេលមានជម្ងឺ ដោយខ្លាចក្រនិងដោយសង្ឃឹមរស់រានមានជីវិត ។"*[197]

---

[196] សូមមើលសៀវភៅ *មុសណាជ៉ូ អាស៊ុម៉ាជ៉ូ អ៊ីបនូ ហ្កាន់បាល់* ជុំទី ៥ ទំព័រ ២២៤-២២៥ ហ្កាឌីស្ហ៍របស់លោក បាស្ហៀរ អ៊ីបនូ ខ៊ុំសាស៊ីយ៉ាស្ស៍ អាល់-សាឌូស៊ី ។

[197] សូមមើល *ស្ហ៍ហ៊្វិះហ៊្វ៍ មុស្លីម* (បោះពុម្ពនៅអេស៊ីបត៍) កណ្ឌទី ៣ "គីតាប អាស្ស៍-ស្ហាកាត្ស៍", "បាប់ បាយ៉ាន អាន់ អាហ្វ៍ដ្ហាល់ អាស្ស៍-ស្ហ៍ដាកោ្វះត៍, ស្ហ៍ដាកោ្វះត៍ អាស្ស៍-ស្ហ៍ហ៊្វិះហ៊្វ៍ អាស្ស៍-ស្ហាហ៊្វិះហ៊្វ៍" ទំព័រ ៩៣-៩៤; មើលសៀវភៅរបស់ លោក អាប់ឌុល-ហ្កាមីដ ស្ហ៊ីដ្ហឌីគ្វី *ស្ហ៍ហ៊្វិះហ៊្វ៍ មុស្លីម* (ច្បាប់ប្រែជាភាសាអង់គ្លេស) ជុំទី ១ វគ្គ ២៩ ហ្កាឌីស្ហ៍លេខ ២២៥១ ។



មកម្ល៉េះ ព្រះអង្គﷺមានបំណងបង្កើតរដ្ឋបាលមាំចាក់គ្រឹះនៅលើជំនឿចំពោះអល់ឡោះហ្ទ៍عز وجل ហើយមានសមត្ថភាពបង្កើតកម្មវិធីសកម្មភាពរបស់សង្គមអ៊ីស្លាមថ្មី ។

ចាំបាច់ត្រូវលើកឡើងនូវភ័ស្តុតាងដែលស្តីអំពីសកម្មភាពសំខាន់នេះរបស់ព្រះសាស្តាﷺដើម្បីសម្រេចគោលដៅនោះ គឺ៖

## ព្រះសាស្តាﷺជាអ្នកបង្កើតរដ្ឋបាលអ៊ីស្លាម

១. កាលព្រះសាស្តាﷺបានទទួលបញ្ជា ឲ្យបើកឲ្យដឹងព្រះបេសកកម្មព្រះអង្គﷺ ព្រះអង្គﷺបានចាប់ផ្តើមរៀបចំក្រុមទប់ទល់ ក្រុមចាត់ចែងនិងក្រុមប្រមូលកម្លាំងមុស្លីម ។ គួបនឹងខ្សែបន្ទាត់នេះ ព្រះអង្គﷺតែងតែ ជួបជាមួយក្រុមអ្នកបំពេញពិធីហ្កាច្ចឯកាក់ុបាស្ស៍ពីឆ្ងាយនិងជិត ដោយអំពាវនាវពួកគេមកកាន់អ៊ីស្លាម ។

ព្រះអង្គﷺបានជួបជាមួយមនុស្សពីរក្រុមមកពីម៉ាឌីណាស្ស៍ នៅឯកន្លែងមួយហៅថា "អាកុ៏បាស្ស៍" ដែលបានសន្យាថានឹងអញ្ជើញព្រះអង្គﷺទៅស្រុកពួកគេហើយនឹងគាំទ្រព្រះអង្គﷺ ។[171] ដូច្នេះ នេះគឺជំហានដំបូងឈានទៅកាន់ការបង្កើតរដ្ឋបាលអ៊ីស្លាម ។

២. ក្រោយពីបានភៀសខ្លួនទៅម៉ាឌីណាស្ស៍ ព្រះសាស្តាﷺអល់ឡោះហ្ទ៍عز وجلបានចាប់ផ្តើមបង្កើតនិងរៀបចំយោធាជាតិធំ គឺទ័ពដែលបានប្រយុទ្ធក្នុង ៨២ សមរភូមិក្នុងរយៈពេលព្រះសាស្តាﷺបំពេញបេសកកម្ម និងដែលបានបំបាត់ឧបសគ្គដែលរាំងការបង្កើតរដ្ឋបាលអ៊ីស្លាម ដោយសារជ័យ

---

[171] សូមមើលសៀវភៅ *ស៊ីរ៉េះត៍ អ៊ីបនូ ហ៊ីស្ហាំ (السيرة ابن هشام)* (បោះពុម្ពលើកទីពីរនៅអេស៊ីបត៍) ជុំទី ១ "រឿងអាកុ៏បាស្ស៍ ដំបូង" ទំព័រ ៤៣១ ។

ជំនះទាំងនេះ ។

៣. ក្រោយពីបានបង្កើតរដ្ឋបាលអ៊ីស្លាមនៅម៉ាឌីណាស្ហ់ ព្រះសាស្ដាﷺ បានបញ្ជូនឯកអគ្គរដ្ឋទូតនិងព្រះរាជសារប្រវត្តិសាស្ត្រ បានទាក់ទងជាមួយមហាអំណាចនយោបាយនិងសង្គមសម័យនោះ ហើយបានធ្វើកិច្ចព្រមព្រៀងផ្នែកសេដ្ឋកិច្ច ផ្នែកនយោបាយនិងយោធាជាមួយពួកមេដឹកនាំមហាអំណាចទាំងនោះ ។

ព្រះជីវប្រវត្តិរបស់ព្រះសាស្ដាﷺមាននូវសេចក្ដីរាយការណ៍លំអិត អំពីព្រះរាជសារព្រះអង្គﷺផ្ញើទៅស្ដេច ឃុសរូ (خسرو) ព្រះចៅអធិរាជនៃអាណាចក្រអ៊ីរ៉ង់ (Emperor of Persia) ទៅសេសារ (Caesar គ៊ីស្ហរ៍ قيصر) ព្រះចៅអធិរាជនៃអាណាចក្របីសង់ទីន (Emperor of Byzantine بِيزَنْطِيَّ) ទៅព្រះចៅម៉ាកៅគ៊ីស (المقوقس) ស្ដេចប្រទេសអេស៊ីបត៍ ទៅព្រះចៅនេគុសស្ដេចប្រទេសអាប៊ីស៊ីនី (Negus, the King of Abyssinia النَّجَاشِيَّ) និងស្ដេចសោយរាជ្យច្រើនទៀតនៃសម័យនោះ ។ [172]

៤. ព្រះសាស្ដាﷺបានតែងតាំងអភិបាល និងអ្នកដឹកនាំច្រើនកុលសម្ព័ន្ធនិងស្រុក ដើម្បីសម្រេចគោលដៅអ៊ីស្លាមនិងបង្រួបបង្រួមសហគមន៍ ។ ឧទាហរណ៍ ខាងក្រោមនេះគឺសេចក្ដីសម្រេចរបស់ព្រះអង្គﷺរឿងនេះ ។

ព្រះសាស្ដាﷺបានចាត់បញ្ជូនលោក រីហ្វាអុស្ហ់ អ៊ីបនូ ស្ហៃដ៍ (رفاعة بن زيد) ជាតំណាងព្រះអង្គﷺ ទៅជួបកុលសម្ព័ន្ធលោក ហើយបានសរសេរព្រះ

[172] សូមមើលសៀវភៅរបស់ លោក ហាមីឌុល-ឡោះហ៍ *អាល់-វ៉ាស្ហាអ៊ិក្វ អាល់-ស៊ីយ៉ាស៊ីយ៉ាស្ហ់ (الوثائق السياسية)* និងសៀវភៅរបស់លោក អុលី អាស្ហ់ម៉ាឌី *ម៉ាកាទីប អារ-រ៉ស៊ូល (مكاتيب الرسول)* ។



*ក្នុងផ្ទាំងសំណេរលាតត្រដាង ។ [អញសូមស្បថ]នឹងព្រះមហាគ្រឹះស្ថានដែលមានប្រជារាស្ត្រមកជាញឹកញយ ! [អញសូមស្បថ]នឹងដោមលើកខ្ពស់ ! [អញសូមស្បថ]នឹងសមុទ្រផុរ (ពុះហៀរ) ! ៥២:១-៦ ។"* [195]

គេឃើញមានការស្បថលើគ្រឿងសម្គាល់នៃមាបនកម្មដូចនេះដែរ នៅក្នុងស៊ូរ៉ោះតុ៍អាល់-មូរសាឡាត់ (៧៧), អាន់-ណាស៊ីអាត់ (៧៩), អាល់-ប៊ូរូច (៨៥), អាត់-តុ៍រិក (៨៦), អាល់-បាឡាដ់ (៩០), អាដ់-ឌុហា (៩៣) និង អាត់-ទីន (៩៥) ។

ពិតប្រាកដណាស់ ប្រសិនបើស្បថលើអ្វីផ្សេងពីអល់ឡោះហ៍عزوجلជាទង្វើស៊ីរិកនិងជាអំពើហ៊ុនហាយមែននោះ ព្រះគម្ពីរគួរអាន ដែលជាគំរូសុក្រឹតបំផុតក្នុងការទទួលស្គាល់តៅហ៊ីដ និងការទទួលស្គាល់អល់ឡោះហ៍عزوجلជាព្រះតែមួយគត់នោះ ប្រាកដជាមិនធ្វើទង្វើនេះជាដាច់ខាត ប្រសិនបើការស្បថបែបនេះកំណត់ទុកសម្រាប់តែអល់ឡោះហ៍عزوجلមួយនោះ អាយ៉ាស្ហ់គួរអានប្រាកដជាបានរំលឹកដាស់តឿនមនុស្សកុំឲ្យប្រព្រឹត្តបែបនេះ ក្រែងខុសឆ្គង ។

២. មុស្លីមទាំងអស់ក្នុងលោកចាត់ទុកព្រះសាស្ដាﷺជាគំរូ ហើយចាត់ទុកទង្វើនិងអាកប្បកិរិយាព្រះអង្គﷺ ជាគំរូសម្រាប់វិនិច្ឆ័យវែកញែករកខុសត្រូវ ។

អស់លោកអ្នកប្រាជនិងអស់លោកអ្នកចងក្រងស្ហ៍ហ៊ិះហ៍ និងមុសណាដ់មុស្លីមទាំងឡាយ បានលើកឡើងនូវការស្បថលើអ្វីផ្សេងពីអល់ឡោះហ៍عزوجلដ៏ច្រើនរបស់ព្រះសាស្ដាﷺ ។

[195195] ស៊ូរ៉ោះតុ៍ អាត់-ទូរ 52:1-6 ។

وَٱلنَّجۡمِ إِذَا هَوَىٰ

*"[អញសូមស្បថ]ចំពោះផ្កាយពេលវាចុះមក ៥៣:១ ។"*[191]

نٓ ۚ وَٱلۡقَلَمِ وَمَا يَسۡطُرُونَ

*"នូន ។ អញសូមស្បថចំពោះប៉ាកកានិងចំពោះអ្វីដែលពួកគេ (មិត្តរបស់អល់ឡោះហ្ម៍) សរសេរ ៦៨:១ ។"*[192]

وَٱلۡعَصۡرِ ١ إِنَّ ٱلۡإِنسَٰنَ لَفِي خُسۡرٍ ٢

*"[អញសូមស្បថ]នឹងសម័យកាល ។ ពិតណាស់ មនុស្សនៅក្នុងសេចក្តីវិនាស ៦៨:១-២ ។"*[193]

وَٱلۡفَجۡرِ ١ وَلَيَالٍ عَشۡرٍ ٢

*"[អញសូមស្បថនឹង]សេតារុណ (គឺពន្លឺសបំព្រាងដែលលេចឡើងដំបូងមុនពេលថ្ងៃរះ) [អញសូមស្បថ]នឹងយប់ទាំងដប់ ៨៩:១-២ ។"*[194]

وَٱلطُّورِ ١ وَكِتَٰبٖ مَّسۡطُورٖ ٢ فِي رَقّٖ مَّنشُورٖ ٣ وَٱلۡبَيۡتِ ٱلۡمَعۡمُورِ ٤
وَٱلسَّقۡفِ ٱلۡمَرۡفُوعِ ٥ وَٱلۡبَحۡرِ ٱلۡمَسۡجُورِ ٦

*"[អញសូមស្បថ]នឹង[ភ្នំ]ទួរ [អញសូមស្បថ]នឹងព្រះគម្ពីរដែលគេចារនៅ*

[191] ស៊ូរ៉ោះត្ទ័ អាន់-ណាច្ជ៉ម៍ 53:1 ។
[192] ស៊ូរ៉ោះត្ទ័ អាល់-ក៉្ទឡាំ 68:1 ។
[193] ស៊ូរ៉ោះត្ទ័ អាល់-អ៊ុស្ស៉រ៍ 103:1-2 ។
[194] ស៊ូរ៉ោះត្ទ័ អាល់-ហ្វាច្ជ៉រ៍ 89:1-2 ។



រាជមួយច្បាប់ថា៖

«بسم الله الرحمن الرّحيم، (هذا كتاب) من محمّد رسول الله (صلَّى الله عليه و آله وسلّم) لرفاعة بن زيدٍ إنّي بعثته إلى قومه عامَّةً ومن دخل فيهم يدعوهم إلى الله وإلى رسوله فمن أقبل منهم ففي حزب الله وحزب رسوله ومن أدبر فله أمانُ شهرين»

*"ក្នុងព្រះនាមអល់ឡោះហ្ម៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។ នេះគឺសំបុត្រពីមូហាំម៉ាដ់ ព្រះសាស្តារបស់អល់ឡោះហ្ម៍ﷺជូនចំពោះ រីហ្វាអ៊ាស់ អ៊ីបនូ ស៊ៃដ៍ ។ ខ្ញុំចាត់បញ្ជូនគេទៅជួបប្រជារាស្ត្ររបស់គេនិងបណ្តាអ្នកដែលជាប់ពាក់ព័ន្ធនឹងពួកគេ ដើម្បីនឹងឲ្យគេអញ្ជើញពួកគេមករកអល់ឡោះហ្ម៍និងព្រះសាស្តាព្រះអង្គ ។ ដូច្នេះ អ្នកណាព្រមទទួលការអញ្ជើញរបស់គេ អ្នកនោះនៅក្នុងបក្សអល់ឡោះហ្ម៍និងព្រះសាស្តាព្រះអង្គ ។ អ្នកណាបដិសេធការអញ្ជើញនេះ អ្នកនោះមានរយៈពេលពីរខែ ។"*[173]

ការប្រព្រឹត្តនិងការសម្រេចរបស់ព្រះសាស្តាﷺបញ្ជាក់ថា ចាប់តាំងពីដើមបេសកកម្មព្រះអង្គﷺម្ល៉េះ ព្រះអង្គﷺមានបំណងបង្កើតរដ្ឋបាលដើម្បីចាត់ចែងច្បាប់អ៊ីស្លាមគ្រប់មុខសម្រាប់មនុស្ស ។

តើគេអាចហៅការធ្វើកិច្ចព្រមព្រៀងជាមួយក្រុម និងកុលសម្ព័ន្ធមានឥទ្ធិពល ការបង្កើតមូលដ្ឋានទ័ពខ្លាំង ការចាត់បញ្ជូនឯកអគ្គរាជទូតទៅឯប្រទេសនានា ការដាស់តឿនស្តេចនិងអ្នកដឹកនាំទាំងឡាយ ការទាក់ទងជាមួយពួកគេ ការតែងតាំងអភិបាលខេត្តនិងស្រុកជិតនិងឆ្ងាយនិងទង្វើស្រដៀងនេះច្រើនទៀត ផ្សេងពីហៅថា "នយោបាយ" ក្នុងអត្ថន័យរៀបចំនិងចាត់ចែងគ្រប់វិស័យរបស់សង្គមបានទេ ?

[173] សូមមើលសៀវភៅ*ម៉ាកាទីប អារ-រ៉ស៊ូល (مكاتيب الرسول) ។*

ក្រៅពីទង្វើរបស់ព្រះសាស្ដាﷺ ការប្រព្រឹត្តរបស់ស្ដេចខ៊ូលិហ្វទាំងបួន ជាពិសេសវិធី ដែលព្រះអគ្គមហាប្រមុខរបស់បណ្ដាអ្នកមានសទ្ធាជ្រះថ្លា អាលី អ៊ីបនូ អាប៊ី តូលិប صلوات الله عليه والسلام បានប្រើនៅក្នុងរជ្ជកាលព្រះអង្គនោះ សម្រាប់មូស្លីមទាំងអស់ ស៊ូនីអាស់និងស៊ុននី ជាភ័ស្ដុតាងបញ្ជាក់ឲ្យឃើញ ថាសាសនានិងនយោបាយនោះសមស្របគ្នា នៅលើខ្សែបន្ទាត់តែមួយ ។

អស់លោកអ្នកប្រាជ្ញទាំងពីរម៉ាស្ហាប់បានផ្ដល់ភ័ស្ដុតាងដ៏ច្រើន ដកស្រង់ពីព្រះគម្ពីរគួរអាននិងស៊ុនណាស់ ដែលស្ដីអំពីការចាំបាច់បង្កើតរដ្ឋបាលអ៊ីស្លាមដើម្បីចាត់ចែងសង្គមកិច្ចក្នុងអ៊ុមម៉ាត់ ។

លោក អាប៊ូ អាល់-ហាសាន់ អាល់-ម៉ាវ៉ារឌី (أبو الحسن الماوردي) មានប្រសាសន៍នៅសៀវភៅលោក អាល់-អាស់កាម អាស់-ស៊ុលត្វន់នីយ៉ាស់ (الأحكام السلطانية) ថា៖

«الامامة موضوعة لخلافة النبوّة في حراسة الدّين وسياسة الدّنيا، وعقدها لمن يقوم بها في الامّةِ واجبٌ بالإجماع».

*"អ៊ីម៉ាម៉ាស់ត្រូវបង្កើតឡើងក្នុងគោលបំណងស្នងសាស្ដាភាព (នូប៊ូវ៉ាស់) ដើម្បីថែរក្សាសាសនា ចាត់ចែងគ្រប់រឿងពាក់ព័ន្ធនិងលោកនេះ ។ ប្ដេជ្ញាទទួលស្គាល់បុគ្គលដែលកាន់អ៊ីម៉ាស់នោះជាការចាំបាច់ ស្របទៅតាមមតិទូទៅរបស់អ៊ុមម៉ាត់ ។"*[174]

លោកអ្នកប្រាជ្ញអាស្ហលុល-ស៊ុនណាស់ដ៏ល្បីមួយរូបនេះ បានបង្ហាញមតិលោកដោយផ្អែកលើភ័ស្ដុតាងសមហេតុផលនិងភ័ស្ដុតាងផ្នែកសាសនា ។

[174] សូមមើលសៀវភៅរបស់លោក អាប៊ូ អាល់-ហាសាន់ អាល់-ម៉ាវ៉ារឌី (أبو الحسن الماوردي) *អាល់-អាស់កាម អាស់-ស៊ុលត្វន់នីយ៉ាស់ (الأحكام السلطانية)* (បោះពុម្ពនៅប្រទេសអេស៊ីបត៍) "បាប់ អាល់-អៅវ៉ាល់" ទំព័រ ៥ ។ និយាយឲ្យស្រួលស្ដាប់គឺមូស្លីមទាំងអស់គ្នាត្រូវទទួលស្គាល់អ៊ីម៉ាម៉ាស់អត់ពីព្រះសាស្ដាﷺទៅ ។



១. នៅក្នុងអាយ៉ាស់ព្រះគម្ពីរគួរអានថ្លៃថ្លា យើងឃើញមានសម្បថចំពោះសត្វលោកថ្លៃថ្នូរដូចជា "ជីវិតរបស់ព្រះសាស្ដា", "ព្រលឹងមនុស្ស", "ប៉ាកកា" ជាដើមដែលជានិមិត្តរូបរបស់លាយលក្ខណ៍អក្សរ "ដួងចន្ទ", "ដួងខែ", "ថ្ងៃនិងយប់", "មេឃនិងផែនដី", "សម័យកាល" និង "ភ្នំនិងសមុទ្រ" ជាដើម ។ យើងសូមលើកយក មកបង្ហាញនូវអាយ៉ាស់ទាំងនេះគឺ៖

لَعَمۡرُكَ إِنَّهُمۡ لَفِي سَكۡرَتِهِمۡ يَعۡمَهُونَ

*"សូមសម្បថចំពោះជីវិតអ្នក [សាស្ដាអើយ] ពួកគេវង្វេងពាសវាលពាសកាលនៅក្នុងមោហ៍បាំង (១៥:៧២) ។"*[189]

وَٱلشَّمۡسِ وَضُحَىٰهَا ۝١ وَٱلۡقَمَرِ إِذَا تَلَىٰهَا ۝٢ وَٱلنَّهَارِ إِذَا جَلَّىٰهَا ۝٣ وَٱلَّيۡلِ إِذَا يَغۡشَىٰهَا ۝٤ وَٱلسَّمَآءِ وَمَا بَنَىٰهَا ۝٥ وَٱلۡأَرۡضِ وَمَا طَحَىٰهَا ۝٦ وَنَفۡسٖ وَمَا سَوَّىٰهَا ۝٧ فَأَلۡهَمَهَا فُجُورَهَا وَتَقۡوَىٰهَا ۝٨

*"[អញសូមសម្បថនឹង]ដួងអាទិត្យនិងជោតិភាពវា [អញសូមសម្បថ]នឹងដួងចន្ទដែលតាមក្រោយវា [អញសូមសម្បថ]នឹងទិវាកាលពេលវាឆ្លុះបញ្ចាំងវា (គឺដួងអាទិត្យ) [អញសូមសម្បថ]នឹងរាត្រីកាលពេលវាដណ្ដប់វា (គឺដួងអាទិត្យ) [អញសូមសម្បថ]នឹងមេឃនិងអ្នកដែលបានសាងវា [អញសូមសម្បថ]នឹងផែនដីនិងអ្នកដែលបានលាតសន្ធឹងវា [អញសូមសម្បថ]នឹងព្រលឹងនិងអ្នកដែលបានធ្វើឲ្យវាសមស្រប ហើយព្រះអង្គបានញ៉ាំងសេចក្ដីអាក្រក់ (គឺបើកចិត្តឲ្យយល់ដឹងអំពើលាមក) និងសេចក្ដីល្អ (គឺសទ្ធាស៊ប់ចិត្ត) ៩១:១-៨ ។"*[190]

[189] ស៊ូរ៉ោះត៍ អាល់-ហ៊ីជ្ជ័រ 15:72 ។

[190] ស៊ូរ៉ោះត៍ អាស្ស-ស្ហាំស៍ 91:1-8 ។

ហ្វាឌីស្ស្រនោះបញ្ជាក់ថានេះជាមតិពិត ។

ស្ថានភាពសង្គមទូទៅនាដើមសម័យអ៊ីស្លាម និងសម្ដីទាំងឡាយរបស់ព្រះសាស្ដាﷺអល់ឡោះហ្វ៍عزّوجلّ ទាក់ទងនឹងការតែងតាំងព្រះអគ្គមហាប្រមុខរបស់បណ្ដាអ្នកមានសទ្ធាជ្រះថ្លា (អ៊ាលីصلوات الله عليه والسلام) ជាអ្នកស្នងព្រះអង្គﷺនោះ បង្ហាញឲ្យឃើញច្បាស់ថារឿងខ៊ិលីហ្វាស្ហ ជារឿងដែលត្រូវដោះស្រាយដោយការតែងតាំងច្បាស់លាស់ដោយអល់ឡោះហ្វ៍عزّوجلّ ហើយជារឿងសំខាន់ដែលចៀសមិនរួច ។

# សំណួរ ២៤ - តើស្បថផ្សេងពីចំពោះព្រះនាមអល់ឡោះហ្វ៍عزّوجلّជាអំពើហ៊ុនហយ (ស្ហ៊ីរិក) ទេ ?

## ចម្លើយ

ន័យរបស់ពាក្យ *"តៅហ៊ីដ្ធ"* (លទ្ធិឯកទិទេពនិយម) និង ពាក្យ *"ស្ហ៊ីរិក"* (ពហុទេពនិយម) ត្រូវតែសមស្របនឹងគួរអាននិងស៊ុនណាស្ហ់របស់ព្រះសាស្ដាﷺ ពីព្រោះព្រះមហាគម្ពីរគួរអាននិងទង្វើរបស់ព្រះសាស្ដាﷺ អល់ឡោះហ្វ៍عزّوجلّជាគំរូដែលមានសុពលភាពជាងគេ ដើម្បីវែកញែកឲ្យឃើញខុសដាច់ឡែកពីត្រូវ តៅហ៊ីដ្ធដាច់ឡែកពីស្ហ៊ីរិក ។

ដូច្នេះ ត្រូវតែវិភាគគ្រប់មតិនិងទង្វើដោយឥតលំអៀងនិងឥតស្មារតីជ្រុលនិយមតាមចម្រោះព្រះបន្ទូលនិងទង្វើរបស់ព្រះសាស្ដាﷺ ។

នេះគឺភ័ស្ដុតាងមាំ ដែលបញ្ជាក់ថាគួរអាននិងស៊ុនណាស្ហ់អនុញ្ញាតឲ្យស្បថផ្សេងពីចំពោះអល់ឡោះហ្វ៍عزّوجلّបាន គឺ៖



នេះគឺភ័ស្ដុតាងសមហេតុផលរបស់លោក គឺ៖

«لما في طباع العقلاء، من التّسليم لزعيم يمنعهم من التّظالم، ويفصل بينهم في التّنازع والتّخاصم، ولولا الْولاة لكانُوا فوضى مهملين وهمجاً مضاعين»

*"លក្ខណៈសម្បត្តិរបស់អ្នកមានប្រាជ្ញាគឺតាមអ្នកដឹកនាំដែលការពារខ្លួនឲ្យចាកផុតពីអយុត្តិធម៌ និងពីការបែកបាក់គ្នាពេលមានការខ្វែងគំនិតគ្នា ។ បើពុំមានអ្នកដឹកនាំទេ មនុស្សនឹងរស់នៅក្នុងភាពចលាចលដូចមនុស្សសាហាវព្រៃផ្សៃ ។"*[175]

នេះគឺភ័ស្ដុតាងរបស់លោក ផ្នែកសាសនា គឺ៖

«ولكن جاء الشّرع بتفويض الامور إلى وليّه في الدّين. قال الله عزّوجلّ: "يا أَيُّهَا الَّذِيْنَ آمَنُوا أَطِيْعُوا اللهَ وَأَطِيْعُوا الرّسُولَ وأولي الْأَمْرِ مِنْكُمْ" ففرض علينا طاعة أولي الامْر فينا وهم الائمة المتامرون علينا»

*"រីឯច្បាប់ផ្នែកសាសនាវិញ គឺប្រគល់អំណាចឲ្យទៅអាជ្ញាធរសាសនាម្នាក់ (គឺអ៉ាលី) ។ អល់ឡោះហ្វ៍عزّوجلّមានព្រះបន្ទូលថា៖ "បណ្ដាអ្នកមានសទ្ធាអើយ ចូរស្ដាប់បង្គាប់អល់ឡោះហ្វ៍ ចូរស្ដាប់បង្គាប់សាស្ដានិងបណ្ដាអាជ្ញាធរក្នុងចំណោមពួកអ្នក (គឺអ្នកកាន់អំណាចស្របតាមច្បាប់អល់ឡោះហ្វ៍) ។"*[176] *ដូច្នេះអល់ឡោះហ្វ៍عزّوجلّដាក់បញ្ញត្តិមកលើយើងឲ្យគោរពបណ្ដាអ្នកកាន់អំណាចដែលជាអ្នកដឹកនាំនិងជាអ្នកកាន់ក្ដាប់របស់យើង ។"*[177]

---

[175] សូមមើលសៀវភៅរបស់លោក អាប៊ូ អាល់-ហ្វាសាន់ អាល់-ម៉ាវ៉ារឌី ( أبو الحسن الماوردي) *អាល់-អាស្ហ្កាម អាស់-ស៊ុលត្វន់នីយ៉ាស្ហ់ (الأحكام السلطانية)* (បោះពុម្ពនៅប្រទេសអេស៊ីបត៍) "បាប់ អាល់-អៅវ៉ាល់" ទំព័រ ៥ ។

[176] ស៊ូរ៉ោះត្ហ៍ អាន់-នីសាអ៍ 4:59 ។

[177] សូមមើលសៀវភៅរបស់លោក អាប៊ូ អាល់-ហ្វាសាន់ អាល់-ម៉ាវ៉ារឌី (أبو الحسن الماوردي) *អាល់-អាស្ហ្កាម អាស់-ស៊ុលត្វន់នីយ៉ាស្ហ់ (الأحكام السلطانية)* (បោះពុម្ពនៅប្រទេសអេស៊ីបត៍) "បាប់ អាល់-អៅវ៉ាល់" ទំព័រ ៥ ។

ស្ហៃខ៍ អាស្ង-ស្ហ៍ឌុក បានរាយការណ៍តមកពីលោក ហ្វាដ្ល៍ អ៊ីបនូ ស្ហាស្ទាន (فضل بن شاذان) នូវហាឌីស្ហរបស់ អ៊ីមុាំ អាលី អ៊ីបនូ មូសា អារ-រីដ្ហ៍ صلوات الله عليه والسلام ។ នៅក្នុងហាឌីស្ហវែងនេះ អ៊ីមុាំមានវចនៈអំពីការចាំបាច់បង្កើតរដ្ឋបាលថា៖

«انّا لانجد فرقةً من الفرق ولا ملّة من الملل بقوا وعاشوا إلا بقيّم ورئيس لِما لابُدّ لهم منه من أمر الدّين والدّنيا فلم يجز في حكمة الحكيم أن يترك الخلق لِما يعلم أنّه لابدّ لهم منه ولاقِوام لهم إلا بِهِ فيقاتلون به عدوَّهم ويقسمون به فيئهم ويقيمون بِهِ جمعتهم وجماعتهم ويمنع ظالمهم من مظلومهم»

*"យើងមិនឃើញមានក្រុមឬសហាគមន៍ណាមួយអាចគង់នៅបាន ដោយគ្មានអ្នកកាន់ក្តាប់និងអ្នកដឹកនាំទេ ព្រោះពួកគេត្រូវការអ្នកកាន់ក្តាប់ម្នាក់ដើម្បីចាត់ចែងរឿងសាសនានិងរឿងលោកនេះ ។ ហេតុដូច្នេះ ព្រះម្ចាស់ដ៏មានព្រះញាណបារមីមិនអន់ប្រាជ្ញាដល់ថ្នាក់ទុកឲ្យមនុស្សគ្មានមេដឹកនាំនោះទេ ព្រោះព្រះអង្គ عزّ وجلّ ទ្រង់ញាណថាមនុស្សត្រូវការមេដឹកនាំនោះ ហើយមនុស្សមិនអាចគង់នៅដោយគ្មានអ្នកកាន់ក្តាប់បានទេ នៅក្រោមបញ្ជាអ្នកកាន់ក្តាប់នោះ ពួកគេវាយសត្រូវ បែងចែកទ្រព្យនិងរបស់បានពីឈ្លើយសឹក ស្ហ៍ឡាត្ហ៍ថ្ងៃសុក្រ និងស្ហ៍ឡាត្ហ៍រួមឯទៀត ហើយអ្នកកាន់ក្តាប់នោះ មិនបណ្តោយឲ្យបណ្តាអ្នករងការគាបសង្កត់នៅក្នុងដៃអ្នកគាបសង្កត់គេឡើយ ។"*[178]

យើងមិនអាចបង្ហាញជូនសេចក្តីអធិប្បាយហាឌីស្ហ និងការវិភាគនានារបស់អស់លោកអ្នកនីតិសាស្ត្រអ៊ីស្លាមទាំងអស់ នៅក្នុងសៀវភៅតូចនេះបានទេ ។ យើងត្រូវការសៀវភៅច្រើនក្បាលសម្រាប់រឿងនេះ ។

---

[178] សូមមើលសៀវភៅ *អ៊ីលឡាល់ អាស្ង-ស្ហារ៉អ៊ីអ៍ (عِلَلُ الشَّرائِع)* ជុំទី ៩ បាប់ ១៨២ ទំព័រ ២៥៣ ។



ស្ថានការណ៍សង្គមបញ្ជាក់ថា ព្រះសាស្តា صلى الله عليه وآله وسلم ត្រូវតែតែងតាំងអ្នកដឹកនាំដើម្បីទប់ស្កាត់ការប្រទូសរ៉ាយ ពេលអត់ពីព្រះអង្គ صلى الله عليه وآله وسلم និងដើម្បីធានាឯកភាពអ៊ីស្លាមដោយបង្កើតខ្សែបន្ទាត់ការពារមាំនិងខ្លាំងក្លា ។ ព្រះអង្គ صلى الله عليه وآله وسلم ត្រូវតែទប់ស្កាត់ ពេលព្រះអង្គ صلى الله عليه وآله وسلم ចាកលោកនេះទៅ កុំឲ្យក្រុមនីមួយៗនឹងថា៖ "អ្នកដឹកនាំត្រូវតែជាមនុស្សក្រុមយើង ។" រឿងនេះមិនអាចធ្វើទៅបានទេបើគ្មានការតែងតាំងនិងការជ្រើសរើសឈ្មោះអ្នកដឹកនាំនោះ ។

ការពិចារណាអំពីស្ថានភាពសង្គមបង្ហាញថា អ្នកដឹកនាំអ៊ុមម៉ាត្ហ៍ពេលអត់ពីព្រះសាស្តា صلى الله عليه وآله وسلم ទៅនោះ នៅលើការតែងតាំងច្បាស់លាស់ ។

## ភ័ស្តុតាងបញ្ជាក់សម្តីព្រះសាស្តា صلى الله عليه وآله وسلم អល់ឡោះហ្វ៍ عزّ وجلّ

ដោយផ្អែកលើស្ថានភាពសង្គមនិងច្រើនចំណុចទៀត ព្រះសាស្តា صلى الله عليه وآله وسلم បានអធិប្បាយរឿងស្នងព្រះអង្គ صلى الله عليه وآله وسلم ចាប់តាំងពីព្រះអង្គ صلى الله عليه وآله وسلم ចាប់ផ្តើមបំពេញបេសកកម្មសាស្តាម្ល៉េះ រហូតដល់អវសានជីវិតព្រះអង្គ صلى الله عليه وآله وسلم ។ ព្រះអង្គ صلى الله عليه وآله وسلم បានតែងតាំងអ្នកស្នងព្រះអង្គ صلى الله عليه وآله وسلم ពីដើមបេសសកម្ម នៅក្នុងឱកាសបើកឲ្យសាច់ញាតិព្រះអង្គ صلى الله عليه وآله وسلم ដឹងថាព្រះអង្គ صلى الله عليه وآله وسلم ជាព្រះសាស្តា صلى الله عليه وآله وسلم នៅក្នុងឱកាសចុងក្រោយនៃជីវិតព្រះអង្គ صلى الله عليه وآله وسلم ពេលត្រឡប់មកពីបំពេញពិធីហាជ្ជលាគ្នាវិញ នៅឯ "ក៏ដ្បៀរ ឃុម" និងនៅក្នុងដំណាក់ការផ្សេងនៃជីវិតព្រះអង្គ صلى الله عليه وآله وسلم ។

អត្ថបទបីដែលយើងបានបង្ហាញដើម្បីឆ្លើយតបសំណួរ "ហេតុអ្វីចាត់ទុកអាលី អ៊ីបនូ អាប៊ី ត្ហ៍លិប صلوات الله عليه والسلام ជាវ៉ាស្ហ៊ី (អ្នកធ្វើតាមមរតកសាសន៍) និងជាអ្នកស្នងព្រះសាស្តា صلى الله عليه وآله وسلم ?" ដោយមានបណ្តាញថ្លែងព័ត៌មានបន្តក្នុងសៀវភៅអស់លោកអ្នកប្រាជ្ញមុស្លីម និងអស់លោកអ្នករាយការណ៍

អង្គﷺបើព្រះអង្គﷺប្រឆាំង ។

ទោះបីឃុសរូ ប៉ារវីស៊ុ ស្តេចប៉ែរ្ស៊ីបានស្លាប់ក្នុងសម័យព្រះសាស្តាﷺក៏ដោយ រឿងឯករាជរបស់ទឹកដីយេមេន ដែលនៅក្រោមអាណានិគមប៉ែរ្ស៊ីតាំងពីយូរមកហើយនោះ នៅតែមិនទាន់ចប់ដាច់ស្រេចនៅឡើយសម្រាប់ស្តេចប៉ែរ្ស៊ីត្រកូលសាស់សានីដែល ព្រោះតែក្រអឺតក្រទម ប្រកាន់ឫកនោះ មិនអាចអត់ទ្រាំឲ្យមានមហាអំណាចបែបនេះបានឡើយ ។

សត្រូវទីបីក្នុងចំណោមគ្រោះថ្នាក់ត្រីកោណនោះ គឺពួកលាក់ពុតត្បុត (ពួកម៉ូណាហ្វ៊ិគួន) ដែលជ្រាបចូលក្នុង ចំណោមមុស្លីមដើម្បីសាបព្រោះជម្លោះ និងប៉ងសម្លាប់ព្រះសាស្តាﷺដែលធ្វើដំណើរពីតាប៊ុក ទៅម៉ាឌីណាស់ ពួកនេះសង្ឃឹមថាបើចលនាអ៊ីស្លាមបានដល់ទីបញ្ចប់ ទាំងអស់គ្នានឹងផុតភ័យ ។[188]

ពួកលាក់ពុតត្បុតមានគ្រោះថ្នាក់ណាស់ ដល់គួរអានចែងអំពីរឿងនេះនៅក្នុងស៊ូរ៉ោះត៍ច្រើន ដូចជាស៊ូរ៉ោះត៍ អាលី អ៊ីមរ៉ន (៣), អាន់-នីសាអ៍ (៤), អាល់-ម៉ាអ៊ីដាស់ (៥), អាល់-អាន់ហ្វាល (៨), អាត់-តៅបាស់ (៩), អាល់-អ៊ាន់កាប៊ូត (២៩), អាល់-អាស់ស្អាប់ (៣៣), មូហាំម៉ាដ់ (៤៧), អាល់-ហ្វាត់ហ៍ (៤៨), អាល់-ហាឌីដ់ (៥៧), អាល់-មូយ៉ាដាឡាស់ (៥៨), អាល់-ហាស្ស៍រ (៥៩), អាល់-មូណាហ្វ៊ិគួន (៦៣) ជាដើម ។

មានសត្រូវគ្រោះថ្នាក់បែបនេះ តើសមហេតុផលទេដែលព្រះសាស្តាﷺមិនអើពើអំពីការតែងតាំងអ្នកដឹកនាំសាសនា និងនយោបាយសម្រាប់សហគមន៍ខ្មីនេះ ?

[188] មើលស៊ូរ៉ោះត៍ អាត់-ទូរ 52:30 ។



ការវិភាគនីតិសាស្ត្រអ៊ីស្លាម (គឺហ្វីកោះហ៍អ៊ីស្លាម) បង្ហាញច្បាស់ថាច្បាប់សាសនាដ៏ច្រើន មិនអាចដាក់ឲ្យអនុវត្តិបានឡើយបើពុំមានរដ្ឋបាលខ្លាំងទេនោះ ។

អ៊ីស្លាមឲ្យយើងធ្វើយ៉ីហាដ់ ការពារជនរងការសង្កត់សង្កិនទល់នឹងជនកំណាច ឲ្យយើងគោរពក្របខ័ណ្ឌ (ហ៊្វូឌូដ حدود) និងវិន័យសាសនា (តាគ្ស៊ីរ៉ត់) ឲ្យណែនាំឲ្យធ្វើល្អនិងឲ្យហាមធ្វើអាក្រក់នៅក្នុងក្របខ័ណ្ឌទូទៅ ឲ្យមានប្រព័ន្ធហិរញ្ញវត្ថុមានរបៀប ឲ្យការពារឯកភាពសង្គមអ៊ីស្លាម ។

ច្បាស់ណាស់ថាគោលដៅខាងលើនេះមិនអាចសម្រេចបានទេ បើពុំមានប្រព័ន្ធខ្លាំងក្លា និងរដ្ឋបាលច្បាស់លាស់ទេនោះ ព្រោះការអភិរក្សព្រះសន្តសាសនានិងការការពារច្បាប់អ៊ីស្លាមទាមទារឲ្យមានកម្លាំងទ័ព ដែលមានរចនាសម្ព័ន្ធត្រឹមត្រូវ ។ ការបង្កើតកម្លាំងទ័ពដ៏ខ្លាំងក្លាបែបនេះ តម្រូវឲ្យមានរដ្ឋបាលរឹងមាំដែលផ្អែកលើខ្លឹមសារអ៊ីស្លាម ។

ដូចគ្នាដែរ គោរពក្របខ័ណ្ឌ (ហ៊្វូឌូដ حدود) និងវិន័យសាសនា (តាគ្ស៊ីរ៉ត់) ដើម្បីបំពេញកាតព្វកិច្ចតាមបញ្ញត្តិសាសនា ដើម្បីទប់ស្កាត់អំពើអាក្រក់ និងការរំលោភសិទ្ធិជនរងការសង្កត់សង្កិននោះ មិនអាចធ្វើទៅបានទេបើពុំមានការរៀបសម្រួល ពុំមានប្រព័ន្ធនិងការរៀបចំរឹងមាំទេនោះ ។ បើពុំមានប្រព័ន្ធឬការរៀបចំបែបនេះទេ ទង្វើទាំងនេះនឹងបណ្តាលឲ្យមានចលាចលនិងការជ្រួលច្របល់ ។

ភ័ស្តុតាងស្តីអំពីការចាំបាច់ត្រូវមានរដ្ឋបាល ក្នុងសាសនាអ៊ីស្លាមនោះមិនមានតែប៉ុណ្ណោះទេ ។ យើងឃើញច្បាស់ហើយថាសាសនាមិនដាច់ឡែកពី

នយោបាយទេ ហើយបង្កើតរដ្ឋបាលអ៊ីស្លាមនៅលើមូលដ្ឋានច្បាប់អ៊ីស្លាមត្រចះត្រចង់នោះជាការចាំបាច់ចៀសវាងមិនបាន ហើយវាជាកាតព្វកិច្ចរបស់មុស្លីមទាំងអស់ក្នុងលោក ។

## សំណួរ ២២ - ហេតុអ្វីស៊ីអ៊ាស់ចាត់ទុកកូនទាំងពីររបស់អ៊ាលី អ៊ីបនូ អាប៊ី ត៏លិប (ហាសាន់និងហ៊ូសៃន៍ عليهم السلام) ជា "កូនរបស់ព្រះសាស្ដា صلى الله عليه وآله وسلم អល់ឡោះហ៍ عز وجل" ?

## ចម្លើយ

ការវិភាគសៀវភៅសម្រាយគួរអាន (តាហ្វ់សៀរ) សៀវភៅប្រវត្តិសាស្ត្រនិងសៀវភៅហាឌីស្ស សឲ្យឃើញថា មិនត្រឹមតែស៊ីអ៊ាស់ទេដែលទទួលស្គាល់សម្ដីនេះ តែអស់លោកអ្នកស្រាវជ្រាវមុស្លីមទាំងអស់ គ្រប់ម៉ាស្ហាប់ទទួលស្គាល់សម្ដីនេះ ។

យើងនឹងពិនិត្យភ័ស្ដុតាងនៅក្នុងព្រះគម្ពីរគួរអាន ក្នុងហាឌីស្សនិងក្នុងសំណេររបស់អស់លោកអ្នកស្រាយគួរអានល្បីៗ ។
ព្រះគម្ពីរគួរអានចាត់ទុកកូនចៅរបស់មនុស្សម្នាក់ជាកូនៗ របស់អ្នកនោះ ហើយហៅបណ្ដាកូនៗដែលកើតពីកូនៗរបស់អ្នកនោះថា "កូនរបស់អ្នកនោះ" ។

នៅក្នុងគួរអាននិងស៊ុនណាស់ មានភ័ស្ដុតាងសន្ទឹកសន្ធាប់ទាក់ទងនឹងរឿងនេះ គឺ៖

១. ព្រះគម្ពីរគួរអាន នៅក្នុងអាយ៉ាស់ខាងក្រោមនេះ ចាត់ទុកព្រះសាស្ដា



អាណានិគមប៊ីសង់ទីនជាប៉ែកគ្រោះថ្នាក់មួយ នៃគ្រោះថ្នាក់ត្រីកោណនោះ ។ មហាអំណាចនេះដែលនៅឯប៉ែកខាងជើងឧបទ្វីបអារ៉ាប់នោះធ្វើឲ្យព្រះសាស្ដា صلى الله عليه وآله وسلم បារម្ភរហូតដល់ពេលចុងក្រោយនៃព្រះជន្មព្រះអង្គ صلى الله عليه وآله وسلم ។

ការប្រឈមមុខគ្នារវាងទ័ពមុស្លីម និងទ័ពប៊ីសង់ទីនកាន់សាសនាគ្រិស្ដនោះបានប្រព្រឹត្តទៅក្នុងឆ្នាំទី 8 សករាជហ៊ិជ្រ៉ះត៏នៅឯប៉ាលេសទីន ។ ការប្រយុទ្ធគ្នានេះបានចប់ដោយបរាជ័យរបស់ទ័ពមុស្លីម ឧត្ដមសេនីយ៍បីរូបបានទទួលមរណៈភាពគឺ៖ យ៉ាក់ហ្វារ អ៊ីបនូ អាប៊ី ត៏លិប អាត់-ត៏យ៉យ៉ារ (جعفر بن أبي طالب الطيار), ស៊ៃដ្ន៍ អ៊ីបនូ ហារីស្សាស់ (زيد بن حارثة) និងអ៊ាប់ឌុលឡោះហ៍ អ៊ីបនូ រ៉ាវ៉ាហាស់ (عبد الله بن رواحة) ។

ការដកថយរបស់ទ័ពមុស្លីម ធ្វើឲ្យទ័ពប៊ីសង់ទីនមានកម្លាំងចិត្តឡើង ហើយគិតថាថ្ងៃណាមួយនឹងវាយយករាជធានីអ៊ីស្លាម ។ អាស្រ័យហេតុនេះ ព្រះសាស្ដា صلى الله عليه وآله وسلم បានលើកទ័ពធំទៅកាន់ទឹកដីស្ហាំ (ស៊ីរី) ដើម្បីបញ្ជាគ្រប់ចលនាទ័ពដោយព្រះអង្គ صلى الله عليه وآله وسلم ផ្ទាល់ ។ នៅក្នុងការធ្វើដំណើរដ៏លំបាកនេះ ទ័ពមុស្លីមមានកិត្យានុភាពនិងឥទ្ធិពលផ្នែកនយោបាយឡើងវិញ ។

ជ័យជំនះនេះមិនធ្វើឲ្យព្រះសាស្ដា صلى الله عليه وآله وسلم កក់ក្ដៅទេ ពីរបីថ្ងៃមុនព្រះអង្គ صلى الله عليه وآله وسلم មានជម្ងឺ ព្រះអង្គ صلى الله عليه وآله وسلم បានប្រគល់បញ្ជាការទ័ពឲ្យទៅ អ៊ូសាម៉ាស់ អ៊ីបនូ ស៊ៃដ្ន៍ ដើម្បីទៅកាន់តំបន់ស្ហាំ (ឆ្នេរស៊ីរី) ។

សត្រូវទីពីរគឺស្ដេចប៉ែរ្ស៍ឬអ៊ីរ៉ង់ ។ ព្រះចៅអធិរាជឃុស្រូនៃអាណាចក្រប៉ែរ្ស៍ក្រោធ បានហែកសារព្រះសាស្ដា صلى الله عليه وآله وسلم ចោល បានបញ្ជូនឯកអគ្គរាជទូតព្រះអង្គ صلى الله عليه وآله وسلم មកវិញដោយប្រមាថ ។ ឃុស្រូបានសរសេរសំបុត្រទៅអភិបាលប្រទេសយេមេនដោយដាក់បញ្ជាឲ្យចាប់ខ្លួនព្រះសាស្ដា صلى الله عليه وآله وسلم ឲ្យសម្លាប់ព្រះ

យកតាមព្រះរាជបញ្ជារបស់អល់ឡោះហ្ទ៍ﷻដែលបានដាក់មកហើយដែលព្រះសាស្តាﷺបានថែង ឬក៏ត្រូវយកតាមការបោះឆ្នោតជ្រើសរើសនោះ យើងមានមតិពីរ ។

ស៊ូន្នីអ៊ុស្លំជឿថាភារកិច្ចដឹកនាំអ៊ុមម៉ាត់ គឺនៅលើព្រះបញ្ជារបស់អល់ឡោះហ្ទ៍ﷻដែលបានដាក់មក អ្នកស្នងព្រះសាស្តាﷺត្រូវតែងតាំងដោយអល់ឡោះហ្ទ៍ﷻ រីឯអាស្ទ់លុល-ស៊ុនណាស្ទ់ជឿថាភារកិច្ចនេះនៅលើការបោះឆ្នោតជ្រើសរើស ហើយអ៊ុមម៉ាត់ត្រូវជ្រើសរើសបុគ្គលម្នាក់ដើម្បីដឹកនាំកិច្ចការរដ្ឋ ។

អស់លោកអ្នកប្រាជ្ញស៊ីអ៊ុស្ទំបានបង្ហាញមូលហេតុ និងភ័ស្តុតាងដ៏ច្រើននៅក្នុងសៀវភៅអស់លោក ដែលស្តីអំពីការចាំបាច់ត្រូវតែមានការតែងតាំងអ្នកកាន់ខ៊ុលីហ្វាស្ទ់ដោយអល់ឡោះហ្ទ៍ﷻ ។ តែយើងបង្ហាញជូនត្រង់នេះនូវការវិភាគស្ថានកាណ៍អ្នកកាន់ក្តាប់សម័យព្រះសាស្តា ដើម្បីជាសំអាងថាមតិស៊ីអ៊ុស្ទំជាមតិត្រូវ ។

ការវិភាគនយោបាយក្រៅប្រទេស និងក្នុងប្រទេសក្នុងសម័យព្រះសាស្តាﷺបញ្ជាក់ថា អ្នកស្នងព្រះសាស្តាﷺត្រូវតែងតាំងដោយអល់ឡោះហ្ទ៍ﷻ តាមរយៈព្រះសាស្តាﷺផ្ទាល់ ព្រោះសហគមន៍អ៊ីស្លាមប្រឈមនឹងគ្រោះថ្នាក់បីជាដរាប (អាណានិគមប៊ីសង់ទីន, អាណានិគមប៉ែរ្ស៊ីឬអ៊ីរ៉ង់ និងពួកលាក់ពុត(មូណាហ្វិគូន)) ។

ដោយបានតែងតាំងអ្នកដឹកនាំនយោបាយ ព្រះសាស្តាﷺបានទទួលជោគជ័យក្នុងការបង្រួបបង្រួមអ៊ុមម៉ាត់ ប្រឆាំងសត្រូវក្រៅនិងទប់ស្កាត់មិនឲ្យសត្រូវជ្រៀតចូលនិងមានប្រៀបលើបានទេ ដែលអាចធ្វើឲ្យមានជម្លោះផ្ទៃក្នុង ។



អ៊ីសាعليه السلامនៅក្នុងចំណោម "កូនៗ" របស់ អ៊ីបរ៉ហ៊ីម អាល់-ខ៊ុលីលعليه السلام (អ៊ីបរ៉ហ៊ីមមិត្តរបស់អល់ឡោះហ្ទ៍ﷻ) - ទោះបី អ៊ីសាعليه السلام ជាព្រះរាជបុត្ររបស់ម៉ារយ៉ាំسلام الله عليهاក៏ដោយ - ហើយព្រះអង្គعليه السلامតភ្ជាប់ជាមួយអ៊ីបរ៉ហ៊ីមعليه السلام តាមរយៈព្រះមាតាព្រះអង្គعليه السلام៖

وَوَهَبْنَا لَهُۥٓ إِسْحَـٰقَ وَيَعْقُوبَ ۚ كُلًّا هَدَيْنَا ۚ وَنُوحًا هَدَيْنَا مِن قَبْلُ ۖ وَمِن ذُرِّيَّتِهِۦ دَاوُۥدَ وَسُلَيْمَـٰنَ وَأَيُّوبَ وَيُوسُفَ وَمُوسَىٰ وَهَـٰرُونَ ۚ وَكَذَٰلِكَ نَجْزِى ٱلْمُحْسِنِينَ ﴿٨٤﴾ وَزَكَرِيَّا وَيَحْيَىٰ وَعِيسَىٰ

*"យើងបានប្រទានអ៊ិសហ្វាក់និងយ៉ាក់គូបឲ្យគេ យើងបានដឹកនាំគេទាំងអស់គ្នា ។ កាលពីមុនយើងបានដឹកនាំនុះហ្វ៍ ហើយក្នុងចំណោមកូនចៅរបស់គេ [យើងបានដឹកនាំ]ដាវុដ ស៊ូឡៃម៉ាន អៃយូប យូស៊ុហ្វ មូសា និងហារូន ។ ដូច្នេះឯងដែលយើងតបស្នងបណ្តាអ្នកប្រព្រឹត្តិល្អ (គឺកសាងខ្លួនឲ្យកាន់តែសុក្រឹតឡើង ពួកគេមាន ចិត្តទូលំទូលាយនិងផ្តល់គុណប្រយោជន៍ដល់សង្គមមនុស្ស ដើម្បីអល់ឡោះហ្ទ៍) ។ ស្ការការីយ៉ា យ៉ាហ្ស៊ុយ៉ា អ៊ីសា... (៦:៨៤:៨៥) ។"*[179]

អស់លោកអ្នកប្រាជ្ញមុស្លីម ចាត់ទុកអាយ៉ាស្ទ់នេះជាភ័ស្តុតាងច្បាស់ក្រឡែតដែលបញ្ជាក់ថា អ៊ីម៉ាំ អាល់-ហ្វាសាន់صلوات الله عليه والسلام និងអ៊ីម៉ាំ អាល់-ហ៊ូសៃន៍صلوات الله عليه والسلامជា "កូនៗ" របស់ព្រះសាស្តាﷺនិងជាបណ្តាកូនចៅរបស់ព្រះអង្គﷺដែរ ។ ឧទាហរណ៍ លោក យ៉ាឡាល់ អាដ្ឌ់-ឌីន អាស់-ស៊ូយូទី (جلال الدين السيوطي) រាយការណ៍ថា៖

«أرسل الحجاج إلى يحيى بن يعمر فقال: بلغني انَّك تزعم أنّ الحسن والحسين من ذرّية النبي (صلَّى الله عليه و آله وسلّم) تجده في كتاب الله وقد قرأته من أوَّله إلى

[179] ស៊ូរ៉ោះត៍ អាល់-អាន់អ៊ាំ 6:84-85 ។

آخره فلم أجده. قال: ألسْت تقرأ سورة الانعام: "وَمِنْ ذُرِّيَّتِهِ داوُودَ وَسُلَيْمانَ" حَتّى بَلَغَ "وَيَحْيى وَعِيْسى"؟ قال: بَلى. قال: ألَيْسَ عِيْسى من ذرية ابراهيم وليس له أبٌ؟ قال: صدقت »

*"ថ្ងៃមួយហាច្ចាច្ច (អ៊ីបនូ យូស៊ុហ្វ) បានឲ្យគេទៅហៅ យ៉ាស្ញ៉ា អ៊ីបនូ យ៉ាក់ម៉ារ មកជួប ។ ហាច្ចាច្ចបានប្រាប់លោកថា៖ "គេបានប្រាប់ខ្ញុំថាលោកបានថាអាល់-ហាសាន់និងអាល់-ហ៊ូសៃន៍عليهم السلامជាកូន និងជាបណ្ដាកូនចៅរបស់ព្រះសាស្ដាصلى الله عليه وآله وسلم ហើយថាលោកឃើញមានភ័ស្ដុតាងរឿងនេះនៅក្នុងគម្ពីរអល់ឡោះហ៍عز وجل តែខ្ញុំសូត្រគួរអានពីដើមដល់ចប់ មិនឃើញមានអ្វីដូចនេះទេ ។" យ៉ាស្ញ៉ា អ៊ីបនូ យ៉ាក់ម៉ារតបថា៖ "លោកមិនបានសូត្រស៊ូរ៉ោះត៍ អាល់-អាន់អ៊ាំ ទេដែលចែងថា៖ "ហើយក្នុងចំណោមកូនចៅរបស់គេ [យើងបានដឹកនាំ]ដាវូដ ស៊ូឡៃម៉ាន..." លុះដល់ "យ៉ាស្ញ៉ា អ៊ីសា..." ?" ហាច្ចាច្ចបានថា៖ "ខ្ញុំបានសូត្រ ។" យ៉ាស្ញ៉ាបានថា៖ "នៅក្នុងសម្ដីគួរអាននេះ អ៊ីសាមិនត្រូវចាត់ទុកជាកូនចៅរបស់អ៊ីបរ៉ហ៊ីមទេ ទោះបីអ៊ីបរ៉ហ៊ីមមិនមែនជាបិតារបស់ព្រះអង្គក៏ដោយនោះ [អ៊ីសាជាប់សាច់សាលោហិតជាមួយអ៊ីបរ៉ហ៊ីមតាមរយៈមាតាព្រះអង្គ] ? ហាច្ចាច្ចបានថា៖ "លោកនិយាយត្រូវ ។"*[180]

អាយ៉ាស្ញខាងលើនេះនិងសម្ដីរបស់អស់លោកអ្នកស្រាយគួរអាន បង្ហាញឲ្យឃើញច្បាស់ថា មិនត្រឹមតែស៊ីអ៊ាស្ញទេ តែអស់លោកអ្នកប្រាជ្ញមុស្លីមទាំងអស់ចាត់ទុក អាល់-ហាសាន់និងអាល់-ហ៊ូសៃន៍عليهم السلامជាព្រះរាជបុត្រនិងជាបណ្ដាកូនចៅរបស់ព្រះសាស្ដាصلى الله عليه وآله وسلم ។

២. អាយ៉ាស្ញគួរអានមួយដែលបញ្ជាក់ថានេះជាការពិតនោះគឺ "អាយ៉ាស្ញ

[180] សូមមើលសៀវភៅ *អាដ្ញ-ឌូរ អាល់-ម៉ាន់ស៊ូរ* (الدر المنثور) (បោះពុម្ពនៅបៃរូត) ជុំទី ៣ ទំព័រ ២៨ មើលសេចក្ដីអធិប្បាយ ស៊ូរ៉ោះត៍ អាល់-អាន់អ៊ាំ ។



*ស្រឡាញ់ខ្ញុំ ។"*[186]

ខ. ពេលចង្អុលអ៊ីម៉ាំអាល់-ហាសាន់និងអ៊ីម៉ាំអាល់-ហ៊ូសៃន៍عليهم السلام ព្រះសាស្ដាصلى الله عليه وآله وسلمមានព្រះវចនៈដែរថា៖

«إنّ ابنيّ هذينَ ريحانتاى من الدّنيا»

*"កូនខ្ញុំទាំងពីរនាក់នេះ ជាជីវក្រអូបមួយបាច់របស់ខ្ញុំនៅក្នុងលោកនេះ ។"*[187]

## សំណួរ ២៣ - ហេតុអ្វីស៊ីអ៊ាស្ញជឿថាខ៍លីហ្វាស្ញជាមុខតំណែងត្រូវតែងតាំងដោយអល់ឡោះហ៍عز وجل ?

## ចម្លើយ

ច្បាស់ណាស់ថាសាសនាអ៊ីស្លាមជាសាសនាសាកលនិងអនន្ត ។ ដរាបណាព្រះសាស្ដាصلى الله عليه وآله وسلمនៅមានព្រះជន្ម ដរាបនោះព្រះអង្គصلى الله عليه وآله وسلمជាអ្នកដឹកនាំអ៊ុមម៉ាត្ញ ។ អត់ពីព្រះអង្គصلى الله عليه وآله وسلم ភារកិច្ចនេះធ្លាក់ទៅលើបុគ្គលសក្ដិសមជាងគេក្នុងអ៊ុមម៉ាត្ញ ។

ទាក់ទងនឹងរឿងភារកិច្ចនេះ ពេលអត់ពីព្រះសាស្ដាصلى الله عليه وآله وسلمនោះ ដែលថាត្រូវ

[186] សូមមើលសៀវភៅរបស់លោក អ៊ីបនូ អ៊ាសាកៀរ (ابن عساكر) *តារិក្ញ ម៉ាឌីណាស្ញ ដាមីស្គក៍ (تاريخ مدينة دمشق)* (បោះពុម្ពនៅបៃរូត ឆ្នាំ ១៤០០ ស.ហ) ទំព័រ ៥៩ ហាឌីស្ញ ១០៦ ។

[187] សូមមើលសៀវភៅរបស់លោក អ៊ីបនូ អ៊ាសាកៀរ (ابن عساكر) *តារិក្ញ ម៉ាឌីណាស្ញ ដាមីស្គក៍ (تاريخ مدينة دمشق)* (បោះពុម្ពនៅបៃរូត ឆ្នាំ ១៤០០ ស.ហ) ទំព័រ ៦២ ហាឌីស្ញ ១១២ ។

*អាល់-ហ៊្សាសាន់និងអាល់-ហ៊្សូសៃន៍عليهم السلام ។"*[184]

គ. លោក អាប៊ូ អ៊្ពុប់ឌុលឡោះហ៍ អាល់-គួរទ្វូប៊ី (ابو عبد الله القرطبي) មានប្រសាសន៍នៅក្នុងសម្រាយគួរអានរបស់លោកថា៖

«[أبناءَنا] دَليلٌ على أنّ ابناء البنات يسمَّون أبناءاً»

*"ពាក្យ "អាប់ណាអ៊ុណា" [أبناءَنا] (កូនៗយើង) នៅក្នុងអាយ៉ាស់គួរអានបង្ហាញថាកូនៗរបស់កូនស្រីក៏ត្រូវចាត់ទុក ជាកូនៗរបស់បុគ្គលនោះដែរ (គឺកូនៗរបស់ជីតា) ។"*[185]

៣. ព្រះវចនៈរបស់ព្រះសាស្ដាصلى الله عليه وآله وسلمអល់ឡោះហ៍عز وجلជាភស្តុតាងត្រចះត្រចង់បំផុតថា អ៊ីម៉ាំអាល់-ហ៊្សាសាន់និងអ៊ីម៉ាំអាល់-ហ៊្សូសៃន៍عليهم السلامជាព្រះរាជបុត្ររបស់ព្រះសាស្ដាصلى الله عليه وآله وسلم ។
ឧទហរណ៍ នេះគឺព្រះវចនៈពីររបស់ព្រះអង្គصلى الله عليه وآله وسلم៖

ក. ព្រះសាស្ដាصلى الله عليه وآله وسلمអល់ឡោះហ៍عز وجلមានព្រះវចនៈអំពីអាល់-ហ៊្សាសាន់ និងអាល់-ហ៊្សូសៃន៍عليهم السلامថា៖

«هذان إبناي من أحبّهما فقد أحبّني»

*"ទាំងពីរនាក់នេះជាកូនរបស់ខ្ញុំ ។ អ្នកណាស្រឡាញ់ពួកគេ អ្នកនោះ*

---

[184] សូមមើល *តាហ្វ់សៀរ ម៉ាហ្វាទិះហ៊្ស៍ អាល់-ក៊ុយ៉ប៍ (التفسير مفاتيح الغيب)* ឬ *តាហ្វ់សៀរ អាល់-កាបៀរ* (التفسير الكبير) (បោះពុម្ពនៅអេស៊ីបត៍ ១៣០៨ ស.ហ) ជុំទី ២ ទំព័រ ៤៨៨ ។

[185] សូមមើល *អាល់-យ៉ាមិអ៊ុ៍ លីអាស៊ហ្កាម អាល់-គួរអាន (الجامع لأحكام القرآن)* (បោះពុម្ពនៅបៃរូត) ជុំទី ៤ ទំព័រ១០៤ ។



មូបាហាឡាស៊ (آية المباهلة)" នៅក្នុង ស៊ូរ៉ោះត៍ អាលី អ៊ីមរ៉ន ។ ខាងក្រោមនេះគឺអាយ៉ាស់ មូបាហាឡាស៊ជាមួយសម្រាយ ។

فَمَنْ حَآجَّكَ فِيهِ مِنۢ بَعْدِ مَا جَآءَكَ مِنَ ٱلْعِلْمِ فَقُلْ تَعَالَوْا۟ نَدْعُ أَبْنَآءَنَا وَأَبْنَآءَكُمْ وَنِسَآءَنَا وَنِسَآءَكُمْ وَأَنفُسَنَا وَأَنفُسَكُمْ ثُمَّ نَبْتَهِلْ فَنَجْعَل لَّعْنَتَ ٱللَّهِ عَلَى ٱلْكَٰذِبِينَ ﴿٦١﴾

*"ដូច្នេះអ្នកណាមួយឈ្លោះប្រកែកជាមួយអ្នកអំពីរឿងនេះ ក្រោយពីព្រះអភិញ្ញាបានមកដល់អ្នកហើយនោះ ចូរអ្នកថា៖ "អស់លោកចូរមកចុះ យើងនឹងហៅកូនប្រុសៗរបស់យើងនិងកូនប្រុសៗ របស់អស់លោក បណ្ដាស្ត្រីរបស់យើងនិងបណ្ដាស្ត្រីរបស់អស់លោក ខ្លួនយើងផ្ទាល់និងខ្លួនអស់លោកផ្ទាល់ រួចហើយយើងបួងសួងយ៉ាងស្មោះអស់ពីចិត្ត សូមឲ្យព្រះបណ្ដាសារបស់អល់ឡោះហ៍ពើបពះលើមុសាវាទី (គឺអ្នកនិយាយកុហក) (៣:៦១) ។"*[181]

អស់លោកអ្នកស្រាយគួរអានមានប្រសាសន៍ថាអាយ៉ាស់ មូបាហាឡាស៊ដ៏ល្បីនេះត្រូវបើកឲ្យដឹងក្នុងពេល ព្រះសាស្ដាصلى الله عليه وآله وسلمជជែកជាមួយពួកមេដឹកនាំសាសនាគ្រិស្តនាតំបន់ណាជ្ជ៉រ៉ន់ដែលចចេសរឹងរូសខ្លាំង ។ ក្រោមព្រះបញ្ជាអល់ឡោះហ៍عز وجل ព្រះសាស្ដាصلى الله عليه وآله وسلمបានចេញទៅខាងក្រៅអមដោយអ៊្ពលី អ៊ីបនូ ត៍លិប, ហ្វាទីម៉ាស៊ អាស់-ស្សាស្ស៉ររ៉អ៊ុ៍, អាល់-ហ៊្សាសាន់និងអាល់-ហ៊្សូសៃន៍عليهم السلام ដើម្បីសូមឲ្យអល់ឡោះហ៍عز وجلទម្លាក់វិនាសមហន្តរាយមកលើបុគ្គលណាដែលខុស ។

លុះពួកមេដឹកនាំសាសនាគ្រិស្តឃើញអាកប្បកិរិយាព្រះសាស្ដាصلى الله عليه وآله وسلم និងព្រះរាជកុលដ្ឋានព្រះអង្គعليهم السلام ពួកគេកើតមានការភ័យខ្លាចនៅក្នុងចិត្ត

---

[181] ស៊ូរ៉ោះត៍ អាលី អ៊ីមរ៉ន 3:61 ។

ហើយសូមឲ្យព្រះសាស្តាﷺអល់ឡោះហ្វ៍ﷻផ្លាស់ប្តូរចិត្តវិញ ក្នុងការសូមឲ្យអល់ឡោះហ្វ៍ﷻទម្លាក់វិនាសមហន្តរាយ និងបណ្តាសាមកលើពួកគេនោះ ។ ព្រះសាស្តាﷺយល់ព្រមចំពោះសំណូមពរពួកគេ ហើយនៅទីបញ្ចប់ពួកគេយល់ព្រមធ្វើកិច្ចសន្យា ។

អស់លោកអ្នកស្រាយគួរអានស៊្មីអ៊ុស្ស៉ និងស៊ុននីមូលមតិគ្នាថាថ្ងៃមូហ្វាឡាស្ស៉ ព្រះអគ្គមហាប្រមុសរបស់អ្នកមានសទ្ធាជ្រះថ្លា (អាមីរុល-មុមីនីន) អ៊ុលីصلوات الله عليه والسلام, ហ្វាទីម៉ាស្ស៉ អាស្ស៉-ស្ស៉ាស្ស៉រ៉អ៊ុ៍سلام الله عليها, អ៊ីមុាំអាល់-ហ្សាសាន់صلوات الله عليه والسلام និងអ៊ីមុាំអាល់-ហ៊្សុសៃន៍صلوات الله عليه والسلامនៅជុំជាមួយព្រះសាស្តាﷺ ។ យើងឃើញច្បាស់ណាស់ថា ព្រះសាស្តាﷺមានព្រះវចនៈថា៖ "អាប់ណាអ៊ុណា (أبنائنا កូនៗយើង)" ព្រះអង្គﷺចង់មានន័យថាអ៊ីមុាំអាល់-ហ្សាសាន់និងអ៊ីមុាំ អាល់-ហ៊្សុសៃន៍عليهم السلام ។ ដូច្នេះ នៅក្នុងអាយ៉ាស្ស៉នេះ អាល់-ហ្សាសាន់និងអាល់-ហ៊្សុសៃន៍عليهم السلامត្រូវចាត់ទុក ជាព្រះរាជបុត្ររបស់ព្រះសាស្តាﷺ ។

បន្ទាប់ពីបានរាយការណ៍ច្រើនហ្សាឌីស្ស៉ស្តីអំពីអាយ៉ាស្ស៉ មូបាហ្វាឡាស្ស៉ អស់លោកអ្នកស្រាយគួរអានទទួលស្គាល់ថា មតិនេះជាមតិត្រឹមត្រូវ ។ នេះគឺឧទាហរណ៍មួយចំនួន៖

ក. លោក យ៉ាឡាល់ អាដ្ឌ-ឌីន អាស់-ស៊្សុយូទី (جلال الدين السيوطي) រាយការណ៍តមកពីលោក ហ្សាគីម, លោក អ៊ីបនូ ម៉ារដ្វាវៃហ្វ៍ (ابن مَرْدَوَيْه) និងលោក ណាអ៊ីម (أبو نعيم) តមកពីលោក យ៉ាបៀរ អ៊ីបនូ អ៊ុប់ឌុលឡោះហ្វ៍ (អាល់-អាន់ស្ស៉រី) ថា៖

«أنفسنا وأنفُسَكم": رسول الله (صلَّى الله عليه و آله وسلّم) وعَلِيّ، وَأبناءنا: الحسن والحسين ونِساءنا: فاطمَة»



*"ពាក្យ "អាន់ហ្វ៊ុសាណា أنفسنا" (ខ្លួនយើងផ្ទាល់) គឺព្រះសាស្តាﷺ អល់ឡោះហ្វ៍ﷻនិងអ៊ុលីصلوات الله عليه والسلام ។ ពាក្យ "អាប់ណាអ៊ុណា (أبنائنا)" (កូនៗយើង) គឺអាល់-ហ្សាសាន់និងអាល់-ហ៊្សុសៃន៍عليهم السلام ។ ពាក្យ "នីសាអ៊ុណា (نسائنا)" (បណ្តាស្ត្រីយើង) គឺហ្វាទីម៉ាស្ស៉ ។"*[182]

ខ. នៅក្នុងសម្រាយគួរអានរបស់លោក លោក ហ្វាក់រី អាដ្ឌ-ឌីន អារ-រ៉ស៊ី (فخرالدين الرازي) បានថ្លែងអាយ៉ាស្ស៉ខាងលើនេះហើយមានប្រសាសន៍ថា៖

«وَاعْلَمْ أنّ هذه الّرواية كالمتّفق على صحتها بين أهل التّفسير والحديث»

*"ចូរដឹងថាហ្សាឌីស្ស៉នេះ អស់លោកអ្នកស្រាយគួរអាននិងអស់លោកអ្នកឯកទេសហ្សាឌីស្ស៉មូលមតិគ្នាអះអាងថាជាហ្សាឌីស្ស៉ពិត ។"*[183]

បន្ទាប់មកលោកបានបន្ថែមថា៖

«المسألة الرّابعة: هذه الآية دالّةٌ على أنّ الحسن والحسين (عليهما السلام) كانا إبنى رسول الله (صلَّى الله عليه و آله وسلّم) وعد أن يدعو ابناءه فدعا الحسن والحسين فوجب أن يكون إبنيه»

*"...អាយ៉ាស្ស៉ដែលលើកមកនិយាយនេះបញ្ជាក់ថា អាល់-ហ្សាសាន់និងអាល់-ហ៊្សុសៃន៍عليهم السلامជាព្រះរាជបុត្ររបស់ព្រះសាស្តាﷺ ព្រោះកាលគេបានឲ្យព្រះអង្គﷺហៅព្រះរាជបុត្រព្រះអង្គﷺមកនោះ ព្រះអង្គﷺបានហៅ*

[182] សូមមើលសៀវភៅ *អាដ្ឌ-ឌូរ អាល់-ម៉ាន់ស៊្សូរ* (الدر المنثور) (បោះពុម្ពនៅបៃរូត) ជុំទី ២ ទំព័រ ៣៩ ចុងសេចក្តីអធិប្បាយអាយ៉ាស្ស៉កំពុងនិយាយនេះ ។

[183] សូមមើល *តាហ្វ៍សៀរ ម៉ាហ្វាទិះហ្សុ៍ អាល់-ក៊ុយប៍ (التفسير مفاتيح الغيب)* ឬ *តាហ្វ៍សៀរ អាល់-កាបៀរ* (التفسير الكبير) (បោះពុម្ពនៅអេស៊ីបត៍ ១៣០៨ ស.ហ) ជុំទី ២ ទំព័រ ៤៨៨ ។